# ព្រះ
# ត្រៃបិដកបាលី
## និង
## សេចក្ដីប្រែជាភាសាខ្មែរ
# វិនយបិដក
## មហាវិភង្គ ចតុត្ថភាគ
# ៤

បាចិត្តិយកណ្ឌ បាដិទេសនិយកណ្ឌ
សេខិយកណ្ឌ និង អធិករណសមថកណ្ឌ

បោះពុម្ពលើកទី ២

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥៥៨

វិនយបិដក មហាវិភង្គ

ចតុត្ថភាគ

៤

បាចិត្តិយកណ្ឌ បាដិទេសនីយកណ្ឌ

សេខិយកណ្ឌ សត្តាធិករណសមថកណ្ឌ

ព. ស. ២៥៤៨

## ឆដ្ឋសិក្ខាបទំ

(១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ វរសេយ្យាយោ បលិពុទ្ធេន្តិ ថេរេ ភិក្ខូ វុដ្ឋាបេន្តិ ។ អថខោ ឆព្ពគ្គិយានំ ភិក្ខូនំ ឯតទហោសិ កេន នុ ខោ មយំ ឧបាយេន ឥធេវ វស្សំ វសេយ្យាមាតិ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ ថេរេ ភិក្ខូ អនុបខជ្ជ សេយ្យំ កប្បេន្តិ យស្ស សម្ពាធោ ភវិស្សតិ សោ បក្កមិស្សតីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ថេរេ ភិក្ខូ អនុបខជ្ជ សេយ្យំ កប្បេស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ថេរេ ភិក្ខូ អនុបខជ្ជ សេយ្យំ កប្បេថាតិ ។ សច្ចំ ភគវា-តិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ

## សិក្ខាបទទី ៦

[១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុង ជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ ទៀតទៀងយកទីដេកល្អ ។ ញុំាងភិក្ខុចាស់ទាំងឡាយឲ្យក្រោកចេញទៅ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុ គិតគ្នាថា យើងទាំងឡាយនៅចាំវស្សាក្នុងទីនេះ ដោយឧបាយដូចម្តេចហ្ន៎ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុចូលទៅដេកទៀតទៀងភិក្ខុចាស់ទាំងឡាយដោយគិតថា ភិក្ខុណាមានសេចក្តីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងចូលទៅដេកទៀតទៀងពួកភិក្ខុចាស់ៗនោះ ។ ទើបភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកកល់គ្នាចូលទៅដេកទៀតទៀងភិក្ខុចាស់ទាំងឡាយ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់អនុគ្រោះ ការនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនសមនឹងចូលទៅដេក

មោឃបុរិសា ថេរេ ភិក្ខូ អនុបខជ្ជ សេយ្យំ កប្បេ-ស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ-សេយ្យាថ យោ បន ភិក្ខុ សង្ឃិកេ វិហារេ ជានំ បុព្វុបគតំ ភិក្ខុំ អនុបខជ្ជ សេយ្យំ កប្បេយ្យ យស្ស សម្ពាធោ ភវិស្សតិ សោ បក្កមិស្សតីតិ ឯតទេវ បច្ច-យំ ករិត្វា អនញ្ញំ បាចិត្តិយន្តិ ។

(២) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សង្ឃិកោ នាម វិហារោ សង្ឃស្ស ទិន្នោ ហោតិ បរិច្ចត្តោ ។ ជានាតិ នាម វុឌ្ឍោតិ ជានាតិ គិលានោតិ ជានាតិ សង្ឃេន ទិន្នោតិ ជានាតិ ។ អនុបខជ្ជាតិ អនុបវិសិត្វា ។ សេយ្យំ កប្បេយ្យាតិ មញ្ចស្ស វា បីឋស្ស វា បវិសន្តស្ស វា និក្ខមន្តស្ស វា ឧបចារេ សេយ្យំ សន្ថរតិ វា សន្ថរាបេតិ វា អាបត្តិ ទុក្កដស្ស អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ



ប្រៀតប្រៀនភិក្ខុចាស់ៗដូច្នោះឡើយ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លានោះទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងហើយចូលទៅប្រៀតប្រៀនភិក្ខុដែលចូលទៅនៅមុនហើយសម្រេចនូវទីដេក ក្នុងវិហាររបស់សង្ឃ ដោយគិតថា ភិក្ខុណាមានសេចក្តីចង្អៀតចង្អល់ ភិក្ខុនោះនឹងចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើនូវសេចក្តីប្រៀតប្រៀននោះឯងឲ្យជាបច្ច័យ មិនមែនព្រោះហេតុដទៃទេ ។

(២) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទមុន នៃចតុត្ថកណ្ឌ ។ វិហារដែលគេលះបង់ឲ្យដល់សង្ឃ ហៅថាវិហាររបស់សង្ឃ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងថា ភិក្ខុនេះចាស់ ដឹងថា ភិក្ខុនេះឈឺ ដឹងថា វិហារនេះសង្ឃឲ្យហើយ ។ ពាក្យថា ចូលទៅប្រៀតប្រៀន គឺចូលទៅប្រៀតជ្រែក ។ ពាក្យថា សម្រេចនូវទីដេក សេចក្តីថា ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេកក្នុងឧបចារ(១)នៃគ្រែក្តី នៃតាំងក្តី នៃភិក្ខុចូលទៅក្តី ចេញមកក្តី ត្រូវអាបត្តិទុក្កដ ភិក្ខុអង្គុយសន្ធឹងក្តី

១ ឧបចារគ្រែនិងតាំង ពាមអង្គទាំង ជាកំណត់ពីរហត្ថមួយចំអាម ។

បាចិត្តិយស្ស ។ ឯតទេវ បច្ចយំ ករិត្វា អនញ្ញន្តិ ន អញ្ញោ កោចិ បច្ចយោ ហោតិ អនុបខជ្ជ សេយ្យំ កប្បេតុំ ។

[៣] សង្ឃិកេ សង្ឃិកសញ្ញី អនុបខជ្ជ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ សង្ឃិកេ វេមតិកោ អនុបខជ្ជ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ សង្ឃិកេ បុគ្គលិកសញ្ញី អនុបខជ្ជ សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ មញ្ចស្ស វា បីឋស្ស វា បវិសន្តស្ស វា និក្ខមន្តស្ស វា ឧបចារំ ឋបេត្វា សេយ្យំ សន្ថរតិ វា សន្ថរាបេតិ វា អាបត្តិ ទុក្កដស្ស ។ អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ ទុក្កដស្ស ។ វិហារស្ស ឧបចារេ វា ឧបដ្ឋានសាលាយំ វា មណ្ឌបេ វា រុក្ខមូលេ វា អជ្ឈោកាសេ វា សេយ្យំ សន្ថរតិ វា សន្ថរាបេតិ វា អាបត្តិ ទុក្កដស្ស ។ អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ សង្ឃិកសញ្ញី





ដេកសន្ធឹតក្តី (លើទីដេកនោះ) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើនូវសេចក្តីប្រៀតប្រៀតនោះឯងឲ្យជាបច្ច័យ មិនមែនហេតុដទៃទេ សេចក្តីថា គ្មានហេតុដទៃទៀតមួយដែលត្រូវការចូលទៅដេកប្រៀតប្រៀតនោះឡើយ ។

[៣] វិហាររបស់សង្ឃ ភិក្ខុសំគាល់ថា វិហាររបស់សង្ឃមែន ហើយចូលទៅដេកប្រៀតប្រៀត ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្តីសង្ស័យ ហើយចូលទៅដេកប្រៀតប្រៀត ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុសំគាល់ថារបស់បុគ្គលវិញ ហើយចូលទៅដេកប្រៀតប្រៀត ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេក វៀរលែងតែឧបចារនៃគ្រែក្តី នៃតាំងក្តី នៃភិក្ខុចូលទៅក្តី ចេញមកក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអង្គុយសន្ធឹតក្តី ដេកសន្ធឹតក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុក្រាលឯងក្តី ប្រើគេឲ្យក្រាលក្តី នូវទីដេក ក្នុងឧបចារនៃវិហារក្តី ក្នុងឧបដ្ឋានសាលាក្តី[១] ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងទីវាលក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអង្គុយសន្ធឹតក្តី ដេកសន្ធឹតក្តី ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថារបស់សង្ឃ

១ ប្រែថា សាលាសម្រាប់បម្រើ តែអដ្ឋកថាថា ជាទីលំ សាលាសម្រាប់ឆាន់ ប្រក្រតី ។

អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ បុគ្គលិកសញ្ញី អញ្ញស្ស បុគ្គលិកេ អាបត្តិ ទុក្កដស្ស ។ អត្តនោ បុគ្គលិកេ អនាបត្តិ ។

(៨) អនាបត្តិ គិលានស្ស បវិសតិ សីតេន វា ឧណ្ហេន វា បីឡិតោ បវិសតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។



ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថារបស់បុគ្គលដែល ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះ ជារបស់បុគ្គល គឺវិហារ នៃភិក្ខុដទៃ ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារ ជារបស់បុគ្គល គឺវិហាររបស់ខ្លួនឯង ។

(៨) អាបត្តិមិនមាន ដល់ភិក្ខុដែលមានជម្ងឺចូលទៅក្តី ដល់ភិក្ខុដែលត្រូវត្រជាក់ឬក្តៅបៀតបៀនហើយចូលទៅក្តី ដល់ភិក្ខុមានសេចក្តីអន្តរាយក្តី ដល់ភិក្ខុឆ្កួតក្តី ដល់ភិក្ខុដើមបញ្ញត្តិក្តី ។

សិក្ខាបទទី ៦ ចប់ ។

## សត្តមសិក្ខាបទំ

[៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ អញ្ញតរំ បច្ចន្តិមំ មហាវិហារំ បដិសង្ខរោន្តិ ឥធ មយំ វស្សំ វសិស្សាមាតិ ។ អទ្ទសំសុ ខោ ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយេ ភិក្ខូ វិហារំ បដិសង្ខរោន្តេ ទិស្វាន ឯវមាហំសុ ឥមេ អាវុសោ សត្តរសវគ្គិយា ភិក្ខូ វិហារំ បដិសង្ខរោន្តិ ហន្ទ នេ[១] វុដ្ឋាបេស្សាមាតិ ។ ឯកច្ចេ ឯវមាហំសុ អាគមេថាវុសោ យាវ បដិសង្ខរោន្តិ បដិសង្ខតេ វុដ្ឋាបេស្សាមាតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយេ ភិក្ខូ ឯតទវោចុំ ឧដ្ឋេថាវុសោ អម្ហាកំ វិហារោ បាបុណាតីតិ ។ ននុ អាវុសោ បដិកច្ចេវ

១ ពេតំ ឃតា ។

## សិក្ខាបទទី ៧

(៧) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកសត្តរសវគ្គិយភិក្ខុ (ភិក្ខុមានពួក ១៧ រូប) នាំគ្នាជួសជុលវិហារធំ ១ មាននៅក្នុងបច្ចន្តប្រទេស ដោយគិតគ្នាថា យើងទាំងឡាយនឹងនៅចាំវស្សាក្នុងទីនេះ ។ ពួកឆព្វគ្គិយភិក្ខុ (ភិក្ខុមានពួក ៦ រូប) បានឃើញពួកសត្តរសវគ្គិយភិក្ខុនាំគ្នាជួសជុលវិហារ លុះឃើញហើយបាននិយាយគ្នាយ៉ាងនេះថា ម្នាលអាវុសោ ពួកសត្តរសវគ្គិយភិក្ខុនេះនាំគ្នាជួសជុលវិហារ បើដូច្នោះ យើងទាំងឡាយនឹងធ្វើឲ្យភិក្ខុទាំងនោះបៀសចេញទៅ ។ ឆព្វគ្គិយភិក្ខុពួកខ្លះបាននិយាយយ៉ាងនេះថា ម្នាលអាវុសោ សូមលោកទាំងឡាយបង្អង់ចាំឲ្យសត្តរសវគ្គិយភិក្ខុទាំងឡាយជួសជុលវិហាររួចសិន លុះជួសជុលស្រេចហើយ យើងទាំងឡាយនឹងធ្វើភិក្ខុទាំងនោះឲ្យបៀសចេញទៅ ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុបាននិយាយពាក្យនេះនឹងពួកសត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាបៀសចេញទៅ វិហារត្រូវបានដល់ពួកយើងទេ ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ ហេតុដូចម្តេច

អាចិក្ខិតព្វំ មយញ្ច អញ្ញំ បដិសង្ខរេយ្យាមាតិ ។ ននុ អាវុសោ សង្ឃិកោ វិហារោតិ ។ អាមាវុសោ សង្ឃិកោ វិហារោតិ ។ ឧដ្ឋេថាវុសោ អម្ហាកំ វិហារោ បាបុណាតីតិ ។ មហល្លកោ អាវុសោ វិហារោ តុម្ហេបិ វសថ មយម្បិ វសិស្សាមាតិ ។ ឧដ្ឋេថាវុសោ អម្ហាកំ វិហារោ បាបុណាតីតិ កុបិតា អនត្តមនា គីវាយំ គហេត្វា និក្កឌ្ឍន្តិ ។ តេ និក្កឌ្ឍិយមានា រោទន្តិ ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ រោទថាតិ ។ ឥមេ អាវុសោ ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា អម្ហេ សង្ឃិកា វិហារា និក្កឌ្ឍន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម



ពួកលោកមិនប្រាប់យើងជាមុនសិន យើងទាំងឡាយនឹងបានជួសជុលវិហារឯទៀតវិញ ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោ ក្រែងវិហារនោះជារបស់សង្ឃទេដឹង ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយតបថា អើអាវុសោ វិហារជារបស់សង្ឃ ។ ពួកឆព្វគ្គិយភិក្ខុពោលថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ។ ពួកសត្តរសវគ្គិយភិក្ខុនិយាយថា ម្នាលអាវុសោ វិហារជាវិហារធំ ពួកលោកក៏នៅបាន ពួកយើងក៏នៅបាន ។ ពួកឆព្វគ្គិយភិក្ខុនិយាយពាក្យផ្សេងទៀតថា ម្នាលអាវុសោ ពួកលោកចូរនាំគ្នាចៀសចេញទៅ វិហារត្រូវបានពួកយើងទេ ហើយមានចិត្តក្រេវក្រោធខ្ញឹងខ្ញៀត នាំគ្នាចាប់កក្រញាញ់ទាញចេញទៅ ។ ពួកសត្តរសវគ្គិយភិក្ខុនោះ កាលត្រូវពួកឆព្វគ្គិយភិក្ខុ ក្រញាញ់កទាញចេញ ក៏នាំគ្នាយំ ។ ទើបភិក្ខុទាំងឡាយ (ភិក្ខុដទៃមកពីភិក្ខុពួកនោះ) បាននាំគ្នាសួរពួកនោះថា ម្នាលអាវុសោ ហេតុអ្វី បានជាពួកលោកយំ ។ ពួកសត្តរស-វគ្គិយភិក្ខុនិយាយតបថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះ មានចិត្តក្រេវក្រោធ ទើបនាំគ្នាបណ្តេញពួកយើងចេញចាកវិហាររបស់សង្ឃ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបី

ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា ភិក្ខូ សង្ឃិកា វិហារា និក្កឌ្ឍន្តិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឆព្ពគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ កុបិតា អនត្តមនា ភិក្ខូ សង្ឃិកា វិហារា និក្កឌ្ឍថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា កុបិតា អនត្តមនា ភិក្ខូ សង្ឃិកា វិហារា និក្កឌ្ឍិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ កុបិតោ អនត្តមនោ សង្ឃិកា វិហារា និក្កឌ្ឍេយ្យ វា និក្កឌ្ឍាបេយ្យ វា បាចិត្តិយន្តិ ។





ខឹងមានចិត្តក្រោធទឹងទង់ទាញភិក្ខុទាំងឡាយចេញចាកវិហាររបស់សង្ឃនោះ ។ ទើបភិក្ខុទាំងនោះក្រាបទូលដំណើរនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ • [illegible] ព្រះដ៏មានព្រះភាគទ្រង់សួរពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយមានចិត្តក្រោធទឹងទង់ទាញភិក្ខុទាំងឡាយចេញចាកវិហាររបស់សង្ឃ មែនឬទេ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងមានចិត្តក្រោធទឹងទង់ទាញភិក្ខុទាំងឡាយចេញចាកវិហាររបស់សង្ឃនោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកទាំងឡាយធ្វើនេះមិនមែននាំឲ្យជ្រះថ្លា ដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមានចិត្តក្រោធទឹងទង់ភិក្ខុដទៃ ហើយទាញឯងក្តី ប្រើគេឲ្យទាញក្តី ចេញចាកវិហាររបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ ។

(៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញំ ភិក្ខុំ ។ កុបិតោ អនត្តមនោតិ អនភិរទ្ធោ អាហតចិត្តោ ខិលជាតោ ។

(៧) សង្ឃិកោ នាម វិហារោ សង្ឃស្ស ទិន្នោ ហោតិ បរិច្ចត្តោ ។ និក្កឌ្ឍេយ្យាតិ គព្ភេ គហេត្វា បមុខំ និក្កឌ្ឍតិ អាបត្តិ បាចិត្តិយស្ស ។ បមុខេ គហេត្វា ពហិ និក្កឌ្ឍតិ អាបត្តិ បាចិត្តិយស្ស ។ ឯកេន បយោគេន ពហុកេបិ ទ្វារេ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។ និក្កឌ្ឍាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ បាចិត្តិយស្ស ។ សកឹ អាណត្តោ ពហុកេបិ ទ្វារេ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។

(៨) សង្ឃិកេ សង្ឃិកសញ្ញី កុបិតោ អនត្តមនោ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ សង្ឃិកេ វេមតិកោ កុបិតោ អនត្តមនោ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ បាចិត្តិយស្ស ។



(៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ពាក្យថា ចំពោះភិក្ខុ គឺចំពោះភិក្ខុដទៃ ។ ពាក្យថា មានចិត្តក្រោធខឹង សេចក្តីថា មានចិត្តមិនត្រេកអរ មានចិត្តដែលគេពាល់ត្រូវហើយ មានចិត្តរឹងរូស ។

(៧) វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឃ ឈ្មោះថា វិហាររបស់សង្ឃ ។ ពាក្យថា ទាញចេញ គឺភិក្ខុចាប់យកភិក្ខុក្នុងបន្ទប់ ហើយទាញទៅឯរបៀងវិហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុចាប់យកភិក្ខុនៅរបៀង ហើយទាញទៅខាងក្រៅ ក៏ត្រូវអាបត្តិបាចិត្តិយ ។ ទុកជាភិក្ខុទាញភិក្ខុឲ្យកន្លងទ្វារ តាំងពីទ្វារយ៉ាងច្រើន តែដោយប្រយោគមួយ ក៏ត្រូវអាបត្តិបាចិត្តិយតែមួយ ។ ពាក្យថា ប្រើគេឲ្យទាញ នោះគឺបង្គាប់អ្នកដទៃ (ភិក្ខុអ្នកបង្គាប់នោះ) ក៏ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់តែម្តង អ្នកទទួលបង្គាប់ទាញភិក្ខុដទៃឲ្យកន្លងទ្វារយ៉ាងច្រើន ក៏ត្រូវអាបត្តិបាចិត្តិយតែមួយ ។

(៨) វិហាររបស់សង្ឃ ភិក្ខុសំគាល់ថាជារបស់សង្ឃមែន ហើយមានចិត្តក្រោធខឹងទាញចេញក្តី ប្រើគេឲ្យទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្តីសង្ស័យ ហើយមានចិត្តក្រោធខឹងទាញចេញក្តី ប្រើគេឲ្យទាញក្តី ត្រូវអាបត្តិបាចិត្តិយ ។

សង្ឃិកេ បុគ្គលិកសញ្ញី កុបិតោ អនត្តមនោ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ តស្ស បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ វិហារស្ស ឧបចារា វា ឧបដ្ឋានសាលាយ វា មណ្ឌបា វា រុក្ខមូលា វា អជ្ឈោកាសា វា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ តស្ស បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នំ វិហារា វា វិហារស្ស ឧបចារា វា ឧបដ្ឋានសាលាយ វា មណ្ឌបា វា រុក្ខមូលា វា អជ្ឈោកាសា វា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ តស្ស បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ សង្ឃិកសញ្ញី អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ បុគ្គលិកសញ្ញី អញ្ញស្ស បុគ្គលិកេ អាបត្តិ ទុក្កដស្ស ។ អត្តនោ បុគ្គលិកេ អនាបត្តិ ។



វិហាររបស់សង្ឃ ភិក្ខុសំគាល់ថាជារបស់បុគ្គលទៅវិញ ហើយមានចិត្តក្រោធខឹងទាញចេញឯងក្ដី ប្រើគេឲ្យទាញចេញក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទាញចេញឯងក្ដី ប្រើគេឲ្យទាញចេញក្ដី នូវបរិក្ខាររបស់ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាញចេញឯងក្ដី ប្រើគេឲ្យទាញចេញក្ដី នូវភិក្ខុឲ្យចាកឧបចារនៃវិហារក្ដី ចាកឧបដ្ឋានសាលាក្ដី ចាកមណ្ឌបក្ដី ចាកម្លប់ឈើក្ដី ចាកទីវាលក្ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាញចេញឯងក្ដី ប្រើគេឲ្យទាញចេញក្ដី នូវបរិក្ខារនៃភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាញចេញឯងក្ដី ប្រើគេឲ្យទាញចេញក្ដី នូវអនុបសម្បន្នឲ្យចាកវិហារក្ដី ចាកឧបចារនៃវិហារក្ដី ចាកឧបដ្ឋានសាលាក្ដី ចាកមណ្ឌបក្ដី ចាកម្លប់ឈើក្ដី ចាកទីវាលក្ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាញចេញឯងក្ដី ប្រើគេឲ្យទាញចេញក្ដី នូវបរិក្ខាររបស់អនុបសម្បន្ននោះ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់សង្ឃ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់បុគ្គល ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះរបស់បុគ្គលនៃភិក្ខុដទៃ តែវិហាររបស់គេ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារនោះរបស់បុគ្គលខ្លួន គឺវិហាររបស់ខ្លួនឯង ។

[៤] អនាបត្តិ អលជ្ជឹ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្ស បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា ឧម្មត្តកំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្ស បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា ភណ្ឌនការកំ វា កលហការកំ វា វិវាទការកំ វា ភស្សការកំ វា សង្ឃេ អធិករណការកំ វា និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្ស បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា អន្តេវាសិកំ វា សទ្ធិវិហារិកំ វា ន សម្មាវត្តន្តំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា តស្ស បរិក្ខារំ និក្កឌ្ឍតិ វា និក្កឌ្ឍាបេតិ វា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។



[៤] អាបត្តិមិនមានដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញ នូវភិក្ខុអលជ្ជី ដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញនូវបរិក្ខារ របស់ភិក្ខុអលជ្ជីនោះ ដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញ នូវភិក្ខុឆ្កួត ដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញនូវបរិក្ខារ របស់ភិក្ខុឆ្កួតនោះ ដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញនូវភិក្ខុ ជាអ្នកធ្វើនូវសេចក្តីបង្កហេតុក្តី អ្នកធ្វើនូវសេចក្តីប្រកួតប្រកាន់ក្តី អ្នកធ្វើនូវសេចក្តីទាស់ទែងក្តី អ្នកធ្វើនូវពាក្យឡេះឡោះតាមតែឫកមាត់ក្តី(១) អ្នកធ្វើនូវអធិករណ៍ក្នុងសង្ឃក្តី ដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញនូវបរិក្ខាររបស់ភិក្ខុទាំងនោះចេញ ដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញនូវអន្តេវាសិក ឬសទ្ធិវិហារិក ដែលប្រព្រឹត្តមិនត្រឹមត្រូវ ដល់ភិក្ខុដែលទាញឯង ឬប្រើគេឲ្យទាញនូវបរិក្ខាររបស់អន្តេវាសិក ឬសទ្ធិវិហារិកដែលប្រព្រឹត្តមិនត្រឹមត្រូវនោះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

---

(១) ពោលពាក្យ [illegible] ។ ន័យអដ្ឋកថា ។

អដ្ឋមសិក្ខាបទំ

[១០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ទ្វេ ភិក្ខូ សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា ឯកោ ហេដ្ឋា វិហរតិ ឯកោ ឧបរិ ។ ឧបរិមោ ភិក្ខុ អាហច្ចបាទកំ មញ្ចំ សហសា អភិនិសីទិ ។ មញ្ចបាទោ និបតិត្វា ហេដ្ឋិមស្ស ភិក្ខុនោ មត្ថកេ អវត្ថាសិ ។ សោ ភិក្ខុ វិស្សរមកាសិ ។ ភិក្ខូ ឧបធាវិត្វា តំ ភិក្ខុំ ឯតទវោចុំ កិស្ស ត្វំ អាវុសោ វិស្សរមកាសីតិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថញ្ហិ នាម ភិក្ខុ សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ សហសា អភិនិសីទិស្សតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា តំ ភិក្ខុំ បដិបុច្ឆិ

សិក្ខាបទទី ៨

(១០) សម័យនោះ ព្រះពុទ្ធមានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុពីររូប ១ រូបនៅជាន់ខាងក្រោម ១ រូបនៅជាន់ខាងលើ ក្នុងវិហាររបស់សង្ឃ ។ ភិក្ខុដែលនៅខាងលើអង្គុយចុះ ដោយហើសសន្ធឹកលើគ្រែដែលមានជើងគ្រាន់តែស៊កចុះ (ដោយបណ្ដោយតាមស្រួល) ។ ជើងគ្រែ (នោះ) ក៏ធ្លាក់ចុះមកត្រូវចំក្បាលភិក្ខុដែលនៅខាងក្រោម ។ ភិក្ខុនោះបានស្រែកសំឡេងខ្លាំង ។ ភិក្ខុទាំងឡាយបានស្ទុះទៅសួរភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីក៏លោកស្រែក ។ ភិក្ខុនោះបានប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុមិនសមបើនឹងអង្គុយចុះ ដោយហើសសន្ធឹកលើគ្រែដែលមានជើងគ្រាន់តែស៊កចុះ (ដោយបណ្ដោយតាមស្រួល) លើជាន់ក្នុងវិហាររបស់សង្ឃសោះ ។ ទើបភិក្ខុទាំងឡាយនោះ នាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគត្រាស់សួរភិក្ខុនោះថា ម្នាលភិក្ខុ ឮថាអ្នកឯង

សច្ចំ កិរ ត្វំ ភិក្ខុ សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ សហសា អភិនិសីទសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ សហសា អភិនិសីទិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ សង្ឃិកេ វិហារេ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ វា បីឋំ វា អភិនិសីទេយ្យ វា អភិនិបជ្ជេយ្យ វា បាចិត្តិយន្តិ ។

(១១) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សង្ឃិកោ នាម វិហារោ សង្ឃស្ស ទិន្នោ ហោតិ បរិច្ចត្តោ ។

(១២) វេហាសកុដី នាម មជ្ឈិមស្ស បុរិសស្ស អសីសឃដ្ដា ។ អាហច្ចបាទកោ នាម អង្គេ វិជ្ឈិត្វា ឋិតោ ហោតិ ។ អាហច្ចបាទកំ នាម



អង្គុយចុះ ដោយរហ័សរហួនលើគ្រែដែលមានជើងគ្រាន់តែស៊កចុក (ដោយមិនបានពិចារណាមុន) លើថ្នាក់កុដិរបស់សង្ឃ ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងមកអង្គុយចុះ ដោយរហ័សរហួនលើគ្រែដែលមានជើងគ្រាន់តែស៊កចុក (ដោយមិនបានពិចារណាមុន) លើថ្នាក់កុដិរបស់សង្ឃទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលអ្នកមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយអង្គុយចុះ ដោយរហ័សរហួន ឬដេករហួនលើគ្រែ ឬលើតាំង ដែលមានជើងគ្រាន់តែស៊កចុក (ដោយមិនបានពិចារណាមុន) លើថ្នាក់កុដិរបស់សង្ឃ ត្រូវអាបត្តិបាចិត្តិយ ។

(១១) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចនឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ វិហារដែលគេបរិច្ចាគប្រគេនដល់សង្ឃ ហៅថា វិហាររបស់សង្ឃ ។

(១២) ថ្នើរ (ដែលគេធ្វើខ្ពស់) មិនទង្គិចក្បាលមជ្ឈិមបុរស ហៅថា ថ្នាក់ ។ គ្រែដែលមានជើងគ្រាន់តែស៊កចូលក្នុងរន្ធហើយតាំងទុក ហៅថា គ្រែដែលមានជើងគ្រាន់តែស៊កចុក ។ តាំងដែលមានជើងគ្រាន់តែស៊ក

បីឋំ អង្គេ វិជ្ឈិត្វា ឋិតំ ហោតិ ។ អភិនិសីទេយ្យាតិ តស្មិំ អភិនិសីទតិ អាបត្តិ បាចិត្តិយស្ស ។ អភិនិបជ្ជេយ្យាតិ តស្មិំ អភិនិបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។

[១៣] សង្ឃិកេ សង្ឃិកសញ្ញី ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ វា បីឋំ វា អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ សង្ឃិកេ វេមតិកោ ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ វា បីឋំ វា អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ សង្ឃិកេ បុគ្គលិកសញ្ញី ឧបរិវេហាសកុដិយា អាហច្ចបាទកំ មញ្ចំ វា បីឋំ វា អភិនិសីទតិ វា អភិនិបជ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ បុគ្គលិកេ សង្ឃិកសញ្ញី អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បុគ្គលិកេ





ពូលកដឹម ហៅថា តាំងដែលមានជើងស្រួចនៃសលាកដុក ។ ពាក្យថា អង្គុយសង្កត់ គឺភិក្ខុអង្គុយសង្កត់លើគ្រែឬតាំងនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ដេកសង្កត់ គឺភិក្ខុដេកសង្កត់លើគ្រែឬតាំងនោះ ត្រូវអាបត្តិបាចិត្តិយ ។

(១៣) វិហាររបស់សង្ឃ ភិក្ខុសំគាល់ថាជារបស់សង្ឃផង ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែ ឬលើតាំង ដែលមានជើងស្រួចនៃសលាកដុកកដឹម (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុមានសេចក្ដីសង្ស័យ ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែ ឬលើតាំង ដែលមានជើងស្រួចនៃសលាកដុកកដឹម (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់សង្ឃ ភិក្ខុសំគាល់ថាជារបស់បុគ្គលវិញ ហើយអង្គុយសង្កត់ ឬដេកសង្កត់លើគ្រែ ឬលើតាំង ដែលមានជើងស្រួចនៃសលាកដុកកដឹម (ដែលគេតាំងទុក) លើថ្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ វិហាររបស់បុគ្គល ភិក្ខុសំគាល់ថាជារបស់សង្ឃវិញ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហាររបស់បុគ្គល

មុក្ខលិកាសញ្ញី អញ្ញស្ស មុក្ខលិកោ អាបត្តិ ទុក្កដស្ស ។ អត្តនោ មុក្ខលិកោ អនាបត្តិ ។

(១៦) អនាបត្តិ អវេហាសកុដិយា សីសឃដ្ដាយ ហេដ្ឋា អបរិភោគំ ហោតិ បទរសញ្ចិតំ ហោតិ បដាណិ ទិន្នា ហោតិ តស្មឹ ឋិតោ គណ្ហាតិ វា លគ្គេតិ វា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



ភិក្ខុសំគាល់ថាជារបស់បុគ្គលដទៃដែល ត្រូវអាបត្តិទុក្កដ ព្រោះវិហារនោះ ជារបស់បុគ្គលដទៃក៏ដោយ នឹងវិហាររបស់គេ ។ ភិក្ខុមិនត្រូវអាបត្តិ ព្រោះវិហារជារបស់ខ្លួន នឹងវិហាររបស់ខ្លួនឯង ។

(១៦) អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយ ឬដេកលើគ្រែ តាំងក្ដី ដែលគេធ្វើទុកលើទីដែលមិនមែនជាថ្នាក់ លើទីណាដែល ដើរទង្គិចក្បាលទីដែលមិនបានប្រើប្រាស់ពីក្រោមឡើយទីនោះ ទីដែលគេក្រាលដាក់ដោយក្ដារ លើគ្រែ ឬតាំងនោះ ដែលគេដាក់គន្លឹះហើយ ដល់ភិក្ខុដែលឈរនៅលើគ្រែ ឬតាំងនោះ ហើយកាន់យក ឬព្យួរទុកបរិក្ខារ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

## នវមសិក្ខាបទំ

(១៩) តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មតោ ឆន្នស្ស ឧបដ្ឋាកោ មហាមត្តោ អាយស្មតោ ឆន្នស្ស វិហារំ ការាបេតិ ។ អថខោ អាយស្មា ឆន្នោ កតបរិយោសិតំ វិហារំ បុនប្បុនំ ឆាទាបេសិ(១) បុនប្បុនំ លិម្បាបេសិ(២) អតិភារិកោ(៣) វិហារោ បរិបតិ ។ អថខោ អាយស្មា ឆន្នោ តិណញ្ច កដ្ឋញ្ច សង្កឌ្ឍន្តោ អញ្ញតរស្ស ព្រាហ្មណស្ស យវក្ខេត្តំ ទូសេសិ ។ អថខោ សោ ព្រាហ្មណោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភទន្តា អម្ហាកំ យវក្ខេត្តំ ទូសេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស ព្រាហ្មណស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឆន្នោ កតបរិយោសិតំ

១ ម. ឆ. ឆាទាបេសិ ។ ២ លិម្បាបេសិ ។ ៣ អតិភារិកោ ។

## សិក្ខាបទទី ៩

(១៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងឃោសិតារាម ជិតក្រុងកោសម្ពី ។ គ្រានោះឯង មហាមាត្យជាឧបដ្ឋាករបស់ឆន្នភិក្ខុដ៏មានអាយុ បានឲ្យគេធ្វើវិហារប្រគេនឆន្នភិក្ខុដ៏មានអាយុ ។ លំដាប់នោះ ឆន្នភិក្ខុដ៏មានអាយុ បានឲ្យគេប្រក់ផង ឲ្យគេលាបវិហារដែលគេធ្វើស្រេចហើយនោះញយ ៗ វិហារនោះធ្ងន់ហួសពេក ក៏បាក់រលំចុះមក ។ គ្រានោះ ឆន្នភិក្ខុដ៏មានអាយុ ក៏ដឹកនាំយកស្មៅនិងឈើមកធ្វើ (វិហារទៀត) បៀតបៀនស្រែស្រូវរបស់ព្រាហ្មណ៍ម្នាក់ ឲ្យខូចខាតទៅ ។ ចំណែកព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយ មិនសមបើនឹងមកបៀតបៀនស្រែស្រូវរបស់យើងឲ្យខូចខាតទៅសោះ ។ ភិក្ខុទាំងឡាយបានឮពាក្យរបស់ព្រាហ្មណ៍នោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នភិក្ខុដ៏មានអាយុ មិនគួរនឹងឲ្យគេប្រក់ហើយ ៗ

វិហារំ បុនប្បុនំ ឆាទាបេស្សតិ បុនប្បុនំ លិម្បាបេស្សតិ អតិភារិកោ វិហារោ បរិបតីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ បេ ។ សច្ចំ កិរ ត្វំ ឆន្ន កតបរិយោសិតំ វិហារំ បុនប្បុនំ ឆាទាបេសិ បុនប្បុនំ លិម្បាបេសិ អតិភារិកោ វិហារោ បរិបតីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស កតបរិយោសិតំ វិហារំ បុនប្បុនំ ឆាទាបេស្សសិ បុនប្បុនំ លិម្បាបេស្សសិ អតិភារិកោ វិហារោ បរិបតិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ មហល្លកំ បន ភិក្ខុនា វិហារំ ការយមានេន យាវ ទ្វារកោសា អគ្គឡដ្ឋបនាយ អាលោកសន្ធិបរិកម្មាយ ទ្វិត្តិច្ឆទនស្ស បរិយាយំ



ប្រក់លាបរឿយ ៗ ឲ្យវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ ធ្លាក់រលំចុះមកនោះ ។ ភិក្ខុអម្បាលនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឆន្ន ឮថា អ្នកឯងឲ្យគេប្រក់រឿយ ៗ ឲ្យប្រក់លាបរឿយ ៗ ឲ្យវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ ធ្លាក់រលំចុះមកពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងមិនសមបើនឹងឲ្យគេប្រក់រឿយ ៗ នឹងប្រក់លាបរឿយ ៗ ឲ្យវិហារដែលគេធ្វើស្រេចហើយ ទាល់តែវិហារនោះធ្ងន់ហួសកំណត់ ធ្លាក់រលំចុះទៅទេ ម្នាលមោឃបុរស អំពើដែលអ្នកធ្វើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុកាលឲ្យគេធ្វើវិហារធំ គប្បីឈរ ([illegible] ១ [illegible]) កំណត់ទីមានទុកសម្រាប់តែសន្លឹកទ្វារ(*) (និងសន្លឹកបង្អួច) ដើម្បីនឹងប្រើប្រាស់ទ្វារ និងដើម្បីលំអកន្លែងសន្លឹកបង្អួច ឯជិត[illegible]

---

* ក្នុងអដ្ឋកថាថា មានទំហំត្រឹមមួយហត្ថមួយជំអាម កប់អំពីមេទ្វារចេញទៅ ក្នុងគម្ពីរខ្លះថា និងកត់ត្រឹមសន្លឹកទ្វារទាំងសងខាងប្រមាណ ក្នុងមហាអដ្ឋកថាថា សន្លឹកទ្វារនោះមួយហត្ថមួយ [illegible] ។

អប្បហរិតេ ឋិតេន អធិដ្ឋាតព្វំ តតោ ចេ ឧត្តរឹ[១] អប្បហ-រិតេបិ ឋិតោ អធិដ្ឋហេយ្យ បាចិត្តិយន្តិ ។

(១៦) មហល្លកោ នាម វិហារោ សស្សាមិកោ វុច្ចតិ ។ វិហារោ នាម ឧល្លិត្តោ វា ហោតិ អវលិត្តោ វា ឧល្លិត្តាវលិត្តោ វា ។ ការយមានេនាតិ ការេន្តោ វា ការាបេន្តោ វា ។ យាវ ទ្វារកោសាតិ បិដ្ឋសង្ឃាដស្ស សាមន្តា ហត្ថបាសា ។ អគ្គឡដ្ឋបនាយាតិ ទ្វារដ្ឋបនាយ ។ អាលោកសន្ធិបរិកម្មាយាតិ វាតបានបរិកម្មាយ សេតវណ្ណំ កាឡវណ្ណំ គេរុកបរិកម្មំ មាលាកម្មំ លតាកម្មំ មករទន្តកំ បញ្ចបដ្ឋិកំ ។ ទ្វិត្តិច្ឆទនស្ស បរិយាយំ អប្បហរិតេ ឋិតេន អធិដ្ឋាតព្វន្តិ ហរិតំ នាម បុព្ពណ្ណំ អបរណ្ណំ ។ សចេ ហរិតេ ឋិតោ អធិដ្ឋាតិ អាបត្តិ ទុក្កដស្ស ។ មគ្គេន

១ ម. ឱ. ឧត្តរឹ ។



ទីដែលគ្មានដំណាំ (ស្មៅខៀវ) ប្រក់បានត្រឹមតែពីរជាន់ បើភិក្ខុប្រក់ឲ្យក្រៃលើសអំពីកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានដំណាំ ក៏គង់ត្រូវអាបត្តិបាចិត្តិយ ។

(១៦) ដែលហៅថា វិហារធំ សំដៅយកវិហារដែលមានទាយកជាម្ចាស់របស់ ។ ដែលហៅថា វិហារ គឺវិហារដែលគេបូកខាងក្នុងក្ដី បូកខាងក្រៅក្ដី បូកទាំងខាងក្នុង ខាងក្រៅក្ដី ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើខ្លួនឯងក្ដី ប្រើគេឲ្យធ្វើក្ដី ។ ពាក្យថា កំណត់ទំនងកាលត្រឹមតែសន្លឹកទ្វារ គឺកំណត់ត្រឹមហត្ថបាសជុំវិញខ្នងក្របទ្វារ ។ ពាក្យថា ដើម្បីទុកប្រើប្រាស់ទ្វារ គឺដើម្បីបើកបិទទ្វារ ។ ពាក្យថា ដើម្បីបរិកម្មនូវសន្ធិកបង្អួច សេចក្ដីថា (គឺជាគ្រឿងអន្លាក) ដូចជាមានពណ៌ស ពណ៌ខ្មៅ ពណ៌ក្រហម ក្បាច់ផ្កា ក្បាច់វល្លិ៍ ក្បាច់ធ្មេញមករ ខ្នងក្បាច់ ឈ្មោះបញ្ចបដ្ឋិក[១] ដើម្បីបរិកម្មនូវសន្ធិកបង្អួច ។ ពាក្យថា ឯងឈរ ក្នុងត្រង់ទីដែលគ្មានដំណាំ (ស្មៅខៀវ) ប្រក់បានត្រឹមតែពីរជាន់ ដំណាំនោះបានដល់ធញ្ញជាតិដែលត្រូវដាំមុន (គឺស្រូវប្រាំង ខាងស្រូវ ស្រូវក្រហមជាដើម) និងធញ្ញជាតិដែលត្រូវដាំក្រោយ (បានដល់សណ្ដែក ពោត សណ្ដែកកន្ធាសជាដើម) ។ បើភិក្ខុឈរលើទីប្រក់ក្នុងទីមានដំណាំ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុប្រើឲ្យគេប្រក់ម្ដងៗ ពេលហើយ

១ ក្បាច់ដែលមានស្រែកាប់ ៥ ឬជាន់ ៥ ។

ឆាទេន្តស្ស ទ្វេ មគ្គេ អធិដ្ឋហិត្វា តតិយំ មគ្គំ អាណាបេត្វា បក្កមិតព្វំ ។ បរិយាយេន ឆាទេន្តស្ស ទ្វេ បរិយាយេ អធិដ្ឋហិត្វា តតិយំ បរិយាយំ អាណាបេត្វា បក្កមិតព្វំ ។

(១៧) តតោ ចេ ឧត្តរិ អប្បហរិតេបិ ឋិតោ អធិដ្ឋហេយ្យ ឥដ្ឋកាយ ឆាទេន្តស្ស ឥដ្ឋកាយ ឥដ្ឋកាយ អាបត្តិ បាចិត្តិយស្ស ។ សិលាយ ឆាទេន្តស្ស សិលាយ សិលាយ អាបត្តិ បាចិត្តិយស្ស ។ សុធាយ ឆាទេន្តស្ស បិណ្ឌេ បិណ្ឌេ អាបត្តិ បាចិត្តិយស្ស ។ តិណេន ឆាទេន្តស្ស ករឡេ ករឡេ អាបត្តិ បាចិត្តិយស្ស ។ បណ្ណេន ឆាទេន្តស្ស បណ្ណេ បណ្ណេ អាបត្តិ បាចិត្តិយស្ស ។

(១៨) អតិរេកទ្វិត្តិបរិយាយេ អតិរេកសញ្ញី អធិដ្ឋាតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកទ្វិត្តិបរិយាយេ វេមតិកោ អធិដ្ឋាតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកទ្វិត្តិបរិយាយេ ឩនកសញ្ញី អធិដ្ឋាតិ អាបត្តិ បាចិត្តិយស្ស ។ ឩនកទ្វិត្តិបរិយាយេ អតិរេកសញ្ញី អាបត្តិ



ត្រូវប្រក់ខ្លួនឯងបានត្រឹមពីរជួរ ដល់ជួរទីបី ត្រូវបង្គាប់គេហើយចៀសចេញទៅ ។ កាលភិក្ខុប្រើឲ្យគេប្រក់មួយជាន់ម្តងហើយ ត្រូវប្រក់ខ្លួនឯងបានត្រឹមពីរជាន់ ដល់ជាន់ទីបី ត្រូវបង្គាប់គេហើយចៀសចេញទៅ ។

(១៧) ត្រង់ពាក្យថា បើភិក្ខុប្រក់ខ្លួនឯងលើសជាងកំណត់នោះទៅ ទុកជាឈរនៅក្នុងទីដែលគ្មានតំណាំ សេចក្តីថា កាលភិក្ខុប្រើគេឲ្យប្រក់ដោយក្បឿង ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ផែនក្បឿង ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយថ្ម ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ផែនថ្ម ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយកំបោរ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ដុំកំបោរ ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយស្មៅ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ កណ្តាប់ ។ កាលភិក្ខុប្រើគេឲ្យប្រក់ដោយស្លឹកឈើ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ សន្លឹក ។

(១៨) វិហារប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសំគាល់ថា លើសមែនហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសង្ស័យហើយនៅតែធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារប្រក់លើសកំណត់ពីរបីជាន់ ភិក្ខុសំគាល់ថាខ្វះវិញ ហើយធ្វើថែម ត្រូវអាបត្តិបាចិត្តិយ ។ វិហារប្រក់មិនទាន់ដល់ពីរបីជាន់ ភិក្ខុសំគាល់ថាលើស ហើយ(ធ្វើថែម) ត្រូវអាបត្តិទុក្កដ ។

ទុក្កដស្ស ។ ឩនកទ្វត្តិបរិយាយេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកទ្វត្តិបរិយាយេ ឩនកសញ្ញី អនាបត្តិ ។

(១៨) អនាបត្តិ ទ្វត្តិបរិយាយេ ឩនកទ្វត្តិបរិយាយេ លេណេ គុហាយ តិណកុដិកាយ អញ្ញស្សត្ថាយ អត្តនោ ធនេន វាសាគារំ ឋបេត្វា សព្វត្ថ អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។



វិហារបូកប្រក់មិនទាន់ដល់ពីរជាន់ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វិហារបូកប្រក់មិនទាន់ដល់ពីរជាន់ ភិក្ខុសំគាល់ថាមិនទាន់ដល់ឡើយ មិនត្រូវអាបត្តិ ។

(១៨) អាបត្តិមិនមាន ដល់ភិក្ខុដែលបូកប្រក់វិហារត្រឹមពីរជាន់ ដល់ភិក្ខុដែលបូកប្រក់វិហារមិនដល់ពីរជាន់ ដល់ភិក្ខុដែលបូកប្រក់ លេណ (ទំគូរ) គុហា កុដិប្រក់ដោយស្មៅ ធ្វើដើម្បីប្រយោជន៍ដល់អ្នកដទៃ ធ្វើដោយទ្រព្យរបស់ខ្លួន ទីសេសសល់ទាំងពួង វៀរលែងតែកុដិសម្រាប់នៅរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

## ទសមសិក្ខាបទំ

(២០) តេន សមយេន ពុទ្ធោ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ តេន ខោ បន សមយេន អាឡវកា ភិក្ខូ នវកម្មំ ករោន្តា ជានំ សប្បាណកំ ឧទកំ តិណម្បិ មត្តិកម្បិ សិញ្ចន្តិបិ សិញ្ចាបេន្តិបិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អាឡវកា ភិក្ខូ ជានំ សប្បាណកំ ឧទកំ តិណម្បិ មត្តិកម្បិ សិញ្ចិស្សន្តិបិ សិញ្ចាបេស្សន្តិបីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ សប្បាណកំ ឧទកំ តិណម្បិ មត្តិកម្បិ សិញ្ចថបិ សិញ្ចាបេថបីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ជានំ សប្បាណកំ ឧទកំ តិណម្បិ មត្តិកម្បិ សិញ្ចិស្សថបិ សិញ្ចាបេស្សថបិ

## សិក្ខាបទទី ១០

(២០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុង អគ្គាឡវចេតិយ ទៀបស្រុកអាឡវី ។ គ្រានោះឯង ភិក្ខុស្រុកអាឡវីទាំងឡាយកាលធ្វើនូវនវកម្ម (កម្មធ្វើថែកសាងថ្មី) ដឹងថាទឹកមានសត្វ ក៏ស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកភិក្ខុស្រុកអាឡវីដឹងថាទឹកមានសត្វហើយមិនសមបើនឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះសោះឡើយ ។ គ្រានោះភិក្ខុទាំងនោះនាំគ្នាក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយដឹងថាទឹកមានសត្វ ហើយស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះ ពិតមែនឬ ។ ភិក្ខុទាំងនោះ ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងដឹងថាទឹកមានសត្វហើយមិនសមបើនឹងយកមកស្រោចឯងខ្លះ ប្រើគេឲ្យស្រោចខ្លះ នូវស្មៅខ្លះ នូវដីខ្លះទេ នែមោឃបុរសទាំងឡាយ ការកើតផល

ចេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ សប្បាណកំ ឧទកំ តិណំ វា មត្តិកំ វា សិញ្ចេយ្យ វា សិញ្ចាបេយ្យ វា បាចិត្តិយន្តិ ។

[៦១] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានំ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ ។

[៦២] សិញ្ចេយ្យាតិ សយំ សិញ្ចតិ អាបត្តិ បាចិត្តិយស្ស ។ សិញ្ចាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ បាចិត្តិយស្ស ។ សកិំ អាណត្តោ ពហុកម្បិ សិញ្ចតិ អាបត្តិ បាចិត្តិយស្ស ។ សប្បាណកេ សប្បាណកសញ្ញី តិណំ វា មត្តិកំ វា សិញ្ចតិ វា សិញ្ចាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ សប្បាណកេ វេមតិកោ តិណំ វា មត្តិកំ វា សិញ្ចតិ វា សិញ្ចាបេតិ វា អាបត្តិ ទុក្កដស្ស ។ សប្បាណកេ អប្បាណកសញ្ញី តិណំ វា មត្តិកំ



អំពើនេះមិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ឬមួយញុំាងបុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងមិនបានទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងជាទឹកមានសត្វហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅឬដី ត្រូវអាបត្តិបាចិត្តិយ ។

[៦១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះក្តី ឈ្មោះថា ភិក្ខុដឹង ។

[៦២] ត្រង់ពាក្យថា ស្រោចឯង គឺភិក្ខុស្រោចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើគេឲ្យស្រោច គឺភិក្ខុបង្គាប់អ្នកដទៃឲ្យស្រោច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រើតែម្តង ហើយអ្នកទទួលបង្គាប់នោះស្រោចច្រើនដង ភិក្ខុអ្នកប្រើត្រូវអាបត្តិបាចិត្តិយ ។ (ទឹក) មានសត្វ ភិក្ខុសំគាល់ថា (ទឹក) មានសត្វមែន ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅឬដី ត្រូវអាបត្តិបាចិត្តិយ ។ (ទឹក) មានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅឬដី ត្រូវអាបត្តិទុក្កដ ។ (ទឹក) មានសត្វ ភិក្ខុសំគាល់ថា គ្មានសត្វវិញ ហើយស្រោចឯងក្តី ប្រើគេឲ្យស្រោចក្តី នូវស្មៅឬដី

វា សិញ្ចតិ វា សិញ្ចាបេតិ វា អនាបត្តិ ។ អប្បាណកេ សប្បាណកសញ្ញី អាបត្តិ ទុក្កដស្ស ។ អប្បាណកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អប្បាណកេ អប្បាណកសញ្ញី អនាបត្តិ ។

(៦៣) អនាបត្តិ អសញ្ចិច្ច អសតិយា អជា-នន្តស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

ភូតគាមវគ្គោ ទុតិយោ ។



មិនត្រូវអាបត្តិអ្វីឡើយ ។ (ទឹក) មិនមានសត្វ ភិក្ខុសំគាល់ថា មានសត្វ ត្រូវអាបត្តិទុក្កដ ។ (ទឹក) មិនមានសត្វ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ (ទឹក) មិនមានសត្វ ភិក្ខុសំគាល់ថា មិនមានសត្វ មិនត្រូវអាបត្តិអ្វីឡើយ ។

(៦៣) អាបត្តិមិនមាន ដល់ភិក្ខុមិនក្លែង ដល់ភិក្ខុមិនមានស្មារតី ដល់ភិក្ខុមិនដឹង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់ ។

ភូតគាមវគ្គទី ២ ចប់ ។

ពាក្យខ្លីយកស្លោក ក្បួនតារាក្ខស្ស ឃ្លាត

កាក្យ ឃ្លាត់

ក្អែក ស្ពាយ ខ្សាយ

បក្សីខ្វែក គេ ធុរ

ម៉ាព្ធ ដំណែលបាបព្ធ ឆ្ងាំ

សប្បុរសកេន[1] ជាតិ ។

---

១ ម. ឱ. ក្រសេបូរាណ ។



ពាក្យខ្លីយកឈ្មោះ ក្បួនតាមវ័ន្ត ឃ្លាន

ចំនួនសិក្ខាបទកាន់ក្នុងតាមវត្តទោះ ១០

កុំស្រែកក្អកតាមផ្លូវដាច់ជាតទី១ កុំយកល្បៀនដៃមកបង្អប់ដើម្បី ចង់ចាប់ឱ្យអស់ខ្លួន១ កុំលើកជាលកំភួនជើងស្មើគ្នាសេរី១ កុំ យកស្រែកដាក់ក្នុងជាក់សិរលលាស្ររពៅលេលកុងទីពល ហើយ ឡើងសំពោញទៅ១ កុំយកកន្ទាលរបស់សង្ឃទៅក្រាល ដោយហើយឡើងសំពោញទៅ១ កុំដើរបៀតបៀតកន្ទក្ក ទៅមុខកន្ទក់សង្ឃ១ កុំនិទាននិក្ខងតៀតហើយបណ្ដេញ ពាក់ព័ន្ធរបស់សង្ឃ១ កុំអង្គុយបុះផងលើគ្រែទាំងជើងសើក ទុក១ កុំឈរបង្ហាញទោរស្នាយ ៗ ទាញក់ណាត់ក្រែមសក្តីតួរ ប្ដូរស្ទឹកបន្ទុំដល់បង្កាញ១ កុំយកទឹកមាត់ស្តោះទៅស្មោចកក្ខ ឬជ័រ១ ។

## ទុតិយវគ្គស្ស បឋមសិក្ខាបទំ

[៦៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តា លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អថ ខោ ឆព្វគ្គិយានំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ អាវុសោ ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តា លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ហន្ទាវុសោ មយំបិ ភិក្ខុនិយោ ឱវទាមាតិ ។ អថ ខោ ឆព្វគ្គិយា ភិក្ខូ ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ ឯថ អម្ហាកំ ភគិនិយោ ឧបសង្កមថ មយំបិ ឱវទិស្សាមាតិ ។ អថ ខោ តា ភិក្ខុនិយោ យេន ឆព្វគ្គិយា ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា ឆព្វគ្គិយេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ អថ ខោ ឆព្វគ្គិយា ភិក្ខូ ភិក្ខុនីនំ បរិត្តំ យេវ ធម្មឹ កថំ កត្វា ទិវសំ តិរច្ឆានកថាយ វីតិនាមេត្វា

## ទុតិយវគ្គ សិក្ខាបទទី ១

[៦៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយឲ្យឱវាទភិក្ខុនីទាំងឡាយ ក៏បាននូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុបាននឹកគ្នាយ៉ាងនេះថា ម្នាលអាវុសោ ឥឡូវនេះភិក្ខុជាថេរៈទាំងឡាយឲ្យឱវាទភិក្ខុនីបានចីវរ បិណ្ឌបាត សេនាសនៈនិងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ម្នាលអាវុសោទាំងឡាយ បើដូច្នោះ យើងទាំងឡាយក៏ឲ្យឱវាទភិក្ខុនីដែរ ។ វេលានោះ ពួកឆព្វគ្គិយភិក្ខុចូលទៅរកភិក្ខុនីទាំងឡាយ ហើយបាននិយាយយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ ពួកនាងចូរមករកពួកយើងខ្លះ នឹងឲ្យឱវាទ ។ គ្រានោះ ភិក្ខុនីទាំងឡាយនោះក៏ចូលទៅរកឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយបានថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយហើយអង្គុយក្នុងទីដ៏សមគួរ ។ ពួកឆព្វគ្គិយភិក្ខុធ្វើធម្មីកថាបន្តិចបន្តួច ដល់ភិក្ខុនី ហើយក៏ពោលតិរច្ឆានកថាឲ្យកន្លងអស់ ១ ថ្ងៃ រួចបញ្ជូនភិក្ខុនីឲ្យត្រឡប់ទៅវិញ ដោយពាក្យថា

ឧយ្យោជេសុំ គច្ឆថ ភគិនិយោតិ ។ អថខោ តា ភិក្ខុនិយោ យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ភិក្ខុនិយោ ភគវា ឯតទវោច កច្ចិ ភិក្ខុនិយោ ឱវាទោ ឥទ្ធោ អហោសីតិ ។ កុតោ ភន្តេ ឱវាទោ ឥទ្ធោ ភវិស្សតិ អយ្យា ឆព្វគ្គិយា អប្បមត្តកំយេវ ធម្មិំ កថំ កត្វា តិរច្ឆានកថាយ ទិវសំ ខេបេត្វា ឧយ្យោជេសុន្តិ ។ អថខោ ភគវា តា ភិក្ខុនិយោ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ តា ភិក្ខុនិយោ ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កមិំសុ ។ អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុនីនំ ឱវទន្តា អប្បមត្តកំយេវ ធម្មិំ កថំ កត្វា តិរច្ឆានកថាយ



ម្នាលប្អូនស្រីទាំងឡាយ អ្នកនាងចូរទៅចុះ ។ គ្រានោះ ភិក្ខុនីទាំងឡាយនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរពួកភិក្ខុនីនោះ ដែលឈរក្នុងទីដ៏សមគួរដោយពុទ្ធដីកាយ៉ាងនេះថា ម្នាលភិក្ខុនីទាំងឡាយ ឱវាទ (នោះ) បានបរិបូណ៌សម្រេចហើយឬ ។ ភិក្ខុនីទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចំរើន ឱវាទ (នោះ) នឹងបរិបូណ៌សម្រេចមកពីណា ព្រោះលោកម្ចាស់ឆព្វគ្គិយទាំងឡាយធ្វើនូវធម្មីកថាតែបន្តិចបន្តួចប៉ុណ្ណោះ ហើយពោលតិរច្ឆានកថាឲ្យកន្លងទៅអស់ ១ ថ្ងៃ រួចក៏បញ្ជូនខ្ញុំព្រះអង្គទាំងឡាយឲ្យត្រឡប់មកវិញ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ភិក្ខុនីទាំងឡាយនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថា ។ លំដាប់នោះ ភិក្ខុនីទាំងឡាយនោះ លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរបញ្ជាក់ឆព្វគ្គិយភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកទាំងឡាយធ្វើឱវាទដល់ភិក្ខុនីទាំងឡាយតិចណាស់ ពោលតែតិរច្ឆានកថា

វីតិនាមេត្វា ឧយ្យោជេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃ-បុរិសា ភិក្ខុនីនំ បរិត្តំយេវ ធម្មឹ កថំ កត្វា ទិវសំ តិរច្ឆានកថាយ វីតិនាមេត្វា ឧយ្យោជេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភិក្ខុនោវាទកំ សម្មន្និតុំ ឯវញ្ច បន ភិក្ខវេ សម្មន្និតព្វោ បឋមំ ភិក្ខុ យាចិតព្វោ ។ យាចិត្វា ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្នេយ្យ ។ ឯសា ញត្តិ ។



ឲ្យកន្លងទៅអស់ ១ ថ្ងៃ ហើយក៏បញ្ជូនភិក្ខុនីទាំងនោះឲ្យត្រឡប់ទៅវិញ ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា ពិតមែន ព្រះមានព្រះភាគ ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃ-បុរសទាំងឡាយ ពួកអ្នកឯងមិនសមបើនឹងធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយ តិចពេក ហើយដោយកាលតែតិរច្ឆានកថាឲ្យកន្លងអស់ ១ ថ្ងៃ ហើយបញ្ជូនភិក្ខុនីទាំងឡាយឲ្យត្រឡប់ទៅវិញសោះ នែមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ឬមួយនាំបុគ្គលអ្នកដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងមិនបាន ។ បេ ។ លុះព្រះដ៏មានព្រះភាគទ្រង់តិះដៀលហើយ ក៏ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ម្នាលភិក្ខុទាំងឡាយ សង្ឃត្រូវសន្មតភិក្ខុ ឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីយ៉ាងនេះ សង្ឃត្រូវអារាធនាភិក្ខុ (នោះ) ជាមុនសិន ។ លុះអារាធនារួចហើយ ភិក្ខុអ្នកឈ្លាសគួរប្រកាសឲ្យសង្ឃដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ បើសង្ឃកម្មនេះមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ នេះជាញត្តិ ប្រកាសសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ

សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ភិក្ខុនោវាទកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។ បេ ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្នតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ ភិក្ខុនោវាទកស្ស សម្មុតិ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សម្មតោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ ភិក្ខុនោវាទកោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ អថខោ ភគវា ឆព្វគ្គិយេ ភិក្ខូ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អសម្មតោ





សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ ការសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី សមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ខ្ញុំពោលសេចក្ដីនេះអស់វារៈជាគំរប់ពីរផង ។ បេ ។ ខ្ញុំពោលសេចក្ដីនេះអស់វារៈជាគំរប់បីផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្ដាប់ខ្ញុំ សង្ឃសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី ។ ការសន្មតភិក្ខុឈ្មោះនេះឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនី គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ ភិក្ខុឈ្មោះនេះសង្ឃបានសន្មតឲ្យជាអ្នកឲ្យឱវាទដល់ភិក្ខុនីហើយ ។ សង្ឃកម្មនេះគួរដល់សង្ឃ ហេតុនោះបានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវកិរិយានេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់តិះដៀលនូវឆព្វគ្គិយភិក្ខុទាំងឡាយដោយបរិយាយជាច្រើន ។ បេ ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដែលសង្ឃមិនបានសន្មត

ភិក្ខុនិយោ ឱវទេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(២៩) តេន ខោ បន សមយេន ថេរា ភិក្ខូ សម្មតា ភិក្ខុនិយោ ឱវទន្តា គរុធម្មេ លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ អថខោ ឆព្ពគ្គិយានំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ អាវុសោ ថេរា ភិក្ខូ សម្មតា ភិក្ខុនិយោ ឱវទន្តា គរុធម្មេ លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ហន្ទាវុសោ មយម្បិ និស្សីមំ គន្ត្វា អញ្ញមញ្ញំ ភិក្ខុនោវាទកំ សម្មន្និត្វា ភិក្ខុនិយោ ឱវទាមាតិ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ និស្សីមំ គន្ត្វា អញ្ញមញ្ញំ ភិក្ខុនោវាទកំ សម្មន្និត្វា ភិក្ខុនិយោ ឧបសង្កមិត្វា ឯតទវោចុំ មយម្បិ ភគិនិយោ សម្មតា អម្ហេ ឧបសង្កមេយ្យាថ មយម្បិ ឱវទិស្សាមាតិ ។ អថខោ តា ភិក្ខុនិយោ យេន ឆព្ពគ្គិយា ភិក្ខូ តេនុបសង្កមឹសុ ឧបសង្កមិត្វា ឆព្ពគ្គិយេ ភិក្ខូ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនិយោ



ហើយទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយដោយប្រការយ៉ាងនេះ ។

(២៩) សម័យនោះឯង ភិក្ខុជាថេរៈទាំងឡាយដែលសង្ឃបានសន្មតហើយ កាលទៅប្រដៅភិក្ខុនីទាំងឡាយ គឺបានចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជបរិក្ខារ ជាបច្ច័យរបស់ភិក្ខុឈឺ យ៉ាងនោះជាដើម ។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយ បានគិតថា អាវុសោ ឥឡូវនេះ ភិក្ខុជាថេរៈទាំងឡាយ ដែលសង្ឃបានសន្មតហើយ កាលទៅប្រដៅភិក្ខុនីទាំងឡាយ បានចីវរ បិណ្ឌបាត សេនាសនៈ គិលានភេសជ្ជបរិក្ខារ ជាបច្ច័យរបស់ភិក្ខុឈឺ យ៉ាងនោះជាដើម អាវុសោ បើដូច្នោះ មានតែពួកយើងទៅកាន់ទីក្រៅសីមា ហើយសន្មតគ្នានឹងគ្នាទៅវិញទៅមក ឲ្យជាអ្នកប្រដៅភិក្ខុនី រួចប្រដៅពួកភិក្ខុនី ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុទាំងនោះ ក៏ទៅកាន់ទីក្រៅសីមា ហើយសន្មតគ្នានឹងគ្នាទៅវិញទៅមក ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយចូលទៅរកភិក្ខុនីទាំងឡាយ ពោលយ៉ាងនេះថា ម្នាលប្អូនស្រីទាំងឡាយ សង្ឃបានសន្មតពួកយើងហើយ នាងទាំងឡាយ ចូរមករកពួកយើងចុះ យើងនឹងប្រដៅម្ចាស់ ។ ចំណែកភិក្ខុនីទាំងឡាយនោះចូលទៅរក ឆព្វគ្គិយភិក្ខុទាំងឡាយ លុះចូលទៅដល់ហើយ ថ្វាយបង្គំឆព្វគ្គិយភិក្ខុទាំងឡាយហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ឆព្វគ្គិយភិក្ខុទាំងឡាយ

បរិត្តាយេវ ធម្មំ កាចំ កត្វា ធីតំ តិជ្ជាតកាជាយ
វិតិណាមេត្វា ឧយ្យោជេសុំ តថ្វេ ភតិសំយោគិ ។
ជេវោ តា ភិក្ខុនំ យេន ភគវា តេនុបសង្កមឹសុ
ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។
ឯកមន្តំ ឋិតា ខោ តេ ភិក្ខូ ភគវា ឯត-
ទវោច កច្ចិ ភិក្ខវេ ខមនីយំ កច្ចិ យាបនីយំ ។
កុតោ តេ ខមនីយំ កុតោ យាបនីយំ អយ្យា
ធម្មិកា បរិត្តាយេវ ធម្មំ កាចំ ធីតំ តិជ្ជា-
តកាជាយ វិតិណាមេត្វា ឧយ្យោជេសុន្តិ ។ អថខោ
ភគវា តេ ភិក្ខូ ធម្មិយា កថាយ សន្ទស្សេសិ
សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ
តេ ភិក្ខូ ភគវតា ធម្មិយា កថាយ សន្ទ-
ស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា
ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា
បក្កមឹសុ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ
បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ធម្មិយំ



ធ្វើទឹកដោះបន្តិចបន្តួចដល់ភិក្ខុទាំងឡាយ ហើយកាលគិលានតាំងឲ្យ
គន្ធឥតស់១ថ្ងៃទៅ រួចហើយបញ្ជូនភិក្ខុទាំងនោះឲ្យត្រឡប់ទៅវិញដោយ
ពាក្យថា ម្នាលភ្លូនស្រីទាំងឡាយ ចូរនាំគ្នាទៅវិញចុះ ។ ពេលភិក្ខុ
ទាំងនោះនាំគ្នាចូលទៅកាន់ទីគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់
ហើយបានថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីដ៏សមគួរ ។
ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរភិក្ខុទាំងឡាយ ដែលឈរនៅក្នុងទី
ដ៏សមគួរនោះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងបានសម្រេចបព្វជ្ជាឬ
ទេ ។ ភិក្ខុទាំងឡាយទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំបាន
សម្រេចបព្វជ្ជាមកពីឯណា លោកម្ចាស់ឡូតួយទាំងឡាយធ្វើទឹកដោះ
បន្តិចបន្តួច ហើយពេលតែតាំងឲ្យគន្ធឥតស់១ថ្ងៃ រួចហើយបញ្ជូន
យើងខ្ញុំឲ្យត្រឡប់មកវិញ ។ សំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់
ភិក្ខុទាំងឡាយនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីក-
រាយដោយធម្មីកថា ។ ភិក្ខុទាំងឡាយនោះលុះព្រះដ៏មានព្រះភាគទ្រង់
ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយដោយព្រះ
ធម្មីកថាហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ
ធ្វើប្រទក្សិណចៀសចេញទៅ ។ គ្រានោះឯ ដំណើរនេះ
ព្រះដ៏មានព្រះភាគ ទ្រង់ឲ្យប្រជុំភិក្ខុសង្ឃព្រោះហេតុនោះ ត្រាស់ធម្មីកថា

ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុនីនំ
បរិត្តកំយេវ ធម្មឹ កថំ កត្វា ទិវសំ តិរច្ឆានកថាយ
វីតិនាមេត្វា ឧយ្យោជេថាតិ ។ សច្ចំ ភគវាតិ ។
វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោ-
ឃបុរិសា ភិក្ខុនីនំ បរិត្តកំយេវ ធម្មឹ កថំ កត្វា
ទិវសំ តិរច្ឆានកថាយ វីតិនាមេត្វា ឧយ្យោជេស្សថ
នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ប-
សន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ
កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អដ្ឋហង្គេហិ
សមន្នាគតំ ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្និតុំ សីលវា
ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរ-
សម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមា-
ទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ
សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យា-
ណា មជ្ឈេកល្យាណា បរិយោសានកល្យាណា
សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ



ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយធ្វើធម្មីកថាដល់ភិក្ខុនីទាំងឡាយ
បន្តិចបន្តួច ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់មួយថ្ងៃ រួចក៏បញ្ជូនភិក្ខុ-
នីទាំងនោះឲ្យត្រឡប់ទៅវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា
សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះ-
ដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកមិនសមបីនឹងធ្វើ
ធម្មីកថាបន្តិចបន្តួចដល់ពួកភិក្ខុនី ហើយពោលតិរច្ឆានកថាឲ្យកន្លងអស់
មួយថ្ងៃ រួចបញ្ជូនភិក្ខុនីទាំងនោះឲ្យត្រឡប់ទៅវិញសោះ ម្នាលមោឃបុរស
ទាំងឡាយ អំពើដែលអ្នកធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយ
ដែលមិនទាន់ជ្រះថ្លាទេ ឬមួយក៏បុគ្គលដែលជ្រះថ្លាហើយ ឲ្យរឹតតែ
ជ្រះថ្លាឡើងមិនបានទេ ។ បេ ។ ទ្រង់តិះដៀលហើយក៏ធ្វើធម្មីកថា
ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ
តថាគតអនុញ្ញាតឲ្យសន្មតភិក្ខុដែលប្រកបដោយអង្គ ៨ ឲ្យជាអ្នក
ប្រដៅភិក្ខុនី គឺភិក្ខុជាអ្នកមានសីលសង្រួមតាមបាតិមោក្ខសំវរៈ បរិបូណ៌
ដោយអាចារ(មារយាទ)និងគោចរ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយ
មានប្រមាណតិចតួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ភិក្ខុជា
ពហុស្សូត ទ្រទ្រង់សុតៈ សន្សំនូវសុតៈ ធម៌ទាំងឡាយណា ពីរោះ
ខាងដើម ពីរោះកណ្តាល ពីរោះខាងចុង ដែលប្រកាសនូវព្រហ្មចរិយធម៌

អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធាតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស បាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តីនិ(១) សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ យេភុយ្យេន ភិក្ខុនីនំ បិយោ ហោតិ មនាបោ បដិពលោ ហោតិ ភិក្ខុនិយោ ឱវទិតុំ ន ខោ បនេតំ ភគវន្តំ ឧទ្ទិស្ស បព្វជិតាយ កាសាយវត្ថវសនាយ គរុធម្មំ អជ្ឈាបន្នបុព្វោ ហោតិ វីសតិវស្សោ វា ហោតិ អតិរេកវីសតិវស្សោ វា អនុជានាមិ ភិក្ខវេ ឥមេហិ អដ្ឋហង្គេហិ សមន្នាគតំ ភិក្ខុំ ភិក្ខុនោវាទកំ សម្មន្និតុន្តិ ។

(៦៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អសម្មតោ នាម ញត្តិចតុត្ថេន កម្មេន អសម្មតោ ។ ភិក្ខុនិយោ នាម ឧភតោសង្ឃេ ឧបសម្បន្នា ។

១ សុប្បវត្តានីតិ បាឋោ ។



ព្រមទាំងអត្ថទាំងព្យញ្ជនៈឲ្យជាសុទ្ធបរិបូណ៌ទាំងអស់ គម្ពីរទាំងឡាយមានសភាពយ៉ាងនេះ ភិក្ខុនោះបានច្រើនហើយ ទ្រទ្រង់ហើយ ស្ទាត់ហើយដោយវាចាដ៏ស្ទាត់រត់មាត់ ចូលចិត្តច្បាស់លាស់ យល់ត្រូវល្អដោយទិដ្ឋិ ១ បាតិមោក្ខទាំងពីរ ភិក្ខុនោះក៏ចេះចាំដោយពិស្តារ ចែកចេញបានដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្តីបានដោយល្អដោយសូត្រ (គឺឧទ្ទេសៈនិទ្ទេសៈ) ដោយអនុព្យញ្ជនៈ ១ ភិក្ខុនោះមានវាចាពោលត្រឹមត្រូវដោយសិថិលធនិតជាដើម មានសំនៀងពីរោះ ១ ភិក្ខុនោះជាទីស្រឡាញ់ពេញចិត្តនៃភិក្ខុនីទាំងឡាយដោយច្រើន ១ ភិក្ខុនោះជាអ្នកអាចដើម្បីទូន្មានប្រដៅភិក្ខុនីបាន ១ ភិក្ខុនោះមិនធ្លាប់ប្រព្រឹត្តកន្លងគរុធម៌នឹងភិក្ខុនីដែលស្លៀកដណ្ដប់សំពត់ដែលជ្រលក់ដោយទឹកចត់ បួសចំពោះព្រះដ៏មានព្រះភាគនេះ ១ ភិក្ខុនោះមានវស្សាម្ភៃ ឬមានវស្សាជាងម្ភៃ ១ ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យសង្ឃសន្មតភិក្ខុដែលប្រកបដោយអង្គទាំងឡាយ ៨ នេះឲ្យជាអ្នកប្រដៅភិក្ខុនី ។

(៦៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចជាក្នុងសិក្ខាបទទី១ នៃផ្នែកបារាជិកកណ្ឌ ។ ភិក្ខុដែលឈ្មោះថាសង្ឃមិនបានសន្មតនោះ គឺសង្ឃមិនបានសន្មតដោយញត្តិចតុត្ថកម្មវាចា ។ ពួកស្រីដែលឈ្មោះថាភិក្ខុនីនោះ បានដល់ស្រីដែលបានឧបសម្បទាហើយក្នុងឧភតោសង្ឃ ។

[២៧] ឱវទេយ្យាតិ អដ្ឋហិ គរុធម្មេហិ ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញេន ធម្មេន ឱវទតិ អាបត្តិ ទុក្កដស្ស ។ ឯកតោ ឧបសម្បន្នំ ឱវទតិ អាបត្តិ ទុក្កដស្ស ។

[២៨] តេន សម្មតេន ភិក្ខុនា បរិវេណំ សម្មជ្ជិត្វា បានីយំ បរិភោជនីយំ ឧបដ្ឋាបេត្វា អាសនំ បញ្ញាបេត្វា ទុតិយំ គហេត្វា និសីទិតព្វំ ។ ភិក្ខុនីហិ តត្ថ គន្ត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ និសីទិតព្វំ ។ តេន សម្មតេន[១] ភិក្ខុនា បុច្ឆិតព្វា សមគ្គត្ថ ភគិនិយោតិ ។ សចេ សមគ្គម្ហាយ្យាតិ ភណន្តិ វត្តន្តិ ភគិនិយោ អដ្ឋ គរុធម្មាតិ ។ សចេ វត្តន្តិ អយ្យាតិ ភណន្តិ ឯសោ ភគិនិយោ ឱវាទោតិ និយ្យាទេតព្វោ ។ សចេ ន វត្តន្តិ អយ្យាតិ ភណន្តិ ឱសារេតព្វា វស្សសតុប-សម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ អយំ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ

១ ម. ឧ. បោត្ថកេ គយំ ទាហេ ។ យោតិ ។



(២៧) ពាក្យថា ប្រដៅ គឺភិក្ខុប្រដៅដោយគរុធម៌ ៨ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រដៅដោយធម៌ដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រដៅភិក្ខុនីដែលបានឧបសម្បទាក្នុងសំណាក់សង្ឃតែមួយខាងណោះ ត្រូវអាបត្តិទុក្កដ ។

(២៨) ភិក្ខុដែលសង្ឃសន្មតនោះ គប្បីបោសសម្អាតបរិវេណ រួចដាក់ទឹកឆាន់ ទឹកប្រើប្រាស់ តែងតាំងអាសនៈ ហើយនាំយកភិក្ខុជាគំរប់ពីរទៅអង្គុយនៅចុះ ។ ភិក្ខុនីទាំងឡាយ គប្បីទៅក្នុងទីនោះ ហើយថ្វាយបង្គំភិក្ខុនោះ រួចអង្គុយនៅក្នុងទីដ៏សមគួរ ។ ភិក្ខុដែលសង្ឃសន្មតនោះ គប្បីសួរភិក្ខុនីទាំងឡាយថា ម្នាលនាងទាំងឡាយ ពួកនាងព្រមព្រៀងគ្នាហើយឬ ។ បើភិក្ខុនីទាំងឡាយពោលថា លោកម្ចាស់ យើងខ្ញុំទាំងឡាយព្រមព្រៀងគ្នាហើយ ភិក្ខុគប្បីសួរថា ម្នាលនាងទាំងឡាយ គរុធម៌ ៨ ចាំស្ទាត់តែមាត់ហើយឬ ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ ចាំស្ទាត់តែមាត់ហើយ ភិក្ខុគប្បីប្រគល់ឱវាទដោយពាក្យថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ ។ បើភិក្ខុនីទាំងឡាយពោលថា នៅមិនទាន់ចាំស្ទាត់ទេ លោកម្ចាស់ ភិក្ខុគប្បីសូត្រប្រាប់ភិក្ខុនីថា ភិក្ខុនីឧបសម្បទាហើយបានមួយរយវស្សា ត្រូវធ្វើអភិវាទនកម្ម បច្ចុដ្ឋានកម្ម អញ្ជលីកម្ម និងសាមីចិកម្ម ដល់ភិក្ខុ (សូម្បី) ទើបឧបសម្បទាហើយក្នុងថ្ងៃនោះ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈគោរពរាប់អានបូជា

អនតិក្កមនីយោ ។ ន ភិក្ខុនិយា អភិក្ខុកេ អាវាសេ វស្សំ វសិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ អន្វឌ្ឍមាសំ ភិក្ខុនិយា ភិក្ខុសង្ឃតោ ទ្វេ ធម្មា បច្ចាសីសិតព្វា ឧបោសថបុច្ឆកញ្ច ឱវាទុបសង្កមនញ្ច អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ វស្សំ វុដ្ឋាយ ភិក្ខុនិយា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតព្វំ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ គរុធម្មំ អជ្ឈាបន្នាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឃេ ឧបសម្បទា បរិយេសិតព្វា អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ ន ភិក្ខុនិយា កេនចិ បរិយាយេន ភិក្ខុ អក្កោសិតព្វោ



កុំប្រព្រឹត្តកន្លងក្នុងទីជាប់អស់មួយជីវិត ។ ភិក្ខុនីមិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អគោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងក្នុងទីជាប់អស់មួយជីវិត ។ ភិក្ខុនីត្រូវប្រាថ្នាធម៌ពីរប្រការ គឺការសាកសួរនូវឧបោសថ ១ ការចូលទៅទទួលឱវាទ ១ អំពីភិក្ខុសង្ឃរៀងរាល់កន្លះខែ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អគោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងក្នុងទីជាប់អស់មួយជីវិត ។ ភិក្ខុនីនៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងឧភតោសង្ឃ ដោយឋានៈបី គឺដោយឃើញក្តី ដោយឮក្តី ដោយរង្កៀសក្តី នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អគោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងក្នុងទីជាប់អស់មួយជីវិត ។ ភិក្ខុនីត្រូវគរុកាបត្តិ(ជាសង្ឃាទិសេស) ហើយត្រូវប្រព្រឹត្តបក្ខមានត្តក្នុងឧភតោសង្ឃ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អគោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងក្នុងទីជាប់អស់មួយជីវិត ។ ភិក្ខុនីត្រូវស្វែងរកនូវឧបសម្បទាក្នុងឧភតោសង្ឃដល់សិក្ខមានាដែលមានសិក្ខាសិក្សាក្នុងធម៌ទាំង ៦ អស់ពីរវស្សាហើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អគោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងក្នុងទីជាប់អស់មួយជីវិត ១ ។ ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចផ្ដាសាភិក្ខុដោយបរិយាយណាមួយឡើយ

បរិភាសិតព្វោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ អជ្ជតគ្គេ ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនបថោ អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោតិ ។ សចេ សមគ្គម្ហាយ្យាតិ ភណន្តិ[១] អញ្ញំ ធម្មំ ភណតិ អាបត្តិ ទុក្កដស្ស ។ សចេ វគ្គម្ហាយ្យាតិ ភណន្តិ[២] អដ្ឋ គរុធម្មេ ភណតិ អាបត្តិ ទុក្កដស្ស ។ ឱវាទំ អនិយ្យាទេត្វា អញ្ញំ ធម្មំ ភណតិ អាបត្តិ ទុក្កដស្ស ។

[២៨] អធម្មកម្មេ អធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ វេមតិកោ ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ សមគ្គសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។

១-២ ឱ. ម. ភណន្តិ ។



នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត ៧ ។ ពួកភិក្ខុនីមិនត្រូវស្តីប្រដៅពួកភិក្ខុឡើយ ពួកភិក្ខុត្រូវស្តីប្រដៅដល់ពួកភិក្ខុនីបាន តាំងពីកាលថ្ងៃនេះជាដើម នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើឲ្យល្អ គោរពរាប់អានបូជា កុំប្រព្រឹត្តកន្លងដរាបអស់មួយជីវិត ៨ ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយព្រមព្រៀងគ្នាហើយ ភិក្ខុពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ ។ បើភិក្ខុនីទាំងឡាយពោលថា បពិត្រលោកម្ចាស់ យើងខ្ញុំទាំងឡាយបែកគ្នាជាពួកៗ ភិក្ខុពោលតែគរុធម៌ ៨ ដដែល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទាន់ប្រគល់ឱវាទឲ្យដល់ភិក្ខុនី ត្រឡប់ពោលធម៌ដទៃវិញ ត្រូវអាបត្តិទុក្កដ ។

[២៨] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថាកម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថាកម្មមិនជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣០] អធម្មកម្មេ វេមតិកោ វគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។បេ។ វេមតិកោ ឱវទតិ ។បេ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។

[៣១] អធម្មកម្មេ ធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។បេ។ វេមតិកោ ឱវទតិ ។បេ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។

[៣២] អធម្មកម្មេ អធម្មកម្មសញ្ញី សមគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។បេ។ វេមតិកោ ឱវទតិ ។បេ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។

[៣៣] អធម្មកម្មេ វេមតិកោ សមគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។បេ។ វេមតិកោ ឱវទតិ ។បេ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។



[៣០] ភិក្ខុសង្ស័យក្នុងកម្មមិនជាធម៌ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកបែក ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យហើយប្រដៅ ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣១] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មជាធម៌ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកបែក ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យហើយប្រដៅ ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣២] កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថា កម្មមិនជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យហើយប្រដៅ ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

[៣៣] កម្មមិនមែនជាធម៌ ភិក្ខុសង្ស័យ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ។បេ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។បេ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។

(៣៤) អធម្មកម្មេ ធម្មកម្មសញ្ញី សមគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។ បេ ។ វេមតិកោ ឱវទតិ ។ បេ ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ ថុល្លច្ចយស្ស ។

(៣៥) ធម្មកម្មេ អធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ វេមតិកោ ឱវទតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ សមគ្គសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។

(៣៦) ធម្មកម្មេ វេមតិកោ វគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។ បេ ។ វេមតិកោ ឱវទតិ ។ បេ ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។

(៣៧) ធម្មកម្មេ ធម្មកម្មសញ្ញី វគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។ បេ ។ វេមតិកោ ឱវទតិ ។ បេ ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។



(៣៤) កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថាកម្មមិនមែនជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ស័យហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិថុល្លច្ច័យ ។

(៣៥) កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មមិនជាធម៌វិញ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

(៣៦) កម្មជាធម៌ ភិក្ខុសង្ស័យ ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

(៣៧) កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ភិក្ខុនីសង្ឃបែកគ្នាជាពួក ភិក្ខុសំគាល់ថាជាពួកមែន ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

(៣៨) ធម្មកម្មេ អធម្មកម្មសញ្ញី សមគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។ បេ ។ វេមតិកោ ឱវទតិ ។ បេ ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។

(៣៩) ធម្មកម្មេ វេមតិកោ សមគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ ។ បេ ។ វេមតិកោ ឱវទតិ ។ បេ ។ សមគ្គសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។

(៤០) ធម្មកម្មេ ធម្មកម្មសញ្ញី សមគ្គំ ភិក្ខុនីសង្ឃំ វគ្គសញ្ញី ឱវទតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ ធម្មកម្មសញ្ញី សមគ្គំ ភិក្ខុនីសង្ឃំ វេមតិកោ ឱវទតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ ធម្មកម្មសញ្ញី សមគ្គំ ភិក្ខុនីសង្ឃំ សមគ្គសញ្ញី ឱវទតិ អនាបត្តិ ។





(៣៨) កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មមិនមែនជាធម៌វិញ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

(៣៩) កម្មជាធម៌ ភិក្ខុមានសេចក្តីសង្ស័យ ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ។ បេ ។ ភិក្ខុសង្ស័យ ហើយប្រដៅ ។ បេ ។ ភិក្ខុសំគាល់ថាព្រមព្រៀងគ្នា ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។

(៤០) កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាបែកគ្នាជាពួកវិញ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសង្ស័យ ហើយប្រដៅ ត្រូវអាបត្តិទុក្កដ ។ កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ភិក្ខុនីសង្ឃព្រមព្រៀងគ្នា ភិក្ខុសំគាល់ថាព្រមព្រៀងគ្នាមែន ហើយប្រដៅ មិនត្រូវអាបត្តិឡើយ ។

(៤១) អនាបត្តិ ឧទ្ទេសំ ទេន្តោ បរិបុច្ឆំ ទេន្តោ ឱសា-
រេហិ អយ្យាតិ វុច្ចមានោ ឱសារេតិ បញ្ហំ បុច្ឆតិ បញ្ហំ
បុដ្ឋោ កថេតិ អញ្ញស្សត្ថាយ ភណន្តំ ភិក្ខុនិយោ
សុណន្តិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស
អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។



(៤០) អាបត្តិមិនមានដល់ភិក្ខុដែលសំដែងនូវឧទ្ទេសនៃគម្ពីរ
ដល់ភិក្ខុដែលសំដែងនូវអដ្ឋកថានៃគម្ពីរ ដល់ភិក្ខុដែលភិក្ខុនីពោល
ថា លោកម្ចាស់ ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា
ហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនី
ចូលស្តាប់ផង ដល់ភិក្ខុប្រាប់ធម៌ដល់សិក្ខមានា ដល់សាមណេរី ដល់
ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់ ។

## ទុតិយសិក្ខាបទំ

(៤២) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តិ បរិយាយេន ។ តេន ខោ បន សមយេន អាយស្មតោ ចូឡបន្ថកស្ស បរិយាយោ ហោតិ ភិក្ខុនិយោ ឱវទិតុំ ។ ភិក្ខុនិយោ ឯវមាហំសុ ន ទានិ អជ្ជ ឱវាទោ ឥទ្ធោ ភវិស្សតិ តញ្ញេវ ទានិ ឧទានំ អយ្យោ ចូឡបន្ថកោ បុនប្បុនំ ភណិស្សតីតិ ។ អថខោ តា ភិក្ខុនិយោ យេនាយស្មា ចូឡបន្ថកោ តេនុបសង្កមិំសុ ឧបសង្កមិត្វា អាយស្មន្តំ ចូឡបន្ថកំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ ។ ឯកមន្តំ និសិន្នា ខោ តា ភិក្ខុនិយោ អាយស្មា ចូឡបន្ថកោ ឯតទវោច សមគ្គត្ថ ភគិនិយោតិ ។ សមគ្គម្ហាយ្យាតិ ។ វត្តន្តិ គរុធម្មាតិ ។ វត្តន្តិ អយ្យាតិ ។ ឯសោ ភគិនិយោ ឱវាទោតិ និយ្យាទេត្វា ឥមំ ឧទានំ បុនប្បុនំ អភាសិ

## សិក្ខាបទទី ២

(៤២) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនីតាមវេនរៀងខ្លួនៗ ។ សម័យនោះឯង ព្រះចូឡបន្ថកដ៏មានអាយុត្រូវវេនប្រដៅភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីនិយាយគ្នាថា ថ្ងៃនេះឱវាទនឹងមិនសម្រេចប្រយោជន៍ទេ លោកម្ចាស់ចូឡបន្ថកនឹងពោលនូវឧទាននោះឯងដដែលៗទៀតហើយ ។ ភិក្ខុនីទាំងនោះនាំគ្នាចូលទៅរកព្រះចូឡបន្ថកដ៏មានអាយុ លុះទៅដល់ហើយ ក៏ថ្វាយបង្គំព្រះចូឡបន្ថកដ៏មានអាយុ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ ឯព្រះចូឡបន្ថកដ៏មានអាយុ បាននិយាយនឹងភិក្ខុនីទាំងនោះ ដែលអង្គុយនៅហើយក្នុងទីដ៏សមគួរ ដោយពាក្យយ៉ាងនេះថា ម្នាលនាងទាំងឡាយ ពួកនាងព្រមព្រៀងគ្នាហើយឬ ។ ពួកភិក្ខុនីតបថា ព្រមព្រៀងគ្នាហើយ លោកម្ចាស់ ។ ព្រះចូឡបន្ថកសួរថា ម្នាលនាងទាំងឡាយ គរុធម៌ ៨ ជាស្អាតហើយឬ ។ ពួកភិក្ខុនីតបថា ជាស្អាតហើយ លោកម្ចាស់ ។ ព្រះចូឡបន្ថកប្រាប់ថា ម្នាលនាងទាំងឡាយ នេះហើយជាឱវាទ ហើយបានពោលនូវឧទាននេះដដែលៗថា

អធិចេតសោ អប្បមជ្ជតោ
មុនិនោ មោនបថេសុ សិក្ខតោ
សោកា ន ភវន្តិ តាទិនោ
ឧបសន្តស្ស សទា សតីមតោតិ ។

[៦៣] ភិក្ខុនិយោ ឯវមាហំសុ ននុ អវោចុម្ហា នទានិ អជ្ជ ឱវាទោ ឥទ្ធោ ភវិស្សតិ តទេវិទានិ ឧទានំ អយ្យោ ចូឡបន្ថកោ បុនប្បុនំ ភណិស្សតីតិ ។ អស្សោសិ ខោ អាយស្មា ចូឡបន្ថកោ តាសំ ភិក្ខុនីនំ ឥមំ កថាសល្លាបំ ។ អថខោ អាយស្មា ចូឡបន្ថកោ វេហាសំ អព្ភុគ្គន្ត្វា អាកាសេ អន្តលិក្ខេ ចង្កមតិបិ តិដ្ឋតិបិ និសីទតិបិ សេយ្យម្បិ កប្បេតិ ធូមាយតិបិ បជ្ជលតិបិ អន្តរធាយតិបិ តញ្ចេវ ឧទានំ ភណតិ អញ្ញញ្ច ពហុំ ពុទ្ធវចនំ ។ ភិក្ខុនិយោ ឯវមាហំសុ អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ ន វត នោ ឥតោ បុព្វេ ឱវាទោ ឯវំ ឥទ្ធោ ភូតបុព្វោ យថា អយ្យស្ស ចូឡបន្ថកស្សាតិ ។ អថខោ អាយស្មា



សេចក្តីសោកទាំងឡាយ រមែងមិនមានដល់បុគ្គលដែលមាន អធិចិត្តមិនប្រមាទ សិក្សានៅក្នុងផ្លូវនៃមោនធម៌ (គឺអរហត្ត-ញាណ) មិនញាប់ញ័រ (ដោយលោកធម៌) មានចិត្តស្ងប់ (ចាកកិលេស) តែងមានស្មារតី ជានិច្ច ។

(៦៣) ភិក្ខុនីទាំងឡាយ បាននិយាយគ្នាយ៉ាងនេះថា យើងទាំងឡាយបាននិយាយគ្នាទុកមកហើយថា ឱវាទថ្ងៃនេះមុខជានឹងមិនសម្រេចប្រយោជន៍ទេ លោកម្ចាស់ចូឡបន្ថក នឹងពោលនូវឧទាននោះឯងដដែលៗទៀត ។ ព្រះចូឡបន្ថកដ៏មានអាយុបានស្ដាប់ពាក្យនិយាយចរចារនេះរបស់ភិក្ខុនីទាំងឡាយនោះហើយ ។ គ្រានោះ ព្រះចូឡបន្ថកដ៏មានអាយុ ហោះទៅកាន់វេហាសស្ថានហើយចង្ក្រមខ្លះ ឈរខ្លះ អង្គុយខ្លះ ដេកខ្លះ បង្ហុយផ្សែងខ្លះ បញ្ចេញភ្លើងខ្លះ បំបាត់ខ្លួនខ្លះ ហើយពោលនូវឧទាននោះទៀតផង នឹងពុទ្ធវចនៈដទៃជាច្រើនផង [illegible] ។ ភិក្ខុនីទាំងឡាយបាននិយាយគ្នាយ៉ាងនេះថា ម្នាលម្ចាស់យើងទាំងឡាយ សេចក្តីអស្ចារ្យ (នេះ) ចំឡែកពេកណាស់ ម្នាលម្ចាស់យើងទាំងឡាយ ហេតុមិនធ្លាប់កើត ។ ហើយ ឱវាទដែលសម្រេចប្រយោជន៍ ដូចជាឱវាទរបស់លោកម្ចាស់ចូឡបន្ថកយ៉ាងនេះ កាលពីដើមយើងមិនធ្លាប់បាន (ស្ដាប់) ទេ ។ លំដាប់នោះព្រះចូឡបន្ថកដ៏មានអាយុ

ចូឡបន្ថកោ តា ភិក្ខុនិយោ យាវ សមន្ធការា ឱវ-
ទិត្វា ឧយ្យោជេសិ គច្ឆថ ភគិនិយោតិ ។ អថខោ
តា ភិក្ខុនិយោ នគរទ្វារេ ថកិតេ ពហិនគរេ វសិត្វា
កាលស្សេវ នគរំ បវិសន្តិ ។ មនុស្សា ឧជ្ឈាយន្តិ
ខីយន្តិ វិបាចេន្តិ អព្រហ្មចារិនិយោ ឥមា ភិក្ខុនិយោ
អារាមេ ភិក្ខូហិ សទ្ធឹ វសិត្វា ឥទានិ នគរំ បវិ-
សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ
ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ
អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ
កថំ ហិ នាម អាយស្មា ចូឡបន្ថកោ អត្ថង្គតេ
សុរិយេ ភិក្ខុនិយោ ឱវទិស្សតីតិ ។ បេ ។ សច្ចំ
កិរ ត្វំ ចូឡបន្ថក អត្ថង្គតេ សុរិយេ ភិក្ខុនិយោ
ឱវទសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ នាម ត្វំ ចូឡបន្ថក
អត្ថង្គតេ សុរិយេ ភិក្ខុនិយោ ឱវទិស្សសិ នេតំ
ចូឡបន្ថក អប្បសន្នានំ វា បសាទាយ ។ បេ ។



ប្រដៅភិក្ខុនីអស់ហ្វូងនោះដរាបដល់ងងឹត ហើយបញ្ជូនទៅវិញថា ម្នាលនាងដ៏
ចំរើនទាំងឡាយ ពួកនាងនិមន្តទៅចុះ ។ វេលានោះទ្វារនគរគេបិទហើយ ភិក្ខុនីទាំង
នោះក៏នៅរាត្រីក្រៅនគរ លុះព្រឹកឡើងទើបចូលទៅកាន់នគរ ។ មនុស្ស
ទាំងឡាយ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីទាំងឡាយនេះ
មិនមែនជាព្រហ្មចារិនី (មិនមែនជាអ្នកប្រព្រឹត្តល្អ) ទេ នៅជាមួយនឹងភិក្ខុ
ទាំងឡាយក្នុងអារាមហើយទើបចូលមកកាន់នគរក្នុងកាលឥឡូវនេះ ។
ភិក្ខុទាំងឡាយ បានឮពាក្យមនុស្សអស់ហ្វូងនោះ ពោលទោស តិះដៀល
បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច
។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចូឡ-
បន្ថកៈដ៏មានអាយុ កាលព្រះអាទិត្យអស្តង្គតហើយមិនគួរនឹងទៅប្រដៅ
ភិក្ខុនីទាំងឡាយទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាល
ចូឡបន្ថកៈ ឮថា កាលព្រះអាទិត្យអស្តង្គតហើយ អ្នកឯងទៅប្រដៅ ភិក្ខុនី
ទាំងឡាយពិតមែនឬ ។ ព្រះចូឡបន្ថកៈដ៏មានអាយុទូលថា សូមទ្រង់
មេត្តាប្រោសពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោស
ថា ម្នាលចូឡបន្ថកៈ កាលព្រះអាទិត្យអស្តង្គតទៅហើយ អ្នកឯងមិនគួរ
នឹងទៅប្រដៅភិក្ខុនីទាំងឡាយទេ ម្នាលចូឡបន្ថកៈ អំពើដែលអ្នកធ្វើនេះ
មិននាំឲ្យជ្រះថ្លា ដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។

ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ

សម្មតោបិ ចេ ភិក្ខុ អត្ថង្គតេ សុរិយេ ភិក្ខុនិយោ ឱវទេយ្យ បាចិត្តិយន្តិ ។

(៦៦) សម្មតោ នាម ញត្តិចតុត្ថេន កម្មេន សម្មតោ ។ អត្ថង្គតេ សុរិយេតិ ឱគ្គតេ សុរិយេ ។ ភិក្ខុនិយោតិ ឧភតោសង្ឃេ ឧបសម្បន្នា ។ ឱវទេយ្យាតិ អដ្ឋហិ វា គរុធម្មេហិ អញ្ញេន វា ធម្មេន ឱវទតិ អាបត្តិ បាចិត្តិយស្ស ។

(៦៧) អត្ថង្គតេ អត្ថង្គតសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ អត្ថង្គតេ វេមតិកោ ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ អត្ថង្គតេ អនត្ថង្គតសញ្ញី ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ ឯកតោ ឧបសម្បន្នំ(១) ឱវទតិ អាបត្តិ ទុក្កដស្ស ។ អនត្ថង្គតេ អត្ថង្គតសញ្ញី អាបត្តិ ទុក្កដស្ស ។ អនត្ថង្គតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនត្ថង្គតេ អនត្ថង្គតសញ្ញី អនាបត្តិ ។

(១) យេភុយ្យេន ឯកតោ ឧបសម្បន្នាយាតិ ទិស្សតិ ។



ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុបើទុកជាសង្ឃ បានសន្មតហើយ កាលបើព្រះអាទិត្យអស្តង្គតហើយទៅប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ ។

(៦៦) ដែលហៅថា សង្ឃបានសន្មតនោះ គឺសង្ឃសន្មតហើយ ដោយញត្តិចតុត្ថកម្ម ។ ត្រង់ពាក្យថា ព្រះអាទិត្យអស្តង្គតហើយ សេចក្តីថា ព្រះអាទិត្យលិចចុះហើយ ។ ពួកស្រីដែលបានឧបសម្បទាក្នុងទីជុំសង្ឃ ទាំង២ចំណែក ហៅថា ភិក្ខុនី ។ ពាក្យថា ប្រដៅ សេចក្តីថា ភិក្ខុប្រដៅភិក្ខុនីដោយគរុធម៌ ៨ ក្តី ដោយធម៌ដទៃក្តី ត្រូវអាបត្តិបាចិត្តិយ ។

(៦៧) ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុសំគាល់ថា អស្តង្គតមែន ហើយទៅប្រដៅ (ភិក្ខុនី) ត្រូវអាបត្តិបាចិត្តិយ ។ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះអាទិត្យអស្តង្គតហើយ ភិក្ខុសំគាល់ថាមិនទាន់អស្តង្គត ហើយទៅប្រដៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុប្រដៅភិក្ខុនីដែលឧបសម្បទាហើយក្នុងទីជុំសង្ឃមួយចំណែក ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុសំគាល់ថាអស្តង្គតហើយ ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ព្រះអាទិត្យមិនទាន់អស្តង្គត ភិក្ខុសំគាល់ថា មិនទាន់អស្តង្គត មិនត្រូវអាបត្តិឡើយ ។

(៤៦) អនាបត្តិ ឧទ្ទេសំ ទេន្តោ បរិបុច្ឆំ ទេន្តោ ឱសារេហិ អយ្យាតិ វុច្ចមានោ ឱសារេតិ បញ្ហំ បុច្ឆតិ បញ្ហំ បុដ្ឋោ កថេតិ អញ្ញស្សត្ថាយ ភណន្តំ ភិក្ខុនិយោ សុណន្តិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។



(៤៦) អាបត្តិមិនមាន ដល់ភិក្ខុដែលសំដែងនូវបាលីនៃគម្ពីរ ដល់ភិក្ខុដែលសំដែងនូវអដ្ឋកថានៃគម្ពីរ ដល់ភិក្ខុដែលភិក្ខុនីពោលថា ព្រះលោកម្ចាស់ចូរសូត្រទៅ ភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយដោះ ដល់ភិក្ខុដែលសំដែងធម៌ឲ្យអ្នកដទៃស្តាប់ ហើយភិក្ខុនីចូលស្តាប់ផង ដល់ភិក្ខុប្រាប់ធម៌ដល់សិក្ខមានាឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់ ។

## តតិយសិក្ខាបទំ

[៤៧] តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ឆព្ពគ្គិយា ភិក្ខុនិយោ ឱវទន្តិ ។ ភិក្ខុនិយោ ឆព្ពគ្គិយា ភិក្ខុនិយោ ឯតទវោចុំ ឯថ អយ្យេ ឱវាទំ គមិស្សាមាតិ ។ យម្បិ[1] មយំ អយ្យេ គច្ឆេយ្យាម ឱវាទស្ស ការណា អយ្យា ឆព្ពគ្គិយា ឥធេវ អម្ហេ ឱវទន្តីតិ ។ ភិក្ខុនិយោ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទន្តីតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទន្តីតិ ។បេ។ សច្ចំ កិរ

១ ម. ឆ. យំ ហិ ។

## សិក្ខាបទទី ៣

[៤៧] សម័យនោះ ព្រះសម្ពុទ្ធមានព្រះភាគ កាលគង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនឈ្មោះសក្កៈ ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ ចូលទៅកាន់លំនៅរបស់ភិក្ខុនី ហើយប្រដៅពួកឆព្វគ្គិយភិក្ខុនីទាំងឡាយ ។ ភិក្ខុនីទាំងឡាយពោលនិយាយប្រាប់ពួកឆព្វគ្គិយភិក្ខុនីយ៉ាងនេះថា ម្នាលនាងទាំងឡាយ ពួកនាងចូរមក យើងនឹងទៅទទួលឱវាទ (ជាមួយគ្នា) ។ ឆព្វគ្គិយភិក្ខុនីនិយាយថា ម្នាលនាងទាំងឡាយ យើងទាំងឡាយ នាំគ្នាទៅព្រោះហេតុនៃឱវាទធ្វើអ្វី ព្រោះឆព្វគ្គិយភិក្ខុជាម្ចាស់ទាំងឡាយមកប្រដៅពួកយើងក្នុងលំនៅនេះហើយ ។ ភិក្ខុនីទាំងឡាយនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងចូលដល់លំនៅភិក្ខុនី ហើយប្រដៅភិក្ខុនីទាំងឡាយទេ ។ លំដាប់នោះ ភិក្ខុនីទាំងនោះក្រាបទូលដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនី ។បេ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ

តុម្ហេ ភិក្ខវេ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៤៨] តេន ខោ បន សមយេន មហាបជាបតិ គោតមី គិលានា ហោតិ ។ ថេរា ភិក្ខូ យេន មហាបជាបតិ គោតមី តេនុបសង្កមឹសុ ឧបសង្កមិត្វា មហាបជាបតឹ គោតមឹ ឯតទវោចុំ កច្ចិ តេ គោតមិ ខមនីយំ កច្ចិ យាបនីយន្តិ ។ ន មេ អយ្យា



ប្រដៅភិក្ខុនីទាំងឡាយចូលដល់លំនៅភិក្ខុនី ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងទៅប្រដៅភិក្ខុនីទាំងឡាយ ចូលដល់លំនៅភិក្ខុនីទេ នែមោឃបុរសទាំងឡាយ អំពើដែលពួកឯងធ្វើនេះ មិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីទាំងឡាយ ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៤៨] សម័យនោះឯង ព្រះមហាបជាបតីគោតមីភិក្ខុនីមានជម្ងឺ ។ ភិក្ខុជាថេរៈទាំងឡាយ ចូលទៅកាន់លំនៅព្រះមហាបជាបតីគោតមីភិក្ខុនី លុះចូលទៅដល់ហើយ បាននិយាយសួរព្រះមហាបជាបតីគោតមីភិក្ខុនីយ៉ាងនេះថា ម្នាលព្រះនាងគោតមី សរីរយន្តព្រះនាងល្មមអត់ទ្រាំបានដែរឬទេ ល្មមប្រព្រឹត្តទៅបានប្រាកដដែរឬទេ ។ ព្រះមហាបជាបតីគោតមីភិក្ខុនីតបថា លោកម្ចាស់ សរីរយន្តខ្ញុំមិនអាចអត់ទ្រាំបានទេ ខ្ញុំមិនអាច

ខមនីយំ ន យាបនីយំ ឥង្ឃយ្យា ធម្មំ ទេសេថាតិ ។ ន ភគិនិ កប្បតិ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ធម្មំ ទេសេតុន្តិ កុក្កុច្ចាយន្តា ន ទេសេសុំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន មហាបជាបតី គោតមី តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា មហាបជាបតី គោតមី ឯតទវោច កច្ចិ តេ គោតមិ ខមនីយំ កច្ចិ យាបនីយន្តិ ។ បុព្វេ មេ ភន្តេ ថេរា ភិក្ខូ អាគន្ត្វា ធម្មំ ទេសេន្តិ តេន មេ ផាសុ ហោតិ ឥទានិ បន ភគវតា បដិក្ខិត្តន្តិ កុក្កុច្ចាយន្តា ន ទេសេន្តិ តេន មេ ន ផាសុ ហោតីតិ ។ អថខោ ភគវា មហាបជាបតី គោតមី ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។



ប្រព្រឹត្តទៅបានស្រួលទេ បពិត្រលោកម្ចាស់ទាំងឡាយ ណ្ហើយចុះ សូមពួកលោកម្ចាស់សំដែងធម៌ឲ្យគាន ។ ភិក្ខុទាំងនោះនិយាយថា ម្នាលនាង កិរិយាដែលភិក្ខុចូលមកកាន់លំនៅរបស់ភិក្ខុនី ហើយសំដែងធម៌ដល់ភិក្ខុនី មិនគួរឡើយ ហើយមានសេចក្ដីសង្ស័យ (យ៉ាងនេះ) ក៏មិនហ៊ានសំដែងធម៌ឡើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរក្នុងវេលាព្រឹក ហើយទ្រង់ស្ដេចចូលទៅកាន់លំនៅរបស់ព្រះមហាបជាបតីគោតមី លុះដល់ហើយទ្រង់គង់លើអាសនៈដែលគេក្រាលទុក ។ ព្រះដ៏មានព្រះភាគទ្រង់គង់ហើយ ទ្រង់ត្រាស់សួរព្រះមហាបជាបតីគោតមីយ៉ាងនេះថា ព្រះនាងគោតមី សរីរយន្ត ព្រះនាងល្មមអត់ទ្រាំបានដែរឬ ល្មមឲ្យប្រព្រឹត្តទៅបានស្រួលដែរឬ ។ ព្រះនាងទូលតបថា បពិត្រព្រះអង្គដ៏ចំរើន កាលមុនភិក្ខុជាថេរៈទាំងឡាយ មកសំដែងធម៌ដល់ខ្ញុំព្រះអង្គ ហេតុនោះខ្ញុំព្រះអង្គមានសេចក្ដីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់ហើយ ព្រោះហេតុនោះ ភិក្ខុជាថេរៈទាំងឡាយ មានសេចក្ដីរាងក្រែង ទើបមិនហ៊ានសំដែង សេចក្ដីមិនសប្បាយមានដល់ខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ព្រះមហាបជាបតីគោតមីឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។

អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភិក្ខុនុបស្សយំ គន្ត្វា គិលានំ ភិក្ខុនឹ ឱវទិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនុបស្សយំ ឧបសង្កមិត្វា ភិក្ខុនិយោ ឱវទេយ្យ អញ្ញត្រ សមយា បាចិត្តិយំ តត្ថាយំ សមយោ គិលានា ហោតិ ភិក្ខុនី អយំ តត្ថ សមយោតិ ។

[៤៨] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុនុបស្សយោ[១] នាម យត្ថ ភិក្ខុនិយោ ឯករត្តម្បិ វសន្តិ ។ ឧបសង្កមិត្វាតិ តត្ថ គន្ត្វា ។ ភិក្ខុនិយោ នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ ឱវទេយ្យាតិ អដ្ឋហិ គរុធម្មេហិ ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ គិលានា នាម ភិក្ខុនី ន សក្កោតិ ឱវាទាយ វា សំវាសាយ វា គន្តុំ ។

១ ភិក្ខុនុបស្សយន្តិបិ បាឋោ ។



ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់សំដែងធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅភិក្ខុនីដែលមានជម្ងឺបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ចូលដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅពួកភិក្ខុនី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ឯសម័យក្នុងសិក្ខាបទនោះ គឺភិក្ខុនីមានជម្ងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។

(៤៨) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ភិក្ខុនីទាំងឡាយនៅក្នុងទីណា សូម្បីអស់រាត្រី ១ ទីនោះហៅថាទីនៅរបស់ភិក្ខុនី ។ ពាក្យថា ចូលដល់ គឺទៅក្នុងទីនោះ ។ ភិក្ខុនីដែលបានឧបសម្បទា ក្នុងសង្ឃទាំងពីរពួក ហៅថា ភិក្ខុនី ។ ពាក្យថា ប្រដៅ គឺភិក្ខុប្រដៅដោយគរុធម៌ ៨ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកលែងតែមានសម័យ ។ ភិក្ខុនីមិនអាចទៅទទួលឱវាទ ឬទៅនៅរួមសង្វាសបាន ហៅថាមានជម្ងឺ ។

[៩០] ឧបសម្បន្នាយ ឧបសម្បន្នសញ្ញី ភិក្ខុ ឧបស្សយំ ឧបសង្កមិត្វា អញ្ញត្រ សមយា ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ វេមតិកោ ភិក្ខុ ឧបស្សយំ ឧបសង្កមិត្វា អញ្ញត្រ សមយា ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នាយ អនុបសម្បន្នសញ្ញី ភិក្ខុ ឧបស្សយំ ឧបសង្កមិត្វា អញ្ញត្រ សមយា ឱវទតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញេន ធម្មេន ឱវទតិ អាបត្តិ ទុក្កដស្ស ។ ឯកតោ ឧបសម្បន្នំ ឱវទតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញី អនាបត្តិ ។



[៩០] ភិក្ខុសំគាល់ភិក្ខុនីដែលបានឧបសម្បទាហើយថាបានឧបសម្បទាមែន ហើយចូលទៅដល់លំនៅរបស់ភិក្ខុនីហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសង្ស័យក្នុងភិក្ខុនីដែលបានឧបសម្បទាហើយ ចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុនីឧបសម្បទាហើយ ភិក្ខុសំគាល់ថាមិនទាន់បានឧបសម្បទាទេ ហើយចូលទៅដល់លំនៅរបស់ភិក្ខុនី ហើយប្រដៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុប្រដៅភិក្ខុនីដោយធម៌ដទៃ (ក្រៅពីគរុធម៌) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រដៅភិក្ខុនីដែលបានឧបសម្បទាក្នុងសង្ឃតែមួយចំណែក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងស្រីមិនទាន់បានឧបសម្បទាថាបានឧបសម្បទាហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងស្រីដែលមិនទាន់បានឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងស្រីដែលមិនទាន់បានឧបសម្បទា ថាមិនទាន់ឧបសម្បទាមែន មិនត្រូវអាបត្តិឡើយ ។

បាចិត្តិយកណ្ឌេ ភិក្ខុនីវគ្គស្ស បឋមសិក្ខាបទស្ស អនាបត្តិវារោ

(៥៧) អនាបត្តិ ឧទ្ទេសំ ទេន្តោ បរិបុច្ឆំ ទេន្តោ ឱសារេហិ អយ្យាតិ វុច្ចមានោ ឱសារេតិ បញ្ហំ បុច្ឆតិ បញ្ហំ បុដ្ឋោ កថេតិ អញ្ញស្សត្ថាយ ភណន្តំ ភិក្ខុនិយោ សុណន្តិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។



បាចិត្តិយកណ្ឌ ភិក្ខុនីវគ្គ សិក្ខាបទទី ១ វារៈដែលមិនត្រូវអាបត្តិ

(៥៧) អាបត្តិមិនមានដល់ភិក្ខុដែលប្រដៅភិក្ខុនីក្នុងសម័យ ដល់ភិក្ខុដែលសំដែងបាឡីនៃឧទ្ទេសក្រែប៉ើ ដល់ភិក្ខុដែលសំដែងអដ្ឋកថានៃឧទ្ទេសក្រែប៉ើ ដល់ភិក្ខុដែលភិក្ខុនីពោលថា លោកម្ចាស់ចូរសូត្រ ទើបភិក្ខុក៏សូត្រ ដល់ភិក្ខុដែលភិក្ខុនីសួរប្រស្នា ហើយឆ្លើយទៅ ដល់ភិក្ខុដែលសំដែងធម៌ដើម្បីអ្នកដទៃ ហើយភិក្ខុនីចូលស្ដាប់ផង ដល់ភិក្ខុដែលប្រដៅចំពោះសិក្ខមានាផង ដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១ ចប់ ។

## ចតុត្ថសិក្ខាបទំ

[៩៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តា លាភិនោ ហោន្តិ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារានំ ។ ឆព្ពគ្គិយា ភិក្ខូ ឯវំ វទេន្តិ[១] ន ពហុកតា ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តិ អាមិសហេតុ ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ឯវំ វក្ខន្តិ ន ពហុកតា ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តិ អាមិសហេតុ ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ឯវំ វទេថ ន ពហុកតា ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តិ អាមិសហេតុ ថេរា ភិក្ខូ ភិក្ខុនិយោ

១ ម. ឆ. វទន្តិ ។

## សិក្ខាបទទី ៤

[៩៦] សម័យនោះ ព្រះសម្ពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី តែងបានទូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យរបស់មនុស្សឈឺ ។ ពួកឆព្វគ្គិយភិក្ខុ និយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយ មិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីទេឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ថ្វីឡើយ ពួកឆព្វគ្គិយភិក្ខុមកនិយាយយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយមិនសូវយកចិត្តទុកដាក់នឹងប្រដៅពួកភិក្ខុនីទេឡើយ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយនិយាយគ្នាយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយមិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីប៉ុន្មានទេ ភិក្ខុជាថេរៈទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ពិតមែនឬ ។

ឱវទន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ឯវំ វក្ខថ ន ពហុកតា ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តិ អាមិសហេតុ ថេរា ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឯវំ វទេយ្យ អាមិសហេតុ ភិក្ខូ ភិក្ខុនិយោ ឱវទន្តីតិ បាចិត្តិយន្តិ ។

(៩៣) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អាមិសហេតូតិ ចីវរហេតុ បិណ្ឌបាតហេតុ សេនាសន-ហេតុ គិលានបច្ចយភេសជ្ជបរិក្ខារហេតុ សក្ការហេតុ គរុការហេតុ មាននហេតុ វន្ទនហេតុ បូជនហេតុ ។

(៩៤) ឯវំ វទេយ្យាតិ ឧបសម្បន្នំ សង្ឃេន សម្មតំ ភិក្ខុនោវាទកំ អវណ្ណំ កត្តុកាមោ អយសំ កត្តុ-កាមោ មង្កុកត្តុកាមោ ឯវំ វទតិ ចីវរហេតុ



ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ ក៏ម្តេចឡើយ ពួកអ្នកឯងមកពោលយ៉ាងនេះថា ភិក្ខុជាថេរៈទាំងឡាយមិនសូវយកចិត្តទុកដាក់នឹងប្រៀនប្រដៅពួកភិក្ខុនីឡើយ ភិក្ខុជាថេរៈទាំងឡាយ ប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស នែមោឃបុរសទាំងឡាយ អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់បុគ្គលទាំងឡាយដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំ-ដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយពោលយ៉ាងនេះថា ភិក្ខុទាំងឡាយប្រដៅពួកភិក្ខុនី ព្រោះហេតុតែអាមិស ត្រូវអាបត្តិបាចិត្តិយ ។

(៩៣) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខា-បទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ព្រោះហេតុតែអាមិស សេចក្តីថា ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ឬគ្រឿងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន ការថ្វាយបង្គំ និងការបូជា ។

(៩៤) ពាក្យថា ពោលយ៉ាងនេះ សេចក្តីថា ភិក្ខុណាប្រាថ្នាដើម្បីនឹងធ្វើនូវពាក្យតិះដៀល ប្រាថ្នាដើម្បីនឹងធ្វើបង្អាប់យស ប្រាថ្នាដើម្បីនឹងធ្វើនូវសេចក្តីបង្អាប់បង្អោន ចំពោះឧបសម្បន្នដែលសង្ឃសន្មត

បិណ្ឌបាតហេតុ សេនាសនហេតុ គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សក្ការហេតុ គរុការហេតុ មាននហេតុ វន្ទនហេតុ បូជនហេតុ ឱវទតីតិ ភណតិ អាបត្តិ បាចិត្តិយស្ស ។

(៥៥) ធម្មកម្មេ ធម្មកម្មសញ្ញី ឯវំ វទតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ ឯវំ វទតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី ឯវំ វទតិ អាបត្តិ បាចិត្តិយស្ស ។

(៥៦) ឧបសម្បន្នំ សង្ឃេន អសម្មតំ ភិក្ខុនោវាទកំ អវណ្ណំ កត្តុកាមោ អយសំ កត្តុកាមោ មង្កុកត្តុកាមោ ឯវំ វទតិ ចីវរហេតុ បិណ្ឌបាតហេតុ សេនាសនហេតុ គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សក្ការហេតុ គរុការហេតុ មាននហេតុ វន្ទនហេតុ បូជនហេតុ ឱវទតីតិ ភណតិ អាបត្តិ ទុក្កដស្ស ។

(៥៧) អនុបសម្បន្នំ សង្ឃេន សម្មតំ វា អសម្មតំ វា ភិក្ខុនោវាទកំ អវណ្ណំ កត្តុកាមោ អយសំ កត្តុកាមោ មង្កុកត្តុកាមោ ឯវំ វទតិ ចីវរហេតុ



ឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សឈឺ ព្រោះនឹងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន ការថ្វាយបង្គំ និងការបូជា (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

(៥៥) កម្មជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌មែន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុសង្ស័យ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ កម្មជាធម៌ ភិក្ខុសំគាល់ថា កម្មមិនមែនជាធម៌វិញ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។

(៥៦) ភិក្ខុណា ប្រាថ្នាដើម្បីធ្វើនូវពាក្យជាទៀល ប្រាថ្នាដើម្បីធ្វើបង្អាប់យស ប្រាថ្នាដើម្បីធ្វើនូវសេចក្តីបង្អាប់បង្អោនចំពោះឧបសម្បន្នដែលសង្ឃមិនបានសន្មតឲ្យជាអ្នកប្រដៅភិក្ខុនី ហើយពោលយ៉ាងនេះ គឺនិយាយថា ភិក្ខុប្រដៅភិក្ខុនី ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ ភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ព្រោះនឹងសក្ការៈ សេចក្តីគោរព សេចក្តីរាប់អាន ការថ្វាយបង្គំ និងការបូជា (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។

(៥៧) ភិក្ខុណា ប្រាថ្នាដើម្បីធ្វើនូវពាក្យជាទៀល ប្រាថ្នាដើម្បីធ្វើបង្អាប់យស ប្រាថ្នាដើម្បីធ្វើនូវសេចក្តីបង្អាប់បង្អោនចំពោះអនុបសម្បន្ន បុគ្គលដែលសង្ឃសន្មតក្តី មិនបានសន្មតក្តី ឲ្យជាអ្នកប្រដៅភិក្ខុនី

បិណ្ឌបាតហេតុ សេនាសនហេតុ គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សក្ការហេតុ គរុការហេតុ មាននហេតុ វន្ទនហេតុ បូជនហេតុ ខីយធម្មំ ភណតិ អាបត្តិ ទុក្កដស្ស ។

(៤៨) អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកា អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

(៤៩) អនាបត្តិ បកតិយា ចីវរហេតុ បិណ្ឌបាតហេតុ សេនាសនហេតុ គិលានប្បច្ចយភេសជ្ជបរិក្ខារហេតុ សក្ការហេតុ គរុការហេតុ មាននហេតុ វន្ទនហេតុ បូជនហេតុ ខីយធម្មំ ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។



ហើយពោលយកទោសនេះ គឺពោលថា ភិក្ខុប្រព្រឹត្តិ ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សឈឺ ព្រោះសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន ការយកថ្វាយបង្គំ និងការយកបូជា (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។

(៤៨) កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថាកម្មជាធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនមែនជាធម៌ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនមែនជាធម៌ ភិក្ខុសំគាល់ថាកម្មមិនមែនជាធម៌ ត្រូវអាបត្តិទុក្កដ ។

(៤៩) អាបត្តិមិនមានដល់ភិក្ខុដែលពោលចំពោះភិក្ខុសង្ឃដែលជាអ្នកប្រព្រឹត្តិ ព្រោះហេតុតែចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ ជាបច្ច័យដល់មនុស្សឈឺ ព្រោះសក្ការៈ សេចក្ដីគោរព សេចក្ដីរាប់អាន ការយកថ្វាយបង្គំ និងការយកបូជាតាមប្រក្រតី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

## បញ្ចមសិក្ខាបទំ

[៦០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សាវត្ថិយំ អញ្ញតរិស្សា វិសិខាយ បិណ្ឌាយ ចរតិ ។ អញ្ញតរាបិ ភិក្ខុនី តស្សា វិសិខាយ បិណ្ឌាយ ចរតិ ។ អថខោ សោ ភិក្ខុ តំ ភិក្ខុនឹ ឯតទវោច គច្ឆ ភគិនិ អមុកស្មឹ ឱកាសេ ភិក្ខា ទីយតីតិ ។ សាបិ ឯវមាហ គច្ឆ អយ្យ អមុកស្មឹ ឱកាសេ ភិក្ខា ទីយតីតិ ។ តេ អភិណ្ហទស្សនេន សន្ទិដ្ឋា អហេសុំ ។ តេន ខោ បន សមយេន សង្ឃស្ស ចីវរំ ភាជីយតិ ។ អថខោ សា ភិក្ខុនី ឱវាទំ គន្ត្វា យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ តំ ភិក្ខុនឹ សោ ភិក្ខុ ឯតទវោច អយំ មេ ភគិនិ ចីវរបដិវឹសោ សាទិយិស្សសីតិ ។ អាម អយ្យ

## សិក្ខាបទទី ៥

[៦០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូបត្រាច់ទៅបិណ្ឌបាត តាមផ្លូវច្រកមួយ ក្នុងក្រុងសាវត្ថី ។ មានភិក្ខុនីមួយរូបទៀតក៏ត្រាច់ទៅបិណ្ឌបាតតាមផ្លូវច្រកនោះដែរ ។ ទើបភិក្ខុនោះនិយាយនឹងភិក្ខុនីនោះយ៉ាងនេះថា ប្អូនស្រី នាងចូរទៅក្នុងឱកាសឯណោះ គេប្រគេនភិក្ខា ។ ឯភិក្ខុនីនោះក៏និយាយយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់ចូរទៅក្នុងឱកាសឯណោះចុះ គេប្រគេនចង្ហាន់ ។ ភិក្ខុនីនិងភិក្ខុនោះបានស្គាល់គ្នា ព្រោះបានឃើញគ្នាញឹកញយ ។ គ្រានោះឯង សង្ឃកំពុងចែកចីវរគ្នា ។ លំដាប់នោះ ភិក្ខុនីនោះកាលទៅទទួលឱវាទក៏ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយថ្វាយបង្គំភិក្ខុនោះហើយបានឈរនៅក្នុងទីដ៏សមគួរ ។ ភិក្ខុនោះបាននិយាយនឹងភិក្ខុនីដែលឈរនៅក្នុងទីដ៏សមគួរនោះយ៉ាងនេះថា ប្អូនស្រី ចំណែកចីវរនេះរបស់យើងនាងនឹងត្រេកអរដែរឬទេ ។ ភិក្ខុនីនោះឆ្លើយថា ករុណាលោកម្ចាស់

ទុព្វលចីវរម្ហីតិ ។ អថខោ សោ ភិក្ខុ តស្សា ភិក្ខុនិយា ចីវរំ អទាសិ ។ សោបិ ខោ ភិក្ខុ ទុព្វលចីវរោ ហោតិ ។ ភិក្ខូ តំ ភិក្ខុំ ឯតទវោចុំ ករោហិទានិ តេ អាវុសោ ចីវរន្តិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំហិ នាម ភិក្ខុ ភិក្ខុនិយា ចីវរំ ទស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ ភិក្ខុនិយា ចីវរំ អទាសីតិ ។ សច្ចំ ភគវាតិ ។ ញាតិកា តេ ភិក្ខុ អញ្ញាតិកាតិ ។ អញ្ញាតិកា ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ បតិរូបំ វា អប្បតិរូបំ វា សន្តំ វា អសន្តំ វា កថំ ហិ នាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ ទស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ



ខ្ញុំករុណាមានចីវរចាស់ហើយ ។ ភិក្ខុនោះឲ្យចីវរដល់ភិក្ខុនីនោះ ។ ចំណែកភិក្ខុនោះជាអ្នកមានចីវរទុព្វលភាព ។ ភិក្ខុទាំងឡាយបាននិយាយនឹងភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរធ្វើចីវររបស់អ្នកក្នុងកាលឥឡូវនេះចុះ ។ ភិក្ខុនោះក្រាបទូលសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនសមបើនឹងឲ្យចីវរដល់ភិក្ខុនីទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងបានឲ្យចីវរដល់ភិក្ខុនី ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលតបថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ភិក្ខុនីនោះជាញាតិរបស់អ្នកឯងឬមិនមែនញាតិទេ ។ ភិក្ខុនោះទូលថា សូមទ្រង់មេត្តាប្រោស ភិក្ខុនីនោះមិនជាញាតិទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែ៎មោឃបុរស បុរសមិនមែនជាញាតិ រមែងមិនដឹងនូវកម្មដ៏សមគួរឬមិនសមគួរ ល្អក្តីឬមិនល្អក្តីរបស់ស្រីដែលមិនមែនជាញាតិទេ នែ៎មោឃបុរស អ្នកឯងមិនគួរនឹងឲ្យចីវរដល់ភិក្ខុនីមិនមែនញាតិទេ នែ៎មោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកបុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យចីវរ

ភិក្ខុនិយា ចីវរំ ទទេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ
ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៦១) តេន ខោ បន សមយេន ភិក្ខូ កុក្កុ-
ច្ចាយន្តា ភិក្ខុនីនំ បារិវត្តកំ ចីវរំ ន ទេន្តិ ។ ភិក្ខុនិយោ
ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយ្យា
អម្ហាកំ បារិវត្តកំ ចីវរំ ន ទស្សន្តីតិ ។ អស្សោសុំ
ខោ ភិក្ខូ តាសំ ភិក្ខុនីនំ ឧជ្ឈាយន្តីនំ ខីយន្តីនំ
វិបាចេន្តីនំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ
អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ
បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុ-
ជានាមិ ភិក្ខវេ បញ្ចន្នំ បារិវត្តកំ ទាតុំ ភិក្ខុស្ស
ភិក្ខុនិយា សិក្ខមានាយ សាមណេរស្ស សាមណេ-
រិយា អនុជានាមិ ភិក្ខវេ ឥមេសំ បញ្ចន្នំ បារិវត្តកំ
ទាតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ
យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ ទទេយ្យ
អញ្ញត្រ បារិវត្តកា បាចិត្តិយន្តិ ។



ដល់ភិក្ខុនីដែលមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ
ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(៦១) សម័យនោះឯង ភិក្ខុទាំងឡាយសង្ស័យមិនហ៊ានផ្លាស់ប្តូរ
ចីវរនឹងភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីទាំងឡាយពោលទោស តិះដៀល បន្តុះ
បង្អាប់ថា លោកម្ចាស់ទាំងឡាយមិនសមបើនឹងមិនហ៊ានផ្លាស់ប្តូរចីវរនឹងពួក
យើងសោះ ។ ភិក្ខុទាំងឡាយបានឮពួកភិក្ខុនីនោះពោលទោស តិះដៀល
បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងនោះនាំគ្នាក្រាបទូលសេចក្តីនុ៎ះចំពោះព្រះ
ដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ
ទ្រង់ធ្វើនូវធម្មីកថា ហើយទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុ
ទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្លាស់ប្តូរចីវរនឹងសហធម្មិកទាំង ៥ គឺ ភិក្ខុ
១ ភិក្ខុនី ១ សិក្ខមានា ១ សាមណេរ ១ សាមណេរី ១ ម្នាលភិក្ខុទាំង
ឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុផ្លាស់ប្តូរចីវរនឹងសហធម្មិកទាំង ៥ នេះបាន
ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាង
នេះថា ភិក្ខុណាមួយឲ្យចីវរដល់ភិក្ខុនីមិនមែនជាញាតិ ត្រូវអាបត្តិបាចិត្តិយ
វៀរតែផ្លាស់ប្តូរគ្នា ។

(៦២) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធា[១] ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ[២] ។ អញ្ញត្រ បារិវត្តកាតិ ឋបេត្វា បារិវត្តកំ ទេតិ អាបត្តិ បាចិត្តិយស្ស ។

(៦៣) អញ្ញាតិកាយ អញ្ញាតិកសញ្ញី ចីវរំ ទេតិ អញ្ញត្រ បារិវត្តកា អាបត្តិ បាចិត្តិយស្ស ។ អញ្ញាតិកាយ វេមតិកោ ចីវរំ ទេតិ អញ្ញត្រ បារិវត្តកា អាបត្តិ បាចិត្តិយស្ស ។ អញ្ញាតិកាយ ញាតិកសញ្ញី ចីវរំ ទេតិ អញ្ញត្រ បារិវត្តកា អាបត្តិ បាចិត្តិយស្ស ។ ឯកតោ ឧបសម្បន្នាយ ចីវរំ ទេតិ អញ្ញត្រ បារិវត្តកា អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិកសញ្ញី

១ អសម្ពន្ធាតិបិ បាឋោ ទិស្សតិ ។ ២ ម. វិកប្បនុបគបច្ឆិមំ ។





(៦២) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ភិក្ខុនីដែលមិនបានសម្ពន្ធជាប់ ទៅក្នុងគល់គឺចំណែកខាងមាតាក្តី ឬគឺចំណែកខាងបិតាក្តី ដរាបដល់ ត្រឹមជីដូនជីតាជាគំរប់ ៧ ហៅថាមិនមែនជាញាតិ ។ ស្រីដែលបានឧបសម្បទាហើយក្នុងសង្ឃទាំងពីរចំណែក ហៅថា ភិក្ខុនី ។ បណ្តាចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតគួរដល់វិកប្បបាន ហៅថា ចីវរ ។ ពាក្យថា វៀរលែងតែដូរផ្លាស់ សេចក្តីថា ភិក្ខុឲ្យ (ចីវរដល់ភិក្ខុនីមិនមែនញាតិ) ត្រូវអាបត្តិបាចិត្តិយ លើកលែងតែដូរផ្លាស់ ។

(៦៣) ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែដូរផ្លាស់ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសង្ស័យ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែដូរផ្លាស់ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថាជាញាតិ ហើយឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែដូរផ្លាស់ ។ ភិក្ខុឲ្យចីវរដល់ភិក្ខុនីដែលបានឧបសម្បទាអំពីសង្ឃមួយចំណែក ត្រូវអាបត្តិទុក្កដ វៀរលែងតែដូរផ្លាស់ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ

អាបត្តិ ទុក្កដស្ស ។ ញាតិកាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ ញាតិកសញ្ញី អនាបត្តិ ។

[៦៦] អនាបត្តិ ញាតិកាយ បារិវត្តកំ បរិត្តេន វា វិបុលំ វិបុលេន វា បរិត្តំ ភិក្ខុនី វិស្សាសំ គណ្ហាតិ តាវកាលិកំ គណ្ហាតិ ឋបេត្វា ចីវរំ អញ្ញំ បរិក្ខារំ គណ្ហាតិ សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។



ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិទេ ។

(៦៦) អាបត្តិមិនមាន ដល់ភិក្ខុដែលទទួលចីវរអំពីភិក្ខុនីជាញាតិ ដល់ភិក្ខុដែលដូរផ្លាស់ចីវរគ្នា ដល់ភិក្ខុដែលដូរយកចីវរមានដំឡៃច្រើនដោយចីវរមានដំឡៃតិច ឬចីវរមានដំឡៃតិចដោយចីវរមានដំឡៃច្រើន ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវររបស់ខ្លួនដោយសេចក្តីស្និទ្ធស្នាល ដល់ភិក្ខុដែលភិក្ខុនីកាន់យកចីវរជារបស់ខ្ចី ដល់ភិក្ខុដែលទទួលបរិក្ខារដទៃវៀរលែងតែចីវរ ដល់ភិក្ខុដែលទទួលចីវរដល់សិក្ខមានា ឬដល់សាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់ ។

# ឆដ្ឋសិក្ខាបទំ

[៦៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយី បដ្ឋោ ហោតិ ចីវរកម្មំ កាតុំ ។ អញ្ញតរា ភិក្ខុនី យេនាយស្មា ឧទាយី តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ ឯតទវោច សាធុ មេ ភន្តេ អយ្យោ ចីវរំ សិព្វេតូតិ ។ អថខោ អាយស្មា ឧទាយី តស្សា ភិក្ខុនិយា ចីវរំ សិព្វេត្វា សុរត្តំ សុបរិកម្មកតំ កត្វា មជ្ឈេ បដិភាណចិត្តំ វុដ្ឋាបេត្វា សំហរិត្វា និក្ខិបិ ។ អថខោ សា ភិក្ខុនី យេនាយស្មា ឧទាយី តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧទាយឹ ឯតទវោច កហំ[១] ភន្តេ ចីវរន្តិ ។ ហន្ទ ភគិនិ ឥមំ ចីវរំ យថាសំហដំ ហរិត្វា និក្ខិបិត្វា យទា ភិក្ខុនីសង្ឃោ ឱវាទំ អាគច្ឆតិ តទា ឥមំ ចីវរំ បារុបិត្វា ភិក្ខុនីសង្ឃស្ស បិដ្ឋិតោ បិដ្ឋិតោ អាគច្ឆាហីតិ ។ អថខោ សា ភិក្ខុនី តំ ចីវរំ

១ កតំ ចេតិ បាឋោ ។ ម. ឆ. កហន្នុ ។

# សិក្ខាបទទី ៦

[៦៩] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ព្រះឧទាយិ៍ដ៏មានអាយុជាអ្នកប្រសប់ធ្វើចីវរកម្ម ។ មានភិក្ខុនីមួយរូបចូលទៅកាន់ទីដែលព្រះឧទាយិ៍ដ៏មានអាយុនៅ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះឧទាយិ៍ដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់ដេរចីវរខ្ញុំផង ។ គ្រានោះ ព្រះឧទាយិ៍ដ៏មានអាយុក៏ដេរចីវរ ហើយធ្វើឲ្យដែលគេគក់ជ្រលក់ល្អប្រពៃប្រកបរូប[១]ត្រង់កណ្ដាលចីវរ ស្រេចហើយបត់ទុកឲ្យភិក្ខុនីនោះ ។ គ្រានោះ ភិក្ខុនីនោះទៅកាន់ទីនៅព្រះឧទាយិ៍ដ៏មានអាយុ លុះទៅដល់ហើយបាននិយាយនឹងព្រះឧទាយិ៍ដ៏មានអាយុយ៉ាងនេះថា បពិត្រលោកម្ចាស់ ចីវររបស់លោកម្ចាស់នោះនៅឯណាទៅ ។ ព្រះឧទាយិ៍ឆ្លើយថា ម្នាលប្អូនស្រី ហ្ន៎ នាងចូរនាំយកចីវរនេះទៅតាមដែលបត់ហើយទុក កាល-ណាភិក្ខុនីសង្ឃមកទទួលឱវាទ ចូរដណ្ដប់ចីវរនេះដើរទៅតាមក្រោយ ។

១ អដ្ឋកថាថា រូបភាពបុរសស្ត្រី ធ្វើសង្វាសគ្នា មានទោឃាយណាយដោយវត្ថុណាមួយ ការដេរជិតរបស់ខ្លួន ត្រង់កណ្ដាលចីវរ ។

យថាសំហដំ ហរិត្វា និក្ខិបិត្វា យទា ភិក្ខុនីសង្ឃោ ឱវាទំ អាគច្ឆន្តិ តទា តំ ចីវរំ បារុបិត្វា ភិក្ខុនីសង្ឃស្ស បិដ្ឋិតោ បិដ្ឋិតោ អាគច្ឆតិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ យាវឆិន្និកា ឥមា ភិក្ខុនិយោ ធុត្តិកា អហិរិកាយោ យត្រ ហិ នាម ចីវរេ បដិភាណចិត្តំ វុដ្ឋាបេស្សន្តីតិ ។ ភិក្ខុនិយោ ឯវមាហំសុ កស្សិទំ កម្មន្តិ ។ អយ្យស្ស ឧទាយិស្សាតិ ។ យេបិ តេ ឆិន្នកា ធុត្តកា អហិរិកា តេសំបិ ឯវរូបំ ន សោភេយ្យ កឹ បន អយ្យស្ស ឧទាយិស្សាតិ ។ អថខោ តា ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយិ ភិក្ខុនិយា ចីវរំ សិព្វេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧទាយិ ភិក្ខុនិយា ចីវរំ សិព្វេសីតិ ។ សច្ចំ ភគវាតិ ។ ញាតិកា



ភិក្ខុនីសង្ឃ ក្នុងកាលណោះ ។ លំដាប់នោះ ភិក្ខុនីនោះនាំយកចីវរនោះទៅទាំងផ្នត់ហើយទុក កាលណាភិក្ខុនីសង្ឃមកទទួលឱវាទ ក៏ដណ្ដប់ចីវរនោះដើរទៅតាមក្រោយ ។ ភិក្ខុនីសង្ឃ ក្នុងកាលណោះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនីអម្បាលនេះជាស្រីឆ្នាសឥតកោតញញើត ជាស្រីអ្នកលេង គ្មានអៀនខ្មាស មិនសមបើនឹងធ្វើគំនូរក្នុងចីវរសោះ ។ ភិក្ខុនីទាំងឡាយបាននិយាយសួរគ្នាយ៉ាងនេះថា នេះជាការធ្វើរបស់អ្នកណា ។ ភិក្ខុនីទាំងឡាយឆ្លើយថា នេះជាការធ្វើរបស់លោកម្ចាស់ឧទាយិ ។ ពួកភិក្ខុនីនិយាយគ្នាថា ជនទាំងឡាយណា ជាអ្នកគ្មានសេចក្ដីកោតញញើត ជាអ្នកលេង ជាអ្នកគ្មានសេចក្ដីអៀនខ្មាស កម្មមានសភាពយ៉ាងនេះក៏គង់មិនល្អដល់ជនទាំងឡាយនោះ នឹងពោលទៅថ្វីដល់លោកម្ចាស់ឧទាយិ ។ ពួកភិក្ខុនីនោះនាំគ្នាប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុមិនគួរនឹងដេរចីវរដល់ភិក្ខុនីសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧទាយិ ឮថាអ្នកឯងដេរចីវរឲ្យភិក្ខុនី ពិតមែនឬ ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា នែឧទាយិ ភិក្ខុនីនោះជាញាតិ

តេ ឧទាយិ អញ្ញាតិកាតិ ។ អញ្ញាតិកា ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា បាសាទិកំ វា អប្បាសាទិកំ វា តត្ថ នាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្វិស្សសិ នេតំ មោឃបុរិស អប្ប-សន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា ចីវរំ សិព្វេយ្យ វា សិព្វា-បេយ្យ វា បាចិត្តិយន្តិ ។

(៦៦) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធា[១] ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ ។ សិព្វេយ្យាតិ សយំ សិព្វតិ អារាបថេ អារាបថេ អាបត្តិ

១ អសម្ពុទ្ធាតិបិ បាឋោ ទិស្សតិ ។



របស់អ្នកឯង ឬមិនមែនជាញាតិទេ ។ ឧទាយិភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស មិនមែនជាញាតិទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា នែមោឃបុរស ប្រុសដែលមិនមែនជាញាតិ រមែងមិនស្គាល់កម្មដ៏សមគួរ មិនសមគួរ កម្មនាំឲ្យជ្រះថ្លា មិននាំឲ្យជ្រះថ្លា របស់ស្ត្រីដែលមិនមែនជាញាតិទេ នែមោឃបុរស អ្នកឯងមិនសមគួរនឹងដេរចីវរឲ្យភិក្ខុនីមិនមែនញាតិទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិននាំឲ្យជ្រះថ្លាដល់បុគ្គលដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរឲ្យភិក្ខុនីមិនមែនញាតិ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

[៦៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចពោលក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ភិក្ខុនីដែលមិនបានជាប់ទាក់ទងតាមអំពីខាងមាតាក្តី អំពីខាងបិតាក្តី ដរាបអំពីតួជីដូនជីតាជាន់ទី ៧ ហៅថាមិនមែនញាតិ ។ ស្រីដែលបានឧបសម្បទាហើយក្នុងសង្ឃពីរចំណែក ហៅថា ភិក្ខុនី ។ បណ្តាចីវរ ៦ យ៉ាងចីវរណាមួយ យ៉ាងតូចបំផុតល្មមវិកប្បបាន ហៅថា ចីវរ ។ ពាក្យថា ដេរឯង គឺភិក្ខុដេរដោយខ្លួនឯង

បាចិត្តិយស្ស ។ សិព្វាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ បាចិត្តិយស្ស ។ សកឹ អាណត្តោ ពហុកំបិ សិព្វេតិ អាបត្តិ បាចិត្តិយស្ស ។

(៦៧) អញ្ញាតិកាយ អញ្ញាតិកសញ្ញី ចីវរំ សិព្វេតិ វា សិព្វាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ អញ្ញាតិកាយ វេមតិកោ ចីវរំ សិព្វេតិ វា សិព្វាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ អញ្ញាតិកាយ ញាតិកសញ្ញី ចីវរំ សិព្វេតិ វា សិព្វាបេតិ វា អាបត្តិ បាចិត្តិយស្ស ។ ឯកតោឧបសម្បន្នាយ ចីវរំ សិព្វេតិ វា សិព្វាបេតិ វា អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតិកាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ ញាតិកសញ្ញី អនាបត្តិ ។

(៦៨) អនាបត្តិ ញាតិកាយ ចីវរំ ឋបេត្វា អញ្ញំ បរិក្ខារំ សិព្វេតិ វា សិព្វាបេតិ វា សិក្ខមានាយ សាមណេរិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។



ត្រូវអាបត្តិបាចិត្តិយរាល់ៗម្ជុល ។ ពាក្យថា ប្រើគេឲ្យដេរ គឺភិក្ខុបង្គាប់អ្នកដទៃឲ្យដេរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់តែម្តង អ្នកទទួលបង្គាប់ដេរច្រើនដង ត្រូវអាបត្តិបាចិត្តិយ(តែមួយ) ។

(៦៧) ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថា មិនមែនញាតិមែន ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុមានសេចក្តីសង្ស័យ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីមិនមែនញាតិ ភិក្ខុសំគាល់ថាជាញាតិ ហើយដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដេរឯងក្តី ប្រើគេឲ្យដេរក្តីនូវចីវរដើម្បីភិក្ខុនីដែលបានឧបសម្បទាអំពីសង្ឃតែមួយពួក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិមែន មិនត្រូវអាបត្តិឡើយ ។

(៦៨) អាបត្តិមិនមានដល់ភិក្ខុដែលដេរចីវរដល់ភិក្ខុនីជាញាតិ ដល់ភិក្ខុដែលដេរឯង ឬប្រើគេឲ្យដេរនូវបរិក្ខារដទៃក្រៅពីចីវរ (ឲ្យភិក្ខុនី) ឲ្យសិក្ខមានា ឲ្យសាមណេរី ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់ ។

# សត្តមសិក្ខាបទំ

[៦៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភិក្ខុនីហិ សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ យថេវ មយំ សប្បជាបតិកា[១] អាហិណ្ឌាម ឯវមេវិមេ សមណា សក្យបុត្តិយា ភិក្ខុនីហិ សទ្ធិំ អាហិណ្ឌន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ភិក្ខុនីហិ សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជិស្សន្តីតិ ។បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុនីហិ សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម

១ ម. សបជាបតិកា ។

# សិក្ខាបទទី ៧

[៦៩] សម័យនោះឯង ព្រះសម្មាសម្ពុទ្ធទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងទាំងឡាយមានប្រពន្ធដើរទៅយ៉ាងណា សមណៈទាំងឡាយនេះ ជាកូនចៅព្រះពុទ្ធជាសក្យបុត្រដើរទៅមួយអន្លើដោយភិក្ខុនីទាំងឡាយ យ៉ាងនោះឯង ។ ភិក្ខុទាំងឡាយបានឮពាក្យមនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកឆព្វគ្គិយភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នាទេ ។បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធដ៏ជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងបបួលភិក្ខុនី

តុម្ហេ មោឃបុរិសា ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកទ្ធា-
នមគ្គំ បដិបជ្ជិស្សថ នេតំ មោឃបុរិសា អប្បសន្នាន-
ំ បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ
សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនិយា
សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ អន្តមសោ
គាមន្តរម្បិ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ
សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៧០) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ច
ភិក្ខុនិយោ ច សាកេតា សាវត្ថឹ អទ្ធានមគ្គប្បដិបន្នា
ហោន្តិ ។ អថខោ តា ភិក្ខុនិយោ តេ ភិក្ខូ ឯតទវោ-
ចុំ មយម្បិ អយ្យេហិ សទ្ធឹ គមិស្សាមាតិ ។ ន
កប្បតិ ភគិនី ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកទ្ធា-
នមគ្គំ បដិបជ្ជិតុំ តុម្ហេ វា បឋមំ គច្ឆថ មយំ វា
គមិស្សាមាតិ ។ អយ្យា ភន្ត អគ្គបុរិសា អយ្យា
វ បឋមំ គច្ឆន្តូតិ ។ អថខោ តាសំ ភិក្ខុនីនំ
បច្ឆា គច្ឆន្តីនំ អន្តរាមគ្គេ ចោរា អច្ឆិន្ទឹសុ ចេវ



ដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការ
នេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាល
ភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា
ភិក្ខុណាមួយបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា យ៉ាងហោច
ទៅសូម្បីកាន់ទីជាចន្លោះនៃស្រុក១ (ភិក្ខុនោះ)ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខា-
បទនេះព្រះដ៏មានព្រះភាគបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(៧០) សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប ដើរទៅ
កាន់ផ្លូវឆ្ងាយអំពីក្រុងសាកេតទៅកាន់ក្រុងសាវត្ថី ។ គ្រានោះ ភិក្ខុ-
នីទាំងឡាយនោះ ឃើញពួកភិក្ខុនោះហើយ បានពោលពាក្យនេះថា
យើងទាំងឡាយនឹងទៅជាមួយនឹងលោកម្ចាស់ទាំងឡាយ ។ ភិក្ខុទាំង
នោះឆ្លើយថា ម្នាលនាង ការដែលភិក្ខុបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយ
មួយជាមួយគ្នាមិនគួរទេ នាងទាំងឡាយទៅមុនចុះ យើងទាំងឡាយ
នឹងទៅមុន ។ ភិក្ខុនីទាំងនោះឆ្លើយថា បពិត្រលោកដ៏ចំរើន លោក
ម្ចាស់ទាំងឡាយជាបុរសដ៏ប្រសើរ គួរតែលោកម្ចាស់ទាំងឡាយនិមន្តទៅ
មុន ។ កាលភិក្ខុនីទាំងនោះដើរទៅជាខាងក្រោយនៃភិក្ខុទាំងឡាយដល់
ពាក់កណ្តាលផ្លូវ ចោរទាំងឡាយក៏ដណ្តើមយក (បាត្រចីវរ) ផង

ទុស្សេសុញ្ច[1] ។ អថ ខោ តា ភិក្ខុនិយោ សាវត្ថិំ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថ ខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ បករណេ ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ សត្ថគមនីយេ មគ្គេ សាសង្កសម្មតេ សប្បដិភយេ ភិក្ខុនិយា សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ អន្តមសោ គាមន្តរម្បិ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ សត្ថគមនីយោ ហោតិ មគ្គោ សាសង្កសម្មតោ សប្បដិភយោ អយំ តត្ថ សមយោតិ ។

(៩០) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មិំ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុនីតិ ឧភតោសង្ឃេ ឧបសម្បន្នា ។

១ ម. ម. អជ្ជុនីសុ ច ទុស្សេសុ ច ។





ប្រទុស្តថប៍ (គឺរំលោភធ្វើសេពមេថុន) ក្នុងកាលនោះឯង ។ ទើបភិក្ខុនីទាំងនោះទៅដល់ក្រុងសាវត្ថី ក៏ប្រាប់សេចក្ដីនុ៎ះដល់ពួកភិក្ខុនី ។ ពួកភិក្ខុនីប្រាប់សេចក្ដីនុ៎ះដល់ពួកភិក្ខុ ។ ពួកភិក្ខុក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យពួកភិក្ខុទាំងឡាយ បបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយជាមួយគ្នា ក្នុងផ្លូវដែលគួរទៅដោយមានគ្នីគ្នាជាពួក ដែលគេសន្មតថា ប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបបួលភិក្ខុនីដើរទៅកាន់ផ្លូវឆ្ងាយមួយជាមួយគ្នា ដោយហោចទៅ សូម្បីទៅកាន់ចន្លោះស្រុកនៃស្រុក ១ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺផ្លូវដែលគួរទៅដោយមានគ្នីគ្នាជាពួក ១ ដែលគេសន្មតថាប្រកបដោយសេចក្ដីរង្កៀស ១ ដែលប្រកបដោយភ័យចំពោះមុខ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

(៩១) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទា

សទ្ធិន្តិ ឯកតោ ។ សំវិធាយាតិ គច្ឆាម ភគិនិ គច្ឆាម អយ្យ គច្ឆាម អយ្យ គច្ឆាម ភគិនិ អជ្ជ វា ហិយ្យោ វា បរេ វា គច្ឆាមាតិ សំវិទហតិ អាបត្តិ ទុក្កដស្ស ។ អន្តមសោ គាមន្តរម្បីតិ កុក្កុដសម្បាតេ គាមេ គាមន្តរេ[១] អាបត្តិ បាចិត្តិយស្ស ។ អគាមកេ អរញ្ញេ អឌ្ឍយោជនេ អឌ្ឍយោជនេ អាបត្តិ បាចិត្តិយស្ស ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ សត្ថគមនីយោ នាម មគ្គោ ន សក្កា ហោតិ វិនា សត្ថេន គន្តុំ ។ សាសង្កំ នាម តស្មឹ មគ្គេ ចោរានំ និវិដ្ឋោកាសោ ទិស្សតិ ភុត្តោកាសោ ទិស្សតិ ឋិតោកាសោ ទិស្សតិ និសិន្នោកាសោ ទិស្សតិ និបន្នោកាសោ ទិស្សតិ ។ សប្បដិភយំ នាម តស្មឹ មគ្គេ ចោរេហិ មនុស្សា ហតា

---

១ ម. គាមន្តរេ គាមន្តរេ ។



ភិក្ខុនី។ រាកាសន្ធិ ។ ពាក្យថា ជាមួយគ្នា សេចក្តីថា រួមជាមួយគ្នា ។ ពាក្យថា បបួល គឺបបួលគ្នាថា ម្នាលនាង យើងនឹងទៅឲ្យដល់ទីនោះទៅ បពិត្រលោកម្ចាស់ យើងនឹងទៅឲ្យដល់ទីនោះទៅ បពិត្រលោកម្ចាស់ យើងនឹងទៅឲ្យដល់ទីនោះទៅ ម្នាលនាង យើងនឹងទៅឲ្យដល់ទីនោះទៅ យើងនឹងទៅឲ្យដល់ទីនោះទៅ ក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ក្នុងថ្ងៃខានស្អែក ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ដោយហោចទៅសូម្បីទៅកាន់ចន្លោះនៃស្រុក ១ សេចក្តីថា (ភិក្ខុបបួលភិក្ខុនីដើរជាមួយគ្នាទៅ) ក្នុងទីជាចន្លោះនៃស្រុក ក្នុងស្រុកមានចម្ងាយល្មមមាន់ហើរទៅដល់ (គឺ ១ លោះមាន់ហើរ) ត្រូវអាបត្តិបាចិត្តិយ ។ (ភិក្ខុបបួលភិក្ខុនីដើរជាមួយគ្នាទៅ) ក្នុងព្រៃដែលមិនមែនស្រុក ត្រូវអាបត្តិបាចិត្តិយគ្រប់ ៗ កន្លះយោជន៍ ។ ពាក្យថា វៀរលែងតែមានសម័យ សេចក្តីថា លើកទុកតែមានសម័យ ។ ផ្លូវដែលហៅថា ផ្លូវដែលគួរទៅដោយមានគ្នាជាពួក គឺផ្លូវដែលបុគ្គលឥតមានគ្នាមិនអាចដើរទៅបាន ។ ផ្លូវដែលហៅថា ផ្លូវប្រកបដោយសេចក្តីរង្កៀស គឺកន្លែងដែលពួកចោរស្រ័យនៅក៏ប្រាកដ កន្លែងដែលពួកចោរបរិភោគអាហារក៏ប្រាកដ កន្លែងដែលពួកចោរឈរនៅក៏ប្រាកដ កន្លែងដែលពួកចោរអង្គុយក៏ប្រាកដ កន្លែងដែលពួកចោរដេកក៏ប្រាកដ ក្នុងផ្លូវនោះ ។ ផ្លូវដែលហៅថា ផ្លូវប្រកបដោយភ័យចំពោះមុខ គឺផ្លូវនោះដែលពួកចោរកាប់ឲ្យ សម្លាប់មនុស្សក៏ប្រាកដ

ទិស្សន្តិ វិលុត្តា ទិស្សន្តិ អាកោដិតា ទិស្សន្តិ ។ សប្បដិភយំ គន្ត្វា អប្បដិភយំ ទស្សេត្វា[1] ឧយ្យោជេតព្វា ភិក្ខុនិយោ ។

(៩៦) សំវិធហិតេ សំវិធហិតសញ្ញី ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អញ្ញត្រ សមយា អាបត្តិ បាចិត្តិយស្ស ។ សំវិធហិតេ វេមតិកោ ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អញ្ញត្រ សមយា អាបត្តិ បាចិត្តិយស្ស ។ សំវិធហិតេ អសំវិធហិតសញ្ញី ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អញ្ញត្រ សមយា អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ សំវិធហតិ ភិក្ខុនី ន សំវិធហតិ អាបត្តិ ទុក្កដស្ស ។ អសំវិធហិតេ សំវិធហិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អសំវិធហិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អសំវិធហិតេ អសំវិធហិតសញ្ញី អនាបត្តិ ។

១ ម. ទស្សិត្វា ។ ឱ. ទស្សេត្វា ។



ឃើញមនុស្សត្រូវចោរប្លន់ ឃើញមនុស្សត្រូវចោរវាយ ។ ភិក្ខុដើរទៅកាន់ផ្លូវដែលប្រកបដោយភ័យចំពោះមុខ ហើយបង្ហាញផ្លូវមិនប្រកបដោយភ័យចំពោះមុខវិញ ត្រូវបញ្ជូនភិក្ខុនីទៅ ដោយពាក្យថា ម្នាលនាងទាំងឡាយ នាងទាំងឡាយចូរទៅចុះ ។

(៩៦) ភិក្ខុបបួលគ្នាហើយសំគាល់ថា បបួលមែន ដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាចន្លោះនៃស្រុក ១ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសន្ស័យក្នុងកិរិយាដែលបបួលគ្នា ហើយដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាចន្លោះនៃស្រុក ១ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុបបួលគ្នា ហើយសំគាល់ថាមិនបានបបួល ដើរទៅកាន់ផ្លូវឆ្ងាយមួយ ដោយហោចទៅសូម្បីទៅកាន់ទីជាចន្លោះនៃស្រុក ១ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុបបួល តែភិក្ខុនីមិនបបួល (ភិក្ខុនោះ) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនបានបបួលគ្នា ហើយសំគាល់ថាបានបបួល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសន្ស័យក្នុងកិរិយាដែលមិនបានបបួល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ថា មិនបានបបួល ក្នុងកិរិយាដែលមិនបានបបួល មិនត្រូវអាបត្តិឡើយ ។

(៧៣) អនាបត្តិ សមយេ អសំវិទហិត្វា គច្ឆន្តិ ភិក្ខុនី សំវិទហតិ ភិក្ខុ ន សំវិទហតិ វិសង្កេតេន គច្ឆន្តិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។



(៧៣) អាបត្តិមិនមាន ដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនីហើយដើរទៅ ដល់ភិក្ខុដែលភិក្ខុនីបបួល តែភិក្ខុមិនបានបបួល ដល់ភិក្ខុនិងភិក្ខុនីដែលទៅដោយខុសសង្កេត ដល់ភិក្ខុដែលទៅ(ជាមួយនឹងភិក្ខុនី)ដោយមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

## អដ្ឋមសិក្ខាបទំ

(៧៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភិក្ខុនីហិ សទ្ធិំ សំវិធាយ ឯកនាវំ អភិរុហន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ យថេវ មយំ សបជាបតិកា នាវាយ កីឡាម ឯវមេវិមេ សមណា សក្យបុត្តិយា ភិក្ខុនីហិ សទ្ធិំ សំវិធាយ នាវាយ កីឡន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថញ្ហិ នាម ឆព្វគ្គិយា ភិក្ខូ ភិក្ខុនីហិ សទ្ធិំ សំវិធាយ ឯកនាវំ អភិរុហិស្សន្តីតិ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុនីហិ សទ្ធិំ សំវិធាយ ឯកនាវំ

## សិក្ខាបទទី ៨

[៧៤] សម័យនោះ ព្រះពុទ្ធមានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយបបួលពួកភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងទាំងឡាយមានប្តីប្រពន្ធជិះលេងលើទូក ១ យ៉ាងណា សមណៈទាំងឡាយនេះជាកូនចៅព្រះពុទ្ធសក្យបុត្រ បបួលពួកភិក្ខុនីជិះលេងលើទូក ១ ជាមួយគ្នា យ៉ាងនោះដែរ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆព្វគ្គិយភិក្ខុទាំងឡាយមិនគួរបើនឹងបបួលពួកភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នាទេ ។ ហើយភិក្ខុទាំងឡាយនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់ទ្រង់សួរចំពោះឆព្វគ្គិយភិក្ខុទាំងឡាយ ក្នុងរឿងនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទាំងឡាយបបួលពួកភិក្ខុនីឡើងជិះទូក

អភិរូហថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខុនីហិ សទ្ធឹ សំវិធាយ ឯកនាវំ អភិរុហិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកនាវំ អភិរុហេយ្យ ឧទ្ធំគាមិនឹ[១] វា អធោគាមិនឹ វា បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៧៨] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ច ភិក្ខុនិយោ ច សាកេតា សាវត្ថឹ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ អន្តរាមគ្គេ នទី តរិតព្វា[២] ហោតិ ។ អថខោ តា ភិក្ខុនិយោ តេ ភិក្ខូ ឯតទវោចុំ មយម្បិ អយ្យេហិ សទ្ធឹ ឧត្តរិស្សាមាតិ ។ ន ភគិនី កប្បតិ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកនាវំ អភិរុហិតុំ តុម្ហេ វា បឋមំ ឧត្តរថ មយំ វា ឧត្តរិស្សាមាតិ ។

១ ឧទ្ធំគាមិនិន្តិ បាឋោ ។ ២ ម. ឥ. តរិតព្វា ។



ជាមួយគ្នា ពិតមែនឬ ។ ចុះភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ការនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងបបួលពួកភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នាទេ ម្នាលមោឃបុរសទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លា ដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបបួលភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា ទៅច្រាសទឹកក្ដី ទៅតាមខ្សែទឹកក្ដី (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៧៨] សម័យនោះឯង ភិក្ខុនិងភិក្ខុនីទាំងឡាយច្រើនរូប ដើរទៅកាន់ផ្លូវឆ្ងាយអំពីក្រុងសាកេតទៅកាន់ក្រុងសាវត្ថី ។ ក្នុងចន្លោះផ្លូវនៅមានស្ទឹង ១ ដែលត្រូវឆ្លង ។ ទើបភិក្ខុនីទាំងឡាយនោះបានពោលពាក្យនេះនឹងភិក្ខុទាំងឡាយនោះថា យើងទាំងឡាយនឹងឆ្លងទៅមួយអន្លើដោយលោកម្ចាស់ទាំងឡាយដែរ ។ ភិក្ខុទាំងឡាយនោះឆ្លើយថា ម្នាលនាង ការដែលភិក្ខុបបួលភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា មិនគួរទេ (បើដូច្នោះ) នាងទាំងឡាយឆ្លងទៅមុនចុះ ។ យើងទាំងឡាយនឹងឆ្លងទៅមុន ។

អយ្យា ភន្តេ អត្តមនា អយ្យា ។ បឋមំ ឧត្តរន្តុ ។ អថខោ តាសំ ភិក្ខុនីនំ បច្ឆា ឧត្តរន្តីនំ ចោរា អច្ឆិន្ទឹសុ ចេវ ទូសេសុញ្ច ។ អថខោ តា ភិក្ខុនិយោ សាវត្ថឹ គន្ត្វា ភិក្ខុនីនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខុនិយោ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ តិរិយំតរណាយ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកំ នាវំ អភិរុហិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធឹ សំវិធាយ ឯកំ នាវំ អភិរុហេយ្យ ឧទ្ធំគាមិនឹ វា អធោគាមិនឹ វា អញ្ញត្រ តិរិយំតរណាយ បាចិត្តិយន្តិ ។

(៧៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខុនី ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ សទ្ធិន្តិ ឯកតោ ។ សំវិធាយាតិ អភិរុហាម ភគិនិ



ភិក្ខុនីទាំងឡាយនិយាយថា បពិត្រលោកដ៏ចំរើន លោកម្ចាស់ទាំងឡាយជាម្ចាស់ដ៏ប្រសើរ លោកម្ចាស់ទាំងឡាយចូរឆ្លងទៅមុនចុះ ។ កាលភិក្ខុនីទាំងឡាយនោះឆ្លងទៅជាខាងក្រោយ ពួកចោរក៏ដណ្តើមយក (ប្លន់)ផង ប្រទូស្តផងក្នុងកាលនោះ ។ លុះភិក្ខុនីទាំងឡាយនោះទៅដល់ក្រុងសាវត្ថីហើយ ក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុនីទាំងឡាយ ។ ពួកភិក្ខុនីក៏ប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុក៏ក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបបួលភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា ដើម្បីឆ្លងទទឹង ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបបួលភិក្ខុនីឡើងជិះទូក ១ ជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី (ភិក្ខុនោះ)ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការឆ្លងទទឹង ។

(៧៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចពោលក្នុងសិក្ខាបទទី ១ នៃឱវាទវគ្គ ។ បេ ។ ដែលហៅថា ភិក្ខុនី ឧបសម្បទាក្នុងសំណាក់នៃឧភតោសង្ឃ[១] ។ ពាក្យថា ជាមួយគ្នា គឺពួកជាមួយ ។ ពាក្យថា បបួល គឺបបួលគ្នាថា ម្នាលនាង យើងទាំងឡាយ

---

១ សង្ឃពីរពួក គឺភិក្ខុសង្ឃ ១ ភិក្ខុនីសង្ឃ ១ ។

អភិរុហាម អយ្យ អភិរុហាម អយ្យ អភិរុហាម ភគិនិ អជ្ជ វា ហិយ្យោ វា បរេ វា អភិរុហាមាតិ សំវិទហតិ អាបត្តិ ទុក្កដស្ស ។ ភិក្ខុនិយា អភិរូឡ្ហេ ភិក្ខុ អភិរុហតិ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុស្មឹ អភិរូឡ្ហេ ភិក្ខុនី អភិរុហតិ អាបត្តិ បាចិត្តិយស្ស ។ ឧភោ(១) វា អភិរុហន្តិ អាបត្តិ បាចិត្តិយស្ស ។ ឧទ្ធង្គាមិនឹ ឧជ្ជវនិកាយ ។ អធោគាមិនឹ ឱជវនិកាយ ។ អញ្ញត្រ តិរិយន្តរណាយាតិ ឋបេត្វា តិរិយន្តរណាយ(២) ។ កុក្កុដសម្បាតេ គាមេ គាមន្តរេ គាមន្តរេ អាបត្តិ បាចិត្តិយស្ស ។ អគាមកេ អរញ្ញេ អឌ្ឍយោជនេ អឌ្ឍយោជនេ អាបត្តិ បាចិត្តិយស្ស ។

(៧៧) សំវិទហិតេ សំវិទហិតសញ្ញី ឯកនាវំ អភិរុហតិ ឧទ្ធង្គាមិនឹ វា អធោគាមិនឹ វា អញ្ញត្រ តិរិយន្តរណាយ អាបត្តិ បាចិត្តិយស្ស ។ សំវិទហិតេ វេមតិកោ ឯកនាវំ អភិរុហតិ ឧទ្ធង្គាមិនឹ វា

១ ឱ. ម. ឧភោ ។ ២ ម. តិរិយន្តរណាយ ។



នឹងឡើងជិះទូក បពិត្រលោកម្ចាស់ យើងតាំងព្យាយាមនឹងឡើងជិះទូក បពិត្រលោកម្ចាស់ យើងតាំងព្យាយាមនឹងឡើងជិះទូក ម្នាលនាង យើងតាំងព្យាយាមនឹងឡើងជិះទូក យើងតាំងព្យាយាមនឹងឡើងជិះទូកក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ក្នុងថ្ងៃខានស្អែក ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនីឡើងជិះទូក ភិក្ខុក៏ឡើងជិះផង ត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុឡើងជិះទូក ភិក្ខុនីក៏ឡើងជិះផង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីនិងភិក្ខុឡើងជិះទូកស្មើគ្នា ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ទៅច្រាសទឹក សេចក្តីថា នាំទៅទីខាងលើទឹក ។ ពាក្យថា ទៅបណ្តោយទឹក សេចក្តីថា នាំទៅទីខាងក្រោមទឹក ។ ពាក្យថា វៀរលែងតែការឆ្លងទទឹង សេចក្តីថា លើកទុកតែការឆ្លងទទឹង ។ (ភិក្ខុបបួលភិក្ខុនីឡើងជិះទូក) ទៅក្នុងស្រុកចម្ងាយមាន់ល្មមហើរទៅដល់ ត្រូវអាបត្តិបាចិត្តិយ គ្រប់ចន្លោះស្រុក ។ (ភិក្ខុបបួលភិក្ខុនីឡើងជិះទូក) ទៅក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗកន្លះយោជន៍ ។

(៧៧) កាលដែលបានបបួលហើយ ភិក្ខុសំគាល់ថា បានបបួលពិតមែន ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី ទៅបណ្តោយទឹកក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការឆ្លងទទឹង ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងការដែលបានបបួលគ្នា ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្តី

អធោគាមិនឹ វា អញ្ញត្រ តិរិយំ តរណាយ អាបត្តិ បាចិត្តិយស្ស ។ សំវិទហិតេ អសំវិទហិតសញ្ញី ឯកំ នាវំ អភិរុហតិ ឧទ្ធគាមិនឹ វា អធោគាមិនឹ វា អញ្ញត្រ តិរិយំ តរណាយ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ សំវិទហតិ ភិក្ខុនី ន សំវិទហតិ អាបត្តិ ទុក្កដស្ស ។ អសំវិទហិតេ សំវិទហិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អសំវិទហិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អសំវិទហិតេ អសំវិទហិតសញ្ញី អនាបត្តិ ។

[៧៨] អនាបត្តិ តិរិយំ តរណាយ អសំវិទហិត្វា អភិរុហន្តិ ភិក្ខុនី សំវិទហតិ ភិក្ខុ ន សំវិទហតិ វិសង្កេតេន អភិរុហន្តិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



ទៅបណ្ដោយទឹកក្ដី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែឆ្លងទទឹង ។ ការដែលបានបបួលគ្នា ភិក្ខុសំគាល់ថាមិនបានបបួលគ្នា ហើយឡើងជិះទូកជាមួយគ្នា ទៅច្រាសទឹកក្ដី ទៅបណ្ដោយទឹកក្ដី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែឆ្លងទទឹង ។ ភិក្ខុបបួល ភិក្ខុនីមិនបានបបួល ត្រូវអាបត្តិទុក្កដ ។ មិនបានបបួលគ្នាទេ តែភិក្ខុសំគាល់ថា បានបបួលគ្នាហើយ ត្រូវអាបត្តិទុក្កដ ។ មិនបានបបួលគ្នាទេ តែភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនបានបបួលគ្នាទេ ភិក្ខុសំគាល់ថា មិនបានបបួលគ្នាមែន មិនត្រូវអាបត្តិ ។

[៧៨] អនាបត្តិមិនមាន ដល់ភិក្ខុដែលឆ្លងទទឹង ដល់ភិក្ខុដែលមិនបានបបួលគ្នា ហើយឡើងជិះទូក ដល់ភិក្ខុដែលមិនបានបបួលភិក្ខុនី តែភិក្ខុនីបបួល ដល់ភិក្ខុដែលឡើងជិះទូកជាមួយនឹងភិក្ខុនីដោយខុសសង្កេតគ្នា ដល់ភិក្ខុដែលមានសេចក្ដីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាទាំងដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

## នវមសិក្ខាបទំ

[៧៨] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ថុល្លនន្ទា ភិក្ខុនី អញ្ញតរស្ស កុលស្ស កុលុបិកា[1] ហោតិ និច្ចភត្តិកា ។ តេន ច គហបតិនា ស្វេ ភិក្ខូ និមន្តិតា ហោន្តិ ។ អថខោ ថុល្លនន្ទា ភិក្ខុនី បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា តំ គហបតិំ ឯតទវោច កិមិទំ គហបតិ បហូតំ ខាទនីយំ ភោជនីយំ បដិយត្តន្តិ ។ ថេរា អយ្យេ និមន្តិតាតិ ។ កេ បន តេ គហបតិ ថេរាតិ ។ អយ្យោ សារិបុត្តោ អយ្យោ មហាមោគ្គល្លានោ អយ្យោ មហាកច្ចានោ អយ្យោ មហាកោដ្ឋិតោ អយ្យោ មហាកប្បិនោ អយ្យោ មហាចុន្ទោ អយ្យោ អនុរុទ្ធោ អយ្យោ រេវតោ អយ្យោ ឧបាលិ អយ្យោ អានន្ទោ អយ្យោ រាហុលោតិ ។ កិំ បន តុំ គហបតិ

១ ឱ. កុលូបកា ។

## សិក្ខាបទទី ៩

[៧៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ វត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ភិក្ខុនីឈ្មោះថុល្លនន្ទា ជាជីដូនរបស់ត្រកូល ១ ជាភិក្ខុនីដែលគេប្រគេនដោយនិច្ចភត្ត ។ ចំណែកគហបតីនោះ ក៏បាននិមន្តពួកភិក្ខុដើម្បីថ្ងៃស្អែក ។ គ្រានោះឯង ភិក្ខុនីឈ្មោះថុល្លនន្ទា ស្លៀកស្បង់ប្រដាប់ដោយបាត្រនិងចីវរ ក្នុងវេលាព្រឹក ហើយចូលទៅកាន់ត្រកូលនោះ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងគហបតីនោះថា ម្នាលគហបតី ខាទនីយភោជនីយាហារនេះច្រើនប្រមាណម្ល៉េះ គេតាក់តែងដើម្បីអ្វី ។ គហបតីឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំបាននិមន្តព្រះថេរៈទាំងឡាយមកឆាន់ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាសួរថា ម្នាលគហបតី ព្រះថេរៈទាំងនោះ គឺព្រះថេរៈណាខ្លះ ។ គហបតីឆ្លើយថា ព្រះសារីបុត្ត ជាម្ចាស់ ព្រះមហាមោគ្គល្លាន ជាម្ចាស់ ព្រះមហាកច្ចានៈ ជាម្ចាស់ ព្រះមហាកោដ្ឋិតៈ ជាម្ចាស់ ព្រះមហាកប្បិន ជាម្ចាស់ ព្រះមហាចុន្ទ ជាម្ចាស់ ព្រះអនុរុទ្ធ ជាម្ចាស់ ព្រះរេវត ជាម្ចាស់ ព្រះឧបាលិ ជាម្ចាស់ ព្រះអានន្ទ ជាម្ចាស់ ព្រះរាហុល ជាម្ចាស់ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាឆ្លើយថា ម្នាលគហបតី កាលព្រះថេរៈមហានាគដ៏ប្រសើរមាននៅក្រៅ

មហានាគេ តិដ្ឋមានេ ចេដកេ និមន្តេសីតិ ។ កេ បន កេ អយ្យេ មហានាគាតិ ។ អយ្យោ ទេវទត្តោ អយ្យោ កោកាលិកោ អយ្យោ កដមោរកតិស្សកោ អយ្យោ ខណ្ឌទេវិយា បុត្តោ អយ្យោ សមុទ្ទទត្តោតិ ។ អយញ្ច-រហិ[១] ថុល្លនន្ទាយ ភិក្ខុនិយា អន្តរា កថា វិប្បកតា ។ អថ ថេរា[២] ភិក្ខូ បវិសិំសុ ។ សច្ចំ មហានាគា ខោ តយា គហបតិ និមន្តិតាតិ ។ ឥទានិ ត្វំ អយ្យេ ចេដកេ អកាសិ ឥទានិ មហានាគេតិ (ឧបរកោ[៣]) និក្ខាមេសិ ចិត្តកត្តញ្ច ឧបច្ឆិន្ទិ[៤] ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ទេវទត្តោ ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌ-បាតំ ភុញ្ជិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ទេវទត្ត ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌបាតំ ភុញ្ជសីតិ ។

១ ម. តយំ ជាហ៊ើ ។ ២ ម. ឥទានិ ។ ៣ ម. ឧបាសកោ ។ ៤ ឧច្ឆិន្ទិ ។





ហេតុដូចម្តេចក៏អ្នកទៅនិមន្តភិក្ខុក្មេងមកវិញ ។ គហបតីសួរថា បពិត្រលោកម្ចាស់ ព្រះថេរៈមហានាគដ៏ប្រសើរទាំងនោះ មានព្រះនាមដូចម្តេចខ្លះ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាឆ្លើយថា លោកម្ចាស់ទេវទត្ត លោកម្ចាស់កោកាលិក លោកម្ចាស់កដមោរកតិស្សកៈ លោកម្ចាស់ខណ្ឌទេវីបុត្រ លោកម្ចាស់សមុទ្ទទត្ត ។ កាលភិក្ខុនីឈ្មោះថុល្លនន្ទាកំពុងតែនិយាយពាក្យនេះមិនទាន់អស់នៅឡើយ ។ ស្រាប់តែភិក្ខុជាថេរៈទាំងឡាយចូលមកក្នុងពេលនោះ ។ ភិក្ខុនីឈ្មោះថុល្លនន្ទាសួរថា ម្នាលគហបតី ព្រះថេរៈមហា-នាគដ៏ប្រសើរទាំងឡាយអ្នកបាននិមន្តហើយ ពិតមែនឬ ។ គហបតីឆ្លើយថា បពិត្រលោកម្ចាស់ ឥឡូវនេះ លោកម្ចាស់បានធ្វើព្រះថេរៈមហា-នាគដ៏ប្រសើរទាំងឡាយជាភិក្ខុក្មេង លោកម្ចាស់ត្រឡប់ធ្វើភិក្ខុជាក្មេងឲ្យជាមហានាគដ៏ប្រសើរវិញ (ជាមួយគ្នានេះហើយ) ក៏បណ្តេញភិក្ខុនីឈ្មោះថុល្លនន្ទាចេញពីផ្ទះផង និងភត្ត (នឹងភ្ជាប់ដែលផ្តត់ផ្តន់ជាទំ) ក៏ផ្តាច់បង់ចេញ នឹងលប់ច្បាស់ទៅទៀតផង ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀលបន្តុះបង្អាប់ថា ម្តេចក៏ព្រះទេវទត្តបានដឹងហើយ មិនគួរនឹងឆាន់បិណ្ឌបាតដែលភិក្ខុនីបានឲ្យទេ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលទេវទត្ត ឮថាអ្នកដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីបានឲ្យមែន ពិតមែនឬ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌបាតំ ភុញ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសា-ទាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌបាតំ ភុញ្ជេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៨០] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ រាជគហា បព្វជិតោ ញាតិកុលំ អគមាសិ ។ មនុស្សា ចិរស្សម្បិ ភទន្តោ អាគតោតិ សក្កច្ចំ ភត្តំ អកំសុ ។ តស្ស កុលស្ស កុលុបិកា ភិក្ខុនី តេ មនុស្សេ ឯតទវោច ទេថ អយ្យស្ស ភត្តន្តិ ។ អថខោ សោ ភិក្ខុ ភគវតា បដិក្ខិត្តំ ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌបាតំ ភុញ្ជិតុន្តិ កុក្កុច្ចាយន្តោ នប្បដិគ្គហេសិ នាសក្ខិ បិណ្ឌាយ ចរិតុំ ឆិន្នភត្តោ អហោសិ ។



ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា នែមោឃបុរស អ្នកឯងដឹងហើយ មិនគួរនឹងឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែងទេ ម្នាលមោឃបុរស ការនេះ មិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៨០] សម័យនោះឯង មានភិក្ខុ១រូប ចេញពីក្រុងរាជគ្រឹះទៅបួស ហើយទៅកាន់ត្រកូលញាតិ ។ មនុស្សទាំងឡាយនិយាយគ្នាថា លោកម្ចាស់ដ៏ចំរើនទាល់តែយូរណាស់ហើយ (ទើបមកដល់ហើយ) ក៏នាំគ្នាធ្វើភត្តដោយប្រ-ណីតដោយគោរព ។ មានភិក្ខុនីម្នាក់ជាកុលូបិការបស់ត្រកូលនោះបាននិយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះថា ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរឲ្យភត្តដល់លោកម្ចាស់ចុះ ។ គ្រានោះ ភិក្ខុនោះមានសេចក្ដីសង្ស័យថា ការដឹងហើយបរិភោគបិណ្ឌបាតដែលភិក្ខុនីចាត់ចែង ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ (សង្ស័យដូច្នោះហើយ) ក៏មិនទទួល (បិណ្ឌបាតនោះ) ហើយមិនអាចនឹងត្រាច់ទៅដើម្បីបិណ្ឌបាតទៀតបាន ក៏ដាច់បាយក្នុងវេលានោះឯង ។

អថខោ សោ ភិក្ខុ អាភតំ ភត្តំ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ បុព្វេ គិហិសមារម្ភំ ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌបាតំ ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ ភិក្ខុនីបរិបាចិតំ បិណ្ឌបាតំ ភុញ្ជេយ្យ អញ្ញត្រ បុព្វេ គិហិសមារម្ភា បាចិត្តិយន្តិ ។

[៨៣] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សា វា អារោចេតិ ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ បរិបាចេតិ នាម បុព្វេ អទាតុកាមានំ អកត្តុកាមានំ អយ្យោ ភាណកោ អយ្យោ ពហុស្សុតោ អយ្យោ សុត្តន្តិកោ អយ្យោ វិនយធរោ អយ្យោ ធម្មកថិកោ ទេថ





ទើបភិក្ខុនោះនាំភត្តមក ហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការបង្គាប់មានគ្រហស្ថប្រារព្ធជាមុនហើយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលដឹងនាំបិណ្ឌបាតដែលភិក្ខុនីចាត់ចែងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកាលដឹងហើយឆាន់បិណ្ឌបាតដែលភិក្ខុនីចាត់ចែង ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែបង្គាប់ដែលគ្រហស្ថបានប្រារព្ធជាមុន ។

(៨៣) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងឯងក្តី ជនទាំងឡាយដទៃដឹងហើយប្រាប់ដល់ភិក្ខុនោះក្តី ភិក្ខុនីនោះប្រាប់ក្តី ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទាក្នុងសំណាក់ឧភតោសង្ឃ ។ ដែលហៅថា ចាត់ចែង ( គឺភិក្ខុនីនិយាយប្រាប់ដល់ជន ) ដែលមិនបានឲ្យ មិនបានធ្វើតាមគួរក្នុងកាលមុនថា លោកម្ចាស់នេះជាអ្នកពោល លោកម្ចាស់នេះជាពហុស្សុត លោកម្ចាស់នេះ ជាអ្នកចេះព្រះសូត្រ លោកម្ចាស់នេះទ្រទ្រង់វិន័យ លោកម្ចាស់នេះជាធម្មកថិក អ្នកទាំងឡាយចូរឲ្យ ( បច្ច័យ )

អយ្យស្ស ការេថ អយ្យស្សាតិ ឯសា បរិបាចេតិ នាម ។ បិណ្ឌបាតោ នាម បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ ។ អញ្ញត្រ បុព្វេ គិហិសមារម្ភាតិ ឋបេត្វា គិហិសមារម្ភំ ។ គិហិសមារម្ភោ នាម ញាតកា វា ហោន្តិ បវារិតា វា បកតិបដិយត្តំ វា ។ អញ្ញត្រ បុព្វេ គិហិសមារម្ភា ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

(៨២) បរិបាចិតេ បរិបាចិតសញ្ញី ភុញ្ជតិ អញ្ញត្រ បុព្វេ គិហិសមារម្ភា អាបត្តិ បាចិត្តិយស្ស ។ បរិបាចិតេ វេមតិកោ ភុញ្ជតិ អញ្ញត្រ បុព្វេ គិហិសមារម្ភា អាបត្តិ ទុក្កដស្ស ។ បរិបាចិតេ អបរិបាចិតសញ្ញី ភុញ្ជតិ អញ្ញត្រ បុព្វេ គិហិសមារម្ភា អនាបត្តិ ។ ឯកតោ ឧបសម្បន្នាយ បរិបាចិតំ ភុញ្ជតិ អញ្ញត្រ បុព្វេ គិហិសមារម្ភា អាបត្តិ ទុក្កដស្ស ។



ដល់លោកម្ចាស់អង្គនេះ ចូរធ្វើ(ចង្ហាន់) ដល់លោកម្ចាស់នេះ ភិក្ខុនីនេះ ហៅថា ជាត់ចែង ។ ដែលហៅថា បិណ្ឌបាត បានដល់ភោជនទាំង៥ ភោជនណាមួយ ។ ពាក្យថា វៀរលែងតែចង្ហាន់ដែលគ្រហស្ថត្រៀមជាមុន សេចក្តីថា លើកទុកតែចង្ហាន់ដែលគ្រហស្ថផ្តើមជាមុន ។ ដែលហៅថាគ្រហស្ថត្រៀម គឺជនទាំងឡាយជាញាតិក្តី បិណ្ឌបាតដែលគេបវារ-ណាក្តី ចង្ហាន់ដែលគេតាក់តែងជាប្រក្រតីក្តី ។ ភិក្ខុទទួលបិណ្ឌបាតដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែបិណ្ឌបាត ដែលគ្រហស្ថត្រៀមជាមុន ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ កះដែលលេបចូល ។

(៨២) ចង្ហាន់ដែលភិក្ខុនីជាត់ចែង ភិក្ខុសំគាល់ថា ភិក្ខុនីជាត់ចែង ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែចង្ហាន់ដែលគ្រហស្ថត្រៀមជាមុន ។ ចង្ហាន់ដែលភិក្ខុនីជាត់ចែង ភិក្ខុមានសេចក្តីសង្ស័យ ហើយឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែចង្ហាន់ដែលគ្រហស្ថត្រៀមជាមុន ។ ចង្ហាន់ដែលភិក្ខុនីជាត់ចែង ភិក្ខុសំគាល់ថា មិនបានជាត់ចែងទេ នឹងចង្ហាន់ដែលគ្រហស្ថបានត្រៀមជាមុន ហើយឆាន់ មិនត្រូវអាបត្តិឡើយ ។ ភិក្ខុឆាន់ភោជន ដែលភិក្ខុនីបានឧបសម្បទាក្នុងឯកតោសង្ឃបានជាត់ចែង ត្រូវអាបត្តិទុក្កដ វៀរលែងតែភោជនដែលគ្រហស្ថគេត្រៀមឡើងជាមុន ។

អបរិបាចិតេ បរិបាចិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អបរិបាចិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អបរិបាចិតេ អបរិបាចិតសញ្ញី អនាបត្តិ ។

[៨៣] អនាបត្តិ(១) គិហិសមារម្ភេ សិក្ខមានា បរិបាចេតិ សាមណេរី បរិបាចេតិ បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។

---

១ ឱ. ម. អនាបត្តិ បុព្វេ ។





ភិក្ខុសំគាល់ភោជនដែលភិក្ខុនីមិនបានចាត់ចែងថា បានចាត់ចែងហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងភោជនដែលភិក្ខុនីមិនបានចាត់ចែង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ភោជន ដែលភិក្ខុនីមិនបានចាត់ចែងថា មិនបានចាត់ចែង មិនត្រូវអាបត្តិ ។

[៨៣] អាបត្តិមិនមាន ដល់ភិក្ខុដែលឆាន់ភោជន ដែលគ្រហស្ថប្រារព្ធទុកហើយជាមុន ដល់ភិក្ខុដែលឆាន់ភោជន ដែលសិក្ខមានាចាត់ចែង ដល់ភិក្ខុដែលឆាន់ភោជន ដែលសាមណេរីចាត់ចែង អាបត្តិមិនមាន ដល់ភិក្ខុដែលឆាន់ភោជនទាំងពួងក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

សិក្ខាបទទី ៩ ចប់ ។

# ទសមសិក្ខាបទំ

[៨៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មតោ ឧទាយិស្ស បុរាណ-ទុតិយិកា ភិក្ខុនីសុ បព្វជិតា ហោតិ ។ សា ភិក្ខុនី[១] អាយស្មតោ ឧទាយិស្ស សន្តិកេ អភិក្ខណំ អាគច្ឆតិ ។ អាយស្មាបិ ឧទាយី តស្សា ភិក្ខុនិយា សន្តិកេ អភិក្ខណំ គច្ឆតិ ។ តេន ខោ បន សម-យេន អាយស្មា ឧទាយី តស្សា ភិក្ខុនិយា សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយី ភិក្ខុនិយា សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ ឧទាយិ ភិក្ខុនិយា សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសីតិ ។ សច្ចំ

១ ម. ឆ. ភិក្ខុនីសទ្ទោ ន ទិស្សតិ ។

# សិក្ខាបទទី ១០

[៨៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ស្រ្តីជាភរិយាដើមរបស់ព្រះឧទាយិដ៏មានអាយុ បួសក្នុងសំណាក់ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីនោះតែងមកក្នុងសំណាក់ព្រះឧទាយិដ៏មានអាយុរឿយៗ ។ ចំណែកខាងព្រះឧទាយិដ៏មានអាយុ តែងទៅក្នុងសំណាក់ភិក្ខុនីនោះរឿយៗ ។ គ្រានោះ ព្រះឧទាយិដ៏មានអាយុម្នាក់ឯង អង្គុយក្នុងទីស្ងាត់ ជាមួយនឹងភិក្ខុនីនោះតែម្នាក់ឯង ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ចុះហេតុ-អ្វី បានជាព្រះឧទាយិដ៏មានអាយុម្នាក់ឯងសម្រេចការអង្គុយក្នុងទីស្ងាត់ ជា-មួយនឹងភិក្ខុនីតែម្នាក់ឯង ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលឧទាយិភិក្ខុ ឮថា អ្នកឯងតែម្នាក់ឯងសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងភិក្ខុនីតែម្នាក់ឯង ពិតមែនឬ ។ ព្រះឧទាយិភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ

ភគវតោ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស ភិក្ខុនិយា សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុនិយា សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ បាចិត្តិយន្តិ ។

(៨៨) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ សទ្ធិន្តិ ឯកតោ ។ ឯកោ ឯកាយាតិ ភិក្ខុ ចេវ ហោតិ ភិក្ខុនី ច ។ រហោ នាម ចក្ខុស្ស រហោ សោតស្ស រហោ ។ ចក្ខុស្ស រហោ នាម ន សក្កា ហោតិ អក្ខឹ វា និខណិយមានេ ភមុកំ វា ឧក្ខិបិយមានេ សីសំ វា ឧក្ខិបិយមានេ បស្សិតុំ ។ សោតស្ស រហោ នាម ន សក្កា ហោតិ បកតិកថា សោតុំ ។ និសជ្ជំ កប្បេយ្យាតិ ភិក្ខុនិយា និសិន្នាយ ភិក្ខុ



ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងនៅតែម្នាក់ឯង មិនគួរនឹងសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងភិក្ខុនីតែម្នាក់ឯងទេ នែមោឃបុរស ការនុះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាក្រៃលែងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងភិក្ខុនីតែម្នាក់នឹងម្នាក់ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

[៨៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទាក្នុងសំណាក់ឧភតោសង្ឃ ។ ពាក្យថា ជាមួយ គឺក្នុងទីជាមួយ ។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺភិក្ខុនឹងភិក្ខុនី ។ ដែលហៅថា ទីស្ងាត់ គឺទីកំបាំងនៃភ្នែក ១ ទីកំបាំងនៃត្រចៀក ១ ។ ដែលហៅថា ទីកំបាំងនៃភ្នែក គឺទីដែលគេមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងើបក្បាលក្តី ក៏មិនអាចនឹងមើលឃើញបាន ។ ដែលហៅថា ទីកំបាំងនៃត្រចៀក គឺទីដែលគេមិនអាចនឹងស្តាប់ពាក្យពោលជាប្រក្រតីបាន ។ ពាក្យថា សម្រេចការអង្គុយ សេចក្តីថា កាលភិក្ខុនីអង្គុយ

ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ និសិន្នេ ភិក្ខុនី ឧបនិសិន្នា វា ហោតិ ឧបនិបន្នា វា អាបត្តិ បាចិត្តិយស្ស ។ ឧភោ វា និសិន្នា ហោន្តិ ឧភោ វា និបន្នា អាបត្តិ បាចិត្តិយស្ស ។

(៨៦) រហោ រហោសញ្ញី ឯកោ ឯកាយ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ រហោ វេមតិកោ ឯកោ ឯកាយ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ រហោ អរហោសញ្ញី ឯកោ ឯកាយ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ អរហោ រហោសញ្ញី អាបត្តិ ទុក្កដស្ស ។ អរហោ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អរហោ អរហោសញ្ញី អនាបត្តិ ។

(៨៧) អនាបត្តិ យោ កោចិ វិញ្ញូ បុរិសោ(១) ទុតិយោ ហោតិ តិដ្ឋតិ ន និសីទតិ អរហោបេក្ខោ អញ្ញវិហិតោ និសីទតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

ឱវាទវគ្គោ តតិយោ ។

---

១ ម. ឧ. បុរិសោ នត្ថិ ។



ភិក្ខុអង្គុយជិតក្តី ដេកជិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ កាលភិក្ខុអង្គុយ ភិក្ខុនីអង្គុយជិតក្តី ដេកជិតក្តី ត្រូវអាបត្តិបាចិត្តិយ ។ ជនទាំងពីរ (គឺភិក្ខុនិងភិក្ខុនី) អង្គុយក្តី ជនទាំងពីរ (គឺភិក្ខុនិងភិក្ខុនី) ដេកក្តី ត្រូវអាបត្តិបាចិត្តិយ ។

(៨៦) ទីស្ងាត់ ភិក្ខុសំគាល់ថាទីស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនីតែមួយនឹងមួយ ត្រូវអាបត្តិបាចិត្តិយ ។ ទីស្ងាត់ ភិក្ខុសង្ស័យ ហើយអង្គុយជាមួយនឹងភិក្ខុនីតែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ទីស្ងាត់ ភិក្ខុសំគាល់ថាមិនស្ងាត់ ហើយអង្គុយជាមួយនឹងភិក្ខុនីតែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ទីមិនស្ងាត់ ភិក្ខុសំគាល់ថាទីស្ងាត់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងទីមិនស្ងាត់ ត្រូវអាបត្តិទុក្កដ ។ ទីមិនស្ងាត់ ភិក្ខុសំគាល់ថាមិនស្ងាត់ មិនត្រូវអាបត្តិទេ ។

(៨៧) អាបត្តិមិនមាន ដល់ភិក្ខុដែលមានបុរសណាមួយដែលដឹងសេចក្តីទៅជាពីរនាក់នឹងខ្លួន ដល់ភិក្ខុដែលឈរមិនអង្គុយ ដល់ភិក្ខុដែលមានបំណងនូវទីមិនស្ងាត់ហើយ (អង្គុយ) ដល់ភិក្ខុដែលមានចិត្តឃ្លាតទៅកាន់អារម្មណ៍ដទៃអង្គុយនៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់ ។

ឱវាទវគ្គ ជាគំរប់ ៣ ចប់ ។

ពាក្យសុំយកស្លោ នៃសាមណេរ ទុក

ឧស្សក្ខាប់

អសម្មត្តិកា ឧបស្សយ·
អាប័សនាលេខ សិក្ខាតិ
អក្កាន់ ជាវ៉ កុញ្ញេយ្យ
វិកោ វិកាយ ភេឧសាតិ ។



ពាក្យសុំយកស្លោ នៃវត្ត ទុក

ចំនួនសិក្ខាបទនៃគ្រឿងវត្តសាមណេរមាន ១០ គឺ

ររសមូតសិក្ខាបទ (កុំរំលោភសិក្ខាបទ)១ អវិន្ទិកសិក្ខាបទ ១ ទបស្សយសិក្ខាប័ទ (កុំទួបស្សយ) ១ គាម័សសិក្ខាបទ ១ គានសិក្ខាបទ (ប៉ែវភានសិក្ខាបទ)១ សិក្ខនសិក្ខាបទ (ប៉ែវ-សិក្ខនសិក្ខាបទ )១ អក្ខានសិក្ខាបទ (សំរិធានសិក្ខាបទ)១ ជាត់គុំរូបានសិក្ខាបទ១ កុញ្ញនសិក្ខាបទ (ប៉ិញ្ញាចនសិក្ខាបទ)១ ជះកោងកាយសិក្ខាបទ (ះបោធិសន្តសិក្ខាបទ )១ ។

# ភោជនវគ្គស្ស បឋមសិក្ខាបទំ

[៨៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយា អវិទូរេ អញ្ញតរស្ស បូគស្ស អាវសថបិណ្ឌោ បញ្ញត្តោ ហោតិ ។ ឆព្វគ្គិយា ភិក្ខូ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ(១) បិណ្ឌាយ បវិសិត្វា បិណ្ឌំ អលភមានា អាវសថំ អគមំសុ ។ មនុស្សា ចិរស្សម្បិ ភទន្តា អាគតាតិ សក្កច្ចំ បរិវិសឹសុ ។ អថខោ ឆព្វគ្គិយា ភិក្ខូ ទុតិយម្បិ ទិវសំ តតិយម្បិ ទិវសំ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សាវត្ថឹ(២) បិណ្ឌាយ បវិសិត្វា បិណ្ឌំ អលភមានា អាវសថំ គន្ត្វា ភុញ្ជឹសុ ។ អថខោ ឆព្វគ្គិយានំ ភិក្ខូនំ ឯតទហោសិ កឹ មយំ ការិស្សាម អារាមំ គតា(៣) ហិយ្យោបិ ឥធេវ អាគន្តព្វំ ភវិស្សតីតិ ។ តត្ថេវ អនុវសិត្វា

១-២ សាវត្ថិយន្តិបិ ទិស្សតិ ។ ៣ ឱ. ម. គន្ត្វា ។

# ភោជនវគ្គ បឋមសិក្ខាបទ

[៨៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានពួកជន ១ ពួក នៅជិតក្រុងសាវត្ថី បានតាំងតាក់តែងបិណ្ឌបាតក្នុងផ្ទះសំណាក់ឬរោងទាន ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយនាំគ្នាស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរក្នុងវេលាព្រឹក ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី លុះមិនបានបិណ្ឌបាតក៏នាំគ្នាទៅកាន់ផ្ទះសំណាក់ឬរោងទាន (នោះ) ។ មនុស្សទាំងឡាយនិយាយថា លោកម្ចាស់ទាំងឡាយ បាននិមន្តមកយូរណាស់ហើយ (ទាំងចូលមកហើយ) ក៏នាំគ្នាអង្គាសដោយគោរព ។ កាលនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ នាំគ្នាស្លៀកស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរក្នុងវេលាព្រឹក ចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត លុះមិនបានក៏នាំគ្នាទៅកាន់ផ្ទះសំណាក់ឬរោងទាន(នោះ) ហើយឆាន់ ក្នុងថ្ងៃទាំងពីរផង ក្នុងថ្ងៃទាំងបីផង ។ ទើបឆព្វគ្គិយភិក្ខុទាំងឡាយមានសេចក្តីត្រិះរិះដូច្នេះថា យើងទាំងឡាយទៅអារាមធ្វើអ្វី យើងនឹងត្រូវតែមកក្នុងផ្ទះសំណាក់ឬរោងទាននេះប៉ុណ្ណោះបានហើយ ។ ឆព្វគ្គិយភិក្ខុទាំងឡាយនៅហើយនៅទៀត ក្នុងផ្ទះសំណាក់នោះឯង

អនុវសិត្វា អាវសថបិណ្ឌំ ភុញ្ជន្តិ ។ តិត្ថិយា អប-
សក្កន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ
ហិ នាម សមណា សក្យបុត្តិយា អនុវសិត្វា អនុវសិត្វា
អាវសថបិណ្ឌំ ភុញ្ជិស្សន្តិ ន យិមេសំ អញ្ញោ អាវសថបិណ្ឌោ
បញ្ញត្តោ សព្ពេសំយេវាយំ អាវសថបិណ្ឌោ បញ្ញត្តោតិ ។
អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ
ខិយ្យន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា
។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ
ហិ នាម ឆព្វគ្គិយា ភិក្ខូ អនុវសិត្វា អនុវសិត្វា
អាវសថបិណ្ឌំ ភុញ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ
តុម្ហេ ភិក្ខវេ អនុវសិត្វា អនុវសិត្វា អាវសថបិណ្ឌំ
ភុញ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា អនុវសិត្វា
អនុវសិត្វា អាវសថបិណ្ឌំ ភុញ្ជិស្សថ នេតំ មោ-
ឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ
វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ



ចាំឆាន់នូវអាវសថបិណ្ឌបាត (គឺបិណ្ឌបាតក្នុងផ្ទះសំណាក់ឬរោងទាន
នោះ) ។ តិរ្ថិយទាំងឡាយក៏ចៀសចេញទៅ ។ មនុស្សទាំងឡាយពោល
ទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាពូជនៃព្រះពុទ្ធជា
សក្យបុត្រមិនគួរនឹងនៅត្រាំត្រែងឆាន់អាវសថបិណ្ឌបាត អាវសថបិណ្ឌ-
បាតមិនមែនដែលគេតាក់តែងដើម្បីតែពួកសមណៈនេះទេ អាវសថបិណ្ឌបាត
ដែលគេតាក់តែងដើម្បីជនទាំងឡាយទាំងពួងគ្រប់គ្នា ។ ភិក្ខុទាំងឡាយបានឮ
មនុស្សទាំងឡាយនោះពោលទោសតិះដៀលបន្តុះបង្អាប់(ដូច្នោះ)ហើយ ។
ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះ
ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុទាំងឡាយ មិនគួរនឹង
នៅត្រាំត្រែងឆាន់អាវសថបិណ្ឌបាតសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា
ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយនៅត្រាំត្រែង ឆាន់អាវសថ-
បិណ្ឌបាត ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទាំងឡាយក្រាបទូលថា បពិត្រ
ព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់
តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងនៅ
ត្រាំត្រែងឆាន់អាវសថបិណ្ឌបាតទេ ម្នាលមោឃបុរសទាំងឡាយ ការនោះ
មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ទាំងមិននាំជនដែល
ជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ឯកោ អាវសថបិណ្ឌោ ភុញ្ជិតព្វោ តតោ ចេ ឧត្តរិ[1] ភុញ្ជេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៨៤) តេន ខោ បន សមយេន អាយស្មា សារិបុត្តោ កោសលេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តោ យេន អញ្ញតរោ អាវសថោ តេនុបសង្កមិ ។ មនុស្សា ចិរស្សម្បិ ថេរោ អាគតោតិ សក្កច្ចំ ភោជេសុំ ។ អថ ខោ អាយស្មតោ សារិបុត្តស្ស ភុត្តាវិស្ស ខរោ អាពាធោ ឧប្បជ្ជិ ។ នាសក្ខិ តម្ហា អាវសថា បក្កមិតុំ ។ អថ ខោ តេ មនុស្សា ទុតិយម្បិ ទិវសំ អាយស្មន្តំ សារិបុត្តំ ឯតទវោចុំ ភុញ្ជថ ភន្តេតិ ។ អថ ខោ អាយស្មា សារិបុត្តោ ភគវតា បដិក្ខិត្តំ អនុវសិត្វា អនុវសិត្វា អាវសថបិណ្ឌំ ភុញ្ជិតុន្តិ កុក្កុច្ចាយន្តោ ន បដិគ្គហេសិ ឆិន្នភត្តោ អហោសិ ។ អថ ខោ អាយស្មា សារិបុត្តោ សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ

១ ឱ. ម. ឧត្តរឹ ។



អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា អាហារក្នុងផ្ទះសំណាក់ឬរោងទាន ភិក្ខុត្រូវឆាន់បានតែមួយ បើឆាន់ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(៨៤) សម័យនោះឯង ព្រះសារីបុត្តដ៏មានអាយុដើរទៅក្រុងសាវត្ថីក្នុងកោសលជនបទ បានចូលទៅកាន់ផ្ទះសំណាក់ឬរោងទាន ១ ។ មនុស្សទាំងឡាយនិយាយគ្នាថា ព្រះថេរៈបានមកយូរណាស់ហើយ (ទើបនឹងបានមកហើយ) ក៏នាំគ្នាអង្គាសដោយគោរព ។ លំដាប់នោះ ព្រះសារីបុត្តដ៏មានអាយុឆាន់រួចហើយ ក៏មានអាពាធជាទម្ងន់ ។ លោកមិនអាចនឹងចៀសចេញពីផ្ទះសំណាក់ឬរោងទាននោះទៅបាន ។ ទើបមនុស្សទាំងឡាយនោះ បានពោលពាក្យនេះនឹងព្រះសារីបុត្តដ៏មានអាយុក្នុងថ្ងៃជាគំរប់ពីរថា បពិត្រព្រះថេរៈដ៏ចំរើន សូមលោកនិមន្តឆាន់ចុះ ។ ព្រះសារីបុត្តដ៏មានអាយុមានសេចក្តីសង្ស័យថា ការដែលនៅក្រៅក្រែងឆាន់បិណ្ឌបាតក្នុងផ្ទះសំណាក់ឬរោងទាន ព្រះដ៏មានព្រះភាគបានហាមហើយ ហើយមិនទទួលបិណ្ឌបាត ក៏អត់ចង្ហាន់ក្នុងវេលានោះ ។ គ្រានោះ ព្រះសារីបុត្តដ៏មានអាយុនិមន្តទៅកាន់ក្រុងសាវត្ថី ហើយក៏ពោលសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ៗ ក្រាបទូលសេចក្តីនុ៎ះចំពោះ

ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា អនុវសិត្វា អនុវសិត្វា អាវសថបិណ្ឌំ ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អគិលានេន ភិក្ខុនា ឯកោ អាវសថបិណ្ឌោ ភុញ្ជិតព្វោ តតោ ចេ ឧត្តរិ ភុញ្ជេយ្យ បាចិត្តិយន្តិ ។

(៩០) អគិលានោ នាម សក្កោតិ តម្ហា អាវសថា បក្កមិតុំ ។ គិលានោ នាម ន សក្កោតិ តម្ហា អាវសថា បក្កមិតុំ ។ អាវសថបិណ្ឌោ នាម បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ សាលាយ(១) វា មណ្ឌបេ វា រុក្ខមូលេ វា អជ្ឈោកាសេ វា អនោទិស្ស យាវទត្ថោ បញ្ញត្តោ ហោតិ ។ អគិលានេន ភិក្ខុនា សកិំ ភុញ្ជិតព្វោ តតោ ចេ ឧត្តរិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

---

១ ម. សាលាយំ ។



ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជម្ងឺអាស្រ័យនៅហើយ ៗ ឆាន់អាហារក្នុងរោងទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា បិណ្ឌបាតក្នុងរោងទាន ភិក្ខុមិនមានជម្ងឺ ត្រូវឆាន់បានតែមួយ បើឆាន់ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

[៩០] ភិក្ខុដែលអាចដើម្បីចៀសចេញក៏កើតបាន នោះហៅថា មិនមានជម្ងឺ ។ ភិក្ខុដែលមិនអាចដើម្បីចៀសចេញក៏កើតបាន នោះហៅថា មានជម្ងឺ ។ ដែលហៅថា បិណ្ឌបាតក្នុងរោងទាន បានដល់ភោជនទាំង៥យ៉ាង ភោជនណាមួយ ដែលគេដាក់តែងក្នុងសាលាក្តី ក្នុងមណ្ឌបក្តី ទៀបគល់ឈើក្តី ក្នុងទីវាលក្តី មិនចំពោះបុគ្គលណា គេដាក់តែងកំណត់ល្មមមួយថ្ងៃ ([illegible]) ។ ភិក្ខុមិនមានជម្ងឺ ត្រូវឆាន់បានតែមួយ បើទទួលឲ្យហួសពីកំណត់នោះទៅ ដោយគិតថាអញនឹងឆាន់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ៗពំនូតដែលលេបចូលទៅ ។

[៩៣] អគិលានោ(១) អគិលានសញ្ញី តទុត្តរិ(២) អាវសថបិណ្ឌំ ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានោ វេមតិកោ តទុត្តរិ អាវសថបិណ្ឌំ ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានោ គិលានសញ្ញី តទុត្តរិ អាវសថបិណ្ឌំ ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ គិលានោ អគិលានសញ្ញី អាបត្តិ ទុក្កដស្ស ។ គិលានោ វេមតិកោ អាបត្តិ ទុក្កដស្ស ។ គិលានោ គិលានសញ្ញី អនាបត្តិ ។

[៩៤] អនាបត្តិ គិលានស្ស អគិលានោ សកិំ ភុញ្ជតិ គច្ឆន្តោ វា អាគច្ឆន្តោ វា ភុញ្ជតិ សាមិកា និមន្តេត្វា ភោជេន្តិ ឱទិស្ស បញ្ញត្តោ ហោតិ ន យាវទត្ថោ បញ្ញត្តោ ហោតិ បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អាវសថសិក្ខាបទំ និដ្ឋិតំ ។

១ ម. អគិលានោ ។ ២ ម. ឧ. តតុត្តរិ ។



[៩៣] ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមិនមានជម្ងឺ ហើយបរិភោគអាវសថបិណ្ឌបាត ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនមានជម្ងឺ ភិក្ខុមានសេចក្តីសង្ស័យ ហើយបរិភោគអាវសថបិណ្ឌបាត ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមានជម្ងឺ ហើយឆាន់អាវសថបិណ្ឌបាត ឲ្យលើសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថាមិនមានជម្ងឺ ត្រូវអាបត្តិទុក្កដ ។ ខ្លួនមានជម្ងឺ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថាមានជម្ងឺ មិនត្រូវអាបត្តិឡើយ ។

[៩៤] អាបត្តិមិនមាន ដល់ភិក្ខុមានជម្ងឺ ដល់ភិក្ខុមិនមានជម្ងឺឆាន់តែម្តង ដល់ភិក្ខុដែលដើរទៅក្តី ដើរមកក្តី ហើយឆាន់(១) ដល់ភិក្ខុដែលម្ចាស់ទានគេនិមន្តឲ្យឆាន់ ដល់ភិក្ខុដែលឆាន់បិណ្ឌបាតដែលគេដាក់ចំពោះ ដល់ភិក្ខុដែលឆាន់បិណ្ឌបាតដែលគេដាក់តែមិនដល់ មួយចំណែក អាបត្តិមិនមាន ដល់ភិក្ខុព្រោះឆាន់ភោជនដទៃ ក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិកបុគ្គល ។

សិក្ខាបទទី ១ ចប់ ។

១ បានដល់ភិក្ខុមានដំណើរចេញពីស្រុក ១ ទៅស្រុក ១ ចម្ងាយផ្លូវគោលមួយថ្ងៃពេញដូចយ៉ាង ថ្ងៃទីមួយទៅដល់ផ្លូវ ថ្ងៃទីពីរត្រឡប់មកវិញដល់ផ្លូវទៀត ។

## ទុតិយសិក្ខាបទំ

(៤៣) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ទេវទត្តោ បហីនលាភសក្ការោ[១] សបរិសោ កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជិស្សន្តិ កស្ស សម្បន្នំ ន មនាបំ កស្ស សាទុំ[២] ន រុច្ចតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ទេវទត្តោ សបរិសោ កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជិស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ ទេវទត្ត សបរិសោ កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជសីតិ ។

១. ម. បរិហីនលាភសក្ការោ ។ ២ កត្ថចិ បោត្ថកេ សាទុន្តិ ទិស្សតិ ។

## សិក្ខាបទទី ២

(៤៣) សម័យនោះ ព្រះពុទ្ធមានព្រះភាគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ទេវទត្ត មានលាភសក្ការៈសាបសូន្យហើយ ព្រមទាំងបរិសទ្យ គឺនាំគ្នាដើរសូមឡើយៗ ក្នុងត្រកូលហើយឆាន់ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាកូនចៅព្រះពុទ្ធ បុត្រសក្យរាជ មិនគួរនឹងនាំគ្នាដើរសូមឡើយៗ ក្នុងត្រកូលហើយឆាន់សោះ (ឆ្អាតមនុស្ស) អ្នកណាមួយដែលមិនគាប់ចិត្តនឹងភោជនល្អ អ្នកណាមួយដែលមិនពេញចិត្តនឹងភោជនដ៏ឆ្ងាញ់ពិសា ។ ភិក្ខុទាំងឡាយ បានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ទេវទត្តព្រមទាំងបរិសទ្យ មិនគួរនឹងនាំគ្នាដើរសូមឡើយៗ ក្នុងត្រកូលទាំងឡាយហើយឆាន់សោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលទេវទត្ត ឮថាអ្នកព្រមទាំងបរិសទ្យ នាំគ្នាដើរសូមឡើយៗ ក្នុងត្រកូលទាំងឡាយហើយឆាន់ ពិតមែនឬ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស សមណោ កុលេសុ វិញ្ញាបេត្វា វិញ្ញាបេត្វា ភុញ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ គណភោជនេ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៩៤] តេន ខោ បន សមយេន មនុស្សា គិលានេ ភិក្ខូ ភត្តេន និមន្តេន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ បដិក្ខិត្តំ ភគវតា គណភោជនន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា គណភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ គណភោជនេ



ទេវទត្តក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងត្រូវជាបព្វជិត មិនគួរនឹងដើរសូមរឿយ ៗ ក្នុងត្រកូលទាំងឡាយៈហើយឆាន់ទេ ម្នាលមោឃបុរស ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា មិនមែននាំជនទាំងឡាយដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាក្រៃលែងឡើយ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុឆាន់គណភោជន ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយ យ៉ាងនេះ ។

[៩៤] សម័យនោះឯង មនុស្សទាំងឡាយនិមន្តពួកភិក្ខុដែលមានជម្ងឺ ដោយភត្ត ។ ពួកភិក្ខុសង្ស័យមិនទទួលដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ទើបពួកភិក្ខុក្រាបទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងហេតុនេះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជម្ងឺឆាន់គណភោជនបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន

អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៩៨) តេន ខោ បន សមយេន មនុស្សា ចីវរទានសមយេ សចីវរភត្តំ បដិយាទេត្វា ភិក្ខូ និមន្តេន្តិ ភោជេត្វា ចីវរេន អច្ឆាទេស្សាមាតិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ បដិក្ខិត្តំ ភគវតា គណភោជនន្តិ ។ ចីវរំ បរិត្តំ ឧប្បជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចីវរទានសមយេ គណភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ គណភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។



វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(៩៨) សម័យនោះឯង មនុស្សទាំងឡាយ តាក់តែងចង្ហាន់ព្រមទាំងចីវរ ក្នុងសម័យចីវរទាន ហើយនិមន្តភិក្ខុទាំងឡាយថា យើងទាំងឡាយនឹងនិមន្តលោកម្ចាស់ទាំងឡាយឲ្យឆាន់ រួចហើយនឹងប្រគេនចីវរឲ្យស្លៀកដណ្ដប់ ។ ភិក្ខុទាំងឡាយ សង្ស័យមិនទទួលដោយគិតថា គណភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ចីវរកើតឡើងដល់ភិក្ខុដោយស្ដួចស្ដើង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយឆាន់គណភោជនក្នុងសម័យចីវរទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ ១ សម័យដែលគេឲ្យចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៩៦] តេន ខោ បន សមយេន មនុស្សា ចីវរការកេ ភិក្ខូ ភត្តេន និមន្តេន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ បដិក្ខិត្តំ ភគវតា គណភោជនន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចីវរការសមយេ គណភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ គណភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ ចីវរការសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៩៧] តេន ខោ បន សមយេន ភិក្ខូ មនុស្សេហិ សទ្ធឹ អទ្ធានំ គច្ឆន្តិ ។ អថខោ តេ ភិក្ខូ តេ មនុស្សេ ឯតទវោចុំ មុហុត្តំ អាវុសោ អាគមេថ បិណ្ឌាយ ចរិស្សាមាតិ ។ តេ ឯវមាហំសុ ឥធេវ ភន្តេ ភុញ្ជថាតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ



[៩៦] សម័យនោះឯង មនុស្សទាំងឡាយ និមន្តពួកភិក្ខុដែលជាអ្នកធ្វើចីវរ ដោយភត្ត ។ ភិក្ខុទាំងឡាយ សង្ស័យមិនទទួល ដោយគិតថា គណភោជន ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជនបាន ក្នុងសម័យដែលធ្វើចីវរ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺសម័យដែលមានជម្ងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៩៧] សម័យនោះឯង ភិក្ខុទាំងឡាយដើរកាត់ផ្លូវឆ្ងាយមួយអន្លើដោយមនុស្សទាំងឡាយ ។ ឯភិក្ខុទាំងនោះនិយាយពាក្យនេះនឹងមនុស្សទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយចូរបង្អង់ចាំ ១ រំពេច យើងទាំងឡាយនឹងត្រាច់ទៅដើម្បីបិណ្ឌបាត ។ មនុស្សទាំងនោះនិយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយនិមន្តឆាន់ក្នុងទីនេះចុះ ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួលដោយគិតថា

បដិក្ខិត្តំ ភគវតា គណភោជនន្តិ ។ ភគវតោ ឯត-
មត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អទ្ធាន-
គមនសមយេ គណភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន
ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ គណភោជនេ
អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ
គិលានសមយោ ចីវរទានសមយោ ចីវរការសមយោ
អទ្ធានគមនសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ
ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៤៨] តេន ខោ បន សមយេន ភិក្ខូ មនុស្សេ-
ហិ សទ្ធឹ នាវាយ គច្ឆន្តិ ។ អថខោ តេ ភិក្ខូ
តេ មនុស្សេ ឯតទវោចុំ មុហុត្តំ អាវុសោ តីរំ
ទាវ[1] ឧបនេថ បិណ្ឌាយ ចរិស្សាមាតិ ។ តេ
ឯវមាហំសុ ឥធេវ អយ្យា ភុញ្ជថាតិ ។ ភិក្ខូ
កុក្កុច្ចាយន្តា ន បដិគ្គណ្ហន្តិ បដិក្ខិត្តំ ភគវតា

១ ម. យ. បោត្ថកេសុ អយំ បាឋោ ន ហោតិ ។



គណភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយក្រាប
ទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ
ទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជន ក្នុងសម័យដែល
ដើរផ្លូវឆ្ងាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវ
សិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណ-
ភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ
សម័យដែលមានជំងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែល
ធ្វើចីវរ ១ សម័យដែលដើរកាត់ផ្លូវឆ្ងាយ ១ នេះជាសម័យក្នុងសិក្ខា-
បទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់
ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៤៨] សម័យនោះឯង ភិក្ខុទាំងឡាយទៅដោយទូកមួយអន្លើ
ដោយមនុស្សទាំងឡាយ ។ ឯភិក្ខុទាំងនោះនិយាយពាក្យនេះនឹងមនុស្ស
ទាំងនោះថា ម្នាលអាវុសោ អ្នកទាំងឡាយ ចូរបង្ខូកទៀបឆ្នេរមួយរំពេច
សិន យើងទាំងឡាយនឹងត្រូវទៅដើម្បីបិណ្ឌបាត ។ មនុស្សទាំង-
ឡាយនោះនិយាយយ៉ាងនេះថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់
ទាំងឡាយឆាន់ក្នុងទីនេះចុះ ។ ភិក្ខុទាំងឡាយសង្ស័យមិនហ៊ាន
ទទួលដោយគិតថា គណភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។

គណភោជនន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ នាវាភិរុហនសមយេ គណភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ គណភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ ចីវរការសមយោ អទ្ធានគមនសមយោ នាវាភិរុហនសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៨៨] តេន ខោ បន សមយេន ទិសាសុ វស្សំវុដ្ឋា ភិក្ខូ រាជគហំ អាគច្ឆន្តិ ភគវន្តំ ទស្សនាយ ។ មនុស្សា នានាវេរជ្ជកេ ភិក្ខូ បស្សិត្វា និមន្តេន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ បដិក្ខិត្តំ ភគវតា គណភោជនន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ មហាសមយេ គណភោជនំ



ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុបាន់គណភោជនក្នុងសម័យឡើងជិះទូកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយព្រោះបាន់គណភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជំងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើចីវរ ១ សម័យដែលដើរទៅកាន់ផ្លូវឆ្ងាយ ១ សម័យដែលឡើងជិះទូក ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៨៨] សម័យនោះឯង ភិក្ខុទាំងឡាយ នៅចាំវស្សាក្នុងទិសទាំងឡាយ លុះចេញវស្សាហើយ ក៏នាំគ្នាមកឯក្រុងរាជគ្រឹះ ដើម្បីគាល់ព្រះដ៏មានព្រះភាគ ។ ពួកមនុស្សឃើញភិក្ខុទាំងឡាយមកពីដែនសីមា(*) ផ្សេងៗគ្នា ហើយក៏និមន្តទៅ ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួលដោយសំគាល់ថា គណភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យអ្នកទាំងឡាយបាន់

* ភិក្ខុអាគន្តុកក្រុងដទៃ ប្រទេសដទៃ ដែនដទៃ ។

ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ-សេយ្យាថ គណភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ ចីវរការសមយោ អទ្ធានគមនសមយោ នាវាភិរុហន-សមយោ មហាសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១០០] តេន ខោ បន សមយេន រញ្ញោ មាគ-ធស្ស សេនិយស្ស ពិម្ពិសារស្ស ញាតិសាលោហិតោ អាជីវកេសុ បព្វជិតោ ហោតិ ។ អថខោ សោ អាជីវកោ យេន រាជា មាគធោ សេនិយោ ពិម្ពិសារោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ មាគធំ សេនិយំ ពិម្ពិសារំ ឯតទវោច ឥច្ឆាមហំ មហារាជ សព្វបា-សណ្ឌិកភត្តំ[១] កាតុន្តិ ។ សចេ ត្វំ ភន្តេ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បឋមំ ភោជេយ្យាសិ ឯវំ ករេយ្យាមីតិ ។

១ ឱ. ម. សព្វបាសណ្ឌិកភត្តំ ។



គណភោជនក្នុងសម័យជាបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺ សម័យដែលមានជម្ងឺ ១ សម័យដែលគេប្រគេនចីវរ ១ សម័យដែលធ្វើនូវចីវរ ១ សម័យដែលទៅកាន់ផ្លូវឆ្ងាយ ១ សម័យដែលឡើងជិះទូក ១ សម័យដែលមានភិក្ខុច្រើន ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០០] សម័យនោះឯង (មានបុរសម្នាក់) ត្រូវជាញាតិសាលោ-ហិតរបស់ព្រះបាទមាគធសេនិយពិម្ពិសាររាជ បានបួសក្នុងសំណាក់អាជី-វកទាំងឡាយ ។ លំដាប់នោះ អាជីវកនោះចូលទៅគាល់ព្រះបាទ មាគធសេនិយពិម្ពិសាររាជ ហើយបានទូលពាក្យនេះចំពោះព្រះបាទ មាគធសេនិយពិម្ពិសាររាជថា បពិត្រមហារាជ អាត្មាប្រាថ្នាដើម្បីធ្វើ នូវភត្តជារបៀបបាសណ្ឌៈសព្វ[១] ។ ព្រះបាទមាគធសេនិយពិម្ពិសា-រាជត្រាស់ថា បពិត្រលោកដ៏ចំរើន បើលោកនិមន្តភិក្ខុសង្ឃមានព្រះពុទ្ធ ជាប្រធានឆាន់មុនសិន (ទើប) យើងត្រូវធ្វើយ៉ាងនេះ (បាន) ។

១ គឺរបៀបធ្វើភត្តរបស់មិច្ឆាទិដ្ឋិ ក្រៅពីព្រះពុទ្ធសាសនា ។

អថខោ សោ អាជីវកោ ភិក្ខូនំ សន្តិកេ ទូតំ បាហេសិ អធិវាសេន្តុ មេ ភិក្ខូ ស្វាតនាយ ភត្តន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ បដិក្ខិត្តំ ភគវតា គណភោជនន្តិ ។ អថខោ សោ អាជីវកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សោ អាជី-វកោ ភគវន្តំ ឯតទវោច ភវំបិ គោតមោ បព្វជិតោ អហំបិ បព្វជិតោ អរហតិ បព្វជិតោ បព្វជិតស្ស បិណ្ឌំ បដិគ្គហេតុំ អធិវាសេតុ មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សោ អាជីវកោ ភគវតោ អធិវាសនំ វិទិត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ សមណភត្តសមយេ គ-ណភោជនំ ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ



អាជីវកនោះក៏ប្រើបម្រើទៅកាន់សំណាក់ភិក្ខុទាំងឡាយ ក្នុងវេលានោះថា ភិក្ខុទាំងឡាយសូមទទួលចង្ហាន់របស់ខ្ញុំដើម្បីភត្តក្នុងថ្ងៃស្អែក ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួលដោយគិតថា គណភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ គ្រានោះ អាជីវកនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ ដល់ហើយក៏ពោលពាក្យរាក់ទាក់ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ ដែលគួររលឹកស្រេចហើយ ក៏ឈរនៅក្នុងទីដ៏សមគួរ ។ អាជីវកនោះលុះឈរនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា ព្រះគោ-តមដ៏ចំរើនជាអ្នកបួស ទាំងខ្ញុំព្រះអង្គក៏ជាអ្នកបួសដែរ អ្នកបួសគួរទទួលដុំបាយរបស់អ្នកបួសផងគ្នា ព្រះគោតមដ៏ចំរើន សូមទទួលចង្ហាន់របស់ខ្ញុំព្រះអង្គដើម្បីភត្តក្នុងថ្ងៃស្អែក មួយអន្លើដោយភិក្ខុសង្ឃ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ អាជីវកនោះដឹងច្បាស់ថាព្រះដ៏មានព្រះភាគទទួលនិមន្តហើយក៏ចៀសចេញទៅក្នុងវេលានោះ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកប្រជុំក្នុងវេលានោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់គណភោជនក្នុងសម័យនៃសមណភត្តបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា

ទ្ទិសេយ្យាថ គណភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ ចីវរការសមយោ អទ្ធានគមនសមយោ នាវាភិរូហនសមយោ មហាសមយោ សមណភត្តសមយោ អយំ តត្ថ សមយោតិ ។

[៣០៣] គណភោជនំ នាម យត្ថ ចត្តារោ ភិក្ខូ បញ្ចន្នំ ភោជនានំ អញ្ញតរេន ភោជនេន និមន្តិតា ភុញ្ជន្តិ ឯតំ គណភោជនំ នាម ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ គិលានសមយោ នាម អន្តមសោ បាទាបិ ផាលិតា ហោន្តិ ។ គិលានសមយោតិ ភុញ្ជិតព្វំ ។ ចីវរទានសមយោ នាម អនត្ថតេ កឋិនេ វស្សានស្ស បច្ឆិមោ មាសោ អត្ថតេ កឋិនេ បញ្ច មាសា ។ ចីវរទានសមយោតិ ភុញ្ជិតព្វំ ។ ចីវរការសមយោ នាម



ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់គណភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលមានជម្ងឺ១ សម័យដែលគេប្រគេនចីវរ១ សម័យដែលធ្វើចីវរ១ សម័យដែលដើរផ្លូវឆ្ងាយ១ សម័យដែលឡើងជិះទូក១ សម័យដែលមានភិក្ខុច្រើនអង្គ១ សម័យនៃសមណភត្ត១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[១០១] ដែលហៅថា គណភោជន គឺភិក្ខុ៤រូបដែលគេនិមន្តឲ្យឆាន់ ឈ្មោះភោជន៥ប្រការ ដោយភោជនណាមួយ ហើយឆាន់ភោជនណា ភោជននុ៎ះ ហៅថា គណភោជន ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកទុកតែមានសម័យ (គឺហេតុដែលគួរនឹងឆាន់បាន) ។ ដែលហៅថា សម័យមានជម្ងឺ ដោយហោចទៅសូម្បីតែជើងទាំងទ្វាយដែលបែក (ធ្លាក់ឆ្អឹងក៏ហៅថាមានជម្ងឺ) ។ ភិក្ខុដឹងថាខ្លួនមានសម័យណាមួយក្តី ហើយគប្បីឆាន់គណភោជនបាន ។ ដែលហៅថា សម័យដែលគេប្រគេនចីវរ គឺជាកាលបើភិក្ខុមិនបានក្រាលកឋិនទេ (សម័យនៃចីវរទាន) បានត្រឹមតែ១ខែ គឺខែជាខាងចុងនៃវស្សានរដូវ[១] បើភិក្ខុបានក្រាលកឋិន (សម័យនៃចីវរទាន) បាន៥ខែ[២] ។ ភិក្ខុដឹងថាមានសម័យនៃចីវរទាន ហើយគប្បីឆាន់គណភោជនបាន ។ ដែលហៅថា សម័យដែលធ្វើចីវរ

១ គឺតាំងពីថ្ងៃ១ រោចខែអស្សុជ ទៅដល់ថ្ងៃពេញបូណ៌មីខែកត្តិក ។ ២ គឺតាំងពីថ្ងៃ១ រោចខែអស្សុជ ទៅដល់ថ្ងៃពេញបូណ៌មីខែផល្គុន ។

ចីវរេ កយិរមានេ ។ ចីវរការសមយោតិ ភុញ្ជិតព្វំ ។
អទ្ធានគមនសមយោ នាម អឌ្ឍយោជនំ គមិស្សាមីតិ
ភុញ្ជិតព្វំ ។ គច្ឆន្តេន ភុញ្ជិតព្វំ ។ គតេន ភុញ្ជិ-
តព្វំ ។ នាវាភិរុហនសមយោ នាម នាវំ អភិរុហិស្សាមីតិ
ភុញ្ជិតព្វំ ។ អារូឡ្ហេន ភុញ្ជិតព្វំ ។ ឱរូឡ្ហេន ភុញ្ជិ-
តព្វំ ។ មហាសមយោ នាម យត្ថ ទ្វេ តយោ ភិក្ខូ
បិណ្ឌាយ ចរិត្វា យាបេន្តិ ចតុត្ថេ អាគតេ ន យាបេន្តិ ។
មហាសមយោតិ ភុញ្ជិតព្វំ ។ សមណភត្តសមយោ
នាម យោ កោចិ បរិព្វាជកសមាបន្នោ ភត្តំ ករោ-
តិ ។ សមណភត្តសមយោតិ ភុញ្ជិតព្វំ ។ អញ្ញត្រ ស-
មយា ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។
អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។





ក៏កាលដែលភិក្ខុកំពុងធ្វើចីវរ ។ ភិក្ខុដឹងថា មានសម័យជាទីធ្វើចីវរហើយ
គប្បីឆាន់គណភោជនបាន ។ ដែលហៅថា សម័យដែលដើរផ្លូវឆ្ងាយ
គឺភិក្ខុដឹងថា អាត្មានឹងដើរផ្លូវឆ្ងាយប្រមាណកន្លះយោជន៍ ហើយគប្បីឆាន់
គណភោជនបាន ។ កាលភិក្ខុកំពុងដើរទៅ ក៏គប្បីឆាន់គណភោជន
បាន ។ កាលភិក្ខុមកវិញ ក៏គប្បីឆាន់គណភោជនបាន ។ ដែលហៅថា
សម័យឡើងជិះទូក គឺភិក្ខុដឹងថា អាត្មានឹងឡើងជិះទូក ហើយគប្បីឆាន់
គណភោជនបាន ។ ភិក្ខុឡើងជិះទូកហើយ គប្បីឆាន់គណភោជនបាន ។
កាលភិក្ខុចុះអំពីទូកហើយ គប្បីឆាន់គណភោជនបាន ។ ដែលហៅថា
សម័យមានភិក្ខុច្រើនអង្គ គឺសម័យដែលភិក្ខុពីរបីរូបអង្គ ត្រាច់ទៅ
ដើម្បីបិណ្ឌបាតហើយបានឆាន់ឆ្អែតគ្រប់ចំណោម កាលភិក្ខុមួយអង្គមកទៀត
ត្រូវជាបួនអង្គ ឆាន់មិនឆ្អែត ។ ភិក្ខុដឹងថា សម័យមានភិក្ខុច្រើនអង្គដូច្នេះ
ហើយគប្បីឆាន់គណភោជនបាន ។ ដែលហៅថា សម័យនៃសមណភត្ត
គឺអ្នកណាមួយដែលរាប់បញ្ចូលក្នុងពួកអ្នកបួស (ក្រៅពីពុទ្ធសាសនា)
ធ្វើភត្ត ។ ភិក្ខុដឹងថា សម័យនៃសមណភត្តហើយ គប្បីឆាន់គណភោជន
បាន ។ ភិក្ខុទទួលគណភោជនដោយគិតថា អាត្មានឹងបរិភោគ ត្រូវអាបត្តិ
ទុក្កដ វៀរលែងតែមានសម័យ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ពំនូត
ដែលលេបចូលទៅក ។

[១០២] គណភោជនេ គណភោជនសញ្ញី អញ្ញត្រ សមយា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ គណភោជនេ វេមតិកោ អញ្ញត្រ សមយា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ គណភោជនេ អគណភោជនសញ្ញី អញ្ញត្រ សមយា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អគណភោជនេ គណភោជនសញ្ញី អាបត្តិ ទុក្កដស្ស ។ អគណភោជនេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អគណភោជនេ អគណភោជនសញ្ញី អនាបត្តិ ។

[១០៣] អនាបត្តិ សមយេ ទ្វេ តយោ ឯកតោ ភុញ្ជន្តិ បិណ្ឌាយ ចរិត្វា ឯកតោ សន្និបតិត្វា ភុញ្ជន្តិ និច្ចភត្តេ សលាកភត្តេ បក្ខិកេ ឧបោសថិកេ បាដិបទិកេ បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។





[១០២] គណភោជន ភិក្ខុសំគាល់ថាគណភោជនមែន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសង្ស័យក្នុងគណភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសំគាល់ក្នុងគណភោជនថា មិនមែនគណភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មិនមែនគណភោជន ភិក្ខុសំគាល់ថាគណភោជន ត្រូវអាបត្តិទុក្កដ ។ មិនមែនគណភោជន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនគណភោជន ភិក្ខុសំគាល់ថា មិនមែនគណភោជន មិនត្រូវអាបត្តិ ។

[១០៣] អាបត្តិមិនមាន ដល់ភិក្ខុមានសម័យ ដល់ភិក្ខុទាំងឡាយពីរឬបីអង្គដែលឆាន់ជាមួយគ្នា ដល់ភិក្ខុទាំងឡាយដែលត្រាច់ទៅដើម្បីបិណ្ឌបាត ហើយប្រជុំគ្នាឆាន់ក្នុងទីជាមួយគ្នា ដល់ភិក្ខុដែលឆាន់និច្ចភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត អាបត្តិមិនមាន ដល់ភិក្ខុដែលឆាន់ភោជនទាំងពួង ក្រៅពីភោជន ៥ យ៉ាង ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់ ។

## តតិយសិក្ខាបទំ

(១០៦) តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន វេសាលិយំ បណីតានំ ភត្តានំ ភត្តបដិបាដិ អធិដ្ឋិតា ហោតិ ។ អថខោ អញ្ញតរស្ស ទលិទ្ទស្ស កម្មការស្ស ឯតទហោសិ ន ខោ ឥទំ ឱរកំ ភវិស្សតិ យថយិមេ[១] មនុស្សា សក្កច្ចំ ភត្តំ ករោន្តិ យន្នូន[២]ហម្បិ ភត្តំ ករេយ្យន្តិ ។ អថខោ សោ ទលិទ្ទោ កម្មការោ យេន កិរបតិកោ តេនុបសង្កមិ ឧបសង្កមិត្វា កិរបតិកំ ឯតទវោច ឥច្ឆាមហំ អយ្យបុត្ត ពុទ្ធប្បមុខស្ស ភិក្ខុសង្ឃស្ស ភត្តំ កាតុំ ទេហិ មេ វេតនន្តិ ។ សោបិ ខោ កិរបតិកោ សទ្ធោ ហោតិ បសន្នោ ។ អថខោ សោ កិរបតិកោ តស្ស ទលិទ្ទស្ស កម្មការស្ស អតិរេកំ[៣] វេតនំ[៤] អទាសិ ។ អថខោ សោ ទលិទ្ទោ កម្មការោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា

១ ឱ. ម. យថយិមេ ។ ២ ឱ. ម. យំនូនាហំ ។ ៣ ឱ. ម. អគ្គតិរេកំ ។ ៤ វេត្តនន្តិ បាឋោ ។

## សិក្ខាបទទី ៣

(១០៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងកូដាគារសាលា ក្នុងមហាវ័ន ក្បែរក្រុងវេសាលី ។ សម័យនោះឯង ក្នុងក្រុងវេសាលីគេបានចាត់ចែងភត្តដ៏ឧត្តមទាំងឡាយតាមវេនជាលំដាប់ ។ គ្រានោះ អ្នកធ្វើការម្នាក់ជាមនុស្សទាល់ក្រ មានសេចក្ដីត្រិះរិះដូច្នេះថា មនុស្សទាំងឡាយនេះធ្វើភត្តដោយគោរព តាមទំនងយ៉ាងណា (ទំនង) នេះមិនមែនជាថោកទាបឡើយ បើដូច្នោះ មានតែអញត្រូវធ្វើភត្តទីទៃដែរ ។ ឯអ្នកធ្វើការដែលជាមនុស្សទាល់ក្រនោះ ចូលទៅរកបុរសឈ្មោះកិរបតិក លុះចូលទៅហើយក៏ពោលពាក្យនេះនឹងបុរសឈ្មោះកិរបតិកនោះថា បពិត្រអយ្យបុត្រ ខ្ញុំប្រាថ្នាដើម្បីធ្វើភត្តដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន សូមអ្នកឲ្យថ្លៃឈ្នួលមកខ្ញុំចុះ ។ បុរសឈ្មោះកិរបតិកនោះឯង ក៏ជាមនុស្សមានសទ្ធាជ្រះថ្លាដែរ ។ ឯបុរសឈ្មោះកិរបតិកនោះ បានឲ្យថ្លៃឈ្នួលច្រើនក្រៃលែងដល់អ្នកធ្វើការដែលជាមនុស្សទាល់ក្រនោះ ។ គ្រានោះ អ្នកធ្វើការដែលជាមនុស្សទាល់ក្រនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយនៅ

ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ទលិទ្ទោ កម្មការោ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ មហា ខោ អាវុសោ ភិក្ខុសង្ឃោ ជានាហីតិ ។ ហោតុ ភន្តេ មហា ភិក្ខុសង្ឃោ ពហូ មេ ពទរា បដិយត្តា ពទរមិស្សេន(១) បេយ្យា បរិបូរិស្សន្តីតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថ ខោ សោ ទលិទ្ទោ កម្មការោ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អស្សោសុំ ខោ ភិក្ខូ ទលិទ្ទេន កិរ កម្មការេន ស្វាតនាយ ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោ ពទរមិស្សេន បេយ្យា បរិបូរិស្សន្តីតិ ។ តេ កាលស្សេវ បិណ្ឌាយ ចរិត្វា ភុញ្ជឹសុ ។ អស្សោសុំ ខោ មនុស្សា ទលិទ្ទេន កិរ កម្មការេន ពុទ្ធប្បមុខោ ភិក្ខុសង្ឃោ និមន្តិតោតិ ។ តេ ទលិទ្ទស្ស កម្មការស្ស បហូតំ ខាទនីយំ ភោជនីយំ អភិហរឹសុ ។

---

១ ម. ពទរមិស្សេន ។



ក្នុងទីដ៏សមគួរ ។ លុះបុរសកម្មករកំសត់ដែលជាមនុស្សទ័លក្រនោះ លុះអង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ព្រះដ៏មានព្រះភាគសូមទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃស្អែកមួយអន្លើដោយភិក្ខុសង្ឃ ។ ព្រះអង្គត្រាស់ថា ម្នាលអាវុសោ ភិក្ខុសង្ឃច្រើនណាស់ អ្នកចូរដឹងចុះ ។ បុរសកំសត់ក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ភិក្ខុសង្ឃច្រើនក៏ច្រើនចុះ (ព្រោះ) ផ្លែពុទ្រាមានប្រមាណច្រើន ខ្ញុំព្រះអង្គបានតាក់តែងហើយ ស្លចំណីទាំងឡាយនឹងបរិបូណ៌ដោយបបរលាយដោយផ្លែពុទ្រា ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ គ្រានោះ បុរសកម្មករកំសត់នោះដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ភិក្ខុទាំងឡាយបានឮដំណឹងថា ឮថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន អ្នកធ្វើការស៊ីឈ្នួលកំសត់បាននិមន្តហើយដើម្បីភត្តកិច្ចក្នុងថ្ងៃស្អែក ស្លចំណីទាំងឡាយនឹងបរិបូណ៌ដោយបបរលាយដោយផ្លែពុទ្រា ។ ភិក្ខុទាំងនោះត្រាច់ទៅដើម្បីបិណ្ឌបាតហើយឆាន់តាំងពីព្រឹក ។ មនុស្សទាំងឡាយបានឮដំណឹងថា ឮថា ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន អ្នកធ្វើការស៊ីឈ្នួលកំសត់បាននិមន្តហើយ ។ មនុស្សទាំងនោះ

អថខោ សោ ទលិទ្ទោ កម្មារោ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវតោ កាលំ អារោចាបេសិ[1] កាលោ ភន្តេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តស្ស ទលិទ្ទស្ស កម្មារស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ អថខោ សោ ទលិទ្ទោ កម្មារោ សក្កច្ចំ ភិក្ខូ បរិវិសតិ ។ ភិក្ខូ ឯវមាហំសុ ថោកំ អាវុសោ ទេហិ ថោកំ អាវុសោ ទេហីតិ ។ មា ខោ តុម្ហេ ភន្តេ អយំ ទលិទ្ទោ កម្មារោតិ ថោកំ ថោកំ បដិគ្គណ្ហិត្ថ បហូតំ មេ ខាទនីយំ ភោជនីយំ បដិយត្តំ បដិគ្គណ្ហថ ភន្តេ យាវទត្ថន្តិ ។ ន មយំ អាវុសោ ឯតំ ការណា ថោកំ ថោកំ បដិគ្គណ្ហាម អបិច មយំ កាលស្សេវ បិណ្ឌាយ ចរិត្វា ភុត្តា តេន មយំ

១ អារោចេសីតិ បាឋោ ។



ទាំងខាទនីយភោជនីយៈ មានប្រមាណច្រើនទៅ ដើម្បីអ្នកធ្វើការដែកដ៏កំសត់ (នោះ) ។ លុះព្រឹកឡើង ទើបអ្នកធ្វើការដែកដ៏កំសត់នោះ ឲ្យមនុស្សតាក់តែងខាទនីយភោជនីយដ៏ឧត្តម ហើយឲ្យគេក្រាបទូលនូវកាលកំណត់ចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលគួរហើយ ភត្តសម្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ ហើយប្រដាប់ដោយបាត្រនិងចីវរពេលព្រឹក រួចហើយយាងចូលទៅកាន់លំនៅអ្នកធ្វើការដែកដ៏កំសត់នោះ លុះចូលទៅដល់ហើយក៏គង់លើអាសនៈ ដែលគេតាក់តែងថ្វាយ មួយអន្លើដោយភិក្ខុសង្ឃ ។ ទើបអ្នកធ្វើការដែកដ៏កំសត់នោះក៏អង្គាសភិក្ខុទាំងឡាយដោយគោរព ។ ពួកភិក្ខុពោលយ៉ាងនេះថា ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចហើយ ម្នាលអាវុសោ អ្នកចូរឲ្យតែបន្តិចហើយ ។ អ្នកធ្វើការដែកដ៏កំសត់នោះទូលថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន លោកម្ចាស់ទាំងឡាយកុំទទួលនូវតែបន្តិចៗ ដោយគិតថា អ្នកធ្វើការដែកនេះជាមនុស្សកំសត់ឡើយ (ព្រោះ) ខាទនីយភោជនីយមានប្រមាណច្រើន ខ្ញុំព្រះករុណាឲ្យគេតាក់តែងហើយ បពិត្រលោកម្ចាស់ទាំងឡាយ សូមលោកម្ចាស់ទាំងឡាយទទួល(ទាន)ត្រាតែឆ្អែត ។ ពួកភិក្ខុតបថា ម្នាលអាវុសោ យើងទាំងឡាយទទួលតែបន្តិចៗ ព្រោះតែហេតុនេះ ក៏មិនមែនទេ មួយទៀតយើងទាំងឡាយត្រាច់ទៅដើម្បីបិណ្ឌបាត

ថោកំ ថោកំ បដិគ្គណ្ហាមាតិ ។ អថខោ សោ ទលិទ្ទោ
កម្មការោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម
ភទ្ទន្តា មយា និមន្តិតា អញ្ញត្រ ភុញ្ជិស្សន្តិ ន ចាហំ
បដិពលោ យាវទត្ថំ ទាតុន្តិ ។ អស្សោសុំ ខោ ភិក្ខូ
តស្ស ទលិទ្ទស្ស កម្មការស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស
វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ
ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ
អញ្ញត្រ និមន្តិតា អញ្ញត្រ ភុញ្ជិស្សន្តីតិ ។ បេ ។
សច្ចំ កិរ ភិក្ខវេ ភិក្ខូ អញ្ញត្រ និមន្តិតា អញ្ញត្រ
ភុញ្ជិស្សន្តីតិ(១) ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា
អញ្ញត្រ និមន្តិតា អញ្ញត្រ ភុញ្ជិស្សន្តិ នេតំ ភិក្ខវេ
អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ
។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ

១ ម. ឧ. ភុញ្ជន្តីតិ ។



ឆាន់តាំងពីព្រឹកហើយ ហេតុនោះ បានជាយើងទាំងឡាយទទួលតែ
បន្តិច ៗ ម្តង ។ លំដាប់នោះ អ្នកធ្វើការស៊ីឈ្នួលកំសត់នោះពោលទោស
តិះដៀល បន្ទុះបង្អាប់ថា មិនសមបើលោកទាំងឡាយដ៏ចំរើនខ្ញុំបាននិមន្ត
ហើយមិនគួរនឹងទៅឆាន់ក្នុងទីដទៃសោះ ម្យ៉ាងខ្ញុំមិនអាចដើម្បីប្រគេនឲ្យឆាន់
ឆ្អែតទេឬ ។ ភិក្ខុទាំងឡាយបានឮអ្នកធ្វើការស៊ីឈ្នួលកំសត់នោះពោលទោស
តិះដៀល បន្ទុះបង្អាប់ (ដូច្នោះ) ហើយ ។ ភិក្ខុទាំងឡាយណាមាន
សេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល
បន្ទុះបង្អាប់ថា ពួកភិក្ខុដែលគេបាននិមន្តក្នុងទីដទៃហើយ មិនគួរនឹងឆាន់
ក្នុងទីដទៃសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ
ឮថាពួកភិក្ខុដែលគេបាននិមន្តក្នុងទីដទៃហើយ ត្រឡប់ឆាន់ក្នុងទីដទៃវិញ
ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិត
មែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ
មោឃបុរសទាំងនោះគេបាននិមន្តក្នុងទីដទៃហើយ មិនគួរនឹងឆាន់ ក្នុង
ទីដទៃ ម្នាលភិក្ខុទាំងឡាយ ការនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំង
ឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនទាំងឡាយដែលជ្រះថ្លាហើយឲ្យរឹត
តែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ-
គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ

បរម្បរភោជនេ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១០៩] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ គិលានោ ហោតិ ។ អញ្ញតរោ ភិក្ខុ បិណ្ឌបាតំ អាទាយ យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច ភុញ្ជាហាវុសោតិ ។ អលំ អាវុសោ អត្ថិ មេ ភត្តបច្ចាសាតិ ។ តស្ស ភិក្ខុនោ បិណ្ឌបាតោ ឧស្សូរេ អាហរិយិត្ថ ។ សោ ភិក្ខុ ន ចិត្តរូបំ ភុញ្ជិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា បរម្បរភោជនំ ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ បរម្បរភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ



ព្រោះឆាន់បរម្បរភោជន[1] (គឺភោជនដែលគេនិមន្តខាងក្រោយ) សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៩] សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺ ។ ភិក្ខុ១រូបទៀតកាន់យកបិណ្ឌបាតចូលទៅរកភិក្ខុនោះ លុះចូលទៅហើយបាននិយាយពាក្យនេះនឹងភិក្ខុនោះថា ម្នាលអាវុសោ លោកចូរឆាន់ ។ ភិក្ខុមានជម្ងឺនោះឆ្លើយថា ម្នាលអាវុសោ កុំឡើយ ចង្ហាន់ដែលគេប្រមើលឲ្យខ្ញុំមានហើយ ។ បិណ្ឌបាតដែលគេនាំយកមកប្រគេនភិក្ខុនោះក្នុងពេលថ្ងៃត្រង់ ។ ភិក្ខុមានជម្ងឺនោះឆាន់មិនបានដោយស្រួលសោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុមានជម្ងឺឆាន់បរម្បរភោជនបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ

---

[1] ព្រោះភិក្ខុនោះទទួលនិមន្តឆាន់ភោជន៥យ៉ាង ក្នុងផ្ទះណាមួយក្នុងទីឯណោះ ហើយត្រឡប់ទៅឆាន់ក្នុងទីឯណេះវិញ ឬទទួលនិមន្តឆាន់ក្នុងទីឯណេះ ហើយត្រឡប់មកឆាន់ក្នុងទីឯណោះវិញ ។

គិលានសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១០៦] តេន ខោ បន សមយេន មនុស្សា ចីវរទានសមយេ សចីវរភត្តំ បដិយាទេត្វា ភិក្ខូ និមន្តេន្តិ ភោជេត្វា ចីវរេន អច្ឆាទេស្សាមាតិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ បដិក្ខិត្តំ ភគវតា បរម្បរភោជនន្តិ ។ ចីវរំ បរិត្តំ ឧប្បជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចីវរទានសមយេ បរម្បរភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ បរម្បរភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១០៧] តេន ខោ បន សមយេន មនុស្សា ចីវរការកេ ភិក្ខូ ភត្តេន និមន្តេន្តិ ។ ភិក្ខូ កុក្កុច្ចាយន្តា



សម័យដែលភិក្ខុមានជម្ងឺ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៦] សម័យនោះឯង មនុស្សទាំងឡាយ តាក់តែងភត្តព្រមទាំងចីវរក្នុងសម័យនៃចីវរទាន ហើយនិមន្តភិក្ខុទាំងឡាយថា ពួកយើងនឹងនិមន្តលោកម្ចាស់ទាំងឡាយឆាន់ រួចនឹងប្រគេនចីវរឲ្យស្លៀកដណ្តប់ ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួលដោយគិតថា បរម្បរភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ចីវរក៏កើតឡើងដល់ភិក្ខុដោយស្តួចស្តើង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់បរម្បរភោជនក្នុងសម័យនៃចីវរទាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យដែលភិក្ខុមានជម្ងឺ ១ សម័យនៃចីវរទាន ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១០៧] សម័យនោះឯង មនុស្សទាំងឡាយ និមន្តពួកភិក្ខុជាអ្នកធ្វើចីវរឲ្យឆាន់ភត្ត ។ ភិក្ខុទាំងឡាយសង្ស័យមិនទទួលដោយគិតថា

ចាតិកសេត្តិ បដិក្ខិត្តំ ភគវតា បរម្បរភោជនន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចីវរការសមយេ បរម្បរភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ បរម្បរភោជនេ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ គិលានសមយោ ចីវរទានសមយោ ចីវរការសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១០៨] អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ អាយស្មតា អានន្ទេន បច្ឆាសមណេន យេន អញ្ញតរំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ តេ មនុស្សា ភគវតោ ច អាយស្មតោ ច អានន្ទស្ស ភោជនំ អទំសុ ។ អាយស្មា អានន្ទោ កុក្កុច្ចាយន្តោ ន បដិគ្គណ្ហាតិ ។ គណ្ហាហិ អានន្ទាតិ ។ អលំ



បរម្បរភោជនព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាល ភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់បរម្បរភោជន ក្នុងសម័យជាទី ធ្វើចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវ សិក្ខាបទនេះយ៉ាងនេះថា ភិក្ខុត្រូវបាចិត្តិយ ព្រោះឆាន់បរម្បរភោជន វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ សម័យ ដែលភិក្ខុមានជម្ងឺ១ សម័យនៃចីវរទាន១ សម័យជាទីធ្វើចីវរ១ នេះជា សម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបាន បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(១០៨) គ្រានោះ វេលាបុព្វណ្ហសម័យ ព្រះដ៏មានព្រះភាគទ្រង់ ស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរ មានព្រះអានន្ទដ៏មានអាយុ ជាបច្ឆាសមណៈ ព្រះអង្គទ្រង់យាងចូលទៅកាន់ត្រកូល ១ លុះចូលទៅ ហើយក៏ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ ទើបមនុស្សទាំង ឡាយនោះបានថ្វាយភោជនដល់ព្រះដ៏មានព្រះភាគផង ដល់ព្រះអានន្ទ ដ៏មានអាយុផង ។ ព្រះអានន្ទដ៏មានអាយុសង្ស័យ មិនហ៊ានទទួល ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ អ្នកទទួលចុះ ។ ព្រះអានន្ទក្រាបទូលថា

កតកំ អត្ថិ តេ ភត្តប្បច្ចាសាតិ ។ តេនហានន្ទ វិកប្បេត្វា ភុញ្ជាហីតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ភត្តប្បច្ចាសំ(១) វិកប្បេត្វា បរម្បរភោជនំ ភុញ្ជិតុំ ។ ឯវញ្ច បន ភិក្ខវេ វិកប្បេតព្វំ មយ្ហំ ភត្តប្បច្ចាសំ ឥត្ថន្នាមស្ស ទម្មីតិ ។

(១០៨) បរម្បរភោជនំ នាម បញ្ចន្នំ ភោជនានំ អញ្ញតរេន ភោជនេន និមន្តិតោ តំ ឋបេត្វា អញ្ញំ បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ ភុញ្ជតិ ឯតំ បរម្បរភោជនំ នាម ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ គិលានសមយោ នាម ន សក្កោតិ ឯកាសនេ និសិន្នោ យាវទត្ថំ ភុញ្ជិតុំ ។ គិលានសមយោតិ ភុញ្ជិតព្វំ ។ ចីវរទានសមយោ នាម អនត្ថតេ

១ ម. ឧ. ហេដ្ឋាកេសុ អយំ បាឋោ ន ហោតិ ។



សូមទ្រង់មេត្តាប្រោស ក៏ទ្រង់មិនគួរ ព្រោះខ្ញុំព្រះអង្គមានបច្ចាសំគេបម្រុងទុកហើយ ។ ព្រះអង្គត្រាស់ថា ម្នាលអានន្ទ បើដូច្នោះ អ្នកចូរកំណត់ (បច្ចាសំនោះដល់ភិក្ខុឯទៀត) ហើយទទួលយក (បច្ចាសំនេះ)ចុះ ។ គ្រានោះឯង ដំណើរនេះ ព្រះមានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ក្នុងហេតុនោះ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុកំណត់នូវបច្ចាសំដែលគេបម្រុងដល់ភិក្ខុឯទៀត ហើយឆាន់បរម្បរភោជនបាន ម្នាលភិក្ខុទាំងឡាយ ភិក្ខុគប្បីកំណត់យ៉ាងនេះថា ខ្ញុំឲ្យនូវភត្តដែលគេបម្រុងទុកដើម្បីខ្ញុំដល់ភិក្ខុឈ្មោះនេះ ។

(១០៨) ដែលហៅថា បរម្បរភោជន គឺ(ភិក្ខុ)ដែលគេនិមន្តដោយភោជន ៥ យ៉ាង ភោជនណាមួយ ហើយវៀរភោជននោះចេញ ឆាន់ភោជន ៥ យ៉ាង ភោជនណាមួយ ដទៃទៀត ភោជននុ៎ះហៅថា បរម្បរភោជន ។ ពាក្យថា វៀរតែមានសម័យ គឺលើកទុកតែមានសម័យ (គឺភោជនដែលគួរនឹងឆាន់បាន) ។ ដែលហៅថា សម័យដែលភិក្ខុមានជម្ងឺ គឺភិក្ខុមិនអាចនឹងអង្គុយឆាន់ឲ្យបានឆ្អែតលើអាសនៈមួយ ។ ភិក្ខុដឹងថាខ្លួនមានសម័យឈឺ ហើយគប្បីឆាន់(បរម្បរភោជនបាន) ។ ដែលហៅថា សម័យថ្វាយចីវរ គឺបើភិក្ខុមិនបានក្រាល

កឋិនេ វស្សានស្ស បច្ឆិមោ មាសោ អត្ថតេ កឋិនេ បញ្ច មាសា ។ ចីវរទានសមយោតិ ភុញ្ជិតព្វំ ។ ចីវរការសមយោ នាម ចីវរេ កយិរមានេ ។ ចីវរការសមយោតិ ភុញ្ជិតព្វំ ។ អញ្ញត្រ សមយា ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

(១០៩) បរម្បរភោជនេ បរម្បរភោជនសញ្ញី អញ្ញត្រ សមយា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ បរម្បរភោជនេ វេមតិកោ អញ្ញត្រ សមយា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ បរម្បរភោជនេ អបរម្បរភោជនសញ្ញី អញ្ញត្រ សមយា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អបរម្បរភោជនេ បរម្បរភោជនសញ្ញី អាបត្តិ ទុក្កដស្ស ។ អបរម្បរភោជនេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អបរម្បរភោជនេ អបរម្បរភោជនសញ្ញី អនាបត្តិ ។



កឋិនេ សម័យដ៏ក្រៅពីនេះ មានតែ ១ ខែ គឺខែជាទីបំផុតនៃវស្សានរដូវ បើភិក្ខុបានក្រាលកឋិន សម័យនៃចីវរទាននោះ មាន ៥ ខែ ។ ភិក្ខុដឹងថាសម័យនៃចីវរទាន គប្បីឆាន់(បរម្បរភោជន) ។ ដែលហៅថា សម័យជាទីធ្វើនូវចីវរ គឺកាលដែលភិក្ខុកំពុងធ្វើចីវរ ។ ភិក្ខុដឹងថាសម័យជាទីធ្វើនូវចីវរ គប្បីឆាន់(បរម្បរភោជន) ។ ភិក្ខុទទួល(បរម្បរភោជន) ដោយគិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដ វៀរលែងតែមានសម័យ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ពំនូតដែលលេប ។

[១១០] ភិក្ខុសំគាល់ ក្នុងបរម្បរភោជនថា បរម្បរភោជនមែន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងបរម្បរភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ភិក្ខុសំគាល់ ក្នុងបរម្បរភោជនថា មិនមែនបរម្បរភោជន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មិនមែនបរម្បរភោជន ភិក្ខុសំគាល់ថាបរម្បរភោជន ត្រូវអាបត្តិទុក្កដ ។ មិនមែនបរម្បរភោជន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនបរម្បរភោជន ភិក្ខុសំគាល់ថាមិនមែនជាបរម្បរភោជន មិនត្រូវអាបត្តិឡើយ ។

(១១១) អនាបត្តិ សមយេ វិកប្បេត្វា ភុញ្ជតិ ទ្វេ តយោ និមន្តនេ ឯកតោ ភុញ្ជតិ និមន្តនបដិបាដិយា ភុញ្ជតិ សកលេន គាមេន និមន្តិតោ តស្មឹ គាមេ យត្ថ កត្ថចិ ភុញ្ជតិ សកលេន បូគេន និមន្តិតោ តស្មឹ បូគេ យត្ថ កត្ថចិ ភុញ្ជតិ និមន្តិយមានោ ភិក្ខំ គហេស្សាមីតិ ភណតិ និច្ចភត្តេ សលាកភត្តេ បក្ខិកេ ឧបោសថិកេ បាដិបទិកេ បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។



[១១១] អាបត្តិមិនមាន ដល់(ភិក្ខុដែលឆាន់បរម្បរភោជន) ក្នុងសម័យ ដល់ភិក្ខុដែលប្តូរគំណាត់ (បរម្បរភោជនដល់ភិក្ខុឯទៀត) ហើយឆាន់ ដល់ភិក្ខុពីរបីអង្គឆាន់ជាមួយគ្នាក្នុងទីដែលគេនិមន្ត ដល់ភិក្ខុឆាន់តាមលំដាប់លំដោយដែលគេនិមន្ត ដល់ភិក្ខុដែលអ្នកស្រុកទាំងអស់និមន្តហើយឆាន់ក្នុងទីណាមួយក្នុងស្រុកនោះ ដល់ភិក្ខុដែលប្រជុំជនទាំងអស់និមន្តហើយឆាន់ក្នុងទីណាមួយក្នុងប្រជុំជននោះ ដល់ភិក្ខុដែលគេនិមន្តហើយពោលថា អាត្មានឹងទទួលតែភិក្ខា (ដែលបានមកដោយត្រាច់បិណ្ឌបាត) ដល់ភិក្ខុដែលឆាន់និច្ចភត្ត សលាកភត្ត បក្ខិកភត្ត ឧបោសថិកភត្ត បាដិបទិកភត្ត អាបត្តិមិនមាន ដល់ភិក្ខុដែលឆាន់ភោជនទាំងឡាយក្រៅពីភោជន ៥ យ៉ាងនេះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិកបុគ្គល ។

សិក្ខាបទទី ៣ ចប់ ។

## ឆដ្ឋសិក្ខាបទំ

(១១៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន កាណមាតា ឧបាសិកា សទ្ធា ហោតិ បសន្នា ។ កាណា គាមកេ អញ្ញតរស្ស បុរិសស្ស ទិន្នា ហោតិ ។ អថ ខោ កាណា មាតុឃរំ អគមាសិ កេនចិទេវ ករណីយេន ។ អថ ខោ កាណាយ សាមិកោ កាណាយ សន្តិកេ ទូតំ បាហេសិ អាគច្ឆតុ កាណា ឥច្ឆាមិ កាណាយ អាគតន្តិ ។ អថ ខោ កាណមាតា ឧបាសិកា កិស្មឹ វិយ រិត្តហត្ថំ គន្តុន្តិ បូវំ បចិ ។ បក្កេ បូវេ អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ កាណមាតាយ ឧបាសិកាយ និវេសនំ បាវិសិ ។ អថ ខោ កាណមាតា ឧបាសិកា តស្ស ភិក្ខុនោ បូវំ ទាបេសិ ។ សោ និក្ខមិត្វា អញ្ញស្ស អារោចេសិ ។ តស្សបិ បូវំ ទាបេសិ ។ សោ និក្ខមិត្វា អញ្ញស្ស អារោចេសិ ។ តស្សបិ បូវំ ទាបេសិ ។

## សិក្ខាបទទី ៦

(១១៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ឧបាសិកាជាមាតារបស់នាងកាណា ជាស្ត្រីមានសទ្ធាជ្រះថ្លា ។ (ឧបាសិកានោះ) បានឲ្យនាងកាណាជាកូន ទៅបុរសម្នាក់ នៅក្នុងស្រុកតូចមួយ ។ គ្រានោះ នាងកាណា បានទៅផ្ទះមាតា ដោយកិច្ចអ្វីមួយដែលខ្លួនត្រូវធ្វើ ។ ទើបប្ដីនាងកាណា ប្រើបម្រើទៅក្នុងសំណាក់នាងកាណាថា នាងកាណាចូរមក អញចង់ឲ្យនាងកាណាត្រឡប់មកវិញ ។ កាលនោះ ឧបាសិកាជាមាតារបស់នាងកាណាគិតថា ការទៅដោយដៃទទេ ដូចម្ដេចមិនកើត (គិតដូច្នេះហើយ) នាងក៏ចំអិននំ ។ ដល់នំឆ្អិន មានភិក្ខុអ្នកត្រាច់បិណ្ឌបាត ១ អង្គចូលទៅកាន់លំនៅរបស់ឧបាសិកាជាមាតានាងកាណា ។ ទើបឧបាសិកា ជាមាតារបស់នាងកាណា ឲ្យគេប្រគេននំដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុដទៃ ។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។

យថាបដិបត្តំ ហុត្វា បវិក្ខេយ្យំ ភេទមាសំ ។ ទុតិយស្ស
ទោ ឃដិកាយ សាមិកោ ឃដិកាយ បច្ចតោ
ឆិទ្ទំ ជាលេសំ អន្តរក្ខេ ឃដិកា វិក្កាមំ ឃដិកាយ
អាគតត្តំ ។ ទុតិយស្ស ទោ ឃដិកាមាតា ឧជាសិកា
កម្មិ វិយ វត្ថមាត្តំ គព្ភិតំ ហូ បជំ ។ បច្ឆេ
ម្ហ វញ្ញាតេ បណ្ហាជាតេសុ ភិក្ខុ ឃដិកា-
សាយ ឧជាសិកាយ ចំបេសនំ ទាវិសិ ។ អជទោ
ឃដិកាមាតា ឧជាសិកា នស្ស កិញ្ចិទោ ហូ
ជាតេសិ ។ សោ ចិត្តាមិត្តា អញ្ញស្ស ភេចិត្តិ ។
ទស្សាមិ ហូ ជាតេសិ ។ សោ ចិត្តាមិត្តា អញ្ញស្ស
ភេចិត្តិ ។ ទស្សាមិ ហូ ជាតេសិ ។ យថាបដិ-
បត្តំ ហុត្វា បរិក្ខេយ្យំ អតមាសំ ។ តតិយស្ស ទោ
ឃដិកាយ សាមិកោ ឃដិកាយ សក្ខិកោ ឆិទ្ទំ
ជាលេសិ អាគន្តុ ឃដិកា វិក្កាមិ ឃដិកាយ
ភេទតំ សបេ ឃដិកា ជាតមំ សង្កេតំ[1] អជាំ
អញ្ញំ បជាបតិ កោចេស្សាមីតិ ។ តតិយស្ស ទោ
ឃដិកាមាតា ឧជាសិកា កម្មិ វិយ វត្ថមាត្តុំ

[1] ម. ឃដ្ដិស្សតិ ។



ទំនៃឈ្មោះមាតាបេសនាទីកាណា ធ្លាខពាក់ថែរហើយហៅរកណាកំអស់គ្នាខ
សស់ ។ ស្វាមីរបស់នាទីកាណាប្រើឲ្យទៅ ក្នុងសំណាក់នាទីកាណា
ជាន់ទៅដល់ដើម នាទីកាណាចូលមកវិញ អញ្ជូនឲ្យនាទីកាណាត្រឡប់
មកវិញ ។ ឃដិកា ជាមាតារបស់នាទីកាណាតិតថា ការទៅជាយ
ថែរខេត្តចម្លងទីរកើត (តិតដូច្នោះហើយ) ក៏ចំអិនចំណេញៈជាតិទៅកែ
ងន ។ កាលទំនួន មាខភិក្ខុ ១ អង្គមកក្រចក្រ ដើម្បីបិណ្ឌបាតចូល
ទៅកាន់លំនៅរបស់ឃដិកា ជាមាតានាទីកាណា ។ រៀបឃដិកា
ជាមាតារបស់នាទីកាណា ឲ្យរងប្រគេនទំហំដល់ភិក្ខុនោះ ។ ភិក្ខុនោះ
ចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ (ឃដិកា) ឲ្យរងប្រគេនទំហំដល់ភិក្ខុនោះ
ទៀត ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ (ឃដិកា) ឲ្យរង
ប្រគេនទំហំដល់ភិក្ខុនោះទៀត ។ ទំនៃឈ្មោះឃដិកាធ្លាខពាក់ថែរហើយ
ពាំនាំខ្ញុំខកំអស់គ្នាខសស់ ។ ស្វាមីរបស់នាទីកាណាក៏ប្រើឲ្យទៅ
ក្នុងសំណាក់នាទីកាណា ជាត់ទៅដល់ទីនោះ នាទីកាណាចូលមកវិញ អញ្ជ
ូនឲ្យនាទីកាណាត្រឡប់មកវិញ ជាប់នាទីកាណាមិនត្រឡប់មកវិញទេ
អញ្ជើញយកប្រពន្ធឯទៀតហើយ ។ ឃដិកា ជាមាតារបស់នាទី
កាណាគិតថា ការទៅជាយថែរខេត្តចម្លងទីរកើត (គិតដូច្នោះហើយ)

គន្តុន្តិ បូវំ បចិ ។ បក្កេ បូវេ អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ កាណមាតាយ ឧបាសិកាយ និវេសនំ បាវិសិ ។ អថខោ កាណមាតា ឧបាសិកា តស្ស ភិក្ខុនោ បូវំ ទាបេសិ ។ សោ និក្ខមិត្វា អញ្ញស្ស អារោចេសិ ។ តស្សបិ បូវំ ទាបេសិ ។ សោ និក្ខមិត្វា អញ្ញស្ស អារោចេសិ ។ តស្សបិ បូវំ ទាបេសិ ។ យថាបដិយត្តំ បូវំ បរិក្ខយំ អគមាសិ ។ អថខោ កាណាយ សាមិកោ អញ្ញំ បជាបតិំ អានេសិ ។ អស្សោសិ ខោ កាណា តេន កិរ បុរិសេន អញ្ញា បជាបតី អានីតាតិ ។ សា រោទន្តី អដ្ឋាសិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន កាណមាតាយ ឧបាសិកាយ និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ កាណមាតា ឧបាសិកា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ កាណមាតរំ ឧបាសិកំ ភគវា ឯតទវោច



ក៏ចំអិននំអន្សម ដាក់ចម្អិន ។ កាលនំឆ្អិន ភិក្ខុអ្នកត្រាច់ទៅបិណ្ឌបាតរូប ១ ក៏ចូលទៅកាន់លំនៅរបស់ឧបាសិកា ជាមាតារបស់នាងកាណា ។ ទើបឧបាសិកា ជាមាតារបស់នាងកាណាឲ្យគេប្រគេននំដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុដទៃទៀត ។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុដទៃទៀត ។ (មាតារបស់នាងកាណា) ឲ្យគេប្រគេននំដល់ភិក្ខុនោះទៀត ។ នំដែលមាតារបស់នាងកាណាបានចាត់ចែងហើយ ក៏ដល់នូវកិរិយាអស់ទៅ ។ កាលនោះ ស្វាមីរបស់នាងកាណា ក៏យកប្រពន្ធទៀត ។ នាងកាណាបានដំណឹងថា ឮថាបុរសនោះយកប្រពន្ធទៀតហើយ ។ នាងកាណាក៏ឈរយំ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្លៀកស្បង់ហើយប្រដាប់បាត្រនិងចីវរ វេលាព្រឹក ចូលទៅកាន់លំនៅរបស់ឧបាសិកា ជាមាតានាងកាណា លុះយាងចូលទៅហើយ ក៏គង់លើអាសនៈ ដែលគេក្រាលតាក់តែងទុក ។ ទើបឧបាសិកា ជាមាតារបស់នាងកាណា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងឧបាសិកា ជាមាតារបស់នាងកាណា ដែលអង្គុយនៅក្នុងទីដ៏សមគួរថា

កិស្សាយំ កាណា រោទតីតិ ។ អថខោ កាណមាតា ឧបាសិកា ភគវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភគវា កាណមាតរំ ឧបាសិកំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយាសនា បក្កាមិ ។

[១១៣] តេន ខោ បន សមយេន អញ្ញតរោ សត្ថោ រាជគហា បដិយាលោកំ គន្តុកាមោ ហោតិ ។ អញ្ញតរោ បិណ្ឌចារិកោ ភិក្ខុ តំ សត្ថំ បិណ្ឌាយ បាវិសិ ។ អញ្ញតរោ ឧបាសកោ តស្ស ភិក្ខុនោ សត្តុំ ទាបេសិ ។ សោ និក្ខមិត្វា អញ្ញស្ស អាចិក្ខិ ។ តស្សាបិ សត្តុំ ទាបេសិ ។ សោ និក្ខមិត្វា អញ្ញស្ស អាចិក្ខិ ។ តស្សាបិ សត្តុំ ទាបេសិ ។ យថាបដិយត្តំ បាថេយ្យំ បរិក្ខយំ អគមាសិ ។ អថខោ សោ ឧបា-សកោ តេ មនុស្សេ ឯតទវោច អជ្ជណ្ហោ អយ្យា



នាងកាណានេះ ហេតុអ្វីបានជាយំ ។ ឧបាសិកាជាមាតារបស់នាងកាណា ក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគក្នុងពេលនោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឧបាសិកាជាមាតារបស់នាងកាណា ឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយក្រោកចាកអាសនៈ យាងទៅវិញ ។

[១១៣] សម័យនោះឯង មានពួករទេះ ១ ពួក មានសេចក្តីប្រាថ្នា ដើម្បីចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ប្រទេសឈ្មោះបដិយាលោក(១) ។ មានភិក្ខុអ្នកត្រាច់ទៅ ដើម្បីបិណ្ឌបាតមួយរូប ចូលទៅកាន់ពួករទេះនោះ ដើម្បីបិណ្ឌបាត ។ មានឧបាសកម្នាក់បានឲ្យគេប្រគេនសត្តុដល់ភិក្ខុនោះ ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ ឧបាសកនោះឲ្យគេប្រគេនសត្តុដល់ភិក្ខុនោះទៀត ។ ភិក្ខុនោះចេញទៅប្រាប់ដល់ភិក្ខុឯទៀត ។ ឧបាសកនោះឲ្យគេប្រគេនសត្តុដល់ភិក្ខុនោះទៀត ។ ស្បៀងដែលឧបាសកនោះបានតាក់តែងហើយ ទាំងប៉ុន្មានក៏អស់គ្មានសល់ ។ ទើបឧបាសកនោះបាននិយាយពាក្យនេះនឹងមនុស្សទាំងនោះថា បពិត្រអ្នកម្ចាស់ទាំងឡាយ សូមអ្នកម្ចាស់ទាំងឡាយរង់ចាំតែថ្ងៃនេះ ១ ថ្ងៃសិន (ព្រោះ)

១ គឺប្រទេសនៅទិសខាងលិចនៃក្រុងរាជគ្រឹះ ។

អាគមេថ យថាបដិយត្តំ បាថេយ្យំ អយ្យានំ ទិន្នំ បាថេយ្យំ បដិយាទេស្សាមីតិ ។ នាយ្យ[១] សក្កា អាគមេតុំ បយាតោ សត្ថោតិ បក្កាមិ ។ អថខោ តស្ស ឧបាសកស្ស បាថេយ្យំ បដិយាទេត្វា បច្ឆា គច្ឆន្តស្ស ចោរា អច្ឆិន្ទឹសុ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា បដិគ្គហេស្សន្តិ អយំ ឥមេសំ ទត្វា បច្ឆា គច្ឆន្តោ ចោរេហិ អច្ឆិន្នោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញាបេស្សាមិ ទស អត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ។បេ។

---

១ ម. នាយ្យោ ។



ស្បៀងដែលខ្ញុំបានតាក់តែងហើយតាំងពីមុនមក ខ្ញុំប្រគេនដល់លោកម្ចាស់ទាំងឡាយអស់ទៅហើយ ខ្ញុំនឹងតាក់តែងស្បៀង (ថ្មីទៀត) ។ មនុស្សទាំងនោះនិយាយថា បពិត្រអ្នកដ៏ចំរើន យើងមិនអាចនឹងរង់ចាំបានទេ (ព្រោះ) ពួកមនុស្សចេញទៅហើយ (ជាមួយគ្នាហើយ) ក៏ចេញទៅ ។ គាលឧបាសកនោះតាក់តែងស្បៀងហើយក៏ទៅក្រោយគេ ពួកចោរទាំងឡាយក៏ដណ្តើមយក (របស់ទ្រព្យ) ក្នុងពេលនោះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈសក្យបុត្រ ទទួលយកមិនដឹងប្រមាណដូច្នេះ ឧបាសកនេះប្រគេនស្បៀងដល់សមណៈទាំងនេះ ហើយទៅតាមក្រោយ ពួកចោរទាំងឡាយ ក៏ដណ្តើមយក (របស់ទ្រព្យ) ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ ។ ទើបភិក្ខុទាំងនោះក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីការប្រពៃដល់សង្ឃ ដើម្បីសេចក្តីស្រួលដល់សង្ឃ ។បេ។ ដើម្បីសេចក្តីអនុគ្រោះ

វិនយានុគ្គហាយ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ នវំ បន ភិក្ខុនា មញ្ចំ វា បីឋំ វា ការយមានេន អដ្ឋង្គុលបាទកំ ការេតព្វំ សុគតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ អដនិយា(១) តំ អតិក្កាមយតោ ឆេទនកំ បាចិត្តិយន្តិ ។ នវំ នាម ករណំ ឧបាទាយ វុច្ចតិ ។ មញ្ចោ នាម ចត្តារោ មញ្ចា មសារកោ ពុន្ទិកាពទ្ធោ កុឡីរបាទកោ អាហច្ចបាទកោ ។

[១០៤] ភិក្ខុំ បនេវ ...

មញ្ចំ ... បីឋំ ... ការយមានេនាតិ ករោន្តោ វា ការាបេន្តោ វា ។ អដ្ឋង្គុលបាទកំ ការេតព្វំ សុគតង្គុលេនាតិ ឋបេត្វា ហេដ្ឋិមំ អដនិំ ។ តំ អតិក្កាមេត្វា ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ ។ បដិលាភេន ឆិន្ទិត្វា ...

---

១ ។ ម. ឆដ្ឋ ។ ២ ។ ម. ...



ផល់គ្រែវិញ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណា ... នូវគ្រែដែលចូលទៅកាន់ត្រកូល ដោយខ្លួនឯងក្តី ដោយឲ្យគេធ្វើក្តី ដើម្បីនាំទៅបានតាម ព្រះពុទ្ធ ។ ភិក្ខុនោះសេចក្តីថា ត្រូវធ្វើឲ្យមានជើងត្រឹមតែប្រាំបីធ្នាប់ ... ត្រូវធ្វើឲ្យមានជើងត្រឹមប្រាំបីធ្នាប់ ដោយធ្នាប់ព្រះសុគត ... ត្រូវកាត់ចេញ ... ដោយភិក្ខុទាំងឡាយ ... សាមីចិកម្ម ...

[១០៤] ត្រង់ពាក្យថា ភិក្ខុដែលចូលទៅកាន់ត្រកូល សេចក្តីថា ដែលហៅថា គ្រែ ... គឺគ្រែ ... ៤ ... ត្រកូលមួយ គ្រែ ... ១ គ្រែ ... ១ គ្រែ ... ១ ។ ពាក្យថា ... ដែលហៅថា ... ដែលគេ ... ដើម្បី ... ។ ដែលហៅថា ... ។ ពាក្យថា ... ដើម្បីនាំទៅតាមព្រះពុទ្ធ សេចក្តីថា (...) ... ព្រះពុទ្ធ ... ។ ពាក្យថា ... សេចក្តី ... ។ ពាក្យថា ត្រូវធ្វើឲ្យមានជើងត្រឹមប្រាំបីធ្នាប់ ...

បដិគ្គហេតព្វាតិ ទ្វេត្តយោបត្តបូរា បដិគ្គហេតព្វា ។ តតោ ចេ ឧត្តរឹ បដិគ្គណ្ហេយ្យាតិ តទុត្តរឹ(១) បដិគ្គណ្ហាតិ អាបត្តិ បាចិត្តិយស្ស ។ ទ្វត្តិបត្តបូរេ បដិគ្គហេត្វា តតោ និក្ខមន្តេន ភិក្ខុំ បស្សិត្វា អាចិក្ខិតព្វំ អមុត្រ មយា ទ្វត្តិបត្តបូរា បដិគ្គហិតា មា ខោ តត្ថ បដិគ្គណ្ហីតិ ។ សចេ បស្សិត្វា នាចិក្ខតិ អាបត្តិ ទុក្កដស្ស ។ សចេ អាចិក្ខិតេ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

(១១៩) តតោ នីហរិត្វា ភិក្ខូហិ សទ្ធឹ សំវិភ-ជិតព្វន្តិ បដិក្កមនំ នីហរិត្វា សំវិភជិតព្វំ ។ អយំ តត្ថ សាមីចីតិ អយំ តត្ថ អនុធម្មតា ។ អតិរេកបត្តបូរេ អតិរេកសញ្ញី បដិគ្គណ្ហាតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកបត្តបូរេ វេមតិកោ ប-ដិគ្គណ្ហាតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកបត្តបូរេ ឩនកសញ្ញី បដិគ្គណ្ហាតិ អាបត្តិ បាចិត្តិយស្ស ។

១ ឱ. ម. តតុត្តរឹ ។



សេចក្តីថា គប្បីទទួលយកបានត្រឹមពេញពីរបីបាត្រ ។ ពាក្យថា បើទទួលឲ្យហួសពីកំណត់នោះទៅ សេចក្តីថា ភិក្ខុទទួលឲ្យលើសលុបពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។ (បើ) ភិក្ខុទទួល (នំបួសដូ) កំណត់ពេញពីរបីបាត្រហើយចេញពីទីនោះមកឃើញភិក្ខុ (ឯទៀត) ត្រូវប្រាប់ថា ក្នុងទីឯណោះខ្ញុំទទួល (នំបួសដូ) ពេញពីរបីបាត្រមកហើយ លោកកុំទៅទទួលក្នុងទីនោះឡើយ ។ បើភិក្ខុឃើញហើយមិនប្រាប់ ត្រូវអាបត្តិទុក្កដ ។ បើប្រាប់ហើយ ភិក្ខុនៅតែទៅទទួល ត្រូវអាបត្តិទុក្កដ ។

(១១៩) ត្រង់ពាក្យថា ត្រូវនាំចេញអំពីទីនោះហើយចែកមួយអន្លើដោយភិក្ខុទាំងឡាយ សេចក្តីថា ក្នុងពេលដែលត្រឡប់មក ត្រូវនាំយក (នំបួសដូ) នោះមកចែកគ្នា ។ ពាក្យថា ការចែកនំបួសដូនេះជាសាមី-ចិកម្មក្នុងសិក្ខាបទនោះ សេចក្តីថា ការចែកនំបួសដូនេះជាទំនៀមដ៏សមគួរក្នុងសិក្ខាបទនោះ ។ ភិក្ខុសំគាល់ក្នុងនំបួសដូដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ថាច្រើនជាងមែន ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងនំបួសដូដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសំគាល់ក្នុងនំបួសដូដ៏ច្រើនជាងកំណត់ពេញពីរបីបាត្រ ថាខ្វះទៅវិញ ហើយទទួល ត្រូវអាបត្តិបាចិត្តិយ ។

ឩនកទ្វិត្តិបត្តបូរេ អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកទ្វិត្តិបត្តបូរេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកទ្វិត្តិបត្តបូរេ ឩនកសញ្ញី អនាបត្តិ ។

(១១៦) អនាបត្តិ ទ្វិត្តិបត្តបូរេ បដិគ្គណ្ហាតិ ឩនកទ្វិត្តិបត្តបូរេ បដិគ្គណ្ហាតិ ន បហេណកត្ថាយ ន បាថេយ្យត្ថាយ បដិយត្តំ ទេតិ បហេណកត្ថាយ វា បាថេយ្យត្ថាយ វា បដិយត្តសេសកំ ទេតិ គមនេ បដិប្បស្សទ្ធេ ទេតិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។



ភិក្ខុសំគាល់ក្នុងនំឬសត្តុដែលមិនពេញកំណត់ពីរបីបាត្រ ថាលើសទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសង្ស័យក្នុងនំឬសត្តុដែលមិនពេញពីរបីបាត្រ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងនំឬសត្តុដែលមិនពេញពីរបីបាត្រ ថាមិនពេញមែន មិនត្រូវអាបត្តិ ។

(១១៦) អនាបត្តិមិនមាន ដល់ភិក្ខុដែលទទួលនំឬសត្តុកំណត់ពេញត្រឹមតែពីរបីបាត្រ ដល់ភិក្ខុដែលទទួលនំឬសត្តុមិនពេញពីរបីបាត្រ ដល់ភិក្ខុដែលទទួលនំ (ឯណាទីមួយ) ដែលគេមិនតាក់តែង ដើម្បីបញ្ជូនទៅ (ញាតិ) មិនតាក់តែង ដើម្បីជាស្បៀង ដល់ភិក្ខុដែលទទួលនំដែលសេសសល់អំពីនំឬសត្តុដែលគេតាក់តែងដើម្បីបញ្ជូនទៅ (ញាតិ) ក្តី ដើម្បីជាស្បៀងក្តី ដល់ភិក្ខុដែលទទួលនំឬសត្តុអំពីជនដែលគេមានដំណើរប្រុងនឹងទៅហើយឈប់វិញ ដល់ភិក្ខុដែលទទួលនំឬសត្តុរបស់ញាតិ ដល់ភិក្ខុដែលទទួលនំឬសត្តុរបស់ជនដែលបវារណា ដល់ភិក្ខុដែលទទួលនំឬសត្តុដើម្បីអ្នកដទៃ ដល់ភិក្ខុដែលទទួលនំឬសត្តុដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិកបុគ្គល ។

សិក្ខាបទទី ៤ ចប់ ។

# បញ្ចមសិក្ខាបទំ

[១០៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ព្រាហ្មណោ ភិក្ខូ និមន្តេត្វា ភោជេសិ ។ ភិក្ខូ ភុត្តាវី បវារិតា ញាតិកុលំ គន្ត្វា ឯកច្ចេ ភុញ្ជឹសុ ឯកច្ចេ បិណ្ឌបាតំ អាទាយ អគមំសុ ។ អថ ខោ សោ ព្រាហ្មណោ បដិវិស្សកេ ឯតទវោច ភិក្ខូ មយា អយ្យា សន្តប្បិតា ឯថ តុម្ហេបិ សន្តប្បេស្សាមីតិ ។ តេ ឯវមាហំសុ កឹ អយ្យោ អម្ហេ សន្តប្បេស្សសិ យេបិ តយា និមន្តិតា តេបិ អម្ហាកំ ឃរានិ អាគន្ត្វា ឯកច្ចេ ភុញ្ជឹសុ ឯកច្ចេ បិណ្ឌបាតំ អាទាយ អគមំសូតិ ។ អថ ខោ សោ ព្រាហ្មណោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភទន្តា អម្ហាកំ ឃរេ ភុញ្ជិត្វា អញ្ញត្រ ភុញ្ជិស្សន្តិ ន ចាហំ បដិពលោ យាវទត្ថំ ទាតុន្តិ ។

# សិក្ខាបទទី ៥

(១០៧) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានព្រាហ្មណ៍ម្នាក់និមន្តភិក្ខុទាំងឡាយឲ្យឆាន់ ។ ពួកភិក្ខុឆាន់ហើយបានហាមភត្តហើយ ក៏ទៅកាន់ត្រកូលញាតិទាំងឡាយ ភិក្ខុពួកខ្លះក៏ឆាន់ ភិក្ខុពួកខ្លះកាន់យកបិណ្ឌបាតទៅ ។ គ្រានោះ ព្រាហ្មណ៍នោះបានពោលពាក្យនេះនឹងពួកជនជាអ្នកស្និទ្ធស្នាលថា បពិត្រអ្នកម្ចាស់ទាំងឡាយ ភិក្ខុទាំងឡាយខ្ញុំបានប្រគេនឲ្យឆ្អែតឆ្អន់បរិបូណ៌ហើយ សូមអ្នកទាំងឡាយអញ្ជើញមក ខ្ញុំនឹងធ្វើអ្នកឲ្យឆ្អែតដូចគ្នាទៀត ។ ពួកស្និទ្ធស្នាលទាំងនោះពោលយ៉ាងនេះថា បពិត្រអ្នកម្ចាស់ អ្នកនឹងធ្វើអ្វីដល់យើងទាំងឡាយឲ្យឆ្អែតដូចម្ដេចបាន សូម្បីភិក្ខុទាំងឡាយណា ដែលអ្នកនិមន្តមកហើយ ភិក្ខុទាំងនោះមកកាន់ផ្ទះពួកយើង ខ្លះឆាន់ ខ្លះកាន់យកបិណ្ឌបាតហើយទៅ ។ ទើបព្រាហ្មណ៍នោះពោលទោស តិះដៀល បន្ទោសបន្ទាប់ថា លោកដ៏ចំរើនទាំងឡាយមិនសមនឹងឆាន់ក្នុងផ្ទះយើងទាំងឡាយហើយទៅឆាន់ក្នុងទីដទៃទៀតនោះ ហាក់ដូចជាខ្ញុំមិនអាចដើម្បីប្រគេនលោកឆាន់ឲ្យឆ្អែតបាន ។

អស្សោសុំ ខោ ភិក្ខូ តស្ស ព្រាហ្មណស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ ភុត្តាវី បវារិតា អញ្ញត្រ ភុញ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ភុត្តាវី បវារិតា អញ្ញត្រ ភុញ្ជន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ភុត្តាវី បវារិតា អញ្ញត្រ ភុញ្ជិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភុត្តាវី បវារិតោ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។





ពួកភិក្ខុបានឮព្រាហ្មណ៍នោះពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយឆាន់ហើយ ហាមភត្តរួចហើយ មិនគួរនឹងទៅឆាន់ក្នុងទីដទៃទៀតសោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយឆាន់ហើយហាមភត្តហើយ ត្រឡប់ទៅឆាន់ក្នុងទីដទៃទៀត ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ ឆាន់ហើយហាមភត្តរួចហើយ ហេតុអ្វីក៏ទៅឆាន់ក្នុងទីដទៃទៀត ម្នាលភិក្ខុទាំងឡាយ ការនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឆាន់ហើយហាមភត្តហើយ ទំពាស៊ីក្ដី បរិភោគក្ដី នូវខាទនីយ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(១១៩) តេន ខោ បន សមយេន ភិក្ខូ គិលានានំ ភិក្ខូនំ បណីតេ បិណ្ឌបាតេ នីហរន្តិ ។ គិលានា ន ចិត្តរូបំ ភុញ្ជន្តិ ។ តានិ ភិក្ខូ ឆឌ្ឌេន្តិ ។ អស្សោសិ ខោ ភគវា ឧច្ចាសទ្ទំ មហាសទ្ទំ កាកោរវសទ្ទំ សុត្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ កិន្នុ ខោ សោ អានន្ទ ឧច្ចាសទ្ទោ មហាសទ្ទោ កាកោរវសទ្ទោតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ ភុញ្ជេយ្យុំ បនានន្ទ ភិក្ខូ គិលានាតិរិត្តន្តិ ។ ន ភុញ្ជេយ្យុំ ភគវាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានស្ស ច អគិលានស្ស ច អតិរិត្តំ ការេតុំ ឯវញ្ច បន ភិក្ខវេ អតិរិត្តំ កាតព្វំ អលមេតំ សព្វន្តិ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ





(១១៩) សម័យនោះឯង ភិក្ខុទាំងឡាយ នាំយកនូវបិណ្ឌបាតដ៏ឧត្តមទៅឲ្យពួកភិក្ខុឈឺ ។ ពួកភិក្ខុឈឺឆាន់មិនបានដោយស្រួល ។ ពួកភិក្ខុចាំបោះចោលបិណ្ឌបាតដ៏ឧត្តមទាំងនោះ ។ ព្រះដ៏មានព្រះភាគបានឮសំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ជ្រៀវនៃក្អែក លុះទ្រង់ឮហើយទ្រង់ហៅព្រះអានន្ទដ៏មានអាយុហើយត្រាស់សួរថា ម្នាលអានន្ទ សំឡេងខ្លាំង សំឡេងធំ សំឡេងកញ្ជ្រៀវនៃក្អែក សំឡេងនោះ ជាសំឡេងអ្វីហ្ន៎ ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុក្រាបទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់សួរថា ម្នាលអានន្ទ ពួកភិក្ខុឆាន់កាកសំណល់អំពីភិក្ខុឈឺ ពិតមែនឬ ។ ព្រះអានន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពួកភិក្ខុមិនឆាន់ទេ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមក ក្នុងពេលនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឆាន់កាកសំណល់អំពីភិក្ខុឈឺក្តី ភិក្ខុមិនឈឺក្តី ម្នាលភិក្ខុទាំងឡាយ ភិក្ខុត្រូវធ្វើកាកសំណល់ (អំពីភិក្ខុឈឺ) ដោយពាក្យយ៉ាងនេះថា របស់នេះទាំងអស់នេះសមគួរហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឆាន់ហើយ

ទ្ទិសេយ្យាថ យោ បន ភិក្ខុ ភុត្តាវី បវារិតោ អនតិរិត្តំ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយន្តិ ។

[១០៩] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខុ. ភុត្តាវី នាម បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ អន្តមសោ កុសគ្គេនបិ ភុត្តំ ហោតិ ។ បវារិតោ នាម អសនំ បញ្ញាយតិ ភោជនំ បញ្ញាយតិ ហត្ថបាសេ ឋិតោ អភិហរតិ បដិក្ខេបោ បញ្ញាយតិ ។ អនតិរិត្តំ



ព្រះឱវាទនេះហើយ ទំពាស៊ីក្តី ឆាន់ក្តី នូវខាទនីយាហារ ឬភោជនី- យាហារដែលមិនមែនជាដំណែល គឺជាវត្ថុដែលមិនបានធ្វើវិនយកម្ម ទំនឹងមិនមែន សេសសល់ពីភិក្ខុឈឺ ត្រូវអាបត្តិបាចិត្តិយ ។

(១០៩) ត្រង់ពាក្យថា ភិក្ខុណាមួយ គឺភិក្ខុឯណាមួយ មានសេចក្តីប្រព្រឹត្តដូចម្តេច ។ បេ ។ នៃពួកភិក្ខុ ។ បេ ។ ដែលហៅថា ឆាន់ហើយ គឺភិក្ខុឆាន់ភោជនទាំង៥យ៉ាង ណាមួយ ដោយហោចទៅ សូម្បីតែត្រឹមចុងស្បូវភ្លាំង ។ ដែលហៅថា ហាមភោជន (គឺហាមមិនឲ្យប្រគេនភត្តយ៉ាងនេះ) គឺភិក្ខុ ឆាន់ហើយ ទាំងភោជននៅប្រាកដ ទាំងបុគ្គលប្រគេនឋិតនៅក្នុងហត្ថបាស ប្រគេន ភោជនមកដល់ហើយ ១ ភិក្ខុហាមឃាត់ ១ ។ ដែលហៅថា អនតិរិត្ត

---

១ ពាក្យថា ដែលហៅថា អនតិរិត្តភោជន បានដល់ភោជនដែលមិនបានធ្វើវិនយកម្ម ដើម្បីកុំឲ្យ ទើសអាបត្តិ ដែលជាដំណែលពីភិក្ខុឈឺ ។

ឯអាការដែលមិនធ្វើវិនយកម្មនោះ មាន៧យ៉ាង

១ វត្ថុទាំងឡាយណាដែលមិនមែនជាកប្បិយ ដែលគេមិនបានធ្វើឲ្យជាកប្បិយ និងវត្ថុដែលមិនទាន់ប្រគេន ។

២ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ហើយធ្វើវិនយកម្ម វត្ថុនោះ មិនទាន់ឈ្មោះដំណែលទេ ។

៣ វត្ថុដែលភិក្ខុកាន់ ហើយធ្វើវិនយកម្ម វត្ថុនោះមិនទាន់ឈ្មោះដំណែលទេ ។

នាម អកប្បិយកតំ ហោតិ អប្បដិគ្គហិតកតំ ហោតិ

អនុច្ចារិតកតំ ហោតិ អហត្ថបាសេ កតំ ហោតិ អ-

ភុត្តាវិនា កតំ ហោតិ ភុត្តាវិនា បវារិតេន អាសនា

វុដ្ឋិតេន កតំ ហោតិ អលមេតំ សព្វន្តិ អវុត្តំ ហោតិ

ន គិលានាតិរិត្តំ ហោតិ ឯតំ អនតិរិត្តំ នាម ។ អតិរិត្តំ

នាម កប្បិយកតំ ហោតិ បដិគ្គហិតកតំ ហោតិ



បានដល់វត្ថុដែលមិនបានធ្វើវិនយកម្ម (ដោយអាការ ៧ យ៉ាង) គឺរបស់ដែលគេមិនបានធ្វើឲ្យជាកប្បិយៈ ១ របស់ដែលភិក្ខុមិនបានទទួលហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុមិនបានលើកឡើង (ឬ) មិនបានបង្អោនចូលទៅជិតដើម្បីឲ្យភិក្ខុធ្វើឲ្យជារបស់គួរ ១ ភិក្ខុមិនបានឋិតនៅក្នុងហត្ថបាសហើយធ្វើ ១ ភិក្ខុមិនទាន់បានឆាន់ហើយធ្វើ ១ ភិក្ខុឆាន់ហើយបានឃាត់ភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ ១ របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ ១ ដំណែកដែលមិនមែនជារបស់សល់អំពីភិក្ខុឈឺ វត្ថុទាំងនោះហៅថា អនតិរិត្ត ២ ដែលហៅថា អតិរិត្តនោះ បានដល់វត្ថុដែលបានធ្វើវិនយកម្ម (ដោយអាការ ៧ យ៉ាង)

---

៦ ភិក្ខុកាន់យកវត្ថុមកដើម្បីឲ្យភិក្ខុផងគ្នាធ្វើវិនយកម្មឡើង តែភិក្ខុអ្នកធ្វើវិនយកម្មនោះឋិតនៅក្រៅហត្ថបាស ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ ។

៨ ភិក្ខុណាមួយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ តែភិក្ខុអ្នកធ្វើវិនយកម្មនោះឯង មិនទាន់បានឆាន់ភោជននៅឡើយ ហើយធ្វើវិនយកម្មថា របស់ទាំងអស់នេះគួរហើយ ។

៩ ភិក្ខុអ្នកធ្វើវិនយកម្មបានឆាន់ហើយ ឃាត់ភោជនហើយ ក្រោកចាកអាសនៈហើយ ទើបធ្វើវិនយកម្មឲ្យថា របស់ទាំងអស់នេះគួរហើយ ។

៧ ភិក្ខុអ្នកធ្វើវិនយកម្ម មិនបានបញ្ចេញវាចាថា របស់ទាំងអស់នេះគួរហើយ ។

ចំណែកទី ៨ យ៉ាង គឺភោជនណាមួយដែលមិនមែនសល់អំពីភិក្ខុឈឺ ។ វត្ថុដែលមិនបានធ្វើវិនយកម្មទាំង ៧ យ៉ាងនេះក្តី ភោជនដែលមិនមែនសល់អំពីភិក្ខុឈឺក្តី ទាំងពីរចំណែកនេះ ហៅថា អនតិរិត្តភោជន ។

ឧច្ចារិតកតំ ហោតិ ហត្ថបាសេ កតំ ហោតិ ភុត្តាវិនា កតំ ហោតិ ភុត្តាវិនា បវារិតេន អាសនា អវុដ្ឋិតេន កតំ ហោតិ អលមេតំ សព្វន្តិ វុត្តំ ហោតិ គិលានាតិរិត្តំ ហោតិ ឯតំ អតិរិត្តំ នាម ។ ខាទនីយំ នាម បញ្ច ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[១៦០] អនតិរិត្តេ អនតិរិត្តសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ អនតិរិត្តេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ អនតិរិត្តេ អតិរិត្តសញ្ញី ខាទនីយំ វា



តិ របស់ដែលគេធ្វើឲ្យជាកប្បិយ ១ របស់ដែលភិក្ខុបានទទួលហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុលើកឡើង ឬបានបង្អោនទៅជិត ដើម្បីធ្វើឲ្យជារបស់គួរ ១ ភិក្ខុនៅក្នុងហត្ថបាសហើយធ្វើ ១ ភិក្ខុឆាន់រួចហើយទើបធ្វើ ១ របស់ដែលភិក្ខុឆាន់ហើយហាមភោជនហើយ មិនទាន់ក្រោកចាកអាសនៈហើយធ្វើ ១ របស់ដែលភិក្ខុពោលថា របស់អស់ទាំងនេះគួរហើយ ១ និងរបស់ដែលសល់អំពីភិក្ខុឈឺ វត្ថុទាំង៨យ៉ាងនេះ ហៅថាអតិរិត្ត ។ ដែលហៅថា ខាទនីយាហារនោះ បានដល់របស់ទាំងអស់វៀរលែងតែភោជន៥យ៉ាង និងរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយាហារ ។ ដែលហៅថា ភោជនីយាហារនោះបានដល់ភោជន៥យ៉ាង គឺបាយ នំស្រួយ នំក្រៀប ត្រី សាច់ ។ ភិក្ខុទទួលដោយគិតថា អាត្មានឹងទំពាស៊ី អាត្មានឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ពំនូតដែលលេបចូល ។

[១៦០] ខាទនីយាហារ ភោជនីយាហារ ជាអនតិរិត្ត ភិក្ខុសំគាល់ថាជាអនតិរិត្តពិតមែន ហើយទំពាស៊ីក្ដី បរិភោគក្ដី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងខាទនីយាហារ ភោជនីយាហារជាអនតិរិត្ត ហើយទំពាស៊ីក្ដី បរិភោគក្ដី នូវខាទនីយាហារ ឬភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសំគាល់ក្នុងខាទនីយាហារ ភោជនីយាហារ ជាអនតិរិត្ត

ភោជនីយំ វា ខាទនីយំ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ អតិរិត្តេ អនតិរិត្តសញ្ញី អាបត្តិ ទុក្កដស្ស ។ អតិរិត្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អតិរិត្តេ អតិរិត្តសញ្ញី អនាបត្តិ ។

(១៤១) អនាបត្តិ អតិរិត្តំ ការាបេត្វា ភុញ្ជតិ អតិរិត្តំ ការាបេត្វា ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អញ្ញស្សត្ថាយ ហរន្តោ គច្ឆតិ គិលានស្ស សេសកំ ភុញ្ជតិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។



ថាជាអតិរិត្តទៅវិញ ហើយទំពាស៊ីក្តី បរិភោគក្តី នូវខាទនីយាហារ ឬ ភោជនីយាហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលរបស់ជា យាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ គ្រប់ៗ ករៈ ដែលលេបចូល ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្ត ថាជាអនតិរិត្តទៅវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្ត ត្រូវអាបត្តិទុក្កដ ។ ភិក្ខុសំគាល់ក្នុងខាទនីយភោជនីយាហារដែលជាអតិរិត្ត ថាជាអតិរិត្តពិតមែន មិនត្រូវអាបត្តិ ។

(១៥១) អាបត្តិមិនមាន ដល់ភិក្ខុដែលឲ្យគេធ្វើវិនយកម្មហើយឆាន់ ដល់ភិក្ខុដែលទទួលរបស់ដោយគិតថា អញនឹងឲ្យគេធ្វើវិនយកម្មហើយឆាន់ ដល់ភិក្ខុដែលនាំយករបស់ទៅដើម្បីភិក្ខុដទៃ ដល់ភិក្ខុដែលឆាន់របស់ជាសំណល់អំពីភិក្ខុឈឺ ដល់ភិក្ខុដែលឆាន់របស់ជាយាមកាលិក សត្តាហកាលិក យាវជីវិកដោយមានហេតុ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិដើមបញ្ញត្តិ ។

សិក្ខាបទទី ៥ ចប់ ។

## ឆដ្ឋសិក្ខាបទំ

(១៦៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ទ្វេ ភិក្ខូ កោសលេសុ ជនបទេសុ សាវត្ថឹ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ ឯកោ ភិក្ខុ អនាចារំ អាចរតិ ។ ទុតិយោ ភិក្ខុ តំ ភិក្ខុំ ឯតទវោច មា អាវុសោ ឯវរូបំ អកាសិ នេតំ កប្បតីតិ ។ សោ តស្មឹ ឧបនន្ធិ ។ អថខោ តេ ភិក្ខូ សាវត្ថឹ អគមំសុ ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរស្ស បូគស្ស សង្ឃភត្តំ ហោតិ ។ ទុតិយោ ភិក្ខុ ភុត្តាវី បវារិតោ ហោតិ ។ ឧបនទ្ធោ ភិក្ខុ ញាតិកុលំ គន្ត្វា បិណ្ឌបាតំ អាទាយ យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ ឯតទវោច ភុញ្ជាហិ អាវុសោតិ ។ អលំ អាវុសោ បរិបុណ្ណោម្ហីតិ ។ សុន្ទរោ អាវុសោ បិណ្ឌបាតោ ភុញ្ជាហីតិ ។ អថខោ សោ

## សិក្ខាបទទី ៦

(១៦៤) កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង មានភិក្ខុពីររូបដើរផ្លូវឆ្ងាយទៅក្រុងសាវត្ថីក្នុងកោសលជនបទ ។ ភិក្ខុ ១ រូប ប្រព្រឹត្តអនាចារ ។ ភិក្ខុជាគំរប់ពីរបាននិយាយពាក្យនេះ (ឃាត់) ភិក្ខុនោះថា ម្នាលលោកដ៏មានអាយុ លោកកុំធ្វើអំពើយ៉ាងនេះ អំពើដែលលោកធ្វើនេះមិនគួរទេ ។ ភិក្ខុដែលប្រព្រឹត្តអនាចារនោះក៏ចងពៀរនឹងភិក្ខុអ្នកឃាត់នោះ ។ គ្រានោះ ភិក្ខុទាំងនោះបានទៅកាន់ក្រុងសាវត្ថី ។ សម័យនោះឯង ក្នុងក្រុងសាវត្ថីមានប្រជុំជនមួយពួក (ធ្វើ) សង្ឃភត្ត ។ ភិក្ខុជាគំរប់ពីរបានឆាន់ស្រេចហើយ ហាមភត្តហើយ ។ ភិក្ខុដែលចងពៀរ ទៅកាន់ត្រកូលជាញាតិ ហើយទទួលបិណ្ឌបាតមក ហើយក៏ចូលទៅរកភិក្ខុដែលហាមភត្តនោះ លុះចូលទៅដល់ហើយ បាននិយាយពាក្យនេះនឹងភិក្ខុអ្នកហាមភត្តនោះថា ម្នាលលោកដ៏មានអាយុ លោកចូរឆាន់ (ចង្ហាន់នេះ) ចុះ ។ ភិក្ខុអ្នកហាមភត្តក៏ប្រកែកថា កុំអាវុសោ ខ្ញុំឆាន់បរិបូណ៌ហើយ ។ ភិក្ខុដែលចងពៀរក៏អង្វរថា ម្នាលអាវុសោ បិណ្ឌបាត(នេះ)ល្អ លោកចូរឆាន់ទៅ ។ កាលបើភិក្ខុអ្នកចងពៀរនោះជម្រុលយ៉ាងនេះ

ភិក្ខុ តេន ភិក្ខុនា និប្បីឡិយមានោ តំ បិណ្ឌបា-
តំ ភុញ្ជិ(១) ។ ឧបនទ្ធោ(២) ភិក្ខុ តំ ភិក្ខុំ ឯតទវោច
ត្វំ ហិ នាម អាវុសោ មំ វត្តុំ មញ្ញសិ យំ ត្វំ
ភុត្តាវី បវារិតោ អនតិរិត្តំ ភោជនំ ភុញ្ជសីតិ ។ ន-
នុ អាវុសោ អាចិក្ខិតព្វន្តិ ។ ននុ អាវុសោ បុច្ឆិតព្វន្តិ ។
អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។
យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ
ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ ភិក្ខុំ
ភុត្តាវឹ បវារិតំ អនតិរិត្តេន ភោជនេន អភិហដ្ឋុំ
បវារេស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ ភិក្ខុ ភិក្ខុំ
ភុត្តាវឹ បវារិតំ អនតិរិត្តេន ភោជនេន អភិហដ្ឋុំ
បវារេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ នាម ត្វំ មោឃបុរិស ភិក្ខុំ ភុត្តាវឹ
បវារិតំ អនតិរិត្តេន ភោជនេន អភិហដ្ឋុំ បវារេស្សសិ
នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ

១ ម. យ. ភុញ្ជតិ ។ ២ ម. ឱ. បមនោ ។



ភិក្ខុអ្នកហាមភត្តនោះ (ព្រោះមិនបាន) ក៏ឆាន់បិណ្ឌបាតនោះទៅ ។ ភិក្ខុដែល
ចងពៀរក៏ពោលពាក្យនេះនឹងភិក្ខុអ្នកហាមភត្តនោះថា ម្នាលអាវុសោ
លោកសំគាល់មកខ្ញុំថាជាបុគ្គលដែលគេត្រូវតែស្តីថាឬអ្វី ក៏ព្រោះលោកឆាន់រួច
ហើយហាមភត្តហើយ ម្តេចឡើយក៏នៅតែឆាន់អនតិរិត្តភោជន ។ ភិក្ខុអ្នក
ហាមភត្តនោះតបថា ម្នាលអាវុសោ ហេតុម្តេច លោកមិនប្រាប់(ខ្ញុំ)ផង ។
ភិក្ខុអ្នកចងពៀរឆ្លើយថា ហេតុម្តេច លោកមិនសួរ(ខ្ញុំជាមុន) ។ ភិក្ខុអ្នក
ហាមភត្តនោះក៏ដំណាលរឿងនុះប្រាប់ភិក្ខុទាំងឡាយគង់ទីនោះ ។
ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោល
ទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងនាំភត្តទៅហើយបវា-
រណាបង្ខំភិក្ខុដែលឆាន់ហើយហាមភត្តហើយ ឲ្យឆាន់នូវអនតិរិត្តភោជន
(ផងៗ) សោះ ។បេ។ ព្រះអង្គត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯង
បាននាំភត្តទៅបវារណាបង្ខំភិក្ខុដែលឆាន់ហើយ ហាមភោជនហើយ ឲ្យ
ឆាន់អនតិរិត្តភោជន ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តា
ប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា
ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងនាំភត្តទៅបវារណាបង្ខំភិក្ខុដែលឆាន់
ហើយហាមភត្តហើយ ឲ្យឆាន់អនតិរិត្តភោជនទេ នែមោឃបុរស អំពើ
ដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា

បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ ភុត្តាវឹ បវារិតំ អនតិរិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេយ្យ ហន្ទ ភិក្ខុ ខាទ វា ភុញ្ជ វាតិ ជានំ អាសាទនាបេក្ខោ ភុត្តស្មឹ បាចិត្តិយន្តិ ។

(១៦៣) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញំ ភិក្ខុំ ។ ភុត្តាវី នាម បញ្ចន្នំ ភោជនានំ អញ្ញតរំ ភោជនំ អន្តមសោ កុសគ្គេនបិ ភុត្តំ ហោតិ ។ បវារិតោ នាម អសនំ បញ្ញាយតិ ភោជនំ បញ្ញាយតិ ហត្ថបាសេ ឋិតោ អភិហរតិ បដិក្ខេបោ បញ្ញាយតិ ។ អនតិរិត្តំ នាម អកប្បិយកតំ ហោតិ អប្បដិគ្គហិតកតំ ហោតិ អនុច្ចារិតកតំ ហោតិ អហត្ថបាសេ កតំ ហោតិ



ឬពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើង ១ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលដឹងហើយនៅតែគេពាសនាំភត្តទៅបវារណាចំពោះភិក្ខុដែលឆាន់ហើយ ហាមភត្តហើយ ឲ្យទំពាស៊ីក្តី បរិភោគក្តី នូវអនតិរិត្តភោជន ដោយពាក្យថា នែភិក្ខុ អ្នកចូរទំពាស៊ីក្តី បរិភោគក្តី ចុះ ទាល់តែភិក្ខុនោះឆាន់ហើយ ត្រូវអាបត្តិបាចិត្តិយ ។

(១៦៣) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ភិក្ខុ គឺភិក្ខុដទៃ ។ ដែលហៅថា ឆាន់ហើយ គឺភិក្ខុបានឆាន់នូវភោជនទាំង ៥ យ៉ាង ភោជនណាមួយ ដោយហោចទៅសូម្បីតែប៉ុនចុងស្បូវភ្លាំង ។ ដែលហៅថា ហាមភត្ត (គឺហាមប្រគេនដោយអង្គ ៥ យ៉ាង) គឺភិក្ខុកំពុងឆាន់ ១ គេយកភោជនចូលប្រគេនទៀត ១ គេឈរនៅក្នុងហត្ថបាស ១ គេបង្អោនភោជនមកចំពោះ ១ ភិក្ខុហាមភោជន ១ ។ ដែលហៅថា អនតិរិត្ត បានដល់វត្ថុដែលមិនបានធ្វើវិនយកម្មដោយ (អាការ ៧ យ៉ាង) គឺរបស់ដែលគេមិនបានធ្វើឲ្យជាគួរ ១ របស់ដែលភិក្ខុមិនបានទទួលហើយធ្វើឲ្យជារបស់គួរ ១ របស់ដែលភិក្ខុមិនបានលើកឡើង (ឬមិនបានដាក់ទទួលទៅដើម្បីធ្វើឲ្យជារបស់គួរ) ១ ភិក្ខុមិនស្ថិតនៅក្នុងហត្ថបាសហើយធ្វើ ១

អភុត្តាវិនា កតំ ហោតិ ភុត្តាវិនា បវារិតេន អាសនា វុដ្ឋិតេន កតំ ហោតិ អលមេតំ សព្វន្តិ អវុត្តំ ហោតិ ន គិលានាតិរិត្តំ ហោតិ ឯតំ អនតិរិត្តំ នាម ។ ខាទនីយំ នាម បញ្ច ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ អភិហដ្ឋុំ បវារេយ្យាតិ យាវតកំ ឥច្ឆសិ តាវតកំ គណ្ហាហីតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ អាសាទនាបេក្ខោតិ ឥមិនា ឥមំ ចោទេស្សាមិ សារេស្សាមិ បដិចោទេស្សាមិ បដិសារេស្សាមិ មង្កុំ ករិស្សាមីតិ អភិហរតិ អាបត្តិ ទុក្កដស្ស ។ តស្ស វចនេន ខាទិស្សាមិ ភុញ្ជិស្សាមីតិ



ភិក្ខុមិនទាន់ឆាន់ហើយធ្វើ ១ ភិក្ខុឆាន់ហើយ ហាមភោជនហើយ ក្រោកចាកអាសនៈហើយធ្វើ ១ របស់ដែលភិក្ខុមិនពោលថា របស់ទាំងអស់នេះគួរហើយ ១ និងវត្ថុដែលមិនមែនជារបស់សល់អំពីភិក្ខុឈឺ ១ វត្ថុទាំង៨យ៉ាងនេះហៅថា អនតិរិត្ត ។ វត្ថុដែលហៅថា ខាទនីយ(នោះ) បានដល់វត្ថុទាំងអស់ លើកលែងតែភោជនទាំង៥យ៉ាង និងវត្ថុជាយាមកាលិក សត្តាហកាលិកនិងយាវជីវិកចេញ ហៅថា ខាទនីយ ។ វត្ថុដែលហៅថា ភោជនីយ បានដល់ភោជនទាំង៥យ៉ាងគឺបាយ ១ នំស្រួល ១ នំស្រៀម ១ ត្រី ១ សាច់ ១ ។ ពាក្យថា នាំភត្តទៅបវារណា (នោះ) គឺភិក្ខុនិយាយថា លោកចង់បានប៉ុន្មាន ចូរទទួលយកប៉ុណ្ណោះចុះ ។ ដែលហៅថា ដឹង (នោះ) គឺភិក្ខុដឹងខ្លួនឯង បុគ្គលដទៃទៀតប្រាប់ដល់ភិក្ខុអ្នកពោលនោះ ឬភិក្ខុអ្នកហាមភោជននោះប្រាប់ ។ ពាក្យថា រិះរកទោស (នោះ)គឺ ភិក្ខុនាំយក (ខាទនីយ ឬភោជនីយ) ទៅដោយគិតថា អញនឹងចោទនឹងរំលឹកភិក្ខុនេះដោយរឿងនេះ អញនឹងចោទត្រឡប់នឹងរំលឹកត្រឡប់ភិក្ខុនេះ ដោយរឿងនេះ អញនឹងធ្វើភិក្ខុនេះឲ្យអាម៉ាស់មុខ ដោយរឿងនេះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកហាមភោជនទទួលដោយគិតថា អញនឹងទំពាស៊ី នឹងឆាន់

បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ ភោជនបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[១៦៤] បវារិតេ បវារិតសញ្ញី អនតិរិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេតិ អាបត្តិ បាចិត្តិយស្ស ។ បវារិតេ វេមតិកោ អនតិរិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេតិ អាបត្តិ ទុក្កដស្ស ។ បវារិតេ អប្បវារិតសញ្ញី(១) អនតិរិត្តេន ខាទនីយេន វា ភោជនីយេន វា អភិហដ្ឋុំ បវារេតិ អនាបត្តិ ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ អភិហរតិ អាបត្តិ ទុក្កដស្ស ។ តស្ស វចនេន ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ អប្បវារិតេ(២) បវារិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អប្បវារិតេ(៣) វេមតិកោ អាបត្តិ ទុក្កដស្ស ។ អប្បវារិតេ(៤) អប្បវារិតសញ្ញី(៥) អនាបត្តិ ។

១-២-៣-៤-៥ ឱ ម. អប្បវារិត ។





តាមពាក្យរបស់លោកអ្នកនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដ គ្រប់ៗ ពំនូតដែលលេប ។ លុះភិក្ខុនោះឆាន់រួចស្រេច ភិក្ខុអ្នកបង្ខំ ត្រូវអាបត្តិបាចិត្តិយ ។

[១៦៤] ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកនោះសំគាល់ថាហាមហើយ ក៏នាំខាទនីយភោជនីយដែលជាអនតិរិត្តៈទៅបង្ខំ (ភិក្ខុនោះ) ឲ្យឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកនោះមានសេចក្តីសង្ស័យ ក៏នាំខាទនីយភោជនីយដែលជាអនតិរិត្តៈទៅបង្ខំឲ្យឆាន់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុហាមភោជនហើយ ភិក្ខុអ្នកនោះសំគាល់ថាមិនទាន់ហាម ក៏នាំខាទនីយភោជនីយដែលជាអនតិរិត្តៈទៅបង្ខំឲ្យឆាន់ មិនត្រូវអាបត្តិ ។ ភិក្ខុអ្នកនោះបង្អោនរបស់ដែលជាយាមកាលិក សត្តាហកាលិក យាវជីវិក ដើម្បីជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុអ្នកហាមភោជនទទួលចំណីនោះ ដោយគិតថា អញនឹងទំពាស៊ី នឹងឆាន់ តាមពាក្យរបស់លោកអ្នកនោះ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដ គ្រប់ៗ ពំនូតដែលលេប ។ ភិក្ខុមិនទាន់ហាមភោជនទេ តែភិក្ខុអ្នកនោះសំគាល់ថាហាម ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទាន់ហាមភោជនទេ ភិក្ខុអ្នកនោះសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមិនទាន់ហាមភោជន ភិក្ខុអ្នកនោះក៏សំគាល់ថា មិនទាន់ហាមមែន មិនត្រូវអាបត្តិ ។

[១២៨] អនាបត្តិ អតិរិត្តំ ការេត្វា ទេតិ អតិរិត្តំ ការាបេត្វា ភុញ្ជាហីតិ ទេតិ អញ្ញស្សត្ថាយ ហរត្ថ គណ្ហាហីតិ ទេតិ គិលានស្ស សេសកំ ទេតិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជាហីតិ ទេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។



[១៦៨] អាបត្តិមិនមាន ដល់ភិក្ខុដែលឲ្យភិក្ខុធ្វើឲ្យជាវិនយកម្មហើយឲ្យ ដល់ភិក្ខុដែលឲ្យដោយពាក្យថា លោកចូរឲ្យគេធ្វើឲ្យជាវិនយ-កម្មហើយនិមន្តឆាន់ចុះ ដល់ភិក្ខុដែលឲ្យដោយពាក្យថា លោកចូរនាំ (ខាទនីយភោជនីយាហារនេះ) ទៅដើម្បីប្រយោជន៍ដល់អ្នកដទៃចុះ ដល់ភិក្ខុដែលឲ្យរបស់សំណល់នៃភិក្ខុឈឺ ដល់ភិក្ខុដែលឲ្យរបស់ជាយាមកាលិក សត្តាហកាលិក យាវជីវិក ដោយពាក្យថា កាលបើមានហេតុចូរលោកឆាន់ចុះ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៦ ចប់ ។

## សត្តមសិក្ខាបទំ

[១៦៦] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន រាជគហេ គិរគ្គសមជ្ជោ ហោតិ ។ សត្តរសវគ្គិយា ភិក្ខូ គិរគ្គសមជ្ជំ ទស្សនាយ អគមំសុ ។ មនុស្សា សត្តរសវគ្គិយេ ភិក្ខូ បស្សិត្វា នហាបេត្វា វិលិម្បេត្វា ភោជេត្វា ខាទនីយំ អទំសុ ។ សត្តរសវគ្គិយា ភិក្ខូ ខាទនីយំ អាទាយ អារាមំ គន្ត្វា ឆព្ពគ្គិយេ ភិក្ខូ ឯតទវោចុំ គណ្ហថាវុសោ ខាទនីយំ ខាទថាតិ ។ កុតោ តុម្ហេហិ អាវុសោ ខាទនីយំ លទ្ធន្តិ ។ សត្តរសវគ្គិយា ភិក្ខូ ឆព្ពគ្គិយានំ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ កឹ បន តុម្ហេ អាវុសោ វិកាលេ ភោជនំ ភុញ្ជថាតិ ។ ឯវមាវុសោតិ ។ ឆព្ពគ្គិយា ភិក្ខូ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម សត្តរសវគ្គិយា ភិក្ខូ វិកាលេ ភោជនំ ភុញ្ជិស្សន្តីតិ ។

## សិក្ខាបទទី ៧

[១៦៦] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ក្រុងរាជគ្រឹះមានមហោស្រពលើកំពូលភ្នំ ។ ពួកសត្តរសវគ្គិយភិក្ខុក៏បាននាំគ្នាទៅដើម្បីមើលមហោស្រពដែលគេលេងលើកំពូលភ្នំ (នោះ) ។ មនុស្សទាំងឡាយ បានឃើញពួកសត្តរសវគ្គិយភិក្ខុហើយ និមន្តឲ្យស្រង់ទឹក ឲ្យលាប ឲ្យឆាន់ ស្រេចហើយក៏ប្រគេនខាទនីយៈ ។ ពួកសត្តរសវគ្គិយភិក្ខុ កាន់យកខាទនីយៈទៅអារាម ហើយនិយាយពាក្យនេះប្រាប់ពួកឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយចូរទទួលយកខាទនីយៈទៅឆាន់ចុះ ។ ពួកឆព្វគ្គិយភិក្ខុទាំងនោះសួរថា ម្នាលអាវុសោទាំងឡាយ ពួកលោកបានខាទនីយៈមកពីណា ។ ពួកសត្តរសវគ្គិយភិក្ខុបានប្រាប់រឿងនុ៎ះដល់ឆព្វគ្គិយភិក្ខុទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោទាំងឡាយ លោកទាំងឡាយបានឆាន់ភោជនក្នុងវេលាដែលមិនគួរមែនឬ ។ ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា មែនអាវុសោទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសត្តរសវគ្គិយភិក្ខុ មិនគួរនឹងឆាន់ភោជនក្នុងវេលាវិកាល (ដូច្នេះ) សោះ ។

វេទោ ឆព្ពគ្គិយា ភិក្ខូ ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សត្តរសវគ្គិយា ភិក្ខូ វិកាលេ ភោជនំ ភុញ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ វិកាលេ ភោជនំ ភុញ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា វិកាលេ ភោជនំ ភុញ្ជិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ វិកាលេ ខាទនីយំ វា ភោជនីយំ វា ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយន្តិ ។

(១៤៨) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ វិកាលោ នាម មជ្ឈន្ហិកេ វីតិវត្តេ យាវ អរុណុគ្គមនា ។ ខាទនីយំ នាម បញ្ច ភោជនានិ

១៣៦


វេលានោះឯង ពួកឆព្វគ្គិយភិក្ខុបានប្រាប់រឿងនុះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសត្តរសវគ្គិយភិក្ខុ មិនគួរឆាន់ភោជនក្នុងវេលាវិកាល (ផុតថ្ងៃ) ទេ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយឆាន់ភោជនក្នុងវេលាវិកាល ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងឆាន់ភោជនក្នុងវេលាវិកាលទេ នែមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា និងមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាស្រាប់ហើយឲ្យរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះដូច្នេះថា ភិក្ខុណាមួយទំពាស៊ី ឬបរិភោគ នូវខាទនីយៈ ឬភោជនីយៈ ក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ ។

(១៤៨) ត្រង់ពាក្យថា ភិក្ខុណាមួយ បានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ ។ វេលាដែលព្រះអាទិត្យទ្រេតពីត្រង់ទៅ លុះដល់ទីអរុណរះឡើង ហៅថា វេលាវិកាល ។ ដែលហៅថា ខាទនីយៈ (នោះ)

យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

(១៦៨) វិកាលេ វិកាលសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ វិកាលេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ វិកាលេ កាលសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ កាលេ



បានដល់របស់ទាំងអស់ វៀរលែងតែកាលិក ៣ យ៉ាង គឺវត្ថុជា យាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយៈ ។ វត្ថុដែលហៅថា ភោជនីយៈ បានដល់ភោជន ៥ យ៉ាងគឺបាយ ១ នំស្រួស ១ នំក្រៀប ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលវត្ថុទាំងនោះដោយគិតថា អញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ វារៈដែលលេបចូលទៅ ។

(១៦៨) វេលាវិកាល ភិក្ខុសំគាល់ថា វេលាវិកាល ហើយទំពាស៊ី បរិភោគនូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ វេលាវិកាល ភិក្ខុមានសេចក្តីសង្ស័យ ហើយទំពាស៊ី បរិភោគនូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ វេលាវិកាល ភិក្ខុសំគាល់ថា កាលគួរ ហើយទំពាស៊ី បរិភោគនូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលវត្ថុជា យាមកាលិក សត្តាហកាលិក នឹងយាវជីវិក ទុកសម្រាប់ជាប្រយោជន៍ដល់អាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះត្រូវអាបត្តិទុក្កដ គ្រប់ៗ វារៈដែលលេបចូលទៅ ។ វេលាជាកាលគួរ

វិកាលសញ្ញី អាបត្តិ ទុក្កដស្ស ។ កាលេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ កាលេ កាលសញ្ញី អនាបត្តិ ។

[១៦៩] អនាបត្តិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ទុម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ



ភិក្ខុសំគាល់ថា ពេលវិកាល ត្រូវអាបត្តិទុក្កដ ។ ពេលជាកាលគួរ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ពេលជាកាលគួរ ភិក្ខុសំគាល់ថា កាលគួរមែន មិនត្រូវអាបត្តិឡើយ ។

[១៦៩] អាបត្តិមិនមាន ដល់ភិក្ខុដែលឆាន់នូវវត្ថុជា យាមកាលិក សត្តាហកាលិក និងយាវជីវិក ដោយមានហេតុដែលគួរឆាន់បាន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

# អដ្ឋមសិក្ខាបទំ

[១៣០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មតោ អានន្ទស្ស ឧបជ្ឈាយោ អាយស្មា ពេលដ្ឋសីសោ(១) អរញ្ញេ វិហរតិ ។ សោ បិណ្ឌាយ ចរិត្វា ពហុំ បិណ្ឌបាតំ លភិត្វា(២) សុក្ខ(៣)កូរំ អារាមំ ហរិត្វា សុក្ខាបេត្វា និក្ខិបតិ ។ យទា អាហារេន អត្ថោ ហោតិ តទា ឧទកេន តេមេត្វា ភុញ្ជតិ ចិរេន គាមំ បិណ្ឌាយ បវិសតិ ។ ភិក្ខូ អាយស្មន្តំ ពេលដ្ឋសីសំ ឯតទវោចុំ កិស្ស ត្វំ អាវុសោ ចិរេន គាមំ បិណ្ឌាយ បវិសសីតិ ។ អថខោ អាយស្មា ពេលដ្ឋសីសោ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។

១ ឱ. ម. ពេលដ្ឋសីសោ ។ ២ ពហុំ បិណ្ឌបាតំ លភិត្វាតិបិ [illegible] ។ ៣ ឱ. ម. សុក្ខកូរំ ។

# សិក្ខាបទទី ៨

[១៣០] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះបេលដ្ឋសីសៈដ៏មានអាយុ ជាឧបជ្ឈាយ៍របស់ព្រះអានន្ទដ៏មានអាយុ គង់នៅក្នុងព្រៃ ។ ព្រះបេលដ្ឋសីសៈនោះត្រាច់ទៅបិណ្ឌបាត លុះបានអាហារបិណ្ឌបាតជាច្រើនហើយ ក៏នាំយកបាយស្ងួត(១)មកកាន់អាវាស រួចហាលបាយឲ្យស្ងួតក្រៀមហើយទុកដាក់ កាលណាមានសេចក្ដីត្រូវការដោយអាហារ ទើបយកបាយក្រៀមនោះមកត្រាំទឹក ហើយក៏ឆាន់ក្នុងកាលនោះ យូរៗ បានលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្ដង ។ ភិក្ខុទាំងឡាយ បាននិយាយពាក្យនេះនឹងព្រះបេលដ្ឋសីសៈដ៏មានអាយុថា ម្នាលអាវុសោ ព្រោះហេតុអ្វីបានជាយូរៗ ទើបលោកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាតម្ដង ។ ទើបព្រះបេលដ្ឋសីសៈដ៏មានអាយុក៏ដំណាលរឿងនុ៎ះប្រាប់ភិក្ខុទាំងឡាយ ។

១ អដ្ឋកថា និយាយតែម្យ៉ាង ចំពោះបាយស្ងួតនឹងខ្លួន [illegible] ។

កឹ បន ត្វំ អាវុសោ សន្និធិការកំ ភោជនំ ភុញ្ជសី-
តិ ។ ឯវមាវុសោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។
តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អា-
យស្មា វេឡដ្ឋសីសោ សន្និធិការកំ ភោជនំ ភុញ្ជិស្ស-
តីតិ ។ បេ ។ សច្ចំ កិរ ត្វំ វេឡដ្ឋសីស សន្និធិការកំ
ភោជនំ ភុញ្ជសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ
ភគវា កថំ ហិ នាម ត្វំ វេឡដ្ឋសីស សន្និធិការកំ
ភោជនំ ភុញ្ជិស្សសិ នេតំ វេឡដ្ឋសីស អប្បសន្នានំ
វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។
ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ
បន ភិក្ខុ សន្និធិការកំ ខាទនីយំ វា ភោជនីយំ វា
ខាទេយ្យ វា ភុញ្ជេយ្យ វា បាចិត្តិយន្តិ ។



ភិក្ខុទាំងនោះសួរថា ម្នាលអាវុសោ ចុះលោកឆាន់នូវ
ភោជនដែលខ្លួនទុកដាក់ឲ្យកន្លងកាលឬ ។ ព្រះវេឡដ្ឋសីសៈឆ្លើយថា
យ៉ាងហ្នឹងហើយ អាវុសោ ។ ភិក្ខុណាដែលមានសេចក្តីប្រាថ្នា
តិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា
ព្រះវេឡដ្ឋសីសៈដ៏មានអាយុ មិនសមបើនឹងឆាន់ភោជនដែលខ្លួនទុកដាក់
ឲ្យកន្លងកាល (ជុំយូរ) ទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា
ម្នាលវេឡដ្ឋសីសៈ ឮថាអ្នកឯងបានឆាន់ភោជនដែលខ្លួនទុកដាក់ឲ្យកន្លង
កាល ពិតមែនឬ ។ ព្រះវេឡដ្ឋសីសៈក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស
ពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាល
វេឡដ្ឋសីសៈ អ្នកឯងមិនសមបើនឹងឆាន់ភោជនដែលខ្លួនទុកដាក់ឲ្យកន្លង
កាល (ជុំយូរ) ទេ ម្នាលវេឡដ្ឋសីសៈ អំពើដែលអ្នកឯងធ្វើនេះមិនមែន
នាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ទាំងមិនមែននាំពួកជនដែល
ជ្រះថ្លាស្រាប់ហើយឲ្យរឹតតែជ្រះថ្លាក្រៃលែងឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំង
ឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុ
ណាមួយទំពាស៊ី ឬឆាន់ នូវខាទនីយៈ ឬភោជនីយៈជាសន្និធិការកៈ
គឺរបស់ដែលខ្លួនទុកដាក់ឲ្យកន្លងកាល ត្រូវអាបត្តិបាចិត្តិយ ។

[១៣១] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សន្និធិការកំ នាម អជ្ជ បដិគ្គហិតំ អបរជ្ជុ ខាទិតំ ហោតិ ។ ខាទនីយំ នាម បញ្ច ភោជនានិ យាគុកាលិកំ សត្តាហកាលិកំ យាវជី-វិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[១៣២] សន្និធិការកេ សន្និធិការកសញ្ញី ខា-ទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ សន្និធិការកេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ សន្និធិការកេ អសន្និធិការកសញ្ញី ខាទនីយំ វា ភោជនីយំ វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាចិត្តិយស្ស ។ យាមកាលិកំ សត្តាហកាលិកំ



[១៣១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ទុកទុកដាក់ឲ្យកន្លងរាត្រី (បានដល់ខាទនីយៈ ឬភោជនីយៈ) ដែលខ្លួនទទួលទុកក្នុងថ្ងៃនេះ ហើយឆាន់ក្នុងថ្ងៃជាន់ក្រោយ ។ ដែលហៅថា ខាទនីយៈ (នោះ) បានដល់វត្ថុពិសេសសម្រាប់ទំពាស៊ី វៀរលែងតែភោជនទាំង ៥ យ៉ាង នឹងវត្ថុជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ហៅថា ខាទនីយៈ ។ ដែលហៅថា ភោជនីយៈ បានដល់ភោជនទាំង ៥ យ៉ាង គឺបាយ ១ នំស្រួស ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលដោយគិតថា អាត្មានឹងទំពាស៊ី អាត្មានឹងឆាន់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗ ពារៈដែលលេបចូលទៅ ។

[១៣២] របស់ដែលជាសន្និធិការកៈ ភិក្ខុសំគាល់ថាជាសន្និធិការកៈមែន ហើយទំពាស៊ីក្ដី ឆាន់ក្ដី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ របស់ដែលជាសន្និធិការកៈ ភិក្ខុមានសេចក្ដីសង្ស័យ ហើយទំពាស៊ីក្ដី ឆាន់ក្ដី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ របស់ដែលជាសន្និធិការកៈ ភិក្ខុសំគាល់ថាមិនមែនជាសន្និធិការកៈ ហើយទំពាស៊ីក្ដី ឆាន់ក្ដី នូវខាទនីយៈ ឬភោជនីយៈ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទទួលវត្ថុជាយាមកាលិក សត្តាហកាលិក

យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ អសន្និធិការកេ សន្និធិការកសញ្ញី អាបត្តិ ទុក្កដស្ស ។ អសន្និធិការកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អសន្និធិការកេ អសន្និធិការកសញ្ញី អនាបត្តិ ។

[១៣៣] អនាបត្តិ យាវកាលិកំ យាវកាលេ និទហិត្វា ភុញ្ជតិ យាមកាលិកំ យាមេ និទហិត្វា ភុញ្ជតិ សត្តាហកាលិកំ សត្តាហំ និទហិត្វា ភុញ្ជតិ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



យាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ គ្រប់ៗខណៈដែលលេបចូលទៅ ។ របស់ដែលមិនមែនជាសន្និធិការកៈ ភិក្ខុសំគាល់ថាជាសន្និធិការកៈ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនជាសន្និធិការកៈ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ របស់មិនមែនជាសន្និធិការកៈ ភិក្ខុក៏សំគាល់ថាមិនមែនជាសន្និធិការកៈ មិនត្រូវអាបត្តិទេ ។

[១៣៣] អាបត្តិមិនមាន ដល់ភិក្ខុដែលទុកដាក់វត្ថុជា យាវកាលិក[១] ហើយឆាន់ត្រូវតាមកំណត់កាល ដល់ភិក្ខុដែលទុកដាក់វត្ថុជា យាមកាលិក[២] ហើយឆាន់ត្រូវតាមកំណត់យាម (គឺថ្ងៃ១ យប់១) ដល់ភិក្ខុដែលទុកដាក់វត្ថុជាសត្តាហកាលិក[៣] ហើយឆាន់អស់ត្រឹម៧ថ្ងៃ ដល់ភិក្ខុដែលឆាន់វត្ថុជា យាវជីវិក[៤] ព្រោះមានហេតុដែលគួរឆាន់បាន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

---

១ គឺអាហារ មានបាយនិងសាច់ជាដើម ដែលអ្នកបួសគប្បីឆាន់បានតាំងពីព្រឹកទាល់ថ្ងៃត្រង់ ហៅថាយាវកាលិក ។ ២ ទឹក ៨ យ៉ាងមានទឹកស្វាយជាដើម ដែលអ្នកបួសគប្បីឆាន់បានត្រឹមថ្ងៃ ១ យប់ ១ ហៅថាយាមកាលិក ។ ៣ ភេសជ្ជៈ ៥ យ៉ាង មានទឹកដោះថ្លាជាដើម ដែលអ្នកបួសគប្បីទុកឆាន់បានក្នុងរវាង ៧ ថ្ងៃ ហៅថា សត្តាហកាលិក ។ ៤ វត្ថុឯទៀតក្រៅពីកាលិកទាំង ៣ មានឫសជាដើម ដែលអ្នកបួសគប្បីទុកឆាន់បានគ្រប់ពេលអស់មួយជីវិត ហៅថា យាវជីវិក ។

## នវមសិក្ខាបទំ

(១៣៦) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សន្តិ កស្ស សម្បន្នំ ន មនាបំ កស្ស សាទុំ ន រុច្ចតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជថាតិ ។ សច្ចំ ភគវាតិ ។

## សិក្ខាបទទី៩

(១៣៦) សម័យនោះ ព្រះសម្មាសម្ពុទ្ធមានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ។ ពួកមនុស្សពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាកូនចៅព្រះពុទ្ធជាសក្យបុត្រ មិនសមបើនឹងសូមភោជនដ៏ឧត្តមទាំងឡាយដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់សោះ អ្នកណាមួយមិនគាប់ចិត្តនឹងភោជនដែលសម្បូរ អ្នកណាមួយមិនចូលចិត្តនឹងភោជនដែលមានរសឆ្ងាញ់ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ដូច្នេះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួន ហើយក៏នាំគ្នាឆាន់ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតមែន ។

វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ បណីតភោជនានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ មច្ឆោ មំសំ ខីរំ ទធិ ។ យោ បន ភិក្ខុ ឯវរូបានិ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១៣៨] តេន ខោ បន សមយេន ភិក្ខូ គិលានា ហោន្តិ ។ គិលានបុច្ឆកា ភិក្ខូ គិលានេ ភិក្ខូ ឯតទវោចុំ កច្ចាវុសោ ខមនីយំ កច្ចិ យាបនីយន្តិ ។ បុព្វេ មយំ អាវុសោ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជាម តេន នោ ផាសុ



ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលពួកបុរសសោះសូន្យ អ្នកទាំងឡាយ មិនសមនឹងសូមភោជនដ៏ឧត្តមទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ដូច្នេះទេ ពួកបុរសសោះសូន្យ អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ មួយទៀតពួកជនដែលជ្រះថ្លាហើយនឹងរឹតតែជ្រះថ្លាតទៅទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ ដូចម្តេច ភោជនដ៏ឧត្តមទាំងនោះគឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ។ ភិក្ខុណាមួយ សូមភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៣៨] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ ។ ពួកភិក្ខុអ្នកសួរជម្ងឺបាននិយាយពាក្យនេះនឹងភិក្ខុឈឺទាំងឡាយថា ម្នាលអាវុសោ លោកអាចអត់ទ្រាំបានឬទេ អាចប្រព្រឹត្តទៅបានឬទេ ។ ពួកភិក្ខុឈឺឆ្លើយថា ម្នាលអាវុសោ កាលមុនយើងទាំងឡាយបានសូមភោជនដ៏ឧត្តមទាំងឡាយមកដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់ ព្រោះហេតុនោះ

ហោតិ ឥទានិ បន ភគវតា បដិក្ខិត្តន្តិ កុក្កុច្ចាយន្តា ន វិញ្ញាបេម តេន នោ ន ផាសុ ហោតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា បណីតភោជនានិ វិញ្ញាបេត្វា ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ បណីតភោជនានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ មច្ឆោ មំសំ ខីរំ ទធិ ។ យោ បន ភិក្ខុ ឯវរូបានិ បណីតភោជនានិ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជេយ្យ បាចិត្តិយន្តិ ។

(១៣៦) យានិ ខោ បន តានិ បណីតភោជនានីតិ សប្បិ នាម គោសប្បិ វា អជិកាសប្បិ វា



ទើបយើងទាំងឡាយមានសេចក្តីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ យើងទាំងឡាយខ្លាចក្រែង មិនហ៊ានសូមទៀត ទើបសេចក្តីមិនសប្បាយមានដល់យើងទាំងឡាយៈដោយហេតុនោះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហៅភិក្ខុទាំងឡាយមកក្នុងពេលនោះហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុឈឺសូមភោជនដ៏ឧត្តមទាំងឡាយ មកៈដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះដូចម្តេច ភោជនដ៏ឧត្តមទាំងនោះគឺ ទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ស្ករអំពៅ ត្រី សាច់ ទឹកដោះស្រស់ ទឹកដោះជូរ ។ ភិក្ខុណាមួយគ្មានជម្ងឺសូមភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ ដើម្បីប្រយោជន៍ដល់ខ្លួនហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។

(១៣៦) ត្រង់ពាក្យថា ភោជនដ៏ឧត្តមទាំងឡាយណាមួយ ភោជនដ៏ឧត្តមទាំងនោះ គឺទឹកដោះថ្លារបស់គោក្តី ទឹកដោះថ្លារបស់ពពែក្តី

មហិសសប្បិ ក[១] យេសំ មំសំ កប្បតិ តេសំ សប្បិ ។ នវនីតំ នាម តេសំយេវ នវនីតំ ។ តេលំ នាម តិលតេលំ សាសបតេលំ មធុកតេលំ ឯរណ្ឌតេលំ វសាតេលំ ។ មធុ នាម មក្ខិកាមធុ ។ ផាណិតំ នាម ឧច្ឆម្ហា និព្វត្តំ ។ មច្ឆោ នាម ឧទកចរោ ក[២] វុច្ចតិ ។ មំសំ នាម យេសំ មំសំ កប្បតិ តេសំ មំសំ ។ ខីរំ នាម គោខីរំ វា អជិកាខីរំ វា មហិសខីរំ វា យេសំ មំសំ កប្បតិ តេសំ ខីរំ ។ ទធិ នាម តេសំយេវ ទធិ ។

[១៣៧] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ឯវរូបានិ បណីតភោជនានីតិ ឯវរូបានិ បណីតភោជនានិ ។ អគិលានោ នាម យស្ស វិនា បណីតភោជនានិ ផាសុ ហោតិ ។

---

១ ។ មហិសំ ក សប្បិ ។ ឧ. មាហឹសា សប្បិ ក ។ ២ សព្វត្ថ ឦ្ញវិសោធនៅ ជាពុំ ទិស្សតិ ភិក្ខុធីរានុញ្ញ តាមសេចក្តីយោបល់ ១៥ សព្វត្ថ ឲ្យករណី ទិស្សតិ ។ វិនយដ្ឋា គហេតព្វំ ។



ទឹកដោះថ្លារបស់ក្របី ហៅថាទឹកដោះថ្លា ម្យ៉ាងទៀតសាច់របស់ពួកសត្វណាក៏គួរ (ដល់វិនយបញ្ញត្តិ) ទឹកដោះថ្លារបស់ពួកសត្វនោះ ហៅថា ទឹកដោះថ្លាដូចគ្នា ។ ទឹកដោះខាប់របស់ពួកសត្វទាំងនោះឯង ហៅថា ទឹកដោះខាប់ដូចគ្នា ។ ប្រេងល្ង ប្រេងស្ពៃ ប្រេងស្រែង ប្រេងល្ហុងខ្វង និងប្រេងខ្លាញ់ ហៅថា ប្រេង ។ ទឹកឃ្មុំរបស់ឃ្មុំ ហៅថា ទឹកឃ្មុំ ។ ទឹកអំពៅដែលកើតអំពីអំពៅ ហៅថា ទឹកអំពៅស្ករអំពៅ ។ សត្វដែលត្រាច់ទៅក្នុងទឹក ហៅថា ត្រីមួយជាតិ ។ សាច់នៃពួកសត្វណាក៏គួរ (ដល់វិនយបញ្ញត្តិ) សាច់នៃពួកសត្វទាំងនោះ ហៅថា សាច់ម្យ៉ាងៈ ។ ទឹកដោះស្រស់របស់គោក្តី ទឹកដោះស្រស់របស់ពពែក្តី ទឹកដោះស្រស់របស់ក្របីក្តី ហៅថា ទឹកដោះស្រស់ចុះទី សាច់របស់ពួកសត្វណាក៏គួរ (ដល់វិនយបញ្ញត្តិ) ទឹកដោះស្រស់របស់ពួកសត្វទាំងនោះ ហៅថា ទឹកដោះស្រស់ចុះទី ។ ទឹកដោះជូររបស់ពួកសត្វទាំងនោះ ហៅថា ទឹកដោះជូរដូចគ្នា ។

[១៣៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ ។ ពាក្យថា ភោជនដ៏ឧត្តមទាំងឡាយមានសភាពយ៉ាងនេះ គឺភោជនដ៏ឧត្តមទាំងឡាយមានសភាពដូច្នោះ ។ ភិក្ខុណាវៀរភោជនដ៏ឧត្តមទាំងឡាយហើយនៅជាសប្បាយបាន ភិក្ខុនោះហៅថាគ្មានជម្ងឺ ។

គិលានោ នាម យស្ស វិនា បណីតភោជនានិ ន ផាសុ ហោតិ ។ អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេតិ បយោគេ ទុក្កដំ ។ បដិលាភេន ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។

[១៣៨] អគិលានោ អគិលានសញ្ញី បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានោ វេមតិកោ បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អគិលានោ គិលានសញ្ញី បណីតភោជនានិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ គិលានោ អគិលានសញ្ញី អាបត្តិ ទុក្កដស្ស ។ គិលានោ វេមតិកោ អាបត្តិ ទុក្កដស្ស ។ គិលានោ គិលានសញ្ញី អនាបត្តិ ។



ភិក្ខុណាបើវៀរចាកភោជនដ៏ថ្លៃៗទាំងឡាយ ហើយនៅសប្បាយមិនបាន ភិក្ខុនោះហៅថាមានជម្ងឺ ។ ភិក្ខុគ្មានជម្ងឺ សូមភោជនថ្លៃនោះ ដើម្បីប្រយោជន៍ដល់ខ្លួន ត្រូវអាបត្តិទុក្កដក្នុងប្រយោគ ។ ភិក្ខុទទួលដោយគំនិតថា អញនឹងឆាន់ ត្រូវអាបត្តិទុក្កដក្នុងខណៈដែលបានមក ។ ភិក្ខុនោះ ត្រូវអាបត្តិបាចិត្តិយគ្រប់ៗ ពំនូតដែលលេបចូលទៅ ។

[១៣៨] ខ្លួនមិនឈឺ ភិក្ខុសំគាល់ថាខ្លួនមិនឈឺ ហើយសូមភោជនដ៏ថ្លៃៗទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនឈឺ ភិក្ខុមានសេចក្ដីសង្ស័យ ហើយសូមភោជនដ៏ថ្លៃៗទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនមិនឈឺ ភិក្ខុសំគាល់ថាខ្លួនឈឺ ហើយសូមភោជនដ៏ថ្លៃៗទាំងឡាយមក ដើម្បីប្រយោជន៍ដល់ខ្លួន ហើយឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ ខ្លួនឈឺ ភិក្ខុសំគាល់ថាខ្លួនមិនឈឺ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្លួនឈឺ ភិក្ខុសំគាល់ថាខ្លួនឈឺ មិនត្រូវអាបត្តិ ។

[១៣៩] អនាបត្តិ គិលានស្ស គិលានោ ហុត្វា វិញ្ញាបេត្វា អគិលានោ ភុញ្ជតិ គិលានស្ស សេសកំ ភុញ្ជតិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។



[១៣៩] អាបត្តិមិនមាន ដល់ភិក្ខុឈឺ ដល់ភិក្ខុដែលមានជម្ងឺហើយសូម លុះសូមបាននមកកំចាត់ជម្ងឺអាពាធហើយឆាន់ ដល់ភិក្ខុដែលឆាន់ភោជនដ៏សេសសល់អំពីភិក្ខុឈឺ , ដល់ភិក្ខុដែលឆាន់ភោជនរបស់ពួកញាតិ ដល់ភិក្ខុដែលឆាន់ភោជនរបស់ពួកជនដែលបានបវារណា ដល់ភិក្ខុដែលសូមដើម្បីប្រយោជន៍ដល់អ្នកឯទៀត ដល់ភិក្ខុដែលឆាន់ភោជនដែលកើតដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាខាងដើមបញ្ញត្តិ ។

សិក្ខាបទទី ៩ ចប់ ។

## ទសមសិក្ខាបទំ

[១៦០] តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សព្ពបំសុកូលិកោ សុសានេ វិហរតិ ។ សោ មនុស្សេហិ ទិយ្យមានំ ន ឥច្ឆតិ បដិគ្គហេតុំ ។ សុសានេបិ រុក្ខមូលេបិ ឧម្មារេបិ អយ្យវោសាដិតកានិ សាមំ គហេត្វា ភុញ្ជតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អយំ ភិក្ខុ អម្ហាកំ អយ្យវោសាដិតកានិ សាមំ គហេត្វា ភុញ្ជិស្សតិ ថេរោយំ ភិក្ខុ វឆោ មនុស្សមំសំ មញ្ញេ ខាទតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ អទិន្នំ មុខទ្វារំ អាហារំ អាហរិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ អទិន្នំ

## សិក្ខាបទទី ១០

[១៦០] គ្រានោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងកូដាគារសាលា ក្នុងមហាវន ទៀបក្រុងវេសាលី ។ សម័យនោះឯង មានភិក្ខុ ១ រូប ជាអ្នកប្រព្រឹត្តបង្សុកូលទាំងអស់គ្រប់យ៉ាង(១) នៅក្នុងព្រៃស្មសាន ។ ភិក្ខុនោះមិនព្រមទទួលយកវត្ថុដែលមនុស្សគេឲ្យឡើយ ។ ភិក្ខុនោះកាន់យកនូវរបស់សែន ក្នុងព្រៃស្មសានខ្លះ ទៀបគល់ឈើខ្លះ ទៀបធរណីទ្វារខ្លះ ដោយខ្លួនឯង ហើយឆាន់ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុនេះមិនគួរបើនឹងកាន់យករបស់សែនរបស់យើងទាំងឡាយដោយខ្លួនឯង ហើយឆាន់ទេ ភិក្ខុនេះ មានកាយធាត់ ដូចជាស៊ីសាច់មនុស្សមែនពិត ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងស៊ីលេបចូលតាមច្រកទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេនសោះ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងស៊ីលេបនូវអាហារ

---

១ អធិប្បាយថា ភិក្ខុនេះប្រព្រឹត្តបង្សុកូលគ្រប់ទាំងអស់ ដោយហោចទៅសូម្បីស្បង់ក៏បង្សុកូលយកដែរ ។

មុខទ្វារំ អាហារំ អាហរាសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស អទិន្នំ មុខទ្វារំ អាហារំ អាហរិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អទិន្នំ មុខទ្វារំ អាហារំ អាហរេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣៥៣] តេន ខោ បន សមយេន ភិក្ខូ ឧទកទន្តបោណេ កុក្កុច្ចាយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧទកទន្តបោណំ សាមំ គហេត្វា ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អទិន្នំ មុខទ្វារំ អាហារំ អាហរេយ្យ អញ្ញត្រ ឧទកទន្តបោណា បាចិត្តិយន្តិ ។



តាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងស៊ីលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន (ដូច្នេះ) ទេ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងរឹតទៅទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៣៥៣] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្ដីសង្ស័យក្នុងទឹកនិងឈើស្ទន់ ។ ពួកភិក្ខុទាំងនោះបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុកាន់យកទឹកនិងឈើស្ទន់ចាប់ដោយខ្លួនឯងបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹកនិងឈើស្ទន់ ។

(១៦៤) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អទិន្នំ នាម អប្បដិគ្គហិតកំ វុច្ចតិ ។ ទិន្នំ នាម កាយេន វា កាយបដិពទ្ធេន វា និស្សគ្គិយេន វា ទេន្តេ ហត្ថបាសេ ឋិតោ កាយេន វា កាយបដិពទ្ធេន វា បដិគ្គណ្ហាតិ ឯតំ ទិន្នំ នាម ។ អាហារោ នាម ឧទកទន្តបោណំ ឋបេត្វា យំកិញ្ចិ អជ្ឈោហរណីយំ ឯសោ អាហារោ នាម ។ អញ្ញត្រ ឧទកទន្តបោណាតិ ឋបេត្វា ឧទកទន្តបោណំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាចិត្តិយស្ស ។



(១៦៤) ត្រង់ពាក្យថា ភិក្ខុណាមួយ ជាដើម សេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា គេមិនបានប្រគេន គឺរបស់ដែលភិក្ខុមិនបានទទួលប្រគេន ។ ដែលហៅថា របស់ដែលគេប្រគេន គឺកាលបើគេយកឲ្យរបស់ណាដោយកាយក្ដី ដោយរបស់ដែលជាប់នឹងកាយក្ដី ដោយបោះឲ្យក្ដី ភិក្ខុក៏ស្ថិតនៅក្នុងហត្ថបាស បានទទួល(១)ដោយកាយ ឬ ដោយរបស់ដែលជាប់នឹងកាយ របស់នេះហៅថា គេប្រគេន ។ ដែលហៅថា អាហារ គឺរបស់ណាមួយដែលគួរលេបចូលទៅបាន វៀរលែងនៃទឹកនឹងឈើស្ទន់ របស់នេះហៅថា អាហារ ។ ពាក្យថា វៀរលែងនៃទឹកនឹងឈើស្ទន់ គឺលើកលែងតែទឹកនឹងឈើស្ទន់ ។ ភិក្ខុទទួលយកដោយគិតថា អញនឹងទំពាស៊ី អញនឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលេបត្រូវអាបត្តិបាចិត្តិយ គ្រប់ៗពំនូតដែលលេបចូលទៅ ។

---

១ អដ្ឋកថា ពិពណ៌នាការទទួលប្រគេនប្រកបដោយអង្គ ៥ គឺ ១ វត្ថុដែលប្រគេនមានទំហំល្មមនឹងបុរសកណ្ដាល លើកឡើងបាន ។ ២ អ្នកប្រគេនឋិតនៅក្នុងហត្ថបាស ។ ៣ អ្នកប្រគេនបង្អោនវត្ថុចូលមក ។ ៤ ទេវតាក្ដី មនុស្សក្ដី សត្វតិរច្ឆានក្ដីប្រគេន ។ ៥ ភិក្ខុទទួលវត្ថុនោះដោយកាយក្ដី ដោយវត្ថុដែលជាប់នឹងកាយក្ដី ។

[១៤៣] អប្បដិគ្គហិតកេ អប្បដិគ្គហិតកសញ្ញី អទិន្នំ មុខទ្វារំ អាហារំ អាហរតិ អញ្ញត្រ ឧទកទន្តបោណា អាបត្តិ បាចិត្តិយស្ស ។ អប្បដិគ្គហិតកេ វេមតិកោ អទិន្នំ មុខទ្វារំ អាហារំ អាហរតិ អញ្ញត្រ ឧទកទន្តបោណា អាបត្តិ បាចិត្តិយស្ស ។ អប្បដិគ្គហិតកេ បដិគ្គហិតកសញ្ញី អទិន្នំ មុខទ្វារំ អាហារំ អាហរតិ អញ្ញត្រ ឧទកទន្តបោណា អាបត្តិ បាចិត្តិយស្ស ។ បដិគ្គហិតកេ អប្បដិគ្គហិតកសញ្ញី អាបត្តិ ទុក្កដស្ស ។ បដិគ្គហិតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បដិគ្គហិតកេ បដិគ្គហិតកសញ្ញី អនាបត្តិ ។

[១៤៤] អនាបត្តិ ឧទកទន្តបោណេ ចត្តារិ មហាវិកដានិ សតិ បច្ចយេ អសតិ កប្បិយការកេ សាមំ គហេត្វា បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

ភោជនវគ្គោ ចតុត្ថោ ។



(១៤៣) វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុក៏សំគាល់ថាមិនបានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹកនិងឈើស្ទន់ ។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសង្ស័យ ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹកនិងឈើស្ទន់ ។ វត្ថុដែលភិក្ខុមិនបានទទួលប្រគេន ភិក្ខុសំគាល់ថាបានទទួលប្រគេន ហើយលេបនូវអាហារតាមទ្វារមាត់ ជាអាហារដែលគេមិនបានប្រគេន ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែទឹកនិងឈើស្ទន់ ។ វត្ថុដែលភិក្ខុបានទទួលប្រគេន ភិក្ខុសំគាល់ថាមិនទាន់បានទទួលប្រគេន ត្រូវអាបត្តិទុក្កដ ។ វត្ថុដែលភិក្ខុទទួលប្រគេន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ វត្ថុដែលភិក្ខុទទួលប្រគេនហើយ ភិក្ខុក៏សំគាល់ថាបានទទួលប្រគេនហើយ មិនត្រូវអាបត្តិឡើយ ។

(១៤៤) អាបត្តិមិនមានដល់ភិក្ខុដែលឆាន់ទឹកនិងឈើស្ទន់ ដល់ភិក្ខុដែលកាន់យកនូវមហាវិកដ ៤ យ៉ាង(១) ដោយខ្លួនឯងហើយឆាន់ ព្រោះមានហេតុ ហើយគ្មានកប្បិយការក ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

សិក្ខាបទទី ១០ ចប់ ។

ភោជនវគ្គទី ៤ ចប់ ។

---

១ មហាវិកដ ៤ គឺ មូត្រ ១ គូថ ១ ផេះ ១ ដី ១ ។

## គសុត្តាប់

បិណ្ឌោ គណោ ពរ បូរ

ទេ ច វុត្តា បករណា[១]

វិការោ[២] សន្ធិ ការ[៣]

បណីតំ ក្ខារតំ គរុតំ[៤]

---

១ ម. ពុត្តា បករណា ។ ២ ម. វិការោ ។ ៣ ម. ស. សន្ធិចំ វីរំ ។ ៤ ម ម

ទក្ខោណេឌ ៤ ទណាតិ ។





ចំនួនសិក្ខាបទក្នុងភោជនវគ្គនោះមាន ១០ យ៉ាង គឺ

បិណ្ឌ (សិក្ខាបទ) ១ គណ (សិក្ខាបទ) ១

បរ (សិក្ខាបទ) ១ បូរ (សិក្ខាបទ) ១

បករណ (សិក្ខាបទ) ភ័រ ក្រះជំហាន ក្រះការកោលរហ័យ

វិការ (សិក្ខាបទ) ១ សន្និធិការ (សិក្ខាបទ) ១

បណីត (សិក្ខាបទ) ១ ក្ខារក (សិក្ខាបទ) ១ ។

## អចេលកវគ្គស្ស បឋមសិក្ខាបទំ

(១៦៥) តេន សមយេន ពុទ្ធោ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន សង្ឃស្ស ខាទនីយំ ឧស្សន្នំ ហោតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ តេនហានន្ទ វិឃាសាទានំ បូវំ ទេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា វិឃាសាទេ បដិបាដិយា និសីទាបេត្វា ឯកេកំ បូវំ ទេន្តោ អញ្ញតរិស្សា បរិព្វាជិកាយ ឯកំ មញ្ញមានោ ទ្វេ បូវេ អទាសិ ។ សាមន្តា បរិព្វាជិកាយោ តំ បរិព្វាជិកំ ឯតទវោចុំ ជារោ តេ ឯសោ សមណោតិ ។ ន មេ សោ សមណោ ជារោ ឯកំ មញ្ញមានោ ទ្វេ បូវេ អទាសីតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ឯកេកំ បូវំ ទេន្តោ តស្សា-យ បរិព្វាជិកាយ ឯកំ មញ្ញមានោ ទ្វេ បូវេ អទាសិ ។

## អចេលកវគ្គ សិក្ខាបទទី ១

[១៦៥] កាលនោះ ព្រះសព្វញ្ញុពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងកូដាគារសាលា ក្នុងព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ សម័យនោះឯង របស់ដែលបុគ្គលគប្បីទំពាស៊ីកើតឡើងដល់សង្ឃ ។ ព្រះអានន្ទដ៏មានអាយុក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ បើដូច្នោះអ្នកចូរឲ្យនំដល់ពួកមនុស្សអ្នកស៊ីដែលចុះ ។ ព្រះអានន្ទដ៏មានអាយុទទួលព្រះពុទ្ធដីកាថា បពិត្រព្រះអង្គដ៏ចំរើន ហើយនឹងញ៉ាំងហើយៗ ក៏ឲ្យពួកមនុស្សដែលជាអ្នកស៊ីដែលអង្គុយតាមលំដាប់ ហើយក៏ឲ្យនំមួយៗ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាងបរិព្វាជិកាម្នាក់ ដោយសំគាល់ថាឲ្យនំមួយដូចគេឯទៀតដែរ ។ ពួកនាងបរិព្វាជិកា (ដែលទៅ) ជុំវិញ បាននិយាយពាក្យនេះចំពោះនាងបរិព្វាជិកានោះថា សមណនេះជាសហាយរបស់នាងទេ ។ នាងបរិព្វាជិកានោះឆ្លើយថា សមណនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថាឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ ក៏ជាគំរប់ពីរដង ព្រះអានន្ទដ៏មានអាយុ ឲ្យនំមួយៗ (ដល់មនុស្សដែលជាអ្នកស៊ីដែល) រួចឲ្យនំពីរទៅនាងបរិព្វាជិកាដដែលនោះ ដោយសំគាល់ថាឲ្យនំមួយដូចគេឯទៀតដែរ ។

សាមន្តា បរិព្វាជិកាយោ តំ បរិព្វាជិកំ ឯតទវោចុំ ជារោ តេ ឯសោ សមណោតិ ។ ន មេ សោ សមណោ ជារោ ឯកំ មញ្ញមានោ ទ្វេ បូវេ អទាសីតិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ ឯកេកំ បូវំ ទេន្តោ តស្សាយេវ បរិព្វាជិកាយ ឯកំ មញ្ញមានោ ទ្វេ បូវេ អទាសិ ។ សាមន្តា បរិព្វាជិកាយោ តំ បរិព្វាជិកំ ឯតទវោចុំ ជារោ តេ ឯសោ សមណោតិ ។ ន មេ សោ សមណោ ជារោ ឯកំ មញ្ញមានោ ទ្វេ បូវេ អទាសីតិ ។ ជារោ ន ជារោតិ ឧជ្ឈាយិំសុ ។ អញ្ញតរោបិ អាជីវកោ បរិវេសនំ អគមាសិ ។ អញ្ញតរោ ភិក្ខុ បហូតេន សប្បិនា ឱទនំ មទ្ទិត្វា តស្ស អាជីវកស្ស មហន្តំ បិណ្ឌំ អទាសិ ។ អថ ខោ សោ អាជីវកោ តំ បិណ្ឌំ អាទាយ អគមាសិ ។ អញ្ញតរោ អាជីវកោ តំ អាជីវកំ ឯតទវោច កុតោ



ពួកនាងបរិព្វាជិកា (ដែលនៅ) ជុំវិញ ក៏និយាយពាក្យនេះនឹងនាងបរិព្វាជិកានោះថា សមណៈនុ៎ះជាសហាយរបស់នាងឬ ។ នាងបរិព្វាជិកានោះឆ្លើយថា សមណៈនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថាឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ ជាគំរប់ពីរដងទៀត ព្រះអានន្ទដ៏មានអាយុ ឲ្យនំមួយៗ (ដល់មនុស្សដែលជាន្ទាស៊ីដង) ឲ្យនំពីរទៅនាងបរិព្វាជិកាដដែលនោះ ដោយសំគាល់ថាឲ្យនំមួយដូចគេ ទាំងគ្នាដែរ ។ ពួកនាងបរិព្វាជិកា (ដែលនៅ) ជុំវិញ ក៏និយាយពាក្យនេះនឹងនាងបរិព្វាជិកានោះថា សមណៈនុ៎ះជាសហាយរបស់នាងឬ ។ នាងបរិព្វាជិកានោះឆ្លើយថា សមណៈនុ៎ះមិនមែនជាសហាយរបស់ខ្ញុំទេ គឺលោកសំគាល់ថាឲ្យនំមួយដល់ខ្ញុំ តែត្រឡប់ទៅជាឲ្យនំពីរមកវិញ ។ ពួកនាងបរិព្វាជិកាទាំងនោះ ក៏តាំងគ្នានិយាយថាអ្នកថា (សមណៈនុ៎ះ) សហាយឬមិនមែនសហាយ ។ (វេលានោះ) មានអាជីវកម្នាក់ដើរទៅកាន់ទីដែលគេអង្គាស ឬចែក(នំ) ។ (វេលានោះ) មានភិក្ខុមួយរូបក៏ច្របាច់បាយលាយជាមួយទឹកដោះថ្លាដ៏ច្រើន ហើយក៏ឲ្យដុំបាយធំដល់អាជីវកនោះ ។ លំដាប់នោះ អាជីវកនោះក៏កាន់យកដុំបាយនោះហើយចេញទៅ ។ (វេលានោះ) មានអាជីវកម្នាក់ទៀតបានពោលពាក្យនេះនឹងអាជីវកនោះថា

តយា អាវុសោ បិណ្ឌោ លទ្ធោតិ ។ តស្សាហាវុសោ សមណស្ស គោតមស្ស មុណ្ឌកគហបតិកស្ស បរិវេសនាយ លទ្ធោតិ ។ អស្សោសុំ ខោ ឧបាសកា តេសំ អាជីវកានំ ឥមំ កថាសល្លាបំ ។ អថខោ តេ ឧបាសកា យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទឹសុ ។ ឯកមន្តំ និសិន្នា ខោ តេ ឧបាសកា ភគវន្តំ ឯតទវោចុំ ឥមេ ភន្តេ តិត្ថិយា អវណ្ណកាមា ពុទ្ធស្ស អវណ្ណកាមា ធម្មស្ស អវណ្ណកាមា សង្ឃស្ស សាធុ ភន្តេ អយ្យា តិត្ថិយានំ សហត្ថា ន ទទេយ្យុន្តិ ។ អថខោ ភគវា តេ ឧបាសកេ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ តេ ឧបាសកា ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា



ម្នាលអាវុសោ អ្នកឯងបានដុំបាយមកពីណា ។ អាជីវកដែលបានដុំបាយនោះឆ្លើយថា ម្នាលអាវុសោ ដុំបាយខ្ញុំបានមកអំពីទីដែលគេអង្គាសនៃមុណ្ឌកគហបតី (គហបតីក្រពើល) របស់ព្រះសមណគោតមនោះ ។ ពួកឧបាសកបានឮពាក្យពោលនៃពួកអាជីវកនោះច្បាស់លាស់ហើយ ។ ទើបពួកឧបាសកទាំងនោះចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក្រាបថ្វាយបង្គំព្រះដ៏មានបុណ្យហើយក៏អង្គុយក្នុងទី ១ ដ៏សមគួរ ។ ឧបាសកទាំងនោះ លុះអង្គុយក្នុងទីដ៏សមគួរហើយក៏ក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ពួកតិរ្ថិយទាំងឡាយនេះ ប្រាថ្នានឹងពោលទោសដល់ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ បពិត្រព្រះអង្គដ៏ចំរើន សូមកុំឲ្យលោកម្ចាស់ទាំងឡាយឲ្យ (វត្ថុ) ដល់ពួកតិរ្ថិយដោយដៃរបស់ខ្លួនឡើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឧបាសកទាំងនោះ ឲ្យឃើញច្បាស់លាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ។ ឯពួកឧបាសកទាំងនោះ កាលព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់លាស់ ទ្រង់ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថា ហើយក៏ក្រោកចាកអាសនៈ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ

បក្កាមិំសុ ។ អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ[១] បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូនំ អននុច្ឆវិកំ អននុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញាបេស្សាមិ ទសអត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ។ បេ ។ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ អចេលកស្ស វា បរិព្វាជកស្ស វា បរិព្វាជិកាយ វា សហត្ថា ខាទនីយំ វា ភោជនីយំ វា ទទេយ្យ បាចិត្តិយន្តិ ។

[១២៦] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មិំ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អចេលកោ នាម យោ កោចិ បរិព្វាជកសមាបន្នោ នគ្គោ ។ បរិព្វាជកោ នាម ភិក្ខុញ្ច

១ ភិក្ខុសង្ឃំ ។បេ។ អនុលោមិកំ មានតែក្នុងបាលីសៀមប៉ុណ្ណោះ ។





ធ្វើប្រទក្សិណ ហើយចៀសចេញទៅ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគ ត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ទ្រង់ធ្វើធម្មីកថាដ៏សមគួរសមគួរតាមហេតុនោះ ដល់ពួកភិក្ខុ ហើយទ្រង់ហៅភិក្ខុទាំងឡាយមកត្រាស់ថា នែភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺ ដើម្បីសេចក្ដីល្អដល់សង្ឃ ១ ដើម្បីសេចក្ដីស្រួលដល់សង្ឃ ១ ។ បេ ។ ដើម្បីតាំងនៅនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះដល់វិន័យ ១ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ឲ្យនូវវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដល់អចេលកក្ដី បរិព្វាជកក្ដី បរិព្វាជិកាក្ដី ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

(១២៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ដែលហៅថា អចេលក គឺបុគ្គលដែលបួសជាបរិព្វាជកមានកាយអាក្រាតទាំងអស់ ។ ដែលហៅថា បរិព្វាជក គឺបុគ្គលដែលបួសជាបរិព្វាជកទាំងអស់ វៀរលែងតែភិក្ខុនឹងសាមណេរចេញ ។ ដែលហៅថា បរិព្វាជិកា គឺស្រីដែលបួសជាបរិព្វាជិកាទាំងអស់

សាមណេរិញ្ច ឋបេត្វា យោ កោចិ បរិព្វាជកសមាបន្នោ ។ បរិព្វាជិកា នាម ភិក្ខុនិញ្ច សិក្ខមានញ្ច សាមណេរិញ្ច ឋបេត្វា យា កាចិ បរិព្វាជិកសមាបន្នា ។ ខាទនីយំ នាម បញ្ច ភោជនានិ ឧទកទន្តបោណំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ទទេយ្យាតិ កាយេន វា កាយបដិពទ្ធេន វា និស្សគ្គិយេន វា ទេតិ អាបត្តិ បាចិត្តិយស្ស ។

[១៤៧] តិត្ថិយេ តិត្ថិយសញ្ញី សហត្ថា ខាទនីយំ វា ភោជនីយំ វា ទេតិ អាបត្តិ បាចិត្តិយស្ស ។ តិត្ថិយេ វេមតិកោ សហត្ថា ខាទនីយំ វា ភោជនីយំ វា ទេតិ អាបត្តិ បាចិត្តិយស្ស ។ តិត្ថិយេ អតិត្ថិយសញ្ញី សហត្ថា ខាទនីយំ វា ភោជនីយំ វា ទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧទកទន្តបោណំ ទេតិ អាបត្តិ ទុក្កដស្ស ។ អតិត្ថិយេ តិត្ថិយសញ្ញី



វៀរលែងភិក្ខុនី សិក្ខមានា និងសាមណេរីចេញ ។ ដែលហៅថា វត្ថុដែលបុគ្គលគួរទំពាស៊ី គឺលើកទុកនូវភោជនៈ ៥ យ៉ាង ព្រមទាំងទឹកនិងឈើស្ទន់ចេញ ក្រៅពីនោះហៅថា វត្ថុដែលបុគ្គលគួរទំពាស៊ីទាំងអស់ ។ ដែលហៅថា វត្ថុដែលបុគ្គលគួរបរិភោគ បានដល់ភោជនៈ ៥ យ៉ាង គឺបាយ ១ នំស្រួយ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ពាក្យថា ឲ្យ គឺភិក្ខុឲ្យដោយកាយក្តី ដោយវត្ថុដែលជាប់នឹងកាយក្តី ដោយការបោះឲ្យក្តី ត្រូវអាបត្តិបាចិត្តិយ ។

(១៤៧) ជនជាតិរ្ថិយ ភិក្ខុក៏សំគាល់ថាជាតិរ្ថិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ជនជាតិរ្ថិយ ភិក្ខុមានសេចក្តីសង្ស័យ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ជនជាតិរ្ថិយ ភិក្ខុសំគាល់ថាមិនមែនជាតិរ្ថិយ ហើយឲ្យវត្ថុដែលគួរទំពាស៊ី ឬវត្ថុដែលគួរបរិភោគ ដោយដៃរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុឲ្យទឹកនិងឈើស្ទន់ ត្រូវអាបត្តិទុក្កដ ។ បុគ្គលមិនមែនជាតិរ្ថិយ

អាបត្តិ ទុក្កដស្ស ។ អនិត្ថិយា វេមតិកា អាបត្តិ ទុក្កដស្ស ។ អនិត្ថិយា អនិត្ថិសញ្ញី អនាបត្តិ ។

[១៥៨] អនាបត្តិ ធោវេតិ ន ឆេតិ ឧបចិក្ខិតា ឆេតិ ពាហិរលេបំ(១) ឆេតិ ឧម្មត្តិកាយ អាទិកម្មិ-កាយាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។

១ ម. ពាហិរលេបំ ។





ភិក្ខុនីសំគាល់ថាជាស្ត្រីយ ត្រូវអាបត្តិទុក្កដ ។ ដល់មិនមែនជាស្ត្រីយ ភិក្ខុនីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ដល់មិនមែនជាស្ត្រីយ ភិក្ខុនីសំគាល់ថា មិនមែនជាស្ត្រីយ មិនត្រូវអាបត្តិឡើយ ។

[១៥៨] អាបត្តិមិនមាន ដល់ភិក្ខុនីដែលប្រើគេឲ្យ មិនឲ្យដោយ ខ្ចប់ ដល់ភិក្ខុនីដែលដាក់(១)ក្នុងភាជន៍ ដល់ភិក្ខុនីដែលឲ្យលាបគ្រឿងលាបខាងក្រៅ(២) ដល់ភិក្ខុនីឆ្កួត ដល់ភិក្ខុនីដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

១ ពិធ្វើការបំរុងភាជន៍ ហើយលើកយកភាជន៍នោះទៅដាក់ទុកលើដី ជាកិរិយា[?]នោះ ហើយឲ្យគេឆ្ពាយ[?] ។ ២ បានដល់គ្រឿងលាបកាយត្រង់ឃើញមានស្នាម[?] ។

# ទុតិយសិក្ខាបទំ

(១៦៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ
វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន
ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ
ភាតុនោ សទ្ធិវិហារិកំ ភិក្ខុំ ឯតទវោច ឯហាវុសោ
គាមំ បិណ្ឌាយ បវិសិស្សាមាតិ ។ តស្ស អទាបេត្វា
ឧយ្យោជេសិ គច្ឆាវុសោ ន មេ តយា សទ្ធឹ កថា វា
និសជ្ជា វា ផាសុ ហោតិ ឯកកស្ស មេ កថា វា
និសជ្ជា វា ផាសុ ហោតីតិ ។ អថខោ សោ ភិក្ខុ
ឧបកដ្ឋេ កាលេ នាសក្ខិ បិណ្ឌាយ ចរិតុំ បដិក្កម-
នេបិ ភត្តំ ឧស្សារិតំ ឆិន្នភត្តោ អហោសិ ។
អថខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ
អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។
តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម
អាយស្មា ឧបនន្ទោ សក្យបុត្តោ ភិក្ខុំ ឯហាវុសោ
គាមំ បិណ្ឌាយ បវិសិស្សាមាតិ តស្ស អទាបេត្វា

# សិក្ខាបទទី ២

[១៦៤] កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុង
វត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង
ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បាននិយាយពាក្យនេះទៅនឹងភិក្ខុជាសទ្ធិ-
វិហារិករបស់ព្រះបង ជាបងប្អូនថា ម្នាលអាវុសោ លោកចូរមក យើង
ទាំងពីរនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត បានចូលហើយ ក៏មិន
ឲ្យគេឲ្យ(ភិក្ខា)ដល់ភិក្ខុនោះឡើយ (រួចដេញ) ដើម្បីឲ្យត្រឡប់ទៅវិញថា
ម្នាលអាវុសោ លោកចូរទៅចុះ ខ្ញុំនឹងនិយាយឬនឹងអង្គុយជាមួយនឹងលោក
មិនសប្បាយទេ ខ្ញុំនឹងនិយាយឬនឹងអង្គុយតែម្នាក់ឯងទើបស្រួលជាង ។ គ្រា
នោះ កាលវេលាដែលត្រាច់ទៅកាន់តែចូលមកជិតហើយ ភិក្ខុនោះមិន
អាចនឹងត្រាច់ទៅបិណ្ឌបាតបាន សូម្បីត្រាន់តែត្រឡប់មកក្នុងវិញ ក៏
មិនទាន់ជាអ្នកឆាន់ទាន់ (មួយពេលនោះឯង) ។ ទើបភិក្ខុនោះទៅកាន់អា-
រាមហើយនិយាយរឿងនុះប្រាប់ភិក្ខុទាំងឡាយ ភិក្ខុណាដែលមាន
សេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះ
បង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើមកបបួលភិក្ខុថា
ម្នាលអាវុសោ លោកចូរមក យើងនាំគ្នាចូលទៅកាន់ស្រុក

ឧយ្យោជេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ ភិក្ខុំ ឯហាវុសោ គាមំ បិណ្ឌាយ បវិសិស្សាមាតិ តស្ស អទាបេត្វា ឧយ្យោជេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស ភិក្ខុំ ឯហាវុសោ គាមំ បិណ្ឌាយ បវិសិស្សាមាតិ តស្ស អទាបេត្វា ឧយ្យោជេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ ឯវំ វទេយ្យ[១] ឯហាវុសោ គាមំ វា និគមំ វា បិណ្ឌាយ បវិសិស្សាមាតិ តស្ស ទាបេត្វា វា អទាបេត្វា វា ឧយ្យោជេយ្យ គច្ឆាវុសោ ន មេ តយា សទ្ធិំ កថា វា និសជ្ជា វា ផាសុ

---

១ ឥទំ បាឋទ្វយំ ឥ. ម. បោត្ថកេសុ ន ទិស្សតិ ។



ដើម្បីបិណ្ឌបាត ហើយមិនឲ្យគេប្រគេនអ្វីៗ ដល់ភិក្ខុនោះ ស្រាប់តែបញ្ជូនឲ្យត្រឡប់ទៅវិញ (ដូច្នេះ) សោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងនិយាយនឹងភិក្ខុថា ម្នាលអាវុសោ លោកចូរមក យើងនឹងចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ហើយមិនឲ្យគេ (ឲ្យអ្វីៗ) ដល់ភិក្ខុនោះ (សោះ) បញ្ជូនឲ្យត្រឡប់ទៅវិញ មែនពិតឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនេះពិតមែន ។ ព្រះសម្ពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងនិយាយនឹងភិក្ខុថា ម្នាលអាវុសោ លោកចូរមក យើងនឹងចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ហើយមិនឲ្យគេឲ្យ(អ្វីៗ)ដល់ភិក្ខុនោះ(សោះ)បញ្ជូនឲ្យត្រឡប់ទៅវិញ ដូច្នេះឡើយ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ម្យ៉ាងទៀត ពួកជនដែលជ្រះថ្លាហើយ ក៏រឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយនិយាយនឹងភិក្ខុយ៉ាងនេះថា ម្នាលអាវុសោ លោកចូរមក យើងទាំងឡាយនឹងទៅកាន់ស្រុកឬនិគមដើម្បីបិណ្ឌបាត ហើយឲ្យគេឲ្យ ឬមិនឲ្យគេឲ្យ(អ្វីៗ) ដល់ភិក្ខុនោះ ហើយបញ្ជូនឲ្យត្រឡប់ទៅវិញយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅវិញចុះ ដ្បិតនិយាយឬអង្គុយជាមួយនឹងលោកមិនសប្បាយទេ

ហោតិ ឯកកស្ស មេ កថា វា និសជ្ជា វា ផាសុ ហោតីតិ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ ការណិយន្តិ ។

[១៥១] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញំ ភិក្ខុំ ។ ឯហាវុសោ គាមំ វា និគមំ វាតិ គាមោបិ និគមោបិ នគរម្បិ គាមោ ចេវ និគមោ ច ។ តស្ស ទាបេត្វាតិ យាគុំ វា ភត្តំ វា ខាទនីយំ វា ភោជនីយំ វា ទាបេត្វា ។ អទាបេត្វាតិ ន កិញ្ចិ ទាបេត្វា ។ ឧយ្យោជេយ្យាតិ មាតុគ្គាមេន សទ្ធិំ ហសិតុកាមោ កីឡិតុកាមោ រហោនិសីទិតុកាមោ អនាចារំ អាចរិតុកាមោ ឯវំ វទេតិ គច្ឆាវុសោ ន មេ តយា សទ្ធិំ កថា វា និសជ្ជា វា ផាសុ ហោតិ ឯកកស្ស មេ កថា វា និសជ្ជា វា ផាសុ ហោតីតិ ឧយ្យោជេតិ អាបត្តិ ទុក្កដស្ស ។ ទស្សនូបចារំ វា សវនូបចារំ វា



ខ្ញុំនិយាយឬអង្គុយតែម្នាក់ឯងស្រួលជាង ដូច្នេះ ត្រូវអាបត្តិទុក្កដ ព្រោះធ្វើនូវហេតុនុ៎ះឯងឲ្យជាបច្ច័យ មិនមែនជាហេតុដទៃទៀយ ។

[១៥១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទ ទី១ នៃបារាជិកកណ្ឌ ។ ពាក្យថា ចំពោះភិក្ខុ គឺចំពោះភិក្ខុដទៃ ។ ពាក្យថា ម្នាលអាវុសោ លោកចូរមក (យើងនឹងទៅ) កាន់ស្រុកឬនិគម (ដើម្បីបិណ្ឌបាត) គឺស្រុកក្តី និគមក្តី នគរក្តី ក៏ហៅថាស្រុកនិងនិគម (ក្នុងសិក្ខាបទនេះ) ។ ពាក្យថា ឲ្យគេឲ្យ(អ្វីៗ) ដល់ភិក្ខុនោះ គឺប្រើគេឲ្យឲ្យយាគូក្តី ភត្តក្តី ខាទនីយក្តី ភោជនីយក្តី (ដល់ភិក្ខុនោះ) ។ ពាក្យថា មិនឲ្យគេឲ្យ គឺមិនឲ្យគេឲ្យនូវអ្វីៗសោះ ។ ពាក្យថា បញ្ជូនឲ្យត្រឡប់ទៅវិញ សេចក្តីថា ភិក្ខុប្រាថ្នាដើម្បីសើច ប្រាថ្នាដើម្បីលេង ប្រាថ្នាដើម្បីអង្គុយក្នុងទីស្ងាត់ ប្រាថ្នាដើម្បីប្រព្រឹត្តអនាចារជាមួយនឹងមាតុគ្រាម ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ លោកចូរទៅវិញចុះ ខ្ញុំនិយាយឬអង្គុយជាមួយនឹងលោកមិនស្រួលទេ ខ្ញុំនិយាយឬអង្គុយតែម្នាក់ឯងស្រួលជាង ដូច្នេះហើយក៏បញ្ជូនឲ្យត្រឡប់ទៅវិញ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនោះកំពុងលះបង់ទីល្មមមើលឃើញឬទីល្មមស្តាប់ឮ

វិជហន្តស្ស អាបត្តិ ទុក្កដស្ស ។ វិជហិតេ អាបត្តិ បាចិត្តិយស្ស ។ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ ន អញ្ញោ កោចិ បច្ចយោ ហោតិ ឧយ្យោជេតុំ ។

(១៥១) ឧបសម្បន្នេ ឧបសម្បន្នសញ្ញី ឧយ្យោជេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ ឧយ្យោជេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី ឧយ្យោជេតិ អាបត្តិ បាចិត្តិយស្ស ។ កលិសាសនំ អារោបេតិ[១] អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នំ ឧយ្យោជេតិ អាបត្តិ ទុក្កដស្ស ។ កលិសាសនំ អារោបេតិ[២] អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

---

១.២ ឧទ្ធិ បោត្ថកេ អារោបេតីតិ ទិស្សតិ ។



ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុនោះឈរបង់ផុត (ឧបចារៈទីឈមមើលឃើញឬទីឈមស្តាប់ឮ) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើនូវហេតុនុ៎ះឯងឲ្យជាបច្ច័យ មិនមែនជាហេតុដទៃឡើយ សេចក្តីថា មិនមានហេតុនីមួយដទៃជាបច្ច័យ ក្រៅអំពីហេតុដែលបញ្ជូនទៅនោះឡើយ ។

(១៥១) ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន តែភិក្ខុសង្ស័យ ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាមិនមែនជាឧបសម្បន្ន ហើយបញ្ជូនទៅ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុលើកឡើងនូវពាក្យបញ្ឈឺចិត្ត (ចំពោះឧបសម្បន្ន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបញ្ជូនអនុបសម្បន្នទៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលើកនូវពាក្យបញ្ឈឺចិត្ត (ចំពោះអនុបសម្បន្ន) ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុសំគាល់ថាជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនជាឧបសម្បន្ន ភិក្ខុក៏សំគាល់ថាមិនមែនជាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(១៩២) អនាបត្តិ ទ្វេ ឯកតោ ន យាបេស្សា-
មាតិ ឧយ្យោជេតិ មហគ្ឃំ ភណ្ឌំ បស្សិត្វា លោភធម្មំ
ឧប្បាទេស្សតីតិ ឧយ្យោជេតិ មាតុគាមំ បស្សិត្វា អន-
ភិរតិំ ឧប្បាទេស្សតីតិ ឧយ្យោជេតិ គិលានស្ស វា ឱហី-
យកស្ស វា វិហារបាលស្ស វា យាគុំ វា ភត្តំ វា[១]
ខាទនីយំ វា ភោជនីយំ វា នីហរាតិ ឧយ្យោជេតិ ន
អនាចារំ អាចរិតុកាមោ សតិ ករណីយេ ឧយ្យោ-
ជេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

---
១ អយំ បាឋោ ម. បោត្ថកេ ន ទិស្សតិ ។



(១៩២) អាបត្តិមិនមាន ដល់ភិក្ខុដែលបញ្ជូនភិក្ខុឯទៀតឲ្យត្រឡប់ទៅវិញ ដោយគិតថា យើងទាំងពីររូបនឹងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅក្នុងទីជាមួយគ្នាមិនបាន ដល់ភិក្ខុដែលបញ្ជូនភិក្ខុឯទៀតឲ្យត្រឡប់ទៅវិញ ដោយគិតថា ភិក្ខុនោះបានឃើញរបស់មានដំឡៃច្រើនហើយ នឹងញ៉ាំងលោភធម៌ឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុឯទៀតឲ្យត្រឡប់ទៅវិញ ដោយគិតថា ភិក្ខុនោះបានឃើញមាតុគ្រាមហើយនឹងញ៉ាំងសេចក្ដីអផ្សុកឲ្យកើតឡើង ដល់ភិក្ខុបញ្ជូនភិក្ខុឯទៀតឲ្យត្រឡប់ទៅវិញដោយពាក្យថា លោកចូរនាំយាគូក្ដី ភត្តក្ដី ខាទនីយក្ដី ភោជនីយក្ដី ទៅឲ្យដល់ភិក្ខុមានជម្ងឺ ឬភិក្ខុដែលនៅគង់ចាំវត្ត ឬអ្នកដែលរក្សាវត្ត ដល់ភិក្ខុមិនប្រាថ្នានឹងប្រព្រឹត្តអនាចារៈ (តែ) កាលបើមានកិច្ចហើយ ក៏បញ្ជូនភិក្ខុឯទៀតទៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ២ ចប់ ។

## តតិយសិក្ខាបទំ

(១៨៣) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សហាយកស្ស ឃរំ គន្ត្វា តស្ស បជាបតិយា សទ្ធឹ សយនិឃរេ និសីទិ ។ អថខោ សោ បុរិសោ យេនាយស្មា ឧបនន្ទោ សក្យបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ បុរិសោ បជាបតឹ ឯតទវោច ទេហាយ្យស្ស ភិក្ខន្តិ ។ អថខោ សា ឥត្ថី អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ភិក្ខំ អទាសិ ។ អថខោ សោ បុរិសោ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច គច្ឆថ ភន្តេ យតោ អយ្យស្ស ភិក្ខា ទិន្នាតិ ។ អថខោ សា ឥត្ថី សល្លក្ខេត្វា បរិយុដ្ឋិតោ អយំ បុរិសោតិ អាយស្មន្តំ ឧបនន្ទំ

## សិក្ខាបទទី ៣

(១៨៣) កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សេ្តចគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ទៅកាន់ផ្ទះរបស់សំឡាញ់ ហើយក៏អង្គុយនៅក្នុងផ្ទះសម្រាប់ដេកជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះ ។ ឯបុរសនោះក៏ចូលសំដៅទៅរកទីដែលព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុអង្គុយនោះ លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ លុះបុរសនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏និយាយពាក្យនេះនឹងប្រពន្ធថា នាងចូរប្រគេនចង្ហាន់ដល់លោកម្ចាស់ចុះ ។ ស្ត្រីនោះក៏ប្រគេនចង្ហាន់ដល់ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុក្នុងគ្រានោះ ។ លំដាប់នោះ បុរសនោះក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់និមន្តទៅចុះ ព្រោះយើងខ្ញុំបានប្រគេនចង្ហាន់ដល់លោកម្ចាស់ហើយ ។ ឯស្ត្រីនោះកំណត់ដឹងថា បុរសនេះមានរាគៈគ្របសង្កត់ហើយ ក៏និយាយពាក្យនេះនឹងព្រះឧបនន្ទ

សក្យបុត្តំ ឯតទវោច និសីទថ ភន្តេ មា អគ-មិត្ថាតិ ។ ទុតិយម្បិ ខោ សោ បុរិសោ ។ បេ ។ តតិយម្បិ ខោ សោ បុរិសោ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច គច្ឆថ ភន្តេ យតោ អយ្យ-ស្ស ភិក្ខា ទិន្នាតិ ។ តតិយម្បិ ខោ សា ឥត្ថី អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ឯតទវោច និសីទថ ភន្តេ មា អគមិត្ថាតិ ។ អថខោ សោ បុរិសោ និក្ខ-មិត្វា ភិក្ខូ ឧជ្ឈាបេសិ អយំ ភន្តេ អយ្យោ ឧបនន្ទោ មយ្ហំ បជាបតិយា សទ្ធឹ សយនិឃរេ និសិន្នោ សោ មយា ឧយ្យោជិយមានោ ន ឥច្ឆតិ គន្តុំ ពហុកិច្ចា មយំ ពហុករណីយាតិ ។ បេ ។ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយ-ស្មា ឧបនន្ទោ សក្យបុត្តោ សភោជនេ កុលេ អនុប-ខជ្ជ និសជ្ជំ កប្បេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧប-នន្ទ សភោជនេ កុលេ អនុបខជ្ជ និសជ្ជំ កប្បេសីតិ ។



ជាសក្យបុត្រដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅ ។ បុរសនោះ(បាននិយាយ)ជាគំរប់ពីរដង ។ បេ ។ បុរសនោះ បាននិយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ជាគំរប់បីដងថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់និមន្តទៅវិញចុះ ព្រោះយើងខ្ញុំបានប្រគេនបិណ្ឌបាតដល់លោកម្ចាស់ហើយ ។ ឯស្ត្រីនោះក៏និយាយពាក្យនេះនឹងព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ជាគំរប់បីដងថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់គង់សិន កុំអាលនិមន្តទៅឡើយ ។ ឯបុរសនោះក៏ដើរចេញអំពីផ្ទះទៅ ហើយពោលទោសទៅភិក្ខុទាំងឡាយថា បពិត្រលោកដ៏ចំរើនទាំងឡាយ លោកម្ចាស់ឧបនន្ទនេះទៅអង្គុយក្នុងផ្ទះសម្រាប់ដេកជាមួយនឹងប្រពន្ធរបស់ខ្ញុំ ព្រះឧបនន្ទនោះកាលខ្ញុំបញ្ជូនឲ្យទៅវិញក៏មិនចង់ទៅ យើងខ្ញុំទាំងឡាយជាអ្នកមានកិច្ចច្រើន មានរវល់ច្រើន ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ម៉េចសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ (គឺតែប្រុសនឹងស្រី) (ផ្ទះ) ដូច្នេះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងបានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់ ពិតមែនឬ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស សភោជនេ កុលេ អនុបខជ្ជ និសជ្ជំ កប្បេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សភោជនេ កុលេ អនុបខជ្ជ និសជ្ជំ កប្បេយ្យ បាចិត្តិយន្តិ ។

[១៥៤] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សភោជនំ នាម កុលំ ឥត្ថី ចេវ ហោតិ បុរិសោ ច ។ ឧភោ[១] អនិក្ខន្តា ហោន្តិ ឧភោ អវីតរាគា ។ អនុបខជ្ជាតិ អនុបវិសិត្វា ។ និសជ្ជំ កប្បេយ្យាតិ មហល្លកេ ឃរេ បិដ្ឋិសង្ឃាដស្ស ហត្ថបាសំ វិជហិត្វា និសីទតិ អាបត្តិ បាចិត្តិយស្ស ។ ខុទ្ទកេ ឃរេ បិដ្ឋិវំសំ អតិក្កមិត្វា និសីទតិ អាបត្តិ បាចិត្តិយស្ស ។

១ ឥតោ បុព្វេ ។ ម. បោត្ថកេសុ ឥត្ថី ច បុរិសោ ចាតិ បទទ្វយំ ទិស្សតិ ។



ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ដំណើរនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានចូលទៅអង្គុយនៅក្នុងត្រកូលដែលមានជនតែពីរនាក់(ប្តីប្រពន្ធ)ទេ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ល។ ម្នាលភិក្ខុទាំងឡាយ បើដូច្នេះ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយចូលទៅសម្រេចការអង្គុយនៅ ក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។

[១៥៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបាចិត្តិយកណ្ឌ ។ ដែលហៅថា ត្រកូលដែលមានជនតែពីរនាក់ គឺមានតែស្រីនិងប្រុសប៉ុណ្ណោះ ។ ជនទាំងពីរនាក់មិនទាន់ចេញទៅ ហើយជនទាំងពីរនាក់នោះ ជាមនុស្សមានតម្រេកនៅឡើយ ។ ពាក្យថា ចូលទៅ គឺដើរចូលទៅ ។ ពាក្យថា សម្រេចការអង្គុយ សេចក្តីថា ភិក្ខុលះហត្ថបាសនៃមេធ្នាក្រោយក្នុងផ្ទះធំ ហើយអង្គុយនៅ ត្រូវអាបត្តិបាចិត្តិយ ។ (បើ) ក្នុងផ្ទះតូច ភិក្ខុដើរហួសធ្នឹមដំបូល[១] ទៅហើយអង្គុយ ត្រូវអាបត្តិបាចិត្តិយ ។

១ អដ្ឋកថា អធិប្បាយថា ភិក្ខុចូលទៅហួសពាក់កណ្តាលផ្ទះ គឺហួសឬស្សីខ្នងផ្ទះ ។

[១៨៩] សយនីឃរេ សយនីឃរសញ្ញី សភោជនេ កុលេ អនុបខជ្ជ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ សយនីឃរេ វេមតិកោ សភោជនេ កុលេ អនុបខជ្ជ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ សយនីឃរេ អសយនីឃរសញ្ញី សភោជនេ កុលេ អនុបខជ្ជ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ អសយនីឃរេ សយនីឃរសញ្ញី អាបត្តិ ទុក្កដស្ស ។ អសយនីឃរេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អសយនីឃរេ អសយនីឃរសញ្ញី អនាបត្តិ ។

[១៩០] អនាបត្តិ មហល្លកេ ឃរេ បិដ្ឋសង្ឃាដស្ស ហត្ថបាសំ អវិជហិត្វា និសីទតិ ខុទ្ទកេ ឃរេ បិដ្ឋិវំសំ អនតិក្កមិត្វា និសីទតិ ភិក្ខុ ទុតិយោ ហោតិ ឧភោ និក្ខន្តា ហោន្តិ ឧភោ វីតរាគា អសយនីឃរេ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។



(១៨៩) ផ្ទះសម្រាប់ដេក ភិក្ខុក៏សំគាល់ថាផ្ទះសម្រាប់ដេក ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ ផ្ទះសម្រាប់ដេក ភិក្ខុសង្ស័យ ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ ផ្ទះសម្រាប់ដេក ភិក្ខុសំគាល់ថាមិនមែនផ្ទះសម្រាប់ដេក ហើយចូលទៅសម្រេចការអង្គុយក្នុងត្រកូលដែលមានជនតែពីរនាក់ ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុសំគាល់ថាផ្ទះសម្រាប់ដេក ត្រូវអាបត្តិទុក្កដ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនផ្ទះសម្រាប់ដេក ភិក្ខុក៏សំគាល់ថាមិនមែនផ្ទះសម្រាប់ដេក មិនត្រូវអាបត្តិ ។

(១៩០) អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយក្នុងផ្ទះធំ មិនលះហត្ថបាសនៃមេទ្វារឬធរណី ដល់ភិក្ខុអង្គុយក្នុងផ្ទះតូច មិនហួសមេដំបូល ដល់ភិក្ខុដែលមានភិក្ខុជាគំរប់ពីរអង្គុយនៅផង ដល់ភិក្ខុដែលអង្គុយនៅ តែជនទាំងពីរនាក់នោះចេញទៅហើយ ដល់ភិក្ខុដែលអង្គុយនៅជាមួយនឹងជនទាំងពីរនាក់ជាបុគ្គលមិនមានរាគៈ ដល់ភិក្ខុអង្គុយនៅក្នុងផ្ទះ ដែលមិនមែនជាផ្ទះសម្រាប់ដេក ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៣ ចប់ ។

## បញ្ចមសិក្ខាបទំ

[១៥៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សហាយកស្ស ឃរំ គន្ត្វា តស្ស បជាបតិយា សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេសិ ។ អថខោ សោ បុរិសោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម អាយស្មា ឧបនន្ទោ មយ្ហំ បជាបតិយា សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បុរិសស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ មាតុគ្គាមេន សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ មាតុគ្គាមេន សទ្ធឹ រហោ បដិច្ឆន្នេ

## សិក្ខាបទទី ៥

(១៥៧) កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់ប្រថាប់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ បានទៅកាន់ផ្ទះរបស់បុរសជាសំឡាញ់ ហើយក៏សម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះ ។ គ្រានោះ បុរសនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាម្ចាស់ មិនគួរបើនឹងមកសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងប្រពន្ធរបស់ខ្ញុំ (ម្ដេច)សោះ ។ ភិក្ខុទាំងឡាយបានឮសំដីនៃបុរសនោះ ដែលពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាដែលមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងមកនៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងមាតុគ្រាម (ម្ដេច)ទេ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងនៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង

អាសនេ និសជ្ជំ កប្បេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស មាតុគាមេន សទ្ធិំ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ មាតុគាមេន សទ្ធិំ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេយ្យ បាចិត្តិយន្តិ ។

[១៥៨] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ មាតុគាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា អន្តមសោ តទហុជាតាបិ ទារិកា បគេវ មហន្តតរី[១] ។ សទ្ធិន្តិ ឯកតោ ។ រហោ នាម ចក្ខុស្ស រហោ សោតស្ស រហោ ។ ចក្ខុស្ស រហោ នាម ន សក្កា ហោតិ អក្ខិំ

១ ឆ. ម. មហត្តរី ។



ជាមួយនឹងមាតុគ្រាម ពិតមែនឬ ។ ព្រះឧទាយិក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្ដីនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានទៅសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងមាតុគ្រាម (ដូច្នេះ) ទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង មួយអន្លើដោយមាតុគ្រាម ត្រូវអាបត្តិបាចិត្តិយ ។

[១៥៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺស្រីមនុស្ស មិនមែនជាយក្សស្រី មិនមែនជាប្រេតស្រី មិនមែនតិរច្ឆានស្រី ដោយហោចទៅសូម្បីតែក្មេងស្រីដែលទើបនឹងកើតក្នុងថ្ងៃនោះ មិនបាច់និយាយទៅដល់ស្រីធំទេ ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ ដែលហៅថា ទីស្ងាត់ គឺទីដែលស្ងាត់ភ្នែក ស្ងាត់ត្រចៀក ។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិនអាចនឹង

វា និខណីយមានេ ភមុកំ វា ឧក្ខិបីយមានេ សីសំ វា ឧក្ខិបីយមានេ បស្សិតុំ ។ សោតស្ស រហោ នាម ន សក្កា ហោតិ បកតិកថា សោតុំ ។ បដិច្ឆន្នំ នាម អាសនំ កុឌ្ឌេន វា កវាដេន វា កិលញ្ជេន វា សាណិបាការេន វា រុក្ខេន វា ថម្ភេន វា កោដ្ឋលិយា វា យេន កេនចិ បដិច្ឆន្នំ ហោតិ ។ និសជ្ជំ កប្បេយ្យាតិ មាតុគ្គាមេ និសិន្នេ ភិក្ខុ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ និសិន្នេ មាតុគ្គាមោ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា អាបត្តិ បាចិត្តិយស្ស ។ ឧភោ វា និសិន្នា ហោន្តិ ឧភោ វា និបន្នា អាបត្តិ បាចិត្តិយស្ស ។

(១៥៨) មាតុគ្គាមេ មាតុគ្គាមសញ្ញី រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ វេមតិកោ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ អមាតុគ្គាមសញ្ញី រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ យក្ខិយា វា



ញាក់ចិញ្ចើមក្តី ងើបក្បាលក្តី បុគ្គលដទៃមិនអាចឃើញបាន ។ ដែលហៅថាទីស្ងាត់ត្រចៀក គឺទីដែលបុគ្គលដទៃមិនអាចស្តាប់ពាក្យជាប្រក្រតីបាន ។ ដែលហៅថា អាសនៈជាទីកំបាំង គឺអាសនៈដែលគេបិទបាំង ដោយជញ្ជាំងក្តី ដោយសន្ទះទ្វារក្តី ដោយកន្ទេលផែនក្តី ដោយវាំងននក្តី ដោយដើមឈើក្តី ដោយសសរក្តី ដោយស្រុំក្តី ឬដោយវត្ថុណាមួយ ។ ពាក្យថា សម្រេចការអង្គុយ គឺកាលបើមាតុគ្រាមអង្គុយ ភិក្ខុអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិត ឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ ទាំងពីរនាក់អង្គុយក្តី ដេកទាំងពីរនាក់ក្តី (ជិតគ្នា) ត្រូវអាបត្តិបាចិត្តិយ ។

(១៥៨) មាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្រេចការអង្គុយលើអាសនៈជាទីស្ងាត់កំបាំង ជាមួយនឹងយក្សស្រីក្តី

បេតិយា វា បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គ-ហិត្ថិយា វា សទ្ធឹ រហោ បដិច្ឆន្នេ អាសនេ និសជ្ជំ កប្បេតិ អាបត្តិ ទុក្កដស្ស ។ អមាតុគាមេ មាតុគាម-សញ្ញី អាបត្តិ ទុក្កដស្ស ។ អមាតុគាមេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អមាតុគាមេ អមាតុគាមសញ្ញី អនាបត្តិ ។

[១៦០] អនាបត្តិ យោ កោចិ វិញ្ញូ បុរិសោ ទុតិយោ ហោតិ តិដ្ឋតិ ន និសីទតិ អរហោបេក្ខោ អញ្ញាវិហិតោ និសីទតិ ឧម្មត្តកស្ស អាទិកម្មិ-កស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។



ប្រេតស្ត្រីក្តី ខ្ទើយក្តី តិរច្ឆានញីដែលមានកាយដូចមនុស្សក្តី ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម មិនត្រូវអាបត្តិឡើយ ។

[១៦០] អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយនៅ មានបុរសណា-មួយដែលជាមនុស្សដឹងក្តី(ទៅ)ជាគំរប់ពីរ ដល់ភិក្ខុឈរមិនបានអង្គុយ ដល់ភិក្ខុបានត្រឡប់គយគន់រកទីមិនស្ងាត់ហើយអង្គុយ ដល់ភិក្ខុមានចិត្តបញ្ជូនទៅកាន់ការម្យ៉ាងដទៃហើយអង្គុយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

## បញ្ចមសិក្ខាបទំ

(១៦១) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សហាយកស្ស ឃរំ គន្ត្វា តស្ស បជាបតិយា សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសិ ។ អថខោ សោ បុរិសោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម អយ្យោ ឧបនន្ទោ មយ្ហំ បជាបតិយា សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សតីតិ ។ អស្សោសុំ ខោ ភិក្ខូ តស្ស បុរិសស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ ឧបនន្ទ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស

## សិក្ខាបទទី៥

(១៦១) កាលនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សម្រេចឥរិយាបថក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ក្បែរក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ ដើរទៅកាន់ផ្ទះរបស់សំឡាញ់ ហើយក៏សម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធរបស់សំឡាញ់នោះតែម្នាក់នឹងម្នាក់ ។ គ្រានោះ បុរសនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាម្ចាស់ មិនសមបើនឹងហ៊ានមកសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងប្រពន្ធរបស់ខ្ញុំតែម្នាក់នឹងម្នាក់ (ដូច្នេះ) សោះ ។ ភិក្ខុទាំងឡាយបានឮពាក្យរបស់បុរសនោះកំពុងពោលទោស តិះដៀល បន្តុះបង្អាប់ (ដូច្នោះ) ហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ មិនសមបើនឹងហ៊ាននៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់នឹងម្នាក់ទេ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងនៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់នឹងម្នាក់ ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ សេចក្តីនោះពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស

មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មាតុគាមេន សទ្ធឹ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេយ្យ បាចិត្តិយន្តិ ។

(១៦៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ មាតុគាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា វិញ្ញូ បដិពលា សុភាសិតទុព្ភាសិតំ ទុដ្ឋុល្លាទុដ្ឋុល្លំ អាជានិតុំ ។ សទ្ធិន្តិ ឯកតោ ។ ឯកោ ឯកាយាតិ ភិក្ខុ ចេវ ហោតិ មាតុគាមោ ច ។ រហោ នាម ចក្ខុស្ស រហោ សោតស្ស រហោ ។ ចក្ខុស្ស រហោ នាម ន សក្កា ហោតិ អក្ខឹ វា និខណីយមានេ ភមុកំ វា ឧក្ខិបីយមានេ សីសំ វា ឧក្ខិបីយមានេ បស្សិតុំ ។ សោតស្ស រហោ នាម



អ្នកឯងមិនសមបើនឹងហ៊ាននៅសម្រេចការអង្គុយក្នុងទីស្ងាត់ ជាមួយនឹងមាតុគ្រាមតែម្នាក់នឹងម្នាក់ (ដូច្នេះ) ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ សម្រេចការអង្គុយក្នុងទីស្ងាត់ មួយអន្លើដោយមាតុគ្រាមតែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។

[១៦៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិកណ្ឌ ។ ដែលហៅថា មាតុគ្រាម គឺជាស្រីមនុស្ស មិនមែនជាយក្ខិនី មិនមែនជាប្រេតស្រី មិនមែនជាតិរច្ឆានញី ជាអ្នកដឹងក្តី ជាអ្នកអាចដើម្បីស្គាល់ពាក្យសំដី ដែលបុគ្គលនិយាយល្អអាក្រក់ ពាក្យពេសគ្រោមមិនមែនអាសគ្រោម ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ ពាក្យថា តែម្នាក់នឹងម្នាក់ គឺមានតែភិក្ខុនឹងមាតុគ្រាមប៉ុណ្ណោះ ។ ដែលហៅថា ទីស្ងាត់ គឺទីស្ងាត់ភ្នែក ស្ងាត់ត្រចៀក ។ ដែលហៅថា ទីស្ងាត់ភ្នែក គឺកាលបើភិក្ខុមិចភ្នែកក្តី ញាក់ចិញ្ចើមក្តី ងើបក្បាលក្តី ដទៃនឹងមិនអាចឃើញបាន ។ ដែលហៅថា ទីស្ងាត់ត្រចៀក

ន សក្កា ហោតិ បកតិកថា សោតុំ ។ និសជ្ជំ កប្បេយ្យាតិ មាតុគ្គាមេ និសិន្នេ ភិក្ខុ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ និសិន្នេ មាតុគ្គាមោ ឧបនិសិន្នោ វា ហោតិ ឧបនិបន្នោ វា អាបត្តិ បាចិត្តិយស្ស ។ ឧភោ វា និសិន្នា ហោន្តិ ឧភោ វា និបន្នា អាបត្តិ បាចិត្តិយស្ស ។

[៣៦៣] មាតុគ្គាមេ មាតុគ្គាមសញ្ញី ឯកោ ឯកាយ រហោ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ វេមតិកោ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ អមាតុគ្គាមសញ្ញី ឯកោ ឯកាយ រហោ និសជ្ជំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ យក្ខិយា វា បេតិយា វា បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គហាយ វា សទ្ធិំ ឯកោ ឯកាយ រហោ និសជ្ជំ កប្បេតិ អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ មាតុគ្គាមសញ្ញី អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អមាតុគ្គាមេ អមាតុគ្គាមសញ្ញី អនាបត្តិ ។





គឺទីដែលបុគ្គលមិនអាចស្តាប់ពាក្យជាប្រក្រតីបាន ។ ពាក្យថា សម្រេចការអង្គុយ គឺកាលដែលមាតុគ្រាម អង្គុយហើយ ភិក្ខុអង្គុយជិតឬដេកជិត ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុអង្គុយ មាតុគ្រាមអង្គុយជិតឬដេកជិត (ក៏ត្រូវ) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនិងស្រីទាំងពីរនាក់ អង្គុយក្តី ដេកក្តី (ក៏ត្រូវ) ត្រូវអាបត្តិបាចិត្តិយ ។

[១៦៣] មាតុគ្រាម ភិក្ខុសំគាល់ថា មាតុគ្រាម ហើយសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយសម្រេចការអង្គុយ ក្នុងទីស្ងាត់តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម ហើយសម្រេចការអង្គុយក្នុងទីស្ងាត់តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសម្រេចការអង្គុយក្នុងទីស្ងាត់ជាមួយនឹងយក្ខិនីក្តី ប្រេតស្រីក្តី ខ្ទើយក្តី តិរច្ឆានស្រីដែលមានកាយដូចមនុស្សក្តី តែម្នាក់នឹងម្នាក់ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិ ។

[១៦៦] អនាបត្តិ យោ កោចិ វិញ្ញូ បុរិសោ ទុតិយោ ហោតិ តិដ្ឋតិ ន និសីទតិ អរហោបេក្ខោ អញ្ញាវិហិតោ និសីទតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។



[១៦៦] អាបត្តិមិនមាន ដល់ភិក្ខុដែលអង្គុយនៅ មានបុរសណាម្នាក់ជាអ្នកដឹងសេចក្ដីនៅជាគំរប់ពីរ ដល់ភិក្ខុឈរមិនបានអង្គុយ ដល់ភិក្ខុមិនក្រឡេកគយគន់រកទីមិនស្ងាត់ហើយអង្គុយនៅ ដល់ភិក្ខុមានចិត្តឃ្លាតនៅកាន់អារម្មណ៍ដទៃអង្គុយនៅ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៤ ចប់ ។

## ឆដ្ឋសិក្ខាបទំ

(១៦៤) តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ឧបដ្ឋាកកុលំ អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ ភត្តេន និមន្តេសិ អញ្ញេបិ ភិក្ខូ ភត្តេន និមន្តេសិ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ បុរេភត្តំ កុលានិ បយិរុបាសតិ ។ អថ ខោ ភិក្ខូ តេ មនុស្សេ ឯតទវោចុំ ទេថាវុសោ ភត្តន្តិ ។ អាគមេថ ភន្តេ យាវ អយ្យោ ឧបនន្ទោ អាគច្ឆតីតិ ។ ទុតិយម្បិ ខោ តេ ភិក្ខូ តេ មនុស្សេ ឯតទវោចុំ ទេថាវុសោ ភត្តន្តិ ។ អាគមេថ ភន្តេ យាវ អយ្យោ ឧបនន្ទោ អាគច្ឆតីតិ ។ តតិយម្បិ ខោ តេ ភិក្ខូ តេ

## សិក្ខាបទទី ៦

(១៦៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់សេ្តចគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ក្បែរក្រុងរាជគ្រឹះ ។ សម័យនោះឯង ត្រកូលជាឧបដ្ឋាករបស់ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ និមន្តព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុដោយភត្ត ហើយក៏និមន្តពួកភិក្ខុឯទៀតដោយភត្តដែរ ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ កាលបើតែចូលទៅកាន់ត្រកូលទាំងឡាយ ក្នុងវេលាមុនឆាន់ ។ ឯភិក្ខុទាំងឡាយនោះ ក៏ពោលនិយាយពាក្យនេះនឹងមនុស្សម្នាក់នោះថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់(មក) ។ ពួកមនុស្សម្នាក់នោះ ក៏និយាយតបថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន សូមលោកម្ចាស់ទាំងឡាយ រង់ចាំសិន ទម្រាំព្រះឧបនន្ទជាម្ចាស់លោកនិមន្តមក ។ ភិក្ខុទាំងឡាយនោះបាននិយាយពាក្យនេះនឹងពួកមនុស្សម្នាក់នោះជាគំរប់ពីរដងថា ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់មក ។ ពួកមនុស្សម្នាក់នោះក៏និយាយតបថា បពិត្រព្រះករុណា ទាំងឡាយដ៏ចំរើន សូមព្រះករុណា ទាំងឡាយរង់ចាំសិនចុះ ទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្តមក ។ ពួកភិក្ខុម្នាក់នោះ ក៏និយាយពាក្យនេះនឹងមនុស្សទាំងឡាយនោះជាគំរប់បីដងថា

មនុស្សេ ឯតទវោចុំ ទេថាវុសោ ភត្តំ បុរាយំ កាលោ អតិក្កមតីតិ ។ យម្បិ មយំ ភន្តេ ភត្តំ ការិម្ហា អយ្យស្ស ឧបនន្ទស្ស ការណា អាគមេថ ភន្តេ យាវ អយ្យោ ឧបនន្ទោ អាគច្ឆតីតិ ។ អថខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ បុរេភត្តំ កុលានិ បយិរុបាសិត្វា ទិវា អាគច្ឆតិ ។ ភិក្ខូ ន ចិត្តរូបំ ភុញ្ជឹសុ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ និមន្តិតោ សភត្តោ សមានោ បុរេភត្តំ កុលេសុ ចារិត្តំ អាបជ្ជិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ និមន្តិតោ សភត្តោ សមានោ បុរេភត្តំ កុលេសុ ចារិត្តំ អាបជ្ជសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស និមន្តិតោ សភត្តោ



ម្នាលអាវុសោទាំងឡាយ អ្នកទាំងឡាយចូរប្រគេនចង្ហាន់មក (ទើនបន្ទន់ទៅ) ក្រែងហួសពេលឆាន់ ។ មនុស្សទាំងឡាយក៏និយាយថា បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន យើងខ្ញុំទាំងឡាយបានធ្វើភត្តទាំងនោះ ព្រោះតែព្រះឧបនន្ទម្ចាស់ (នេះ) បពិត្រព្រះករុណាទាំងឡាយដ៏ចំរើន សូមព្រះករុណាទាំងឡាយនៅចាំទម្រាំតែព្រះឧបនន្ទជាម្ចាស់និមន្តមកសិន ។ លំដាប់នោះ ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុអាស្រ័យតែចូលទៅគាល់រកនូវទីត្រកូលទាំងឡាយ ក្នុងវេលាមុនឆាន់ ហើយក៏មកក្នុងវេលាថ្ងៃត្រង់ ។ ភិក្ខុទាំងឡាយក៏ឆាន់ពុំឆ្អែតមិនល្មមដល់ចិត្ត ។ ភិក្ខុទាំងឡាយណា ដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ បានទទួលនិមន្តគេជាអ្នកមានភត្តហើយ មិនគួរនឹងត្រាច់ទៅក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងវេលាមុនឆាន់ (ដូច្នេះ) សោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថាអ្នកឯងបានទទួលនិមន្តគេជាអ្នកមានភត្តហើយ ត្រាច់ទៅក្នុងត្រកូលទាំងឡាយ (ដទៃ) ក្នុងវេលាមុនឆាន់ ពិតមែនឬ ។ ព្រះឧបនន្ទក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីនោះពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងបានទទួលនិមន្តគេជាអ្នកមានភត្តហើយ មិនគួរនឹងត្រាច់ទៅ

សមានោ បុរេភត្តំ កុលេសុ ចារិត្តំ អាបជ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ និមន្តិតោ សភត្តោ សមានោ បុរេភត្តំ កុលេសុ ចារិត្តំ អាបជ្ជេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១៦៦] តេន ខោ បន សមយេន អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស ឧបដ្ឋាកកុលំ សង្ឃស្សត្ថាយ ខាទនីយំ បាហេសិ អយ្យស្ស ឧបនន្ទស្ស ទស្សេត្វា សង្ឃស្ស ទាតព្វន្តិ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ គាមំ បិណ្ឌាយ បវិដ្ឋោ ហោតិ ។ អថខោ តេ មនុស្សា អារាមំ គន្ត្វា ភិក្ខូ បុច្ឆឹសុ កហំ ភន្តេ អយ្យោ ឧបនន្ទោតិ ។ ឯសាវុសោ អាយស្មា ឧបនន្ទោ សក្យបុត្តោ គាមំ បិណ្ឌាយ បវិដ្ឋោតិ ។ ឥទំ ភន្តេ ខាទនីយំ អយ្យស្ស



ក្នុងត្រកូលទាំងឡាយ (ដើរ) ក្នុងពេលមុនឆាន់ (ថ្ងៃត្រង់) ទេ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ មួយទៀតពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបាននិមន្តទុកជាអ្នកមានភត្តហើយ ដល់នូវកិរិយាត្រាច់ទៅ ក្នុងត្រកូលទាំងឡាយក្នុងពេលមុនឆាន់ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៦] គ្រានោះ ត្រកូលឧបដ្ឋាករបស់ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុ បានបញ្ជូនខាទនីយាហារទៅដើម្បីប្រគេនដល់សង្ឃដោយពាក្យថា ខាទនីយៈនេះអ្នកឯងត្រូវបង្ហាញដល់ព្រះឧបនន្ទជាម្ចាស់ហើយសឹមប្រគេនដល់សង្ឃចុះ ។ សម័យនោះឯង ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ឯពួកមនុស្សទាំងនោះទៅកាន់អារាមហើយសួរភិក្ខុទាំងឡាយថា បពិត្រលោកម្ចាស់ទាំងឡាយដ៏ចំរើន ព្រះឧបនន្ទជាម្ចាស់និមន្តទៅឯណា ។ ពួកភិក្ខុទាំងនោះឆ្លើយថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាតហើយ ។ មនុស្សទាំងឡាយ

ឧបនន្ទស្ស ធាសេបុត្តោ សព្វស្ស ធាតព្វន្តិ ។ មនុស្សា
បច្ឆាមគ្គំ អារោចេសុំ(១) ។ តេនហិ ភិក្ខវេ បដិក្ខលោហា
ឋិក្ខុំបថ ហេវ ឧបនន្ទោ ភគវន្តំតិ ។ វេជេទា
អាយស្មា ឧបនន្ទោ សក្យបុត្តោ ភគវតា បដិក្ខិត្តំ
បុរាណកំ គព្ភេសុ ជាតំ អាបជ្ជិតព្វំ បញ្ញាតកំ គព្ភេហិ
បយុត្តាសិក្ខា ឋិក បដិក្ខិមំ ។ មាឍនិយំ ឧស្សាភ-
យិត្វា(២) ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ
ទីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧបនន្ទោ
សក្យបុត្តោ បញ្ញាកត្តំ គព្ភេសុ ជាតិត្តំ អាបជ្ជិស្សតីតិ
។ បេ ។ សច្ចំ កិរ តុំ ឧបនន្ទ បញ្ញាកត្តំ គព្ភេសុ
ជាតិត្តំ អាបជ្ជសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ
ពុទ្ធោ ភគវា កថំ ហិ នាម តុំ មោឃបុរិស
បញ្ញាកត្តំ គព្ភេសុ ជាតិត្តំ អាបជ្ជិស្សសិ នេតំ

១ ឱកា បរំ អធិកោ ភគោ ឯកស្មិំ ទិវសេ ធម្មំ ទេសេ គព្ភ ភិក្ខុ អាបន្នស្សតិ ជាតិ សព្វភោគេសុ ទិស្សតិ ។ សោ វិភាគត្ថា ១ ២ ទ. សេក្ខិយតិ ។



គំនិយាយថា បក់ក្រែសាកគ្មាស់អ៊ីចឹង តាំងពីយាយតានេះ ស្មូរណោគ
ម្ចាស់ទាំងឡាយបញ្ញើផល់ព្រះឧបនន្ទមិនចាំយូរ ហើយស៊ើមប្រែតខ
ផល់សម្រេច ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនោះចំពោះព្រះដ៏មាន
ព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ
អ្នកទាំងឡាយត្រូវឱ្យទៅហើយផ្ទួលពុតខ្មែរឧបនន្ទក្រឡប់មកវិញ ។
គ្រានោះ ព្រះឧបនន្ទ ជាសក្យបុត្រដ៏មានអាយុគិតថា ព្រះដ៏មានព្រះភាគ
ទ្រង់ហាមឃាត់មិនឲ្យក្រាប់ទៅកទីក្រគូល ទាំងឡាយគត់វេលាមុនភត្ត
កិច្ចដូច្នោះហើយ ក៏ចូលទៅកាន់ក្រគូល ទាំងឡាយគត់វេលាក្រោយភត្ត
ហើយត្រឡប់មកវិញវិញហ្វូសពេល ។ ពួកមនុស្សនាំគ្នាតិះដៀលត្រឡប់ទៅ
វិញ ។ ភិក្ខុទាំងឡាយមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏
ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះឧបនន្ទជាសក្យបុត្រដ៏មានអាយុ
មិនគួរបើមិនក្រាប់ទៅកទីក្រគូលទាំងឡាយគត់វេលាក្រោយភត្ត (ដូច្នោះ)
សោះ ។ បេ ។ ព្រះអង្គត្រាស់សួរថា ម្នាលឧបនន្ទ ឮថា អ្នកឯងត្រាច់
ទៅកទីក្រគូលទាំងឡាយគត់វេលាក្រោយភត្ត ពិតមែនឬ ។ ព្រះឧបនន្ទ
ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស សេចក្តីនោះពិតមែន ។
ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯង
មិនគួរនឹងត្រាច់ទៅកទីក្រគូលទាំងឡាយគត់វេលាក្រោយភត្ត (ដូច្នេះ)

ហោយ បុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ និមន្តិតោ សភត្តោ សមានោ បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(១៦៨) តេន ខោ បន សមយេន ភិក្ខូ ចីវរទានសមយេ កុក្កុច្ចាយន្តា កុលានិ ន បយិរុបាសន្តិ ។ ចីវរំ បរិត្តំ ឧប្បជ្ជតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចីវរទានសមយេ កុលានិ បយិរុបាសិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ និមន្តិតោ សភត្តោ សមានោ បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។





ទេ នែមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទៀតទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបានទទួលនិមន្តគេជាអ្នកមានភត្តហើយដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយក្នុងកាលមុនភត្តក្ដី ក្រោយភត្តក្ដី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(១៦៨) សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្ដីសង្ស័យក្នុងសម័យនៃចីវរទាន ហើយមិនចូលទៅកាន់ត្រកូលទាំងឡាយ ។ ចីវរក៏កើតឡើងតិចស្ដួចស្ដើង ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅកាន់ត្រកូលទាំងឡាយ ក្នុងសម័យនៃចីវរទាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវតែសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តគេ ជាអ្នកមានភត្តហើយដល់នូវកិរិយាត្រាច់ទៅ ក្នុងត្រកូលទាំងឡាយ ក្នុងកាលមុនភត្តក្ដី ក្រោយភត្តក្ដី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។

តត្ថាយំ សមយោ ចីវរទានសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(១៦៨) តេន ខោ បន សមយេន ភិក្ខូ ចីវរកម្មំ ករោន្តិ អត្ថោ ច ហោតិ សូចិយាបិ សុត្តេនបិ សត្ថកេនបិ ។ ភិក្ខូ កុក្កុច្ចាយន្តា កុលានិ ន ឧបសង្កមន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចីវរការសមយេ កុលានិ ឧបសង្កមិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ និមន្តិតោ សភត្តោ សមានោ បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ចីវរទានសមយោ ចីវរការសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។



ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(១៦៨) សម័យនោះឯង ភិក្ខុទាំងឡាយធ្វើចីវរកម្ម គឺការដេរចីវរ ក៏មានសេចក្តីត្រូវការដោយម្ជុលខ្លះ ដោយខ្សែខ្លះ ដោយកំបិតខ្លះ ។ ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យ មិនបានចូលទៅកាន់ត្រកូលទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុចូលទៅកាន់ត្រកូលទាំងឡាយ ក្នុងសម័យធ្វើចីវរបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តគេជាមួយភត្ត ហើយដល់នូវកិរិយាត្រាច់ទៅកាន់ត្រកូលទាំងឡាយក្នុងវេលាមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ ១ កាលដែលភិក្ខុធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៦៩] តេន ខោ បន សមយេន ភិក្ខូ គិលានា ហោន្តិ អត្ថោ ច ហោតិ ភេសជ្ជេហិ ។ ភិក្ខូ កុក្កុច្ចាយន្តា កុលានិ ន បយិរុបាសន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ សន្តំ ភិក្ខុំ អាបុច្ឆា កុលានិ បយិរុបាសិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ និមន្តិតោ សភត្តោ សមានោ សន្តំ ភិក្ខុំ អនាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ចីវរទានសមយោ ចីវរការសមយោ អយំ តត្ថ សមយោតិ ។

[១៧០] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ និមន្តិតោ នាម បញ្ចន្នំ ភោជនានំ អញ្ញតរេន ភោជនេន និមន្តិតោ ។ សភត្តោ នាម យេន និមន្តិតោ តេន សភត្តោ ។ សន្តោ នាម ភិក្ខុ សក្កា



[១៦៩] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ ក៏មានសេចក្តីត្រូវការដោយភេសជ្ជៈទាំងឡាយ ។ ភិក្ខុទាំងឡាយក៏សង្ស័យមិនបានចូលទៅកាន់ត្រកូលទាំងឡាយឡើយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាប្រាប់ភិក្ខុដែលមាននៅ ហើយសឹមចូលទៅកាន់ត្រកូលទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ បានទទួលនិមន្តគេជាអ្នកមានភត្ត ហើយមិនបានលាប្រាប់ភិក្ខុដែលមាននៅ ហើយដល់នូវកិរិយាត្រាច់ទៅកាន់ត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះគឺ កាលដែលទាយកប្រគេនចីវរ ១ កាលដែលភិក្ខុធ្វើចីវរ ១ នេះជាសម័យក្នុងសិក្ខាបទនោះ ។

[១៧០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា និមន្ត គឺជនអ្នកនិមន្តដោយភោជនទាំង ៥ យ៉ាង ភោជនណាមួយ ។ ដែលហៅថា ជាអ្នកមានភត្ត គឺភិក្ខុដែលគេនិមន្តដោយភត្តណា ឈ្មោះថាជាអ្នកមានភត្តព្រោះភត្តនោះឯង ។ ដែលហៅថា ភិក្ខុមាននៅនោះ គឺភិក្ខុអាចនឹងលា

ហោតិ អាបុច្ឆា បវិសិតុំ ។ អសន្តំ នាម ភិក្ខុំ ន សក្កា ហោតិ អាបុច្ឆា បវិសិតុំ ។ បុរេភត្តំ នាម យេន និមន្តិតោ តំ អភុត្តាវី ។ បច្ឆាភត្តំ នាម យេន និមន្តិតោ អន្តមសោ កុសគ្គេនបិ ភុត្តំ ហោតិ ។ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណកុលំ វេស្សកុលំ សុទ្ទកុលំ ។ កុលេសុ ចារិត្តំ អាបជ្ជេយ្យាតិ អញ្ញស្ស ឃរូបចារំ ឱក្កមន្តស្ស អាបត្តិ ទុក្កដស្ស ។ បឋមំ បាទំ ឧម្មារំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ។ ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ ចីវរទានសមយោ នាម អនត្ថតេ កឋិនេ វស្សានស្ស បច្ឆិមោ មាសោ អត្ថតេ កឋិនេ បញ្ច មាសា ។ ចីវរការសមយោ នាម ចីវរេ កយិរមានេ ។



ភិក្ខុផងគ្នាហើយចូលទៅកាន់ (ត្រកូល) បាន ។ ភិក្ខុដែលមិនមាននៅនោះ គឺភិក្ខុមិនអាចលាភិក្ខុផងគ្នាហើយចូលទៅកាន់ (ត្រកូល) ឡើយ ។ ដែលហៅថា ក្នុងវេលាមុនភត្ត គឺដែលនិមន្តដោយភត្តណា ហើយភិក្ខុមិនទាន់បានឆាន់ភត្តនោះ ។ ដែលហៅថា ក្នុងវេលាក្រោយភត្ត គឺដែលនិមន្តដោយភត្តណា ភិក្ខុបានឆាន់ភត្តនោះហើយ ដោយហោចទៅសូម្បីត្រឹមចុងនៃស្បូវ ។ ដែលហៅថា ត្រកូល គឺត្រកូលទាំងឡាយ ៤ គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលវេស្សៈ (អ្នករកស៊ីជួញប្រែធ្វើស្រែចំការ) ១ ត្រកូលសុទ្ទៈ (អ្នកធ្វើការស៊ីឈ្នួល) ១ ។ ពាក្យថា ដល់នូវកិរិយាត្រាច់ទៅក្នុងត្រកូលទាំងឡាយ គឺកាលដែលភិក្ខុឈានចូលទៅដល់ឧបចារផ្ទះរបស់បុគ្គលដទៃទៅ ត្រូវអាបត្តិទុក្កដ ។ ឈានជើងទីមួយឲ្យកន្លងហួសធរណីទ្វារទៅ ត្រូវអាបត្តិទុក្កដ ។ ឈានជើងទីពីរឲ្យកន្លងហួសទៅ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកទុកតែមានសម័យ ។ ដែលហៅថា កាលដែលទាយកប្រគេនចីវរនោះ គឺថា បើភិក្ខុមិនបានក្រាលកឋិន គំលាត់កាល ត្រឹម១ខែជាទីបំផុតនៃវស្សានរដូវ (គឺតាំងពីថ្ងៃ១កើតខែអស្សុជទៅដល់ថ្ងៃ១៥កើតខែកត្តិក) បើភិក្ខុបានក្រាលកឋិន គំលាត់កាលត្រឹម៥ខែ (តាំងពីថ្ងៃ១រោចខែអស្សុជទៅដល់ ១៥ កើតខែផល្គុន) ។ ដែលហៅថា កាលដែលភិក្ខុធ្វើចីវរនោះ គឺភិក្ខុកំពុងធ្វើចីវរ ។

[១៧១] និមន្តិតេ និមន្តិតសញ្ញី សន្តំ ភិក្ខុំ អនាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជតិ អញ្ញត្រ សមយា អាបត្តិ បាចិត្តិយស្ស ។ និមន្តិតេ វេមតិកោ សន្តំ ភិក្ខុំ អនាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជតិ អញ្ញត្រ សមយា អាបត្តិ បាចិត្តិយស្ស ។ និមន្តិតេ អនិមន្តិតសញ្ញី សន្តំ ភិក្ខុំ អនាបុច្ឆា បុរេភត្តំ វា បច្ឆាភត្តំ វា កុលេសុ ចារិត្តំ អាបជ្ជតិ អញ្ញត្រ សមយា អាបត្តិ បាចិត្តិយស្ស ។ អនិមន្តិតេ និមន្តិតសញ្ញី អាបត្តិ ទុក្កដស្ស ។ អនិមន្តិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនិមន្តិតេ អនិមន្តិតសញ្ញី អនាបត្តិ ។



[១៧១] មានគេនិមន្តហើយ ភិក្ខុសំគាល់ថាគេនិមន្តហើយ មិនបានលាភិក្ខុឯទៀតដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មានគេនិមន្តហើយ ភិក្ខុសង្ស័យ មិនបានលាភិក្ខុឯទៀតដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មានគេនិមន្តហើយ ភិក្ខុសំគាល់ថាមិនទាន់និមន្ត ហើយមិនបានលាភិក្ខុឯទៀតដែលមាននៅ ហើយត្រាច់ទៅក្នុងត្រកូលទាំងឡាយ ក្នុងវេលាមុនភត្តក្តី ក្រោយភត្តក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ គេមិនបាននិមន្ត ភិក្ខុសំគាល់ថានិមន្តហើយ ត្រូវអាបត្តិទុក្កដ ។ គេមិនបាននិមន្ត ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ គេមិនបាននិមន្ត ភិក្ខុសំគាល់ថាមិនបាននិមន្ត មិនត្រូវអាបត្តិ ។

[១៧៦] អនាបត្តិ សមយេ សន្តំ ភិក្ខុំ អាបុច្ឆា បវិសតិ អសន្តំ ភិក្ខុំ អនាបុច្ឆា បវិសតិ អញ្ញស្ស ឃរេន មគ្គោ ហោតិ ឃរុបចារេ មគ្គោ ហោតិ អន្តរារាមំ[១] គច្ឆតិ ភិក្ខុនុបស្សយំ គច្ឆតិ តិត្ថិយសេយ្យំ គច្ឆតិ បដិក្កមនំ គច្ឆតិ ភត្តិយឃរំ គច្ឆតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចារិត្តសិក្ខាបទំ និដ្ឋិតំ ។

---

១ ម. អន្តរាមំ ។



[១៧៦] អាបត្តិមិនមាន ដល់ភិក្ខុដែលមានសម័យ ដល់ភិក្ខុដែលបានលាភិក្ខុដទៃដែលមាននៅ ហើយចូលទៅ ដល់ភិក្ខុដែលមិនបានលាភិក្ខុដទៃ ព្រោះមិនមានភិក្ខុដទៃ ហើយចូលទៅ ដល់ភិក្ខុដែលដើរទៅតាមផ្លូវក្បែរផ្ទះនៃបុគ្គលដទៃ ដល់ភិក្ខុដែលដើរទៅតាមផ្លូវតាមឧបចារនៃផ្ទះ ដល់ភិក្ខុដែលទៅកាន់អារាមដែលមានក្នុងចន្លោះស្រុក ដល់ភិក្ខុដែលទៅកាន់លំនៅនៃនាងភិក្ខុនី ដល់ភិក្ខុដែលទៅកាន់លំនៅនៃតិរ្ថិយ ដល់ភិក្ខុដែលដើរត្រឡប់មកវិញ ដល់ភិក្ខុទៅកាន់ផ្ទះនៃទាយក ជាម្ចាស់ភត្ត ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុជាអាទិកម្មិក ។

សិក្ខាបទទី ៦ ចប់ ។

## សត្តមសិក្ខាបទំ

(១៧៣) តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន មហានាមស្ស សក្កស្ស ភេសជ្ជំ ឧស្សន្នំ ហោតិ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ សង្ឃំ ចាតុម្មាសំ ភេសជ្ជេន បវារេតុន្តិ ។ សាធុ សាធុ មហានាម តេនហិ ត្វំ មហានាម សង្ឃំ ចាតុម្មាសំ ភេសជ្ជេន បវារេហីតិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ចាតុម្មាសប្បច្ចយបវារណំ

## សិក្ខាបទទី ៧

(១៧៣) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង មហានាមសក្យៈ(១) មានថ្នាំសម្រាប់កែរោគដ៏បរិបូណ៌ ។ លំដាប់នោះ មហានាមសក្យៈក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ក្រាបទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃដោយថ្នាំសម្រាប់កែរោគគំរោង ៤ ខែ ។ ព្រះអង្គត្រាស់ថា មហានាម ការនេះប្រពៃណាស់ហើយ មហានាម បើដូច្នោះ ចូរព្រះអង្គបវារណាសង្ឃ ដោយថ្នាំសម្រាប់កែរោគគំរោង ៤ ខែចុះ ។ ភិក្ខុទាំងនោះមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយ ក្រាបទូលសេចក្ដីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរនឹងការបវារណា

---

១ អដ្ឋកថាថា មហានាមសក្យៈនេះ ជាបុត្រនៃចូឡបិតារបស់ព្រះដ៏មានព្រះភាគ ជាព្រះរៀមរបស់ព្រះអនុរុទ្ធ ក៏មានច្រើនភាពប្រមាណ ១ ខែ ដោយហេតុការផ្ដល់ [illegible] នឹងផលរាកាលមិនស ។

សាទិតុំ ។ តេន ខោ បន សមយេន ភិក្ខូ មហានាមំ សក្កំ បរិត្តំយេវ(១) ភេសជ្ជំ វិញ្ញាបេន្តិ ។ អថខោ មហានាមស្ស សក្កស្ស ភេសជ្ជំ ឧស្សន្នំ ហោតិ ។ ទុតិយម្បិ ខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ សង្ឃំ អបរំបិ ចាតុម្មាសំ ភេសជ្ជេន បវារេតុន្តិ ។ សាធុ សាធុ មហានាម តេនហិ ត្វំ មហានាម សង្ឃំ អបរំបិ ចាតុម្មាសំ ភេសជ្ជេន បវារេហីតិ ។ ភិក្ខូ កុក្កុច្ចាយន្តា ន សាទិយន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ បុន បវារណំបិ សាទិតុំ ។ តេន ខោ បន សមយេន ភិក្ខូ មហានាមំ សក្កំ បរិត្តំយេវ ភេសជ្ជំ វិញ្ញាបេន្តិ ។ អថខោ មហានាមស្ស សក្កស្ស ភេសជ្ជំ ឧស្សន្នំ ហោតិ ។ តតិយម្បិ ខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ

១ ឱ. បរិត្តំ ។



ណាបច្ច័យកំណត់ត្រឹម ៤ ខែ ។ សម័យនោះឯង ភិក្ខុទាំងឡាយទៅសូមភេសជ្ជៈនឹងមហានាមសក្យៈតែបន្តិចៗ ។ ភេសជ្ជៈរបស់មហានាមសក្យៈក៏ជារបស់នៅតែបរិបូណ៌ដដែល ។ ឯមហានាមសក្យៈក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគជាគំរប់ពីរដងទៀត លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យៈ អង្គុយនៅក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចំរើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃដោយភេសជ្ជៈកំណត់ ៤ ខែតទៅទៀត ។ ព្រះអង្គត្រាស់ថា មហានាម ការនេះប្រពៃហើយ ។ មហានាម បើដូច្នោះ ចូរព្រះអង្គបវារណាសង្ឃ ដោយភេសជ្ជៈកំណត់ ៤ ខែតទៅទៀតចុះ ។ ពួកភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ឲ្យភិក្ខុត្រេកអរនឹងការបវារណាថែមថ្មីទៀត ។ ក៏សម័យនោះឯង ភិក្ខុទាំងឡាយទៅសូមភេសជ្ជៈនឹងមហានាមសក្យៈតែបន្តិចៗ ។ ដោយហេតុនោះឯង ភេសជ្ជៈរបស់មហានាមសក្យៈក៏នៅតែបរិបូណ៌ដដែល ។ មហានាមសក្យៈ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគជាគំរប់បីដងទៀត

ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ សង្ឃំ យាវជីវំ ភេសជ្ជេន បវារេតុន្តិ ។ សាធុ សាធុ មហានាម តេនហិ ត្វំ មហានាម សង្ឃំ យាវជីវំ ភេសជ្ជេន បវារេហីតិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ និច្ចប្បវារណំ សាទិតុន្តិ ។

[១៧៤] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទុន្និវត្ថា ហោន្តិ ទុប្បារុតា អនាកប្បសម្បន្នា មហានាមេន សក្កេន វុត្តា ហោន្តិ(១) កិស្ស តុម្ហេ ភន្តេ ទុន្និវត្ថា ទុប្បារុតា អនាកប្បសម្បន្នា ននុ នាម បព្វជិតេន សុនិវត្ថេន ភវិតព្វំ សុបារុតេន អាកប្ប-សម្បន្នេនាតិ ។ ឆព្វគ្គិយា ភិក្ខូ មហានាមេ សក្កេ ឧបនន្ធឹសុ ។ អថខោ ឆព្វគ្គិយានំ ភិក្ខូនំ ឯតទហោសិ

១ ឧ. ម. មហានាមោ សក្កោ វត្តា ហោតិ ។





លុះចូលទៅដល់ហើយ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏អង្គុយនៅក្នុងទីដ៏សមគួរ ។ លុះមហានាមសក្យៈអង្គុយនៅក្នុងទីដ៏សមគួរហើយ បានក្រាបបង្គំទូលពាក្យនេះចំពោះព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គចង់បវារណាព្រះសង្ឃ ដោយភេសជ្ជៈដរាបដល់អស់ជីវិត ។ ព្រះអង្គត្រាស់ថា មហានាម ការនោះប្រពៃហើយៗ មហានាម បើដូច្នោះ ចូរមហាបពិត្របវារណាសង្ឃ ដោយភេសជ្ជៈដរាបដល់អស់ជីវិតចុះ ។ ពួកភិក្ខុមានសេចក្ដីសង្ស័យ ក៏មិនហ៊ានទទួល ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់អនុញ្ញាតថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុត្រេកអរទទួលការបវារណាអស់កាលជានិច្ចក៏បាន ។

[៦៧៤] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ស្លៀកដណ្ដប់មិនត្រឹមត្រូវ បានអាកប្បកិរិយាមិនសមគួរ មហានាមសក្យៈក៏និយាយថា បពិត្រលោកម្ចាស់ដ៏ចំរើន ហេតុដូចម្ដេច បានជាលោកម្ចាស់ទាំងឡាយស្លៀកដណ្ដប់សំពត់មិនត្រឹមត្រូវ មានអាកប្បកិរិយាមិនសមគួរ (ដូច្នេះ) ធម្មតាអ្នកបួសគេត្រូវស្លៀកដណ្ដប់សំពត់ឲ្យត្រឹមត្រូវល្អ ហើយមានអាកប្បកិរិយាដ៏សមគួរទេតើ ។ ពួកឆព្វគ្គិយភិក្ខុក៏ចងគំនុំនឹងមហានាមសក្យៈ ។ សេចក្ដីត្រិះរិះនេះក៏កើតមានដល់ពួកឆព្វគ្គិយភិក្ខុទាំងនោះថា

កេន នុ ខោ មយំ ឧបាយេន មហាជនំ សង្ឃំ មត្តិ-
ការេយ្យាមាតិ ។ អថខោ ឆព្ពគ្គិយានំ ភិក្ខូនំ ឯតទ-
ហោសិ មហាជនោ(១) អាវុសោ សង្ឃេន សន្ធេ-
គេសញ្ចេន បវារិតោ ហន្ទ មយំ អាវុសោ មហាជនំ
សង្ឃំ សព្វំ វិញ្ញាបេមាតិ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ
យេន មហាជនោ សង្ឃោ តេនុបសង្កមិំសុ ឧបស-
ង្កមិត្វា មហាជនំ សង្ឃំ ឯតទវោចុំ [illegible]
អាវុសោ សង្ឃេន អត្ថោតិ ។ អជ្ជុណ្ហោ ភន្តេ អាគមេថ
មនុស្សា វជំ គតា សប្បិំ អាហរិតុំ កាលេ បវារេស្ស-
ថាតិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ
ឆព្ពគ្គិយា ភិក្ខូ មហាជនំ សង្ឃំ ឯតទវោចុំ [illegible]
អាវុសោ សង្ឃេន អត្ថោតិ ។ អជ្ជុណ្ហោ ភន្តេ អាគមេថ
មនុស្សា វជំ គតា សប្បិំ អាហរិតុំ កាលេ បវារេស្ស-
ថាតិ ។ កឹ បន តយា អាវុសោ អនាគតកាលេន

---

១ សីហោ ចាំ ម. ម. យោត្តកាល ពោសក្ខ ចំណ្យតិ ។



យើងទាំងឡាយ គួរធ្វើមហាជនសង្ឃឲ្យរាប់រាយដោយឧបាយដូចម្ដេច
នេះ ។ គ្រានោះ ពួកឆព្វគ្គិយភិក្ខុគិតឃើញថា ម្នាលលោក
ដ៏មានអាយុទាំងឡាយ មហាជនសង្ឃនេះបែកលោកសង្ឃដោយគេស្គាល់
ហើយ ណ្ហើយចុះ ម្នាលលោកដ៏មានអាយុទាំងឡាយ យើងទាំងឡាយ
ទៅសូមសង្ឃអំពីមហាជនសង្ឃចុះ ។ ទើបពួកឆព្វគ្គិយភិក្ខុចូលទៅរក
មហាជនសង្ឃ លុះចូលទៅដល់ហើយ ក៏និយាយពាក្យនេះនឹងមហាជន
សង្ឃថា ម្នាលអាវុសោ ពួកអាត្មាត្រូវការដោយសង្ឃមួយពេលៈ ។
ឯមហាជនសង្ឃឆ្លើយតបថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់
បង្អង់ចាំត្រឹមថ្ងៃនេះ ១ ថ្ងៃសិន មនុស្សទាំងឡាយនេះទៅឯក្រោលគោដើម្បី
នាំសប្បិមក លោកម្ចាស់ទាំងឡាយនឹងយកសប្បិនោះទៅគង់កាលដ៏គួរ ។
ពួកឆព្វគ្គិយភិក្ខុនិយាយសូមជាគំរប់ពីរដងដែរ ។ បេ ។ ឆព្វគ្គិយភិក្ខុនិយាយ
ពាក្យនេះនឹងមហាជនសង្ឃជាគំរប់បីដងថា ម្នាលអាវុសោ ពួកអាត្មាត្រូវ
ការដោយសង្ឃមួយពេលៈ ។ មហាជនសង្ឃឆ្លើយតបថា បពិត្រលោក
ម្ចាស់ដ៏ចំរើន សូមលោកម្ចាស់បង្អង់ចាំត្រឹមថ្ងៃនេះ ១ ថ្ងៃសិន មនុស្សទាំង
ឡាយនេះទៅឯក្រោលគោដើម្បីនាំសប្បិមក លោកម្ចាស់ទាំងឡាយនឹងយកសប្បិនោះ
ទៅគង់កាលដ៏គួរ ។ ពួកឆព្វគ្គិយភិក្ខុសួរថា ម្នាលអាវុសោ អ្នកបង្អង់ពេល

បាចិត្តិយកណ្ឌេ អចេលកវគ្គស្ស សត្តមសិក្ខាបទស្ស និទានំ

បវារិតេន យំ ត្វំ បវារេត្វា ន ទេសីតិ ។ អថខោ មហានាមោ សក្កោ ឧជ្ឈាយតិ ខីយតិ វិបាចេតិ កថំ ហិ នាម ភទ្ទន្តា អជ្ជណ្ហោ ភន្តេ អាគមេថាតិ វុច្ចមានា នាគមេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ មហានាមស្ស សក្កស្ស ឧជ្ឈាយន្តស្ស ខីយន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ មហានាមេន សក្កេន អជ្ជណ្ហោ ភន្តេ អាគមេថាតិ វុច្ចមានា នាគមេស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ មហានាមេន សក្កេន អជ្ជណ្ហោ ភន្តេ អាគមេថាតិ វុច្ចមានា នាគមេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា មហានាមេន សក្កេន អជ្ជណ្ហោ ភន្តេ អាគមេថាតិ វុច្ចមានា នាគមេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ



បាចិត្តិយកណ្ឌ អចេលកវគ្គ សិក្ខាបទទី ៧ និទាន

ដោយគេសង្គ្រះណាហើយមិនឲ្យវិញ (ប្រយោជន៍អ្វីដោយគេសង្គ្រះដែលអ្នកបវារណាតែមិនចង់ឲ្យនោះ ។ គ្រានោះ មហានាមសក្យៈក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា លោកដ៏ចំរើនទាំងឡាយ ខ្ញុំបាទអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំតែថ្ងៃនេះ ១ ថ្ងៃសិន ចុះហេតុដូចម្តេចបានជាមិនរង់ចាំ ។ ភិក្ខុទាំងឡាយបានឮមហានាមសក្យៈពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុកាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំតែថ្ងៃនេះ ១ ថ្ងៃសិន មិនគួរមិនរង់ចាំសោះ ។ បេ ។ ព្រះពុទ្ធអង្គម្ចាស់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំតែថ្ងៃនេះ ១ ថ្ងៃសិនដូច្នេះ ហើយមិនរង់ចាំ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលពួកមោឃបុរស អ្នកទាំងឡាយ កាលដែលមហានាមសក្យៈបានអង្វរថា លោកម្ចាស់ដ៏ចំរើន សូមពួកលោកម្ចាស់បង្អង់ចាំតែថ្ងៃនេះ ១ ថ្ងៃសិន ហើយមិនគប្បីមិនរង់ចាំ (ដូច្នេះ) សោះ ដែលមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនោះ

វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អគិលានេន ភិក្ខុនា ចាតុម្មាសប្បច្ចយប្បវារណា សាទិតព្វា អញ្ញត្រ បុនប្បវារណាយ អញ្ញត្រ និច្ចប្បវារណាយ តតោ ចេ ឧត្តរិ(១) សាទិយេយ្យ បាចិត្តិយន្តិ ។

[១៩៨] អគិលានេន ភិក្ខុនា ចាតុម្មាសប្បច្ចយប្បវារណា សាទិតព្វាតិ គិលានប្បច្ចយប្បវារណា សាទិតព្វា បុនប្បវារណាបិ សាទិតព្វា យទា គិលានោ ភវិស្សាមិ តទា វិញ្ញាបេស្សាមីតិ និច្ចប្បវារណាបិ សាទិតព្វា យទា គិលានោ ភវិស្សាមិ តទា វិញ្ញាបេស្សាមីតិ ។

[១៩៩] តតោ ចេ ឧត្តរិ សាទិយេយ្យាតិ អត្ថិ បវារណា ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា អត្ថិ បវារណា រត្តិបរិយន្តា ន ភេសជ្ជបរិយន្តា អត្ថិ បវារណា ភេសជ្ជបរិយន្តា ច រត្តិបរិយន្តា ច អត្ថិ បវារណា នេវ ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា ។ ភេសជ្ជបរិយន្តា

១. ម. ឧត្តរឹ ។



មិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា នឹងមិនមែននាំឲ្យរីករឹតតែជ្រះថ្លាដល់ពួកជនដែលជ្រះថ្លាស្រាប់ហើយនោះទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុដែលគ្មានជម្ងឺ ត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម ៤ ខែ បើភិក្ខុត្រេកអរក្រៃលែងជាងនោះទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែការបវារណាថែមទៀត វៀរលែងតែការបវារណាជានិច្ច ។

[១៩៨] ត្រង់ពាក្យថា ភិក្ខុដែលគ្មានជម្ងឺ ត្រូវត្រេកអរនឹងការបវារណាដោយបច្ច័យកំណត់ត្រឹម ៤ ខែ សេចក្តីថា ភិក្ខុគួរត្រេកអរនឹងការបវារណាដោយគិលានបច្ច័យ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណាថែមទៀតដោយគិតថា អាត្មាអញមានជម្ងឺកាលណា អាត្មាអញនឹងសូមក្នុងកាលនោះ ម្យ៉ាងទៀត ភិក្ខុគួរត្រេកអរនឹងការបវារណាជាប់ជានិច្ច ដោយគិតថា អាត្មាអញមានជម្ងឺកាលណា អាត្មាអញនឹងសូមក្នុងកាលនោះ ។

[១៩៩] ត្រង់ពាក្យថា បើភិក្ខុត្រេកអរក្រៃលែងជាងនោះ សេចក្តីថា បវារណាកំណត់ត្រឹមភេសជ្ជៈ មិនកំណត់ត្រឹមរាត្រី បវារណាកំណត់ត្រឹមរាត្រី មិនកំណត់ត្រឹមភេសជ្ជៈ បវារណាកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រី បវារណាមិនកំណត់ទាំងភេសជ្ជៈ មិនកំណត់ទាំងរាត្រី ។ ដែលហៅថា បវារណា

នាម ភេសជ្ជានិ បរិគ្គហិតានិ ហោន្តិ ឯត្តកេហិ ភេសជ្ជេហិ បវារេមីតិ ។ រត្តិបរិយន្តា នាម រត្តិយោ បរិគ្គហិតាយោ ហោន្តិ ឯត្តកាសុ រត្តីសុ បវារេមីតិ ។ ភេសជ្ជបរិយន្តា ច រត្តិបរិយន្តា ច នាម ភេសជ្ជានិ ច បរិគ្គហិតានិ ហោន្តិ រត្តិយោ ច បរិគ្គហិតាយោ ហោន្តិ ឯត្តកេហិ ភេសជ្ជេហិ ឯត្តកាសុ រត្តីសុ បវារេមីតិ ។ នេវ ភេសជ្ជបរិយន្តា ន រត្តិបរិយន្តា នាម ភេសជ្ជានិ ច អបរិគ្គហិតានិ ហោន្តិ រត្តិយោ ច អបរិគ្គហិតាយោ ហោន្តិ ឯត្តកេហិ ភេសជ្ជេហិ ឯត្តកាសុ រត្តីសុ បវារេមីតិ ។

(១៥៥) ភេសជ្ជបរិយន្តេ យេហិ ភេសជ្ជេហិ បវារិតោ ហោតិ តានិ ភេសជ្ជានិ ឋបេត្វា អញ្ញានិ ភេសជ្ជានិ វិញ្ញាបេតិ អាបត្តិ បាចិត្តិយស្ស ។ រត្តិបរិយន្តេ យាសុ រត្តីសុ បវារិតោ ហោតិ តា រត្តិយោ ឋបេត្វា អញ្ញាសុ រត្តីសុ វិញ្ញាបេតិ



កំណត់ភេសជ្ជៈ (នោះ) គឺភេសជ្ជៈដែលគេកំណត់ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណា ដោយភេសជ្ជៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ ។ ដែលហៅថា បវារណាកំណត់រាត្រី គឺរាត្រីដែលគេកំណត់ដោយពាក្យថា ខ្ញុំព្រះករុណាបវារណាអស់រាត្រីទាំងឡាយមានប្រមាណប៉ុណ្ណេះ ។ ដែលហៅថា បវារណាកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រីនោះ គឺគេកំណត់ភេសជ្ជៈទាំងឡាយផង កំណត់រាត្រីទាំងឡាយផង ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណា ដោយភេសជ្ជៈទាំងឡាយ មានប្រមាណប៉ុណ្ណេះ អស់រាត្រីទាំងឡាយមានប្រមាណប៉ុណ្ណេះ ។ ដែលហៅថា បវារណាមិនកំណត់ភេសជ្ជៈ មិនកំណត់រាត្រី (នោះ) គឺគេមិនកំណត់ភេសជ្ជៈទាំងឡាយ ទាំងមិនកំណត់រាត្រីទាំងឡាយ ដោយពាក្យថា ខ្ញុំព្រះករុណាសូមបវារណា ដោយភេសជ្ជៈទាំងឡាយមានប្រមាណប៉ុណ្ណេះ ទាំងអស់រាត្រីទាំងឡាយមានប្រមាណប៉ុណ្ណេះ ។

(១៥៧) ឯពាក្យដែលថា កំណត់ភេសជ្ជៈនោះ អធិប្បាយថា គេបវារណាភិក្ខុដោយភេសជ្ជៈណា ភិក្ខុក្រឡប់ទៅសូមភេសជ្ជៈទាំងឡាយដទៃវិញ ក្រៅពីភេសជ្ជៈដែលគេបវារណានោះ ត្រូវអាបត្តិបាចិត្តិយ ។ ឯកំណត់រាត្រីនោះ គឺគេបវារណាភិក្ខុក្នុងរាត្រីទាំងឡាយណា ភិក្ខុក្រឡប់សូមក្នុងរាត្រីទាំងឡាយឯទៀតវិញ ក្រៅពីរាត្រីដែលគេបវារណានោះ

អាបត្តិ បាចិត្តិយស្ស ។ ភេសជ្ជបរិយន្តេ ច រត្តិបរិយន្តេ ច យេហិ ភេសជ្ជេហិ បវារិតោ ហោតិ តានិ ភេសជ្ជានិ ឋបេត្វា យាសុ រត្តីសុ បវារិតោ ហោតិ តា រត្តិយោ ឋបេត្វា អញ្ញានិ ភេសជ្ជានិ អញ្ញាសុ រត្តីសុ វិញ្ញាបេតិ អាបត្តិ បាចិត្តិយស្ស ។ នេវ ភេសជ្ជបរិយន្តេ ន រត្តិបរិយន្តេ អនាបត្តិ ។

(១៧៨) ន ភេសជ្ជេន ករណីយេន[១] ភេសជ្ជំ វិញ្ញាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញេន ភេសជ្ជេន ករណីយេន[២] អញ្ញំ ភេសជ្ជំ វិញ្ញាបេតិ អាបត្តិ បាចិត្តិយស្ស ។ តតុត្តរិ[៣] តតុត្តរិសញ្ញី ភេសជ្ជំ វិញ្ញាបេតិ អាបត្តិ បាចិត្តិយស្ស ។ តតុត្តរិ វេមតិកោ ភេសជ្ជំ វិញ្ញាបេតិ អាបត្តិ បាចិត្តិយស្ស ។ តតុត្តរិ នតតុត្តរិសញ្ញី ភេសជ្ជំ វិញ្ញាបេតិ អាបត្តិ បាចិត្តិយស្ស ។

១ ឱ. ម. នភេសជ្ជករណីយេន ។ ២ ឱ. ម. ករណីយេន ។ ៣ តតុត្តរិ ។



ត្រូវអាបត្តិបាចិត្តិយ ។ ឯកំណត់ទាំងភេសជ្ជៈ កំណត់ទាំងរាត្រីនោះ គឺគេបវារណាភិក្ខុដោយភេសជ្ជៈទាំងឡាយណា ភិក្ខុវៀរលែងភេសជ្ជៈទាំងនោះ គេបវារណាភិក្ខុក្នុងរាត្រីណា ភិក្ខុវៀរលែងរាត្រីទាំងនោះ ហើយត្រឡប់ទៅសូមភេសជ្ជៈទាំងឡាយដទៃ ក្នុងរាត្រីទាំងឡាយឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ឯមិនកំណត់ភេសជ្ជៈ ទាំងមិនកំណត់រាត្រី មិនជាអាបត្តិឡើយ ។

(១៧៨) កាលបើមិនមានកិច្ចដោយភេសជ្ជៈ ហើយភិក្ខុទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ ។ កាលបើមានកិច្ចដោយភេសជ្ជៈឯទៀត ហើយភិក្ខុទៅសូមភេសជ្ជៈឯទៀតវិញ ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសំគាល់ថា ហួសកំណត់ដែលគេបវារណាមែន ហើយទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសង្ស័យ ហើយទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ ។ ហួសកំណត់ដែលគេបវារណាហើយ ភិក្ខុសំគាល់ថាមិនហួសកំណត់ដែលគេបវារណាទេ ហើយទៅសូមភេសជ្ជៈ ត្រូវអាបត្តិបាចិត្តិយ ។

នតតុត្តរិ តតុត្តរិសញ្ញី អាបត្តិ ទុក្កដស្ស ។ នត-តុត្តរិ វេមតិកោ អាបត្តិ ទុក្កដស្ស ។ នតតុត្តរិ នត-តុត្តរិសញ្ញី អនាបត្តិ ។

(១៧៩) អនាបត្តិ យេហិ ភេសជ្ជេហិ បវារិតោ ហោតិ តានិ ភេសជ្ជានិ វិញ្ញាបេតិ យាយ រត្តិយា បវារិតោ ហោតិ តាយ រត្តិយា វិញ្ញាបេតិ ឥមេហិ តយា ភេសជ្ជេហិ បវារិតម្ហា អម្ហាកញ្ច ឥមិនា ច ឥមិនា ច ភេសជ្ជេន អត្ថោតិ អាចិក្ខិត្វា វិញ្ញាបេតិ យាយ តយា រត្តិយា បវារិតម្ហា សា ច រត្តិ វីតិវត្តា អម្ហាកញ្ច ភេសជ្ជេន អត្ថោតិ អាចិក្ខិត្វា វិញ្ញាបេតិ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្ត-នោ ធនេន ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។



មិនចាត់ជាហួសកំណត់ដែលគេបវារណាទេ ភិក្ខុសំគាល់ថាហួសកំណត់ដែលគេបវារណាហើយ ត្រូវអាបត្តិទុក្កដ ។ មិនចាត់ជាហួសកំណត់ដែលគេបវា-រណាទេ ភិក្ខុសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនចាត់ជាហួសកំណត់ដែលគេបវារណាទេ ភិក្ខុសំគាល់ថាមិនចាត់ជាហួសកំណត់បវារណា មិនមានអាបត្តិ ។

(១៧៩) អាបត្តិមិនមាន ដល់ភិក្ខុដែលគេបវារណាដោយភេសជ្ជៈទាំងឡាយណា ភិក្ខុសូមភេសជ្ជៈទាំងឡាយនោះ ដល់ភិក្ខុដែលគេបវារណាក្នុងរាត្រីទាំងឡាយណា ភិក្ខុសូមក្នុងរាត្រីទាំងឡាយនោះ ដល់ភិក្ខុដែលនិយាយប្រាប់គេថា យើងទាំងឡាយអ្នកបានបវារណាហើយដោយភេសជ្ជៈទាំងឡាយនេះ (អម្បូរនេះ) យើងទាំងឡាយត្រូវការដោយភេសជ្ជៈនេះផងនេះផងហើយសូម ដល់ភិក្ខុដែលនិយាយប្រាប់គេថា យើងទាំងឡាយអ្នកបានបវារណាហើយក្នុងរាត្រីទាំងឡាយណា ឯរាត្រីទាំងឡាយនោះកន្លងហួសទៅហើយ (អម្បូរនេះ) យើងទាំងឡាយត្រូវការដោយភេសជ្ជៈហើយសូម ដល់ភិក្ខុដែលសូមចំពោះពួកញាតិ ដល់ភិក្ខុដែលសូមចំពោះពួកជនដែលគេបានបវារណា ដល់ភិក្ខុដែលសូមដើម្បីជាប្រយោជន៍ដល់ភិក្ខុឯទៀត ដល់ភិក្ខុដែលបានមកដោយទ្រព្យរបស់ខ្លួន ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៧ ចប់ ។

## អដ្ឋមសិក្ខាបទំ

[១៨០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ សេនាយ អព្ភុយ្យាតោ ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ឧយ្យុត្តំ សេនំ ទស្សនាយ អគមំសុ ។ អទ្ទសា ខោ រាជា បសេនទិ កោសលោ ឆព្វគ្គិយេ ភិក្ខូ ទូរតោវ អាគច្ឆន្តេ ទិស្វាន បក្កោសាបេត្វា ឯតទវោច កិស្ស តុម្ហេ ភន្តេ អាគតត្ថាតិ ។ មហារាជានំ មយំ ទដ្ឋុកាមាតិ ។ កឹ ភន្តេ មំ ទិដ្ឋេន យុទ្ធាភិនន្ទិំ ននុ ភគវា បស្សិតព្វោតិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ឧយ្យុត្តំ សេនំ ទស្សនាយ អាគច្ឆិស្សន្តិ អម្ហាកម្បិ អលាភា អម្ហាកម្បិ ទុល្លទ្ធំ យេ មយំ អាជីវស្ស ហេតុ បុត្តទារស្ស ការណា សេនាយ អាគច្ឆាមាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា

## សិក្ខាបទទី ៨

[១៨០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះបាទបសេនទិកោសលរាជ ទ្រង់លើកកងទ័ពចេញទៅ ។ ពួកឆព្វគ្គិយភិក្ខុក៏បានទៅមើលកងទ័ពដែលស្តេចលើកចេញទៅហើយ ។ ព្រះបាទបសេនទិកោសលរាជ បានទតឃើញពួកឆព្វគ្គិយភិក្ខុដើរមកពីចម្ងាយ លុះទ្រង់ឃើញហើយក៏ហៅឲ្យចូលមកហើយទ្រង់ត្រាស់សួរដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចំរើន ពួកលោកនាំគ្នាមកធ្វើអ្វី ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា ពួកអាត្មាមានប្រាថ្នានឹងមើលមហាបពិត្រ ។ ស្តេចក៏ទ្រង់ត្រាស់ថា បពិត្រលោកម្ចាស់ ការមើលខ្ញុំព្រះករុណាជាអ្នកត្រេកអរក្នុងការច្បាំងនឹងមានប្រយោជន៍អ្វី ពួកលោកត្រូវតែគប្បីមើលព្រះដ៏មានព្រះភាគទេតើ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រ មិនគួរនឹងមកមើលកងទ័ព ដែលស្តេចលើកចេញទៅសោះ ពួកយើងឯណាមកក្នុងកងទ័ព ព្រោះហេតុតែការចិញ្ចឹមជីវិតនិងបុត្រភរិយា យើងនោះឈ្មោះថាគ្មានលាភផង ឈ្មោះថាបានរបស់អាក្រក់ផង ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សនោះពោលទោស តិះដៀល បន្ទុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណាជាអ្នកមានសេចក្តីប្រាថ្នាតិច

បាចិត្តិយកណ្ឌេ អចេលកវគ្គស្ស អដ្ឋមសិក្ខាបទស្ស បឋមបញ្ញត្តិ

។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[១៨១] តេន ខោ បន សមយេន អញ្ញតរស្ស ភិក្ខុនោ មាតុលោ សេនាយ គិលានោ ហោតិ ។ សោ តស្ស ភិក្ខុនោ សន្តិកេ ទូតំ បាហេសិ អហញ្ហិ សេនាយ គិលានោ អាគច្ឆតុ ភទន្តោ ឥច្ឆាមិ ភទន្តស្ស អាគតន្តិ ។ អថខោ តស្ស ភិក្ខុនោ ឯតទហោសិ



បាចិត្តិយកណ្ឌ អចេលកវគ្គ សិក្ខាបទទី ៨ សេចក្តីបញ្ញត្តិជាដំបូង

។ បេ ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងនាំគ្នាទៅមើលកងទ័ពដែលស្តេចលើកចេញទៅសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយនាំគ្នាទៅមើលកងទ័ពដែលស្តេចលើកទៅពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងទៅមើលកងទ័ពដែលស្តេចលើកចេញទៅទេ នែមោឃបុរសទាំងឡាយ អំពើនុះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទៅ ដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[១៨១] សម័យនោះឯង មាតុលរបស់ភិក្ខុមួយរូប បានជម្ងឺក្នុងកងទ័ព ។ អ្នកនោះបញ្ជូនទូតទៅកាន់សំណាក់ភិក្ខុនោះថា ខ្ញុំព្រះករុណាមានជម្ងឺក្នុងកងទ័ព សូមលោកម្ចាស់និមន្តមក ខ្ញុំព្រះករុណាចង់ឲ្យលោកម្ចាស់និមន្តមកណាស់ ។ លំដាប់នោះ ភិក្ខុនោះមានសេចក្តីត្រិះរិះ

ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ន ឧយ្យុត្តំ សេនំ ទស្សនាយ គន្តព្វន្តិ អយញ្ច មេ មាតុលោ សេនាយ គិលានោ កថំ នុ ខោ មយា បដិបជ្ជិតព្វន្តិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ តថារូបប្បច្ចយា សេនំ(១) គន្តុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឧយ្យុត្តំ សេនំ ទស្សនាយ គច្ឆេយ្យ អញ្ញត្រ តថារូបប្បច្ចយា បាចិត្តិយន្តិ ។

(១៩៦) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ឧយ្យុត្តា នាម សេនា គាមតោ និក្ខមិត្វា និវិដ្ឋា វា ហោតិ បយាតា វា ។ សេនា នាម ហត្ថី អស្សា រថា បត្តី ។ ទ្វាទសបុរិសោ ហត្ថី ។ តិបុរិសោ អស្សោ ។ ចតុប្បុរិសោ រថោ ។

១ ឧយ្យុត្តំ សេនន្តិបិ បាឋោ មោក្ខកេ ទិស្សតិ ។



ដូច្នេះថា ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយថា ភិក្ខុមិនត្រូវទៅមើលកងទ័ពដែលគេលើកចេញទៅទេ តែឥឡូវឪពុកធំ អញនេះមានជម្ងឺនៅក្នុងកងទ័ព អាត្មាអញត្រូវប្រតិបត្តិដូចម្ដេចហ្ន៎ ។ ទើបភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ គ្រានោះ ក្នុងនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថាហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យទៅកាន់កងទ័ពបាន ព្រោះហេតុមានសភាពយ៉ាងនោះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយទៅ ដើម្បីមើលកងទ័ពដែលគេលើកចេញទៅ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។

(១៩៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទខាងដើមនោះហើយ ។ ដែលហៅថា កងទ័ពដែលគេលើកចេញទៅ គឺកងទ័ពលើកចេញពីស្រុកទៅឈប់សំចតនៅក្ដី ចេញទៅហើយដើរតទៅទៀតក្ដី ។ ដែលហៅថា កងទ័ព គឺពលដំរី ពលសេះ ពលរថ ពលថ្មើរជើង ។ ពលដំរី(មួយៗ) មានបុរស ១២នាក់ ។ ពលសេះ(មួយៗ) មានបុរសបីនាក់ ។ ពលរថ(មួយៗ) មានបុរសបួននាក់ ។

ចត្តារោ បុរិសា សរហត្ថា បត្តិ ។ ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតោ បស្សតិ អាបត្តិ បាចិត្តិយស្ស ។ ទស្សនូបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញត្រ តថារូបប្បច្ចយាតិ ឋបេត្វា តថារូបប្បច្ចយំ ។

(១៨៣) ឧយ្យុត្តេ ឧយ្យុត្តសញ្ញី ទស្សនាយ គច្ឆតិ អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ បាចិត្តិយស្ស ។ ឧយ្យុត្តេ វេមតិកោ ទស្សនាយ គច្ឆតិ អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ បាចិត្តិយស្ស ។ ឧយ្យុត្តេ ឧយ្យុត្តសញ្ញី ទស្សនាយ គច្ឆតិ អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ បាចិត្តិយស្ស ។ ឯកមេកំ ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតោ បស្សតិ អាបត្តិ ទុក្កដស្ស ។ ទស្សនូបចារំ វិជហិត្វា បុនប្បុនំ បស្សតិ



ពលថ្មើរជើង (មួយៗ) មានបុរសបួននាក់កាន់ធ្នូ ។ ភិក្ខុដើរទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើល (កងទ័ពនោះ) នៅទីណា ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ (ក្នុងទីនោះ) ។ ភិក្ខុលះបង់ឧបចារសម្រាប់មើលឃើញ ហើយមើលរឿយៗ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ គឺលើកលែងតែហេតុមានសភាពយ៉ាងហ្នឹង ។

(១៨៣) កងទ័ពលើកចេញទៅហើយ ភិក្ខុសំគាល់ថាកងទ័ពលើកចេញទៅមែន ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។ កងទ័ពលើកចេញទៅហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយនៅតែដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។ កងទ័ពលើកចេញទៅហើយ ភិក្ខុសំគាល់ថា លើកចេញទៅមែន ហើយដើរទៅដើម្បីមើល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។ ភិក្ខុដើរទៅដើម្បីមើលកងទ័ពមួយៗ (ក្នុងកងទ័ពទាំង ៤) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលកងទ័ពនៅទីណា ត្រូវអាបត្តិទុក្កដនៅទីនោះ ។ ភិក្ខុលះបង់ឧបចារសម្រាប់មើលឃើញ ហើយមើលរឿយៗ ។

អាបត្តិ ទុក្កដស្ស ។ អនុយ្យុត្តេ ឧយ្យុត្តសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុយ្យុត្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុយ្យុត្តេ អនុយ្យុត្តសញ្ញី អនាបត្តិ ។

(១៩៦) អនាបត្តិ អារាមេ ឋិតោ បស្សតិ ភិក្ខុស្ស ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគច្ឆតិ បដិបថំ គច្ឆន្តោ បស្សតិ តថារូបប្បច្ចយា អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅនៅ ភិក្ខុសំគាល់ថាលើកចេញទៅហើយ ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅនៅ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កងទ័ពមិនទាន់លើកចេញទៅនៅ ភិក្ខុសំគាល់ថា មិនទាន់លើកចេញទៅនៅ មិនត្រូវអាបត្តិ ។

(១៩៦) អាបត្តិមិនមាន ដល់ភិក្ខុដែលឈរនៅក្នុងអារាម ហើយមើលឃើញ ដល់ភិក្ខុដែលកងទ័ពដើរមកកាន់ទីដែលភិក្ខុឈរនៅ (ក្តី) អង្គុយនៅ (ក្តី) ដេកនៅ (ក្តី) ដល់ភិក្ខុដែលដើរទៅជួបប្រទះគ្នាមុខ ឃើញកងទ័ព ដល់ភិក្ខុដែលមានហេតុមានសភាពយ៉ាងនោះ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយកើតឡើង[១] ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ៨ ចប់ ។

---

១ បើមានសេចក្តីអន្តរាយដល់ជីវិត ដល់ព្រហ្មចរិយធម៌ ភិក្ខុគិតថា គួរទៅក្នុងកងទ័ព ជាស្ពានសេចក្តីអន្តរាយ ហើយដើរចូលទៅក្នុងកងទ័ព មិនត្រូវអាបត្តិ ។

## នវមសិក្ខាបទំ

[១៨៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សតិ ករណីយេ សេនំ គន្ត្វា អតិរេកតិរត្តំ សេនាយ វសន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា សេនាយ វសិស្សន្តិ អម្ហាកម្បិ អលាភា អម្ហាកម្បិ ទុល្លទ្ធំ យេ មយំ អាជីវស្ស ហេតុ បុត្តទារស្ស ការណា សេនាយ បដិវសាមាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អតិរេកតិរត្តំ សេនាយ វសិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អតិរេកតិរត្តំ សេនាយ វសថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា

## សិក្ខាបទទី ៩

(១៨៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុមានកិច្ចធុរៈ ក៏នាំគ្នាទៅកាន់កងទ័ព ហើយឈប់នៅក្នុងកងទ័ពលើសជាងបីរាត្រីទៅ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈសក្យបុត្រមិនគួរនឹងនៅក្នុងកងទ័ពទេ ពួកយើងណាមកអាស្រ័យនៅក្នុងកងទ័ពក៏ព្រោះតែការចិញ្ចឹមជីវិតនឹងចិញ្ចឹមបុត្រភរិយា យើងទាំងនោះឈ្មោះថា គ្មានលាភផង ឈ្មោះថា បានរបស់អាក្រក់ផង ។ ពួកភិក្ខុបានឮពួកមនុស្សនោះពោលទោស តិះដៀល បន្តុះបង្អាប់ដូច្នោះហើយ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងនៅក្នុងកងទ័ពលើសជាងបីរាត្រីសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងនៅក្នុងកងទ័ពលើសជាងបីរាត្រីមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរ

អតិរេកតិរត្តំ សេនាយ វសិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ សេនំ គមនាយ ទិរត្តតិរត្តំ តេន ភិក្ខុនា សេនាយ វសិតព្វំ ។ តតោ ចេ ឧត្តរិ វសេយ្យ បាចិត្តិយន្តិ ។

(១៩៦) សិយា ច តស្ស ភិក្ខុនោ កោចិទេវ បច្ចយោ សេនំ គមនាយាតិ សិយា បច្ចយោ សិយា ករណីយំ ។ ទិរត្តតិរត្តំ តេន ភិក្ខុនា សេនាយ វសិតព្វន្តិ ទ្វេ តិស្សោ រត្តិយោ វសិតព្វំ ។ តតោ ចេ ឧត្តរិ វសេយ្យាតិ ចតុត្ថេ ទិវសេ អត្ថង្គតេ សូរិយេ សេនាយ វសតិ អាបត្តិ បាចិត្តិយស្ស ។

(១៩៧) អតិរេកតិរត្តេ អតិរេកសញ្ញី សេនាយ វសតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកតិរត្តេ វេមតិកោ សេនាយ វសតិ អាបត្តិ បាចិត្តិយស្ស ។ អតិ-





ចង់នៅក្នុងកងទ័ពឲ្យលើសជាងបីរាត្រីដូច្នេះ ម្នាលមោឃបុរសទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា (បើ) ភិក្ខុនោះមានហេតុអ្វីៗ គួរនឹងទៅកាន់កងទ័ពនោះ ភិក្ខុនោះត្រូវនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី ។ បើនៅឲ្យហួសពីកំណត់នោះទៅ ត្រូវអាបត្តិបាចិត្តិយ ។

(១៩៦) ត្រង់ពាក្យថា (បើ) ភិក្ខុនោះមានហេតុអ្វីៗគួរនឹងទៅកាន់កងទ័ពនោះ គឺភិក្ខុមានហេតុ មានកិច្ចធុរៈ (ដែលគួរនាំខ្លួនទៅ) ។ ពាក្យថា ភិក្ខុនោះគប្បីនៅក្នុងកងទ័ពបានត្រឹមពីរបីរាត្រី គឺភិក្ខុត្រូវនៅបានត្រឹមពីរបីយប់ ។ ពាក្យថា បើនៅឲ្យហួសពីកំណត់នោះទៅ សេចក្តីថា កាលព្រះអាទិត្យ អស្តង្គតក្នុងថ្ងៃទី៤ ភិក្ខុនៅក្នុងកងទ័ពនោះ ត្រូវអាបត្តិបាចិត្តិយ ។

(១៩៧) កាលហួសកំណត់បីរាត្រីហើយ ភិក្ខុសំគាល់ថាហួសមែន ហើយនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលហួសកំណត់បីរាត្រីហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលហួសកំណត់បីរាត្រីហើយ

រេកតិរត្តេ ឩនកសញ្ញី សេនាយ វសតិ អាបត្តិ បាចិត្តិយស្ស ។ ឩនកតិរត្តេ អតិរេកសញ្ញី អាបត្តិ ទុក្កដស្ស ។ ឩនកតិរត្តេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឩនកតិរត្តេ ឩនកសញ្ញី អនាបត្តិ ។

(១៥៨) អនាបត្តិ ទ្វេ តិស្សោ រត្តិយោ វសតិ ឩនកទ្វេតិស្សោ រត្តិយោ វសតិ ទ្វេ រត្តិយោ វសិត្វា តតិយាយ រត្តិយា បុរារុណា និក្ខមិត្វា បុន វសតិ គិលានោ វសតិ គិលានស្ស ករណីយេន វសតិ សេនាយ វា បដិសេនាយ វា រុទ្ធោ ហោតិ កេនចិ បលិពុទ្ធោ ហោតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។





ភិក្ខុសំគាល់ថាលើស ហើយប្រើនៅក្នុងកងទ័ព ត្រូវអាបត្តិបាចិត្តិយ ។ កាលមិនទាន់ដល់បីរាត្រី ភិក្ខុសំគាល់ថាហួសហើយ ត្រូវអាបត្តិទុក្កដ ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលមិនទាន់ដល់បីរាត្រីទេ ភិក្ខុក៏សំគាល់ថាមិនទាន់ដល់ មិនត្រូវអាបត្តិ ។

(១៥៨) អាបត្តិមិនមាន ដល់ភិក្ខុដែលនៅត្រឹមតែពីរបីរាត្រី ដល់ភិក្ខុដែលនៅមិនទាន់ដល់ពីរបីរាត្រី ដល់ភិក្ខុដែលនៅត្រឹមពីររាត្រីហើយ ក្នុងរាត្រីជាគំរប់បី ចាកចេញទៅមុនអរុណរះ ហើយត្រឡប់មកនៅវិញទៀត ដល់ភិក្ខុដែលមានជម្ងឺនៅ (ក្នុងកងទ័ព) ដល់ភិក្ខុដែលនៅដោយកិច្ចរបស់ភិក្ខុមានជម្ងឺ ដល់ភិក្ខុដែលនៅក្នុងកងទ័ពហើយមានកងទ័ពជាសត្រូវមករាំងព័ទ្ធកងទ័ព (ទោះឯងវិ) ដល់ភិក្ខុដែលជាប់ចំពាក់ (ដោយបុគ្គលមាន កៀវថ្មស្បប្រជែង) ណាមួយ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី៩ ចប់ ។

# ទសមសិក្ខាបទំ

[១៨៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទិរត្តតិរត្តំ សេនាយ វសមានា ឧយ្យោធិកំបិ ពលគ្គំបិ សេនាព្យូហំបិ អនីកទស្សនំបិ គច្ឆន្តិ ។ អញ្ញតរោបិ ឆព្វគ្គិយោ ភិក្ខុ ឧយ្យោធិកំ គន្ត្វា កណ្ឌេន បដិវិទ្ធោ ហោតិ ។ មនុស្សា តំ ភិក្ខុំ(១) ឧប្បណ្ឌេសុំ កច្ចិ ភន្តេ សុយុទ្ធំ អហោសិ កតិ តេ លក្ខានិ លទ្ធានីតិ ។ សោ ភិក្ខុ តេហិ មនុស្សេហិ ឧប្បណ្ឌិយមានោ មង្កុ អហោសិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ឧយ្យោធិកំ ទស្សនាយ អាគច្ឆិស្សន្តិ អម្ហាកម្បិ អលាភា អម្ហាកម្បិ ទុល្លទ្ធំ យេ មយំ អាជីវស្ស ហេតុ បុត្តទារស្ស ការណា ឧយ្យោធិកំ អាគច្ឆាមាតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ

១ បល្លិវា ឧប្បណ្ឌេសុន្តិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។

# សិក្ខាបទទី ១០

[១៨៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កាលនៅរួមកងទ័ពអស់ពីរបីរាត្រី បានទៅកាន់ទីដែលគេច្បាំងគ្នាខ្លះ ទៅកាន់ទីត្រួតពលខ្លះ ទីតាំងនៅនៃកងទ័ពខ្លះ ទីសម្រាប់មើលសេនាសម្ព័ន្ធខ្លះ ។ មានឆព្វគ្គិយភិក្ខុមួយរូប ទៅកាន់ទីដែលគេច្បាំង ហើយភិក្ខុនោះត្រូវសរ ។ មនុស្សទាំងឡាយក៏ស្រែកឡកឡឺយឲ្យភិក្ខុនោះថា លោកម្ចាស់ លោកច្បាំងស្រួលឬទេ លោកបានខ្លួចប៉ុន្មានហើយ ។ កាលមនុស្សទាំងឡាយនោះនាំគ្នាចំអកឲ្យ ភិក្ខុនោះក៏អៀនអន់ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្រមិនគួរនឹងនាំគ្នាមកមើលច្បាំងសោះ ចំពួកយើងមកកាន់ច្បាំងក៏ព្រោះតែហេតុចិញ្ចឹមជីវិតនិងបុត្រភរិយា ជាការមិនមែនជាលាភរបស់ពួកយើងទេ គឺទ្រព្យដែលពួកយើងបានមក ឈ្មោះថាបានហើយដោយអាក្រក់ទេតើ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំងនោះពោលទោស

ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ឧយ្យោធិកំ ទស្សនាយ គច្ឆិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ឧយ្យោធិកំ ទស្សនាយ គច្ឆថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ឧយ្យោធិកំ ទស្សនាយ គច្ឆិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ទិរត្តតិរត្តញ្ចេ ភិក្ខុ សេនាយ វសមានោ ឧយ្យោធិកំ វា ពលគ្គំ វា សេនាព្យូហំ វា អនីកទស្សនំ វា គច្ឆេយ្យ បាចិត្តិយន្តិ ។

[៤៩០] ទិរត្តតិរត្តញ្ចេ ភិក្ខុ សេនាយ វសមានោតិ ទ្វេ តិស្សោ រត្តិយោ វសមានោ ។ ឧយ្យោធិកំ នាម យត្ថ សម្បហារោ ទិស្សតិ ។ ពលគ្គំ នាម



តិះដៀល បន្តុះបង្អាប់ហើយ ។ ពួកភិក្ខុណាជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ពួកភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរទៅដើម្បីមើលចម្បាំងសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយទៅមើលចម្បាំង ពិតមែនឬ ។ ពួកភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកឯងមិនគួរនឹងទៅមើលចម្បាំងទេ ម្នាលមោឃបុរសទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា កាលបើភិក្ខុនៅក្នុងកងទ័ព សំណាក់ពីរបីរាត្រីហើយ ទៅកាន់ទីដែលគេច្បាំងគ្នាក្តី ទីដែលគេត្រួតពលក្តី ទីតាំងនៃកងទ័ពក្តី ទីសម្រាប់មើលកងទ័ពក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៤៩០] ត្រង់ពាក្យថា បើភិក្ខុនៅក្នុងកងទ័ព សំណាក់ពីរបីរាត្រីហើយ សេចក្តីថា ភិក្ខុនៅក្នុងកងទ័ពអស់ពីរបីយប់ ។ ដែលហៅថា ទីដែលគេច្បាំងគ្នានោះ គឺទីដែលគេប្រហារគ្នា ។ ដែលហៅថា

ឯត្តកា ហត្ថី ឯត្តកា អស្សា ឯត្តកា រថា ឯត្តកា បត្តី ។ សេនាព្យូហំ នាម ឥតោ ហត្ថី ហោន្តុ ឥតោ អស្សា ហោន្តុ ឥតោ រថា ហោន្តុ ឥតោ បត្តិកា ហោន្តុ ។ អនីកំ នាម ហត្ថានីកំ អស្សានីកំ រថានីកំ បត្តានីកំ ។ តយោ ហត្ថី បច្ឆិមំ ហត្ថានីកំ ។ តយោ អស្សា បច្ឆិមំ អស្សានីកំ ។ តយោ រថា បច្ឆិមំ រថានីកំ ។ ចត្តារោ បុរិសា សរហត្ថា បច្ឆិមំ បត្តានីកំ ។

[១៩១] ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតោ បស្សតិ អាបត្តិ បាចិត្តិយស្ស ។ ទស្សនុបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ បាចិត្តិយស្ស ។ ឯកមេកំ ទស្សនាយ គច្ឆតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតោ បស្សតិ អាបត្តិ ទុក្កដស្ស ។ ទស្សនុបចារំ វិជហិត្វា បុនប្បុនំ បស្សតិ អាបត្តិ ទុក្កដស្ស ។



ទ័ពដែលគេត្រួតពលនោះ គឺទ័ពដែលគេកំណត់ថា ពលដំរីមានប៉ុណ្ណេះ ពលសេះមានប៉ុណ្ណេះ ពលរថមានប៉ុណ្ណេះ ពលថ្មើរជើងមានប៉ុណ្ណេះ ។ ដែលហៅថា ទ័ពតាំងនៅទុកទ័ពនោះ គឺពលដំរីនៅត្រង់កន្លែងនេះ ពលសេះនៅត្រង់កន្លែងនេះ ពលរថនៅត្រង់កន្លែងនេះ ពលថ្មើរជើងនៅត្រង់កន្លែងនេះ ។ ដែលហៅថា ក្បួនទ័ពនោះ គឺក្បួនសេនាដំរី ១ ក្បួនសេនាសេះ ១ ក្បួនសេនារថ ១ ក្បួនសេនាថ្មើរជើង ១ ។ ដំរីបី ហៅថា សេនាដំរីយ៉ាងតិចបំផុត ។ សេះបី ហៅថា ក្បួនសេនាសេះយ៉ាងតិចបំផុត ។ រថបី ហៅថា ក្បួនសេនារថយ៉ាងតិចបំផុត ។ បុរសបួននាក់កាន់សរក្នុងដៃ ហៅថា ក្បួនសេនាថ្មើរជើងយ៉ាងតិចបំផុត ។

[១៩១] ភិក្ខុទៅដើម្បីមើល ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុលះបង់ឧបចារនៃទីមើល ហើយក៏នៅមើលឃើញរឿយ ៗ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុទៅដើម្បីមើលកងទ័ពមួយ ៗ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរមើលឃើញក្នុងទីណា ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលះបង់ឧបចារនៃទីមើល ហើយក៏នៅតែមើលឃើញរឿយ ៗ ត្រូវអាបត្តិទុក្កដ ។

(១៩២) អនាបត្តិ អារាមេ ឋិតោ បស្សតិ ភិក្ខុស្ស ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគន្ត្វា សម្បហារោ ទិស្សតិ បដិបថំ គច្ឆន្តោ បស្សតិ សតិ ករណីយេ គន្ត្វា បស្សតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

អចេលកវគ្គោ បញ្ចមោ ។

តស្សុទ្ទានំ

បូវំ កថោបនន្ទស្ស
តយោ បដិច្ឆាទេន ច
មហានាមោ បវេសនំ
សេនា វិយោធំ វសេ ឧសភាតិ ។



(១៩២) អាបត្តិមិនមាន ដល់ភិក្ខុដែលឈរមើលនៅក្នុងអារាម ដល់ភិក្ខុដែលឃើញចម្បាំងដែលគេមកកាន់ទីដែលខ្លួនឈរក្តី អង្គុយក្តី ដេកក្តី ដល់ភិក្ខុដែលដើរទៅប្រទះឃើញតាមផ្លូវ ដល់ភិក្ខុដែលមានកិច្ច (ត្រូវទៅ) ហើយប្រទះឃើញ ដល់ភិក្ខុដែលមានសេចក្តីអន្តរាយ ដល់ភិក្ខុឆ្កួត ដល់ភិក្ខុដើមបញ្ញត្តិ ។

សិក្ខាបទទី ១០ ចប់ ។

អចេលកវគ្គ ជាគំរប់ ៥ ចប់ ។

ឧទ្ទាននៃអចេលកវគ្គនោះមាន ១០ សិក្ខាបទ គឺ

បូវសិក្ខាបទ ១ កថាសិក្ខាបទ ១
បដិច្ឆន្ន ៣ សិក្ខាបទ ចារិត្តសិក្ខាបទ ១
មហានាមសិក្ខាបទ ១ បវេសនសិក្ខាបទ ១
សេនាសិក្ខាបទ ១ វិទ្ធសិក្ខាបទ ១ ។

## សុរាបានវគ្គស្ស បឋមសិក្ខាបទំ

[១៨៣] តេន សមយេន ពុទ្ធោ ភគវា ចេតិយេសុ[១] ចារិកំ ចរមានោ យេន ភទ្ទវតិកា តេន បាយាសិ ។ អទ្ទសំសុ ខោ គោបាលកា បសុបាលកា កស្សកា បថាវិនោ ភគវន្តំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោចុំ មា ភន្តេ ភគវា អម្ពតិត្ថំ អគមាសិ អម្ពតិត្ថេ ភន្តេ ជដិលស្ស អស្សមេ នាគោ បដិវសតិ ឥទ្ធិមា អាសីវិសោ ឃោរវិសោ សោ ភគវន្តំ មា វិហេឋេសីតិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ គោបាលកា បសុបាលកា កស្សកា បថាវិនោ ភគវន្តំ ឯតទវោចុំ មា ភន្តេ ភគវា អម្ពតិត្ថំ អគមាសិ អម្ពតិត្ថេ ភន្តេ ជដិលស្ស អស្សមេ នាគោ បដិវសតិ ឥទ្ធិមា អាសីវិសោ

---

១ ឧក្កាលេសុ ចេតិយេ ចារិកញ្ចិ ភទ្ទវតិ ទិស្វាតិ ។

## សុរាបានវគ្គ សិក្ខាបទទី ១

[១៨៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងចេតិយជនបទ ហើយយាងទៅកាន់ស្រុកភទ្ទវតិកា ។ ពួកអ្នកឃ្វាលគោ ពួកអ្នកឃ្វាលបសុសត្វ (សត្វសម្រាប់ចិញ្ចឹមជាអាហារ) ពួកអ្នកស្រែ ពួកអ្នកដើរផ្លូវ បានឃើញព្រះដ៏មានព្រះភាគយាងមកអំពីចម្ងាយ លុះឃើញហើយក៏នាំគ្នាក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគកុំយាងទៅកាន់កំពង់ឈ្មោះអម្ពតិត្ថៈឡើយ បពិត្រព្រះអង្គដ៏ចំរើន នាគមានរិទ្ធិជាសត្វអាសិរពិស មានពិសដ៏ក្លៀវក្លា អាស្រ័យនៅក្នុងអាស្រម របស់ជដិលទៀបកំពង់ឈ្មោះអម្ពតិត្ថៈ កុំឲ្យនាគនោះបៀតបៀនព្រះដ៏មានព្រះភាគបានឡើយ ។ កាលពួកជនទាំងនោះក្រាបទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគជាម្ចាស់ក៏ស្ងៀម ។ ពួកអ្នកឃ្វាលគោ អ្នកឃ្វាលបសុសត្វ អ្នកស្រែ អ្នកដើរផ្លូវ បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាគំរប់ពីរដងផង ។ បេ ។ បីដងផងថា បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គកុំយាងទៅកាន់កំពង់អម្ពតិត្ថៈឡើយ បពិត្រព្រះអង្គដ៏ចំរើន (ព្រោះថា) នាគមានរិទ្ធិជាសត្វអាសិរពិស មានពិសដ៏ក្លៀវក្លា អាស្រ័យនៅ

ឃោរវិសោ សោ ភគវន្តំ មា វិហេឋេសីតិ ។ តតិយម្បិ ខោ ភគវា តុណ្ហី អហោសិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន ភទ្ទវតិកា តទវសរិ ។ តត្រ សុទំ ភគវា ភទ្ទវតិកាយំ វិហរតិ ។ អថខោ អាយស្មា សាគតោ យេន អម្ពតិត្ថស្ស[១] ជដិលស្ស អស្សមោ តេនុបសង្កមិ ឧបសង្កមិត្វា អគ្យាគារំ បវិសិត្វា តិណសន្ថារកំ បញ្ញបេត្វា និសីទិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ អទ្ទសា ខោ សោ នាគោ អាយស្មន្តំ សាគតំ បវិដ្ឋំ ទិស្វាន ទុក្ខី ទុម្មនោ បធូបាសិ ។ អាយស្មាបិ សាគតោ បធូបាសិ ។ អថខោ សោ នាគោ មក្ខំ អសហមានោ បជ្ជលិ ។ អាយស្មាបិ សាគតោ តេជោធាតុំ សមាបជ្ជិត្វា បជ្ជលិ ។ អថខោ អាយស្មា សាគតោ តស្ស នាគស្ស តេជសា តេជំ បរិយាទិយិត្វា យេន ភទ្ទវតិកា តេនុបសង្កមិ ។ អថខោ ភគវា ភទ្ទវតិកាយំ យថាភិរន្តំ វិហរិត្វា យេន កោសម្ពី

---

១ ឱ. អម្ពតិត្ថកស្ស ។ ម. អម្ពតិត្ថស្ស ។



កាន់អាស្រមរបស់ជដិលឈ្មោះអម្ពតិត្ថៈ កុំឡើយ នាគនោះនឹងបៀតបៀនព្រះដ៏មានព្រះភាគពុំខានឡើយ ។ ព្រះដ៏មានព្រះភាគក៏ទ្រង់ស្ងៀម ដល់គំរប់បីដង ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាច់ទៅកាន់ចារិកដោយលំដាប់ ក៏បានយាងទៅដល់ស្រុកភទ្ទវតិកា ។ មានដំណឹងល្បីថា ព្រះដ៏មានព្រះភាគគង់នៅក្នុងស្រុកភទ្ទវតិកានោះ ។ គ្រានោះឯង ព្រះសាគតៈដ៏មានអាយុបានចូលទៅកាន់អាស្រមរបស់ជដិលឈ្មោះអម្ពតិត្ថៈ លុះចូលទៅដល់ហើយ ក៏ចូលទៅក្នុងរោងភ្លើង ក្រាលកម្រាលស្មៅ ហើយក៏អង្គុយពែនភ្នែន តាំងកាយឲ្យត្រង់ដម្កល់សតិឲ្យតម្រង់ ។ ឯនាគនោះ បានឃើញព្រះសាគតៈដ៏មានអាយុចូលមកហើយ លុះឃើញហើយក៏កើតទុក្ខទោមនស្សបង្ហុយផ្សែង (ពិសចំពោះសាគតត្ថេរ) ។ ចំណែកខាងព្រះសាគតៈដ៏មានអាយុ ក៏បង្ហុយផ្សែងតបទៅវិញ ។ លំដាប់នោះ នាគនោះទ្រាំទ្រនូវសេចក្ដីលុបគុណ (នោះ) មិនបាន ក៏បណ្ដាលភ្លើងកើតឡើង ។ ឯព្រះសាគតៈដ៏មានអាយុក៏បានចូលតេជោធាតុ ហើយបណ្ដាលភ្លើងតបទៅវិញ ។ គ្រានោះឯង ព្រះសាគតៈដ៏មានអាយុ ក៏បានគ្របសង្កត់តេជៈរបស់នាគនោះ ដោយតេជៈ (របស់ខ្លួន) ហើយក៏ចូលទៅកាន់ស្រុកភទ្ទវតិកា ។ កាលដែលព្រះដ៏មានព្រះភាគ គង់នៅក្នុងស្រុកភទ្ទវតិកាតាមសមគួរដល់ព្រះហឫទ័យហើយ

តេន ចារិកំ បក្កាមិ ។ អស្សោសុំ ខោ កោសម្ពិកា ឧបាសកា អយ្យោ កិរ សាគតោ អម្ពតិត្ថកេន នាគេន សទ្ធឹ សង្គាមេសីតិ ។ អថខោ ភគវា អនុបុព្វេន ចារិកំ ចរមានោ យេន កោសម្ពី តទវសរិ ។ អថខោ កោសម្ពិកា ឧបាសកា ភគវតោ បច្ចុគ្គមនំ ករិត្វា យេនាយស្មា សាគតោ តេនុបសង្កមិំសុ ឧបសង្កមិត្វា អាយស្មន្តំ សាគតំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ កោសម្ពិកា ឧបាសកា អាយស្មន្តំ សាគតំ ឯតទវោចុំ កឹ ភន្តេ អយ្យានំ ទុល្លភញ្ច មនាបញ្ច កឹ បដិយាទេមាតិ ។ ឯវំ វុត្តេ ឆព្ពគ្គិយា ភិក្ខូ កោសម្ពិកេ ឧបាសកេ ឯតទវោចុំ អត្ថាវុសោ កាបោតិកា នាម បសន្នា ភិក្ខូនំ ទុល្លភា ច មនាបា ច តំ បដិយាទេថាតិ ។ អថខោ កោសម្ពិកា ឧបាសកា ឃរេ ឃរេ កាបោតិកំ បសន្នំ បដិយាទេត្វា អាយស្មន្តំ សាគតំ បិណ្ឌាយ ចរន្តំ(១) ទិស្វាន

---

១ ម. ឧ. បវិដ្ឋំ ។



ក៏ទ្រង់ពុទ្ធដំណើរទៅកាន់ចារិកឯក្រុងកោសម្ពី ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពីបានឮគេនិយាយថា លោកម្ចាស់សាគតៈបានច្បាំងនឹងនាគឈ្មោះអម្ពតិត្ថកៈ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរទៅកាន់ចារិកដោយលំដាប់ ហើយទ្រង់ស្តេចទៅដល់ក្រុងកោសម្ពីនោះ ។ គ្រានោះឯង ពួកឧបាសកនៅក្នុងក្រុងកោសម្ពីទាំងឡាយទៅទទួលព្រះដ៏មានព្រះភាគ ហើយក៏ចូលទៅរកព្រះសាគតៈដ៏មានអាយុ លុះចូលទៅហើយ ក៏ថ្វាយបង្គំព្រះសាគតៈដ៏មានអាយុ ហើយក៏ឋិតនៅក្នុងទីដ៏សមគួរ ។ ពួកឧបាសកនៅក្នុងក្រុងកោសម្ពី លុះឋិតនៅក្នុងទីដ៏សមគួរហើយ ទើបនិយាយពាក្យនេះ នឹងព្រះសាគតៈដ៏មានអាយុថា បពិត្រលោកម្ចាស់ដ៏ចំរើន វត្ថុអ្វីដែលលោកម្ចាស់បានដោយកម្រផង ជាទីគាប់ចិត្តផង ពួកយើងខ្ញុំនឹងតាក់តែងវត្ថុអ្វីប្រគេន ។ លុះឧបាសកទាំងនោះបានពោលពាក្យយ៉ាងនេះហើយ ពួកឆព្វគ្គិយភិក្ខុ បាននិយាយពាក្យនេះនឹងពួកឧបាសកដែលនៅក្រុងកោសម្ពីថា ម្នាលអ្នកទាំងឡាយ សុរាថ្លាឈ្មោះកាបោតិកា (មានពណ៌ក្រហមដូចជើងព្រាប) ដែលភិក្ខុទាំងឡាយរកបានដោយកម្រផង ជាទីគាប់ចិត្តរបស់ពួកភិក្ខុផង ពួកអ្នកឯងចូរតាក់តែងវត្ថុនោះប្រគេនលោកចុះ ។ លំដាប់នោះឯង ពួកឧបាសកនៅក្រុងកោសម្ពីទាំងឡាយតាក់តែងសុរាថ្លាឈ្មោះកាបោតិកាគ្រប់ៗផ្ទះ បានឃើញព្រះសាគតៈ

អាយស្មន្តំ សាគតំ ឯតទវោចុំ បិវតុ ភន្តេ អយ្យោ សាគតោ កាបោតិកំ បសន្នំ បិវតុ ភន្តេ អយ្យោ សាគតោ កាបោតិកំ បសន្នន្តិ ។ អថខោ អាយស្មា សាគតោ ឃរេ ឃរេ កាបោតិកំ បសន្នំ បិវិត្វា នគរម្ហា និក្ខមន្តោ នគរទ្វារេ បរិបតិ ។ អថខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ នគរម្ហា និក្ខមន្តោ អទ្ទស អាយស្មន្តំ សាគតំ នគរទ្វារេ បរិបតិតំ ទិស្វាន ភិក្ខូ អាមន្តេសិ គណ្ហថ ភិក្ខវេ សាគតន្តិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បដិស្សុណិត្វា អាយស្មន្តំ សាគតំ អារាមំ នេត្វា យេន ភគវា តេន សីសំ កត្វា និបាតេសុំ ។ អថខោ អាយស្មា សាគតោ បរិវត្តិត្វា យេន ភគវា តេន បាទេ កត្វា សេយ្យំ កប្បេសិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ ននុ ភិក្ខវេ សាគតោ តថាគតេ សគារវោ អហោសិ សប្បតិស្សោតិ ។ ឯវំ





ដ៏មានអាយុកំពុងដើរទៅបិណ្ឌបាត ហើយបានពោលពាក្យនេះនឹងព្រះសាគតៈដ៏មានអាយុថា បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់សាគតៈនិមន្តឆាន់សុរាថ្លាឈ្មោះកាបោតិកចុះ បពិត្រលោកដ៏ចំរើន សូមលោកម្ចាស់សាគតៈនិមន្តឆាន់សុរាថ្លាឈ្មោះកាបោតិកចុះ ។ លំដាប់នោះ ព្រះសាគតៈដ៏មានអាយុ លុះបានឆាន់សុរាថ្លាឈ្មោះកាបោតិកគ្រប់ៗ ផ្ទះហើយចេញចាកនគរទៅ ក៏ដួលដេកទៀបទ្វារនគរ ។ គ្រានោះ ព្រះដ៏មានព្រះភាគកាលចេញចាកនគរជាមួយនឹងពួកភិក្ខុជាច្រើនអង្គ បានទតឃើញព្រះសាគតៈដ៏មានអាយុដួលដេកនៅទៀបទ្វារនគរ លុះទ្រង់ឃើញហើយក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរនាំសាគតភិក្ខុទៅ ។ ភិក្ខុទាំងនោះក៏ទទួលព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគដោយពាក្យថា បពិត្រព្រះអង្គដ៏ចំរើន យ៉ាងហ្នឹងហើយ ។ ក៏នាំព្រះសាគតៈដ៏មានអាយុទៅកាន់អារាម ហើយផ្តេកក្បាលទៅរកព្រះដ៏មានព្រះភាគ ។ លំដាប់នោះ ព្រះសាគតៈដ៏មានអាយុក៏ប្រែត្រឡប់ដេកដាក់ជើងទៅរកព្រះដ៏មានព្រះភាគវិញ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អំពីដើមមកសាគតភិក្ខុមានសេចក្តីគោរពកោតក្រែងដល់តថាគតមែនឬទេ ។ ពួកភិក្ខុក្រាបទូលថា

ភន្តេ ។ អបិ នុ ខោ ភិក្ខវេ សាគតោ ឯតរហិ តថា-
គតេ សគារវោ សប្បតិស្សោតិ ។ នោ ហេតំ ភន្តេ ។
ននុ ភិក្ខវេ សាគតោ អម្ពតិត្ថកេន នាគេន សង្គាមេ-
សីតិ ។ ឯវំ ភន្តេ ។ អបិ នុ ខោ ភិក្ខវេ សាគតោ
ឯតរហិ បហោតិ ទេណ្ឌុភេនបិ[១]សទ្ធឹ សង្គាមេតុន្តិ ។
នោ ហេតំ ភន្តេ ។ អបិ នុ ខោ ភិក្ខវេ តំ បា-
តព្វំ យំ បិវិត្វា វិសញ្ញី អស្សាតិ ។ នោ ហេតំ
ភន្តេ ។ អននុច្ឆវិកំ ភិក្ខវេ សាគតស្ស អននុលោ-
មិកំ អប្បតិរូបំ អស្សាមណកំ អកប្បិយំ អករ-
ណីយំ កថញ្ហិ នាម ភិក្ខវេ សាគតោ មជ្ជំ បិវិស្សតិ
នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា

១ ដុណ្ឌុភេន សទ្ធិន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។



សូមទ្រង់មេត្តាប្រោស ពិតយ៉ាងនឹងហើយ ។ ព្រះអង្គទ្រង់ត្រាស់សួរថា
ម្នាលភិក្ខុទាំងឡាយ ចុះឥឡូវនេះ សាគតភិក្ខុមានសេចក្តីគោរពកោតក្រែង
ចំពោះតថាគតឬទេ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិនគោ-
រពទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ សាគតភិក្ខុធ្លាប់
ច្បាំងនឹងអម្ពតិត្ថកនាគ ពិតមែនឬទេ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តា
ប្រោស ពិតមែន ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ចុះ
ឥឡូវនេះ សាគតភិក្ខុ (ដែលដួលដេកមិនដឹងខ្លួនយ៉ាងនេះ) អាចច្បាំងនឹង
ពស់ទឹក[១]បានឬទេ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស មិន
បានទេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រាសចាក
សញ្ញាព្រោះផឹកទឹកណា ទឹកនោះគួរផឹកឬទេ ។ ពួកភិក្ខុក្រាបទូលថា
សូមទ្រង់មេត្តាប្រោស មិនគួរផឹកទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា
ម្នាលភិក្ខុទាំងឡាយ កម្មរបស់សាគតភិក្ខុមិនសមគួរ មិនទំនង មិនត្រូវបែប
មិនមែនជារបស់សមណៈ មិនគប្បី មិនគួរធ្វើ ម្នាលភិក្ខុទាំងឡាយ សាគត-
ភិក្ខុមិនគួរនឹងផឹកទឹកស្រវឹងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិននាំ
ឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ

១ ពស់ទឹកពិស បានដល់ពស់តូចមួយ ធំគស់ព្រួលជើងគេ ។

ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ សុរាមេរយបានេ បាចិត្តិយន្តិ ។

(១៩៦) សុរា នាម បិដ្ឋសុរា បូវសុរា ឱទនសុរា កិណ្ណបក្ខិត្តា សម្ភារសំយុត្តា ។ មេរយោ នាម បុប្ផាសវោ ផលាសវោ មធ្វាសវោ គុឡាសវោ សម្ភារសំយុត្តោ ។ បិវេយ្យាតិ(១) អន្តមសោ កុសគ្គេនបិ បិវតិ អាបត្តិ បាចិត្តិយស្ស ។

(១៩៧) មជ្ជេ មជ្ជសញ្ញី បិវតិ អាបត្តិ បាចិត្តិយស្ស ។ មជ្ជេ វេមតិកោ បិវតិ អាបត្តិ បាចិត្តិយស្ស ។ មជ្ជេ អមជ្ជសញ្ញី បិវតិ អាបត្តិ បាចិត្តិយស្ស ។ អមជ្ជេ

---

១ ឧសប ញាណេ វិជាមនេក្ខា មាតិកាយំ អដ្ឋកថា ។



ឲ្យរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុផឹកសុរានិងមេរ័យ ត្រូវអាបត្តិបាចិត្តិយ ។

(១៩៦) ដែលហៅថា សុរា គឺសុរាធ្វើដោយម្សៅ ១ សុរាធ្វើដោយនំ ១ សុរាធ្វើដោយបាយ ១ សុរាដែលគេដាក់ធូបសុរា ១ សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ១ ។ ដែលហៅថា មេរ័យនោះ គឺទឹកស្រវឹងដែលគេធ្វើដោយផ្កាឈើ ១ ទឹកស្រវឹងដែលគេធ្វើដោយផ្លែឈើ ១ ទឹកស្រវឹងដែលគេធ្វើដោយផ្លែចន្ទន៍ ឬគេធ្វើដោយទឹកឃ្មុំ ១ ទឹកស្រវឹងដែលគេធ្វើដោយទឹកអំពៅ ១ ទឹកស្រវឹងដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ១ ។ ត្រង់ពាក្យថា ផឹក សេចក្ដីថា ដោយហោចទៅសូម្បីតែភិក្ខុផឹកប្រមាណប៉ុនចុងស្បូវ ក៏ត្រូវអាបត្តិបាចិត្តិយ ។

(១៩៧) ទឹកស្រវឹង ភិក្ខុសំគាល់ថា ទឹកស្រវឹង ហើយផឹក ត្រូវអាបត្តិបាចិត្តិយ ។ ទឹកស្រវឹង ភិក្ខុមានសេចក្ដីសង្ស័យ ហើយផឹក ត្រូវអាបត្តិបាចិត្តិយ ។ ទឹកស្រវឹង ភិក្ខុសំគាល់ថា មិនមែនទឹកស្រវឹង ហើយផឹក ត្រូវអាបត្តិបាចិត្តិយ ។ មិនមែនទឹកស្រវឹង ភិក្ខុសំគាល់

មជ្ជសញ្ញី អាបត្តិ ទុក្កដស្ស ។ អមជ្ជេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អមជ្ជេ អមជ្ជសញ្ញី អនាបត្តិ ។

[៤៩៦] អនាបត្តិ អមជ្ជញ្ច ហោតិ មជ្ជវណ្ណំ មជ្ជគន្ធំ មជ្ជរសំ តំ បិវតិ សូបសម្បាកេ មំសសម្បាកេ តេលសម្បាកេ អាមលកផាណិតេ អមជ្ជំ អរិដ្ឋំ បិវតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។



ថា ទឹកស្រវឹង ត្រូវអាបត្តិទុក្កដ ។ មិនមែនទឹកស្រវឹង ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនទឹកស្រវឹង ភិក្ខុសំគាល់ថា មិនមែនទឹកស្រវឹង មិនត្រូវអាបត្តិឡើយ ។

[៤៩៦] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៥យ៉ាង) គឺភិក្ខុផឹកទឹកមិនស្រវឹង តែទឹកនោះមានពណ៌ដូចជាទឹកស្រវឹង មានក្លិនដូចជាទឹកស្រវឹង មានរសដូចជាទឹកស្រវឹង ១ ទឹកស្រវឹងដែលគេចំអិនលាយនឹងសម្ល ១ ទឹកស្រវឹងដែលគេចំអិនលាយនឹងសាច់ ១ ទឹកស្រវឹងដែលគេចំអិនលាយនឹងប្រេង ១ ទឹកអំពៅដែលគេត្រាំនឹងផ្លែកន្ទួតព្រៃ ១ ភិក្ខុផឹកថ្នាំអរិដ្ឋ[១]មិនស្រវឹង ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១ ចប់ ។

---

១ ថ្នាំដែលគេធ្វើដោយផលនៃឈើ មានផ្លែកន្ទួតព្រៃជាដើម ។

## ទុតិយសិក្ខាបទំ

(១៩៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយំ ភិក្ខុំ អង្គុលិបតោទកេន ហាសេសុំ ។ សោ ភិក្ខុ ឧត្តសន្តោ អនស្សាសកោ កាលមកាសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ភិក្ខុំ អង្គុលិបតោទកេន ហាសេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុំ អង្គុលិបតោទកេន ហាសេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខុំ អង្គុលិបតោទកេន ហាសេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អង្គុលិបតោទកេ បាចិត្តិយន្តិ ។

## សិក្ខាបទទី ២

(១៩៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើសត្តរសវគ្គិយភិក្ខុមួយរូប ឲ្យសើចដោយដខ្ទុញគឺម្រាមដៃ(១) ។ ភិក្ខុនោះសើចតាំងពីដកដង្ហើមមិនរួចក៏ធ្វើកាលកិរិយាទៅ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងធ្វើភិក្ខុផងគ្នាឲ្យសើចដោយដខ្ទុញគឺម្រាមដៃសោះ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងធ្វើភិក្ខុផងគ្នាឲ្យសើចដោយដខ្ទុញគឺម្រាមដៃ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងធ្វើភិក្ខុផងគ្នាឲ្យសើចដោយដខ្ទុញគឺម្រាមដៃទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងក៏ទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុចាក់ក្រលេកប្រលែងគ្នាដោយដខ្ទុញគឺម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។

---

១ គឺយកម្រាមដៃចាក់ក្រលេកលេង ។

[១៩៨] អង្គុលិបតោទកោ នាម អង្គុលិយាបិ តុទន្តិ ។ ឧបសម្បន្នោ ឧបសម្បន្នំ ហសាធិប្បាយោ[១] កាយេន កាយំ អាមសតិ អាបត្តិ បាចិត្តិយស្ស ។

[១៩៩] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី អង្គុលិបតោទកេន ហាសេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ អង្គុលិបតោទកេន ហាសេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី អង្គុលិបតោទកេន ហាសេតិ អាបត្តិ បាចិត្តិយស្ស ។

[២០០] កាយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយបដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយបដិពទ្ធេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយបដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

---

១ ។ ហាសាធិប្បាយោ ម. ហាសាធិប្បាយោ ។



[១៩៨] ដែលហៅថា ដន្លុញនឹងម្រាមដៃនោះ គឺភិក្ខុចាក់ដោយម្រាមដៃ ។ ឧបសម្បន្ន ចង់នឹងឲ្យសើចលេង ហើយប៉ះត្រូវកាយរបស់ឧបសម្បន្នដទៃគ្នា ដោយកាយរបស់ខ្លួន ត្រូវអាបត្តិបាចិត្តិយ ។

[១៩៩] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយធ្វើឲ្យសើចដោយដន្លុញនឹងម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ហើយធ្វើឲ្យសើចដោយដន្លុញនឹងម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាជាអនុបសម្បន្នទៅវិញ ហើយធ្វើឲ្យសើចដោយដន្លុញនឹងម្រាមដៃ ត្រូវអាបត្តិបាចិត្តិយ ។

[២០០] ភិក្ខុពាល់ត្រូវវត្ថុដែលជាប់ដោយកាយ (របស់ភិក្ខុដទៃគ្នា) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវកាយ (របស់ភិក្ខុដទៃគ្នា) ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់ភិក្ខុដទៃគ្នា) ដោយវត្ថុដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវកាយ (របស់ភិក្ខុដទៃគ្នា) ដោយវត្ថុសម្រាប់បោះពាល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុដែលជាប់នឹងកាយ (របស់ភិក្ខុដទៃគ្នា) ដោយវត្ថុសម្រាប់បោះពាល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់ត្រូវវត្ថុសម្រាប់បោះពាល (របស់ភិក្ខុដទៃគ្នា) ដោយវត្ថុសម្រាប់បោះពាល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។

(២០១) អនុបសម្បន្នំ កាយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ កាយប្បដិពទ្ធេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន កាយប្បដិពទ្ធំ អាមសតិ អាបត្តិ ទុក្កដស្ស ។ និស្សគ្គិយេន និស្សគ្គិយំ អាមសតិ អាបត្តិ ទុក្កដស្ស ។

(២០២) អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

(២០៣) អនាបត្តិ ន ហស្សាធិប្បាយោ សតិ ករណីយេ អាមសតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។



(២០១) ភិក្ខុពាល់នូវកាយរបស់អនុបសម្បន្ន ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់នូវគ្រឿងដែលជាប់នឹងកាយ (របស់អនុបសម្បន្ន) ដោយកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់នូវកាយ (របស់អនុបសម្បន្ន) ដោយគ្រឿងដែលជាប់នឹងកាយ (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់នូវគ្រឿងដែលជាប់ជាមួយកាយរបស់អនុបសម្បន្ន ដោយគ្រឿងដែលជាប់ជាមួយកាយរបស់ខ្លួន ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់នូវកាយ (របស់អនុបសម្បន្ន) ដោយគ្រឿងសម្រាប់ប្រុះបាល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់នូវគ្រឿងដែលជាប់នឹងកាយ (របស់អនុបសម្បន្ន) ដោយគ្រឿងសម្រាប់ប្រុះបាល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពាល់នូវគ្រឿងសម្រាប់ប្រុះបាល (របស់អនុបសម្បន្ន) ដោយគ្រឿងសម្រាប់ប្រុះបាល (របស់ខ្លួន) ត្រូវអាបត្តិទុក្កដ ។

(២០២) អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(២០៣) ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុគ្មានចំណង់នឹងសើចលេង ១ ភិក្ខុមានកិច្ចហើយពាល់ត្រូវ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ២ ចប់ ។

## តតិយសិក្ខាបទំ

[២០៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ អចិរវតិយា នទិយា ឧទកេ កីឡន្តិ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ មល្លិកាយ ទេវិយា សទ្ធឹ ឧបរិបាសាទវរគតោ ហោតិ ។ អទ្ទសា ខោ រាជា បសេនទិ កោសលោ សត្តរសវគ្គិយេ ភិក្ខូ អចិរវតិយា នទិយា ឧទកេ កីឡន្តេ ទិស្វាន មល្លិកំ ទេវឹ ឯតទវោច ឯតេ តេ មល្លិកេ អរហន្តោ ឧទកេ កីឡន្តីតិ ។ និស្សំសយំ ខោ មហារាជ ភគវតា សិក្ខាបទំ អប្បញ្ញត្តំ តេ វា ភិក្ខូ អប្បកតញ្ញុនោតិ ។ អថ ខោ រញ្ញោ បសេនទិស្ស កោសលស្ស ឯតទហោសិ កេន នុ ខោ អហំ ឧបាយេន ភគវតោ ច ន អារោចេយ្យំ ភគវា ច ជានេយ្យ ឥមេ ភិក្ខូ ឧទកេ កីឡន្តីតិ ។ អថ ខោ រាជា បសេនទិ កោសលោ សត្តរសវគ្គិយេ ភិក្ខូ បក្កោសាបេត្វា

## សិក្ខាបទទី ៣

[២០៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុលេងទឹកក្នុងស្ទឹងឈ្មោះអចិរវតី ។ គ្រានោះ ព្រះបាទបសេនទិកោសល ទ្រង់គង់នៅលើប្រាសាទដ៏ប្រសើរ ជាមួយនឹងព្រះទេវីព្រះនាមមល្លិកា ។ ព្រះបាទបសេនទិកោសល ទ្រង់ទតឃើញពួកសត្តរសវគ្គិយភិក្ខុកំពុងលេងទឹក ក្នុងស្ទឹងអចិរវតី លុះទ្រង់ទតឃើញហើយ ក៏ត្រាស់ព្រះបន្ទូលនឹងនាងមល្លិកាទេវីថា នែនាងមល្លិកា ព្រះអរហន្តទាំងនេះលេងទឹកទេ ។ នាងមល្លិកាទេវីក្រាបទូលថា បពិត្រមហារាជ សូមព្រះអង្គកុំសង្ស័យ ព្រះដ៏មានព្រះភាគមិនទាន់បញ្ញត្តសិក្ខាបទទេ ពុំនោះសោត ភិក្ខុទាំងនោះជាអ្នកមិនដឹងនូវសិក្ខាបទ ដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តរួចហើយ ។ លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រិះរិះយ៉ាងនេះថា ដោយឧបាយដូចម្តេចហ្ន៎ ដែលអញមិនបាច់ក្រាបទូលព្រះដ៏មានព្រះភាគផង តែព្រះដ៏មានព្រះភាគគង់ទ្រង់ជ្រាបថា ភិក្ខុទាំងនេះលេងទឹកផង ។ កាលនោះ ព្រះបាទបសេនទិកោសល ទ្រង់ឲ្យនិមន្តពួកសត្តរសវគ្គិយភិក្ខុមក

តេសំ មហន្តំ គុឡបិណ្ឌំ អទាសិ ឥមំ ភន្តេ គុឡបិណ្ឌំ ភគវតោ ទេថាតិ ។ សត្តរសវគ្គិយា ភិក្ខូ តំ គុឡបិណ្ឌំ អាទាយ យេន ភគវា តេនុបសង្កមិំសុ ឧបសង្កមិត្វា ភគវតោ ឯតទវោចុំ ឥមំ ភន្តេ គុឡបិណ្ឌំ រាជា ភគវតោ ទេតីតិ ។ កហំ បន តុម្ហេ ភិក្ខវេ រាជា អទ្ទសាតិ ។ អចិរវតិយា នទិយា ភគវា ឧទកេ កីឡន្តេតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ឧទកេ កីឡិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ឧទកេ ហស្សធម្មេ(១) បាចិត្តិយន្តិ ។

(៤០៧) ឧទកេ ហស្សធម្មំ នាម ឧបរិគោប្ផកេ ឧទកេ ហស្សាធិប្បាយោ និមុជ្ជតិ វា ឧម្មុជ្ជតិ វា បលវតិ វា អាបត្តិ បាចិត្តិយស្ស ។

---

១ ហសធម្មេតិ បាឋោ ។



ហើយប្រទានដុំស្ករអំពៅមួយដុំធំដល់ពួកភិក្ខុទាំងនោះ ដោយព្រះតម្រាស់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយថ្វាយដុំស្ករអំពៅនេះដល់ព្រះដ៏មានព្រះភាគផង ។ ពួកសត្តរសវគ្គិយភិក្ខុយកដុំស្ករអំពៅនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ស្ដេចថ្វាយដុំស្ករអំពៅនេះចំពោះព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ស្ដេចឃើញពួកអ្នកឯងនៅឯណា ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ស្ដេចទតឃើញពួកខ្ញុំព្រះអង្គកំពុងលេងទឹកក្នុងស្ទឹងអចិរវតី ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងនាំគ្នាលេងទឹកទេ ម្នាលមោឃបុរសទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេដែរ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុលេងទឹក ត្រូវអាបត្តិបាចិត្តិយ ។

[៤០៧] ដែលហៅថា លេងទឹកនោះ គឺភិក្ខុមានចំណង់នឹងលេងទឹក ដែលជ្រៅជាងកជើងឡើងទៅ ដោះមុជចុះក្តី ងើបឡើងក្តី ហែលក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៦០៦] ឧទកេ ហស្សធម្មេ ហស្សធម្មសញ្ញី អាបត្តិ បាចិត្តិយស្ស ។ ឧទកេ ហស្សធម្មេ វេមតិកោ អាបត្តិ បាចិត្តិយស្ស ។ ឧទកេ ហស្សធម្មេ អហស្សធម្មសញ្ញី អាបត្តិ បាចិត្តិយស្ស ។

[៦០៧] ហេដ្ឋាគោប្ផកេ ឧទកេ កីឡតិ អាបត្តិ ទុក្កដស្ស ។ នាវាយ កីឡតិ អាបត្តិ ទុក្កដស្ស ។ ហត្ថេន វា បាទេន វា កដ្ឋេន វា កឋលាយ វា ឧទកំ បហរតិ(១) អាបត្តិ ទុក្កដស្ស ។ ភាជនគតំ ឧទកំ វា កញ្ជិកំ វា ខីរំ វា តក្កំ វា រជនំ វា បស្សាវំ វា ចិក្ខល្លំ វា កីឡតិ អាបត្តិ ទុក្កដស្ស ។

[៦០៨] ឧទកេ អហស្សធម្មេ ហស្សធម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ ឧទកេ អហស្សធម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ឧទកេ អហស្សធម្មេ អហស្សធម្មសញ្ញី អនាបត្តិ ។

១ ឱ. ម. ឧទកំ បហរតិ ។



[៦០៦] លេងទឹក ភិក្ខុសំគាល់ថាលេងទឹក ត្រូវអាបត្តិបាចិត្តិយ ។ លេងទឹក ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ ។ លេងទឹក ភិក្ខុសំគាល់ថា មិនមែនលេងវិញ ត្រូវអាបត្តិបាចិត្តិយ ។

[៦០៧] ភិក្ខុលេងទឹកទាបជាងកជើង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលេងទឹកដោយទូក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុប្រហារទឹកដោយដៃក្តី ជើងក្តី កំណាត់ឈើក្តី អំបែងក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលេងទឹកដែលមានក្នុងភាជន៍ក្តី លេងទឹកខ្មេះក្តី ទឹកដោះស្រស់ក្តី ទឹកដោះជូរក្តី ទឹកជ្រលក់ក្តី ទឹកនោមក្តី ភក់ក្តី ត្រូវអាបត្តិទុក្កដ ។

[៦០៨] មិនមែនលេងទឹកទេ ភិក្ខុសំគាល់ថាលេង ត្រូវអាបត្តិទុក្កដ ។ មិនមែនលេងទឹក ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនលេងទឹក ភិក្ខុសំគាល់ថាមិនមែនលេង មិនត្រូវអាបត្តិឡើយ ។

បាចិត្តិយកណ្ឌេ សុរាបានវគ្គស្ស តតិយសិក្ខាបទស្ស អនាបត្តិវារោ

(៦០៩) អនាបត្តិ ន ហសាធិប្បាយោ សតិ ករណីយេ ឧទកំ ឱតរិត្វា និមុជ្ជតិ វា ឧម្មុជ្ជតិ វា បលវតិ វា បារំ គច្ឆន្តោ និមុជ្ជតិ វា ឧម្មុជ្ជតិ វា បលវតិ វា អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។



បាចិត្តិយកណ្ឌ សុរាបានវគ្គ សិក្ខាបទទី ៣ វារៈដែលមិនត្រូវអាបត្តិ

(៦០៩) វារៈដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុគ្មានចំណង់នឹងលេង ១ ភិក្ខុមានកិច្ចហើយចុះទឹកមុជចុះក្តី ងើបក្តី ហែលក្តី ១ ភិក្ខុចង់ទៅត្រើយម្ខាង មុជចុះក្តី ងើបក្តី ហែលក្តី ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់ ។

## ចតុត្ថសិក្ខាបទំ

[៦១០] តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ អនាចារំ អាចរតិ ។ ភិក្ខូ ឯវមាហំសុ មា អាវុសោ ឆន្ន ឯវរូបំ អកាសិ នេតំ កប្បតីតិ ។ សោ អនាទរិយំ បដិច្ច ករោតិយេវ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឆន្នោ អនាទរិយំ ករិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឆន្ន អនាទរិយំ ករោសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស អនាទរិយំ ករិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ អនាទរិយេ បាចិត្តិយន្តិ ។

## សិក្ខាបទទី ៤

[៦១០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង ឆន្នដ៏មានអាយុក៏តែប្រព្រឹត្ត អនាចារ ។ ភិក្ខុទាំងឡាយក៏និយាយយ៉ាងនេះថា ម្នាលឆន្នដ៏មានអាយុ លោកកុំធ្វើអំពើមានសភាពដូច្នេះឡើយ អំពើនេះមិនសមគួរទេ ។ ឆន្នភិក្ខុនោះក៏ប្រព្រឹត្តសេចក្តីមិនអើពើ ហើយនៅតែធ្វើ (អនាចារ) ដដែល ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឆន្នដ៏មានអាយុ មិនគួរធ្វើនូវសេចក្តីមិនអើពើសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឆន្ន ឮថាអ្នកឯងធ្វើនូវសេចក្តីមិនអើពើ ពិតមែនឬ ។ ឆន្នភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងធ្វើនូវសេចក្តីមិនអើពើទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។

[៦០១] អនាទរិយំ នាម ទ្វេ អនាទរិយានិ បុគ្គលានាទរិយញ្ច ធម្មានាទរិយញ្ច ។ បុគ្គលានាទរិយំ នាម ឧបសម្បន្នេន បញ្ញត្តេន វចនេន វុច្ចមានោ អយំ ឧក្ខិត្តកោ វា វម្ភិតោ វា គរហិតោ វា ឥមស្ស វចនំ អកតំ ភវិស្សតីតិ អនាទរិយំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មានាទរិយំ នាម ឧបសម្បន្នេន បញ្ញត្តេន វចនេន វុច្ចមានោ កថាយំ នស្សេយ្យ វា វិនស្សេយ្យ វា អន្តរធាយេយ្យ វាតិ តំ វា ន សិក្ខិតុកាមោ អនាទរិយំ ករោតិ អាបត្តិ បាចិត្តិយស្ស ។

[៦០២] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី អនាទរិយំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ អនាទរិយំ ករោតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី អនាទរិយំ ករោតិ អាបត្តិ បាចិត្តិយស្ស ។

[៦០៣] ឧបសម្បន្នេន អបញ្ញត្តេន វចនេន វុច្ចមានោ ឥទំ ន សល្លេខាយ ន ធុតត្តាយ ន បាសាទិកតាយ





[៦០១] ដែលហៅថា មិនអើពើ បានដល់សេចក្ដីមិនអើពើពីរយ៉ាង គឺមិនអើពើនឹងបុគ្គល១ មិនអើពើនឹងធម៌១ ។ ដែលហៅថា មិនអើពើនឹងបុគ្គលនោះ គឺឧបសម្បន្ន កាលបើមានឧបសម្បន្នដទៃ ពោលដាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ក៏គិតថា ភិក្ខុនេះ សង្ឃបានលើកវត្តហើយក្ដី សង្ឃបង្អាប់ហើយក្ដី សង្ឃតិះដៀលហើយក្ដី ពាក្យរបស់ភិក្ខុនេះ អញនឹងមិនធ្វើតាមទេ ហើយក៏ធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។ ដែលហៅថា មិនអើពើនឹងធម៌នោះ គឺឧបសម្បន្ន កាលបើមានឧបសម្បន្នដទៃ ពោលដាស់តឿនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគ ទ្រង់បញ្ញត្តហើយ ក៏គិតថា ធ្វើដូចម្ដេច ធម៌នេះគប្បីវិនាសទៅក្ដី សាបសូន្យទៅក្ដី អន្តរធានទៅក្ដី ឬមិនចង់សិក្សានូវធម៌នោះ ហើយក៏ធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។

[៦០២] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្នទៅវិញ ហើយធ្វើសេចក្ដីមិនអើពើ ត្រូវអាបត្តិបាចិត្តិយ ។

[៦០៣] ឧបសម្បន្ន កាលបើមានឧបសម្បន្នដទៃ ពោលដាស់តឿនដោយពាក្យឯទៀត ដែលមិនមែនជាវិន័យបញ្ញត្តិ ហើយគិតថា

ន អបចយាយ ន វីរិយារម្ភាយ សំវត្តតីតិ អនាទរិយំ ករោតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេន បញ្ញត្តេន វា អបញ្ញត្តេន វា វុច្ចមានោ នេតំ ន សល្លេខាយ ន ធុតត្ថាយ ន បាសាទិកតាយ ន អបចយាយ ន វីរិយារម្ភាយ សំវត្តតីតិ អនាទរិយំ ករោតិ អាបត្តិ ទុក្កដស្ស ។

(៦១៧) អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

(៦១៨) អនាបត្តិ ឯវំ អម្ហាកំ អាចរិយានំ ឧគ្គហោ បរិបុច្ឆាតិ ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។



ពាក្យនេះមិនតាំងឲ្យចិត្តផូរផង់ មិនតាំងឲ្យកំចាត់បង់កិលេសបាន មិនតាំងឲ្យកើតសេចក្តីជ្រះថ្លា មិនមែនតាំងឲ្យកើតសេចក្តីមិនសន្សំទុកនូវកិលេសបាន មិនតាំងឲ្យប្រារព្ធសេចក្តីព្យាយាម ហើយធ្វើនូវសេចក្តីមិនអើពើ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន កាលបើមានអនុបសម្បន្នពោលថា សំគៀនតាមសិក្ខាបទដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយក្តី មិនបញ្ញត្តហើយក្តី ហើយគិតថា ពាក្យនេះមិនតាំងឲ្យចិត្តផូរផង់ មិនតាំងឲ្យកំចាត់បង់កិលេសបាន មិនតាំងឲ្យកើតសេចក្តីជ្រះថ្លា មិនមែនតាំងឲ្យកើតសេចក្តីមិនសន្សំទុកនូវកិលេសបាន មិនតាំងឲ្យប្រារព្ធសេចក្តីព្យាយាម ហើយធ្វើសេចក្តីមិនអើពើ ត្រូវអាបត្តិទុក្កដ ។

(៦១៧) អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៦១៨) ភាពដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៣ យ៉ាង) ភិក្ខុពោលថា ធម្មឧគ្គហៈ[១]នៃអាចារ្យទាំងឡាយ របស់យើងយ៉ាងនេះ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៤ ចប់ ។

---

១ ពាក្យរៀនបានមកអំពីក្នុងគ្រូស្រួតនិងប្រែអត្ថ ។

## បញ្ចមសិក្ខាបទំ

[៦១៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ សត្តរសវគ្គិយេ ភិក្ខូ ភឹសាបេន្តិ ។ តេ ភឹសាបិយមានា រោទន្តិ ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ រោទថាតិ ។ ឥមេ អាវុសោ ឆព្ពគ្គិយា ភិក្ខូ អម្ហេ ភឹសាបេន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ភិក្ខូ ភឹសាបេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខូ ភឹសាបេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខូ ភឹសាបេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ ភឹសាបេយ្យ បាចិត្តិយន្តិ ។

## សិក្ខាបទទី ៥

(៦១៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ធ្វើសត្តរសវគ្គិយភិក្ខុឲ្យខ្លាច ។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះ កាលបើគេធ្វើឲ្យខ្លាចក៏ស្រែកយំ ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាអ្នកទាំងឡាយស្រែកយំ ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះធ្វើបំភ័យពួកខ្ញុំឲ្យខ្លាច ។ ពួកភិក្ខុណាជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ពួកភិក្ខុទាំងនោះ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងធ្វើភិក្ខុដទៃឲ្យខ្លាចសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយធ្វើភិក្ខុដទៃឲ្យខ្លាច ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងបំភ័យភិក្ខុដទៃទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទៀតទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយធ្វើភិក្ខុដទៃឲ្យខ្លាច ត្រូវអាបត្តិបាចិត្តិយ ។

[៦១៧] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខុន្តិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខុ ។ ភិក្ខុន្តិ អញ្ញំ ភិក្ខុំ ។ ភឹសាបេយ្យាតិ ឧបសម្បន្នោ ឧបសម្បន្នំ ភឹសាបេតុកាមោ រូបំ វា សទ្ទំ វា គន្ធំ វា រសំ វា ផោដ្ឋព្វំ វា ឧបសំហរតិ ភាយេយ្យ វា សោ ន វា ភាយេយ្យ អាបត្តិ បាចិត្តិយស្ស ។ ចោរកន្តារំ វា វាឡកន្តារំ វា បិសាចកន្តារំ វា អាចិក្ខតិ ភាយេយ្យ វា សោ ន វា ភាយេយ្យ អាបត្តិ បាចិត្តិយស្ស ។

[៦១៨] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី ភឹសាបេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ ភឹសាបេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី ភឹសាបេតិ អាបត្តិ បាចិត្តិយស្ស ។

[៦១៩] ឧបសម្បន្នោ អនុបសម្បន្នំ ភឹសាបេតុកាមោ រូបំ វា សទ្ទំ វា គន្ធំ វា រសំ វា ផោដ្ឋព្វំ វា ឧបសំហរតិ ភាយេយ្យ វា សោ ន វា ភាយេយ្យ



[៦១៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងបទបុព្វភាគដើម ។ ពាក្យថា ភិក្ខុដទៃ គឺភិក្ខុដទៃ (ក្រៅពីខ្លួន) ។ ពាក្យថា ឲ្យខ្លាច គឺឧបសម្បន្ន មានបំណងនឹងធ្វើឧបសម្បន្នឲ្យខ្លាច ហើយសំដែងរូបក្ដី សំឡេងក្ដី ក្លិនក្ដី រសក្ដី ផ្សព្វក្ដី ទោះបីឧបសម្បន្ននោះខ្លាចក្ដី មិនខ្លាចក្ដី ក៏ត្រូវអាបត្តិបាចិត្តិយ ។ (ឧបសម្បន្នមានសេចក្ដីប្រាថ្នាដើម្បីបន្លាចឧបសម្បន្នដទៃ) ហើយប្រាប់ផ្លូវលំបាកដោយចោរក្ដី ផ្លូវលំបាកដោយម្រឹគសាហាវក្ដី ផ្លូវលំបាកដោយខ្មោចក្ដី ទោះបីឧបសម្បន្ននេះខ្លាចក្ដី មិនខ្លាចក្ដី ត្រូវអាបត្តិបាចិត្តិយ ។

[៦១៨] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយបន្លាច ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសង្ស័យ ហើយបន្លាច ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្នទៅវិញ ហើយបន្លាច ត្រូវអាបត្តិបាចិត្តិយ ។

[៦១៩] ឧបសម្បន្ន មានបំណងនឹងបន្លាចអនុបសម្បន្ន ហើយសំដែងរូបក្ដី សំឡេងក្ដី ក្លិនក្ដី ផ្សព្វក្ដី រសក្ដី ទោះបីអនុបសម្បន្ននោះខ្លាចក្ដី

អាបត្តិ ទុក្កដស្ស ។ ចោរកន្តារំ វា វាឡកន្តារំ វា បិសាចកន្តារំ វា អាចិក្ខតិ ភាយេយ្យ វា សោ មា វា ភាយេយ្យ អាបត្តិ ទុក្កដស្ស ។

[៦៦០] អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[៦៦១] អនាបត្តិ ន ភឹសាបេតុកាមោ រូបំ វា សទ្ទំ វា គន្ធំ វា រសំ វា ផោដ្ឋព្វំ វា ឧបសំហរតិ ចោរកន្តារំ វា វាឡកន្តារំ វា បិសាចកន្តារំ វា អាចិក្ខតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។



មិនខ្លាចក្តី ក៏ត្រូវអាបត្តិទុក្កដ ។ (ឧបសម្បន្នមានសេចក្តីប្រាថ្នាដើម្បីបន្លាចអនុបសម្បន្ន) ហើយប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី ទោះបីអនុបសម្បន្ននោះខ្លាចក្តី មិនខ្លាចក្តី ត្រូវអាបត្តិទុក្កដ ។

[៦៦០] អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្នវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[៦៦១] វារៈដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុគ្មានចំណង់នឹងបន្លាច ហើយសំដែងរូបក្តី សំឡេងក្តី ក្លិនក្តី រសក្តី ផ្សព្វក្តី ១ ភិក្ខុ (គ្មានចំណង់នឹងបន្លាចហើយ) ប្រាប់ផ្លូវលំបាកដោយចោរក្តី ផ្លូវលំបាកដោយម្រឹគសាហាវក្តី ផ្លូវលំបាកដោយខ្មោចក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៥ ចប់ ។

# ឆដ្ឋសិក្ខាបទំ

[៦៦៦] តេន សមយេន ពុទ្ធោ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន ភិក្ខូ ហេមន្តិកេ មាសេ អញ្ញតរំ មហន្តំ សុសិរកដ្ឋំ ជោតឹ សមាទហិត្វា វិសិព្វេសុំ ។ តស្មិំ ច សុសិរេ កណ្ហសប្បោ អគ្គិនា សន្តត្តោ និក្ខមិត្វា ភិក្ខូ បរិបាតេសិ ។ ភិក្ខូ តហំ តហំ ឧបធាវិំសុ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ ជោតឹ សមាទហិត្វា វិសិព្វេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ជោតឹ សមាទហិត្វា វិសិព្វេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ជោតឹ សមាទហិត្វា វិសិព្វេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ

# សិក្ខាបទទី ៦

[៦៦៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅភេសកឡាវ័ន ជាទីឲ្យភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ សម័យនោះឯង ភិក្ខុទាំងឡាយនាំគ្នាបង្កាត់ភ្លើងនឹងដើមឈើដែលមានប្រហោងធំ ១ ដុត ហើយនាំគ្នាអាំងក្នុងរដូវរងា ។ មានពស់វែក ១ នៅក្នុងប្រហោងឈើនោះ ត្រូវក្តៅភ្លើងក៏លូនចេញមក ហើយដេញភិក្ខុទាំងឡាយ ឲ្យផ្លូលផាសពាស ។ ភិក្ខុទាំងឡាយក៏ស្ទុះរត់ទៅក្នុងទីនោះៗ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនគួរនឹងបង្កាត់ភ្លើងអាំងសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយបង្កាត់ភ្លើងអាំងពិតមែនឬ ។ ភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែភិក្ខុទាំងឡាយ មោឃបុរសទាំងនោះ មិនគួរនឹងបង្កាត់ភ្លើងអាំងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងក៏ទេដែរ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ

វិសេវាបទេស្ហា(១) ហោតិ សមានហេយ្យ វា សមានហាបេយ្យ វា ទាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៤៤៣] តេន ខោ បន សមយេន ភិក្ខុនិយោ ភិក្ខុនីហិ ។ ភិក្ខុនិយោ ឧបដ្ឋាកា ភិក្ខុនិយោ ភិក្ខុនីហិ ឯកតោ សន្និហិតា ហោន្តិ ។ កច្ចិ នុ ខោ អាវុសោ ធម្មំ ភាសតិ ទានីយំ ហោតិ វិសេវាបទេស្ហា ហោតិ ។ អថ ខោ ភិក្ខុនិយោ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ភិក្ខុនីហិ សមានហិត្វា វា សមានហាបេត្វា វា វិសេវាបទេស្ហា ហោតិ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យា បន ភិក្ខុនី អភិណ្ហោ វិសេវាបទេស្ហា ហោតិ សមានហេយ្យ វា សមានហាបេយ្យ វា ទាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខុនីនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

១ ម. វិសុក្ខាបេត្វា ។



មានបំណងនឹងតាំងក្តី បញ្ជាក់ខ្លួនឯងក្តី ប្រើគេឲ្យបញ្ជាក់ក្តី ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះ ដល់ភិក្ខុនីទាំងឡាយយ៉ាងនេះហើយ ។

[៤៤៤] សម័យនោះឯង ភិក្ខុនីទាំងឡាយមានជម្ងឺ ។ ពួកភិក្ខុនីអ្នកសួរជម្ងឺ និយាយពាក្យនេះនឹងភិក្ខុនីដែលមានជម្ងឺថា ម្នាលអាវុសោ អ្នកទាំងឡាយលួមអត់ធន់បានឬទេ លួមញុំាងអត្តភាពឲ្យប្រព្រឹត្តទៅបានឬទេ ។ ពួកភិក្ខុនីមានជម្ងឺឆ្លើយថា ម្នាលអាវុសោ ពីដើមយើងកាលតាំងក្តីអំពើបានធ្វើមុនសេចក្តីសុខសប្បាយរាល់គ្នា ដោយហេតុបានតាំងក្តីនោះ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហេតុនោះយើងមានសេចក្តីខ្លាចក្រែង មិនហ៊ានតាំងក្តី បានជាយើងមិនមានសេចក្តីសុខសប្បាយ ដោយហេតុនោះឯង ។ ភិក្ខុនីទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុនីទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុនីដែលមានជម្ងឺបញ្ជាក់ក្តីខ្លួនឯងក្តី ប្រើគេឲ្យបញ្ជាក់ក្តី ហើយតាំងបាន ម្នាលភិក្ខុនីទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនីណាមួយមិនមានជម្ងឺ ប្រាថ្នានឹងតាំងក្តីហើយបញ្ជាក់ខ្លួនឯងក្តី ប្រើគេឲ្យបញ្ជាក់ក្តី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុនីទាំងឡាយយ៉ាងនេះ ។

[៦៦៦] តេន ខោ បន សមយេន ភិក្ខូ បទីបេបិ ជោតិកេបិ ជន្តាឃរេបិ កុក្កុច្ចាយន្តិ(១) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ តថារូបប្បច្ចយា ជោតឹ សមាទហិតុំ សមាទហាបេតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ អគិលានោ វិសិព្វនាបេក្ខោ ជោតឹ សមាទហេយ្យ វា សមាទហាបេយ្យ វា អញ្ញត្រ តថារូបប្បច្ចយា បាចិត្តិយន្តិ ។

[៦៦៧] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អគិលានោ នាម យស្ស វិនា អគ្គិនា ផាសុ ហោតិ ។ គិលានោ នាម យស្ស វិនា អគ្គិនា ន ផាសុ ហោតិ ។ វិសិព្វនាបេក្ខោតិ តប្បិតុកាមោ ។ ជោតិ នាម អគ្គិ វុច្ចតិ ។ សមាទហេយ្យាតិ សយំ សមាទហតិ អាបត្តិ បាចិត្តិយស្ស ។ សមាទហាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ បាចិត្តិយស្ស ។ សកឹ អាណត្តោ ពហុកំបិ សមាទហតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញត្រ តថារូបប្បច្ចយាតិ ឋបេត្វា តថារូបប្បច្ចយំ ។

១ ឱ. តេន ខោ បន សមយេន ភិក្ខូ ។ បទីបេសុ ជោតិកេសុ ជន្តាឃរេ កុក្កុច្ចាយន្តិ ។



[៦៦៦] សម័យនោះឯង ភិក្ខុទាំងឡាយមានសេចក្តីសង្ស័យក្នុងការអុជប្រទីបខ្លះ បង្កាត់ភ្លើងដុតកប្បាសជាដើមខ្លះ រោងភ្លើងខ្លះ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើមានហេតុយ៉ាងនោះ តថាគតអនុញ្ញាតឲ្យភិក្ខុបង្កាត់ភ្លើងខ្លួនឯង ឬប្រើគេឲ្យបង្កាត់បាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនមានជម្ងឺ មានចំណងនឹងកំដៅភ្លើង ហើយបង្កាត់ខ្លួនឯងក្តី ប្រើគេឲ្យបង្កាត់ក្តី នូវភ្លើង ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុ មានសភាពយ៉ាងនោះ ។

[៦៦៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិក ។ ភិក្ខុណាវៀរចាកភ្លើងហើយសប្បាយ ភិក្ខុនោះហៅថា ជាអ្នកមិនមានជម្ងឺ ។ ភិក្ខុណាវៀរចាកភ្លើង ហើយមិនសប្បាយ ភិក្ខុនោះហៅថា អ្នកមានជម្ងឺ ។ ពាក្យថា មានចំណងនឹងកំដៅភ្លើង គឺចង់កំដៅកាយ ។ ដែលហៅថា ភ្លើង គឺភ្លើងធម្មតានោះឯង ។ ពាក្យថា បង្កាត់ខ្លួនឯង គឺភិក្ខុបង្កាត់ខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើឲ្យគេបង្កាត់ គឺភិក្ខុបង្គាប់អ្នកដទៃ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់តែម្តង អ្នកទទួលបង្គាប់ទៅបង្កាត់ភ្លើងច្រើនដង (ភិក្ខុអ្នកបង្គាប់) ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ គឺលើកទុកចេញនូវហេតុមានសភាពយ៉ាងនោះ ។

[៤៤៦] អគិលានោ អគិលានសញ្ញី វិសិព្វនាបេក្ខោ ជោតឹ សមាទហតិ វា សមាទហាបេតិ វា អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ បាចិត្តិយស្ស ។ អគិលានោ វេមតិកោ វិសិព្វនាបេក្ខោ ជោតឹ សមាទហតិ វា សមាទហាបេតិ វា អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ បាចិត្តិយស្ស ។ អគិលានោ គិលានសញ្ញី វិសិព្វនាបេក្ខោ ជោតឹ សមាទហតិ វា សមាទហាបេតិ វា អញ្ញត្រ តថារូបប្បច្ចយា អាបត្តិ បាចិត្តិយស្ស ។ បដិលាតំ ឧក្ខិបតិ អាបត្តិ ទុក្កដស្ស ។ គិលានោ អគិលានសញ្ញី អាបត្តិ ទុក្កដស្ស ។ គិលានោ វេមតិកោ អាបត្តិ ទុក្កដស្ស ។ គិលានោ គិលានសញ្ញី អនាបត្តិ ។

[៤៤៧] អនាបត្តិ គិលានស្ស អញ្ញេន កតំ វិសិព្វេតិ វីតច្ចិតង្គារំ វិសិព្វេតិ បទីបេ ជោតិកេ ជន្តាឃរេ តថារូបប្បច្ចយា អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ជោតិសិក្ខាបទំ និដ្ឋិតំ ។



[៤៤៦] ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមិនមានជម្ងឺ មានបំណងចង់កំដៅភ្លើង ហើយបង្កាត់ភ្លើងឯងក្តី ប្រើអ្នកដទៃឲ្យបង្កាត់ក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។ ខ្លួនមិនមានជម្ងឺ ភិក្ខុមានសេចក្តីសង្ស័យ មានបំណងចង់កំដៅភ្លើង ហើយបង្កាត់ភ្លើងខ្លួនឯងក្តី ប្រើឲ្យអ្នកដទៃបង្កាត់ក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។ ខ្លួនមិនមានជម្ងឺ ភិក្ខុសំគាល់ថាមានជម្ងឺ មានបំណងចង់កំដៅភ្លើង ហើយបង្កាត់ភ្លើងខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យបង្កាត់ក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានហេតុមានសភាពយ៉ាងនោះ ។ ភិក្ខុចាប់អង្កត់ភ្លើងលើកឡើង ត្រូវអាបត្តិទុក្កដ ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថាមិនមានជម្ងឺ ត្រូវអាបត្តិទុក្កដ ។ ខ្លួនមានជម្ងឺ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ខ្លួនមានជម្ងឺ ភិក្ខុសំគាល់ថាមានជម្ងឺ មិនត្រូវអាបត្តិឡើយ ។

[៤៤៧] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមានជម្ងឺ១ ភិក្ខុកំដៅភ្លើងដែលអ្នកដទៃបង្កាត់១ ភិក្ខុកំដៅរងើកភ្លើងដែលគ្មានអណ្តាត១ ភិក្ខុមានហេតុមានសភាពយ៉ាងនោះគឺអុជប្រទីបក្តី បង្កាត់ភ្លើង (ដើម្បីផុតឲ្យត្រជាក់ដើម) ក្តី បង្កាត់ភ្លើងក្នុងរោងភ្លើងក្តី ១ ភិក្ខុមានសេចក្តីអន្តរាយ(*)១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១ ។

សិក្ខាបទទី ៦ ចប់ ។

---

* ភិក្ខុគង់នឹក ដោយ ឬម្រឹគសាហាវបៀតបៀនដាំងដើម ហៅថា មានសេចក្តីអន្តរាយ ។

## សត្តមសិក្ខាបទំ

[៦៦៨] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភិក្ខូ តបោទេ ន្ហាយន្តិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ សីសំ ន្ហាយិស្សាមីតិ តបោទំ គន្ត្វា យាវ អយ្យា ន្ហាយន្តីតិ ឯកមន្តំ បដិមានេសិ ។ ភិក្ខូ យាវ សមន្ធការា ន្ហាយឹសុ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ វិកាលេ សីសំ ន្ហាយិត្វា នគរទ្វារេ ថក្កិតេ ពហិនគរេ វសិត្វា កាលស្សេវ អសម្ភិន្នេន វិលេបនេន យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ រាជានំ មាគធំ សេនិយំ ពិម្ពិសារំ ភគវា ឯតទវោច កិស្ស ត្វំ មហារាជ កាលស្សេវ អាគតោ អសម្ភិន្នេន វិលេបនេនាតិ ។ អថខោ រាជា

## សិក្ខាបទទី ៧

[៦៦៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ សម័យនោះឯង ពួកភិក្ខុនាំគ្នាទៅស្រង់ទឹកងូតក្នុងកំពង់ទឹកឈ្មោះតបោទ ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ ទ្រង់យាងទៅកាន់កំពង់ទឹកឈ្មោះតបោទ ដោយតាំងព្រះហឫទ័យថា នឹងស្រង់ជម្រះព្រះសិរ្ស ហើយក៏ទ្រង់ប្រថាប់ចាំ ក្នុងទីដ៏សមគួរ ដោយតាំងព្រះហឫទ័យថា ចាំលោកម្ចាស់ទាំងឡាយស្រង់ទឹករួចសិន ។ ភិក្ខុទាំងឡាយក៏ស្រង់ទឹកទាល់ព្រលប់ងងឹត ។ គ្រានោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ ស្រង់ជម្រះព្រះសិរ្សក្នុងវេលាវិកាល ពួកជនបិទទ្វារនគរ (ហួស) ទៅ ស្ដេចក៏ប្រថាប់នៅក្រៅនគរ លុះដល់វេលាព្រឹកឡើង ស្ដេចមានគ្រឿងលាបព្រះអង្គមិនទាន់បាត់សំអាត ហើយទ្រង់ព្រះដំណើរទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅហើយក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅក្នុងទីដ៏សមគួរ ។ លុះព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ គង់ក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា បពិត្រមហារាជ ហេតុអ្វីបានជាព្រះអង្គមានគ្រឿងលាបមិនទាន់បាត់សំអាត ហើយស្ដេចមកក្នុងវេលាព្រឹក (យ៉ាងនេះ) ។ គ្រានោះ ព្រះបាទ

មាគធោ សេនិយោ ពិម្ពិសារោ ភគវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភគវា រាជានំ មាគធំ សេនិយំ ពិម្ពិសារំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា មាគធោ សេនិយោ ពិម្ពិសារោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ភិក្ខូ រាជានំបិ បស្សិត្វា ន មត្តំ ជានិត្វា ន្ហាយន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា រាជានំបិ បស្សិត្វា ន មត្តំ ជានិត្វា ន្ហាយិស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន



ពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ ក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយក្នុងវេលានោះ ដោយធម្មីកថា ។ លំដាប់នោះ ព្រះបាទពិម្ពិសារសេនិយរាជ ជាឥស្សរៈក្នុងដែនមគធៈ លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យកព្រម ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ទ្រង់ក្រោកពីអាសនៈ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រោះរឿងនេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ត្រាស់សួរបញ្ជាក់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកភិក្ខុបានឃើញស្ដេចហើយ ងូតទឹកមិនដឹងប្រមាណកាល ពិតមែនឬ ។ ពួកភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះ បានឃើញស្ដេចហើយ មិនគួរនឹងងូតទឹកមិនដឹងប្រមាណកាលសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ

ភិក្ខុ ឱរេនទ្ធមាសំ(១) ន្ហាយេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៦៦៤] តេន ខោ បន សមយេន ភិក្ខូ ឧណ្ហសមយេ បរិឡាហសមយេ កុក្កុច្ចាយន្តា ន ន្ហាយន្តិ សេទគតេន គត្តេន សយន្តិ ។ ចីវរំបិ សេនាសនំបិ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ ឧណ្ហសមយេ បរិឡាហសមយេ ឱរេនទ្ធមាសំ ន្ហាយិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឱរេនទ្ធមាសំ ន្ហាយេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ទិយឌ្ឍោ មាសោ សេសោ គិម្ហានន្តិ វស្សានស្ស បឋមោ មាសោ ឥច្ចេតេ អឌ្ឍតេយ្យមាសា ឧណ្ហសមយោ បរិឡាហសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

១ ឱរេនទ្ធមាសន្តិបិ បាឋោ ។



មិនទាន់ដល់កណ្ដាលខែនៅ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ ។

[៦៦៤] សម័យនោះឯង ភិក្ខុទាំងឡាយសង្ស័យ ក្នុងសម័យក្ដៅ ក្នុងសម័យស្អុះស្អាប់ ក៏មិនហ៊ានងូតទឹកឡើយ មានខ្លួនប្រឡាក់ដោយញើសក្អួល ហើយក៏ដេកលក់ទៅ ។ ចីវរក្ដី សេនាសនៈក្ដី ក៏ប្រឡាក់ប្រឡូស (ដោយហេតុនោះ) ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យក្ដៅ សម័យស្អុះស្អាប់ ទុកជាមិនទាន់ដល់កន្លះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កណ្ដាលខែនៅ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្លះជាសេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមទាំងនេះត្រូវជា ២ ខែកន្លះ ហៅថាសម័យក្ដៅ(១) សម័យស្អុះស្អាប់(២) នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ ។

១-២ មួយខែកន្លះខាងចុងគិម្ហរដូវ គឺតាំងពី ១ រោចខែជេស្ឋ ទៅដល់ ១៥ កើតខែអាសាឍ្ហ នេះជាវេលានៃសម័យក្ដៅ ។ ឯមួយខែខាងដើមនៃវស្សានរដូវ គឺតាំងពី ១ រោចខែអាសាឍ្ហ ទៅដល់ ១៥ កើតខែស្រាពណ៍ នេះជាវេលានៃសម័យស្អុះស្អាប់ ។

[៦៣០] តេន ខោ បន សមយេន ភិក្ខូ គិលានា ហោន្តិ ។ គិលានបុច្ឆកា ភិក្ខូ គិលានេ ភិក្ខូ ឯតទវោចុំ កច្ចាវុសោ ខមនីយំ កច្ចិ យាបនីយន្តិ ។ បុព្វេ មយំ អាវុសោ ឱរេនឌ្ឍមាសំ នហាយាម តេន នោ ផាសុ ហោតិ ឥទានិ បន ភគវតា បដិក្ខិត្តន្តិ កុក្កុច្ចាយន្តា ន នហាយាម តេន នោ ន ផាសុ ហោតីតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា ឱរេនឌ្ឍមាសំ នហាយិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ នហាយេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ទិយឌ្ឍោ មាសោ សេសោ គិម្ហានន្តិ វស្សានស្ស បឋមោ មាសោ ឥច្ចេតេ អឌ្ឍតេយ្យមាសា ឧណ្ហសមយោ





[៦៣០] សម័យនោះឯង ភិក្ខុមានជម្ងឺជាច្រើនអង្គ ។ ឯពួកភិក្ខុជាអ្នកសួរជម្ងឺបាននិយាយពាក្យនេះនឹងភិក្ខុដែលមានជម្ងឺថា ម្នាលអាវុសោ អ្នកទាំងឡាយល្មមអត់ធន់បានឬទេ ល្មមញុំាងឥរិយាបថឲ្យប្រព្រឹត្តទៅបានឬទេ ។ ពួកភិក្ខុមានជម្ងឺប្រាប់ថា ម្នាលអាវុសោ កាលដើមយើងទាំងឡាយមិនទាន់ដល់កណ្តាលកន្លះខែ ក៏តែងតែងូតទឹក ព្រោះហេតុនោះបានជាពួកយើងមានសេចក្តីសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាមហើយ ហេតុនេះយើងទាំងឡាយមានសេចក្តីសង្ស័យមិនហ៊ានងូតទឹកឡើយ បានជាយើងមិនបានសេចក្តីសប្បាយដោយហេតុនោះឯង ។ ទើបភិក្ខុទាំងឡាយនាំសេចក្តីនុ៎ះក្រាបទូលចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានជម្ងឺ ទុកជាមិនទាន់ដល់កណ្តាលកន្លះខែ តថាគតអនុញ្ញាតឲ្យងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កណ្តាលកន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ មួយខែខាងដើមនៃវស្សានរដូវ រួមទាំងនេះត្រូវជា ២ ខែកន្លះ ហៅថា សម័យក្តៅ

បរិឡាហសមយោ គិលានសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[២៣១] តេន ខោ បន សមយេន ភិក្ខូ នវកម្មំ ករោន្តា កុក្កុច្ចាយន្តា ន ន្ហាយន្តិ សេទគតេន គត្តេន សយន្តិ ។ ចីវរំបិ សេនាសនំបិ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ កម្មសមយេ ឱរេនឌ្ឍមាសំ ន្ហាយិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ ន្ហាយេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ទិយឌ្ឍោ មាសោ សេសោ គិម្ហានន្តិ វស្សានស្ស បឋមោ មាសោ ឥច្ចេតេ អឌ្ឍតេយ្យមាសា ឧណ្ហសមយោ បរិឡាហសមយោ គិលានសមយោ កម្មសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។



សម័យស្អុះស្អាប់ សម័យភិក្ខុមានជម្ងឺ នេះហៅថា សម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយ យ៉ាងនេះរួចហើយ ។

[២៣១] សម័យនោះឯង ភិក្ខុទាំងឡាយ ធ្វើនវកម្មៈ ហើយមានសេចក្ដីរង្កៀស (ខ្លាចក្រែងត្រូវទោស) មិនហ៊ានងូតទឹកឡើយ ហើយក៏សឹងដេកទាំងខ្លួនប្រឡាក់ ដោយញើសស្អុល ។ ចីវរក្ដី សេនាសនៈក្ដី ក៏សៅហ្មងទៅ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យធ្វើការងារ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ដោយមិនទាន់ដល់កំណត់កន្លះខែ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ មិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហខែ មួយខែខាងដើមនៃវស្សានខែ រួមទាំងនេះត្រូវជាពីរខែកន្លះ ហៅថា សម័យក្ដៅ សម័យស្អុះស្អាប់ សម័យភិក្ខុមានជម្ងឺ សម័យធ្វើការងារ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុយ៉ាងនេះហើយ ។

[៦៣៦] តេន ខោ បន សមយេន ភិក្ខូ អទ្ធានមគ្គំ គន្ត្វា កុក្កុច្ចាយន្តា ន ន្ហាយន្តិ សេទគតេន គត្តេន សយន្តិ ។ ចីវរម្បិ សេនាសនម្បិ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ អទ្ធានគមនសមយេ ឱរេនឌ្ឍមាសំ ន្ហាយិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ ន្ហាយេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ទិយឌ្ឍោ មាសោ សេសោ គិម្ហានន្តិ វស្សានស្ស បឋមោ មាសោ ឥច្ចេតេ អឌ្ឍតេយ្យមាសា ឧណ្ហសមយោ បរិឡាហសមយោ គិលានសមយោ កម្មសមយោ អទ្ធានគមនសមយោ អយំ តត្ថ សមយោតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៦៣៧] តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អជ្ឈោកាសេ ចីវរកម្មំ ករោន្តា សរជេន វាតេន ឱកិណ្ណា ហោន្តិ ។ ទេវោ ច ថោកំ ថោកំ ផុសិ ។



[៦៣៦] សម័យនោះឯង ភិក្ខុទាំងឡាយ ដើរផ្លូវឆ្ងាយ មានសេចក្តីរង្កៀស (ខ្លាចក្រែងត្រូវអាបត្តិ) ក៏មិនហ៊ានងូតទឹក ហើយក៏ដេកទាំងខ្លួនដែលសើមទៅដោយញើសស្អុល ។ ចីវរក្តី សេនាសនៈក្តី ក៏សៅហ្មងទៅ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យដើរផ្លូវឆ្ងាយ ទោះមិនទាន់ដល់កំណត់កន្លះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្លះជាសេស (ខាងចុង) នៃគិម្ហរដូវ នឹងមួយខែខាងដើមនៃវស្សានរដូវ រួមទាំងពីរនេះត្រូវជាពីរខែកន្លះ ហៅថា សម័យក្តៅ សម័យស្អុះស្អាប់ សម័យមានជម្ងឺ សម័យធ្វើការងារ សម័យដើរផ្លូវឆ្ងាយ នេះជាសម័យក្នុងសិក្ខាបទនោះ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តដល់ភិក្ខុទាំងឡាយយ៉ាងនេះរួចហើយ ។

[៦៣៧] សម័យនោះឯង ភិក្ខុជាច្រើនរូប ធ្វើចីវរកម្មក្នុងទីវាល ត្រូវខ្យល់បក់ជាយកាំងធូលីមក ទាំងភ្លៀងក៏ធ្លាក់ចុះមកព្រាបព្រិច ៗ ផង ។

ភិក្ខូ កុក្កុច្ចាយន្តា ន ន្ហាយន្តិ សេទគតេន គត្តេន សយន្តិ ។ ចីវរម្បិ សេនាសនម្បិ ទុស្សតិ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អនុជានាមិ ភិក្ខវេ វាតវុដ្ឋិសមយេ ឱរេនឌ្ឍមាសំ ន្ហាយិតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ ឱរេនឌ្ឍមាសំ ន្ហាយេយ្យ អញ្ញត្រ សមយា បាចិត្តិយំ ។ តត្ថាយំ សមយោ ទិយឌ្ឍោ មាសោ សេសោ គិម្ហានន្តិ វស្សានស្ស បឋមោ មាសោ ឥច្ចេតេ អឌ្ឍតេយ្យមាសា ឧណ្ហសមយោ បរិឡាហសមយោ គិលានសមយោ កម្មសមយោ អទ្ធានគមនសមយោ វាតវុដ្ឋិសមយោ អយំ តត្ថ សមយោតិ ។

[៦៣៤] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ឱរេនឌ្ឍមាសន្តិ ឩនកឌ្ឍមាសំ ។



ភិក្ខុទាំងឡាយមានសេចក្តីរង្កៀស (ខ្លាចក្រែងត្រូវទោស) ក៏មិនហ៊ានងូតទឹក ស៊ឹងដេកទាំងខ្លួនប្រឡាក់ប្រឡូស (ញើស) ។ ចីវរក្តី សេនាសនៈក្តី ក៏សៅហ្មងទៅ ។ ភិក្ខុទាំងឡាយក៏ក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យខ្យល់នឹងភ្លៀង ទុកជាមិនទាន់ដល់កំណត់កន្លះខែ តថាគតអនុញ្ញាតឲ្យភិក្ខុងូតទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនទាន់ដល់កំណត់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ ឯសម័យក្នុងសិក្ខាបទនោះ គឺមួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ នឹងមួយខែខាងដើមនៃវស្សានរដូវ រួមខែទាំងនេះត្រូវជាពីរខែកន្លះ ហៅថា សម័យក្តៅ សម័យស្អុះស្អាប់ សម័យមានជម្ងឺ(១) សម័យធ្វើការ(២) សម័យដើរផ្លូវឆ្ងាយ(៣) សម័យខ្យល់នឹងភ្លៀង(៤) នេះជាសម័យក្នុងសិក្ខាបទនោះ ។

(៦៣៤) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចក្នុងបឋមបារាជិក ។ ពាក្យថា មិនទាន់ដល់កំណត់កន្លះខែ គឺខ្វះកន្លះខែ ។

---

១-២-៣-៤ សម័យទាំង ៤ យ៉ាងនេះមិនចំពោះរដូវណា ថ្ងៃណាទេ ដែលមានកំណត់ពីរខែកន្លះនោះតែសម័យពីរយ៉ាងខាងដើម ។

ន្ហាយេយ្យាតិ ចុណ្ណេន វា មត្តិកាយ វា ន្ហាយតិ បយោគេ ទុក្កដំ ។ ន្ហានបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។ អញ្ញត្រ សមយាតិ ឋបេត្វា សមយំ ។ ឧណ្ហសមយោ នាម ទិយឌ្ឍោ មាសោ សេសោ គិម្ហានំ ។ បរិឡាហសមយោ នាម វស្សានស្ស បឋមោ មាសោ ។ ឥច្ចេតេ អឌ្ឍតេយ្យមាសា ឧណ្ហសមយោ បរិឡាហសមយោតិ ន្ហាយិតព្វំ ។ គិលានសមយោ នាម យស្ស វិនា ន្ហានេន ន ផាសុ ហោតិ ។ គិលានសមយោតិ ន្ហាយិតព្វំ ។ កម្មសមយោ នាម អន្តមសោ បរិវេណម្បិ សម្មដ្ឋំ ហោតិ ។ កម្មសមយោតិ ន្ហាយិតព្វំ ។ អទ្ធានគមនសមយោ នាម អឌ្ឍយោជនំ គច្ឆិស្សាមីតិ ន្ហាយិតព្វំ គច្ឆន្តេន ន្ហាយិតព្វំ គតេន ន្ហាយិតព្វំ ។ វាតវុដ្ឋិសមយោ នាម ភិក្ខូ សរជេន វាតេន ឱកិណ្ណា ហោន្តិ ទ្វេ វា តីណិ វា ឧទកផុសិតានិ កាយេ បតិតានិ ហោន្តិ ។ វាតវុដ្ឋិសមយោតិ ន្ហាយិតព្វំ ។



ពាក្យថា ងូតទឹក គឺភិក្ខុកំពុងងូតទឹកដោយម្សៅក្តី ដោយដីល្អិតក្តី ត្រូវអាបត្តិទុក្កដក្នុងខណៈប្រយោគ ។ លុះងូតរួចស្រេច ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានសម័យ គឺលើកលែងចំពោះសម័យដែលគួរ ។ មួយខែកន្លះដ៏សេស (ខាងចុង) នៃគិម្ហរដូវ ហៅថា សម័យក្តៅ ។ មួយខែខាងដើមនៃវស្សានរដូវ ហៅថា សម័យស្អុះស្អាប់ ។ រួមទាំងពីរនេះ ត្រូវជាពីរខែកន្លះ ហៅថា សម័យក្តៅ សម័យស្អុះស្អាប់ ភិក្ខុគិតថាដូច្នេះហើយ គប្បីងូតទឹកចុះ ។ ភិក្ខុណាវៀរចាកការងូតទឹកមានសេចក្តីមិនសប្បាយ ភិក្ខុនោះហៅថា មានសម័យមានជម្ងឺ ឬថា មានសម័យឈឺថ្កាត់ ។ ភិក្ខុគិតដូច្នេះថា មានសម័យឈឺថ្កាត់ហើយ គប្បីងូតទឹកចុះ ។ ការធ្វើដោយហោចទៅ សូម្បីតែបោសច្រាសបរិវេណ គឺហៅថា សម័យធ្វើការងារ ។ ភិក្ខុគិតដូច្នេះថា សម័យធ្វើការងារហើយ គប្បីងូតទឹកចុះ ។ ដែលហៅថា សម័យដើរផ្លូវឆ្ងាយ គឺភិក្ខុគិតថា អាត្មានឹងដើរផ្លូវប្រមាណកន្លះយោជន៍ ហើយគប្បីងូតទឹកបាន ភិក្ខុកំពុងដំណើរគប្បីងូតទឹកបាន ភិក្ខុដើរទៅហើយគប្បីងូតទឹកបាន ។ ដែលហៅថា សម័យខ្យល់និងភ្លៀង គឺពួកភិក្ខុត្រូវខ្យល់ប្រកបដោយធូលីហើយ មានដំណក់ទឹកពីរដំណក់ក្តី បីដំណក់ក្តី ធ្លាក់ត្រូវកាយ ។ ភិក្ខុដឹងថា មានសម័យខ្យល់និងភ្លៀង គប្បីងូតទឹកបាន ។

[២៣៥] ឩនកឌ្ឍមាសេ ឩនកសញ្ញី អញ្ញត្រ សមយា ន្ហាយតិ អាបត្តិ បាចិត្តិយស្ស ។ ឩនកឌ្ឍមាសេ វេមតិកោ អញ្ញត្រ សមយា ន្ហាយតិ អាបត្តិ បាចិត្តិយស្ស ។ ឩនកឌ្ឍមាសេ អតិរេកសញ្ញី អញ្ញត្រ សមយា ន្ហាយតិ អាបត្តិ បាចិត្តិយស្ស ។ អតិរេកឌ្ឍមាសេ ឩនកសញ្ញី អាបត្តិ ទុក្កដស្ស ។ អតិរេកឌ្ឍមាសេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អតិរេកឌ្ឍមាសេ អតិរេកសញ្ញី អនាបត្តិ ។

[២៣៦] អនាបត្តិ សមយេ អឌ្ឍមាសំ ន្ហាយតិ អតិរេកឌ្ឍមាសំ ន្ហាយតិ(*) បារំ គច្ឆន្តោ ន្ហាយតិ សព្វបច្ចន្តិមេសុ ជនបទេសុ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។

* [illegible] ន្ហាយតិ បារំ គច្ឆន្តោ [illegible] ។



[២៣៥] មិនទាន់ដល់កន្លះខែ ភិក្ខុសំគាល់ថា មិនទាន់ដល់កន្លះខែ ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មិនទាន់ដល់កន្លះខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ មិនទាន់ដល់កន្លះខែ ភិក្ខុសំគាល់ថា លើស ហើយងូតទឹក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានសម័យ ។ កាលលើសជាងកន្លះខែ ភិក្ខុសំគាល់ថាខ្វះវិញ ត្រូវអាបត្តិទុក្កដ ។ កាលលើសជាងកន្លះខែ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលលើសជាងកន្លះខែ ភិក្ខុសំគាល់ថា លើសមែន មិនត្រូវអាបត្តិឡើយ ។

[២៣៦] ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមានសម័យ ១ កន្លះខែភិក្ខុងូតទឹកម្តង ១ លើសជាងកន្លះខែភិក្ខុងូតទឹក ១ ភិក្ខុឆ្លងទៅត្រើយម្ខាងហើយងូត ១ ភិក្ខុនៅក្នុងជនបទក្នុងដែនបច្ចន្តទាំងអស់ ១ ភិក្ខុមានសេចក្តីអន្តរាយ(១) ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៧ ចប់ ។

១ គឺភិក្ខុមានសង្ឃាដិ[illegible] ហើយមុជទៅក្នុងទឹក ដើម្បីរួចអំពីសេចក្តីអន្តរាយនោះ ហៅថា មានសេចក្តីអន្តរាយ ក្នុងសិក្ខាបទនេះ ។

## អដ្ឋមសិក្ខាបទំ

[៦៣៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ ច ភិក្ខុនិយោ ច សាកេតា សាវត្ថឹ អទ្ធានមគ្គប្បដិបន្នា ហោន្តិ ។ អន្តរាមគ្គេ ចោរា និក្ខមិត្វា តេ អច្ឆិន្ទឹសុ ។ សាវត្ថិយា រាជភដា និក្ខមិត្វា តេ ចោរេ សភណ្ឌេ គហេត្វា ភិក្ខូនំ សន្តិកេ ទូតំ បាហេសុំ អាគច្ឆន្តុ ភទ្ទន្តា សកំ សកំ ចីវរំ សញ្ជានិត្វា គណ្ហន្តូតិ ។ ភិក្ខូ ចីវរំ ន សញ្ជានន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយន្តិ វិបាចេន្តិ កថំ ហិ នាម ភទ្ទន្តា អត្តនោ អត្តនោ ចីវរំ ន សញ្ជានិស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ

## សិក្ខាបទទី ៨

[៦៣៧] សម័យនោះ ព្រះពុទ្ធមានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកភិក្ខុនិង ពួកភិក្ខុនីទាំងឡាយ ជាច្រើនរូបនាំគ្នាដើរផ្លូវឆ្ងាយ ពីក្រុងសាកេតទៅក្រុងសាវត្ថី ។ លុះដល់ពាក់កណ្តាលផ្លូវ មានពួកចោរចេញមកប្លន់ពួកភិក្ខុនិងពួកភិក្ខុនីទាំងនោះ ។ រាជភដទាំងឡាយនាំគ្នាចេញពីក្រុងសាវត្ថី មកចាប់ចោរទាំងនោះបានព្រមទាំងរបស់ ហើយប្រើបម្រើទៅកាន់សំណាក់ពួកភិក្ខុថា លោកម្ចាស់ទាំងឡាយចូរនិមន្តមកយកចីវររបស់ខ្លួន ៗ តាមស្គាល់ចុះ ។ ភិក្ខុទាំងឡាយក៏មិនស្គាល់ចីវរ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា លោកម្ចាស់ទាំងឡាយមិនគួរនឹងមិនស្គាល់ចីវររបស់ខ្លួន ៗ សោះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ទើបភិក្ខុទាំងនោះក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះរឿងនេះ ដំណើរនេះ

ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូនំ តទនុច្ឆវិកំ តទនុលោមិកំ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញបេស្សាមិ ទស អត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ សង្ឃផាសុតាយ ។ បេ ។ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ នវំ បន ភិក្ខុនា ចីវរលាភេន តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ អាទាតព្វំ នីលំ វា កទ្ទមំ វា កាឡសាមំ វា ។ អនាទា ចេ ភិក្ខុ តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ នវំ ចីវរំ បរិភុញ្ជេយ្យ បាចិត្តិយន្តិ ។

(២៣៨) នវំ នាម អកតកប្បំ វុច្ចតិ ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ ។ តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ អាទាតព្វន្តិ អន្តមសោ កុសគ្គេនបិ អាទាតព្វំ ។ នីលំ នាម ទ្វេ នីលានិ



ទើបព្រះដ៏មានព្រះភាគទ្រង់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់ធ្វើធម្មីកថាដ៏សមគួរ សមគួរដល់រឿងនោះ ៗ ដល់ភិក្ខុទាំងឡាយ ហើយទ្រង់ត្រាស់ហៅពួកភិក្ខុដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ តថាគតនឹងបញ្ញត្តសិក្ខាបទដល់ភិក្ខុទាំងឡាយ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បីល្អដល់សង្ឃ ១ ដើម្បីសប្បាយដល់សង្ឃ ១ ។ បេ ។ ដើម្បីឋិតនៅនៃព្រះសទ្ធម្ម ១ ដើម្បីអនុគ្រោះព្រះវិន័យ ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុបានចីវរថ្មីមកហើយ គប្បីកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង គឺពណ៌ខៀវក្ដី ពណ៌ភក់ក្ដី ពណ៌ខ្មៅចាំក្ដី វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ បើភិក្ខុមិនកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ ។

(២៣៨) ដែលហៅថា ថ្មី គឺចីវរដែលមិនទាន់បានធ្វើកប្ប ។ ដែលហៅថា ចីវរ គឺបណ្ដាចីវរទាំង ៦ ចីវរណាមួយ ។ ត្រង់ពាក្យថា គប្បីកាន់យកនូវវត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង វត្ថុសម្រាប់ធ្វើឲ្យខូចពណ៌ណាមួយ សេចក្ដីថា ភិក្ខុត្រូវធ្វើកប្បពិន្ទុយ៉ាងហោចណាស់យ៉ាងតូចបំផុតត្រឹមចុងនៃស្បូវ ។ ដែលហៅថា ពណ៌ខៀវ នោះមានពណ៌ខៀវពីរយ៉ាង

កំសនីលំ បលាសនីលំ ។ កទ្ទមោ នាម ឱទកោ វុច្ចតិ ។ កាឡសាមំ នាម យំកិញ្ចិ កាឡកំ(១) ។ អនាទា ចេ ភិក្ខុ តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណន្តិ អន្តមសោ កុសគ្គេនបិ អនាទិយិត្វា តិណ្ណំ ទុព្វណ្ណករណានំ អញ្ញតរំ ទុព្វណ្ណករណំ នវំ ចីវរំ បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។

[៦៣៩] អនាទិន្នេ អនាទិន្នសញ្ញី បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អនាទិន្នេ វេមតិកោ បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អនាទិន្នេ អាទិន្នសញ្ញី បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អាទិន្នេ អនាទិន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អាទិន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អាទិន្នេ អាទិន្នសញ្ញី អនាបត្តិ ។

១ ម. កាឡសាមកំ ។





ពុខដល់ពណ៌ខៀវដូចសំរឹទ្ធ ១ ពណ៌ខៀវដូចស្លឹកឈើ ១ ។ ដែលហៅថា ពណ៌ភក់ គឺសំដៅយកភក់ដែលនៅក្នុងទឹក ។ ដែលហៅថា ពណ៌ខ្មៅ គឺវត្ថុមានពណ៌ខ្មៅណាមួយ ។ ពាក្យថា បើភិក្ខុមិនកាន់យកនូវគ្រឿងសំរាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង គ្រឿងសំរាប់ធ្វើឲ្យខូចពណ៌ណាមួយ សេចក្តីថា ភិក្ខុមិនធ្វើកប្បពិន្ទុ បណ្តាគ្រឿងសំរាប់ធ្វើឲ្យខូចពណ៌ ៣ យ៉ាង ដោយគ្រឿងសំរាប់ធ្វើឲ្យខូចពណ៌ណាមួយ ដោយកំណត់ប្រមាណយ៉ាងតូចបំផុតត្រឹមចុងស្បូវ ហើយប្រើប្រាស់ចីវរថ្មី ត្រូវអាបត្តិបាចិត្តិយ ។

[៦៣៩] ចីវរដែលភិក្ខុមិនធ្វើកប្បពិន្ទុ ភិក្ខុសំគាល់ថាមិនទាន់ធ្វើកប្បពិន្ទុ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរមិនទាន់ធ្វើកប្បពិន្ទុ ភិក្ខុមានសេចក្តីសង្ស័យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរមិនទាន់ធ្វើកប្បពិន្ទុ ភិក្ខុសំគាល់ថាធ្វើកប្បពិន្ទុហើយ ។ ប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុសំគាល់ថាមិនទាន់បានធ្វើកប្បពិន្ទុ ត្រូវអាបត្តិទុក្កដ ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរបានធ្វើកប្បពិន្ទុហើយ ភិក្ខុសំគាល់ថាបានធ្វើកប្បពិន្ទុហើយ មិនត្រូវអាបត្តិឡើយ ។

[៦៦០] អនាបត្តិ អាទិយិត្វា បរិភុញ្ជតិ កប្បោ នដ្ឋោ ហោតិ កប្បកតោកាសោ ជិណ្ណោ ហោតិ កប្បកតេន អកប្បកតំ សំសិព្វិតំ ហោតិ អគ្គឡេ អនុវាតេ បរិភណ្ឌេ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



[៦៦០] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុបានធ្វើកប្បពិន្ទុ ហើយប្រើប្រាស់ ១ កប្បពិន្ទុខូចបាត់ទៅ ១ កន្លែងដែលធ្វើកប្បពិន្ទុគ្រាំគ្រាទៅ ១ ភិក្ខុដេរចីវរដែលមិនបានធ្វើកប្បពិន្ទុភ្ជាប់ជាមួយនឹងចីវរដែលបានធ្វើកប្បពិន្ទុហើយ ១ ចីវរដែលប៉ះដោយចំណាះថ្មី ១ ចីវរដែលដាក់ផ្នត់ថ្មី ១ ចីវរចាស់ប្រក់ថែមថ្មី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់ ។

## នវមសិក្ខាបទំ

(៦៦០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ ភាតុនោ សទ្ធិវិហារិកស្ស ភិក្ខុនោ សាមំ ចីវរំ វិកប្បេត្វា អបច្ចុទ្ធារណំ បរិភុញ្ជតិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ អយំ អាវុសោ អាយស្មា ឧបនន្ទោ សក្យបុត្តោ មយ្ហំ សាមំ ចីវរំ វិកប្បេត្វា អបច្ចុទ្ធារណំ បរិភុញ្ជតីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថញ្ហិ នាម អាយស្មា ឧបនន្ទោ សក្យបុត្តោ ភិក្ខុស្ស សាមំ ចីវរំ វិកប្បេត្វា អបច្ចុទ្ធារណំ បរិភុញ្ជិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ឧបនន្ទ ភិក្ខុស្ស សាមំ ចីវរំ វិកប្បេត្វា អបច្ចុទ្ធារណំ បរិភុញ្ជសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ

## សិក្ខាបទទី៩

(៦៦០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុបានវិកប្បចីវររបស់ខ្លួនដោយខ្លួនឯង រួចផ្ញើនឹងភិក្ខុជាសទ្ធិវិហារិករបស់ព្រះថេរៈជាបងប្អូន ហើយមិនបានឲ្យដកវិកប្បចេញ ក៏ចេះតែប្រើប្រាស់ទៅ ។ លំដាប់នោះ ភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោ ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុនេះ បានវិកប្បចីវររបស់ខ្លួនដោយខ្លួនឯងផ្ញើនឹងខ្ញុំ ហើយមិនឲ្យដកវិកប្ប (ចាំមុន) ហើយចេះតែប្រើប្រាស់ទៅ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្ទុះបង្អាប់ថា ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុមិនគួរនឹងវិកប្បចីវររបស់ខ្លួនដោយខ្លួនឯង ផ្ញើនឹងភិក្ខុដទៃ ហើយមិនបានឲ្យដកវិកប្បចេញសិន ចេះតែប្រើប្រាស់ទៅសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា នែឧបនន្ទ ឮថា អ្នកឯងបានវិកប្បចីវររបស់ខ្លួនដោយខ្លួនឯងនឹងភិក្ខុដទៃ ហើយមិនឲ្យដកវិកប្បចេញសិន ចេះតែប្រើប្រាស់ទៅ ពិតមែនឬ ។ ឧបនន្ទដ៏មានអាយុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា

នាម ត្វំ មោឃបុរិស ភិក្ខុស្ស សាមំ ចីវរំ វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជិស្សសិ ។ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស វា ភិក្ខុនិយា វា សិក្ខមានាយ វា សាមណេរស្ស វា សាមណេរិយា វា សាមំ ចីវរំ វិកប្បេត្វា អប្បច្ចុទ្ធារកំ បរិភុញ្ជេយ្យ បាចិត្តិយន្តិ ។

(៤៤៤) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ សិក្ខមានា នាម ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខា ។ សាមណេរោ នាម ទសសិក្ខាបទិកោ ។ សាមណេរី នាម ទសសិក្ខាបទិកា ។ សាមន្តិ សយំ វិកប្បេត្វា ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ



នែមោឃបុរស អ្នកឯងមិនគួរនឹងវិកប្បចីវររបស់ខ្លួនដោយខ្លួនឯងនឹងភិក្ខុដទៃគ្នា ហើយប្រើប្រាស់ចីវរ ដែលមិនបានឲ្យគេដកវិកប្បចេញសិនទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបានវិកប្បចីវរដោយខ្លួនឯងចំពោះភិក្ខុដទៃគ្នាក្តី ភិក្ខុនីក្តី សិក្ខមានាក្តី សាមណេរក្តី សាមណេរីក្តី ហើយប្រើប្រាស់ចីវរដែលមិនទាន់ឲ្យគេដកវិកប្បចេញសិន ត្រូវអាបត្តិបាចិត្តិយ ។

[៤៤៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ ។ ពាក្យថា ភិក្ខុដទៃគ្នា គឺភិក្ខុឯទៀត ។ ដែលហៅថា ភិក្ខុនី គឺភិក្ខុនីដែលបានឧបសម្បទាក្នុងសង្ឃទាំងពីរពួក ។ ដែលហៅថា សិក្ខមានា គឺស្រីដែលបានសិក្សាសិក្ខាក្នុងធម៌ទាំង ៦ គ្រប់ពីរឆ្នាំហើយ ។ ដែលហៅថា សាមណេរ គឺកុលបុត្រ (ដែលបានសម្រេចបព្វជ្ជាកម្មហើយ) ទ្រទ្រង់នូវសិក្ខាបទទាំង ១០ ។ ដែលហៅថា សាមណេរី គឺស្រី (ដែលបានសម្រេចបព្វជ្ជាកម្មហើយ) ទ្រទ្រង់នូវសិក្ខាបទទាំង ១០ ។ ពាក្យថា ដោយខ្លួនឯង គឺវិកប្បដោយខ្លួនឯង ។ ដែលហៅថា ចីវរ គឺបណ្តាចីវរទាំង ៦ ចីវរណាមួយ យ៉ាងតូចបំផុតល្មមសម្រេច

បច្ឆិមំ ។ វិកប្បនំ នាម ទ្វេ វិកប្បនា សម្មុខាវិកប្បនា ច បរម្មុខាវិកប្បនា ច ។ សម្មុខាវិកប្បនា នាម ឥមំ ចីវរំ តុយ្ហំ វិកប្បេមិ ឥត្ថន្នាមស្ស វាតិ ។ បរម្មុខាវិកប្បនា នាម ឥមំ ចីវរំ វិកប្បនត្ថាយ តុយ្ហំ ទម្មីតិ ។ តេន វត្តព្វោ កោ តេ មិត្តោ វា សន្ទិដ្ឋោ វាតិ ។ ឥត្ថន្នាមោ ច ឥត្ថន្នាមោ ចាតិ ។ តេន វត្តព្វោ អហំ តេសំ ទម្មិ តេសំ សន្តកំ បរិភុញ្ជ វា វិស្សជ្ជេហិ វា យថាបច្ចយំ វា ករោហីតិ ។ អបច្ចុទ្ធារកំ នាម តស្ស វា អទិន្នំ តស្ស វា អវិស្សសន្តោ បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។

(៤៤៣) អបច្ចុទ្ធារកេ អបច្ចុទ្ធារកសញ្ញី បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អបច្ចុទ្ធារកេ វេមតិកោ បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អបច្ចុទ្ធារកេ



ក៏ចូលវិកប្បបាន ។ ដែលហៅថា វិកប្ប គឺវិកប្បមានពីរយ៉ាងគឺ បាន ផលវិកប្បចំពោះមុខ ១ វិកប្បកំបាំងមុខ ១ ។ ដែលហៅថា វិកប្បចំពោះមុខ គឺភិក្ខុកំណត់ដោយពាក្យថា ខ្ញុំវិកប្បចីវរនេះចំពោះលោក ឬចំពោះភិក្ខុឈ្មោះនេះ ។ ដែលហៅថា វិកប្បកំបាំងមុខ គឺភិក្ខុកំណត់ដោយពាក្យថា ខ្ញុំឲ្យចីវរនេះដល់លោក ដើម្បីវិកប្បទុក ។ ភិក្ខុនោះត្រូវសួរភិក្ខុជាម្ចាស់ចីវរថា លោកណាជាមិត្តរបស់លោក ឬលោកស្គាល់លោកណា ។ ភិក្ខុម្ចាស់ចីវរត្រូវប្រាប់ថា ភិក្ខុឈ្មោះនេះផង ភិក្ខុឈ្មោះនេះផង ។ ភិក្ខុអ្នកទទួលវិកប្បនោះត្រូវនិយាយនឹងភិក្ខុម្ចាស់ចីវរថា ខ្ញុំឲ្យចីវរដល់ភិក្ខុទាំងនោះ លោកចូរប្រើប្រាស់ក្តី ឬលោកចូរលះបង់ក្តី លោកចូរធ្វើតាមសមគួរដល់បច្ច័យក្តី នូវចីវររបស់ភិក្ខុទាំងនោះចុះ ។ ដែលហៅថា មិនបានឲ្យគេដកវិកប្ប គឺភិក្ខុជាម្ចាស់ចីវរប្រើប្រាស់ចីវរដែលភិក្ខុអ្នកទទួលវិកប្បនោះមិនបានប្រគល់ឲ្យក្តី មិនស្និទ្ធស្នាលនឹងភិក្ខុជាអ្នកទទួលវិកប្បនោះ ហើយប្រើប្រាស់ក្តី ត្រូវអាបត្តិបាចិត្តិយ ។

(៤៤៣) ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថាមិនបានឲ្យគេដកវិកប្ប ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុមានសេចក្តីសង្ស័យ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដែលមិនបានឲ្យគេដកវិកប្ប ភិក្ខុសំគាល់ថា

បច្ចុទ្ធារកសញ្ញី បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ អធិដ្ឋេតិ វា វិស្សជ្ជេតិ វា អាបត្តិ ទុក្កដស្ស ។ បច្ចុទ្ធារកេ អប្បច្ចុទ្ធារកសញ្ញី អាបត្តិ ទុក្កដស្ស ។ បច្ចុទ្ធារកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បច្ចុទ្ធារកេ បច្ចុទ្ធារកសញ្ញី អនាបត្តិ ។

(៤៤៦) អនាបត្តិ សោ ច ទេតិ តស្ស ច វិស្សាសេន្តោ បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។



បានឲ្យគេដកហើយ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុអធិដ្ឋានក្ដី លះបង់ចោលក្ដី ត្រូវអាបត្តិទុក្កដ ។ ចីវរដែលបានឲ្យគេដកហើយ ភិក្ខុសំគាល់ថាមិនបានឲ្យគេដកហើយវិញ ត្រូវអាបត្តិទុក្កដ ។ ចីវរដែលបានឲ្យគេដកហើយ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ចីវរដែលបានឲ្យគេដកហើយ ភិក្ខុសំគាល់ថាបានឲ្យគេដកហើយ មិនត្រូវអាបត្តិទេ ។

(៤៤៦) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុប្រើប្រាស់ចីវរដែលភិក្ខុអ្នកទទួលវិកប្បនោះឲ្យក្ដី ភិក្ខុប្រើប្រាស់ដោយស្និទ្ធស្នាលនឹងភិក្ខុជាអ្នកទទួលវិកប្បនោះក្ដី ១ ភិក្ខុឆ្កួត ១ ភិក្ខុជាដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៩ ចប់ ។

# ទសមសិក្ខាបទំ

[៤៤៥] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សត្តរសវគ្គិយា ភិក្ខូ អសន្និធិការកបរិក្ខារា ហោន្តិ ។ ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយានំ ភិក្ខូនំ បត្តម្បិ ចីវរម្បិ អបនិធេន្តិ ។ សត្តរសវគ្គិយា ភិក្ខូ ឆព្វគ្គិយេ ភិក្ខូ ឯតទវោចុំ ទេថាវុសោ អម្ហាកំ បត្តម្បិ ចីវរម្បីតិ ។ ឆព្វគ្គិយា ភិក្ខូ ហសន្តិ ។ តេ រោទន្តិ ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ រោទថាតិ ។ ឥមេ អាវុសោ ឆព្វគ្គិយា ភិក្ខូ អម្ហាកំ បត្តម្បិ ចីវរម្បិ អបនិធេន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ភិក្ខូនំ បត្តម្បិ ចីវរម្បិ អបនិធេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខូនំ បត្តម្បិ ចីវរម្បិ អបនិធេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខូនំ បត្តម្បិ ចីវរម្បិ

# សិក្ខាបទទី ១០

[៤៤៥] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកសត្តរសវគ្គិយភិក្ខុមិនបានទុកគ្រឿងបរិក្ខារដោយស្រួល ។ ពួកឆព្វគ្គិយភិក្ខុលាក់ទុកបាត្រ និងចីវរ របស់ពួកសត្តរសវគ្គិយភិក្ខុ ។ ពួកសត្តរសវគ្គិយភិក្ខុក៏និយាយពាក្យនេះនឹងពួកឆព្វគ្គិយភិក្ខុថា ម្នាលអាវុសោ អ្នកទាំងឡាយចូរឲ្យបាត្រ និងចីវរដល់យើង ។ ពួកឆព្វគ្គិយភិក្ខុក៏នាំគ្នាសើច ។ ពួកសត្តរសវគ្គិយភិក្ខុទាំងនោះក៏យំ ។ ភិក្ខុទាំងឡាយសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាអ្នកទាំងឡាយយំ ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះ លាក់ទុកនូវបាត្រ និងចីវរ របស់យើង ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា មិនសមបើពួកឆព្វគ្គិយភិក្ខុលាក់ទុកនូវបាត្រ និងចីវរ របស់ភិក្ខុទាំងឡាយសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយលាក់ទុកនូវបាត្រ និងចីវរ របស់ភិក្ខុទាំងឡាយ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ

អបនិធេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា
បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច
បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន
ភិក្ខុ ភិក្ខុស្ស បត្តំ វា ចីវរំ វា និសីទនំ វា សូចិឃរំ
វា កាយពន្ធនំ វា អបនិធេយ្យ វា អបនិធាបេយ្យ
វា អន្តមសោ ហស្សាបេក្ខោបិ(១) បាចិត្តិយន្តិ ។

(៤៤៦) យោ បនាតិ យោ យាទិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ
ភិក្ខូតិ ។ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ បត្តោ
នាម ទ្វេ បត្តា អយោបត្តោ មត្តិកាបត្តោ ។ ចីវរំ នាម
ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ ។
និសីទនំ នាម សទសំ វុច្ចតិ ។ សូចិឃរំ នាម
សសូចិកំ វា អសូចិកំ វា ។ កាយពន្ធនំ នាម ទ្វេ
កាយពន្ធនានិ បដ្ដិកំ សូករន្តកំ ។ អបនិធេយ្យាតិ

១ ម. ហាសាបេក្ខោបិ ។ ឱ. ហាសាបេក្ខោបិ ។





មិនសមប្បីបើអ្នកឯងទាំងឡាយនាំគ្នាមកលាក់ទុកនូវបាត្រខ្លះ ចីវរខ្លះ របស់ភិក្ខុទាំង
នោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលពួកអ្នកឯងធ្វើនេះ
មិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា មួយទៀតពួកជនដែល
ជ្រះថ្លាហើយ ក៏មិនរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ
អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ
លាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី
ប្រដាប់ម្ជុលក្តី វត្ថុពន្ធចង្កេះក្តី របស់ភិក្ខុដទៃ ដោយហោចទៅសូម្បីគ្រាន់
តែមានចំណង់នឹងសើចលេង ត្រូវអាបត្តិបាចិត្តិយ ។

(៤៤៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចបាននិទ្ទេសហើយ-
ក្នុងសិក្ខាបទ ។ ពាក្យថា ភិក្ខុដទៃ គឺភិក្ខុឯទៀត ។ ដែលហៅថា
បាត្រ គឺបាត្រមានពីរយ៉ាង បាត្រដែក១ បាត្រដី១ ។ ដែល
ហៅថា ចីវរ គឺបណ្តាចីវរទាំង៦ ចីវរណាមួយយ៉ាងតូចបំផុតល្មម
វិកប្បបាន ។ ដែលហៅថា និសីទនៈ សំដៅយកនិសីទនៈដែលមានជាយ ។
ដែលហៅថា ប្រដាប់ម្ជុល គឺប្រដាប់ម្ជុលដែលមានម្ជុលក្តី ឥតម្ជុលក្តី ។ ដែល
ហៅថា វត្ថុពន្ធចង្កេះ គឺវត្ថុពន្ធចង្កេះមានពីរយ៉ាង គឺក្រវាត់ឈ្មោះ
បដ្ដិកា (ចំបៀតសម្ពត់)១ វត្ថុពន្ធឈ្មោះសូករន្តកៈ (គឺវត្ថុពន្ធមានសណ្ឋាន
ដូចពោះវៀនជ្រូក)១ ។ ពាក្យថា លាក់ទុកឯង គឺភិក្ខុលាក់ទុក

សយំ អបនិធេតិ អាបត្តិ បាចិត្តិយស្ស ។ អបនិធាបេយ្យាតិ អញ្ញំ អាណាបេតិ អាបត្តិ បាចិត្តិយស្ស ។ សកឹ អាណត្តោ ពហុកម្បិ អបនិធេតិ អាបត្តិ បាចិត្តិយស្ស ។ អន្តមសោ ហសាបេក្ខោបីតិ កីឡាធិប្បាយោ ។

[៤៤៧] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី បត្តំ វា ចីវរំ វា និសីទនំ វា សូចិឃរំ វា កាយពន្ធនំ វា អបនិធេតិ វា អបនិធាបេតិ វា អន្តមសោ ហសាបេក្ខោបិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ បត្តំ វា ចីវរំ វា និសីទនំ វា សូចិឃរំ វា កាយពន្ធនំ វា អបនិធេតិ វា អបនិធាបេតិ វា អន្តមសោ ហសាបេក្ខោបិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី បត្តំ វា ចីវរំ វា និសីទនំ វា សូចិឃរំ វា កាយពន្ធនំ វា អបនិធេតិ វា អបនិធាបេតិ វា អន្តមសោ ហសាបេក្ខោបិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញំ បរិក្ខារំ អបនិធេតិ វា អបនិធាបេតិ វា អន្តមសោ ហសាបេក្ខោបិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នស្ស បត្តំ វា



ដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ប្រើគេឲ្យលាក់ គឺភិក្ខុបង្គាប់អ្នកដទៃ (ឲ្យលាក់ទុក) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់តែម្តង អ្នកទទួលបង្គាប់លាក់ទុកច្រើនដង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ដោយហោចទៅ សូម្បីត្រាន់តែមានបំណង ចំអកលេង គឺភិក្ខុមានសេចក្តីប្រាថ្នាចំអកលេង ។

[៤៤៧] ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី ដោយហោចទៅ សូម្បីត្រាន់តែមានបំណងចំអកលេង ក៏ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី ដោយហោចទៅ សូម្បីត្រាន់តែមានបំណងចំអកលេង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្នវិញ ហើយលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបាត្រក្តី ចីវរក្តី និសីទនៈក្តី បំពង់ម្ជុលក្តី វត្ថពន្ធចង្កេះក្តី ដោយហោចទៅ សូម្បីត្រាន់តែមានបំណងចំអកលេង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក នូវបរិក្ខារដទៃ ដោយហោចទៅ សូម្បីត្រាន់តែមានបំណងចំអកលេង ត្រូវអាបត្តិទុក្កដ ។ ភិក្ខុលាក់ទុកឯង ឬប្រើគេឲ្យលាក់ទុក

ចីវរំ វា អញ្ញំ វា បរិក្ខារំ អបនិធេតិ វា អបនិធាបេតិ វា អន្តមសោ ហសាបេក្ខោបិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[៦៦៨] អនាបត្តិ ន ហសាធិប្បាយោ ទុន្និក្ខិត្តំ បដិសាមេតិ ធម្មិំ កថំ កត្វា ទស្សាមីតិ បដិសាមេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

សុរាបានវគ្គោ ឆដ្ឋោ ។

តស្សុទ្ទានំ

សុរា អង្គុលិ ហាសោ ច[១]
អនាទរិយញ្ច ភឹសនា
ជោតិ ន្ហានំ ទុព្វណ្ណំ
សាមំ អបនិធេន ចាតិ ។

១ ឱ, ម, តោយញ្ច ។



ខ្លួនត្រូវ ចីវរក្តី បរិក្ខារដទៃក្តី របស់អនុបសម្បន្ន ដោយគិតនាំទៅសើច ត្រាំតែមានបំណងនឹងសើចលេង ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្នវិញ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[៦៦៨] ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុមិនប្រាថ្នានឹងសើចលេង ហើយទុកដាក់នូវបរិក្ខារដែលគេទុកដាក់មិនល្អ ១ ភិក្ខុទុកដាក់ដោយគិតថា អញនឹងធ្វើធម្មីកថាហើយនឹងឲ្យវិញ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១០ ចប់ ។

សុរាបានវគ្គ ទី ៦ ចប់ ។

ឧទ្ទាននៃសុរាបានវគ្គនោះ (មាន ១០ សិក្ខាបទ) គឺ

សុរាសិក្ខាបទ ១ អង្គុលិសិក្ខាបទ ១
ហសសិក្ខាបទ ១ អនាទរិយសិក្ខាបទ ១
ភឹសនសិក្ខាបទ ១ ជោតិសិក្ខាបទ ១
ន្ហានសិក្ខាបទ ១ ទុព្វណ្ណសិក្ខាបទ ១
សាមសិក្ខាបទ ១ អបនិធិសិក្ខាបទ ១ ។

## សប្បាណកវគ្គស្ស បឋមសិក្ខាបទំ

(៦៤៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧទាយី ឥស្សាសោ ហោតិ ។ កាកា ចស្ស អមនាបា ហោន្តិ ។ សោ កាកេ វិជ្ឈិត្វា សីសំ ឆិន្ទិត្វា សូលេ បដិបាដិយា ឋបេសិ ។ ភិក្ខូ ឯវមាហំសុ កេនិមេ អាវុសោ កាកា ជីវិតា វោរោបិតាតិ ។ មយា អាវុសោ អមនាបា មេ កាកាតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឧទាយី សញ្ចិច្ច បាណំ ជីវិតា វោរោបេស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ ឧទាយិ សញ្ចិច្ច បាណំ ជីវិតា វោរោបេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស សញ្ចិច្ច បាណំ ជីវិតា វោរោបេស្សសិ នេតំ មោឃបុរិស

## សប្បាណកវគ្គ សិក្ខាបទទី ១

(៦៤៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧទាយិ ដ៏មានអាយុ (ជាប់) ជាខាងបាញ់ធ្នូ ។ លោកនោះមិនពេញចិត្ត នឹងសត្វក្អែកទាំងឡាយ ។ ឧទាយិនោះក៏បាញ់សត្វក្អែកទាំងឡាយ កាត់ក្បាលហើយដោតលើឈើស្នក ដោយលំដាប់គ្នា ។ ភិក្ខុទាំងឡាយ សួរយ៉ាងនេះថា ម្នាលអាវុសោ លោកណាសម្លាប់សត្វក្អែកទាំងនេះ ។ ឧទាយិឆ្លើយថា ម្នាលអាវុសោ ខ្ញុំសម្លាប់ (ព្រោះ) សត្វក្អែកខ្ញុំមិនគួរជាទីពេញចិត្តសោះ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ឧទាយិដ៏មានអាយុ មិនគួរនឹងក្លែងផ្តាច់បង់សត្វចាកជីវិតសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលឧទាយិ ឮថា អ្នកឯងក្លែងផ្តាច់បង់សត្វចាកជីវិត ពិតមែនឬ ។ ឧទាយិក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងមិនគួរនឹងក្លែងផ្តាច់បង់សត្វចាកជីវិតទេ ម្នាលមោឃបុរស អំពើនេះមិនមែនជាទីជ្រះថ្លា

អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សញ្ចិច្ច បាណំ ជីវិតា វោរោបេយ្យ បាចិត្តិយន្តិ ។

(២៩០) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សញ្ចិច្ចាតិ ជានន្តោ សញ្ជានន្តោ ចេច្ច អភិវិតរិត្វា វីតិក្កមោ ។ បាណោ នាម តិរច្ឆានគតបាណោ វុច្ចតិ ។ ជីវិតា វោរោបេយ្យាតិ ជីវិតិន្ទ្រិយំ ឧបច្ឆិន្ទតិ ឧបរោធេតិ សន្តតឹ វិកោបេតិ អាបត្តិ បាចិត្តិយស្ស ។

(២៩១) បាណោ បាណសញ្ញី ជីវិតា វោរោបេតិ អាបត្តិ បាចិត្តិយស្ស ។ បាណោ វេមតិកោ ជីវិតា វោរោបេតិ អាបត្តិ ទុក្កដស្ស ។ បាណោ អប្បាណសញ្ញី ជីវិតា វោរោបេតិ អនាបត្តិ ។ អប្បាណោ



ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬដើម្បីពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្លែងផ្តាច់បង់សត្វចាកជីវិត ត្រូវអាបត្តិបាចិត្តិយ ។

(២៩០) ត្រង់ពាក្យថា ភិក្ខុណាមួយ ខាងដើមសេចក្តីដូចគ្នានឹងបឋមបារាជិកសិក្ខាបទ ។ ពាក្យថា ក្លែង គឺដឹងស្គាល់ជាក់ ហើយក្លែងប្រព្រឹត្តល្មើស ប្រព្រឹត្តកន្លង ។ ដែលហៅថា សត្វ គឺសំដៅយកសត្វតិរច្ឆាន ។ ពាក្យថា ផ្តាច់បង់នូវសត្វចាកជីវិត គឺផ្តាច់បង់ បំផ្លាញបង់នូវជីវិតិន្ទ្រិយ គឺធ្វើតំណជីវិតរបស់សត្វឲ្យកក្រើក ត្រូវអាបត្តិបាចិត្តិយ ។

(២៩១) សត្វ (តិរច្ឆាន) ភិក្ខុសំគាល់ថាសត្វ (តិរច្ឆាន) ហើយផ្តាច់បង់ចាកជីវិត (សម្លាប់) ត្រូវអាបត្តិបាចិត្តិយ ។ សត្វ (តិរច្ឆាន) ភិក្ខុមានសេចក្តីសង្ស័យ ហើយផ្តាច់បង់ចាកជីវិត ត្រូវអាបត្តិទុក្កដ ។ សត្វ (តិរច្ឆាន) ភិក្ខុសំគាល់ថាមិនមែនសត្វ (តិរច្ឆាន) ហើយផ្តាច់បង់ចាកជីវិត មិនត្រូវអាបត្តិឡើយ ។ មិនមែនសត្វ (តិរច្ឆាន) ភិក្ខុសំគាល់ថា

បាណសញ្ញី អាបត្តិ ទុក្កដស្ស ។ អប្បាណេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អប្បាណេ អប្បាណសញ្ញី អនាបត្តិ ។

[៤៩២] អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស ន មរណាធិប្បាយស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។





សត្វ (តិរច្ឆាន) ត្រូវអាបត្តិទុក្កដ ។ មិនមែនសត្វ (តិរច្ឆាន) តែភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនសត្វ (តិរច្ឆាន) តែភិក្ខុសំគាល់ថាមិនមែនសត្វ (តិរច្ឆាន) មិនត្រូវអាបត្តិឡើយ ។

[៤៩២] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុមិនក្លែង ១ មិនមានស្មារតី ១ មិនដឹង ១ មិនប៉ុនប៉ងសម្លាប់ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១ ចប់ ។

## ទុតិយសិក្ខាបទំ

[៤៩៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ជានំ សប្បាណកំ ឧទកំ បរិភុញ្ជន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ជានំ សប្បាណកំ ឧទកំ បរិភុញ្ជិស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ សប្បាណកំ ឧទកំ បរិភុញ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ជានំ សប្បាណកំ ឧទកំ បរិភុញ្ជិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ សប្បាណកំ ឧទកំ បរិភុញ្ជេយ្យ បាចិត្តិយន្តិ ។

## សិក្ខាបទទី ២

[៤៩៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថាទឹកមានសត្វហើយយកទៅប្រើប្រាស់ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោសតិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងថាទឹកមានសត្វហើយមិនគួរនឹងយកទៅប្រើប្រាស់សោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយដឹងថាទឹកមានសត្វហើយយកទៅប្រើប្រាស់ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកដឹងថាទឹកមានសត្វហើយមិនគួរនឹងយកទៅប្រើប្រាស់ទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹងរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងហើយបរិភោគទឹកដែលមានសត្វមានជីវិត (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

[៤៨៦] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ ។ សប្បាណកន្តិ ជានំ បរិភោគេន មរិស្សន្តីតិ ជានន្តោ បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។

[៤៨៧] សប្បាណកេ សប្បាណកសញ្ញី បរិភុញ្ជតិ អាបត្តិ បាចិត្តិយស្ស ។ សប្បាណកេ វេមតិកោ បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។ សប្បាណកេ អប្បាណកសញ្ញី បរិភុញ្ជតិ អនាបត្តិ ។ អប្បាណកេ សប្បាណកសញ្ញី អាបត្តិ ទុក្កដស្ស ។ អប្បាណកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អប្បាណកេ អប្បាណកសញ្ញី អនាបត្តិ ។

[៤៨៨] អនាបត្តិ សប្បាណកន្តិ អជានន្តោ អប្បាណកន្តិ ជានន្តោ បរិភោគេន ន មរិស្សន្តីតិ ជានន្តោ បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។





[៤៨៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីអធិប្បាយ ក្នុងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌរួចហើយ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងខ្លួនឯង ពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះ ។ ភិក្ខុដឹងថាទឹកមានសត្វមានជីវិត (ឬ) ដឹងថាពួកសត្វនឹងស្លាប់ដោយការប្រើប្រាស់ ហើយប្រើប្រាស់ ត្រូវអាបត្តិបាចិត្តិយ ។

[៤៨៧] ទឹកមានសត្វមានជីវិត ភិក្ខុសំគាល់ថាទឹកមានសត្វមានជីវិត ហើយប្រើប្រាស់ទឹកនោះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុសង្ស័យក្នុងទឹកដែលមានសត្វមានជីវិត ហើយប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។ ទឹកមានសត្វមានជីវិត ភិក្ខុសំគាល់ថាទឹកគ្មានសត្វ ហើយប្រើប្រាស់ មិនត្រូវអាបត្តិ ។ ទឹកគ្មានសត្វ ភិក្ខុសំគាល់ថាមានសត្វ ត្រូវអាបត្តិទុក្កដ ។ ទឹកគ្មានសត្វ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ទឹកគ្មានសត្វ ភិក្ខុសំគាល់ថាគ្មានសត្វ មិនត្រូវអាបត្តិ ។

[៤៨៨] ភាពដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺ ភិក្ខុមិនដឹងថាទឹកមានសត្វ (ក្ដី) ដឹងថាទឹកគ្មានសត្វរស់ (ក្ដី) ដឹងថាពួកសត្វនឹងមិនស្លាប់ដោយការប្រើប្រាស់ (ក្ដី) ហើយប្រើប្រាស់ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ២ ចប់ ។

# តតិយសិក្ខាបទំ

(៤៨៧) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ជានំ យថាធម្មំ និហតាធិករណំ បុនកម្មាយ ឧក្កោដេន្តិ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មំ អនិហតំ ទុន្និហតំ បុន និហន្តព្វន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជានំ យថាធម្មំ និហតាធិករណំ បុនកម្មាយ ឧក្កោដេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ យថាធម្មំ និហតាធិករណំ បុនកម្មាយ ឧក្កោដេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ជានំ យថាធម្មំ និហតាធិករណំ បុនកម្មាយ ឧក្កោដេស្សថ នេតំ មោឃបុរិសា

# សិក្ខាបទទី ៣ .

[៤៨៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថាអធិករណ៍(១) ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយស្រើរើ ដើម្បីធ្វើជាថ្មីទៀតថា កម្ម(នោះ) គឺសង្ឃមិនបានធ្វើ កម្ម(នោះ) គឺសង្ឃធ្វើមិនត្រឹមត្រូវ ពួកយើងត្រូវធ្វើជាថ្មីទៀត កម្មឈ្មោះថា សង្ឃរម្ងាប់ហើយមិនស្រេច រម្ងាប់ហើយមិនល្អ ពួកយើងត្រូវរម្ងាប់ជាថ្មីទៀត ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងថាអធិករណ៍ ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ មិនគួរនឹងស្រើរើ ដើម្បីធ្វើជាថ្មីទៀតសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកដឹងថាអធិករណ៍ ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ ស្រើរើដើម្បីធ្វើជាថ្មីទៀត ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកដឹងថាអធិករណ៍ ដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ មិនគួរនឹងស្រើរើ ដើម្បីធ្វើជាថ្មីទៀតទេ

១ មានសេចក្ដីអធិប្បាយក្នុងសិក្ខាបទទី ៤ នៃសេកណ្ឌសៀវភៅទី ២ ស្រេចហើយ ។

អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ យថាធម្មំ និហតាធិករណំ បុនកម្មាយ ឧក្កោដេយ្យ បាចិត្តិយន្តិ ។

[៦៨៨] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ យថាធម្មំ នាម ធម្មេន វិនយេន សត្ថុសាសនេន កតំ ឯតំ យថាធម្មំ នាម ។

[៦៨៩] អធិករណំ នាម ចត្តារិ អធិករណានិ វិវាទាធិករណំ អនុវាទាធិករណំ អាបត្តាធិករណំ កិច្ចាធិករណំ ។ បុនកម្មាយ ឧក្កោដេយ្យាតិ អកតំ កម្មំ ទុក្កដំ កម្មំ បុន កាតព្វំ កម្មំ អនិហតំ ទុន្និហតំ បុន និហនិតព្វន្តិ ឧក្កោដេតិ អាបត្តិ បាចិត្តិយស្ស ។





នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា មួយទៀតពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលដឹងថាអធិករណៈដែលសង្ឃរម្ងាប់សមគួរតាមធម៌ហើយ សើរើដើម្បីធ្វើជាថ្មីទៀត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៦៨៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចនឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ដល់ភិក្ខុនោះក្តី ភិក្ខុដែលមានរឿងនោះប្រាប់ក្តី ។ ដែលហៅថា សមគួរតាមធម៌ គឺអធិករណៈដែលសង្ឃធ្វើ (រម្ងាប់) ហើយតាមធម៌តាមវិន័យតាមពាក្យប្រៀនប្រដៅព្រះសាស្តា នេះហៅថា សមគួរតាមធម៌ ។

[៦៨៩] ដែលហៅថា អធិករណៈ គឺ អធិករណៈមាន ៤ យ៉ាង គឺវិវាទាធិករណៈ ១ អនុវាទាធិករណៈ ១ អាបត្តាធិករណៈ ១ កិច្ចាធិករណៈ ១ ។ ពាក្យថា សើរើដើម្បីធ្វើជាថ្មីទៀត គឺភិក្ខុសើរើថា សង្ឃធ្វើកម្មមិនស្រេច សង្ឃធ្វើកម្មមិនល្អ ហើយត្រូវធ្វើជាថ្មីទៀត សង្ឃរម្ងាប់កម្មមិនស្រេច សង្ឃរម្ងាប់កម្មមិនល្អ ហើយត្រូវរម្ងាប់ជាថ្មីទៀត ដូច្នេះ ត្រូវអាបត្តិបាចិត្តិយ ។

[៤២០] ធម្មកម្មេ ធម្មកម្មសញ្ញី ឧក្កោដេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ ឧក្កោដេតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី ឧក្កោដេតិ អនាបត្តិ ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អនាបត្តិ ។

[៤២១] អនាបត្តិ អធម្មេន វា វគ្គេន វា នកម្មារហស្ស វា កម្មំ កតន្តិ ជានន្តោ ឧក្កោដេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឧក្កោដនសិក្ខាបទំ និដ្ឋិតំ ។



(៤២០) កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយរើរើឡើង ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយរើរើ ត្រូវអាបត្តិទុក្កដ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយរើរើ មិនត្រូវអាបត្តិ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិ ។

(៤២១) ភិក្ខុដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុដឹងថា កម្មដែលសង្ឃធ្វើហើយដោយពួកដែលមិនមែនជាធម្មិក[១] ដោយវគ្គ[២] សង្ឃធ្វើកម្មដល់ភិក្ខុដែលមិនគួរដល់កម្ម ហើយរើរើ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់ ។

---

១ បានដល់កម្មដែលធ្វើមិនត្រូវតាមច្បាប់ ។ ២ បានដល់កម្មដែលធ្វើបែកទៅជាពួក មិនព្រមព្រៀងគ្នា ។

## ចតុត្ថសិក្ខាបទំ

[៦៦៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អាបត្តឹ អាបជ្ជិត្វា ភាតុនោ សទ្ធិវិហារិកស្ស ភិក្ខុនោ អារោចេសិ អហំ អាវុសោ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អាបត្តឹ អាបន្នោ មា កស្សចិ អារោចេសីតិ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អាបត្តឹ អាបជ្ជិត្វា សង្ឃំ តស្សា អាបត្តិយា បរិវាសំ យាចិ ។ តស្ស សង្ឃោ តស្សា អាបត្តិយា បរិវាសំ អទាសិ ។ សោ បរិវសន្តោ តំ ភិក្ខុំ បស្សិត្វា ឯតទវោច អហំ អាវុសោ សញ្ចេតនិកំ សុក្កវិសដ្ឋឹ អាបត្តឹ អាបជ្ជឹ សង្ឃំ តស្សា អាបត្តិយា បរិវាសំ យាចឹ តស្ស មេ សង្ឃោ តស្សា អាបត្តិយា បរិវាសំ អទាសិ សោហំ បរិវសាមិ វេទយាមហំ អាវុសោ វេទយតីតិ មំ អាយស្មា ធារេតូតិ ។ កឹ នុ ខោ អាវុសោ យោ អញ្ញោបិ ឥមំ អាបត្តឹ

## សិក្ខាបទទី ៤

[៦៦៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះឧបនន្ទសក្យបុត្រដ៏មានអាយុ ត្រូវអាបត្តិឈ្មោះសញ្ចេតនិកសុក្កវិសដ្ឋិ(១) ហើយប្រាប់ដល់ភិក្ខុជាសទ្ធិវិហារិក របស់ព្រះថេរៈជាបងប្អូនថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិហើយ លោកកុំប្រាប់ដល់អ្នកណាឡើយ ។ សម័យនោះឯង ភិក្ខុ ១ រូបត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិ ហើយសូមនូវបរិវាស ដើម្បីអាបត្តិនោះអំពីសង្ឃ ។ សង្ឃបានឲ្យបរិវាស ដើម្បីអាបត្តិនោះដល់ភិក្ខុនោះ ។ ភិក្ខុនោះ កំពុងនៅបរិវាស ក៏បានឃើញភិក្ខុដែលព្រះឧបនន្ទ ប្រាប់អាបត្តិនោះ ហើយបាននិយាយពាក្យនេះថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសញ្ចេតនិកសុក្កវិសដ្ឋិ ហើយសុំបរិវាស ដើម្បីអាបត្តិនោះអំពីសង្ឃ សង្ឃបានឲ្យបរិវាស ដើម្បីអាបត្តិនោះដល់ខ្ញុំនោះឯង ខ្ញុំនោះកំពុងនៅបរិវាស នែអាវុសោ ខ្ញុំសូមប្រាប់ឲ្យដឹង លោកដ៏មានអាយុចូរចាំទុកនូវខ្ញុំថា ភិក្ខុនេះបានប្រាប់ឲ្យដឹង ។ ភិក្ខុនោះសួរវិញថា នែអាវុសោ ចុះភិក្ខុដទៃណា ក៏ត្រូវអាបត្តិនេះ ភិក្ខុនោះក៏

---

១ បានប្រែក្នុងសិក្ខាបទទី ១ នៃសង្ឃាទិសេសរួចហើយ ។

អាបជ្ជតិ សោបិ ឯវំ ករោតីតិ ។ ឯវមាវុសោតិ ។ អយំ អាវុសោ អាយស្មា ឧបនន្ទោ សក្យបុត្តោ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ អាបត្តឹ អាបជ្ជិត្វា(១) សោ មេ អារោចេសិ អហំ អាវុសោ សញ្ចេតនិកំ សុក្កវិស្សដ្ឋឹ អាបត្តឹ អាបន្នោ មា កស្សចិ អារោចេសីតិ ។ កឹ បន ត្វំ អាវុសោ តំ បដិច្ឆាទេសីតិ ។ ឯវមាវុសោតិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ ភិក្ខុស្ស ជានំ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ ភិក្ខុស្ស ជានំ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស ភិក្ខុស្ស ជានំ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ

១ អាបជ្ជិតំ ម. យុ. ។



ធ្វើយ៉ាងនេះឬ ។ ភិក្ខុដែលនៅបរិវាសតបថា យ៉ាងហ្នឹងហើយ អាវុសោ ។ ភិក្ខុនោះនិយាយថា នែអាវុសោ លោកឧបនន្ទសក្យបុត្រដ៏មានអាយុនេះ ត្រូវអាបត្តិសញ្ចេតនិកសុក្កវិស្សដ្ឋិហើយ លោកឧបនន្ទនោះបានប្រាប់ខ្ញុំថា នែអាវុសោ ខ្ញុំត្រូវអាបត្តិសញ្ចេតនិកសុក្កវិស្សដ្ឋិហើយ លោកកុំប្រាប់ដល់អ្នកណាឡើយ ។ ភិក្ខុដែលនៅបរិវាសនោះនិយាយថា នែអាវុសោ ចុះលោកបានបិទបាំងអាបត្តិនោះឬ ។ ភិក្ខុនោះប្រាប់ថា យ៉ាងហ្នឹងហើយ អាវុសោ ។ លំដាប់នោះឯង ភិក្ខុនោះប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុកាលដឹងហើយមិនគួរនឹងបិទបាំងអាបត្តិគ្រោះរបស់ភិក្ខុដទៃសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា អ្នកឯងកាលដឹងហើយបិទបាំងអាបត្តិគ្រោះរបស់ភិក្ខុដទៃ ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស អ្នកឯងកាលដឹងហើយមិនគួរនឹងបិទបាំងអាបត្តិគ្រោះរបស់ភិក្ខុដទៃទេ នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ

ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស ជានំ ទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេយ្យ បាចិត្តិយន្តិ ។

(៦៦៣) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ ទុដ្ឋុល្លា នាម អាបត្តិ ចត្តារិ ច បារាជិកានិ តេរស ច សង្ឃាទិសេសា ។ បដិច្ឆាទេយ្យាតិ ឥមំ ជានិត្វា ចោទេស្សន្តិ សារេស្សន្តិ ខុំសេស្សន្តិ វម្ភេស្សន្តិ មង្កុំ ករិស្សន្តិ(១) នាហំ ទស្សាមីតិ ធុរំ និក្ខិត្តមត្តេ អាបត្តិ បាចិត្តិយស្ស ។

(៦៦៤) ទុដ្ឋុល្លាយ អាបត្តិយា ទុដ្ឋុល្លាបត្តិសញ្ញី បដិច្ឆាទេតិ អាបត្តិ បាចិត្តិយស្ស ។ ទុដ្ឋុល្លាយ អាបត្តិយា វេមតិកោ បដិច្ឆាទេតិ អាបត្តិ ទុក្កដស្ស ។ ទុដ្ឋុល្លាយ អាបត្តិយា អទុដ្ឋុល្លាបត្តិសញ្ញី បដិច្ឆាទេតិ អាបត្តិ ទុក្កដស្ស ។ អទុដ្ឋុល្លំ អាបត្តឹ បដិច្ឆាទេតិ

១ ឧប្បណ្ឌេស្សន្តិ អវណ្ណំ ករិស្សន្តីតិ ចតុ បោត្ថកេ ឥតិ ។



ទ្រង់សំដែងព្រះពុទ្ធប្បញ្ញត្តិនេះឡើងវិញថា ឲ្យលោកទាំងឡាយសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយ កាលដឹងហើយបិទបាំងទុកនូវអាបត្តិអាក្រក់ របស់ភិក្ខុដទៃ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

(៦៦៣) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបាចិត្តិយវគ្គ ។ ពាក្យថា ភិក្ខុដទៃ បានដល់ភិក្ខុដទៃ ។ ដែលហៅថា ដឹងនោះ គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ភិក្ខុនោះក្តី ភិក្ខុដែលត្រូវអាបត្តិនោះប្រាប់ក្តី ។ ដែលហៅថា អាបត្តិអាក្រក់ បានដល់អាបត្តិបារាជិក៤ និងអាបត្តិសង្ឃាទិសេស១៣ ។ ពាក្យថា បិទបាំងទុក សេចក្តីថា (ភិក្ខុណា) គ្រាន់តែដាក់ធុរៈថា ភិក្ខុទាំងឡាយដឹងនូវភិក្ខុនេះហើយ នឹងចោទ នឹងរំលឹក នឹងជេរ នឹងប្រទេច នឹងធ្វើឲ្យអៀនខ្មាស (ហេតុនោះ) អាត្មាមិនប្រាប់ឡើយ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

(៦៦៤) អាបត្តិអាក្រក់ (ជាទុដ្ឋុល្លៈ) ភិក្ខុសំគាល់ថាអាបត្តិអាក្រក់ ហើយបិទបាំងទុក ត្រូវអាបត្តិបាចិត្តិយ ។ អាបត្តិអាក្រក់ ភិក្ខុសង្ស័យ ហើយបិទបាំងទុក ត្រូវអាបត្តិទុក្កដ ។ អាបត្តិអាក្រក់ ភិក្ខុសំគាល់ថាមិនមែនអាបត្តិអាក្រក់ (ស្រាល) ហើយបិទបាំងទុក ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបិទបាំងនូវអាបត្តិមិនអាក្រក់ទុក ត្រូវអាបត្តិ

អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នស្ស ទុដ្ឋុល្លំ វា អទុដ្ឋុល្លំ វា អជ្ឈាចារំ បដិច្ឆាទេតិ អាបត្តិ ទុក្កដស្ស ។ អទុដ្ឋុល្លាយ អាបត្តិយា ទុដ្ឋុល្លាបត្តិសញ្ញី អាបត្តិ ទុក្កដស្ស ។ អទុដ្ឋុល្លាយ អាបត្តិយា វេមតិកោ អាបត្តិ ទុក្កដស្ស ។ អទុដ្ឋុល្លាយ អាបត្តិយា អទុដ្ឋុល្លាបត្តិសញ្ញី អាបត្តិ ទុក្កដស្ស ។

(២៦៨) អនាបត្តិ សង្ឃស្ស ភណ្ឌនំ វា កលហោ វា វិគ្គហោ វា វិវាទោ វា ភវិស្សតីតិ នារោចេតិ សង្ឃភេទោ វា សង្ឃរាជិ វា ភវិស្សតីតិ នារោចេតិ អយំ កក្ខឡោ ផរុសោ ជីវិតន្តរាយំ វា ព្រហ្មចរិយន្តរាយំ វា ករិស្សតីតិ នារោចេតិ អញ្ញេ បតិរូបេ ភិក្ខូ អបស្សន្តោ នារោចេតិ នច្ឆាទេតុកាមោ នារោចេតិ បញ្ញាយិស្សតិ សកេន កម្មេនាតិ នារោចេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។



ទុក្កដ ។ ភិក្ខុបិទបាំងនូវអាបត្តិប្រព្រឹត្តល្មើសអាក្រក់ (ធ្ងន់) ក្ដី មិនអាក្រក់ (ស្រាល) ក្ដី របស់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អាបត្តិមិនអាក្រក់ ភិក្ខុសំគាល់ថាអាបត្តិអាក្រក់ ត្រូវអាបត្តិទុក្កដ ។ អាបត្តិមិនអាក្រក់ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អាបត្តិមិនអាក្រក់ ភិក្ខុសំគាល់ថាអាបត្តិមិនអាក្រក់ ត្រូវអាបត្តិទុក្កដ ។

(២៦៨) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាងគឺ) ភិក្ខុមិនប្រាប់ដោយគិតថា សេចក្ដីបរិភាសក្ដី ជំលោះក្ដី ប្រកួតប្រកាន់ក្ដី វិវាទក្ដី នឹងមានដល់សង្ឃ ១ ភិក្ខុមិនប្រាប់ដោយគិតថា សង្ឃនឹងបែកធ្លាក់ឬសង្ឃនឹងបែកគ្នា ១ ភិក្ខុមិនប្រាប់ដោយគិតថា ភិក្ខុនេះ កាចអាក្រក់ នឹងធ្វើនូវសេចក្ដីអន្តរាយដល់ជីវិត ឬនូវសេចក្ដីអន្តរាយដល់ព្រហ្មចារ្យ ១ ភិក្ខុមិនឃើញភិក្ខុដទៃគួរល្មមនឹងសមគួរ (ដើម្បីប្រាប់) ហើយមិនប្រាប់ ១ ភិក្ខុមិនប្រាថ្នានឹងបិទបាំង ហើយមិនបានប្រាប់ ១ ភិក្ខុមិនប្រាប់ដោយគិតថា ភិក្ខុដែលត្រូវអាបត្តិនោះ នឹងប្រាកដដោយកម្មរបស់ខ្លួនឯង ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៤ ចប់ ។

## បញ្ចមសិក្ខាបទំ

[៤៦៦] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន រាជគហេ សត្តរសវគ្គិយា ទារកា សហាយកា ហោន្តិ ។ ឧបាលិ ទារកោ តេសំ បមុខោ[១] ហោតិ ។ អថខោ ឧបាលិស្ស មាតាបិតូនំ ឯតទហោសិ កេន នុ ខោ ឧបាយេន ឧបាលិ អម្ហាកំ អច្ចយេន សុខញ្ច ជីវេយ្យ ន ច កិលមេយ្យាតិ ។ អថខោ ឧបាលិស្ស មាតាបិតូនំ ឯតទហោសិ សចេ ខោ ឧបាលិ លេខំ សិក្ខេយ្យ ឯវំ ខោ ឧបាលិ អម្ហាកំ អច្ចយេន សុខញ្ច ជីវេយ្យ ន ច កិលមេយ្យាតិ ។ អថខោ ឧបាលិស្ស មាតាបិតូនំ ឯតទហោសិ សចេ ខោ ឧបាលិ លេខំ សិក្ខិស្សតិ អង្គុលិយោ[២] ទុក្ខា ភវិស្សន្តិ សចេ ខោ ឧបាលិ គណនំ សិក្ខេយ្យ ឯវំ ខោ ឧបាលិ អម្ហាកំ អច្ចយេន សុខញ្ច ជីវេយ្យ ន ច កិលមេយ្យាតិ ។ អថខោ ឧបាលិស្ស មាតាបិតូនំ

---

១ ឱ. ម. បាមោក្ខោ ។ ២ អង្គុលិយស្សាតិ បាឋោ ។

## សិក្ខាបទទី ៥

[៤៦៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ ។ សម័យនោះឯង ក្មេងប្រុសទាំងឡាយ មានពួក ១៧ នាក់ ជាសំឡាញ់នឹងគ្នានៅក្នុងក្រុងរាជគ្រឹះ ។ ក្មេងឈ្មោះឧបាលិជាប្រធាននៃក្មេងទាំងនោះ ។ លំដាប់នោះឯង មាតាបិតាឧបាលិកុមារ បានគិតគ្នាដូច្នេះថា កាលបើផុតអំពីយើងទៅ ឧបាលិនឹងរស់នៅសប្បាយផង មិនលំបាកផង ដោយឧបាយដូចម្ដេចហ្ន៎ ។ មាតាបិតារបស់ឧបាលិកុមារ បានគិតគ្នា ក្នុងរឿងនេះទៀតថា បើឧបាលិរៀនសរសេរអក្សរ ដល់ផុតអំពីយើងទៅ ឧបាលិនឹងរស់នៅសប្បាយផង មិនលំបាកផង ដោយប្រការដូច្នេះ ។ មាតាបិតារបស់ឧបាលិកុមារ បានគិតគ្នា (ទៀត) ក្នុងរឿងនេះថា បើឧបាលិនឹងរៀនសរសេរអក្សរ ម្រាមដៃនឹងឈឺ បើឧបាលិរៀនគិត លុះផុតអំពីយើងទៅ ឧបាលិនឹងរស់នៅសប្បាយផង មិនលំបាកផង ដោយអាការហេតុនេះឯង ។ មាតាបិតា

ឯតទហោសិ សចេ ខោ ឧបាលិ គណនំ សិក្ខិ-
ស្សតិ ឧរស្ស ទុក្ខោ ភវិស្សតិ សចេ ខោ ឧបាលិ
រូបំ សិក្ខេយ្យ ឯវំ ខោ ឧបាលិ អម្ហាកំ អច្ចយេន
សុខញ្ច ជីវេយ្យ ន ច កិលមេយ្យាតិ ។ អថ ខោ
ឧបាលិស្ស មាតាបិតូនំ ឯតទហោសិ សចេ ខោ ឧបាលិ
រូបំ សិក្ខិស្សតិ អក្ខីនិស្ស ទុក្ខានិ ភវិស្សន្តិ ឥមេ
ខោ សមណា សក្យបុត្តិយា សុខសីលា សុខសមាចារា
សុភោជនានិ ភុញ្ជិត្វា និវាតេសុ សយនេសុ សយន្តិ
សចេ ខោ ឧបាលិ សមណេសុ សក្យបុត្តិយេសុ
បព្វជេយ្យ ឯវំ ខោ ឧបាលិ អម្ហាកំ អច្ចយេន សុខញ្ច
ជីវេយ្យ ន ច កិលមេយ្យាតិ ។

(២៦៧) អស្សោសិ ខោ ឧបាលិ ទារកោ មាតា-
បិតូនំ ឥមំ កថាសល្លាបំ ។ អថ ខោ ឧបាលិ
ទារកោ យេន តេ ទារកា តេនុបសង្កមិ ឧបសង្កមិត្វា
តេ ទារកេ ឯតទវោច ឯថ មយំ អយ្យា សមណេសុ
សក្យបុត្តិយេសុ បព្វជិស្សាមាតិ ។ សចេ ខោ ត្វំ
អយ្យ បព្វជិស្សសិ ឯវំ មយម្បិ បព្វជិស្សាមាតិ ។



របស់ឧបាលិកុមារ បានគិតគ្នាតទៅទៀតថា បើឧបាលិនឹងរៀនគត់ នឹង
ឈឺទ្រូងឥតល្ហែ បើឧបាលិរៀនមើលរូបនិមិត្ត ដល់កាលកន្លងយើងទៅ
ឧបាលិនឹងរស់នៅជាសុខផង មិនលំបាកផង ដោយអាការយ៉ាងនេះ
ឯង ។ មាតាបិតាឧបាលិបានគិតគ្នាតទៅទៀតថា បើឧបាលិរៀន
មើលរូបនិមិត្ត ភ្នែករបស់ឧបាលិនោះនឹងឈឺលំបាក ឯពួកសមណៈ
ជាសក្យបុត្រនេះ មានសីលជាសុខ មានសេចក្តីប្រព្រឹត្តល្អជាសុខ ឆាន់
ភោជនល្អ សឹងដេកលើទីសំណាក់ ដែលខ្យល់មិនបានចូលទៅ បើឧបាលិ
បួសក្នុងសំណាក់ សមណៈទាំងឡាយជាសក្យបុត្រ ដល់កាលកន្លងយើងទៅ
ឧបាលិនឹងរស់នៅជាសុខផង មិនលំបាកផង ដោយអាការៈយ៉ាង
នេះឯង ។

(២៦៧) ទារកៈឈ្មោះឧបាលិ បានស្តាប់ពាក្យមាតាបិតាពិគ្រោះគ្នា
យ៉ាងនេះហើយ ។ ទើបឧបាលិទារក ចូលទៅរកពួកក្មេងទាំងនោះ លុះ
ចូលទៅហើយបាននិយាយពាក្យនេះនឹងពួកក្មេងទាំងនោះថា នែអ្នកទាំង
ឡាយ ពួកអ្នកចូរមក យើងនឹងទៅបួសក្នុងសំណាក់សមណៈទាំងឡាយ
ជាសក្យបុត្រ ។ ក្មេងទាំងនោះនិយាយថា នែអ្នក បើអ្នកនឹងបួស យើង

អថ ខោ តេ ទារកា ឯកមេកស្ស មាតាបិតរោ ឧបសង្កមិត្វា បព្វជ្ជំ អនុជានាថ អម្ហាកំ អគារស្មា អនគារិយំ បព្វជ្ជាយាតិ ។ អថ ខោ តេសំ ទារកានំ មាតាបិតរោ សព្វេបិមេ ទារកា សមានច្ឆន្ទា កល្យាណាធិប្បាយាតិ អនុជានឹសុ ។ តេ ភិក្ខូ ឧបសង្កមិត្វា បព្វជ្ជំ យាចឹសុ ។ តេ ភិក្ខូ បព្វាជេសុំ ឧបសម្បាទេសុំ ។ តេ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ រោទន្តិ យាគុំ ទេថ ភត្តំ ទេថ ខាទនីយំ ទេថាតិ ។ ភិក្ខូ ឯវមាហំសុ អាគមេថ អាវុសោ យាវ រត្តិ វិភាយតិ[១] សចេ យាគុ ភវិស្សតិ បិវិស្សថ សចេ ភត្តំ ភវិស្សតិ ភុញ្ជិស្សថ សចេ ខាទនីយំ ភវិស្សតិ ខាទិស្សថ នោ ចេ ភវិស្សតិ យាគុ វា ភត្តំ វា ខាទនីយំ វា បិណ្ឌាយ ចរិត្វា ភុញ្ជិស្សថាតិ ។ ឯវម្បិ ខោ តេ ភិក្ខូ ភិក្ខូហិ វុច្ចមានា រោទន្តិយេវ យាគុំ ទេថ ភត្តំ ទេថ ខាទនីយំ ទេថាតិ សេនាសនំ ឩហទន្តិបិ ឧម្មិហន្តិបិ ។

១ យាវ វិភាតាយ រត្តិយាតិបិ កត្ថចិ បោត្ថកេ ទិស្សតិ ។



ទំនងបួសយ៉ាងនេះដែរ ។ លំដាប់នោះ ក្មេងទាំងនោះចូលទៅរកមាតាបិតារៀងៗខ្លួន ហើយពោលពាក្យនេះថា សូមលោកម្ដាយលោកឪពុកអនុញ្ញាតឲ្យយើងខ្ញុំចេញចាកផ្ទះទៅបួស ក្នុងព្រះគោតមសាសនា ។ ទើបមាតាបិតាក្មេងទាំងនោះក៏បានអនុញ្ញាត ដោយគិតឃើញថា ក្មេងទាំងអស់នេះមានចំណង់ស្មើគ្នា មានសេចក្ដីប្រាថ្នាល្អ ។ ពួកក្មេងទាំងនោះចូលទៅរកភិក្ខុទាំងឡាយហើយសូមបព្វជ្ជា ។ ភិក្ខុទាំងនោះក៏បានឲ្យបព្វជ្ជានិងឧបសម្បទា ។ ពួកភិក្ខុ (ថ្មីៗ) នោះ ក្រោកឡើងក្នុងគ្រាសម័យជិតភ្លឺហើយយំថា អ្នកទាំងឡាយចូរឲ្យបបរ ចូរឲ្យបាយ ចូរឲ្យខាទនីយៈ (នំចំណី) ។ ភិក្ខុទាំងឡាយនិយាយយ៉ាងនេះថា នែអាវុសោ អ្នកទាំងឡាយចូររង់ចាំទំរាំភ្លឺសិន បើមានបបរ អ្នកទាំងឡាយនឹងបានផឹកបបរ បើមានបាយ អ្នកទាំងឡាយនឹងបានបរិភោគ បើមានខាទនីយៈ ពួកអ្នកនឹងបានទំពា បើបបរបាយ ឬខាទនីយៈគ្មានទេ ពួកអ្នកនឹងត្រាច់ទៅបិណ្ឌបាតហើយឆាន់ ។ ពួកភិក្ខុក្មេងទាំងនោះ ដែលភិក្ខុទាំងឡាយនិយាយយ៉ាងនេះក៏ដោយ នៅតែយំថា អ្នកទាំងឡាយចូរឲ្យបបរ ចូរឲ្យបាយ ចូរឲ្យខាទនីយៈ ជុះដាក់សេនាសនៈផង នោមដាក់ផង ។

(២៦៨) អស្សោសិ ខោ ភគវា រត្តិយា បច្ចូសសមយំ បច្ចុដ្ឋាយ ទារកសទ្ទំ សុត្វាន អាយស្មន្តំ អានន្ទំ អាមន្តេសិ កឹ នុ ខោ សោ អានន្ទ ទារកសទ្ទោតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ ឯតមត្ថំ អារោចេសិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ជានំ ឩនវីសតិវស្សំ បុគ្គលំ ឧបសម្បាទេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម តេ ភិក្ខវេ មោឃបុរិសា ជានំ ឩនវីសតិវស្សំ បុគ្គលំ ឧបសម្បាទេស្សន្តិ ឩនវីសតិវស្សោ ភិក្ខវេ បុគ្គលោ អក្ខមោ ហោតិ សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកសវាតាតបសរីសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អនធិវាសកជាតិកោ ហោតិ វីសតិវស្សោ ច ខោ ភិក្ខវេ បុគ្គលោ ខមោ ហោតិ



(២៦៨) ព្រះដ៏មានព្រះភាគទ្រង់ក្រោកក្នុងរាត្រីសម័យជិតភ្លឺបានឮសំឡេងក្មេង លុះឮហើយក៏ត្រាស់ហៅព្រះអានន្ទដ៏មានអាយុមកថា ម្នាលអានន្ទ សំឡេងនោះជាសំឡេងក្មេងអ្វី ។ ទើបព្រះអានន្ទដ៏មានអាយុក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយដឹងហើយ ឲ្យឧបសម្បទាដល់បុគ្គលមានអាយុខ្វះពី២០ឆ្នាំ ពិតមែនឬ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះដឹងហើយ មិនគួរនឹងឲ្យឧបសម្បទាដល់បុគ្គលមានអាយុខ្វះពី២០ឆ្នាំទេ ម្នាលភិក្ខុទាំងឡាយ (ព្រោះថា) បុគ្គលមានអាយុមិនគ្រប់២០ឆ្នាំ តែងមិនធន់ទ្រាំត្រជាក់ក្ដៅ ឃ្លានស្រេក សម្ផស្សរបស់រោមមូសខ្យល់កំដៅថ្ងៃសត្វទីឃជាតិ(១)ទាំងឡាយ មិនអត់ធន់នូវពាក្យដែលបុគ្គលពោលអាក្រក់ មិនអត់ធន់នូវពាក្យអាក្រក់ដែលបុគ្គលនាំមកប្រាប់ មិនអត់ធន់នូវវេទនាប្រកបក្នុងសរីរៈដ៏ក្លៀវក្លា រឹង អាក្រក់ មិនស្រួល មិនជាទីគាប់ចិត្ត អាចផ្ដាច់បង់នូវជីវិតដែលកើតឡើងហើយ ព្រោះជាអ្នកមានជាតិមិនអត់ទ្រាំ ម្នាលភិក្ខុទាំងឡាយ ចំណែកខាងបុគ្គល

១ ជាឈ្មោះសត្វវែងៗ មានពស់ក្អែបជាដើម ។

សីតស្ស ឧណ្ហស្ស ជិឃច្ឆាយ បិបាសាយ ឌំសមកស-វាតាតបសិរឹសបសម្ផស្សានំ ទុរុត្តានំ ទុរាគតានំ វចនបថានំ ឧប្បន្នានំ សារីរិកានំ វេទនានំ ទុក្ខានំ តិព្វានំ ខរានំ កដុកានំ អសាតានំ អមនាបានំ បាណហរានំ អធិវាសកជាតិកោ ហោតិ ។ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ ឩនវីសតិវស្សំ បុគ្គលំ ឧបសម្បាទេយ្យ សោ ច បុគ្គលោ អនុបសម្បន្នោ តេ ច ភិក្ខូ គារយ្ហា ឥទំ តស្មឹ បាចិត្តិយន្តិ ។



មានវស្សាក្រោម ២០ ទើបទ្រាំត្រជាក់ក្តៅឃ្លានស្រេកសម្ផស្សរបោមមូស ខ្យល់កំដៅថ្ងៃសត្វទីឃជាតិទាំងឡាយ មិនអត់ធន់នូវពាក្យដែលបុគ្គលពោលអាក្រក់មានមក មិនអត់ធន់នូវពាក្យអាក្រក់ដែលបុគ្គលនាំមកប្រាប់ មិនទ្រាំនូវវេទនាប្រកបដោយទុក្ខសរីរៈដ៏ក្លៀវក្លាក្រៃលែងអាក្រក់ មិនស្រួល មិនជាទីគាប់ចិត្ត ជាទីនាំបង់នូវជីវិតដែលកើតឡើងហើយ បានជាអ្នកមានជាតិអត់ទ្រាំបាន ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកាលដឹងចំហើយ ឲ្យឧបសម្បទាដល់បុគ្គលដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំ(១) បុគ្គលដែលមានអាយុមិនទាន់គ្រប់ ២០ ឆ្នាំនោះក៏នៅជាអនុបសម្បន្នដដែល ចំណែកភិក្ខុទាំងឡាយនោះ អ្នកប្រាជ្ញគប្បីតិះដៀល ទោសជាបាចិត្តិយ ក្នុងរឿងនោះ ។

---

១ តាំងពីឆ្នាំចាស់គ្រប់ ២០ ហើយ ត្រូវរាប់ទាំងខែក្នុងផ្ទៃ ដូចមនុស្សណាមួយកាលនៅក្នុងផ្ទៃមាតាបាន ៩ ខែ កាលដែលសម្រាល ១ ទៅថ្ងៃ ១៤ កើតខែពិសាខ ឆ្នាំជូត លុះដល់ចូលថ្ងៃ ១៤ កើតខែពិសាខ ឆ្នាំមមែ ទាល់ ២០ ឆ្នាំ ៣ ខែ លុះដល់ថ្ងៃ ១៤ កើតខែស្រាពណ៍ ឆ្នាំមមែ ហើយរាប់លាក់ ៩ ខែក្នុងផ្ទៃ ... ៦ ខែ ... ទើបបានគ្រប់ ២០ ឆ្នាំគត់ ។

(៦៦៩) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ ឩនវីសតិវស្សំ នាម អសម្បត្តវីសតិវស្សំ ។ ឧបសម្បាទេស្សាមីតិ គណំ វា អាចរិយំ វា បត្តំ វា ចីវរំ វា បរិយេសតិ សីមំ វា សម្មន្នតិ អាបត្តិ ទុក្កដស្ស ។ ញត្តិយា ទុក្កដំ ។ ទ្វីហិ កម្មវាចាហិ ទុក្កដា ។ កម្មវាចាបរិយោសានេ ឧបជ្ឈាយស្ស អាបត្តិ បាចិត្តិយស្ស គណស្ស ច អាចរិយស្ស ច អាបត្តិ ទុក្កដស្ស ។

(៦៧០) ឩនវីសតិវស្សេ ឩនវីសតិវស្សសញ្ញី ឧប-សម្បាទេតិ អាបត្តិ បាចិត្តិយស្ស ។ ឩនវីសតិវស្សេ វេមតិកោ ឧបសម្បាទេតិ អាបត្តិ ទុក្កដស្ស ។ ឩនវី-សតិវស្សេ បរិបុណ្ណវីសតិវស្សសញ្ញី ឧបសម្បាទេតិ អនាបត្តិ ។ បរិបុណ្ណវីសតិវស្សេ ឩនវីសតិវស្សសញ្ញី



(៦៦៩) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចក្នុងសិក្ខាបទទី ១ នៃចុល្លវគ្គ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្ដី ពួកភិក្ខុដទៃប្រាប់ដល់ភិក្ខុនោះក្ដី កុលបុត្រដែលខ្លួនឲ្យឧបសម្បទា នោះប្រាប់ក្ដី ។ បុគ្គលដែលមានវស្សាមិនទាន់ដល់២០ ឆ្នាំ ហៅថាមានវស្សាមិនទាន់គ្រប់ ២០ ឆ្នាំ ។ ភិក្ខុគិតថាអញនឹងឲ្យឧបសម្បទា ហើយស្វែងរកគណៈសង្ឃក្ដី អាចារ្យក្ដី បាត្រក្ដី ចីវរក្ដី សម្មតសីមា (ថ្មី)ក្ដី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ។ ភិក្ខុត្រូវអាបត្តិទុក្កដ ពីរដង ក្នុងខណៈចប់កម្មវាចាពីរដង ។ ឧបជ្ឈាយ៍ត្រូវអាបត្តិបាចិត្តិយ គណៈសង្ឃនឹងអាចារ្យ ត្រូវអាបត្តិទុក្កដក្នុងខណៈចប់កម្មវាចាស្រេច ។

(៦៧០) កុលបុត្រមានវស្សាមិនគ្រប់ ២០ ភិក្ខុសំគាល់ថាមានវស្សាមិនគ្រប់ ២០ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិបាចិត្តិយ ។ កុលបុត្រមានវស្សាមិនគ្រប់ ២០ ភិក្ខុមានសេចក្ដីសង្ស័យ ហើយឲ្យឧបសម្បទា ត្រូវអាបត្តិទុក្កដ ។ កុលបុត្រមានវស្សាមិនគ្រប់ ២០ ភិក្ខុសំគាល់ថា មានវស្សាគ្រប់ ២០ ហើយឲ្យឧបសម្បទា មិនត្រូវអាបត្តិ ។ កុលបុត្រមានវស្សាគ្រប់ ២០ ភិក្ខុសំគាល់ថា មានវស្សាមិនគ្រប់ ២០ ត្រូវអាបត្តិ

អាបត្តិ ទុក្កដស្ស ។ បរិបុណ្ណវីសតិវស្សេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បរិបុណ្ណវីសតិវស្សេ បរិបុណ្ណវីស-តិវស្សសញ្ញី អនាបត្តិ ។

(២៧០) អនាបត្តិ ឩនវីសតិវស្សំ បុគ្គលំ បរិបុណ្ណ-វីសតិវស្សសញ្ញី ឧបសម្បាទេតិ បរិបុណ្ណវីសតិវស្សំ បរិបុណ្ណវីសតិវស្សសញ្ញី ឧបសម្បាទេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បញ្ចមសិក្ខាបទំ និដ្ឋិតំ ។



ទុក្កដ ។ កុលបុត្រមានវស្សាគ្រប់ ២០ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កុលបុត្រមានវស្សាគ្រប់ ២០ ភិក្ខុសំគាល់ថា មានវស្សាគ្រប់ ២០ មិនត្រូវអាបត្តិ ។

(២៧០) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុសំគាល់បុគ្គលដែលមានវស្សាមិនទាន់គ្រប់២០ថាមានវស្សាគ្រប់២០ ហើយឲ្យឧបសម្បទា ១ ភិក្ខុសំគាល់បុគ្គលដែលមានវស្សាគ្រប់ ២០ ថា មានវស្សាគ្រប់ ២០ ហើយឲ្យឧបសម្បទា ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៥ ចប់

## ឆដ្ឋសិក្ខាបទំ

[៦៧៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ សត្ថោ រាជគហា បដិយាលោកំ គន្តុកាមោ ហោតិ ។ អញ្ញតរោ ភិក្ខុ តេ មនុស្សេ ឯតទវោច អហំបាយស្មន្តេហិ សទ្ធឹ គមិស្សាមីតិ ។ មយំ ខោ ភន្តេ សុង្កំ បរិហរិស្សាមាតិ ។ បជានាថាវុសោតិ ។ អស្សោសុំ ខោ កម្មិកា សត្ថោ កិរ សុង្កំ បរិហរិស្សតីតិ ។ តេ មគ្គេ បរិយុដ្ឋឹសុ ។ អថខោ តេ កម្មិកា តំ សត្ថំ គហេត្វា អច្ឆិន្ទិត្វា តំ ភិក្ខុំ ឯតទវោចុំ កិស្ស ត្វំ ភន្តេ ជានំ ថេយ្យសត្ថេន សទ្ធឹ គច្ឆសីតិ បលិពុន្ធិត្វា មុញ្ចឹសុ ។ អថខោ សោ ភិក្ខុ សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ ជានំ

## សិក្ខាបទទី ៦

[៦៧៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង មានពួកឈ្មួញរទេះ ១ ពួក មានសេចក្តីប្រាថ្នាចេញពីក្រុងរាជគ្រឹះ ហើយទៅកាន់ប្រទេសឈ្មោះបដិយាលោក ។ ភិក្ខុ ១ រូបបាននិយាយពាក្យនេះនឹងមនុស្សទាំងនោះថា អាត្មានឹងទៅជាមួយនឹងអ្នកមានអាយុទាំងឡាយដែរ ។ ពួកមនុស្សទាំងនោះនិយាយវិញថា សូមបាន ពួកយើងនឹងគេចពីស្បួចពន្ធទេតើ ។ ភិក្ខុនោះនិយាយថា នែអ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរដឹងចុះ ។ ពួកអ្នកធ្វើការគយបានឮគេនិយាយថា ពួកឈ្មួញនឹងគេចពីស្បួចពន្ធ ហើយចាំស្ទាក់ពួកមនុស្សទាំងនោះក្នុងផ្លូវ ។ ឯពួកអ្នកធ្វើការគយនោះក៏ចាប់រឹបយកពួកឈ្មួញរទេះនោះ ហើយបាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកដ៏ចំរើន ហេតុអ្វីបានជាទៅជាមួយនឹងពួកឈ្មួញចោរដែលគេចពីស្បួចពន្ធ ទាំងដឹងខ្លួនហើយក៏ឃាត់ភិក្ខុនោះទុក ហើយលែងទៅ ។ លំដាប់នោះឯង ភិក្ខុនោះទៅកាន់ក្រុងសាវត្ថីហើយ ប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុដឹងហើយ មិនគួរនឹងបបួលគ្នាដើរទៅកាន់ផ្លូវឆ្ងាយជាមួយពួក

ថេយ្យសត្ថេន សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិ-
បជ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ ថេយ្យ-
សត្ថេន សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជថាតិ ។
សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម
តុម្ហេ មោឃបុរិសា ជានំ ថេយ្យសត្ថេន សទ្ធិំ សំវិធាយ
ឯកទ្ធានមគ្គំ បដិបជ្ជិស្សថ នេតំ មោឃបុរិសា
អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភា-
វាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ ថេយ្យសត្ថេន
សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ អន្តមសោ
គាមន្តរម្បិ បាចិត្តិយន្តិ ។

[២៧៣] យោ បនាតិ យោ យាទិសោ ។ បេ ។
ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ
ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ
វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ ថេយ្យ-
សត្ថោ នាម ចោរា កតកម្មា វា ហោន្តិ អកត-
កម្មា វា រាជានំ វា ថេយ្យំ គច្ឆន្តិ វា



មួយអន្លើដោយពួកឈ្មួញគេចពន្ធដូច្នោះ ។ ព្រះដ៏មានព្រះភាគ
ត្រាស់សួរថា នែភិក្ខុ ឮថា អ្នកដឹងហើយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា
មួយអន្លើដោយពួកឈ្មួញដែលគេចពន្ធដូច្នោះ ពិតមែនឬ ។ ភិក្ខុទាំងនោះ
ក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ
ទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកដឹងហើយម្តេចក៏បបួលគ្នាដើរផ្លូវ
ឆ្ងាយជាមួយគ្នា មួយអន្លើដោយពួកឈ្មួញដែលគេចពន្ធដូច្នេះ នែ
មោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា
ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាល
ភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះ
ថា ភិក្ខុណាមួយដឹងហើយ បបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើ
ដោយពួកឈ្មួញជាចោរ ដោយហោចទៅសូម្បីចន្លោះស្រុកមួយ
ត្រូវអាបត្តិបាចិត្តិយ ។

(២៧៣) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹង
សិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយ
ខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ភិក្ខុនោះក្តី ពួកឈ្មួញនោះប្រាប់ក្តី ។
ដែលហៅថាពួកឈ្មួញជាចោរ គឺពួកចោរដែលធ្លាប់ធ្វើការ (លួច) ហើយក្តី
មិនធ្លាប់ធ្វើការ (លួច) ហើយក្តី ដល់នូវកិរិយាលួច (របស់) ស្តេចក្តី

[illegible] ។ សទ្ធិន្តិ ឯកតោ ។ សំវិធាយាតិ គច្ឆា-
មភគិនិ គច្ឆាម អយ្យេ គច្ឆាម អយ្យ គច្ឆាមភគិនិ
អជ្ជ វា ហិយ្យោ វា បរេ វា គច្ឆាមាតិ សំវិទហតិ
អាបត្តិ ទុក្កដស្ស ។ អន្តមសោ គាមន្តរម្បិ កុក្កុ-
ដសម្បាតេ គាមេ គាមន្តរេ គាមន្តរេ អាបត្តិ បាចិត្តិ-
យស្ស ។ អគាមកេ អរញ្ញេ អឌ្ឍយោជនេ អឌ្ឍយោជនេ
អាបត្តិ បាចិត្តិយស្ស ។

(២៨៦) ថេយ្យសត្ថេ ថេយ្យសត្ថសញ្ញី សំវិធាយ
ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អាបត្តិ
បាចិត្តិយស្ស ។ ថេយ្យសត្ថេ វេមតិកោ សំវិធាយ
ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អាបត្តិ
ទុក្កដស្ស ។ ថេយ្យសត្ថេ អថេយ្យសត្ថសញ្ញី សំវិធាយ
ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អនា-
បត្តិ ។ ភិក្ខុ សំវិទហតិ មនុស្សា ន សំវិទហន្តិ
អាបត្តិ ទុក្កដស្ស ។ អថេយ្យសត្ថេ ថេយ្យសត្ថសញ្ញី



[illegible] ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ ពាក្យថា បបួល
គឺភិក្ខុនិងឈ្មួញបបួលគ្នាថា នែកប្អូនស្រី យើងនឹងទៅ បពិត្រលោកម្ចាស់
ដ៏ចំរើន យើងនឹងទៅ បពិត្រលោកម្ចាស់ដ៏ចំរើន យើងនឹងទៅ នែកប្អូនស្រី
យើងនឹងទៅ យើងនឹងទៅក្នុងថ្ងៃនេះក្តី ថ្ងៃស្អែកក្តី ខានស្អែកក្តី ភិក្ខុនោះ
ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ដោយហោចទៅសូម្បីចន្លោះស្រុកមួយ
សេចក្តីថា ភិក្ខុដើរទៅក្នុងស្រុកមានចម្ងាយល្មមមាន់ហើរដល់ ត្រូវ
អាបត្តិបាចិត្តិយ តែម្តងចន្លោះស្រុក ។ ភិក្ខុដើរទៅក្នុងព្រៃមិនមែន
ជាស្រុក ត្រូវអាបត្តិបាចិត្តិយ តែម្តង ៗ កន្លះយោជន៍ ។

(២៧៦) ពួកឈ្មួញដែលជាចោរ ភិក្ខុសំគាល់ថាពួកឈ្មួញ
ជាចោរ ហើយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅសូម្បី
ចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ ។ ពួកឈ្មួញដែលជាចោរ ភិក្ខុ
មានសេចក្តីសង្ស័យ ហើយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោច
ទៅសូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិទុក្កដ ។ ពួកឈ្មួញដែលជាចោរ
ភិក្ខុសំគាល់ថា មិនមែនពួកឈ្មួញជាចោរ ហើយបបួលគ្នាដើរផ្លូវឆ្ងាយ
ជាមួយគ្នា ដោយហោចទៅសូម្បីចន្លោះស្រុកមួយ មិនត្រូវអាបត្តិ ។
ភិក្ខុបបួល តែមនុស្សទាំងឡាយមិនបបួល (ភិក្ខុនោះ) ត្រូវអាបត្តិ
ទុក្កដ ។ ពួកឈ្មួញមិនមែនជាចោរ ភិក្ខុសំគាល់ថាពួកឈ្មួញជាចោរ

អាបត្តិ ទុក្កដស្ស ។ អថេយ្យសត្ថេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អថេយ្យសត្ថេ អថេយ្យសត្ថសញ្ញី អនាបត្តិ ។

[២៧៨] អនាបត្តិ អសំវិទហិត្វា គច្ឆតិ មនុស្សា សំវិទហន្តិ ភិក្ខុ ន សំវិទហតិ វិសង្កេតេន គច្ឆតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។



ត្រូវអាបត្តិទុក្កដ ។ ពួកឈ្មួញមិនមែនជាចោរ ភិក្ខុសង្ស័យ ត្រូវអាបត្តិ ទុក្កដ ។ ពួកឈ្មួញមិនមែនជាចោរ ភិក្ខុសំគាល់ថាពួកឈ្មួញមិនមែនជាចោរ មិនត្រូវអាបត្តិ ។

[២៧៨] ភិក្ខុមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុមិនបបួលគ្នា ដើរទៅ ១ មនុស្សទាំងឡាយបបួល ភិក្ខុមិនបបួល ១ ភិក្ខុទៅខុសសង្កេត[១] ១ ភិក្ខុទៅក្នុងគ្រាមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៦ ចប់ ។

---

១ បានដល់ភិក្ខុបបួលគ្នាទៅថ្ងៃនេះ ពេលនេះ តែទៅថ្ងៃផ្សេង ពេលផ្សេងវិញ ។

## សត្តមសិក្ខាបទំ

[២៧៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កោសលេសុ ជនបទេសុ សាវត្ថិំ គច្ឆន្តោ អញ្ញតរេន គាមទ្វារេន អតិក្កមតិ ។ អញ្ញតរា ឥត្ថី សាមិកេន សហ ភណ្ឌិត្វា គាមតោ និក្ខមិត្វា តំ ភិក្ខុំ បស្សិត្វា ឯតទវោច កហំ ភន្តេ អយ្យោ គមិស្សតីតិ ។ សាវត្ថិំ ខោ អហំ ភគិនិ គមិស្សាមីតិ ។ អហំ អយ្យេន សទ្ធិំ គមិស្សាមីតិ ។ ឯយ្យាសិ ភគិនីតិ ។ អថខោ តស្សា ឥត្ថិយា សាមិកោ គាមតោ និក្ខមិត្វា មនុស្សេ បុច្ឆិ អបយ្យា ឯវរូបិំ ឥត្ថិំ បស្សេយ្យាថាតិ ។ ឯសាយ្យ បព្វជិតេន សហ គច្ឆតីតិ ។ អថខោ សោ បុរិសោ អនុពន្ធិត្វា តំ ភិក្ខុំ គហេត្វា អាកោដេត្វា មុញ្ចិ ។ អថខោ សោ ភិក្ខុ អញ្ញតរស្មិំ រុក្ខមូលេ(១)បជ្ជុបេត្វា និសីទិ ។ អថខោ សា ឥត្ថី តំ បុរិសំ ឯតទវោច នាយ្យ សោ ភិក្ខុ មំ និប្បាតេសិ

១ ឆក្ខុម ចត្តំ ហេចត្តាតិ កទ្ធចិ ហោន្តុក អត្ថិ ។

## សិក្ខាបទទី ៧

[២៧៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុ ១ រូប ទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទ បានចេញទៅតាមទ្វារមួយ ។ ស្រី ១ នាក់ឈ្លោះនឹងប្ដីហើយចេញពីស្រុកទៅ ឃើញភិក្ខុនោះហើយ បាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់នឹងទៅទីណា ។ ភិក្ខុនោះនិយាយថា នែនាង អាត្មានឹងទៅក្រុងសាវត្ថី ។ ស្រីនោះនិយាយថា ខ្ញុំម្ចាស់នឹងទៅជាមួយលោកម្ចាស់ដែរ ។ ភិក្ខុនោះឆ្លើយថា មកចុះនាង ។ ខណៈនោះឯង ប្ដីនៃស្រីនោះចេញពីស្រុកទៅហើយ សួរមនុស្សទាំងឡាយថា នែអ្នកទាំងឡាយ អ្នកទាំងឡាយបានឃើញស្រីមានរូបភាពយ៉ាងនេះទេ ។ គេប្រាប់ថា នែអ្នក ស្រីនោះទៅជាមួយនឹងអ្នកបួសទៅហើយ ។ ទើបបុរសនោះទៅតាមចាប់ភិក្ខុនោះ វាយហើយលែងទៅ ។ ភិក្ខុនោះទ្រមក្រៀមក្រំអង្គុយនៅក្បែរគល់ឈើ ១ ដើម ក្នុងកាលនោះ ។ ឯស្រីនោះបាននិយាយពាក្យនេះនឹងបុរសនោះថា នែអ្នក ភិក្ខុនោះមិនមែនបបួលនាំខ្ញុំមកទេ តែថាខ្ញុំឯង

អហញ្ច មហាមត្ត តេន ភិក្ខុនា សទ្ធិំ គច្ឆាមិ អការកោ សោ ភិក្ខុ គច្ឆ តំ ខមាបេហីតិ ។ អថខោ សោ បុរិសោ តំ ភិក្ខុំ ខមាបេសិ ។ អថខោ សោ ភិក្ខុ សាវត្ថិំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ មាតុគ្គាមេន សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ មាតុគ្គាមេន សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស មាតុគ្គាមេន សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មាតុគ្គាមេន សទ្ធិំ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជេយ្យ អន្តមសោ គាមន្តរម្បិ បាចិត្តិយន្តិ ។



ទៅជាមួយនឹងភិក្ខុនោះទេ ភិក្ខុនោះមិនមែនជាអ្នកធ្វើ (សេចក្ដីខុស) ទេ អ្នកចូរទៅឲ្យភិក្ខុនោះអត់ទោសទៅ ។ ហើយបុរសនោះ សូមទោសនឹងភិក្ខុនោះ ។ លំដាប់នោះ ភិក្ខុនោះទៅកាន់ក្រុងសាវត្ថីហើយប្រាប់ដំណើររឿងនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះពោលទោស តិះដៀល បន្ទុះបង្អាប់ថា ភិក្ខុនេះគួរនឹងបបួលគ្នាហើយដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាមសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងបបួលគ្នាហើយដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាម ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាមទេ ។ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយបបួលគ្នាដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយមាតុគ្រាម ដោយហោចទៅសូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ ។

[២៧៧] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ មាតុគ្គាមោ នាម មនុស្សិត្ថី ន យក្ខី ន បេតី ន តិរច្ឆានគតា វិញ្ញូ បដិពលា សុភាសិតទុព្ភាសិតំ ទុដ្ឋុល្លាទុដ្ឋុល្លំ អាជានិតុំ ។ សទ្ធិន្តិ ឯកតោ ។ សំវិធាយាតិ គច្ឆាម ភគិនិ គច្ឆាម អយ្យ គច្ឆាម អយ្យ គច្ឆាម ភគិនិ អជ្ជ វា ហិយ្យោ វា បរេ វា គច្ឆាមាតិ សំវិទហតិ អាបត្តិ ទុក្កដស្ស ។ អន្តមសោ គាមន្តរម្បិ កុក្កុដសម្បាតេ គាមេ គាមន្តរេ គាមន្តរេ អាបត្តិ បាចិត្តិយស្ស ។ អគាមកេ អរញ្ញេ អឌ្ឍយោជនេ អឌ្ឍយោជនេ អាបត្តិ បាចិត្តិយស្ស ។

[២៧៨] មាតុគ្គាមេ មាតុគ្គាមសញ្ញី សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ វេមតិកោ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អាបត្តិ បាចិត្តិយស្ស ។ មាតុគ្គាមេ អមាតុគ្គាមសញ្ញី សំវិធាយ



[២៧៧] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១នៃបារាជិកកណ្ឌ ។ ដែលហៅថា មាតុគ្រាម សំដៅយកមនុស្សស្រី មិនសំដៅយកយក្សស្រី ប្រេតស្រី តិរច្ឆានញីទេ មនុស្សស្រីនោះគាន់ជាអ្នកដឹងក្តីអាចដឹងសព្វ នូវពាក្យដែលគេពោលល្អ ពោលអាក្រក់ ពាក្យទ្រគោះ មិនមែនពាក្យទ្រគោះ ។ ពាក្យថា មួយអន្លើ គឺជាមួយគ្នា ។ ពាក្យថា បបួលគ្នា គឺភិក្ខុនឹងមាតុគ្រាមបបួលគ្នាថា នែនាង យើងនឹងទៅ លោកម្ចាស់ យើងនឹងទៅ លោកម្ចាស់ យើងនឹងទៅ នែនាង យើងនឹងទៅ យើងនឹងទៅថ្ងៃនេះ ថ្ងៃស្អែក ឬខានស្អែក ភិក្ខុនោះ ត្រូវអាបត្តិទុក្កដ ។ ពាក្យថា ដោយហោចទៅ សូម្បីចន្លោះស្រុកមួយ គឺភិក្ខុទៅក្នុងស្រុកមានចន្លោះល្មមមាន់ហើរទៅដល់ ត្រូវអាបត្តិបាចិត្តិយ គ្រប់ចន្លោះស្រុក ។ ភិក្ខុដើរទៅក្នុងព្រៃមិនមែនជាស្រុក ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗកន្លះយោជន៍ ។

[២៧៨] មាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ហើយបបួលដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅសូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសង្ស័យ ហើយបបួលដើរផ្លូវឆ្ងាយជាមួយគ្នា ដោយហោចទៅសូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ ។ មាតុគ្រាម ភិក្ខុសំគាល់ថាមិនមែនមាតុគ្រាម ហើយបបួលដើរផ្លូវឆ្ងាយជាមួយគ្នា

ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ សំវិទហតិ មាតុគាមោ ន សំវិទហតិ អាបត្តិ ទុក្កដស្ស ។ យក្ខិយា វា បេតិយា វា បណ្ឌកេន វា តិរច្ឆានគតមនុស្សវិគ្គហិត្ថិយា វា សទ្ធឹ សំវិធាយ ឯកទ្ធានមគ្គំ បដិបជ្ជតិ អន្តមសោ គាមន្តរម្បិ អាបត្តិ ទុក្កដស្ស ។ អមាតុគាមេ មាតុគាមសញ្ញី អាបត្តិ ទុក្កដស្ស ។ អមាតុគាមេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អមាតុគាមេ អមាតុគាមសញ្ញី អនាបត្តិ ។

[៤៧៩] អនាបត្តិ អសំវិទហិត្វា គច្ឆតិ មាតុគាមោ សំវិទហតិ ភិក្ខុ ន សំវិទហតិ វិសង្កេតេន គច្ឆតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។





ដោយហោចទៅសូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបបួល មាតុគ្រាមមិនបបួល ភិក្ខុត្រូវអាបត្តិទុក្កដ ។ ភិក្ខុបបួលដើរផ្លូវឆ្ងាយជាមួយគ្នា មួយអន្លើដោយយក្សស្រី ប្រេតស្រី មនុស្សខ្ទើយ និងតិរច្ឆានញី មានកាយដូចមនុស្ស ដោយហោចទៅសូម្បីចន្លោះស្រុកមួយ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថាមាតុគ្រាម ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនមាតុគ្រាម ភិក្ខុសំគាល់ថា មិនមែនមាតុគ្រាម មិនត្រូវអាបត្តិ ។

(៤៧៩) ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុមិនបបួលហើយទៅ១ មាតុគ្រាមបបួល ភិក្ខុមិនបបួល១ ភិក្ខុទៅដោយខុសសង្កេត១ ភិក្ខុទៅព្រោះមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១ ។

សិក្ខាបទទី ៧ ចប់ ។

# អដ្ឋមសិក្ខាបទំ

[៦៨០] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អរិដ្ឋស្ស នាម ភិក្ខុនោ គទ្ធ[១]ពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ អរិដ្ឋស្ស កិរ នាម ភិក្ខុនោ គទ្ធពាធិបុព្វស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អថខោ តេ ភិក្ខូ យេន អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតទវោចុំ សច្ចំ កិរ តេ អាវុសោ អរិដ្ឋ ឯវរូបំ បាបកំ

១

[១] គព្ភោតិ ជាយោ ។

## សិក្ខាបទទី ៨

[៦៨០] សម័យនោះ ព្រះពុទ្ធមានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ភិក្ខុឈ្មោះអរិដ្ឋជាកូននៃត្រកូលអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ខាងសភាពយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ធ្វើនូវសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុជាច្រើនរូបបានឮពាក្យនោះថា ឮថាភិក្ខុឈ្មោះអរិដ្ឋ ជាកូននៃត្រកូលអ្នកសម្លាប់ត្មាត មានទិដ្ឋិអាក្រក់ខាងសភាពយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថាធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ទើបភិក្ខុទាំងនោះ ចូលទៅរកអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតនោះ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតថា ម្នាលអាវុសោអរិដ្ឋ ឮថាអ្នកមានទិដ្ឋិអាក្រក់

ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជា-
នាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា
តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា
ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជា-
នាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគ-
វតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ មា
អាវុសោ អរិដ្ឋ ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន
ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ
វទេយ្យ អនេកបរិយាយេន អាវុសោ អរិដ្ឋ អន្តរា-
យិកា ធម្មា វុត្តា(១) ភគវតា អលញ្ច បន តេ
បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា
ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ
ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា

១ ម. ម. អន្តរាយិកា វុត្តា ។



ដ៏លាមកយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណា ដែលព្រះដ៏
មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ
មិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់
នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះមែនឬ ។
អរិដ្ឋភិក្ខុឆ្លើយថា នែអាវុសោ ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះ
ភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាច
ធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់
នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។
ភិក្ខុទាំងឡាយនិយាយថា នែអាវុសោអរិដ្ឋ អ្នកកុំនិយាយយ៉ាងនេះ
អ្នកកុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មាន
ព្រះភាគមិនល្អទេ ព្រោះថាព្រះដ៏មានព្រះភាគមិនបានត្រាស់ថាយ៉ាង
នេះទេ នែអាវុសោអរិដ្ឋ ធម៌ទាំងឡាយដែលធ្វើសេចក្តីអន្តរាយ ព្រះ
ដ៏មានព្រះភាគសំដែងហើយដោយបរិយាយច្រើន ធម៌ទាំងឡាយនោះ
រមែងអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេពពិតមែន ព្រះដ៏មានព្រះភាគ
សំដែងហើយថា កាមទាំងឡាយមានសេចក្តីត្រេកអរតិច មានទុក្ខច្រើន មាន
សេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះ
ដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគ្រោងឆ្អឹង

ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ ។ មំសបេសូបមា កាមា វុត្តា ភគវតា ។ បេ ។ តិណុ-ក្កូបមា កាមា វុត្តា ភគវតា ។ បេ ។ អង្គារកា-សូបមា កាមា វុត្តា ភគវតា ។ បេ ។ សុបិនកូបមា កាមា វុត្តា ភគវតា ។ បេ ។ យាចិតកូបមា កាមា វុត្តា ភគវតា ។ បេ ។ រុក្ខផលូបមា កាមា វុត្តា ភគវតា ។ បេ ។ អសិសូនូបមា កាមា វុត្តា ភគវតា ។ បេ ។ សត្តិសូលូបមា កាមា វុត្តា ភគវតា ។ បេ ។ សប្បសិ-រូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ ឯវម្បិ ខោ អរិដ្ឋោ ភិក្ខុ គទ្ធពាធិបុព្វោ តេហិ ភិក្ខូហិ វុច្ចមានោ តថេវ តំ បាបកំ ទិដ្ឋិគតំ(១) ថាមសា បរាមាសា អភិនិវិស្ស

១ ឧត្តរ ទិដ្ឋិគតំ កត្ថចិ បោត្ថកេ នត្ថិ ។





មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសគឺកាមទាំងឡាយនេះមានច្រើន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងស្មៅ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយសុបិន្ត ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងទីជ្រញ់ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសគឺកាមទាំងឡាយនេះមានច្រើន ។ អរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាត ទុកជាភិក្ខុទាំងឡាយនិយាយប្រដៅយ៉ាងនេះ ក៏នៅតែប្រកាន់ទិដ្ឋិលាមកនោះដោយសេចក្តីប្រកាន់មាំ ដោយកំលាំង ហើយពោលយ៉ាងនេះ

ហោតីតិ ឯវំ ព្យា ខោ អហំ អាវុសោ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ យតោ ខោ តេ ភិក្ខូ នាសក្ខឹសុ អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ អថខោ តេ ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា អរិដ្ឋំ ភិក្ខុំ គទ្ធពាធិបុព្វំ បដិបុច្ឆិ សច្ចំ កិរ តេ អរិដ្ឋ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា



ដោយពាក្យថា នែអាវុសោ ធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងហើយថាធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុទាំងឡាយនោះ មិនអាចដោះភិក្ខុឈ្មោះអរិដ្ឋជាកូននៃត្រកូលអ្នកសម្លាប់ត្មាតចេញពីទិដ្ឋិអាក្រក់យ៉ាងនេះបាន ក្នុងកាលណា ភិក្ខុទាំងឡាយនោះក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងកាលនោះឯង លុះចូលទៅហើយក៏ក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ប្រជុំភិក្ខុសង្ឃ ហើយត្រាស់សួរចំពោះអរិដ្ឋភិក្ខុជាកូននៃត្រកូលអ្នកសម្លាប់ត្មាតថា នែអរិដ្ឋ ឮថាអ្នកមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថាធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ពិតមែនឬ ។ អរិដ្ឋភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយ

តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ កស្ស នុ ខោ នាម ត្វំ មោឃបុរិស មយា ឯវំ ធម្មំ ទេសិតំ អាជានាសិ ននុ មយា មោឃបុរិស អនេកបរិយាយេន អន្តរាយិកា ធម្មា វុត្តា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា មយា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា មយា ។បេ។ មំសបេសូបមា កាមា វុត្តា មយា ។បេ។ តិណុក្កូបមា កាមា វុត្តា មយា ។បេ។ អង្គារកាសូបមា កាមា វុត្តា មយា ។បេ។ សុបិនកូបមា កាមា វុត្តា មយា ។បេ។ យាចិតកូបមា កាមា វុត្តា មយា ។បេ។ រុក្ខផលូបមា កាមា វុត្តា មយា ។បេ។ អសិសូនូបមា



នោះមិនគួរធ្វើនូវសេចក្ដីអន្តរាយដល់អ្នកសេព ដោយប្រការណា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះឯង ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ មកពីអ្នកណា នែមោឃបុរស ធម៌ធ្វើសេចក្ដីអន្តរាយតថាគតសំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះសោតគួរធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពប្រាកដពិតមែន តថាគតសំដែងហើយថា កាមទាំងឡាយមានសេចក្ដីត្រេកអរតិច មានទុក្ខច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគ្រឿងឆ្អឹង ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងពីស្មៅ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្ដៅរងើកភ្លើង ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយការយល់សប្តិ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយ

កាមា វុត្តា មយា ។ បេ ។ សត្តិសូលូបមា កាមា
វុត្តា មយា ។ បេ ។ សប្បសិរូបមា កាមា វុត្តា មយា
ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អថ
ច បន ត្វំ មោឃបុរិស អត្តនា ទុគ្គហិតេន ទិដ្ឋិគតេន
អម្ហេ ចេវ អព្ភាចិក្ខសិ អត្តានញ្ច ខនសិ ពហុញ្ច
អបុញ្ញំ បសវសិ តញ្ហិ តេ មោឃបុរិស ភវិស្សតិ
ទីឃរត្តំ អហិតាយ ទុក្ខាយ នេតំ មោឃបុរិស
អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភា-
វាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ឯវំ វទេយ្យ តថាហំ
ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ
អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ
នាលំ អន្តរាយាយាតិ ។ សោ ភិក្ខុ ភិក្ខូហិ ឯវមស្ស
វចនីយោ មា អាយស្មា ឯវំ អវច មា ភគវន្តំ



មានឧបមាដោយគំនរឆ្អឹង ។ បេ ។ តថាគតសំដែងហើយថា
កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច ។ បេ ។ តថាគត
សំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខ
ច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយ
នេះមានច្រើន ម្នាលមោឃបុរស កាលបើហេតុមានយ៉ាងនេះ អ្នក
ឯងនៅតែពោលបង្កាច់យើងផង ជីកគាស់ខ្លួនឯងផង បានបាប
ច្រើនផង ដោយទិដ្ឋិដែលខ្លួនប្រកាន់ខុស ម្នាលមោឃបុរស ព្រោះថា
ទិដ្ឋិរបស់អ្នកឯងនោះ នឹងប្រព្រឹត្តទៅដើម្បីទោសមិនមែនជាប្រយោជន៍
ដើម្បីទុក្ខ អស់កាលជាអង្វែង ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យ
ជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យ
រឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ
គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយពោលយ៉ាង
នេះថា ធម៌ទាំងឡាយណាដែលថាធ្វើនូវសេចក្តីអន្តរាយដែលព្រះដ៏មាន
ព្រះភាគសំដែងហើយ ធម៌ទាំងឡាយនោះមិនអាចធ្វើនូវសេចក្តីអន្តរាយ
ដល់បុគ្គលអ្នកសេពទេ ដោយប្រការយ៉ាងណា ខ្ញុំដឹងច្បាស់នូវធម៌ដែល
ព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការយ៉ាងនោះ ។ ភិក្ខុនោះ
ពួកភិក្ខុទាំងឡាយគប្បីនិយាយប្រាប់យ៉ាងនេះថា លោកដ៏មានអាយុ លោកកុំ

អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាយាតិ ។ ឯវញ្ច[1] សោ ភិក្ខុ ភិក្ខូហិ វុច្ចមានោ តថេវ បគ្គណ្ហេយ្យ សោ ភិក្ខុ ភិក្ខូហិ យាវតតិយំ សមនុភាសិតព្វោ តស្ស បដិនិស្សគ្គាយ ។ យាវតតិយញ្ចេ សមនុភាសិយមានោ តំ បដិនិស្សជ្ជេយ្យ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជេយ្យ បាចិត្តិយន្តិ ។

[៦៨១] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ឯវំ វទេយ្យាតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។

១ ឱ. ម. ឯវញ្ចបន ។



កុំពោលយ៉ាងនេះឡើយ កុំពោលបន្លំព្រះដ៏មានព្រះភាគឡើយ ការពោលបន្លំព្រះដ៏មានព្រះភាគមិនល្អទេ ព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោ ធម៌ទាំងឡាយដែលធ្វើនូវសេចក្តីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយដ៏ច្រើន ធម៌ទាំងឡាយនោះអាចធ្វើនូវសេចក្តីអន្តរាយដល់អ្នកសេពមែន ។ ឯភិក្ខុនោះកាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះហើយ គង់នៅតែប្រកាន់យ៉ាងនោះដដែល ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈបីដង ដើម្បីឲ្យលះទិដ្ឋិនោះចេញ ។ បើភិក្ខុនោះ កាលភិក្ខុទាំងឡាយសូត្រសមនុភាសនកម្មអស់វារៈបីដង ហើយលះបង់នូវទិដ្ឋិនោះបាន ។ ការលះបង់បាននេះជាការល្អ បើភិក្ខុនោះមិនលះបង់ទេ ត្រូវអាបត្តិបាចិត្តិយ ។

[៦៨១] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃចុភនិកវគ្គ ។ ពាក្យថា ភិក្ខុនោះពោលយ៉ាងនេះ គឺភិក្ខុនោះពោលថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។

បាចិត្តិយកណ្ឌេ សប្បាណកវគ្គស្ស អដ្ឋមសិក្ខាបទស្ស សិក្ខាបទវិភង្គោ

[៤២៦] សោ ភិក្ខូតិ យោ សោ ឯវំវាទី ភិក្ខុ ។
តេហិ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ
សុណន្តិ តេហិ វត្តព្វោ មា អាយស្មា ឯវំ អវច មា
ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន
ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ
អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ
បដិសេវតោ អន្តរាយាយាតិ ។ ទុតិយម្បិ វត្តព្វោ
តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ
កុសលំ ។ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។
សុត្វា ន វទន្តិ អាបត្តិ ទុក្កដស្ស ។ សោ ភិក្ខុ
សង្ឃមជ្ឈម្បិ អាកឌ្ឍិត្វា វត្តព្វោ មា អាយស្មា ឯវំ
អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ
អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន
អាវុសោ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន



បាចិត្តិយកណ្ឌ សប្បាណកវគ្គ សិក្ខាបទទី ៨ សិក្ខាបទវិភង្គ

(៤២៦) ពាក្យថា ភិក្ខុនោះ គឺភិក្ខុដែលនិយាយយ៉ាងនេះនោះ
ឯង ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយដទៃ ។ ភិក្ខុទាំងឡាយ
ណាឃើញ ភិក្ខុទាំងឡាយណាឮ ភិក្ខុទាំងឡាយនោះត្រូវនិយាយនឹង
ភិក្ខុដែលមានទិដ្ឋិអាក្រក់នោះថា ម្នាលលោកដ៏មានអាយុ លោកកុំនិយាយ
យ៉ាងហ្នឹង កុំពោលបង្កាច់ព្រះដ៏មានព្រះភាគយ៉ាងហ្នឹង ការពោល
បង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះ
ទេ ម្នាលអាវុសោ ធម៌ទាំងឡាយធ្វើសេចក្តីអន្តរាយដែលព្រះដ៏មានព្រះ
ភាគសំដែងហើយដោយបរិយាយច្រើន ធម៌ទាំងឡាយនោះ អាច
ធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពមែន ។ ភិក្ខុទាំងឡាយត្រូវនិយាយ
ប្រដៅឲ្យភិក្ខុមានទិដ្ឋិអាក្រក់នោះអស់វារៈពីរដងផង ត្រូវនិយាយប្រដៅឲ្យ
អស់វារៈបីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះជាការល្អ
បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយឮហើយមិននិយាយ
ប្រដៅ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុទាំងឡាយត្រូវទាញភិក្ខុនោះមកកាន់ទី
កណ្តាលសង្ឃ ហើយនិយាយប្រដៅថា លោកដ៏មានអាយុ លោកកុំ
ពោលយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគ ការពោលបង្កាច់
ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះ
ទេ ម្នាលអាវុសោ ធម៌ទាំងឡាយតែងធ្វើសេចក្តីអន្តរាយព្រះដ៏មានព្រះភាគ

តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ អាបត្តិ ទុក្កដស្ស ។

[៤៩៣] សោ ភិក្ខុ ភិក្ខូហិ សមនុភាសិតព្វោ ។ ឯវញ្ច បន ភិក្ខវេ សមនុភាសិតព្វោ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ សោ តំ ទិដ្ឋឹ ន បដិនិស្សជ្ជតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសេយ្យ តស្សា ទិដ្ឋិយា បដិនិស្សគ្គាយ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស



សំដែងហើយដោយបរិយាយជាច្រើន ធម៌ទាំងឡាយនោះ កាលបើសេពគប់ អន្តរាយដល់អ្នកសេពមែន ។ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅភិក្ខុមានទិដ្ឋិគ្រាក់នោះអស់វារៈពីរដងផង ត្រូវនិយាយប្រដៅអស់វារៈបីដងផង ។ បើភិក្ខុនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើមិនលះបង់ទេ ត្រូវអាបត្តិទុក្កដ ។

[៤៩៣] ភិក្ខុនោះត្រូវភិក្ខុទាំងឡាយសូត្រសមនុភាសនកម្ម ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយត្រូវសូត្រសមនុភាសនកម្ម (ដល់ភិក្ខុមានទិដ្ឋិគ្រាក់) យ៉ាងនេះ ។ ភិក្ខុដែលឈ្លាសអាច ត្រូវឲ្យដឹងសង្ឃថា បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះមានទិដ្ឋិគ្រាក់មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុនោះ មិនលះបង់ទិដ្ឋិនោះ ។ បើកម្មមានកាលគួរដល់សង្ឃហើយ សង្ឃគប្បីសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះ ដើម្បីឲ្យលះបង់ទិដ្ឋិនោះ ។ នេះជាញត្តិ ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ

ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ សោ តំ ទិដ្ឋឹ នប្បដិ-និស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្សា ទិដ្ឋិយា បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា តស្សា ទិដ្ឋិយា បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទុតិយម្បិ ឯតមត្ថំ វទាមិ ។បេ។ តតិយម្បិ ឯតមត្ថំ វទាមិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ ឯវរូបំ បាបកំ ទិដ្ឋិ-គតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ សោ តំ



ភិក្ខុឈ្មោះនេះមានទិដ្ឋិដ៏អាក្រក់មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា គុណធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ គុណធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុនោះមិនលះបង់ទិដ្ឋិនោះ ។ (ឥឡូវនេះ) សង្ឃសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះដើម្បីឲ្យលះបង់ទិដ្ឋិនោះ ។ ការសូត្រសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះដើម្បីឲ្យលះបង់ទិដ្ឋិនោះគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈពីរដងផង ។បេ។ ខ្ញុំប្រកាសសេចក្តីនេះអស់វារៈបីដងផង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះមានទិដ្ឋិដ៏អាក្រក់មានសភាពយ៉ាងនេះកើតឡើង (ដូច្នេះ) ថា គុណធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ គុណធម៌ទាំងឡាយនោះមិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។ ភិក្ខុនោះ

ទិដ្ឋឹ នប្បដិនិស្សជ្ជតិ ។ សង្ឃោ ឥត្ថន្នាមំ ភិក្ខុំ សមនុភាសតិ តស្សា ទិដ្ឋិយា បដិនិស្សគ្គាយ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ សមនុភាសនា តស្សា ទិដ្ឋិយា បដិនិស្សគ្គាយ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ សមនុភដ្ឋោ សង្ឃេន ឥត្ថន្នាមោ ភិក្ខុ តស្សា ទិដ្ឋិយា បដិនិស្សគ្គាយ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

[៤៨៤] ញត្តិយា ទុក្កដំ ។ ទ្វីហិ កម្មវាចាហិ ទុក្កដា ។ កម្មវាចាបរិយោសានេ អាបត្តិ បាចិត្តិយស្ស ។

[៤៨៥] ធម្មកម្មេ ធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ នប្បដិនិស្សជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី នប្បដិនិស្សជ្ជតិ អាបត្តិ



មិនលះបង់ទិដ្ឋិនោះទេ ។ (សង្ឃគួរ) សង្ឃស្រែកសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះដើម្បីឲ្យលះបង់ទិដ្ឋិនោះហើយ ។ ការស្រែកសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះដើម្បីឲ្យលះបង់ទិដ្ឋិនោះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវនិយាយឡើង ។ សង្ឃស្រែកសមនុភាសនកម្មចំពោះភិក្ខុឈ្មោះនេះដើម្បីឲ្យលះបង់ទិដ្ឋិនោះហើយ ។ ការស្រែកសមនុភាសនកម្មនេះគួរដល់សង្ឃ ហេតុនោះសង្ឃស្ងៀម ។ ខ្ញុំចាំទុកនូវសេចក្ដីនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

[៤៨៤] ភិក្ខុត្រូវអាបត្តិទុក្កដ ក្នុងខណៈចប់ញត្តិ ។ ភិក្ខុត្រូវអាបត្តិទុក្កដពីរខ្សួយ ក្នុងខណៈចប់កម្មវាចាពីរ (លើក) ។ ភិក្ខុត្រូវអាបត្តិបាចិត្តិយ ក្នុងខណៈចប់កម្មវាចាស្រេច ។

[៤៨៥] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្ដីសង្ស័យ តែមិនលះបង់ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ តែមិនលះបង់ ត្រូវអាបត្តិ

បាចិត្តិយស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៤៨៦] អនាបត្តិ អសមនុភាសន្តស្ស បដិនិស្សជ្ជន្តស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។





បាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

[៤៨៦] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺ សង្ឃមិនសូត្រសមនុភាសនកម្ម ១ ភិក្ខុលះបង់ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់ ។

# នវមសិក្ខាបទំ

[៦៨៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ជានំ តថាវាទិនា អរិដ្ឋេន ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជន្តិបិ សំវសន្តិបិ សហាបិ សេយ្យំ កប្បេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជានំ តថាវាទិនា អរិដ្ឋេន ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជិស្សន្តិបិ សំវសិស្សន្តិបិ សហាបិ សេយ្យំ កប្បេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ តថាវាទិនា អរិដ្ឋេន ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជថាបិ សំវសថាបិ សហាបិ សេយ្យំ កប្បេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ជានំ

# សិក្ខាបទទី៩

[៦៨៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងហើយ បរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចសិរិយាបថដេករួមខ្លះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ មិនបានធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះចេញ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុដឹងហើយមិនគួរនឹងបរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចសិរិយាបថដេករួមខ្លះ ជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ ជាអ្នកមិនធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយដឹងហើយ បរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចសិរិយាបថដេករួមខ្លះជាមួយនឹងអរិដ្ឋភិក្ខុដែលនៅតែពោលយ៉ាងនោះ ជាអ្នកមិនបានធ្វើតាមធម៌ ជាអ្នកមិនលះបង់ទិដ្ឋិនោះ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់តិះបន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយដឹងហើយមិនគួរនឹង

តថាវាទិនា អរិដ្ឋេន ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជិស្សន្តិ សំវសិស្ស-ន្តិ សហាបិ សេយ្យំ កប្បេស្សន្តិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិ-សេយ្យាថ យោ បន ភិក្ខុ ជានំ តថាវាទិនា ភិក្ខុនា អកដានុធម្មេន តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ សម្ភុញ្ជេយ្យ វា សំវសេយ្យ វា សហ វា សេយ្យំ កប្បេយ្យ បាចិត្តិយន្តិ ។

[៦៨៨] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ តថាវាទិនាតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ឯវំវាទិនា ។



បរិភោគរួមខ្លះ នៅរួមខ្លះ សម្រេចសេយ្យាបថដេករួមខ្លះ ជាមួយនឹងអរិដ្ឋភិក្ខុ ដែលនៅតែពោលយ៉ាងនោះ មិនធ្វើតាមធម៌ មិនលះបង់ទិដ្ឋិនោះ ។ បេ ។ ឱមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងហើយ បរិភោគរួមក្តី នៅរួមក្តី សម្រេចសេយ្យាបថដេករួមក្តី ជាមួយនឹងភិក្ខុដែលមានប្រក្រតីពោលយ៉ាងនោះ ជាអ្នកមិនធ្វើតាមធម៌ ជាអ្នកមិនលះបង់ទិដ្ឋិនោះ ត្រូវអាបត្តិបាចិត្តិយ ។

[៦៨៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងបឋម-បារាជិក ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកភិក្ខុដទៃប្រាប់ភិក្ខុនោះក្តី ភិក្ខុមានទិដ្ឋិអាក្រក់នោះប្រាប់ក្តី ។ ពាក្យថា មានប្រក្រតីពោលយ៉ាងនោះ គឺនៅតែនិយាយយ៉ាងនេះថា ធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងហើយថា ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់អ្នកសេព ដោយប្រការណា ខ្ញុំដឹងច្បាស់នូវធម៌នោះដែលព្រះដ៏មានព្រះភាគសំដែងហើយ ដោយប្រការដូច្នោះ ។

អកដានុធម្មោ នាម ឧក្ខិត្តោ អនោសារិតោ ។ តំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធិន្តិ ឯតំ ទិដ្ឋឹ អប្បដិនិស្សដ្ឋេន សទ្ធឹ ។ សម្ភុញ្ជេយ្យ វាតិ សម្ភោគោ នាម ទ្វេ សម្ភោគា អាមិសសម្ភោគោ ច ធម្មសម្ភោគោ ច ។ អាមិសសម្ភោគោ នាម អាមិសំ ទេតិ វា បដិគ្គណ្ហាតិ វា អាបត្តិ បាចិត្តិយស្ស ។ ធម្មសម្ភោគោ នាម ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា ។ បទេន ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា បទេ បទេ អាបត្តិ បាចិត្តិយស្ស ។ អក្ខរាយ ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា អក្ខរក្ខរាយ អាបត្តិ បាចិត្តិយស្ស ។ សំវសេយ្យ វាតិ ឧក្ខិត្តកេន



ភិក្ខុណា ដែលសង្ឃលើកវត្ត[១] ហើយសង្ឃមិនបានហៅចូលពួកវិញ ភិក្ខុនោះហៅថាមិនធ្វើតាមធម៌ ។ ពាក្យថា ជាមួយនឹង(ភិក្ខុ) មិនលះបង់ទិដ្ឋិនោះ គឺជាមួយនឹង(ភិក្ខុ) ដែលមិនលះបង់នូវទិដ្ឋិនោះឲ្យដាច់ស្រឡះ ។ ពាក្យថា បរិភោគរួមក្តី[២] សេចក្តីថា ដែលហៅថាបរិភោគរួម គឺបរិភោគរួមមានពីរយ៉ាង បរិភោគរួមដោយអាមិសៈ១ បរិភោគរួមដោយធម៌១ ។ ដែលហៅថា បរិភោគរួមដោយអាមិសៈនោះគឺ ភិក្ខុឲ្យអាមិសៈ (ដល់ភិក្ខុនោះក្តី) ទទួលអាមិសៈអំពីភិក្ខុនោះក្តី ត្រូវអាបត្តិបាចិត្តិយ ។ ដែលហៅថា បរិភោគរួមដោយធម៌ គឺភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ)ក្តី ឲ្យ(ភិក្ខុនោះ) សំដែងធម៌ឲ្យស្តាប់ក្តី ។ ភិក្ខុសំដែងធម៌ (ដល់ភិក្ខុនោះ)ក្តី ឲ្យ(ភិក្ខុនោះ) សំដែងធម៌ឲ្យស្តាប់ក្តី ដោយបទ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗបទ ។ ភិក្ខុសំដែងធម៌(ដល់ភិក្ខុនោះ)ក្តី ឲ្យ(ភិក្ខុនោះ) សំដែងធម៌ឲ្យស្តាប់ក្តី ដោយអក្ខរៈ ត្រូវអាបត្តិបាចិត្តិយ គ្រប់ៗអក្ខរៈ ។ ពាក្យថា នៅរួមក្តី ភិក្ខុ

---

១ គឺភិក្ខុដែលសង្ឃលើកវត្តដោយបានសូត្រញត្តិចតុត្ថកម្ម ព្រោះភិក្ខុនោះមិនឃើញអាបត្តិ មិនសំដែងអាបត្តិ មិនលះបង់ទិដ្ឋិ ហៅថាភិក្ខុដែលសង្ឃលើកវត្ត ឯភិក្ខុនោះមិនត្រូវបរិភោគរួមនឹងសង្ឃឡើយ ។ សេចក្តីពិស្តារក្នុងកម្មក្ខន្ធកៈ គម្ពីរចុល្លវគ្គ ។ ២ បរិភោគក្នុងទីនេះសំដៅយកការសេពគប់ ។

សទ្ធឹ ឧបោសថំ វា បវារណំ វា សង្ឃកម្មំ វា ករោតិ អាបត្តិ បាចិត្តិយស្ស ។ សហ វា សេយ្យំ កប្បេយ្យាតិ ឯកច្ឆន្នេ ឧក្ខិត្តកេ និបន្នេ ភិក្ខុ និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ និបន្នេ ឧក្ខិត្តកោ និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ឧភោ វា និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។ ឧដ្ឋហិត្វា បុនប្បុនំ និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។

[២៥៨] ឧក្ខិត្តកេ ឧក្ខិត្តកសញ្ញី សម្ភុញ្ជតិ វា សំវសតិ វា សហ វា សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ ឧក្ខិត្តកេ វេមតិកោ សម្ភុញ្ជតិ វា សំវសតិ វា សហ វា សេយ្យំ កប្បេតិ អាបត្តិ ទុក្កដស្ស ។ ឧក្ខិត្តកេ អនុក្ខិត្តកសញ្ញី សម្ភុញ្ជតិ វា សំវសតិ វា សហ វា សេយ្យំ កប្បេតិ



ធ្វើឧបោសថក្តី បវារណាក្តី សង្ឃកម្មក្តី ជាមួយនឹងភិក្ខុដែលសង្ឃលើកវត្ត ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា សម្រេចសេយ្យាបថដេករួមក្តី គឺកាលបើភិក្ខុដែលសង្ឃលើកវត្តបានដេកហើយ ភិក្ខុក៏ដេកក្នុងទីបិទបាំងជាមួយគ្នា ត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុដេកហើយ ភិក្ខុដែលសង្ឃលើកវត្តក៏ដេកដែរ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ម្យ៉ាងភិក្ខុទាំងពីររូបដេក (ជាមួយគ្នា) ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រោកឡើងហើយដេកវិញញយៗ ត្រូវអាបត្តិបាចិត្តិយ ។

[២៥៨] ភិក្ខុដែលសង្ឃលើកវត្តហើយ ភិក្ខុសំគាល់ថាសង្ឃលើកវត្តហើយ បរិភោគរួមក្តី នៅរួមក្តី សម្រេចសេយ្យាបថដេករួមក្តី ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុដែលសង្ឃលើកវត្តហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយបរិភោគរួមក្តី នៅរួមក្តី សម្រេចសេយ្យាបថដេករួមក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលសង្ឃលើកវត្តហើយ ភិក្ខុសំគាល់ថាសង្ឃមិនបានលើកវត្តទេ ហើយបរិភោគរួមក្តី នៅរួមក្តី សម្រេចសេយ្យាបថដេករួមក្តី

អនាបត្តិ ។ អនុក្ខិត្តកេ ឧក្ខិត្តកសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុក្ខិត្តកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុក្ខិត្តកេ អនុក្ខិត្តកសញ្ញី អនាបត្តិ ។

(២៩០) អនាបត្តិ អនុក្ខិត្តោតិ ជានាតិ ឧក្ខិត្តោ ឱសារិតោតិ ជានាតិ ឧក្ខិត្តោ តំ ទិដ្ឋឹ បដិនិស្សដ្ឋោតិ ជានាតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។



មិនត្រូវអាបត្តិ ។ ភិក្ខុដែលសង្ឃមិនបានលើកវត្ត ភិក្ខុសំគាល់ថាសង្ឃលើកវត្តហើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលសង្ឃមិនលើកវត្ត ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុដែលសង្ឃមិនលើកវត្ត ភិក្ខុសំគាល់ថា សង្ឃមិនលើកវត្ត មិនត្រូវអាបត្តិ ។

(២៩០) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ ពួក) គឺភិក្ខុដឹងថា ភិក្ខុនោះសង្ឃមិនលើកវត្ត ១ ភិក្ខុដឹងថា ភិក្ខុដែលសង្ឃលើកវត្តហើយ ដែលសង្ឃបានសូត្រហៅចូលក្នុងវិញ ១ ភិក្ខុដឹងថា ភិក្ខុដែលសង្ឃលើកវត្តហើយ ។ បានលះបង់ទិដ្ឋិនោះចេញហើយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៩ ចប់ ។

## ទសមសិក្ខាបទំ

[៥៤១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន កណ្ឌកស្ស នាម សមណុទ្ទេសស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អស្សោសុំ ខោ សម្ពហុលា ភិក្ខូ កណ្ឌកស្ស នាម កិរ សមណុទ្ទេសស្ស ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ អថខោ តេ ភិក្ខូ យេន កណ្ឌកោ សមណុទ្ទេសោ តេនុបសង្កមឹសុ ឧបសង្កមិត្វា កណ្ឌកំ សមណុទ្ទេសំ ឯតទវោចុំ សច្ចំ កិរ តេ អាវុសោ កណ្ឌក ឯវរូបំ

## សិក្ខាបទទី ១០

[៥៤១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះ ឯសមណុទ្ទេស(១) ឈ្មោះកណ្ឌកៈ មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ថា) ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ ធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពបានទេ ។ ភិក្ខុជាច្រើនបានឮដំណឹងថា សមណុទ្ទេសឈ្មោះកណ្ឌកៈ មានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង (ថា) ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគសំដែងហើយ ធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគ សំដែងថាជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ លំដាប់នោះ ភិក្ខុទាំងឡាយនោះចូលទៅរកសមណុទ្ទេស ឈ្មោះកណ្ឌកៈ លុះចូលទៅហើយបាននិយាយពាក្យនេះនឹងកណ្ឌកសមណុទ្ទេសថា នែអាវុសោកណ្ឌកៈ ឮថា

---

(១) សមណុទ្ទេស ជាពាក្យចាស់ៗ ប្រើសំរាប់ហៅសាមណេរ នឹងហៅថាសមណុទ្ទេសក៏បាន ហៅសាមណេរក៏បាន ។

បាបកំ ទិដ្ឋិគតំ ឧប្បន្នំ ហោតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ មា អាវុសោ អរិដ្ឋ ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ អរិដ្ឋ អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា ភគវតា ។ បេ ។



អ្នកឯងមានទិដ្ឋិអាក្រក់មានសភាពយ៉ាងនេះកើតឡើង (ពិតឬ)ថា ខ្ញុំដឹងច្បាស់នូវធម៌ ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងថាជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយ ដល់បុគ្គលអ្នកសេពទេ ពិតមែនឬ ។ [illegible]ឡើងថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំករុណាដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងយ៉ាងនេះថា ធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគ សំដែងថាជាធម៌ធ្វើសេចក្តីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពពិតមែន ។ ភិក្ខុទាំងឡាយនិយាយថា ម្នាលអាវុសោអរិដ្ឋៈ អ្នកកុំនិយាយយ៉ាងនេះឡើយ កុំចោទប្រកាន់ព្រះដ៏មានព្រះភាគឡើយ ការចោទប្រកាន់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រះដ៏មានព្រះភាគ មិនបានត្រាស់យ៉ាងនេះទេ ម្នាលអាវុសោអរិដ្ឋៈ ធម៌ទាំងឡាយធ្វើសេចក្តីអន្តរាយ ដែលព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយដ៏ច្រើន ធម៌ទាំងឡាយនោះអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេពពិតមែន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានសេចក្តីស្រួលតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង ។ បេ ។

មំសបេសូបមា កាមា វុត្តា ភគវតា ។ បេ ។ តិណុក្កូបមា កាមា វុត្តា ភគវតា ។ បេ ។ អង្គារកាសូបមា កាមា វុត្តា ភគវតា ។ បេ ។ សុបិនកូបមា កាមា វុត្តា ភគវតា ។ បេ ។ យាចិតកូបមា កាមា វុត្តា ភគវតា ។ បេ ។ រុក្ខផលូបមា កាមា វុត្តា ភគវតា ។ បេ ។ អសិសូនូបមា កាមា វុត្តា ភគវតា ។ បេ ។ សត្តិសូលូបមា កាមា វុត្តា ភគវតា ។ បេ ។ សប្បសិរូបមា កាមា វុត្តា ភគវតា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោតិ ។ ឯវំបិ ខោ កណ្ដកោ សមណុទ្ទេសោ តេហិ ភិក្ខូហិ វុច្ចមានោ តថេវ តំ បាបកំ ទិដ្ឋិគតំ ថាមសា បរាមាសា អភិនិវិស្ស វោហរតិ ឯវំ ព្យា ខោ អហំ ភគវតា ធម្មំ ទេសិតំ



ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើង ដែលធ្វើដោយស្មៅ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្តិ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ ។ បេ ។ ព្រះដ៏មានព្រះភាគ សំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងជ្រញ់ ។ បេ ។ ព្រះដ៏មានព្រះភាគ សំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច ។ បេ ។ ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន ។ សមណុទ្ទេសឈ្មោះកណ្ដកៈកាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះ គឺនៅប្រកាន់ទិដ្ឋិអាក្រក់នោះដោយសេចក្តីប្រកាន់មាំ ហើយពោលយ៉ាងនោះដដែលថា បពិត្រលោកដ៏ចំរើន ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគ សំដែងហើយយ៉ាងនេះថា ធម៌ទាំងឡាយណា

អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ យតោ ខោ តេ ភិក្ខូ នាសក្ខឹសុ កណ្ដកំ សមណុទ្ទេសំ ឯតស្មា បាបកា ទិដ្ឋិគតា វិវេចេតុំ អថខោ តេ ភិក្ខូ យេន ភគវា តេនុបសង្កមឹសុ ឧបសង្កមិត្វា ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ភិក្ខុសង្ឃំ សន្និបាតាបេត្វា កណ្ដកំ សមណុទ្ទេសំ បដិបុច្ឆិ សច្ចំ កិរ តេ កណ្ដក ឯវរូបំ បាបកំ ទិដ្ឋិគតំ ឧប្បន្នំ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ កស្ស នុ ខោ នាម ត្វំ មោឃបុរិស មយា ឯវំ ធម្មំ ទេសិតំ



ដែលព្រះដ៏មានព្រះភាគសំដែងហើយថាជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ ។ ភិក្ខុទាំងឡាយនោះ មិនអាចនឹងដោះសមណុទ្ទេសឈ្មោះកណ្ដកៈចេញពីទិដ្ឋិអាក្រក់នោះបានក្នុងកាលណា ភិក្ខុទាំងឡាយនោះ ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងកាលនោះ លុះចូលទៅហើយ ក្រាបទូលសេចក្ដីនុ៎ះដល់ព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគឲ្យប្រជុំភិក្ខុសង្ឃហើយ ត្រាស់សួរចំពោះកណ្ដកសមណុទ្ទេសក្នុងកាលនោះថា នែកណ្ដកៈ ឮថាអ្នកឯងមានទិដ្ឋិអាក្រក់ មានសភាពយ៉ាងនេះកើតឡើង(ដូច្នេះ)ថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ ពិតមែនឬ ។ កណ្ដកសមណុទ្ទេសនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយយ៉ាងនេះថា ធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងហើយថាជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌ដែលតថាគតសំដែងហើយយ៉ាងនេះ

អាជានាសិ ននុ មយា មោឃបុរិស អនេកបរិយាយេន អន្តរាយិកា ធម្មា វុត្តា អលញ្ច បន តេ បដិសេវតោ អន្តរាយាយ អប្បស្សាទា កាមា វុត្តា មយា ពហុទុក្ខា ពហុបាយាសា អាទីនវោ ឯត្ថ ភិយ្យោ អដ្ឋិកង្កលូបមា កាមា វុត្តា មយា ។បេ។ មំសបេសូបមា កាមា វុត្តា មយា ។បេ។ តិណុក្កូបមា កាមា វុត្តា មយា ។បេ។ អង្គារកាសូបមា កាមា វុត្តា មយា ។បេ។ សុបិនកូបមា កាមា វុត្តា មយា ។បេ។ យាចិតកូបមា កាមា វុត្តា មយា ។បេ។ រុក្ខផលូបមា កាមា វុត្តា មយា ។បេ។ អសិសូនូបមា កាមា វុត្តា មយា ។បេ។ សត្តិសូលូបមា កាមា វុត្តា មយា ។បេ។ សប្បសិរូបមា កាមា វុត្តា មយា ពហុទុក្ខា ពហុ-



តាំងពីបុគ្គលណាមក នែមោឃបុរស ធម៌ទាំងឡាយដែលធ្វើសេចក្តីអន្តរាយ តថាគតសំដែងហើយដោយបរិយាយច្រើន ក៏ធម៌ទាំងឡាយនោះអាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព (មែន) តថាគតសំដែងហើយថា កាមទាំងឡាយមានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរាងឆ្អឹង ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយដុំសាច់ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយគប់ភ្លើងធ្វើដោយស្មៅ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរណ្តៅរងើកភ្លើង ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយអ្នកយល់សប្តិ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយរបស់ដែលខ្ចីគេ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយផ្លែឈើ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយកាំបិតនិងទីជ្រញ់ ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយលំពែងនិងដែកស្រួច ។បេ។ តថាគតសំដែងហើយថា កាមទាំងឡាយមានឧបមាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន

បាយាសា អាទីនវោ ឯត្ថ ភិយ្យោ អថ ច បន ត្វំ មោឃបុរិស អត្តនា ទុគ្គហិតេន ទិដ្ឋិគតេន អម្ហេ ចេវ អព្ភាចិក្ខសិ អត្តានញ្ច ខណសិ ពហុញ្ច អបុញ្ញំ បសវសិ តំ ហិ តេ មោឃបុរិស ភវិស្សតិ ទីឃរត្តំ អហិតាយ ទុក្ខាយ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ អថខ្វេតំ មោឃបុរិស អប្បសន្នានញ្ចេវ អប្បសាទាយ បសន្នានញ្ច ឯកច្ចានំ អញ្ញថត្តាយាតិ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ សង្ឃោ កណ្ដកំ សមណុទ្ទេសំ នាសេតុ ឯវញ្ច បន ភិក្ខវេ នាសេតព្វោ អជ្ជតគ្គេ



ទោសក្នុងកាមទាំងឡាយនេះមានច្រើន នែមោឃបុរស កាលបើដូច្នោះហើយ អ្នកឯងនៅតែពោលបង្កាច់យើងផង គាស់គាយខ្លួនឯងផង សោយបាបជាច្រើនផង ព្រោះទិដ្ឋិដែលខ្លួនកាន់យកខុស នែមោឃបុរស ទិដ្ឋិដែលអ្នកឯងកាន់យកតាក្រាំនោះ នឹងបង្កសេចក្ដីមិនជាប្រយោជន៍ ជាទុក្ខដល់អ្នកឯង អស់កាលជាអង្វែង នែមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ម្នាលមោឃបុរស ទង្វើអាក្រក់របស់អ្នកនេះនាំតែនាំមិនឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាផង ដើម្បីសេចក្ដីក្លាយដល់មនុស្សពួកខ្លះដែលជ្រះថ្លាហើយផង ។ ព្រះដ៏មានព្រះភាគបន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ សង្ឃចូរញុំាងកណ្ដកសមណុទ្ទេសឲ្យវិនាសចុះ[១] ម្នាលភិក្ខុទាំងឡាយ កណ្ដកសមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវឲ្យវិនាសយ៉ាងនេះថា នែអាវុសោកណ្ដកៈ កាលមាន

---

១ អដ្ឋកថា ថាវិនាសនោះមាន ៣ យ៉ាង គឺ សំវាសនាសនា វិនាសដោយការនៅរួមជាមួយនឹងសង្ឃ ១ លិង្គនាសនា វិនាសភេទ គឺត្រូវផ្សឹកចេញ ១ ទណ្ឌកម្មនាសនា វិនាសដោយត្រូវទណ្ឌកម្ម ហាមមិនឲ្យសេពគប់ជាមួយនឹងភិក្ខុអស់ពីរបីរាត្រីជាដើម ១ កណ្ដកៈនេះត្រូវទណ្ឌកម្មនាសនា ។

តេ អាវុសោ កណ្ឌក ន ចេវ សោ ភគវា សត្ថា អប-ទិសិតព្វោ យម្បិ ចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទិរត្តតិរត្តំ សហសេយ្យំ សាបិ តេ នត្ថិ ចរ បិរេ[១] វិនស្សាតិ ។ អថខោ សង្ឃោ កណ្ឌកំ សមណុទ្ទេសំ នាសេសិ ។

[៦៤២] តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ជានំ តថានាសិតំ កណ្ឌកំ សមណុទ្ទេសំ ឧបលាបេន្តិបិ ឧបដ្ឋាបេន្តិបិ សម្ភុញ្ជន្តិបិ សហាបិ សេយ្យំ កប្បេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជានំ តថានាសិតំ កណ្ឌកំ សមណុទ្ទេសំ ឧបលាបេស្សន្តិបិ ឧបដ្ឋាបេស្សន្តិបិ សម្ភុញ្ជិស្សន្តិបិ សហាបិ សេយ្យំ កប្បេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ តថានាសិតំ កណ្ឌកំ សមណុទ្ទេសំ ឧបលាបេថាបិ ឧបដ្ឋាបេថាបិ សម្ភុញ្ជថាបិ សហាបិ សេយ្យំ កប្បេថាតិ ។ សច្ចំ ភគវាតិ ។

១ បិរេតិ បរ អមាមកាតិ វណ្ណនា ។



ថ្ងៃនេះជាដើម អ្នកឯងមិនត្រូវអាងព្រះដ៏មានព្រះភាគអង្គនោះថាជាសាស្តា របស់អ្នកឡើយ សមណុទ្ទេសដទៃទៀតដែលបាននូវកិរិយាដេករួម ឯណា អស់រាត្រីពីរនឹងរាត្រីបីជាមួយនឹងភិក្ខុទាំងឡាយ កិរិយាដេករួមនោះមិនមានដល់អ្នកទេ វៃមនុស្សក្រៅការ អ្នកឯងចូរចៀសចេញទៅ អ្នកចូរវិនាសទៅ ។ ក្នុងកាលនោះឯង សង្ឃបានឲ្យកណ្ឌកសមណុទ្ទេស វិនាសហើយ ។

[៦៤៦] សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដឹងថា កណ្ឌកសមណុទ្ទេសសង្ឃឲ្យវិនាសហើយនោះហើយ បញ្ចុះបញ្ចូលខ្លះ ឲ្យបម្រើខ្លះ បរិភោគរួមខ្លះ សម្រេចកិរិយាដេករួមខ្លះ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្ទោសថា ពួកឆព្វគ្គិយភិក្ខុដឹងថា កណ្ឌកសមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយនោះហើយ មិនគួរនឹងបញ្ចុះបញ្ចូលខ្លះ ឲ្យបម្រើខ្លះ បរិភោគរួមខ្លះ សម្រេចកិរិយាដេករួមខ្លះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយដឹងថា កណ្ឌកសមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយនោះហើយ បញ្ចុះបញ្ចូលខ្លះ ឲ្យបម្រើខ្លះ បរិភោគរួមខ្លះ សម្រេចកិរិយាដេករួមខ្លះ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។

វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម តុម្ហេ មោឃបុរិសា ជានំ តថានាសិតំ កណ្ដកំ សមណុទ្ទេសំ ឧបលាបេស្សថ ឧបដ្ឋាបេស្សថ សម្ភុញ្ជិស្សថ សហាបិ សេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ សមណុទ្ទេសោបិ ចេ ឯវំ វទេយ្យ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។ សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ មា អាវុសោ សមណុទ្ទេស ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ សមណុទ្ទេស អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាយាតិ ។ ឯវញ្ច សោ សមណុទ្ទេសោ ភិក្ខូហិ





ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយដឹងថា កណ្ដកសមណុទ្ទេសដែលសង្ឃឲ្យវិនាស យ៉ាងនោះហើយ មិនគួរនឹងបញ្ចុះបញ្ចូល ឲ្យបម្រើ បរិភោគរួម សម្រេចឥរិយាបថដេករួមផង ម្នាលមោឃបុរសទាំងឡាយ អំពើនុ៎ះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា បើសមណុទ្ទេសពោលយ៉ាងនេះថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគ សំដែងហើយថាជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុទ្ទេស អ្នកឯងកុំនិយាយយ៉ាងនេះឡើយ អ្នកកុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោសមណុទ្ទេស ធម៌ទាំងឡាយធ្វើសេចក្ដីអន្តរាយដែលព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយដ៏ច្រើន ធម៌ទាំងឡាយនោះអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេព (ពិត) ។ សមណុទ្ទេសនោះកាលដែលភិក្ខុ

វុច្ចមានោ តថេវ បគ្គណ្ហេយ្យ សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ អជ្ជតគ្គេ តេ អាវុសោ សមណុទ្ទេស ន ចេវ សោ ភគវា សត្ថា អបទិសិតព្វោ យម្បិចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទិរត្តតិរត្តំ សហសេយ្យំ សាបិ តេ នត្ថិ ចរ បិរេ វិនស្សាតិ ។ យោ បន ភិក្ខុ ជានំ តថានាសិតំ សមណុទ្ទេសំ ឧបលាបេយ្យ វា ឧបដ្ឋាបេយ្យ វា សម្ភុញ្ជេយ្យ វា សហ វា សេយ្យំ កប្បេយ្យ បាចិត្តិយន្តិ ។

[៦៩៣] សមណុទ្ទេសោ នាម សាមណេរោ វុច្ចតិ ។ ឯវំ វទេយ្យាតិ តថាហំ ភគវតា ធម្មំ ទេសិតំ អាជានាមិ យថា យេមេ អន្តរាយិកា ធម្មា វុត្តា ភគវតា តេ បដិសេវតោ នាលំ អន្តរាយាយាតិ ។

[៦៩៤] សោ សមណុទ្ទេសោតិ យោ សោ ឯវំវាទី សមណុទ្ទេសោ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ យេ បស្សន្តិ យេ សុណន្តិ តេហិ វត្តព្វោ មា



ទាំងឡាយពោលយ៉ាងនេះហើយ គង់នៅតែប្រកាន់ដដែល សមណុទ្ទេសនោះភិក្ខុទាំងឡាយត្រូវនិយាយប្រដៅយ៉ាងនេះថា នែអាវុសោសមណុទ្ទេស តាំងអំពីថ្ងៃនេះទៅ អ្នកមិនត្រូវអាងព្រះដ៏មានព្រះភាគនោះ ថាជាសាស្ដារបស់អ្នកឡើយ សាមណេរទាំងឡាយដទៃនូវតែបាននូវការដេករួមចំណោមអស់ពីរបីរាត្រី ជាមួយនឹងភិក្ខុទាំងឡាយ ការដេករួម នោះ មិនមានដល់អ្នកទេ នែមនុស្សទ្រគោះ អ្នកចូរចៀសចេញទៅ ចូរវិនាសទៅ ។ ភិក្ខុណាមួយដឹងថា សមណុទ្ទេសដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ បញ្ចុះបញ្ចូលក្ដី ឲ្យបម្រើក្ដី បរិភោគរួមក្ដី សម្រេចសំរាបជាប់ដេករួមក្ដី ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៦៩៣] ដែលហៅថា សមណុទ្ទេស គឺសំដៅយកសាមណេរ ។ ពាក្យថា ពោលយ៉ាងនេះ គឺពោលថា ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយណា ដែលព្រះដ៏មានព្រះភាគសំដែងថាជាធម៌ធ្វើសេចក្ដីអន្តរាយ ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពទេ ។

[៦៩៤] ពាក្យថា សមណុទ្ទេសនោះ គឺសមណុទ្ទេសដែលជាអ្នកពោលយ៉ាងនេះនោះឯង ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយដទៃ ។ ភិក្ខុទាំងឡាយណាឃើញ ភិក្ខុទាំងឡាយណាឮ ភិក្ខុ

អាវុសោ សមណុទ្ទេស ឯវំ អវច មា ភគវន្តំ អព្ភាចិក្ខិ ន ហិ សាធុ ភគវតោ អព្ភក្ខានំ ន ហិ ភគវា ឯវំ វទេយ្យ អនេកបរិយាយេន អាវុសោ សមណុទ្ទេស អន្តរាយិកា ធម្មា វុត្តា ភគវតា អលញ្ច បន តេ បដិសេវតោ អន្តរាយាយាតិ ។ ទុតិយម្បិ វត្តព្វោ តតិយម្បិ វត្តព្វោ ។ សចេ បដិនិស្សជ្ជតិ ឥច្ចេតំ កុសលំ នោ ចេ បដិនិស្សជ្ជតិ សោ សមណុទ្ទេសោ ភិក្ខូហិ ឯវមស្ស វចនីយោ អជ្ជតគ្គេ តេ អាវុសោ សមណុទ្ទេស ន ចេវ សោ ភគវា សត្ថា អបទិសិតព្វោ យម្បិចញ្ញេ សមណុទ្ទេសា លភន្តិ ភិក្ខូហិ សទ្ធឹ ទិរត្តតិរត្តំ សហសេយ្យំ សាបិ តេ នត្ថិ ចរ បិរេ វិនស្សាតិ ។

[៤៨៩] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា



ទាំងឡាយនោះត្រូវពោលនឹងសមណុទ្ទេសនោះថា នែអាវុសោសមណុទ្ទេស អ្នកកុំពោលយ៉ាងនេះឡើយ កុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ការពោលបង្កាច់ព្រះដ៏មានព្រះភាគមិនសមគួរប្រយោជន៍ទេ ព្រោះព្រះដ៏មានព្រះភាគមិនពោលយ៉ាងនេះទេ នែអាវុសោសមណុទ្ទេស ធម៌ទាំងឡាយ ដែលធ្វើសេចក្តីអន្តរាយ ព្រះដ៏មានព្រះភាគសំដែងហើយដោយបរិយាយដ៏ច្រើន ធម៌ទាំងឡាយនោះ អាចធ្វើសេចក្តីអន្តរាយដល់បុគ្គលអ្នកសេព (មែន) ។ សមណុទ្ទេសនោះភិក្ខុទាំងឡាយត្រូវពោលអស់វារៈពីរដងផង ត្រូវពោលអស់វារៈបីដងផង ។ បើសមណុទ្ទេសនោះលះបង់បាន ការលះបង់បាននេះជាការល្អ បើលះបង់មិនបានទេ សមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវនិយាយយ៉ាងនេះថា នែអាវុសោសមណុទ្ទេស តាំងពីថ្ងៃនេះទៅ អ្នកមិនត្រូវអាងព្រះដ៏មានព្រះភាគនោះថាជាសាស្តារបស់អ្នកឡើយ សមណុទ្ទេសទាំងឡាយដទៃទៀតបានការដេកនៅរួមដំណេកអស់ត្រឹមពីរទិវាត្រឹមបីជាមួយនឹងភិក្ខុទាំងឡាយ ការដេកនៅរួមនោះមិនមានដល់អ្នកទេ នែមនុស្សអាក្រក់ អ្នកចូរចៀសចេញទៅ ចូរវិនាសទៅ ។

[៤៨៩] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃមុសាវាទវគ្គ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី

តស្ស អារោចេន្តិ សោ វា អារោចេតិ ។ តថានាសិតន្តិ ឯវំ នាសិតំ ។ សមណុទ្ទេសោ នាម សាមណេរោ វុច្ចតិ ។ ឧបលាបេយ្យាតិ តស្ស បត្តំ វា ចីវរំ វា ឧទ្ទេសំ វា បរិបុច្ឆំ វា ទស្សាមីតិ ឧបលាបេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបដ្ឋាបេយ្យាតិ តស្ស ចុណ្ណំ វា មត្តិកំ វា ទន្តកដ្ឋំ វា មុខោទកំ វា សាទិយតិ អាបត្តិ បាចិត្តិយស្ស ។ សម្ភុញ្ជេយ្យាតិ សម្ភោគោ នាម ទ្វេ សម្ភោគា អាមិសសម្ភោគោ ច ធម្មសម្ភោគោ ច ។ អាមិសសម្ភោគោ នាម អាមិសំ ទេតិ វា បដិគ្គណ្ហាតិ វា អាបត្តិ បាចិត្តិយស្ស ។ ធម្មសម្ភោគោ នាម ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា ។ បទេន ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា បទេ បទេ អាបត្តិ បាចិត្តិយស្ស ។ អក្ខរាយ ឧទ្ទិសតិ វា ឧទ្ទិសាបេតិ វា អក្ខរក្ខរាយ អាបត្តិ បាចិត្តិយស្ស ។ សហ វា សេយ្យំ កប្បេយ្យាតិ ឯកច្ឆន្នេ នាសិតកេ សមណុទ្ទេសេ និបន្នេ ភិក្ខុ និបជ្ជតិ



អ្នកដទៃទៀតប្រាប់ភិក្ខុនោះក្តី ឬសមណុទ្ទេសនោះប្រាប់ក្តី ។ ពាក្យថា ដែលសង្ឃឲ្យវិនាសយ៉ាងនោះហើយ គឺសង្ឃឲ្យវិនាសយ៉ាងនេះហើយ ។ ដែលហៅថា សមណុទ្ទេស គឺសាមណេរ ។ ពាក្យថា បញ្ចុះបញ្ចូលក្តី គឺភិក្ខុបញ្ចុះបញ្ចូលដោយគិតថា អាត្មានឹងឲ្យបាត្រក្តី ចីវរក្តី ឧទ្ទេសក្តី បរិបុច្ឆាក្តី ដល់សមណុទ្ទេសនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ឲ្យបម្រើក្តី គឺភិក្ខុត្រេកអរនឹងគ្រឿងលំអិតក្តី ដីស្អិតក្តី ឈើស្ទន់ក្តី ទឹកខ្ពុរមាត់ក្តី របស់សមណុទ្ទេសនោះ ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា បរិភោគរួមក្តី គឺបរិភោគរួមមាន ២ គឺ បរិភោគរួមដោយអាមិសៈ ១ បរិភោគរួមដោយធម៌ ១ ហៅថាបរិភោគរួម ។ ដែលហៅថាបរិភោគរួមដោយអាមិសៈ គឺភិក្ខុឲ្យអាមិសៈក្តី ទទួលក្តី ត្រូវអាបត្តិបាចិត្តិយ ។ ដែលហៅថា បរិភោគរួមដោយធម៌ គឺភិក្ខុសំដែងធម៌ដល់សមណុទ្ទេសនោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ។ ភិក្ខុសំដែងធម៌ដល់សមណុទ្ទេសនោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ដោយបទ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ៗ បទ ។ ភិក្ខុសំដែងធម៌ដល់សមណុទ្ទេសនោះក្តី ឲ្យសមណុទ្ទេសនោះសំដែងឲ្យស្តាប់ក្តី ដោយអក្សរ ត្រូវអាបត្តិបាចិត្តិយ គ្រប់ ៗ អក្សរ ។ ពាក្យថា សម្រេចកិរិយាដេករួមក្តី គឺកាលបើសមណុទ្ទេសដែលសង្ឃឲ្យវិនាសនោះដេកហើយ ភិក្ខុក៏ដេកក្នុងទីបិទបាំង

អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុ និបន្នេ នាសិតកោ សមណុទ្ទេសោ និបជ្ជតិ អាបត្តិ បាចិត្តិយស្ស ។ ឧភោ វា និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។ ឧដ្ឋហិត្វា បុនប្បុនំ និបជ្ជន្តិ អាបត្តិ បាចិត្តិយស្ស ។

[៤៩៦] នាសិតកេ នាសិតកសញ្ញី ឧបលាបេតិ វា ឧបដ្ឋាបេតិ វា សម្ភុញ្ជតិ វា សហ វា សេយ្យំ កប្បេតិ អាបត្តិ បាចិត្តិយស្ស ។ នាសិតកេ វេមតិកោ ឧបលាបេតិ វា ឧបដ្ឋាបេតិ វា សម្ភុញ្ជតិ វា សហ វា សេយ្យំ កប្បេតិ អាបត្តិ ទុក្កដស្ស ។ នាសិតកេ អនាសិតកសញ្ញី ឧបលាបេតិ វា ឧបដ្ឋាបេតិ វា សម្ភុញ្ជតិ វា សហ វា សេយ្យំ កប្បេតិ អនាបត្តិ ។ អនាសិតកេ នាសិតកសញ្ញី អាបត្តិ ទុក្កដស្ស ។ អនាសិតកេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនាសិតកេ អនាសិតកសញ្ញី អនាបត្តិ ។



ជាមួយ ត្រូវអាបត្តិបាចិត្តិយ ។ កាលបើភិក្ខុដេកហើយ សមណុទ្ទេសដែលសង្ឃឲ្យវិនាសក៏ដេកទៅ (ដែរ) ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ឬដេកទាំងពីរនាក់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រោកឡើងហើយ ដេកញយ ៗ ត្រូវអាបត្តិបាចិត្តិយ ។

[៤៩៦] សមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយ ភិក្ខុសំគាល់ថាសង្ឃឲ្យវិនាសហើយ ១ បញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី ត្រូវអាបត្តិបាចិត្តិយ ។ សមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយបញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី ត្រូវអាបត្តិទុក្កដ ។ សមណុទ្ទេសដែលសង្ឃឲ្យវិនាសហើយ ភិក្ខុសំគាល់ថាសង្ឃមិនបានឲ្យវិនាសទៅវិញហើយ ១ បញ្ចុះបញ្ចូលក្តី ឲ្យបម្រើក្តី បរិភោគរួមក្តី សម្រេចកិរិយាដេករួមក្តី មិនត្រូវអាបត្តិ ។ សមណុទ្ទេសដែលសង្ឃមិនឲ្យវិនាស ភិក្ខុសំគាល់ថាសង្ឃឲ្យវិនាស ត្រូវអាបត្តិទុក្កដ ។ សមណុទ្ទេសដែលសង្ឃមិនឲ្យវិនាស ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ សមណុទ្ទេសដែលសង្ឃមិនឲ្យវិនាស ភិក្ខុសំគាល់ថាសង្ឃមិនឲ្យវិនាស មិនត្រូវអាបត្តិ ។

បាចិត្តិយកណ្ឌេ សប្បាណកវគ្គស្ស ទសមសិក្ខាបទស្ស អនាបត្តិវារោ

(៤៩៧) អនាបត្តិ អនាសិតកោ ហោតិ ជានាតិ តំ ទិដ្ឋឹ បដិនិស្សដ្ឋោតិ ជានាតិ ឧម្មត្តកស្ស អាទិកម្មិ-កស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

សប្បាណកវគ្គោ សត្តមោ ។

តស្សុទ្ទានំ

សញ្ចិច្ចវធសប្បាណំ ឧក្កោដទុដ្ឋុល្លឆាទនំ

ឩនវីសតិ សត្ថញ្ច សំវិធានរិដ្ឋកំ

ឧក្ខិត្តកណ្ដកញ្ចេវ ទស សិក្ខាបទា ឥមេតិ ។



បាចិត្តិយកណ្ឌ សប្បាណកវគ្គ សិក្ខាបទទី ១០ វារៈនៃសេចក្តីមិនត្រូវអាបត្តិ

(៤៩៧) វារៈមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុដឹងថា សមណុទ្ទេសនោះសង្ឃមិនបានឲ្យវិនាស ១ ភិក្ខុដឹងថាសមណុទ្ទេសនោះលះបង់ទិដ្ឋិនោះហើយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១០ ចប់ ។

សប្បាណកវគ្គទី ៧ ចប់ ។

## ឧទ្ទាននៃសប្បាណកវគ្គនោះ មាន ១០ សិក្ខាបទនេះគឺ

សញ្ចិច្ចសិក្ខាបទ ១ សប្បាណសិក្ខាបទ ១

ឧក្កោដសិក្ខាបទ ១ ទុដ្ឋុល្លឆាទនសិក្ខាបទ ១

ឩនវីសតិសិក្ខាបទ ១ សត្ថសិក្ខាបទ ១

សំវិធានសិក្ខាបទ ១ អរិដ្ឋកសិក្ខាបទ ១

ឧក្ខិត្តសិក្ខាបទ ១ កណ្ដកសិក្ខាបទ ១ ។

## សហធម្មិកវគ្គស្ស បឋមសិក្ខាបទំ

[៥៩៨] តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា ឆន្នោ អនាចារំ អាចរតិ ។ ភិក្ខូ ឯវមាហំសុ មា អាវុសោ ឆន្ន ឯវរូបំ អកាសិ នេតំ កប្បតីតិ ។ សោ ឯវំ វទេតិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា ឆន្នោ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ ឯវំ វក្ខតិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ ។បេ។ សច្ចំ កិរ ត្វំ ឆន្ន ភិក្ខូហិ សហធម្មិកំ វុច្ចមានោ ឯវំ វទេសិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ ។

## សហធម្មិកវគ្គ សិក្ខាបទទី ១

[៥៩៨] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅ ឃោសិតារាម ទៀបក្រុងកោសម្ពី ។ សម័យនោះឯង ឆន្នៈដ៏មានអាយុ តែងប្រព្រឹត្តអនាចារ ។ ភិក្ខុទាំងឡាយ និយាយយ៉ាងនេះថា នែអាវុសោឆន្នៈ អ្នកកុំធ្វើកម្មមានសភាពយ៉ាងនេះ កម្មដែលអ្នកធ្វើនេះ មិនគួរទេ ។ ឆន្នភិក្ខុនោះនិយាយយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់សាកសួរភិក្ខុដទៃ ដែលឈ្លាសវៃដែលទ្រទ្រង់វិន័យ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្ទោសថា ឆន្នៈដ៏មានអាយុ កាលបើភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ មិនគួរនឹងពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្លាសវៃដែលទ្រទ្រង់វិន័យនៅឡើយ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលឆន្នៈ ឮថា អ្នកឯងកាលបើភិក្ខុទាំងឡាយពោលពាក្យប្រកបដោយធម៌ និយាយ (នឹងភិក្ខុទាំងឡាយ) យ៉ាងនេះវិញថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្លាសវៃដែលទ្រទ្រង់វិន័យនៅឡើយ ពិតមែនឬ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម ត្វំ មោឃបុរិស ភិក្ខូហិ សហធម្មិកំ វុច្ចមានោ ឯវំ វក្ខសិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ ភិក្ខូហិ សហធម្មិកំ វុច្ចមានោ ឯវំ វទេយ្យ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បរិបុច្ឆាមីតិ បាចិត្តិយំ ។ សិក្ខមានេន ភិក្ខវេ ភិក្ខុនា អញ្ញាតព្វំ បរិបុច្ឆិតព្វំ បរិបញ្ហិតព្វំ ។ អយំ តត្ថ សាមីចីតិ ។

[៥៤៤] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខូហីតិ អញ្ញេហិ ភិក្ខូហិ ។ សហធម្មិកំ នាម យំ ភគវតា បញ្ញត្តំ សិក្ខាបទំ ឯតំ សហធម្មិកំ នាម ។



ឆន្នភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធមានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរស កាលបើភិក្ខុទាំងឡាយនិយាយពាក្យប្រកបដោយធម៌ អ្នកឯងមិនគួរនឹងពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្លាសវៃចេះទ្រទ្រង់វិន័យនៅឡើយ នែមោឃបុរស អំពើនេះ មិនមែននាំឲ្យជ្រះថ្លាដល់ពួកជន ដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកាលភិក្ខុទាំងឡាយ ពោលពាក្យប្រកបដោយធម៌ ហើយពោលយ៉ាងនេះថា នែអាវុសោទាំងឡាយ ខ្ញុំមិនទាន់សាកសួរភិក្ខុដទៃ ដែលឈ្លាសវៃចេះទ្រទ្រង់វិន័យដរាបណា ខ្ញុំនឹងមិនសិក្សាសិក្ខាបទនេះដរាបនោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុកាលសិក្សា គួរដឹងច្បាស់ គួរសាកសួរ គួរពិចារណា ។ នេះជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ ។

[៥៤៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ភិក្ខុទាំងឡាយ គឺភិក្ខុទាំងឡាយដទៃ ។ ដែលហៅថា ពាក្យប្រកបដោយធម៌ គឺសិក្ខាបទណា ដែលព្រះដ៏មានព្រះភាគបញ្ញត្តហើយ សិក្ខាបទនោះហៅថា ពាក្យប្រកបដោយធម៌ ។

កេន វុច្ចមានោ ឯវំ វទេតិ ន តាវាហំ អាវុសោ ឯតស្មិំ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បណ្ឌិតំ មេធាវឹ ពហុស្សុតំ ធម្មកថិកំ បរិបុច្ឆាមីតិ ភណតិ អាបត្តិ បាចិត្តិយស្ស ។

[៣០០] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី ឯវំ វទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ ឯវំ វទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី ឯវំ វទេតិ អាបត្តិ បាចិត្តិយស្ស ។ អប្បញ្ញត្តេន វុច្ចមានោ ឥទំ ន សល្លេខាយ ន ធុតត្តាយ ន បាសាទិកតាយ ន អបចយាយ ន វិរិយារម្ភាយ សំវត្តតីតិ ឯវំ វទេតិ ន តាវាហំ អាវុសោ ឯតស្មិំ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ



ភិក្ខុនោះ កាលភិក្ខុទាំងឡាយពោលតាមសិក្ខាបទនោះ ត្រឡប់ជាពោលយ៉ាងនេះ គឺពោលថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាក្នុងសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្លាសជាវិនយធរ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថិកនៅឡើយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៣០០] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្នពិតមែន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា មិនមែនឧបសម្បន្ន ហើយពោលយ៉ាងនេះ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុកាលភិក្ខុទាំងឡាយពោលតាមពាក្យដែលមិនមែនជាវិនយបញ្ញត្តិ ហើយពោលយ៉ាងនេះថា ពាក្យនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីផ្ចូរផ្ចិតកិលេស មិនប្រព្រឹត្តទៅដើម្បីកំចាត់បង់កិលេស មិនប្រព្រឹត្តទៅដើម្បីនាំមកនូវសេចក្តីជ្រះថ្លា មិនប្រព្រឹត្តទៅដើម្បីមិនសន្សំនូវកិលេសវដ្ត មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាមទេ (ម្យ៉ាងទៀត) ពោលថា ម្នាលអាវុសោទាំងឡាយ ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់

ព្យត្តំ វិនយធរំ បណ្ឌិតំ មេធាវឹ ពហុស្សុតំ ធម្មកថិកំ បរិបុច្ឆាមីតិ ភណតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេន បញ្ញត្តេន វា អបញ្ញត្តេន វា វុច្ចមានោ នេតំ ន សល្លេខាយ ន ធុតត្ថាយ ន បាសាទិកតាយ ន អបចយាយ ន វិរិយារម្ភាយ សំវត្តតីតិ ឯវំ វទតិ ន តាវាហំ អាវុសោ ឯតស្មឹ សិក្ខាបទេ សិក្ខិស្សាមិ យាវ ន អញ្ញំ ភិក្ខុំ ព្យត្តំ វិនយធរំ បណ្ឌិតំ មេធាវឹ ពហុស្សុតំ ធម្មកថិកំ បរិបុច្ឆាមីតិ ភណតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។





សាកសួរភិក្ខុដទៃ ដែលឈ្លាសវៃទ្រទ្រង់វិន័យ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថិក នៅឡើយ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុកាល អនុបសម្បន្ន ពោលដោយនូវបញ្ញត្តិក្តី ដោយពុទ្ធវចនៈដែលមិនមែនជាវិនយបញ្ញត្តិក្តី ក៏ឆ្លើយពោលយ៉ាងនេះថា ពាក្យនេះមិនប្រព្រឹត្តទៅដើម្បីសេចក្តីដុះផុតនៃកិលេស មិនប្រព្រឹត្តទៅដើម្បីកំចាត់កិលេស មិនប្រព្រឹត្តទៅដើម្បីនាំមកនូវសេចក្តីជ្រះថ្លា មិនប្រព្រឹត្តទៅដើម្បីមិនសន្សំនូវកិលេសវដ្ត មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាមទេ (ម្យ៉ាងទៀត) ពោលថា ម្នាលអាវុសោ ជាដំបូង ខ្ញុំមិនទាន់សិក្សាសិក្ខាបទនេះទេ ព្រោះខ្ញុំមិនទាន់បានសាកសួរភិក្ខុដទៃ ដែលឈ្លាសវៃទ្រទ្រង់វិន័យ ជាបណ្ឌិតមានប្រាជ្ញា ជាពហុស្សូត ជាធម្មកថិកនៅឡើយ ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថា មិនមែនឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

[៣០១] សិក្ខមានោ ជានាតិ សិក្ខាកុការមេវ ។ អញ្ញាតត្ថំ ជានិតព្វំ ។ បរិបុច្ឆិតព្វំ គរុំ ការេ គរុំ គរុស្ស ភោគោ អនុញ្ញាតំ ។ បរិបញ្ហិតព្វំ ជិនេតព្វំ តុលយិតព្វំ ។ អយំ តត្ថ សាមីចិ អយំ តត្ថ អនុធម្មតា ។

[៣០២] អនាបត្តិ ជានិស្សាមិ សិក្ខិស្សាមីតិ ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។





[៣០១] ត្រង់ពាក្យថា អ្នកសិក្សា គឺអ្នកមានសេចក្តីប្រាថ្នា ដើម្បីនឹងសិក្សា ។ ពាក្យថា គួរដឹងច្បាស់ គឺគួរចេះ ។ ពាក្យថា គួរសាកសួរ គឺគួរសាកសួរថា បពិត្រលោកដ៏ចំរើន ពាក្យនេះដូចម្ដេច ពាក្យនេះមានសេចក្តីដូចម្តេច ។ ពាក្យថា គួរពិចារណា គឺគួរគិត គួរថ្លឹង ។ ពាក្យថា នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ គឺជាវេន តាមទំនៀមក្នុងសិក្ខាបទនោះ ។

[៣០២] ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុពោលថា ខ្ញុំនឹងដឹង ខ្ញុំនឹងសិក្សា ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១ ចប់ ។

## ទុតិយសិក្ខាបទំ

[៣០៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវា ភិក្ខូនំ អនេកបរិយាយេន វិនយកថំ កថេតិ វិនយស្ស វណ្ណំ ភាសតិ វិនយបរិយត្តិយា វណ្ណំ ភាសតិ អាទិស្ស អាទិស្ស អាយស្មតោ ឧបាលិស្ស វណ្ណំ ភាសតិ ។ ភិក្ខូ ភគវា ខោ អនេកបរិយាយេន វិនយកថំ កថេតិ វិនយស្ស វណ្ណំ ភាសតិ វិនយបរិយត្តិយា វណ្ណំ ភាសតិ អាទិស្ស អាទិស្ស អាយស្មតោ ឧបាលិស្ស វណ្ណំ ភាសតិ ហន្ទ មយំ អាវុសោ អាយស្មតោ ឧបាលិស្ស សន្តិកេ វិនយំ បរិយាបុណាមាតិ ។ តេ ច ពហូ ភិក្ខូ ថេរា ច នវា ច មជ្ឈិមា ច អាយស្មតោ ឧបាលិស្ស សន្តិកេ វិនយំ បរិយាបុណន្តិ ។ អថខោ ឆព្វគ្គិយានំ ភិក្ខូនំ ឯតទហោសិ ឯតរហិ ខោ អាវុសោ ពហូ ភិក្ខូ ថេរា ច នវា ច មជ្ឈិមា ច អាយស្មតោ ឧបាលិស្ស សន្តិកេ វិនយំ បរិយាបុណន្តិ សចេ

## សិក្ខាបទទី ២

[៣០៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី សម័យនោះឯង ព្រះដ៏មានព្រះភាគទ្រង់សំដែងវិនយកថា សំដែងគុណនៃវិន័យ ទ្រង់សំដែងគុណនៃការរៀនវិន័យ ទ្រង់កំណត់រឿយៗ ហើយទ្រង់សំដែងគុណរបស់ព្រះឧបាលិដ៏មានអាយុដល់ភិក្ខុទាំងឡាយដោយបរិយាយដ៏ច្រើន ។ ភិក្ខុទាំងឡាយនិយាយថា ព្រះដ៏មានព្រះភាគទ្រង់សំដែងវិនយកថា ទ្រង់សំដែងគុណនៃវិន័យ ទ្រង់សំដែងគុណនៃការរៀនវិន័យ ទ្រង់កំណត់រឿយៗ ហើយទ្រង់សំដែងគុណរបស់ព្រះឧបាលិដ៏មានអាយុ ដោយបរិយាយដ៏ច្រើន នែអាវុសោទាំងឡាយ បើដូច្នោះយើងនឹងរៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ ។ ទើបភិក្ខុទាំងឡាយនោះ ជាថេរៈខ្លះ ជាភិក្ខុថ្មីខ្លះ ជាភិក្ខុកណ្តាលខ្លះច្រើនរូប រៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ ។ លំដាប់នោះឯង ពួកឆព្វគ្គិយភិក្ខុមានគំនិតដូច្នេះថា នែអាវុសោទាំងឡាយ ឥឡូវនេះឯង ភិក្ខុច្រើនគ្នា ជាថេរៈខ្លះ ជាភិក្ខុថ្មីខ្លះ ជាភិក្ខុកណ្តាលខ្លះ រៀនវិន័យក្នុងសំណាក់ព្រះឧបាលិដ៏មានអាយុ បើភិក្ខុទាំងឡាយនេះជាអ្នកចេះស្ទាត់

ឥមេ វិនយេ បកតញ្ញុនោ ភវិស្សន្តិ អម្ហេ យេនិច្ឆកំ យទិច្ឆកំ យាវទិច្ឆកំ អាកឌ្ឍិស្សន្តិ បរិកឌ្ឍិស្សន្តិ ហន្ទ មយំ អាវុសោ វិនយំ វិវណ្ណេមាតិ ។ អថខោ ឆព្វគ្គិយា ភិក្ខូ ភិក្ខូ ឧបសង្កមិត្វា ឯវំ វទន្តិ កឹ បនិមេហិ ខុទ្ទានុខុទ្ទកេហិ សិក្ខាបទេហិ ឧទ្ទិដ្ឋេហិ យាវទេវ កុក្កុច្ចាយ វិហេសាយ វិលេខាយ សំវត្តន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ វិនយំ វិវណ្ណេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ វិនយំ វិវណ្ណេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា វិនយំ វិវណ្ណេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ បាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេយ្យ កឹ បនិមេហិ



គង់នឹងវិន័យនឹងទាញមក ទំនងក្រោនទៅនូវយើងទាំងឡាយតាមតែចិត្ត នែលោកម្ចាស់ទាំងឡាយ ណ្ហើយចុះ យើងនឹងពោលបង្អាប់វិន័យវិញ ។ ទើបពួកឆព្វគ្គិយភិក្ខុ ចូលទៅរកភិក្ខុទាំងឡាយ ហើយនិយាយយ៉ាងនេះថា ប្រយោជន៍អ្វីនឹងសិក្ខាបទតូចៗទាំងនេះ ដែលបុគ្គលណាមួយសំដែងឡើងហើយ សិក្ខាបទទាំងនេះ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីក្ដៅក្រហាយចិត្ត ដើម្បីសេចក្ដីលំបាកចិត្ត ដើម្បីសេចក្ដីសៅហ្មងចិត្ត ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងពោលបង្អាប់វិន័យសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយពោលបង្អាប់វិន័យ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងពោលបង្អាប់វិន័យទេ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយកាលបើគេសំដែងឡើងនូវបាតិមោក្ខ ហើយពោលយ៉ាងនេះថា ប្រយោជន៍អ្វីដោយសិក្ខាបទ

ខុទ្ទានុខុទ្ទកេហិ សិក្ខាបទេហិ ឧទ្ទិដ្ឋេហិ យាវទេវ កុក្កុច្ចាយ វិហេសាយ វិលេខាយ សំវត្តន្តីតិ សិក្ខាបទវិវណ្ណនកេ បាចិត្តិយន្តិ ។

[៣០៥] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ បាតិមោក្ខេ ឧទ្ទិស្សមានេតិ ឧទ្ទិសន្តេ វា ឧទ្ទិសាបេន្តេ វា សជ្ឈាយំ វា ករោន្តេ ។ ឯវំ វទេយ្យាតិ កិំ បនិមេហិ ខុទ្ទានុខុទ្ទកេហិ សិក្ខាបទេហិ ឧទ្ទិដ្ឋេហិ យាវទេវ កុក្កុច្ចាយ វិហេសាយ វិលេខាយ សំវត្តន្តីតិ យេ ឥមំ បរិយាបុណន្តិ តេសំ កុក្កុច្ចំ ហោតិ វិហេសា ហោតិ វិលេខា ហោតិ យេ ឥមំ ន បរិយាបុណន្តិ តេសំ កុក្កុច្ចំ ន ហោតិ វិហេសា ន ហោតិ វិលេខា ន ហោតិ អនុទ្ទិដ្ឋំ ឥទំ វរំ អនុគ្គហិតំ ឥទំ វរំ អបរិយាបុតំ[១]

---

១ អបរិយាបុណិតន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។



តូច ៗ ទាំងនេះដែលភិក្ខុណាមួយសំដែងឡើងហើយ សិក្ខាបទទាំងឡាយនេះប្រព្រឹត្តទៅ ដើម្បីសេចក្តីក្តៅក្រហាយចិត្ត ដើម្បីសេចក្តីលំបាកចិត្ត ដើម្បីសេចក្តីសៅហ្មងចិត្តប៉ុណ្ណោះឯង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះពោលបន្ទាបសិក្ខាបទ ។

[៣០៥] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ពាក្យថា កាលបើភិក្ខុសំដែងឡើងនូវបាតិមោក្ខ គឺកាលបើភិក្ខុសំដែងឡើងឯងក្តី ឲ្យគេសំដែងឡើងក្តី ធ្វើសជ្ឈាយក្តី ។ ពាក្យថា ពោលយ៉ាងនេះ គឺភិក្ខុណាពោលបន្ទាបឲ្យយើងដល់ទៅសម្បូរផងទាំងឡាយ ប្រយោជន៍អ្វីដោយសិក្ខាបទតូច ៗ ទាំងនេះដែលភិក្ខុណាមួយសំដែងឡើងហើយ សិក្ខាបទទាំងនេះប្រព្រឹត្តទៅដើម្បីសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីសៅហ្មងចិត្តប៉ុណ្ណោះឯង ភិក្ខុណារៀនសិក្ខាបទនេះ ភិក្ខុនោះមានសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីសៅហ្មងចិត្ត ភិក្ខុណាមិនរៀនសិក្ខាបទនេះ ភិក្ខុនោះមិនមានសេចក្តីក្តៅក្រហាយចិត្ត សេចក្តីលំបាកចិត្ត សេចក្តីសៅហ្មងចិត្តទេ សិក្ខាបទនេះបើមិនមានអ្នកណាសំដែងឡើងក៏ជាការល្អ សិក្ខាបទនេះបើមិនមានអ្នកណាសិក្សាក៏ជាការល្អ សិក្ខាបទនេះ

ឥធំ វា អជាវិធំ ឥធំ វា វិលេខោ ហោតិ អត្ថុទ្ធារាយេតុំ ឥមេ ហិ ភិក្ខូ អបគតញ្ញាណា ហោន្តិ ឧបសម្បន្នស្ស វិនយំ វិវណ្ណេតិ អាបត្តិ បាចិត្តិយស្ស ។

(៣០៥) ឧបសម្បន្នេ ឧបសម្បន្នសញ្ញី វិនយំ វិវណ្ណេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ វិនយំ វិវណ្ណេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី វិនយំ វិវណ្ណេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញំ ធម្មំ វិវណ្ណេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នស្ស វិនយំ វា អញ្ញំ វា ធម្មំ វិវណ្ណេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

(៣០៦) អនាបត្តិ ន វិវណ្ណេតុកាមោ ឥង្ឃ តាវ សុត្តន្តេ វា គាថាយោ វា អភិធម្មំ វា បរិយាបុណស្សុ បច្ឆា វិនយំ បរិយាបុណិស្សសីតិ ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។



បើមិនមានអ្នកណារៀនក៏ជាការល្អ សិក្ខាបទទាំងនេះមិនមានអ្នកណាចេះចាំក៏ជាការល្អ នឹងឃ្លាតអន្តរធានទៅ ឬភិក្ខុគិតឡើយអាចនេះ ជួយកុំឱ្យវេទ ជំទាស់ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

(៣០៥) ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយពោលបន្ថោកវិន័យ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ហើយពោលបន្ថោកវិន័យ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា មិនមែនឧបសម្បន្ន ហើយពោលបន្ថោកវិន័យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុពោលបន្ថោកធម៌ដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុពោលបន្ថោកវិន័យក្ដី ធម៌ដទៃក្ដី ចំពោះអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ មិនមែនឧបសម្បន្ន ភិក្ខុសំគាល់ថា មិនមែនឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៣០៦) អនាបត្តិមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៤ យ៉ាង) គឺភិក្ខុមិនចង់ពោលបន្ថោក ១ ភិក្ខុពោលថាណ្ហើយចុះអ្នកចូររៀនព្រះសូត្រ ក៏បានក្ដី គាថាក៏បានក្ដី អភិធម្មក្ដី ជាមុនសិន ចាំរៀនវិន័យ ជាខាងក្រោយវិញ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាអាទិកម្មិក ១ ។

សិក្ខាបទទី ២ ចប់ ។

## តតិយសិក្ខាបទំ

(៣០៨) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ អនាចារំ អាចរិត្វា អញ្ញាណកេន អាបន្នាតិ ជានន្តូតិ បាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេន្តិ ឥទានេវ ខោ មយំ ជានាម អយម្បិ កិរ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ បាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វក្ខន្តិ ឥទានេវ ខោ មយំ ជានាម អយម្បិ កិរ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ បាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេថ ឥទានេវ ខោ មយំ ជានាម អយម្បិ កិរ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតីតិ ។

## សិក្ខាបទទី ៣

(៣០៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាប្រព្រឹត្តអនាចារហើយនឹកថា ភិក្ខុទាំងឡាយចូរដឹងថា យើងទាំងឡាយត្រូវអាបត្តិដោយសេចក្តីល្ងង់ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ក៏នាំគ្នាពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងឥឡូវនេះថា ធម៌នេះមកហើយក្នុងសូត្រ រាប់ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេស (ការសំដែង) រាល់កន្លះខែ ។ ភិក្ខុទាំងឡាយណា ជាអ្នកមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ម្តេចក៏នាំគ្នាពោលយ៉ាងនេះថា យើងទាំងឡាយទើបតែដឹងក្នុងកាលឥឡូវនេះថា ធម៌នេះមកហើយក្នុងសូត្រ រាប់ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេសរាល់កន្លះខែ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា អ្នកទាំងឡាយ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ក៏នាំគ្នាពោលយ៉ាងនេះថា យើងទាំងឡាយទើបតែនឹងដឹងឥឡូវនេះថា ធម៌នេះមកហើយក្នុងសូត្រ រាប់ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេសរាល់កន្លះខែ ពិតមែនឬ ។

សព្វំ គហកំតំ ។ វិហារំ ញាណោ គហកំ គតំ ហំ ជាម ញុត្តេ មោយ បុរិសា ជាតិមោក្ខោ ឧទ្ទិស្សមោចេ បរំ ខេត្តេ សំនាមេតិ ទោ មយំ ជានាម អយម្បិ ភិក្ខុ ជេម្មោ សុគ្គាគតោ សុត្តមាំយកបញ្ហា អនុជានាសិ ឧទ្ទេសំ អាគច្ឆតិ ចេតំ មោយ បុរិសា អប្បសន្នាចំ ក បសាទាយ បសន្នានំ ក ភិយ្យោភាវាយ ។ បេ ។ វិញ្ញូ ចន ភិក្ខុវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អជ្ឈត្តរូបំ ជាតិមោក្ខោ ឧទ្ទិស្សមោចេ បរំ ភរេយ្យ សំនាមេ ទោ មយំ ជានាមិ អយម្បិ ភិក្ខុ ចេម្មោ សុគ្គាគតោ សុត្តមាំយកបញ្ហា អនុជានាសិ ឧទ្ទេសំ អាគច្ឆតិ ។ ឥតោ ភិក្ខុ អញ្ញោ ភិក្ខុ ជានេយ្យ និសិន្នបុព្វំ ឥមិនា ភិក្ខុនា ទុក្កដទុក្កដំ ជាតិមោក្ខោ ឧទ្ទិស្សមោចេ តោ បន ករោ ភិយ្យោតិ ៤ ៤ តស្ស ភិក្ខុនោ អញ្ញាណាគោន មុត្តិ អត្ថិ យញ្ច តត្ថ អាបត្តិ អាបន្នោ តញ្ច យថាធម្មោ ការេតព្វោ ឧត្តរិញ្ចស្ស[១] មោហោ អារោបេតព្វោ តស្ស តេ អាវុសោ

---

១ ម. ឆ. ឧត្តរិ ចស្ស ។



ពួកពុទ្ធស្រាវកភិក្ខុរួចហើយ សូមទ្រង់មេត្តាប្រោស ភិក្ខុមែន ។ ព្រះពុទ្ធ ទ្រង់មានព្រះភាគទ្រង់ត្រាស់ថា ម្នាលពួកបុរសទាំងឡាយ អ្នក ទាំងឡាយកាលភិក្ខុកំពុងសំដែងធាតុមោក្ខ មិនគួរនឹងមកពោលយ៉ាងនេះ ថា យើងទាំងឡាយទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ធម៌នេះមកហើយ ក្នុងសូត្រ រាប់បញ្ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេសរាល់កន្លះខែ ម្នាល ពួកបុរសទាំងឡាយ សេចក្តីនេះមិនមែននាំមកនូវសេចក្តីជ្រះថ្លា ដល់អ្នកដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទ នេះយ៉ាងនេះថា ភិក្ខុណាមួយ កាលភិក្ខុកំពុងសំដែងធាតុមោក្ខរាល់កន្លះ ខែ ហើយពោលយ៉ាងនេះថា ខ្ញុំទើបតែនឹងដឹងក្នុងកាលឥឡូវនេះថា ធម៌ ធម៌នេះមកហើយក្នុងសូត្រ រាប់បញ្ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេសរាល់ កន្លះខែ ។ បើពួកភិក្ខុទាំងឡាយដទៃដឹងនូវភិក្ខុនោះថា ភិក្ខុនេះធ្លាប់អង្គុយ ស្តាប់ធាតុមោក្ខ ដែលភិក្ខុសំដែងអស់ពីរដងបីដងហើយ នឹងពោលទៅ ថ្វីទៀតអស់ការស្តាប់ប្រែទនដង សេចក្តីថា (ចាត់តាំងបត្តិ) ដោយការដែល មិនដឹងនឹងមានទោសដល់ភិក្ខុនោះទេ ភិក្ខុនោះត្រូវធ្វើតាមធម៌ ក្នុងរឿងអាបត្តិ នោះ សង្ឃគប្បីញ៉ាំងភិក្ខុនោះឲ្យត្រូវនូវទោសនោះ ដោយត្រូវផ្តើម ម្យ៉ាងទៀត គប្បីលើកទោសមោហៈដល់ភិក្ខុនោះថែមទៀតថា ម្នាល

អលាភា តស្ស តេ ទុល្លទ្ធំ យំ ត្វំ បាតិមោក្ខេ ឧទ្ទិស្សមានេ ន សាធុកំ អដ្ឋិកត្វា មនសិករោសីតិ ។ ឥទំ តស្មឹ មោហនកេ បាចិត្តិយន្តិ ។

[៣០៨] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អន្វទ្ធមាសន្តិ អនុបោសថិកំ ។ បាតិមោក្ខេ ឧទ្ទិស្សមានេតិ ឧទ្ទិសន្តេ ។ ឯវំ វទេយ្យាតិ អនាចារំ អាចរិត្វា អញ្ញាណេន អាបន្នោតិ ជានន្តុ មន្តិ បាតិមោក្ខេ ឧទ្ទិស្សមានេ ឯវំ វទេតិ ឥទានេវ ខោ អហំ ជានាមិ អយម្បិ កិរ ធម្មោ សុត្តាគតោ សុត្តបរិយាបន្នោ អន្វទ្ធមាសំ ឧទ្ទេសំ អាគច្ឆតីតិ អាបត្តិ ទុក្កដស្ស ។



អាវុសោ (ការនេះ) មិនជាលាភរបស់អ្នកឯងទេ អ្នកឯងបាននូវរបស់អាក្រក់ ដោយហេតុថា កាលភិក្ខុកំពុងសំដែងបាតិមោក្ខ អ្នកមិនបានធ្វើទុកក្នុងចិត្តឲ្យស្រួល ប្រមូលប្រយោជន៍ចិត្តល្អទៀយ ។ នេះជាអាបត្តិបាចិត្តិយ ព្រោះភិក្ខុធ្វើវង្វេងនោះ (ធ្វើល្ងង់) ។

[៣០៨] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា រាល់កន្លះខែ គឺរាល់ថ្ងៃឧបោសថ ។ ពាក្យថា កាលភិក្ខុកំពុងសំដែងបាតិមោក្ខ សេចក្ដីថា កាលភិក្ខុកំពុងសូត្របាតិមោក្ខ ។ ពាក្យថា ពោលយ៉ាងនេះ សេចក្ដីថា ភិក្ខុណាប្រព្រឹត្តអនាចារហើយប្រាថ្នាថា ភិក្ខុទាំងឡាយចូរដឹងថា យើងត្រូវអាបត្តិដោយសារការមិនដឹង កាលភិក្ខុកំពុងសំដែងបាតិមោក្ខ ភិក្ខុនោះពោលយ៉ាងនេះថា ខ្ញុំទើបតែនឹងដឹងក្នុងវេលានេះថា ឮថាធម៌នេះមកហើយក្នុងសូត្រ រាប់ចូលហើយក្នុងសូត្រ មកកាន់ឧទ្ទេសរាល់កន្លះខែដូច្នេះ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

[៣០៩] តញ្ចេ មោហេតុកាមំ ភិក្ខុំ អញ្ញេ ភិក្ខូ ជានេយ្យុំ និសិន្នបុព្វំ ឥមិនា ភិក្ខុនា ទ្វិត្តិក្ខត្តុំ បាតិមោក្ខេ ឧទ្ទិស្សមានេ កោ បន វាទោ ភិយ្យោតិ ន ច តស្ស ភិក្ខុនោ អញ្ញាណកេន មុត្តិ អត្ថិ យញ្ច តត្ថ អាបត្តឹ អាបន្នោ តញ្ច យថាធម្មោ ការេតព្វោ ឧត្តរិ ចស្ស មោហោ អារោបេតព្វោ ។ ឯវញ្ច បន ភិក្ខវេ អារោបេតព្វោ ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ បាតិមោក្ខេ ឧទ្ទិស្សមានេ ន សាធុកំ អដ្ឋិំកត្វា មនសិករោតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស ភិក្ខុនោ មោហំ អារោបេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ អយំ ឥត្ថន្នាមោ ភិក្ខុ បាតិមោក្ខេ ឧទ្ទិស្សមានេ ន សាធុកំ អដ្ឋិំកត្វា មនសិករោតិ ។ សង្ឃោ ឥត្ថន្នាមស្ស



[៣០៩] ពាក្យថា បើ (ភិក្ខុទាំងឡាយដទៃដឹង) នូវភិក្ខុនោះ សេចក្តីថា ភិក្ខុទាំងឡាយដទៃដឹងនូវភិក្ខុអ្នកប្រាថ្នានូវសេចក្តីវង្វេងថា ភិក្ខុនេះធ្លាប់អង្គុយ (ស្តាប់) បាតិមោក្ខដែលភិក្ខុសំដែងអស់ពីរដងបីដងហើយ មិនបាច់ពោលទៅថ្វីទៀតដល់ការស្តាប់ច្រើនដងទេ សេចក្តីរួច (ចាកអាបត្តិ) ដោយអាការដែលមិនដឹងមិនមានដល់ភិក្ខុនោះទេ ភិក្ខុនោះត្រូវអាបត្តិណា ក្នុងរឿងអនាចារៈនោះ សង្ឃគប្បីញ៉ាំងភិក្ខុនោះឲ្យធ្វើនូវអាបត្តិនោះ ដោយគួរតាមធម៌ ម្យ៉ាងទៀតគប្បីលើកសេចក្តីវង្វេង គឺមោហារោបនកម្មដល់ភិក្ខុនោះថែមទៀត ។ ម្នាលភិក្ខុទាំងឡាយ សង្ឃគប្បីលើកមោហារោបនកម្មឡើងយ៉ាងនេះ ។ ភិក្ខុដែលជាអ្នកឈ្លាស អង់អាច គប្បីញ៉ាំងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អឡើយ ។ បើមោហារោបនកម្ម មានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីលើកមោហារោបនកម្ម ដល់ភិក្ខុឈ្មោះនេះ ។ នេះជាពាក្យប្រកាសឲ្យសង្ឃដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន សូមព្រះសង្ឃស្តាប់ខ្ញុំ ភិក្ខុឈ្មោះនេះ កាលភិក្ខុកំពុងសំដែងបាតិមោក្ខ មិនបានធ្វើទុកក្នុងចិត្តឲ្យសម្រេចប្រយោជន៍ដ៏ល្អទេ ។ សង្ឃលើកនូវ

ភិក្ខុនោ មោហំ អារោបេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស ភិក្ខុនោ មោហស្ស អារោបនា សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ អារោបិតោ សង្ឃេន ឥត្ថន្នាមស្ស ភិក្ខុនោ មោហោ ។ ខមតិ សង្ឃស្ស តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

(៣១០) អនារោបិតេ មោហេ មោហេតិ អាបត្តិ ទុក្កដស្ស ។ អារោបិតេ មោហេ មោហេតិ អាបត្តិ បាចិត្តិយស្ស ។

(៣១១) ធម្មកម្មេ ធម្មកម្មសញ្ញី មោហេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ មោហេតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី មោហេតិ អាបត្តិ បាចិត្តិយស្ស ។ អធម្មកម្មេ



មោហារោបនកម្មដល់ភិក្ខុឈ្មោះនេះ ។ ការលើកមោហារោបនកម្មដល់ភិក្ខុឈ្មោះនេះ គួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីស្ងៀមនៅ មិនគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ មោហារោបនកម្មសង្ឃបានលើកឡើងហើយដល់ភិក្ខុឈ្មោះនេះ ។ ការលើកមោហារោបនកម្មនេះគួរដល់សង្ឃ ព្រោះហេតុនោះ សង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវមោហារោបនកម្មនេះ ដោយការស្ងៀមនៅយ៉ាងនេះ ។

(៣១០) កាលមោហារោបនកម្ម សង្ឃមិនទាន់លើកឡើងនៅ ទើ ភិក្ខុតែងធ្វើវង្វេង ត្រូវអាបត្តិទុក្កដ ។ កាលមោហារោបនកម្មសង្ឃលើកឡើងហើយ ភិក្ខុនៅតែធ្វើវង្វេងទៀត ត្រូវអាបត្តិបាចិត្តិយ ។

(៣១១) កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយតែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្ដីសង្ស័យ ហើយតែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយតែងធ្វើវង្វេង ត្រូវអាបត្តិបាចិត្តិយ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា

ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣១៦] អនាបត្តិ ន វិត្ថារេន សុតំ ហោតិ ឩនកទ្វត្តិក្ខត្តុំ វិត្ថារេន សុតំ ហោតិ ន ឱហិតុកាមស្ស ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។



កម្មប្រកបដោយធម៌ ហើយ (ភិក្ខុនឹងធ្វើព្រងើយ) ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៣១៦) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺ ភិក្ខុមិនទាន់បានស្តាប់បាតិមោក្ខដោយពិស្តារ ១ ភិក្ខុស្តាប់បាតិមោក្ខដោយពិស្តារអស់វារៈមិនទាន់ដល់ពីរបីដង ១ ភិក្ខុមិនចង់នឹងធ្វើព្រងើយ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់ ។

## ចតុត្ថសិក្ខាបទំ .

[៣១៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កុបិតា អនត្តមនា សត្តរសវគ្គិយានំ ភិក្ខូនំ បហារំ ទេន្តិ ។ តេ រោទន្តិ ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ រោទថាតិ ។ ឥមេ អាវុសោ ឆព្វគ្គិយា ភិក្ខូ កុបិតា អនត្តមនា អម្ហាកំ បហារំ ទេន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ កុបិតា អនត្តមនា ភិក្ខូនំ បហារំ ទស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ កុបិតា អនត្តមនា ភិក្ខូនំ បហារំ ទេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា កុបិតា អនត្តមនា ភិក្ខូនំ បហារំ ទស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ

## សិក្ខាបទទី ៤

[៣១៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុក្រោធខឹង ហើយឲ្យប្រហារដល់ពួកសត្តរសវគ្គិយភិក្ខុ (ភិក្ខុមានពួក ១៧) ។ សត្តរសវគ្គិយភិក្ខុទាំងនោះនាំគ្នាស្រែកយំ ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ អ្នកទាំងឡាយ ហេតុអ្វីបានជាយំ ។ ពួកសត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះក្រោធខឹងបានឲ្យប្រហារដល់ពួកយើង ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងក្រោធខឹង ហើយទៅប្រហារភិក្ខុទាំងឡាយសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយក្រោធខឹង ហើយនាំគ្នាប្រហារភិក្ខុទាំងឡាយ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងក្រោធខឹង ហើយនាំគ្នាប្រហារភិក្ខុទាំងឡាយទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែន

បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស កុបិតោ អនត្តមនោ បហារំ ទទេយ្យ បាចិត្តិយន្តិ ។

[៣០៤] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ កុបិតោ អនត្តមនោតិ អនភិរទ្ធោ អាហតចិត្តោ ខិលជាតោ ។ បហារំ ទទេយ្យាតិ កាយេន វា កាយប្បដិពទ្ធេន វា និស្សគ្គិយេន វា អន្តមសោ ឧប្បលបត្តេនបិ បហារំ ទេតិ អាបត្តិ បាចិត្តិយស្ស ។

[៣០៥] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី កុបិតោ អនត្តមនោ បហារំ ទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ កុបិតោ អនត្តមនោ បហារំ ទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី កុបិតោ អនត្តមនោ បហារំ ទេតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នស្ស កុបិតោ អនត្តមនោ បហារំ ទេតិ





ឲ្យប្រហារដល់ពួកជនដែលមិនគប្បីប្រហារ មួយទៀតពួកជនដែលប្រហារហើយ ឲ្យទាស់ទែងប្រហារឡើងវិញ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្រោធខឹង ហើយឲ្យប្រហារដល់ភិក្ខុដទៃ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៣០៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ពាក្យថា ដល់ភិក្ខុដទៃ គឺដល់ភិក្ខុដទៃ ។ ពាក្យថា ក្រោធខឹង សេចក្តីថា មានចិត្តមិនត្រេកអរ មានចិត្តខឹង មានចិត្តរឹងរូស ។ ពាក្យថា ឲ្យប្រហារ គឺឲ្យប្រហារដោយកាយក្តី ដោយវត្ថុជាប់នឹងកាយក្តី ដោយវត្ថុសម្រាប់បោះក្តី ដោយហោចទៅ សូម្បីតែដោយស្លឹកព្រលិត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៣០៥] ឧបសម្បន្ន[១] ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយក្រោធខឹងឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្រោធខឹងឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាជាអនុបសម្បន្ន[២] ហើយក្រោធខឹងឲ្យប្រហារ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រោធខឹង ហើយឲ្យប្រហារដល់អនុបសម្បន្ន

---

១ បានដល់ភិក្ខុ ។ ២ បានដល់ជនមិនមែនភិក្ខុ ។

អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

[៣១៦] អនាបត្តិ កេនចិ វិហេឋិយមានោ មោក្ខា-ធិប្បាយោ បហារំ ទេតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។





ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ (ហើយឲ្យប្រហារ) ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៣១៦) វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុដែលជនណាមួយបៀតបៀន ហើយមានសេចក្តីប្រាថ្នាដើម្បីនឹងរួច ក៏ឲ្យប្រហារទៅវិញ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៤ ចប់ ។

# បញ្ចមសិក្ខាបទំ

[៣១៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា សត្តរសវគ្គិយានំ ភិក្ខូនំ តលសត្តិកំ ឧគ្គិរន្តិ ។ តេ បហារសមុច្ចិតា រោទន្តិ ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ រោទថាតិ ។ ឥមេ អាវុសោ ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា អម្ហាកំ តលសត្តិកំ ឧគ្គិរន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ កុបិតា អនត្តមនា[១] ភិក្ខូនំ តលសត្តិកំ ឧគ្គិរិស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ កុបិតា អនត្តមនា ភិក្ខូនំ តលសត្តិកំ ឧគ្គិរថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា កុបិតា អនត្តមនា ភិក្ខូនំ តលសត្តិកំ ឧគ្គិរិស្សថ

១ ឯកច្ចេ សត្តរសវគ្គិយានន្តិ បាឋោ បោត្ថកេ ទិស្សតិ ។

# សិក្ខាបទទី ៥

[៣១៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុក្រោធខឹង ហើយលើកបាតដៃឡើងសំដៅពួកសត្តរសវគ្គិយភិក្ខុ (ធ្វើអាការបីដូចជានឹងវាយ) សត្តរសវគ្គិយភិក្ខុទាំងនោះធ្លាប់តែនឹងរួចអំពីប្រហារមកហើយ (មានសេចក្តីភិតភ័យ) ក៏នាំគ្នាយំ ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ហេតុអ្វីបានជាពួកអ្នកយំ ។ សត្តរសវគ្គិយភិក្ខុឆ្លើយថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុទាំងនេះក្រោធខឹង ហើយលើកបាតដៃឡើងដូចជាលំពែងសំដៅពួកយើង ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោសតិះដៀលបន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងក្រោធខឹង ហើយលើកបាតដៃឡើងដូចជាលំពែងសំដៅភិក្ខុទាំងឡាយសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកទាំងឡាយក្រោធខឹង ហើយលើកបាតដៃឡើងដូចជាលំពែងសំដៅភិក្ខុទាំងឡាយ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងក្រោធខឹង ហើយលើកបាតដៃឡើងដូចជាលំពែងសំដៅភិក្ខុទាំងឡាយទេ

នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរេយ្យ បាចិត្តិយន្តិ ។

(៣១៨) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ កុបិតោ អនត្តមនោតិ អនភិរទ្ធោ អាហតចិត្តោ ខិលជាតោ ។ តលសត្តិកំ ឧគ្គិរេយ្យាតិ កាយំ វា កាយប្បដិពទ្ធំ វា អន្តមសោ ឧប្បលបត្តម្បិ ឧច្ចារេតិ អាបត្តិ បាចិត្តិយស្ស ។

(៣១៩) ឧបសម្បន្នេ ឧបសម្បន្នសញ្ញី កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នស្ស



ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្រោធខឹង ហើយគក់ឡើងនូវលំពែងគឺបាតដៃសំដៅភិក្ខុដទៃ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

(៣១៨) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ពាក្យថា សំដៅភិក្ខុដទៃ គឺសំដៅភិក្ខុដទៃ ។ ពាក្យថា ក្រោធខឹង គឺមានចិត្តមិនត្រេកអរ មានចិត្តគុំគួន មានចិត្តរឹងរូស ។ ពាក្យថា គក់ឡើងនូវលំពែងគឺបាតដៃ សេចក្តីថា ភិក្ខុលើកកាយក្តី លើកវត្ថុជាប់នឹងកាយក្តី ឡើងជូន ដោយហោចទៅ សូម្បីតែស្លឹកព្រលិត ត្រូវអាបត្តិបាចិត្តិយ ។

(៣១៩) ឧបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ហើយក្រោធខឹង គក់លំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្រោធខឹងគក់លំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ហើយក្រោធខឹង គក់លំពែងគឺបាតដៃឡើង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្រោធខឹងដល់

កុបិតោ អនត្តមនោ តលសត្តិកំ ឧគ្គិរតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

(៣៦០) អនាបត្តិ កេនចិ វិហេឋិយមានោ មោក្ខាធិប្បាយោ តលសត្តិកំ ឧគ្គិរតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តលសត្តិកសិក្ខាបទំ និដ្ឋិតំ ។



អនុបសម្បន្ន ហើយគ្រាន់តែលើកបាតដៃឡើង ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៣៦០) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុដែលជនណាមួយបៀតបៀនហើយមានសេចក្តីប្រាថ្នាដើម្បីនឹងឲ្យរួចខ្លួនគឺគ្រាន់តែលើកបាតដៃឡើង ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៥ ចប់ ។

## ឆដ្ឋសិក្ខាបទំ

[៣៦១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ

## សិក្ខាបទទី ៦

[៣៦១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុនាំគ្នាកំចាត់ (គឺចោទ) ភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូល ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូលសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូល ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងចោទភិក្ខុផងគ្នាដោយអាបត្តិសង្ឃាទិសេសមិនមានមូលទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬមួយក៏ពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ

។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុំ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេយ្យ បាចិត្តិយន្តិ ។

(៣៦៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុន្តិ អញ្ញំ ភិក្ខុំ ។ អមូលកំ នាម អទិដ្ឋំ អស្សុតំ អបរិសង្កិតំ ។ សង្ឃាទិសេសេនាតិ តេរសន្នំ អញ្ញតរេន ។ អនុទ្ធំសេយ្យាតិ ចោទេតិ វា ចោទាបេតិ វា អាបត្តិ បាចិត្តិយស្ស ។

(៣៦៧) ឧបសម្បន្នេ ឧបសម្បន្នសញ្ញី អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី អមូលកេន សង្ឃាទិសេសេន អនុទ្ធំសេតិ អាបត្តិ បាចិត្តិយស្ស ។ អាចារវិបត្តិយា វា ទិដ្ឋិវិបត្តិយា វា អនុទ្ធំសេតិ អាបត្តិ ទុក្កដស្ស ។



។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ ចោទភិក្ខុដទៃគ្នា ដោយអាបត្តិសង្ឃាទិសេស មិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។

(៣៦៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ភិក្ខុដទៃគ្នា គឺភិក្ខុដទៃ ។ ពាក្យថា មិនមានមូល គឺអាបត្តិសង្ឃាទិសេសដែលខ្លួនមិនបានឃើញ មិនបានឮ មិនបានរង្កៀស ។ ពាក្យថា ដោយអាបត្តិសង្ឃាទិសេស គឺបណ្តាសង្ឃាទិសេសទាំង ១៣ សិក្ខាបទ សិក្ខាបទណាមួយ ។ ពាក្យថា ចោទ សេចក្តីថា ភិក្ខុចោទឯងក្តី ប្រើគេឲ្យចោទក្តី ត្រូវអាបត្តិបាចិត្តិយ ។

(៣៦៧) ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយចោទដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយចោទដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ហើយចោទដោយអាបត្តិសង្ឃាទិសេសមិនមានមូល ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុចោទដោយអាចារវិបត្តិក្តី ដោយទិដ្ឋិវិបត្តិក្តី ត្រូវអាបត្តិទុក្កដ ។

អនុបសម្បន្នំ អនុទ្ធំសេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។

(៣៦៤) អនាបត្តិ តថាសញ្ញី ចោទេតិ វា ចោទាបេតិ វា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។



ភិក្ខុចោទអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្ន (ហើយចោទ) ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៣៦៤) វារៈដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុមានសេចក្ដីសំគាល់គិតមែនហើយចោទឯងក្ដី ប្រើគេឲ្យចោទក្ដី ១ ភិក្ខុឆ្កួត ១ ភិក្ខុជាអាទិកម្មិក ១ ។

សិក្ខាបទទី ៦ ចប់ ។

# សត្តមសិក្ខាបទំ

[៣៦៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សត្តរសវគ្គិយានំ ភិក្ខូនំ សញ្ចិច្ច កុក្កុច្ចំ ឧបទហន្តិ ភគវតា អាវុសោ សិក្ខាបទំ បញ្ញត្តំ ន ឩនវីសតិវស្សោ បុគ្គលោ ឧប-សម្បាទេតព្វោតិ តុម្ហេ ច ឩនវីសតិវស្សា ឧបសម្បន្នា កច្ចិ នោ តុម្ហេ អនុបសម្បន្នាតិ ។ តេ រោទន្តិ ។ ភិក្ខូ ឯវមាហំសុ កិស្ស តុម្ហេ អាវុសោ រោទថាតិ ។ ឥមេ អាវុសោ ឆព្វគ្គិយា ភិក្ខូ អម្ហាកំ សញ្ចិច្ច កុក្កុច្ចំ ឧបទហន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ[១] ភិក្ខូនំ សញ្ចិច្ច កុក្កុច្ចំ ឧបទហិស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខូនំ សញ្ចិច្ច កុក្កុច្ចំ

១ ឯកច្ចេ សត្តរសវគ្គិយានន្តិបិ បាឋំ ពោត្ថកេ អត្ថិ ។

# សិក្ខាបទទី ៧

(៣៦៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុក៏ក្លែងបង្កើតហេតុឲ្យមានសេចក្ដីសង្ស័យកើតដល់ពួកសត្តរសវគ្គិយភិក្ខុថា ម្នាលអាវុសោ សិក្ខាបទ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តទុកហើយថា បុគ្គលមានឆ្នាំមិនគ្រប់ ២០ សង្ឃមិនគប្បីឲ្យឧបសម្បទាឡើយ ចំណែកពួកលោកមានអាយុមិនទាន់ដល់ ២០ ឆ្នាំ មកចូលឧបសម្បទា ពួកលោកមិនមែនជាឧបសម្បន្នទេដឹង ។ សត្តរសវគ្គិយភិក្ខុទាំងនោះក៏នាំគ្នាយំ ។ ភិក្ខុទាំងឡាយបានសួរយ៉ាងនេះថា ម្នាលអាវុសោ ពួកលោកយំព្រោះអ្វី ។ ពួកសត្តរសវគ្គិយភិក្ខុប្រាប់ថា អាវុសោ ឆព្វគ្គិយភិក្ខុទាំងនេះ ក្លែងបង្កើតហេតុឲ្យមានសេចក្ដីសង្ស័យដល់ពួកយើង ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះ ទោសតិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរក្លែងបង្កើតហេតុឲ្យមានសេចក្ដីសង្ស័យ ដល់ភិក្ខុទាំងឡាយផងនោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកក្លែងបង្កើតហេតុឲ្យមានសេចក្ដីសង្ស័យដល់ភិក្ខុ

ឧបទហថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខូនំ សញ្ចិច្ច កុក្កុច្ចំ ឧបទហិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខុស្ស សញ្ចិច្ច កុក្កុច្ចំ ឧបទហេយ្យ ឥតិស្ស មុហុត្តម្បិ អផាសុ ភវិស្សតីតិ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ បាចិត្តិយន្តិ ។

(៣៦៦) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខុស្សាតិ អញ្ញស្ស ភិក្ខុស្ស ។ សញ្ចិច្ចាតិ ជានន្តោ សញ្ជានន្តោ ចេច្ច អភិវិតរិត្វា វីតិក្កមោ ។ កុក្កុច្ចំ ឧបទហេយ្យាតិ ឩនវីសតិវស្សោ មញ្ញេ ត្វំ



ទាំងឡាយដោយចេតនា ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់ម្រេចព្រះអង្គ ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងធ្វើហេតុឲ្យមានសេចក្ដីរង្កៀសសង្ស័យដល់ភិក្ខុទាំងឡាយដោយចេតនាសោះ ម្នាលមោឃបុរសទាំងឡាយ អំពើនុះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយក្លែងបន្តហេតុឲ្យមានសេចក្ដីរង្កៀសសង្ស័យដល់ភិក្ខុដទៃ ដោយគិតថា (សេចក្ដីរង្កៀសសង្ស័យនេះ) កើតឡើង ការមិនសប្បាយចិត្តនឹងមានដល់ភិក្ខុនោះ ១ រំពេចមិនខាន ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើសេចក្ដីរង្កៀសសង្ស័យនោះឯងជាហេតុតែ មិនមែនហេតុដទៃឡើយ ។

(៣៦៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ដល់ភិក្ខុដទៃ គឺដល់ភិក្ខុដទៃ ។ ពាក្យថា ក្លែង សេចក្ដីថា ភិក្ខុដឹងទាំងដឹងជាក់ ក្លែងល្មើសប្រព្រឹត្តកន្លង ។ ពាក្យថា បន្តហេតុឲ្យមានសេចក្ដីរង្កៀសសង្ស័យ សេចក្ដីថា ភិក្ខុណាបន្តហេតុឲ្យមានសេចក្ដីរង្កៀសសង្ស័យថា លោកចង់នឹង

ឧបសម្បន្នោ វិកាលេ មញ្ញេ តយា ភុត្តំ មជ្ជំ មញ្ញេ តយា បីតំ មាតុគ្គាមេន សទ្ធិំ រហោ មញ្ញេ តយា និសិន្នន្តិ កុក្កុច្ចំ ឧប្បាទេតិ អាបត្តិ បាចិត្តិយស្ស ។ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ ន អញ្ញោ កោចិ បច្ចយោ ហោតិ កុក្កុច្ចំ ឧប្បាទេតុំ ។

[៣៤៧] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី សញ្ចិច្ច កុក្កុច្ចំ ឧប្បាទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ សញ្ចិច្ច កុក្កុច្ចំ ឧប្បាទេតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី សញ្ចិច្ច កុក្កុច្ចំ ឧប្បាទេតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នស្ស សញ្ចិច្ច កុក្កុច្ចំ ឧប្បាទេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។



ថាមានឆ្នាំមិនទាន់គ្រប់ ២០ ហើយឧបសម្បទាទេដឹង លោកបរិភោគអាហារក្នុងវេលាវិកាលទេដឹង លោកផឹកទឹកស្រវឹងទេដឹង លោកអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមទេដឹង ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះធ្វើសេចក្តីរង្កៀសសង្ស័យនោះឯងជាហេតុពិត មិនមែនហេតុដទៃឡើយ សេចក្តីថា ហេតុណាមួយដទៃគ្មាន ចំពោះគ្រឿងបង្កហេតុឱ្យមានសេចក្តីរង្កៀសសង្ស័យកើតឡើងប៉ុណ្ណោះឯង ។

[៣៤៧] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឱ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ហើយក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឱ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ហើយក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឱ្យកើតឡើង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុក្លែងផ្តើមសេចក្តីរង្កៀសសង្ស័យឱ្យកើតឡើងដល់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។

(៣៦៨) អនាបត្តិ ន កុក្កុច្ចំ ឧបទហិតុកាមោ ឩនវីសតិវស្សោ មញ្ញេ ត្វំ ឧបសម្បន្នោ វិកាលេ មញ្ញេ តយា ភុត្តំ មជ្ជំ មញ្ញេ តយា បីតំ មាតុគាមេន សទ្ធឹ រហោ មញ្ញេ តយា និសិន្នំ ឥង្ឃ ជានាហិ មា តេ បច្ឆា កុក្កុច្ចំ អហោសីតិ ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។



(៣៦៨) ភាវៈដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុមិនមានបំណងនឹងផ្តើមសេចក្តីរង្កៀសសង្ស័យឲ្យកើតឡើង តែពោល (តាមសេចក្តីយល់) ថា លោកប្រហែលមានឆ្នាំមិនគ្រប់ដល់ ២០ ហើយ បួសឧបសម្បទាឡើង លោកបរិភោគអាហារក្នុងវេលាវិកាលឡើង លោកផឹកទឹកស្រវឹងឡើង លោកអង្គុយក្នុងទីស្ងាត់ជាមួយនឹងមាតុគ្រាមឡើង ណ្ហើយចុះ លោកចូរដឹងចុះ លោកកុំរង្កៀសសង្ស័យស្តាយក្រោយឡើយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៧ ចប់ ។

## អដ្ឋមសិក្ខាបទំ

(៣៦៤) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បេសលេហិ ភិក្ខូហិ សទ្ធឹ ភណ្ឌន្តិ ។ បេសលា ភិក្ខូ ឯវំ វទន្តិ អលជ្ជិនោ ឥមេ អាវុសោ ឆព្វគ្គិយា ភិក្ខូ ន សក្កា ឥមេហិ សហ ភណ្ឌិតុន្តិ ។ ឆព្វគ្គិយា ភិក្ខូ ឯវំ វទន្តិ កិស្ស តុម្ហេ អាវុសោ អម្ហេ អលជ្ជិវាទេន បាបេថាតិ ។ កហំ បន តុម្ហេ អាវុសោ អស្សុត្ថាតិ ។ មយំ អាយស្មន្តានំ ឧបស្សុតឹ តិដ្ឋាមាតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ ឧបស្សុតឹ តិដ្ឋិស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ ឧបស្សុតឹ តិដ្ឋថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា

## សិក្ខាបទទី ៨

(៣៦៤) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុឈ្លោះនឹងភិក្ខុទាំងឡាយដែលមានសីលជាទីស្រឡាញ់ ។ ពួកភិក្ខុដែលមានសីលជាទីស្រឡាញ់និយាយគ្នាយ៉ាងនេះថា ម្នាលអាវុសោ ពួកឆព្វគ្គិយភិក្ខុទាំងនេះជាពួកអលជ្ជី ពួកយើងមិនអាចឈ្លោះនឹងពួកនេះទេ ។ ពួកឆព្វគ្គិយភិក្ខុ (ឮទាន់) ក៏និយាយយ៉ាងនេះថា ម្នាលអាវុសោ ព្រោះហេតុអ្វី អ្នកទាំងឡាយញ៉ាំងពួកយើងឲ្យដល់ដោយពាក្យថាអលជ្ជី ។ ពួកភិក្ខុមានសីលជាទីស្រឡាញ់សួរថា ម្នាលអាវុសោ ចុះពួកអ្នកបានឮក្នុងទីណា ។ ពួកឆព្វគ្គិយភិក្ខុឆ្លើយថា យើងទាំងឡាយឈរស្តាប់ពួកលោកដ៏មានអាយុ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ កាលភិក្ខុទាំងឡាយបង្កើតហេតុប្រកួតប្រកាន់ទាស់ទែងគ្នា មិនគួរនឹងឈរស្តាប់សោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា កាលភិក្ខុទាំងឡាយបង្កើតហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ពួកអ្នកឯងឈរស្តាប់ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ

កថំ ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ ឧបស្សុតឹ តិដ្ឋិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ភិក្ខូនំ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានំ ឧបស្សុតឹ តិដ្ឋេយ្យ យំ ឥមេ ភណិស្សន្តិ តំ សោស្សាមីតិ ឯតទេវ បច្ចយំ ករិត្វា អនញ្ញំ បាចិត្តិយន្តិ ។

[៣៣០] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ភិក្ខូនន្តិ អញ្ញេសំ ភិក្ខូនំ ។ ភណ្ឌនជាតានំ កលហជាតានំ វិវាទាបន្នានន្តិ អធិករណជាតានំ ។ ឧបស្សុតឹ តិដ្ឋេយ្យាតិ ឥមេសំ សុត្វា ចោទេស្សាមិ សារេស្សាមិ បដិចោទេស្សាមិ បដិសារេស្សាមិ មង្កុំ ករិស្សាមីតិ



ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ការដែលភិក្ខុទាំងឡាយ បង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ពួកអ្នកឯងមិនគួរនឹងឈរអែបស្ដាប់ទេ ម្នាលមោឃបុរសទាំងឡាយ អំពើនុ៎ះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយការដែលភិក្ខុទាំងឡាយ បង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា ទៅឈរអែបស្ដាប់ដោយគិតថា ភិក្ខុទាំងនេះនឹងពោលពាក្យណា អាត្មានឹងស្ដាប់ពាក្យនោះ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ព្រោះធ្វើកិរិយាឈរអែបស្ដាប់នោះជាហេតុពិត មិនមែនហេតុដទៃឡើយ ។

[៣៣០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ការដែលភិក្ខុទាំងឡាយ គឺការដែលភិក្ខុទាំងឡាយដទៃ ។ ពាក្យថា បង្កហេតុប្រកួតប្រកាន់ទាស់ទែងគ្នា គឺភិក្ខុទាំងនោះមានអធិករណៈកើតឡើងហើយ ។ ពាក្យថា ឈរអែបស្ដាប់ គឺភិក្ខុដើរទៅដោយគិតថា អាត្មាស្ដាប់ភិក្ខុទាំងនេះហើយនឹងចោទនឹងរំលឹក នឹងចោទចំពោះនឹងរំលឹកចំពោះ នឹងធ្វើឲ្យអៀនខ្មាស

គច្ឆតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតោ សុណាតិ អាបត្តិ បាចិត្តិយស្ស ។ បច្ឆតោ គច្ឆន្តោ តុរិតោ គច្ឆតិ សោស្សាមីតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតោ សុណាតិ អាបត្តិ បាចិត្តិយស្ស ។ បុរតោ គច្ឆន្តោ ឱហីយតិ សោស្សាមីតិ អាបត្តិ ទុក្កដស្ស ។ យត្ថ ឋិតោ សុណាតិ អាបត្តិ បាចិត្តិយស្ស ។ ភិក្ខុស្ស ឋិតោកាសំ វា និសិន្នោកាសំ វា និបន្នោកាសំ វា អាគន្ត្វា មន្តេន្តំ ឧក្កាសិតព្វំ វិជានាបេតព្វំ ។ នោ ចេ ឧក្កាសេយ្យ វា វិជានាបេយ្យ វា អាបត្តិ បាចិត្តិយស្ស ។ ឋិតកេ បច្ចយំ ការិត្វា អនញ្ញត្តិ ន អញ្ញោ កោចិ បច្ចយោ ហោតិ ឧបស្សុតិំ តិដ្ឋតិ ។

[៣៣១] ឧបសម្បន្នេ ឧបសម្បន្នសញ្ញី ឧបស្សុតិំ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ វេមតិកោ ឧបស្សុតិំ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ ឧបសម្បន្នេ អនុបសម្បន្នសញ្ញី ឧបស្សុតិំ តិដ្ឋតិ អាបត្តិ បាចិត្តិយស្ស ។ អនុបសម្បន្នស្ស ឧបស្សុតិំ តិដ្ឋតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ ឧបសម្បន្នសញ្ញី



ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនោះឈរស្ដាប់ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុដើរទៅតាមក្រោយ ដើរទៅដោយរហ័សដោយគិតថា អញនឹងស្ដាប់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរស្ដាប់ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុដើរទៅមុខហើយ ឈប់ដោយគិតថា អញនឹងស្ដាប់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុឈរស្ដាប់ក្នុងទីណា ត្រូវអាបត្តិបាចិត្តិយ ក្នុងទីនោះ ។ ភិក្ខុណាមកកាន់ទីឈរក្ដី ទីអង្គុយក្ដី ទីដេកក្ដី របស់ភិក្ខុដទៃ ភិក្ខុនោះគប្បីក្អក គប្បីញុំាងភិក្ខុដែលកំពុងប្រឹក្សាគ្នានោះឲ្យដឹង ។ បើភិក្ខុនោះមិនក្អកក្ដី មិនឲ្យគេដឹងក្ដី ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ព្រោះមកពីយោបល់ឈរ ដែលស្ដាប់នោះដោយហេតុគិត មិនមែនហេតុដទៃឡើយ សេចក្ដីថា ហេតុឯណានីមួយដទៃគ្មានទេ ចំពោះតែការឈរដែលស្ដាប់ប៉ុណ្ណោះឯង ។

[៣៣១] ឧបសម្បន្ន ភិក្ខុសំគាល់ថា ឧបសម្បន្ន ហើយឈរដែលស្ដាប់ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុមានសេចក្ដីសង្ស័យ ហើយឈរដែលស្ដាប់ ត្រូវអាបត្តិបាចិត្តិយ ។ ឧបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្ន ហើយឈរដែលស្ដាប់ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុឈរដែលស្ដាប់អនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា

អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នេ អនុបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស

[៣៣៤] អនាបត្តិ ឥមេសំ សុត្វា វូបសមិស្សាមិ វិរមិស្សាមិ វូបសមេស្សាមិ អត្តានំ បរិមោចេស្សាមីតិ គច្ឆតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



នុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថា អនុបសម្បន្នដដែល ត្រូវអាបត្តិទុក្កដ ។

[៣៣៤] ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុដើរទៅដោយគិតថា អញនឹងស្តាប់ភិក្ខុទាំងនេះហើយនឹងឈប់ចេញ នឹងវៀរ នឹងរម្ងាប់ (សេចក្តីប្រកួតប្រកាន់) នឹងដោះខ្លួន ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់ ។

## នវមសិក្ខាបទំ

[១១១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អនាចារំ អាចរិត្វា ឯកមេកស្ស កម្មេ កយិរមានេ បដិក្កោសន្តិ ។ តេន ខោ បន សមយេន សង្ឃស្ស សន្និបាតោ ហោតិ កេនចិទេវ ករណីយេន ។ ឆព្វគ្គិយា ភិក្ខូ ចីវរកម្មំ ករោន្តា ឯកស្ស ឆន្ទំ អទំសុ ។ អថខោ សង្ឃោ អយំ អាវុសោ ឆព្វគ្គិយោ ភិក្ខុ ឯកកោ អាគតោ ហន្ទស្ស មយំ កម្មំ ករោមាតិ តស្ស កម្មំ អកាសិ ។ អថខោ សោ ភិក្ខុ យេន ឆព្វគ្គិយា ភិក្ខូ តេនុបសង្កមិ ។ ឆព្វគ្គិយា ភិក្ខូ តំ ភិក្ខុំ ឯតទវោចុំ កឹ អាវុសោ សង្ឃោ អកាសីតិ ។ សង្ឃោ មេ អាវុសោ កម្មំ អកាសីតិ ។ ន មយំ អាវុសោ ឯតទត្ថាយ ឆន្ទំ អទម្ហា តុយ្ហំ កម្មំ ករិស្សតីតិ សចេ មយំ ជានេយ្យាម តុយ្ហំ កម្មំ ករិស្សតីតិ ន មយំ ឆន្ទំ

## សិក្ខាបទទី ៩

[១១១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុ បានប្រព្រឹត្តអនាចារ កាលសង្ឃធ្វើកម្ម (ដើម្បីដាក់ទោស) ដល់ភិក្ខុម្តងមួយរូប ៗ ក៏តាំងខ្លួននិយាយឃាត់ ។ គ្រានោះឯង សង្ឃបានប្រជុំគ្នាដោយសង្ឃកិច្ចនីមួយ ។ ឯពួកឆព្វគ្គិយភិក្ខុ កំពុងធ្វើចីវរកម្ម បានឲ្យឆន្ទៈ (សេចក្តីគាប់ចិត្តរបស់ខ្លួន) ដល់ភិក្ខុមួយរូប ។ គ្រានោះឯង សង្ឃប្រឹក្សាគ្នាថា ម្នាលអាវុសោ ឆព្វគ្គិយភិក្ខុនេះមកតែម្នាក់ឯង បើដូច្នោះ ពួកយើងត្រូវធ្វើកម្មដល់ភិក្ខុនោះចុះ ហើយបានធ្វើកម្មដល់ភិក្ខុនោះ ។ ទើបភិក្ខុនោះចូលទៅរកពួកឆព្វគ្គិយភិក្ខុ ។ ពួកឆព្វគ្គិយភិក្ខុបានសួរភិក្ខុនោះយ៉ាងនេះថា ម្នាលអាវុសោ សង្ឃបានធ្វើអ្វី ។ ភិក្ខុនោះប្រាប់ថា ម្នាលអាវុសោ សង្ឃបានធ្វើកម្មដល់ខ្ញុំ ។ ពួកឆព្វគ្គិយភិក្ខុបាននិយាយថា ម្នាលអាវុសោ យើងទាំងឡាយបានឲ្យឆន្ទៈ ដើម្បីជាប្រយោជន៍ដល់កម្មនេះដោយគិតថា សង្ឃនឹងធ្វើកម្មដល់លោកក៏ទេ បើយើងទាំងឡាយដឹងថាសង្ឃនឹងធ្វើកម្មដល់លោកសោត យើងទាំងឡាយ

ទទេយ្យាមាតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ធម្មិកានំ កម្មានំ ឆន្ទំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ បាចិត្តិយន្តិ ។

[៣៣៤] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ធម្មិកំ នាម កម្មំ អបលោកនកម្មំ ញត្តិកម្មំ



មិនឲ្យឆន្ទះទេ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងឲ្យឆន្ទះដល់សង្ឃកម្មទាំងឡាយដែលប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកឯងឲ្យឆន្ទះដើម្បីសង្ឃកម្មដែលប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងឲ្យឆន្ទះដើម្បីសង្ឃកម្មប្រកបដោយធម៌ ហើយត្រឡប់មកតិះដៀលជាខាងក្រោយវិញទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លា ហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យឆន្ទះដើម្បីកម្មទាំងឡាយដែលប្រកបដោយធម៌ ហើយពោលតិះដៀលជាខាងក្រោយ (ភិក្ខុនោះ) ត្រូវអាបត្តិបាចិត្តិយ ។

[៣៣៤] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃខាងដើមកណ្ឌ ។ កម្មដែលហៅថាប្រកបដោយធម៌នោះ

ញត្តិទុតិយកម្មំ ញត្តិចតុត្ថកម្មំ ធម្មេន វិនយេន សត្ថុ សាសនេន កតំ ឯតំ ធម្មិកំ នាម កម្មំ ។ ឆន្ទំ ទត្វា ខីយតិ អាបត្តិ បាចិត្តិយស្ស ។

(៣៣៨) ធម្មកម្មេ ធម្មកម្មសញ្ញី ឆន្ទំ ទត្វា ខីយតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ ឆន្ទំ ទត្វា ខីយតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី ឆន្ទំ ទត្វា ខីយតិ អនាបត្តិ ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អនាបត្តិ ។

(៣៣៩) អនាបត្តិ អធម្មេន វា វគ្គេន វា ន កម្មារហស្ស វា កម្មំ កតន្តិ ជានន្តោ ខីយតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។



គឺ អបលោកនកម្ម ១ ញត្តិកម្ម ១ ញត្តិទុតិយកម្ម ១ ញត្តិចតុត្ថកម្ម ១ ដែលសង្ឃធ្វើតាមធម៌តាមវិន័យ តាមពាក្យប្រដៅរបស់ព្រះសាស្តា កម្មនេះ ហៅថា កម្មប្រកបដោយធម៌ ។ ភិក្ខុឲ្យឆន្ទៈ ហើយត្រឡប់តិះដៀល (ជាខាងក្រោយវិញ) ត្រូវអាបត្តិបាចិត្តិយ ។

(៣៣៨) កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយឲ្យឆន្ទៈត្រឡប់តិះដៀលវិញ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយឲ្យឆន្ទៈត្រឡប់តិះដៀលវិញ ត្រូវអាបត្តិទុក្កដ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយឲ្យឆន្ទៈត្រឡប់តិះដៀល មិនត្រូវអាបត្តិ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ (ហើយឲ្យឆន្ទៈត្រឡប់តិះដៀល) ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិ ។

(៣៣៩) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុដឹងថាកម្មដែលសង្ឃធ្វើដោយមិនជាធម៌ក្តី ដោយពួកក្តី ដល់ភិក្ខុអ្នកមិនគួរដល់កម្មក្តី ហើយតិះដៀល ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៩ ចប់ ។

# ទសមសិក្ខាបទំ

[២៣៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សង្ឃោ សន្និបតិតោ ហោតិ កេនចិទេវ ករណីយេន ។ ឆព្វគ្គិយា ភិក្ខូ ចីវរកម្មំ ករោន្តា ឯកស្ស ឆន្ទំ អទំសុ ។ អថខោ សង្ឃោ យស្សត្ថាយ សន្និបតិតោ តំ កម្មំ ករិស្សាមាតិ ញត្តិំ ឋបេសិ ។ អថខោ សោ ភិក្ខុ ឯវមេវិមេ ឯកមេកស្ស កម្មំ ករោន្តិ កស្ស តុម្ហេ ឆន្ទំ ទស្សថាតិ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កាមិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមសីតិ ។ សច្ចំ ភគវាតិ ។

# សិក្ខាបទទី ១០

[២៣៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង សង្ឃបានប្រជុំគ្នាដោយសង្ឃកិច្ចឯណាមួយ ។ ពួកឆព្វគ្គិយភិក្ខុកំពុងធ្វើចីវរហើយបានឲ្យឆន្ទៈដល់ភិក្ខុមួយរូប ។ គ្រានោះឯង សង្ឃប្រជុំគ្នាដើម្បីប្រយោជន៍ដល់កម្មណា ហើយតាំងញត្តិឡើងដោយប្រាថ្នាថា យើងទាំងឡាយនឹងធ្វើនូវកម្មនោះ ។ ខណៈនោះ ភិក្ខុនោះបាននិយាយថា ភិក្ខុទាំងនេះតែងធ្វើកម្មដល់ភិក្ខុមួយរូបៗ យ៉ាងនេះឯង ( ថា ) លោកទាំងឡាយនឹងឲ្យឆន្ទៈដល់អ្នកណាបាន ហើយមិនឲ្យឆន្ទៈក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលសង្ឃកំពុងប្រកបវិនិច្ឆ័យ ភិក្ខុមិនបានឲ្យឆន្ទៈ មិនគួរនឹងក្រោកចាកអាសនៈចៀសចេញទៅសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថា កាលសង្ឃកំពុងប្រកបវិនិច្ឆ័យ ( គឺសង្ឃកំពុងវិនិច្ឆ័យរឿងក្តីមួយមិនទាន់ហើយ ) អ្នកឯងមិនបានឲ្យឆន្ទៈហើយក្រោកចាកអាសនៈចៀសចេញទៅពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា បពិត្រព្រះដ៏មានព្រះភាគ ពិតមែន ។

វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម ត្វំ មោឃបុរិស សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សង្ឃេ វិនិច្ឆយកថាយ វត្តមានាយ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមេយ្យ បាចិត្តិយន្តិ ។

(៣៣៨) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សង្ឃេ វិនិច្ឆយកថា នាម វត្ថុ វា អារោចិតំ ហោតិ អវិនិច្ឆិតំ ញត្តិ វា ឋបិតា ហោតិ កម្មវាចា វា វិប្បកតា ហោតិ ។ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមេយ្យាតិ កថំ ឥទំ កម្មំ កុប្បំ អស្ស វគ្គំ អស្ស ន ករេយ្យាតិ គច្ឆតិ អាបត្តិ ទុក្កដស្ស ។ បរិសាយ ហត្ថបាសំ វិជហន្តស្ស អាបត្តិ ទុក្កដស្ស ។ វិជហិតេ អាបត្តិ បាចិត្តិយស្ស ។



ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស កាលសង្ឃកំពុងប្រឹក្សាវិនិច្ឆ័យ ហេតុអ្វីក៏អ្នកឯង មិនឲ្យឆន្ទៈហើយក្រោកចាកអាសនៈចៀសចេញទៅ ម្នាលមោឃបុរស អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ កាលពាក្យវិនិច្ឆ័យកំពុងប្រព្រឹត្តទៅក្នុងសង្ឃ មិនឲ្យឆន្ទៈហើយក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។

(៣៣៨) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី១ នៃបារាជិកកណ្ឌ ។ រឿងដែលសង្ឃប្រាប់ហើយ តែមិនទាន់បានវិនិច្ឆ័យក្តី ញត្តិសង្ឃតាំងទុកហើយក្តី កម្មវាចាសង្ឃផ្តើមមិនទាន់ហើយក្តី ឈ្មោះថាពាក្យវិនិច្ឆ័យ(កំពុងប្រព្រឹត្តទៅ)ក្នុងសង្ឃ ។ ពាក្យថា ភិក្ខុមិនឲ្យឆន្ទៈហើយក្រោកចាកអាសនៈចៀសចេញទៅ សេចក្តីថា ភិក្ខុចេញទៅដោយគិតថា មិនដឹងជាការអ្វី កម្មនេះជាកម្មកំរើកទេ ជាពួកទេ សង្ឃមិនត្រូវធ្វើទេ ត្រូវអាបត្តិទុក្កដ ។ កាលភិក្ខុកំពុងលះហត្ថបាសបរិសទ្យ ត្រូវអាបត្តិទុក្កដ ។ កាលលះហត្ថបាសហើយ ត្រូវអាបត្តិបាចិត្តិយ ។

[៣១៩] ធម្មកម្មេ ធម្មកម្មសញ្ញី ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមតិ អាបត្តិ ទុក្កដស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី ឆន្ទំ អទត្វា ឧដ្ឋាយាសនា បក្កមតិ អនាបត្តិ ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អនាបត្តិ ។

[៣២០] អនាបត្តិ សង្ឃស្ស ភណ្ឌនំ វា កលហោ វា វិគ្គហោ វា វិវាទោ វា ភវិស្សតីតិ គច្ឆតិ សង្ឃភេទោ វា សង្ឃរាជិ វា ភវិស្សតីតិ គច្ឆតិ អធម្មេន វា វគ្គេន វា ន កម្មារហស្ស វា



[៣១៩] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថា កម្មប្រកបដោយធម៌ ហើយមិនឲ្យឆន្ទៈក្រោកចាកអាសនៈចៀសចេញទៅ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្ដីសង្ស័យ ហើយមិនឲ្យឆន្ទៈ ក្រោកចាកអាសនៈ ចៀសចេញទៅ ត្រូវអាបត្តិទុក្កដ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយមិនឲ្យឆន្ទៈ ក្រោកចាកអាសនៈចៀសចេញទៅ មិនត្រូវអាបត្តិ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ (ហើយមិនឲ្យឆន្ទៈ ក្រោកចាកអាសនៈចៀសចេញទៅ) ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្ដីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ មិនត្រូវអាបត្តិ ។

[៣២០] ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៤ យ៉ាង)- គឺភិក្ខុទៅ ដោយគិតថា សេចក្ដីបរិហានក្ដី សេចក្ដីប្រកួតប្រកាន់ក្ដី សេចក្ដីប្រកាន់ខុសគ្នាក្ដី សេចក្ដីតាស់តែងក្ដី នឹងមានដល់សង្ឃ ១ ភិក្ខុទៅដោយគិតថា ការបែកធ្លាយនៃសង្ឃក្ដី ការប្រេះឆានៃសង្ឃក្ដី នឹងមាន ១ ភិក្ខុទៅដោយគិតថា សង្ឃនឹងធ្វើកម្មមិនប្រកបដោយធម៌ក្ដី នឹងធ្វើកម្មជាពួកក្ដី នឹងធ្វើកម្មដល់ភិក្ខុដែលមិនគួរដល់កម្មក្ដី ១

កម្មំ ករិស្សតីតិ គច្ឆតិ គិលានោ គច្ឆតិ គិលានស្ស ករណីយេន គច្ឆតិ ឧច្ចារេន វា បស្សាវេន វា បីឡិតោ គច្ឆតិ ន កម្មំ កោបេតុកាមោ បុន បច្ចាគមិស្សាមីតិ គច្ឆតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។



ភិក្ខុមានជម្ងឺឡើងសោះចេញទៅ ១ ភិក្ខុទៅដោយកិច្ចដែលត្រូវធ្វើដល់ភិក្ខុឈឺ ១ ភិក្ខុដែលឧច្ចារៈ បស្សាវៈ បៀតបៀនហើយទៅ ១ ភិក្ខុមិនប្រាថ្នាដើម្បីនឹងញុំាងកម្មឲ្យកម្រើកហើយចេញទៅដោយគិតថា អញនឹងត្រឡប់មកវិញទៀត ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១០ ចប់ ។

## ឯកាទសមសិក្ខាបទំ

[៣៤៦] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន អាយស្មា ទព្វោ មល្លបុត្តោ សង្ឃស្ស សេនាសនញ្ច បញ្ញាបេតិ ភត្តានិ ច ឧទ្ទិសតិ ។ សោ ចាយស្មា ទុព្វលចីវរោ ហោតិ ។ តេន ខោ បន សមយេន សង្ឃស្ស ឯកំ ចីវរំ ឧប្បន្នំ ហោតិ ។ អថ ខោ សង្ឃោ តំ ចីវរំ អាយស្មតោ ទព្វស្ស មល្លបុត្តស្ស អទាសិ ។ ឆព្ពគ្គិយា ភិក្ខូ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ យថាសន្ថុតំ ភិក្ខូ សង្ឃិកំ លាភំ បរិណាមេន្តីតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ សមគ្គេន សង្ឃេន ចីវរំ ទត្វា បច្ឆា ខីយធម្មំ អាបជ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ សមគ្គេន សង្ឃេន ចីវរំ ទត្វា បច្ឆា ខីយធម្មំ អាបជ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា សមគ្គេន

## សិក្ខាបទទី ១១

[៣៤០] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង ព្រះទព្វមល្លបុត្រដ៏មានអាយុ តាក់តែងសេនាសនៈ និងសំដែងភត្តដល់សង្ឃ ។ ព្រះទព្វមល្លបុត្រដ៏មានអាយុនោះជាអ្នកមានចីវរទ្រុឌទ្រោម ។ សម័យនោះឯង ចីវរ ១ បានកើតឡើងដល់សង្ឃ ។ សង្ឃឲ្យចីវរនោះដល់ព្រះទព្វមល្លបុត្រដ៏មានអាយុ ។ ពួកឆព្វគ្គិយភិក្ខុនាំគ្នាពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយបង្អោនលាភរបស់សង្ឃទៅតាមសេចក្តីស្និទ្ធស្នាល ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ការដែលសង្ឃព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយ ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងមកតិះដៀលជាខាងក្រោយសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាសង្ឃព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយ អ្នកទាំងឡាយត្រឡប់មកតិះដៀលជាខាងក្រោយវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធមានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ (ការដែល) សង្ឃព្រមព្រៀងគ្នា

សង្ឃេន ចីវរំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ។ យោ បន ភិក្ខុ សមគ្គេន សង្ឃេន ចីវរំ ទត្វា បច្ឆា ខីយនធម្មំ អាបជ្ជេយ្យ យថាសន្ថុតំ ភិក្ខូ សង្ឃិកំ លាភំ បរិណាមេន្តីតិ បាចិត្តិយន្តិ ។

[៣៤៥] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សមគ្គោ នាម សង្ឃោ សមានសំវាសកោ សមានសីមាយំ ឋិតោ ។ ចីវរំ នាម ឆន្នំ ចីវរានំ អញ្ញតរំ ចីវរំ វិកប្បនុបគំ បច្ឆិមំ ។ ទត្វាតិ សយំ ទត្វា ។ យថាសន្ថុតំ នាម យថាមិត្តតា យថាសន្ទិដ្ឋតា យថាសម្ភត្តតា យថាសមានុបជ្ឈាយកតា យថាសមានា-



ឲ្យចីវរ (ដល់ភិក្ខុ) ហើយ មិនគួរនឹងពួកអ្នកឯង តិះដៀលជាខាងក្រោយវិញទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លាទេ ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ (កាលបើ) សង្ឃព្រមព្រៀងគ្នាឲ្យចីវរ (ដល់ភិក្ខុ) ហើយ ក៏ដល់នូវធម៌គឺតិះដៀលជាខាងក្រោយវិញថា ភិក្ខុទាំងឡាយបង្អោនលាភរបស់សង្ឃ តាមសេចក្ដីគាប់ចិត្ត ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

(៣៤៦) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចខាងដើម សិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ សង្ឃមានសំវាសស្មើគ្នា ឋិតនៅក្នុងសីមាស្មើគ្នា ហៅថា ព្រមព្រៀងគ្នា ។ ដែលហៅថា ចីវរ គឺបណ្ដាចីវរ ៦ យ៉ាង ចីវរណាមួយ យ៉ាងតូចបំផុតល្មមនឹងវិកប្បបាន(១) ។ ពាក្យថា ឲ្យ គឺឲ្យដោយខ្លួនឯង ។ ដែលហៅថា តាមសេចក្ដីគាប់ចិត្តនោះ គឺតាមបុគ្គលដែលជាមិត្ត តាមបុគ្គលដែលធ្លាប់ស្គាល់គ្នា តាមបុគ្គលដែលធ្លាប់គប់គ្នា តាមបុគ្គលដែលមានឧបជ្ឈាយ៍ស្មើគ្នា តាមបុគ្គល

---

១ គន្លឹកថា ចាប់តាំងពីសំពត់ដែលមាន បណ្ដោយ ៨ ធ្នាប់ ទទឹង ៤ ធ្នាប់ដោយធ្នាប់ព្រះសុគតឡើងទៅ ហៅថា សម្ពត់ល្មមដល់ការវិកប្ប ។

ចរិយកតា ។ សង្ឃិកំ នាម សង្ឃស្ស ទិន្នំ ហោតិ បរិច្ចត្តំ ។ លាភោ នាម ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា អន្តមសោ ចុណ្ណបិណ្ឌោបិ ទន្តកដ្ឋម្បិ ទសិកសុត្តម្បិ ។ បច្ឆា ខីយនធម្មំ អាបជ្ជេយ្យាតិ ឧបសម្បន្នស្ស សង្ឃេន សម្មតស្ស សេនាសនបញ្ញាបកស្ស វា ភត្តុទ្ទេសកស្ស វា យាគុភាជកស្ស វា ផលភាជកស្ស វា ខជ្ជភាជកស្ស វា អប្បមត្តកវិស្សជ្ជកស្ស វា ចីវរំ ទិន្នេ ខីយតិ អាបត្តិ បាចិត្តិយស្ស ។

[៣៤៣] ធម្មកម្មេ ធម្មកម្មសញ្ញី ចីវរំ ទិន្នេ ខីយតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ វេមតិកោ ចីវរំ ទិន្នេ ខីយតិ អាបត្តិ បាចិត្តិយស្ស ។ ធម្មកម្មេ អធម្មកម្មសញ្ញី ចីវរំ ទិន្នេ ខីយតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញំ បរិក្ខារំ ទិន្នេ ខីយតិ អាបត្តិ ទុក្កដស្ស ។ ឧបសម្បន្នស្ស សង្ឃេន អសម្មតស្ស សេនាសនបញ្ញាបកស្ស វា ភត្តុទ្ទេសកស្ស វា យាគុភាជកស្ស វា



ដែលមានអាចារ្យស្មើគ្នា ។ ដែលហៅថា របស់សង្ឃនោះ បានដល់លាភដែលគេលះបង់ប្រគេនដល់សង្ឃ ។ ដែលហៅថា លាភនោះ បានដល់ចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់មនុស្សឈឺ ដោយហោចទៅសូម្បីតែដុំលំអិតក្តី ឈើស្ទន់ក្តី អម្បោះរវៃជើងចីវរក្តី (ក៏ហៅជាលាភ) ។ ពាក្យថា ដល់នូវធម៌គឺការយកតិះដៀល ជាខាងក្រោយ សេចក្តីថា ភិក្ខុតិះដៀលសង្ឃដែលបានឲ្យចីវរ ដល់ឧបសម្បន្នដែលសង្ឃសន្មតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ជាអ្នកសំដែងនូវភត្តក្តី ជាអ្នកចែកនូវបបរក្តី ជាអ្នកចែកនូវផ្លែឈើក្តី ជាអ្នកចែកនូវបង្អែមក្តី ជាអ្នកលះចែកនូវគ្រឿងបន្តិចបន្តួចក្តី ត្រូវអាបត្តិបាចិត្តិយ ។

[៣៤៣] កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ហើយតិះដៀលសង្ឃដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ហើយតិះដៀលសង្ឃដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ ។ កម្មប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ហើយតិះដៀលសង្ឃដែលបានឲ្យចីវរ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុតិះដៀលសង្ឃដែលបានឲ្យបរិក្ខារដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុតិះដៀលសង្ឃដែលបានឲ្យចីវរឬបរិក្ខារដទៃ ដល់ឧបសម្បន្នដែលសង្ឃមិនបានសន្មតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ជាអ្នកសំដែងនូវភត្តក្តី ជាអ្នក

ផលភាជកស្ស វា ខជ្ជភាជកស្ស វា អប្បមត្តក-វិស្សជ្ជកស្ស វា ចីវរំ វា បត្តំ វា បរិក្ខារំ ទិន្នេ ខីយតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នស្ស សង្ឃេន សម្មតស្ស វា អសម្មតស្ស វា សេនាសនបញ្ញាបកស្ស វា ភត្តុទ្ទេសកស្ស វា យាគុភាជកស្ស វា ផលភាជកស្ស វា ខជ្ជភាជកស្ស វា អប្បមត្តកវិស្សជ្ជកស្ស វា ចីវរំ វា បត្តំ វា បរិក្ខារំ ទិន្នេ ខីយតិ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ ធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អធម្មកម្មេ អធម្មកម្មសញ្ញី អាបត្តិ ទុក្កដស្ស ។

(៣៦៦) អនាបត្តិ បកតិយា ឆន្ទា ទោសា មោហា ភយា ករោន្តំ ក្វត្ថោ តស្ស ទិន្នេន លទ្ធាបិ វិនិបាតេស្សតិ ន សម្មា ឧបនេស្សតីតិ ខីយតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។



ចែកនូវបបរក្តី ជាអ្នកចែកនូវផ្លែឈើក្តី ជាអ្នកចែកនូវបង្អែមក្តី ជាអ្នកចាត់ចែងនូវគ្រឿងបន្តិចបន្តួចក្តី ត្រូវអាបត្តិទុក្កដ ។ ភិក្ខុតិះដៀលសង្ឃដែលបានឲ្យចីវរ ឬបរិក្ខារដទៃ ដល់អនុបសម្បន្នដែលសង្ឃសន្មតឬមិនបានសន្មតឲ្យជាអ្នកក្រាលនូវសេនាសនៈក្តី ជាអ្នកសំដែងនូវភត្តក្តី ជាអ្នកចែកនូវបបរក្តី ជាអ្នកចែកនូវផ្លែឈើក្តី ជាអ្នកចែកនូវបង្អែមក្តី ជាអ្នកចាត់ចែងនូវគ្រឿងបន្តិចបន្តួចក្តី ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កម្មមិនប្រកបដោយធម៌ ភិក្ខុសំគាល់ថាកម្មមិនប្រកបដោយធម៌ ត្រូវអាបត្តិទុក្កដ ។

(៣៦៦) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺភិក្ខុតិះដៀលសង្ឃអ្នកធ្វើ ព្រោះឆន្ទាគតិ ទោសាគតិ មោហាគតិ ភយាគតិដោយប្រក្រតី ប្រយោជន៍អ្វីដោយលាភ ដែលសង្ឃឲ្យដល់ភិក្ខុនោះ ភិក្ខុនោះទុកជាបានហើយក៏នឹងធ្វើលាភនោះឲ្យវិនាសទៅដែល មិនមែនបាននាំយកទៅដោយប្រពៃ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១០ ចប់ ។

## ទ្វាទសមសិក្ខាបទំ

(៣៤៩) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរស្ស បូគស្ស សង្ឃស្ស សចីវរភត្តំ បដិយត្តំ ហោតិ ភោជេត្វា ចីវរេន អច្ឆាទេស្សាមាតិ ។ អថខោ ឆព្ពគ្គិយា ភិក្ខូ យេន សោ បូគោ តេនុបសង្កមឹសុ ឧបសង្កមិត្វា តំ បូគំ ឯតទវោចុំ ទេថាវុសោ អម្ហាកំ ឥមានិ ចីវរានិ ភិក្ខូនន្តិ ។ ន មយំ ភន្តេ ទស្សាម អម្ហាកំ សង្ឃស្ស អនុវស្សំ សចីវរភិក្ខា បញ្ញត្តាតិ ។ ពហូ អាវុសោ សង្ឃស្ស ទាយកា ពហូ សង្ឃស្ស ភត្តា មយំ តុម្ហេ និស្សាយ តុម្ហេ សម្បស្សន្តា ឥធ វិហរាម តុម្ហេ ចេ អម្ហាកំ ន ទស្សថ អថ កោ ចរហិ អម្ហាកំ ទស្សតិ ទេថាវុសោ អម្ហាកំ ឥមានិ ចីវរានិ ភិក្ខូនន្តិ ។ អថខោ សោ បូគោ ឆព្ពគ្គិយេហិ ភិក្ខូហិ

## សិក្ខាបទទី ១២

(៣៤៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ប្រជុំជនពួកមួយក្នុងក្រុងសាវត្ថី តាំងភត្តព្រមទាំងចីវរទុកដើម្បីថ្វាយសង្ឃ ដោយគិតថា យើងនឹងឲ្យភិក្ខុឆាន់ ហើយនឹងប្រគេនចីវរ ។ លំដាប់នោះ ពួកឆព្វគ្គិយភិក្ខុចូលទៅរកប្រជុំជននោះ លុះចូលទៅហើយ បាននិយាយពាក្យនេះនឹងប្រជុំជននោះថា ម្នាលអាវុសោ ពួកអ្នកចូរឲ្យចីវរទាំងនេះដល់ភិក្ខុទាំងឡាយនេះ ។ ពួកជនទាំងនោះបាននិយាយតបវិញថា ព្រះករុណា ពួកខ្ញុំមិនថ្វាយទេ ពួកខ្ញុំតាំងភត្តព្រមទាំងចីវរទុកដើម្បីថ្វាយសង្ឃរាល់ៗឆ្នាំ ។ ពួកឆព្វគ្គិយភិក្ខុនិយាយតបវិញថា ម្នាលអាវុសោ ទាយករបស់សង្ឃមានច្រើន ភត្តរបស់សង្ឃក៏មានច្រើន ភិក្ខុអាត្មាទាំងនេះបានពឹងផ្អែកលើអ្នកទាំងឡាយ បានជួបប្រទះអ្នកទាំងឡាយ ទើបមកគង់នៅក្នុងទីនេះបាន បើអ្នកទាំងឡាយមិនប្រគេនដល់លោកទាំងនេះ ចុះអ្នកណាទៀតនឹងប្រគេនដល់លោកទាំងនេះបាន ម្នាលអាវុសោ ចូរអ្នកទាំងឡាយឲ្យចីវរទាំងឡាយនេះដល់ភិក្ខុអាត្មាទាំងនេះ ។ ប្រជុំជននោះ កាលត្រូវពួកឆព្វគ្គិយភិក្ខុ

និប្បីឡិយមានោ យថាបដិយត្តំ ចីវរំ ឆព្វគ្គិយានំ ភិក្ខូនំ ទត្វា សង្ឃំ ភត្តេន បរិវិសិ ។ យេ តេ ភិក្ខូ ជានន្តិ សង្ឃស្ស សចីវរភត្តំ បដិយត្តំ ន ច ជានន្តិ ឆព្វគ្គិយានំ ភិក្ខូនំ ទិន្នន្តិ តេ ឯវមាហំសុ ឱណោជេថ អាវុសោ សង្ឃស្ស ចីវរន្តិ ។ នត្ថិ ភន្តេ យថាបដិយត្តំ ចីវរំ អយ្យា ឆព្វគ្គិយា អយ្យានំ ឆព្វគ្គិយានំ បរិណាមេសុន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គលស្ស បរិណាមេស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គលស្ស បរិណាមេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គលស្ស បរិណាមេស្សថ





ខ្ទើះ ទៀត ទើបឲ្យចីវរដែលខ្លួនតាក់តែងទុក ដល់ពួកឆព្វគ្គិយភិក្ខុអស់ទៅ ហើយអង្គាសសង្ឃដោយភត្តប៉ុណ្ណោះ ។ ភិក្ខុទាំងឡាយណា ដឹងថា ភត្តព្រមទាំងចីវរដែលប្រជុំជនតាក់តែងទុកដើម្បីឲ្យសង្ឃ តែមិនដឹងថា គេឲ្យដល់ពួកឆព្វគ្គិយភិក្ខុទៅហើយ ភិក្ខុទាំងឡាយនោះបាននិយាយយ៉ាងនេះ (នឹងប្រជុំជននោះ) ថា ម្នាលអាវុសោ អ្នកទាំងឡាយចូរបង្អោនថ្វាយចីវរដល់សង្ឃចុះ ។ ប្រជុំជននោះបាននិយាយប្រាប់ថា បពិត្រព្រះករុណា ចីវរដែលតាក់តែងទុកនោះគ្មានទេ លោកម្ចាស់ឆព្វគ្គិយទាំងឡាយបង្អោនទៅដើម្បីពួកលោកម្ចាស់ឆព្វគ្គិយអស់ទៅហើយ ។ ភិក្ខុទាំងឡាយណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុកាលបើដឹងថា លាភរបស់សង្ឃគេបង្អោន (ដើម្បីសង្ឃ) ទៅហើយ មិនគួរនឹងបង្អោនទៅដើម្បីបុគ្គលសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយកាលបើដឹងថា លាភរបស់សង្ឃដែលគេបង្អោនទៅដើម្បីសង្ឃហើយ ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយកាលបើដឹងថា លាភរបស់សង្ឃគេបង្អោនទៅ

នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ ជានំ សង្ឃិកំ លាភំ បរិណតំ បុគ្គលស្ស បរិណាមេយ្យ បាចិត្តិយន្តិ ។

[៣៤៦] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ជានាតិ នាម សាមំ វា ជានាតិ អញ្ញេ វា តស្ស អារោចេន្តិ សោ វា អារោចេតិ ។ សង្ឃិកំ នាម សង្ឃស្ស ទិន្នំ ហោតិ បរិច្ចត្តំ ។ លាភោ នាម ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារា អន្តមសោ ចុណ្ណបិណ្ឌោបិ ទន្តកដ្ឋម្បិ ទសិកសុត្តម្បិ ។ បរិណតំ នាម ទស្សាម ករិស្សាមាតិ វាចា ភិន្នា ហោតិ ។ បុគ្គលស្ស បរិណាមេតិ អាបត្តិ បាចិត្តិយស្ស ។



(ដើម្បីសង្ឃហើយ) ហេតុអ្វីបានជាបង្អោនទៅដើម្បីបុគ្គលវិញ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយដឹងថា លាភរបស់សង្ឃគេបង្អោនទៅ (ដើម្បីសង្ឃហើយ) ត្រឡប់បង្អោនទៅដើម្បីបុគ្គលវិញ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។

[៣៤៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីថា ដូចគ្នានឹងសិក្ខាបទទី ១ នៃពួកចតុក្កកណ្ឌ ។ ដែលហៅថា ដឹង គឺភិក្ខុដឹងដោយខ្លួនឯងក្តី ពួកអ្នកដទៃប្រាប់ភិក្ខុនោះក្តី អ្នកម្ចាស់ទាននោះប្រាប់ (ដល់ភិក្ខុនោះ) ក្តី ។ ដែលហៅថា របស់សង្ឃ គឺលាភដែលទាយកបានថ្វាយ បានបរិច្ចាគដល់សង្ឃ ។ ដែលហៅថា លាភនោះ បានដល់ចីវរ បិណ្ឌបាត សេនាសនៈ និងបរិក្ខារគឺថ្នាំជាបច្ច័យដល់មនុស្សឈឺ ដោយហោចទៅ សូម្បីតែដុំនៃលំអិតក្តី ឈើស្ទន់ក្តី អម្បោះនៃជើងជម្ពញក្តី (គេហៅថាលាភក្នុងសិក្ខាបទនេះ) ។ ដែលហៅថា គេបង្អោនទៅ គឺម្ចាស់របស់គេបញ្ចេញវាចាថា ពួកខ្ញុំនឹងថ្វាយ ពួកខ្ញុំនឹងធ្វើ ។ ភិក្ខុបង្អោនទៅដើម្បីបុគ្គលវិញ ត្រូវអាបត្តិបាចិត្តិយ ។

[១៥៧] បរិណតេ បរិណតសញ្ញី បុគ្គលស្ស បរិណាមេតិ អាបត្តិ បាចិត្តិយស្ស ។ បរិណតេ វេមតិកោ បុគ្គលស្ស បរិណាមេតិ អាបត្តិ ទុក្កដស្ស ។ បរិណតេ អបរិណតសញ្ញី បុគ្គលស្ស បរិណាមេតិ អនាបត្តិ ។ សង្ឃស្ស បរិណតំ អញ្ញស្ស សង្ឃស្ស វា ចេតិយស្ស វា បរិណាមេតិ អាបត្តិ ទុក្កដស្ស ។ ចេតិយស្ស បរិណតំ អញ្ញស្ស ចេតិយស្ស វា សង្ឃស្ស វា បុគ្គលស្ស វា បរិណាមេតិ អាបត្តិ ទុក្កដស្ស ។ បុគ្គលស្ស បរិណតំ អញ្ញស្ស បុគ្គលស្ស វា សង្ឃស្ស វា ចេតិយស្ស វា បរិណាមេតិ អាបត្តិ ទុក្កដស្ស ។ អបរិណតេ បរិណតសញ្ញី អាបត្តិ ទុក្កដស្ស ។ អបរិណតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អបរិណតេ អបរិណតសញ្ញី អនាបត្តិ ។



[១៥៧] លាភគេបង្អោនទៅហើយ ភិក្ខុសំគាល់ថាគេបង្អោនទៅហើយ ក្រឡប់បង្អោនមកដើម្បីបុគ្គលវិញ ត្រូវអាបត្តិបាចិត្តិយ ។ លាភគេបង្អោនទៅហើយ ភិក្ខុមានសេចក្តីសង្ស័យ ហើយបង្អោនមកដើម្បីបុគ្គលវិញ ត្រូវអាបត្តិទុក្កដ ។ លាភគេបង្អោនទៅហើយ ភិក្ខុសំគាល់ថា គេមិនទាន់បង្អោនទៅទេ ហើយបង្អោនមកដើម្បីបុគ្គល មិនត្រូវអាបត្តិឡើយ ។ លាភគេបង្អោនទៅ ដើម្បីសង្ឃ តែភិក្ខុបង្អោនមក ដើម្បីសង្ឃដទៃវិញក្តី ដើម្បីចេតិយក្តី ត្រូវអាបត្តិទុក្កដ ។ លាភគេបង្អោនទៅហើយដើម្បីចេតិយ ភិក្ខុបង្អោនមកដើម្បីចេតិយដទៃវិញក្តី ដើម្បីសង្ឃក្តី ដើម្បីបុគ្គលក្តី ត្រូវអាបត្តិទុក្កដ ។ លាភគេបង្អោនទៅដើម្បីបុគ្គលហើយ ភិក្ខុក្រឡប់បង្អោនមក ដើម្បីបុគ្គលដទៃវិញក្តី ដើម្បីសង្ឃក្តី ដើម្បីចេតិយក្តី ត្រូវអាបត្តិទុក្កដ ។ លាភគេមិនទាន់បង្អោនទៅទេ ភិក្ខុសំគាល់ថាគេបង្អោនទៅហើយ ត្រូវអាបត្តិទុក្កដ ។ លាភគេមិនទាន់បង្អោនទៅទេ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ លាភគេមិនទាន់បង្អោនទៅទេ ភិក្ខុសំគាល់ថាគេមិនទាន់បង្អោនទេ មិនត្រូវអាបត្តិ ។

[៣៦៨] អនាបត្តិ កត្ថ ទេមាតិ បុច្ឆិយមានោ យត្ថ តុម្ហាកំ ទេយ្យធម្មោ បរិភោគំ វា លភេយ្យ បដិសង្ខារំ(១) វា លភេយ្យ ចិរដ្ឋិតិកោ វា អស្ស យត្ថ វា បន តុម្ហាកំ ចិត្តំ បសីទតិ តត្ថ ទេថាតិ ភណតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទ្វាទសមសិក្ខាបទំ និដ្ឋិតំ ។

សហធម្មិកវគ្គោ អដ្ឋមោ ។

តស្សុទ្ទានំ

សហធម្មវិលេខញ្ច មោហាបនប្បហារកំ
តលសត្តិ អមូលញ្ច សញ្ចិច្ច ច ឧបស្សុតិ
បដិពាហនឆន្ទញ្ច ទព្វញ្ច បរិណាមនន្តិ ។

១ បដិសង្ខារន្តិ បាឋោ ខេត្តកេ ទិស្សតិ ។





[៣៦៨] ភិក្ខុមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៣ យ៉ាង) គឺកាលបើពួកឧបាសកសួរថា ពួកខ្ញុំនឹងថ្វាយក្នុងទីណា ភិក្ខុឆ្លើយថា ទេយ្យធម៌របស់អ្នកទាំងឡាយ នឹងបានបរិភោគក្តី នឹងបានការជួសជុលក្តី នឹងបានតាំងនៅយូរអង្វែងក្តី ក្នុងទីណា មួយទៀតចិត្តរបស់អ្នកទាំងឡាយជ្រះថ្លាក្នុងទីណា អ្នកទាំងឡាយ ចូរថ្វាយក្នុងទីនោះចុះ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១២ ចប់ ។

សហធម្មិកវគ្គ ទី ៨ ចប់ ។

ឧទ្ទាននៃសហធម្មិកវគ្គនោះ (មាន ១២ សិក្ខាបទ) គឺ

សហធម្មិកសិក្ខាបទ ១ វិលេខនសិក្ខាបទ ១
មោហាបនសិក្ខាបទ ១ បហារកសិក្ខាបទ ១
តលសត្តិកសិក្ខាបទ ១ អមូលកសិក្ខាបទ ១
សញ្ចិច្ចសិក្ខាបទ ១ ឧបស្សុតិសិក្ខាបទ ១
បដិពាហនសិក្ខាបទ ១ ឆន្ទសិក្ខាបទ ១
ទព្វសិក្ខាបទ ១ បរិណាមនសិក្ខាបទ ១ ។

## រាជវគ្គស្ស បឋមសិក្ខាបទំ

[៣៦៤] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ ឧយ្យានបាលំ អាណាបេសិ គច្ឆ ភណេ ឧយ្យានំ សោធេហិ ឧយ្យានំ គមិស្សាមាតិ ។ ឯវំ ទេវាតិ ខោ សោ ឧយ្យានបាលោ រញ្ញោ បសេនទិស្ស កោសលស្ស បដិស្សុណិត្វា ឧយ្យានំ សោធេន្តោ អទ្ទស ភគវន្តំ អញ្ញតរស្មឹ រុក្ខមូលេ និសិន្នំ ទិស្វាន យេន រាជា បសេនទិ កោសលោ តេនុបសង្កមិ ឧបសង្កមិត្វា រាជានំ បសេនទឹ កោសលំ ឯតទវោច សុទ្ធំ(១) ទេវ ឧយ្យានំ អបិច ភគវា តត្ថ និសិន្នោតិ ។ ហោតុ ភណេ មយំ ភគវន្តំ បយិរុបាសិស្សាមាតិ ។ អថខោ រាជា បសេនទិ កោសលោ ឧយ្យានំ គន្ត្វា យេន ភគវា តេនុបសង្កមិ ។ តេន ខោ បន សមយេន អញ្ញតរោ ឧបាសកោ ភគវន្តំ បយិរុបាសន្តោ និសិន្នោ

១ សុទ្ធំ ភាណិ ឥន្ទំ ពោត្ថកេ ទិស្សតិ ។

## រាជវគ្គ សិក្ខាបទទី ១

[៣៦៤] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ស្តេចព្រះនាមបសេនទិកោសល ទ្រង់ត្រាស់បង្គាប់នាយឧយ្យានបាល (អ្នករក្សាឧទ្យាន) ថា ម្នាលនាយ ឯងចូរទៅជម្រះសំអាតឧទ្យាន យើងនឹងទៅឧទ្យាន ។ នាយឧយ្យានបាលនោះទទួលព្រះឱង្ការរបស់ព្រះបាទបសេនទិកោសលថា បពិត្រព្រះសម្មតិទេព យ៉ាងហ្នឹងហើយ ។ កំពុងជម្រះឧទ្យាន ទទួលបានឃើញព្រះដ៏មានព្រះភាគគង់នៅក្រោមម្លប់ឈើមួយ លុះឃើញហើយ ក៏ចូលទៅគាល់ព្រះបាទបសេនទិកោសល លុះចូលទៅដល់ហើយបានក្រាបទូលព្រះបាទបសេនទិកោសលយ៉ាងនេះថា សូមទ្រង់ម្ចាស់ទ្រាប ឧទ្យានស្អាតបាតហើយ ម្យ៉ាងទៀតព្រះដ៏មានព្រះភាគក៏គង់ក្នុងទីនោះដែរ ។ ព្រះបាទបសេនទិកោសលទ្រង់តបថា ម្នាលនាយ បើដូច្នោះ យើងនឹងទៅគាល់ព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រះបាទបសេនទិកោសលទ្រង់យាងទៅកាន់ឧទ្យាន ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ វេលានោះឯង មានឧបាសកម្នាក់កំពុងអង្គុយ

ហោតិ ។ អទ្ទសា ខោ ភគវា បសេនទិ កោសលោ
តំ ឧបាសកំ ភគវន្តំ បយិរុបាសន្តំ និសិន្នំ ទិស្វាន
គិហេ អជ្ឈាសំ ។ អថខោ រញ្ញោ បសេនទិស្ស កោ-
សលស្ស ឯតទហោសិ កោ នាមាយំ បុរិសោ ឱរកោ
ហោតុ យថា ភគវន្តំ បយិរុបាសតីតិ ។ យេន ភគវា
តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯក-
មន្តំ និសីទិ ។ អថខោ សោ ឧបាសកោ ភគវតោ
គារវេន រញ្ញោ បសេនទិ កោសលស្ស នេវ អភិវាទេសិ
ន បច្ចុដ្ឋាសិ ។ អថខោ រាជា បសេនទិ កោសលោ
អនត្តមនោ អហោសិ កថំ ហិ នាម អយំ បុរិសោ
មយិ អាគតេ នេវ អភិវាទេស្សតិ ន បច្ចុដ្ឋេស្សតីតិ ។
អថខោ ភគវា រាជានំ បសេនទិ កោសលំ អនត្តមនំ
វិទិត្វា រាជានំ បសេនទិ កោសលំ ឯតទវោច ឯសោ
ខោ មហារាជ ឧបាសកោ ពហុស្សុតោ អាគតាគមោ
កាមេសុ វីតរាគោតិ ។ អថខោ រញ្ញោ បសេនទិស្ស
កោសលស្ស ឯតទហោសិ ន ហាយំ ឧបាសកោ
ឱរកោ ហោតុ ភគវាបិ ឥមស្ស វណ្ណំ ភាសតីតិ ។



គាល់ជិតព្រះដ៏មានព្រះភាគ ។ ទើបព្រះបាទបសេនទិកោសលទ្រង់ទត
ឃើញ ។ ឧបាសកនោះគង់អង្គុយគាល់ជិតព្រះដ៏មានព្រះភាគ លុះទ្រង់ទតឃើញ
ហើយទ្រង់មានសេចក្តីគិតថា ហើយក៏ទ្រង់ប្រកាស (បុគ្គលឈរសេង) ។
លំដាប់នោះ ព្រះបាទបសេនទិកោសល ទ្រង់ត្រិះរិះយ៉ាងនេះថា បុរសនេះ
មិនមែនជាមនុស្សអាក្រក់ទេ បានជាអង្គុយគាល់ជិតព្រះដ៏មានព្រះភាគ ។
ឯព្រះបាទបសេនទិកោសលស្តេចក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគដែរ
លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់នៅក្នុងទី
ដ៏សមគួរ ។ ចំណែកឧបាសកនោះមិនបានថ្វាយបង្គំ មិនក្រោកទទួល
ព្រះបាទបសេនទិកោសលឡើយ ព្រោះគោរពដល់ព្រះដ៏មានព្រះភាគ ។
គ្រានោះ ព្រះបាទបសេនទិកោសលទ្រង់តូចព្រះទ័យថា បុរសនេះកាល
ឃើញអញមកហើយ មិនគួរនឹងមិនថ្វាយបង្គំ មិនក្រោកទទួល(អញ)សោះ ។
ខណៈនោះ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា ព្រះបាទបសេនទិកោសល
ស្តេចមានព្រះទ័យតាក់តែងហើយ ទើបទ្រង់ត្រាស់នឹងព្រះបាទបសេនទិ-
កោសលយ៉ាងនេះថា បពិត្រមហារាជ ឧបាសកនេះឯងជាពហុស្សូតជាអ្នក
ស្ទាត់ក្នុងបិដក មានចិត្តប្រាសចាកកាមទាំងឡាយទៅហើយ ។
ព្រះបាទបសេនទិកោសលទ្រង់ត្រិះរិះយ៉ាងនេះថា ឧបាសកនេះមិនមែន
ជាមនុស្ស[illegible] សូម្បីព្រះដ៏មានព្រះភាគក៏ទ្រង់សរសើរគេដែរ ។

តំ ឧបាសកំ ឯតទវោច កិលេយ្យាសិ ឧបាសក យេន អត្ថោតិ ។ សុដ្ឋុ ទេវាតិ ។ អថខោ ភគវា រាជានំ បសេនទិ កោសលំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា បសេនទិ កោសលោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

[៣៥០] តេន ខោ បន សមយេន រាជា បសេនទិ កោសលោ ឧបរិបាសាទវរគតោ ហោតិ ។ អទ្ទសា ខោ រាជា បសេនទិ កោសលោ តំ ឧបាសកំ រថិយាយ ឆត្តបាណឹ គច្ឆន្តំ ទិស្វាន បក្កោសាបេត្វា ឯតទវោច ត្វំ កិរ ឧបាសក ពហុស្សុតោ អាគតាគមោ សាធុ ឧបាសក អម្ហាកំ ឥត្ថាគារំ ធម្មំ វាចេហីតិ ។ យមហំ ទេវ ជានាមិ អយ្យានំ វាហសា អយ្យា ទេវស្ស ឥត្ថាគារំ ធម្មំ វាចេស្សន្តីតិ ។ អថខោ រាជា បសេនទិ កោសលោ



ព្រះបាទបសេនទិកោសល ទ្រង់មានព្រះបន្ទូលទៅនោះនឹងឧបាសកនោះ យ៉ាងនេះថា ម្នាលឧបាសក អ្នកត្រេកអរដោយហេតុណា ហើយក៏ប្រាថ្នាដល់យើងចុះ ។ ឧបាសកនោះទូលថា បពិត្រព្រះសម្មតិទេព ត្រូវហើយ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់ស្ដេចបសេនទិកោសល ឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថា ។ ព្រះបាទបសេន-ទិកោសល លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថាហើយ ស្ដេចក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយទ្រង់ធ្វើប្រទក្សិណចៀសចេញទៅ ។

[៣៥០] គ្រានោះឯង ព្រះបាទបសេនទិកោសលស្ដេចគង់ទីជាន់ខាងលើនៃប្រាសាទដ៏ប្រសើរ ។ ព្រះបាទបសេនទិកោសលបានទតឃើញឧបាសកនោះដើរកាន់ឆត្រទៅតាមផ្លូវ លុះទតហើយទ្រង់ឲ្យហៅមក ហើយមានព្រះបន្ទូលយ៉ាងនេះថា ម្នាលឧបាសក ឮថាអ្នកជាពហុ-ស្សូតស្ទាត់ក្នុងបិដក ម្នាលឧបាសក ល្អហើយ អ្នកចូរបង្ហាញធម៌ក្នុងផ្ទះវាំងពួកស្រីរបស់យើងផង ។ ឧបាសកនោះទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គដឹងធម៌ណា ព្រោះអាស្រ័យលោកម្ចាស់ទាំងឡាយ លោកម្ចាស់ទាំងឡាយនឹងសម្ដែងធម៌នោះក្នុងផ្ទះវាំងពួកស្រី (នឹងពួកព្រះស្នំ) របស់ព្រះអង្គបាន ។ លំដាប់នោះ ព្រះបាទបសេនទិកោសល

សន្តំ តេ ទុទាសកោ អាហរាតិ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា បសេនទិ កោសលោ ភគវន្តំ ឯតទវោច សាធុ ភន្តេ ភគវា ឯកំ ភិក្ខុំ អាណាបេតុ យោ អម្ហាកំ ឱរោធំ ធម្មំ វាចេស្សតីតិ ។ អថខោ ភគវា រាជានំ បសេនទិំ កោសលំ ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ រាជា បសេនទិ កោសលោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ តេនហានន្ទ រញ្ញោ ឱរោធំ ធម្មំ វាចេហីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា កាលេន កាលំ បវិសិត្វា រញ្ញោ ឱរោធំ ធម្មំ វាចេសិ ។ អថខោ អាយស្មា អានន្ទោ បុព្វណ្ហសមយំ



ទ្រង់ត្រាស់ថា ។ ម្ចាស់ករុណាពិតមែន ទើបទ្រង់ក៏ដំណើរទៅកាន់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ទ្រង់ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយគង់នៅក្នុងទីដ៏សមគួរ ។ ព្រះបាទបសេនទិកោសល លុះគង់ក្នុងទីដ៏សមគួរហើយក៏ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគទ្រង់ប្រើភិក្ខុមួយរូបដែលអាចនឹងបង្ហាញធម៌ ក្នុងផ្ទៃនៃពួកស្រីរបស់ខ្ញុំព្រះអង្គ ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ព្រះបាទបសេនទិកោសលឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថា ។ ព្រះបាទបសេនទិកោសល លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអង់អាច ឲ្យរីករាយដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគហើយធ្វើប្រទក្សិណចៀសចេញទៅ ។ គ្រានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ អ្នកចូរបង្ហាញធម៌ក្នុងផ្ទៃនៃពួកស្រីរបស់ស្ដេច ។ ព្រះអានន្ទដ៏មានអាយុបានទទួលព្រះតម្រាស់ព្រះដ៏មានព្រះភាគថា សូមទ្រង់មេត្តាប្រោស យ៉ាងហ្នឹងហើយ ។ ចូលទៅបង្ហាញធម៌ក្នុងផ្ទៃនៃពួកស្រីរបស់ស្ដេចរឿយៗ ។ វេលាតាមសមគួរ ។ វេលាព្រឹក ព្រះអានន្ទដ៏មានអាយុស្លៀកស្បង់ប្រដាប់ដោយបាត្រ

និវាសេត្វា បត្តចីវរមាទាយ យេន រញ្ញោ បសេនទិស្ស កោសលស្ស និវេសនំ តេនុបសង្កមិ ។ តេន ខោ បន សមយេន រាជា បសេនទិ កោសលោ មល្លិកាយ ទេវិយា សទ្ធឹ សយនគតោ ហោតិ ។ អទ្ទសា ខោ មល្លិកា ទេវី អាយស្មន្តំ អានន្ទំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន សហសា វុដ្ឋាសិ ។ បីតកមដ្ឋំ ទុស្សំ បភស្សិត្ថ ។ អថខោ អាយស្មា អានន្ទោ តតោ វ បដិនិវត្តិត្វា អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថញ្ហិ នាម អាយស្មា អានន្ទោ បុព្វេ អប្បដិសំវិទិតោ រញ្ញោ អន្តេបុរំ បវិសិស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ អានន្ទ បុព្វេ អប្បដិសំវិទិតោ រញ្ញោ អន្តេបុរំ បាវិសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម ត្វំ អានន្ទ បុព្វេ អប្បដិសំវិទិតោ រញ្ញោ អន្តេបុរំ



និងចីវរ ហើយចូលទៅកាន់និវេសន៍របស់ព្រះបាទបសេនទិកោសល ។ វេលានោះឯង ព្រះបាទបសេនទិកោសលស្តេចកំពុងផ្ទំជាមួយព្រះទេវីព្រះនាមមល្លិកា ។ នាងមល្លិកាទេវីបានឃើញព្រះអានន្ទដ៏មានអាយុមកអំពីចម្ងាយ លុះឃើញហើយក៏ក្រោកឡើងដោយប្រញាប់ ។ សំពត់មានពណ៌លឿងរលើងរលោងក៏របូតចុះ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុត្រឡប់ពីទីនោះមកកាន់អារាម ប្រាប់ដំណើរនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះអានន្ទដ៏មានអាយុ ស្តេចមិនទាន់ទ្រង់ជ្រាបជាមុន មិនគួរនឹងចូលទៅកាន់ក្នុងព្រះរាជវាំងរបស់ស្តេចសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលអានន្ទ ឮថាស្តេចមិនទាន់ជ្រាបជាមុន អ្នកឯងក៏ហ៊ានចូលទៅកាន់ក្នុងព្រះរាជវាំងរបស់ស្តេច ពិតមែនឬ ។ ព្រះអានន្ទទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលអានន្ទ ស្តេចមិនទាន់ជ្រាបជាមុន អ្នកឯងមិនគួរនឹងចូលទៅកាន់ក្នុងព្រះរាជវាំងរបស់ស្តេចទេ

បវិសិស្សសំ នេតំ អាវុសោ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ ។

[៣៥០] ទសយិមេ(១) ភិក្ខវេ អាទីនវា រាជន្តេបុរប្បវេសនេ ។ កតមេ ទស ។ ឥធ ភិក្ខវេ រាជា មហេសិយា សទ្ធឹ សយនគតោ(២) ហោតិ ។ តត្ថ ភិក្ខុ បវិសតិ ។ មហេសី វា ភិក្ខុំ ទិស្វា សិតំ បាតុករោតិ ភិក្ខុ វា មហេសឹ ទិស្វា សិតំ បាតុករោតិ ។ តត្ថ រញ្ញោ ឯវំ ហោតិ អទ្ធា ឥមេសំ កតំ វា ករិស្សន្តិ វាតិ ។ អយំ ភិក្ខវេ បឋមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រាជា ពហុកិច្ចោ ពហុករណីយោ អញ្ញតរំ ឥត្ថឹ គន្ត្វា ន សរតិ ។ សា តេន គព្ភំ គណ្ហាតិ(៣) ។ តត្ថ រញ្ញោ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។

១ ម. ទសិមេ ។ ២ ម. ឧ. និសិន្នោ ។ ៣ គណ្ហី ។



ម្នាលអាវុសោ អំពើនេះមិនមែននាំឲ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ទ្រង់បន្ទោសហើយទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមក ដោយព្រះពុទ្ធដីកាថា ។

[៣៥១] ម្នាលភិក្ខុទាំងឡាយ ទោសទាំង ១០ យ៉ាងនេះរមែងមាន ក្នុងកិរិយាចូលទៅកាន់ក្នុងបុរីរបស់ស្ដេច ។ ទោសទាំង ១០ យ៉ាងនោះ ដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ស្ដេចក្នុងលោកនេះ ទ្រង់ប្រថាប់លើគ្រែព្រះបន្ទំជាមួយមហេសី ។ ភិក្ខុចូលទៅក្នុងទីនោះ ។ មហេសីបានឃើញភិក្ខុ រមែងធ្វើកិរិយាញញឹមឲ្យប្រាកដខ្លះ ភិក្ខុឃើញមហេសី រមែងធ្វើកិរិយាញញឹមឲ្យប្រាកដខ្លះ ។ ស្ដេចរមែងរង្កៀសក្នុងរឿងនោះ យ៉ាងនេះថា ការមិនគួរអ្នកទាំងពីរនាក់នេះបានធ្វើហើយ ឬថាអ្នកទាំងពីរនេះនឹងធ្វើនូវការមិនគួរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសក្នុងកិរិយាចូលទៅកាន់ក្នុងបុរីនៃស្ដេចជាបឋម ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្ដេចជាបុគ្គលមានកិច្ចច្រើន មានការដែលគួរធ្វើច្រើន ទ្រង់យាងទៅរកស្រីដទៃហើយភ្លេច ។ ឯស្រីនោះក៏មានគភ៌ដោយស្ដេចនោះ ។ ស្ដេចរមែងរង្កៀសក្នុងរឿងនោះយ៉ាងនេះថា ជនដទៃមួយទៀតចូលទៅក្នុងទីនេះមិនមានទេ វៀរលែងតែបព្វជិត ចុះនេះជាកម្មរបស់បព្វជិតទេដឹង ។

អយំ ភិក្ខវេ ទុតិយោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រញ្ញោ អន្តេបុរេ អញ្ញតរំ រតនំ នស្សតិ ។ តត្ថ រញ្ញោ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ តតិយោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រញ្ញោ អន្តេបុរេ អព្ភន្តរា គុយ្ហមន្តា ពហិទ្ធា សម្ភេទំ គច្ឆន្តិ ។ តត្ថ រញ្ញោ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ ចតុត្ថោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រញ្ញោ អន្តេបុរេ បិតា វា បុត្តំ បត្ថេតិ បុត្តោ វា បិតរំ បត្ថេតិ ។ តេសំ ឯវំ ហោតិ ន ខោ ឥធ អញ្ញោ កោចិ បវិសតិ អញ្ញត្រ បព្វជិតេន សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ បញ្ចមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ



ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី២ ក្នុងកិរិយាចូលទៅកាន់ក្នុងបុរីនៃស្តេច ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃទៅមានតទៅទៀត គឺវត្ថុណាមួយក្នុងបុរីនៃស្តេចបាត់ទៅ ។ ស្តេចក៏មានត្រិះរិះក្នុងរឿងនោះយ៉ាងនេះថា ជនឯទៀតដទៃចូលទៅក្នុងទីនេះមិនមានទេ វៀរលែងតែបព្វជិត ទំនងជាកម្មរបស់បព្វជិតនេះហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី៣ ក្នុងកិរិយាចូលទៅកាន់ក្នុងបុរីនៃស្តេច ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃទៅមានតទៅទៀត មន្តទាំងឡាយ ដែលស្តេចត្រូវបំបាំងទុកក្នុង មាននៅកាន់ក្នុងបុរីនៃស្តេច ត្រូវបែកសាយទៅខាងក្រៅ ។ ស្តេចក៏មានត្រិះរិះក្នុងរឿងនោះយ៉ាងនេះថា ជនឯទៀតដទៃចូលមកក្នុងទីនេះមិនមានទេ វៀរលែងតែបព្វជិត ទំនងជាកម្មរបស់បព្វជិតនេះហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី៤ ក្នុងកិរិយាចូលទៅកាន់ក្នុងបុរីនៃស្តេច ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃទៅមានតទៅទៀត ព្រះរាជបុត្រប្រាថ្នានឹងបៀតបៀនចំពោះព្រះរាជបិតាក្នុងបុរីនៃស្តេចក្តី ព្រះរាជបិតាប្រាថ្នានឹងបៀតបៀនចំពោះព្រះរាជបុត្រក្តី ។ ព្រះរាជបុត្រ ព្រះរាជបិតានោះក៏មានត្រិះរិះក្នុងរឿងនោះយ៉ាងនេះថា ជនឯទៀតដទៃចូលមកក្នុងទីនេះមិនមានទេ វៀរលែងតែបព្វជិត ទំនងជាកម្មរបស់បព្វជិតនេះហើយ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី៥ ក្នុងកិរិយាចូលទៅកាន់ក្នុងបុរីនៃស្តេច ។ ម្នាលភិក្ខុ

រាជា នីចដ្ឋានិយំ ឧច្ចឋានេ[1] ឋបេតិ ។ យេសំ តំ
អមនាបំ តេសំ ឯវំ ហោតិ រាជា ខោ បព្វជិតេន
សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ
ភិក្ខវេ ឆដ្ឋោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន
ចបរំ ភិក្ខវេ រាជា ឧច្ចដ្ឋានិយំ នីចឋានេ[2] ឋបេតិ ។
យេសំ តំ អមនាបំ តេសំ ឯវំ ហោតិ រាជា ខោ បព្វជិ-
តេន សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។
អយំ ភិក្ខវេ សត្តមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។
បុន ចបរំ ភិក្ខវេ រាជា អកាលេ សេនំ ឧយ្យោជេតិ ។
យេសំ តំ អមនាបំ តេសំ ឯវំ ហោតិ រាជា ខោ
បព្វជិតេន សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស
កម្មន្តិ ។ អយំ ភិក្ខវេ អដ្ឋមោ អាទីនវោ រាជន្តេបុរប្ប-
វេសនេ ។ បុន ចបរំ ភិក្ខវេ រាជា កាលេ សេនំ

១ ម. ឧ. ឧច្ចដ្ឋានេ ។ ២ នីចដ្ឋានេ ។



ទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្ដេចទ្រង់តាំងមន្ត្រីដែលតាំង
នៅក្នុងទីទាបឲ្យឡើងតាំងទីខ្ពស់ ។ ការតាំងនោះមិនជាទីគាប់ចិត្តរបស់ជន
ទាំងឡាយណា ជនទាំងឡាយនោះរមែងរង្កៀសយ៉ាងនេះថា ស្ដេចតែង
ប្រឡូកប្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាល
ភិក្ខុទាំងឡាយ នេះជាទោសទីប្រាំមួយ ក្នុងកិរិយាចូលទៅកាន់ក្នុងវាំង
ស្ដេច ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្ដេចទ្រង់
បន្ថយមន្ត្រីដែលតាំងនៅក្នុងទីខ្ពស់ឲ្យតាំងនៅក្នុងទីទាប ។ ការតាំងនោះមិន
ជាទីគាប់ចិត្តរបស់ជនទាំងឡាយណា ជនទាំងឡាយនោះរមែងរង្កៀស
យ៉ាងនេះថា ស្ដេចតែងប្រឡូកប្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វ-
ជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទីប្រាំពីរ ក្នុងកិរិយាចូល
ទៅកាន់ក្នុងវាំងស្ដេច ។ ម្នាលភិក្ខុទាំងឡាយ ហេតុដទៃនៅមាន
តទៅទៀត ស្ដេចទ្រង់បញ្ជូនកងទ័ពទៅក្នុងកាលមិនសមគួរ ។
ការបញ្ជូនកងទ័ពនោះ មិនជាទីគាប់ចិត្តរបស់ជនទាំងឡាយណា
ជនទាំងឡាយនោះរមែងរង្កៀសយ៉ាងនេះថា ស្ដេចតែងប្រឡូកប្រឡំ
ដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតទេដឹង ។ ម្នាលភិក្ខុទាំងឡាយ
នេះជាទោសទីប្រាំបី ក្នុងកិរិយាចូលទៅកាន់ក្នុងវាំងស្ដេច ។ ម្នាលភិក្ខុ
ទាំងឡាយ ហេតុដទៃនៅមានតទៅទៀត ស្ដេចទ្រង់ឲ្យបញ្ជូនកងទ័ព

ឧយ្យោជេត្វា អន្តរាមគ្គតោ និវត្តាបេតិ ។ យេ តេសំ អមនាបា ហោន្តិ តេ ឯវមាហំសុ រាជា ខោ បព្វជិតេន សំសដ្ឋោ សិយា នុ ខោ បព្វជិតស្ស កម្មន្តិ ។ អយំ ភិក្ខវេ នវមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ បុន ចបរំ ភិក្ខវេ រាជន្តេបុរំ[១] ហត្ថិសម្មទ្ទំ អស្សសម្មទ្ទំ រថសម្មទ្ទំ រជនីយានិ រូបសទ្ទគន្ធរសផោដ្ឋព្វានិ យានិ ន បព្វជិតស្ស សារុប្បានិ ។ អយំ ខោ ភិក្ខវេ ទសមោ អាទីនវោ រាជន្តេបុរប្បវេសនេ ។ ឥមេ ខោ ភិក្ខវេ ទស អាទីនវា រាជន្តេបុរប្បវេសនេតិ ។

(៣៨៦) អថខោ ភគវា អាយស្មន្តំ អានន្ទំ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ទុប្បោសតាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ រញ្ញោ ខត្តិយស្ស មុទ្ធាភិសិត្តស្ស[២] អនិក្ខន្តរាជកេ អនិគ្គតរតនកេ[៣] បុព្វេ អប្បដិសំវិទិតោ ឥន្ទខីលំ អតិក្កាមេយ្យ បាចិត្តិយន្តិ ។

---

១ ឱ. ម. រញ្ញោ អន្តេបុរំ ។ ២ មុទ្ធាវសិត្តស្ស ។ សោ បន បទភាជនេ ៤ សទិសំ ។
៣ អនិក្ខន្តរាជកេតិ ចយ ។ សោ បន ៤ សទិសំ ។



ទៅក្នុងកាលដ៏សមគួរ ហើយទ្រង់ឲ្យត្រឡប់វិលវិញពាក់កណ្តាលផ្លូវ ។ ការត្រឡប់វិលវិញនោះ មិនជាទីគាប់ចិត្តរបស់ពួកជនទាំងឡាយណា ពួកជនទាំងឡាយនោះ រមែងនិយាយយ៉ាងនេះថា ស្តេចនៃយើងច្រឡូកច្រឡំដោយបព្វជិត ទំនងជាកម្មរបស់បព្វជិតនេះទេដឹង ។ ម្នាលភិក្ខុទាំងឡាយ នេះជាទោសទី៩ គួរកិរិយាចូលទៅកាន់ក្នុងបុរីនៃស្តេច ។ ម្នាលភិក្ខុទាំងឡាយ ហេតុមួយទៀតមានតទៅទៀត ការក្នុងបុរីតែងតែដែលដើរទៅដោយដំរី ដែលដើរទៅដោយសេះ ដែលដើរទៅដោយរថ មានរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ ជាទីតាំងនៃសេចក្តីត្រេកអរ ស្ទើតែជារបស់មិនសមគួរដល់បព្វជិត ។ ម្នាលភិក្ខុទាំងឡាយ នេះឯងជាទោសទី១០ គួរកិរិយាចូលទៅកាន់ក្នុងបុរីនៃស្តេច ។ ម្នាលភិក្ខុទាំងឡាយ ទោស១០យ៉ាងនេះឯង ជាទោសក្នុងកិរិយាចូលទៅកាន់ក្នុងបុរីនៃស្តេច ។

[៣៨៦] លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់បន្ទោសព្រះអានន្ទដ៏មានអាយុដោយបរិយាយជាច្រើន ។បេ។ ហើយទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយ (បើ) ស្តេចជាក្សត្រិយ៍បានមុទ្ធាភិសេកហើយ មិនទាន់ប្រាប់ជាមុន ឈានកន្លងធរណីចូលទៅក្នុងក្រឡាព្រះបន្ទំ ដែលស្តេចមិនទាន់យាងចេញ ស្រីកែវក៏មិនទាន់ចេញ ត្រូវអាបត្តិបាចិត្តិយ ។

### បាចិត្តិយកណ្ឌេ រតនវគ្គស្ស បឋមសិក្ខាបទស្ស សិក្ខាបទវិភង្គោ

(៣៩៣) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ ខត្តិយោ នាម ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ។ មុទ្ធាវសិត្តោ នាម ខត្តិយាភិសេកេន អភិសិត្តោ ហោតិ ។ អនិក្ខន្តរាជកេតិ រាជា សយនីឃរា អនិក្ខន្តោ ហោតិ ។ អនិគ្គតរតនកេតិ មហេសី សយនីឃរា អនិក្ខន្តា ហោតិ ឧភោ វា អនិក្ខន្តា ហោន្តិ ។ បុព្វេ អប្បដិសំវិទិតោតិ បុព្វេ អនាមន្តិតោ ។ ឥន្ទខីលោ នាម សយនីឃរស្ស ឧម្មារោ វុច្ចតិ ។ សយនីឃរំ នាម យត្ថ កត្ថចិ រញ្ញោ សយនំ បញ្ញត្តំ ហោតិ អន្តមសោ សាណិបាការបរិក្ខិត្តំបិ ។ ឥន្ទខីលំ អតិក្កាមេយ្យាតិ បឋមំ បាទំ ឧម្មារំ អតិក្កាមេតិ អាបត្តិ ទុក្កដស្ស ។ ទុតិយំ បាទំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។



### បាចិត្តិយកណ្ឌ រតនវគ្គ សិក្ខាបទទី ១ សិក្ខាបទវិភង្គ

(៣៩៣) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ក្សត្រិយ៍នោះ បានដល់ជនអ្នកមានជាតិល្អទាំងសងខាង គឺខាងមាតានិងខាងបិតា ជាអ្នកកាន់យកជាតិបរិសុទ្ធ ដរាបអំពីតួនដីដូនជីតាជាតំបូង ៧ គេមិនបានបោះបង់ចោល មិនបានតិះដៀលដោយជាតិ ។ ដែលហៅថា មុទ្ធាភិសេកហើយ គឺស្ដេចដែលគេបានអភិសេក ដោយអភិសេកឲ្យជាក្សត្រិយ៍ ។ ពាក្យថា ស្ដេចមិនទាន់យាងចេញ គឺស្ដេចមិនទាន់ចេញអំពីក្រឡាព្រះបន្ទំ ។ ពាក្យថា ស្រីកែវមិនទាន់ចេញ គឺមហេសី មិនទាន់ចេញអំពីក្រឡាព្រះបន្ទំ ឬមួយស្ដេចនឹងមហេសីទាំងពីរ មិនទាន់ចេញអំពីក្រឡាព្រះបន្ទំ ។ ពាក្យថា មិនទាន់ទូលប្រាប់ជាមុន គឺស្ដេចមិនទាន់និមន្តជាមុន ។ ដែលហៅថា ឥន្ទខីល គឺសំដៅយកធរណីនៃក្រឡាព្រះបន្ទំ (បានដល់ក្របទ្វារខាងក្រោម) ។ ចំណែកក្រឡាព្រះបន្ទំរបស់ស្ដេច ដែលគេតែងតាំងទុក ក្នុងទីណាមួយ ដោយហោចទៅសូម្បីតែទីដែលគេបាំងជុំវិញព័ទ្ធដោយរនាំង គឺហៅថាក្រឡាព្រះបន្ទំទាំងអស់ ។ ពាក្យថា ឈានកន្លងធរណីចូលទៅ សេចក្ដីថា ភិក្ខុឈានជើងបាទទី ១ ចូលទៅ ត្រូវអាបត្តិទុក្កដ ។ ឈានជើងបាទទី ២ ចូលទៅ ត្រូវអាបត្តិបាចិត្តិយ ។

(៣៩៦) អប្បដិសំវិទិតេ អប្បដិសំវិទិតសញ្ញី ឥន្ទខីលំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។ អប្បដិសំវិទិតេ វេមតិកោ ឥន្ទខីលំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។ អប្បដិសំវិទិតេ បដិសំវិទិតសញ្ញី ឥន្ទខីលំ អតិក្កាមេតិ អាបត្តិ បាចិត្តិយស្ស ។ បដិសំវិទិតេ អប្បដិសំវិទិតសញ្ញី អាបត្តិ ទុក្កដស្ស ។ បដិសំវិទិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បដិសំវិទិតេ បដិសំវិទិតសញ្ញី អនាបត្តិ ។

(៣៩៧) អនាបត្តិ បដិសំវិទិតេ ន ខត្តិយោ ហោតិ ន ខត្តិយាភិសេកេន អភិសិត្តោ ហោតិ រាជា សយនឃរា និក្ខន្តោ ហោតិ មហេសី សយនឃរា និក្ខន្តា ហោតិ ឧភោ វា សយនឃរា និក្ខន្តា ហោន្តិ ន សយនឃរេ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បឋមសិក្ខាបទំ និដ្ឋិតំ ។



(៣៩៦) ស្តេចមិនបានទទួល ភិក្ខុសំគាល់ថាស្តេចមិនបានទទួល ហើយដើរកន្លងធរណីចូលទៅ ត្រូវអាបត្តិបាចិត្តិយ ។ ស្តេចមិនបានទទួល ភិក្ខុមានសេចក្តីសង្ស័យ ហើយដើរកន្លងធរណីចូលទៅ ត្រូវអាបត្តិបាចិត្តិយ ។ ស្តេចមិនបានទទួល ភិក្ខុសំគាល់ថាស្តេចទទួល ហើយដើរកន្លងធរណីចូលទៅ ត្រូវអាបត្តិបាចិត្តិយ ។ ស្តេចទទួលហើយ ភិក្ខុសំគាល់ថាស្តេចមិនបានទទួល ត្រូវអាបត្តិទុក្កដ ។ ស្តេចទទួលហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ស្តេចទទួលហើយ ភិក្ខុសំគាល់ថាស្តេចទទួលហើយ មិនត្រូវអាបត្តិ ។

(៣៩៧) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺស្តេចបានទទួល ១ ជននោះមិនមែនជាក្សត្រិយ៍ ១ ជាស្តេចតែមិនបានទទួលអភិសេកដោយអភិសេកជាក្សត្រិយ៍ ១ ស្តេចយាងចេញពីក្រឡាព្រះបន្ទំ ១ មហេសីចេញពីក្រឡាព្រះបន្ទំ ១ ឬមួយស្តេចនឹងមហេសីទាំងពីរ ចេញពីក្រឡាព្រះបន្ទំ ១ ស្តេចនឹងមហេសីមិនបាននៅក្នុងក្រឡាព្រះបន្ទំ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១ ចប់ ។

## ទុតិយសិក្ខាបទំ

[៣៨៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អចិរវតិយា នទិយា ន្ហាយតិ ។ អញ្ញតរោបិ ព្រាហ្មណោ បញ្ចសតានំ ថវិកំ ថលេ និក្ខិបិត្វា អចិរវតិយា នទិយា ន្ហាយិត្វា(១) វិស្សរិត្វា អគមាសិ ។ អថខោ សោ ភិក្ខុ តស្សាយំ ព្រាហ្មណស្ស ថវិកា មា នស្សីតិ អគ្គហេសិ ។ អថខោ សោ ព្រាហ្មណោ សរិត្វា តុរិតោ អាធាវិត្វា តំ ភិក្ខុំ ឯតទវោច អបិ មេ ភោ ថវិកំ បស្សេយ្យាសីតិ ។ ហន្ទ ព្រាហ្មណាតិ អទាសិ ។ អថខោ តស្ស ព្រាហ្មណស្ស ឯតទហោសិ កេន នុ ខោ អហំ ឧបាយេន ឥមស្ស ភិក្ខុនោ បុណ្ណបត្តំ ន ទទេយ្យន្តិ ។ ន មេ ភោ បញ្ចសតានិ សហស្សំ មេតិ បលិពុទ្ធិត្វា មុញ្ចិ ។ អថខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ យេ តេ ភិក្ខូ អប្បិច្ឆា

១ ម. ម. ន្ហាយន្តោ ។

## សិក្ខាបទទី ២

[៣៨៦] សម័យនោះ ព្រះពុទ្ធមានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ភិក្ខុមួយរូបងូតទឹកក្នុងស្ទឹងអចិរវតី ។ មានព្រាហ្មណ៍ម្នាក់ទៀតបានទុកថង់ប្រាក់ចំនួន ៥០០ កហាបណៈលើគោក ហើយចុះងូតទឹកក្នុងស្ទឹងអចិរវតី (ឡើងមកហើយ) ក៏ភ្លេចថង់ប្រាក់ ដើរចៀសចេញទៅ ។ លំដាប់នោះ ភិក្ខុនោះក៏រើសយកដោយគិតថា ថង់នេះប្រាកដជាថង់ប្រាក់របស់ព្រាហ្មណ៍នោះ កុំបីវិនាសបាត់ឡើយ ។ ឯព្រាហ្មណ៍នោះនឹកឃើញក៏ត្រឡប់វិលមកវិញដោយប្រញាប់ ហើយបានសួរភិក្ខុនោះយ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់បានឃើញថង់ប្រាក់របស់ខ្ញុំដែរឬ ។ ភិក្ខុនោះបានឲ្យថង់ប្រាក់នោះទៅដោយពាក្យថា យកចុះព្រាហ្មណ៍ ។ ទើបព្រាហ្មណ៍នោះបានគិតយ៉ាងនេះថា អញមិនគប្បីឲ្យរង្វាន់ដល់ភិក្ខុនេះ ដោយឧបាយដូចម្តេចហ្ន៎ ។ ព្រាហ្មណ៍នោះតវ៉ាប្រកាន់ថា បពិត្រលោកម្ចាស់ កហាបណៈរបស់ខ្ញុំមិនមែន ៥០០ ទេ របស់ខ្ញុំប្រាកដជា ១០០០ រួចបានចាប់ភិក្ខុនោះហើយក៏លែងទៅ ។ ចំណែកភិក្ខុនោះទៅកាន់អារាមហើយប្រាប់សេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច

។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ រតនំ ឧគ្គហេស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ រតនំ ឧគ្គហេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស រតនំ ឧគ្គហេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ រតនំ វា រតនសម្មតំ វា ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣៥៧] តេន ខោ បន សមយេន សាវត្ថិយា ឧស្សវោ ហោតិ ។ មនុស្សា អលង្កតប្បដិយត្តា ឧយ្យានំ គច្ឆន្តិ ។ វិសាខាបិ មិគារមាតា អលង្កតប្បដិយត្តា ឧយ្យានំ គមិស្សាមីតិ គាមតោ និក្ខមិត្វា ក្យាហំ ករិស្សាមិ ឧយ្យានំ គន្ត្វា យន្នូនាហំ ភគវន្តំ បយិរុបា-



។ បេ ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងរើសយករតនៈមានមាសប្រាក់ជាដើមសោះ ។ បេ ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងរើសយករតនៈ ពិតមែនឬ ។ ភិក្ខុនោះទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធម្ចាស់ដ៏មានព្រះភាគទ្រង់តិះដៀលថា ម្នាលមោឃបុរស អ្នកឯងមិនគួរនឹងរើសយករតនៈទេ ម្នាលមោឃបុរស អំពើនេះមិនមែននាំឱ្យជ្រះថ្លាដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយឱ្យរឹតតែជ្រះថ្លាទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយរើសយកឯងក្តី ឱ្យគេរើសយកក្តី នូវរតនៈក្តី នូវវត្ថុដែលគេសន្មតថារតនៈក្តី ត្រូវអាបត្តិបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៣៥៧] សម័យនោះឯង មានមហោស្រពក្នុងក្រុងសាវត្ថី ។ មនុស្សទាំងឡាយប្រដាប់តាក់តែងខ្លួនទៅកាន់ឧទ្យាន ។ សូម្បីនាងវិសាខាមិគារមាតា ក៏បានប្រដាប់តាក់តែងកាយ ហើយក៏ចេញចាកស្រុកទៅដោយគិតថា អាត្មាអញនឹងទៅកាន់ឧទ្យានដែរ ហើយគិតទៀតថា ចុះអាត្មាអញនឹងទៅកាន់ឧទ្យានធ្វើអ្វី បើដូច្នោះគួរតែអញចូលគាល់ព្រះដ៏មាន

ះសេយ្យន្តិ អាភរណំ ឱមុញ្ចិត្វា ឧត្តរាសង្គេន ភណ្ឌិកំ កត្វា ទាសិយា អទាសិ ហន្ទ ជេ ឥមំ ភណ្ឌិកំ គណ្ហាហីតិ ។ អថខោ វិសាខា មិគារមាតា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ធម្មិយា កថាយ សន្ទស្សេសិ សមាទបេសិ សមុត្តេជេសិ សម្បហំសេសិ ។ អថខោ វិសាខា មិគារមាតា ភគវតា ធម្មិយា កថាយ សន្ទស្សិតា សមាទបិតា សមុត្តេជិតា សម្បហំសិតា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សា ទាសី តំ ភណ្ឌិកំ វិស្សរិត្វា អគមាសិ ។ ភិក្ខូ បស្សិត្វា ភគវតោ អារោចេសុំ ។ តេនហិ ភិក្ខវេ ឧគ្គហេត្វា និក្ខិបថាតិ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ រតនំ វា រតនសម្មតំ វា អជ្ឈារាមេ ឧគ្គហេត្វា វា



ព្រះភាគវិញ ហើយក៏ដោះនូវគ្រឿងអាភរណៈចេញចាប់បង្វិចដោយសំពត់ឧត្តរ ហើយបានប្រគល់ឲ្យទៅទាសីថា ហៃនាង ឯងចូរយកបង្វិចនេះទៅ ។ លំដាប់នោះ នាងវិសាខាមិគារមាតា បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះដ៏មានព្រះភាគទ្រង់ពន្យល់នាងវិសាខាមិគារមាតា ដែលអង្គុយនៅក្នុងទីដ៏សមគួរហើយ ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ។ ឯនាងវិសាខាមិគារមាតា លុះព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឲ្យឃើញ ឲ្យកាន់យក ឲ្យអាចហាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណហើយចៀសចេញទៅ ។ ឯទាសីនោះក៏ភ្លេចបង្វិចនោះ ហើយដើរចេញទៅ ។ ភិក្ខុទាំងឡាយឃើញហើយ បានក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូររើសយកទុក ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយ ដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរើសឯង ឬប្រើគេឲ្យរើស នូវរតនៈក្តី នូវវត្ថុដែលគេសន្មតថារតនៈក្តី

ឧគ្គហាបេត្វា វា និក្ខិបិតព្វំ យស្ស ភវិស្សតិ សោ ហរិស្សតីតិ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ រតនំ វា រតនសម្មតំ វា អញ្ញត្រ អជ្ឈារាមា ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៣៨៨) តេន ខោ បន សមយេន កាសីសុ ជនបទេសុ អនាថបិណ្ឌិកស្ស គហបតិស្ស កម្មន្តគាមោ ហោតិ ។ តេន ច គហបតិនា អន្តេវាសី អាណត្តោ ហោតិ សចេ អយ្យា អាគច្ឆន្តិ ភត្តំ ករេយ្យាសីតិ ។ តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កាសីសុ ជនបទេសុ ចារិកំ ចរមានា យេន អនាថបិណ្ឌិកស្ស គហបតិស្ស កម្មន្តគាមោ តេនុបសង្កមឹសុ ។ អទ្ទសា ខោ សោ បុរិសោ តេ ភិក្ខូ ទូរតោវ អាគច្ឆន្តេ ទិស្វាន យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ អភិវាទេត្វា ឯតទវោច អធិវាសេន្តុ ភន្តេ អយ្យា ស្វាតនាយ គហបតិនោ ភត្តន្តិ ។



ភិក្ខុកាន់យកហើយទុកដោយគិតថា រតនៈរបស់អ្នកណា អ្នកនោះនឹងយកទៅ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយរើសឯងក្តី ឲ្យគេរើសក្តី នូវរតនៈក្តី នូវវត្ថុដែលគេសន្មតថារតនៈក្តី ក្រៅតែក្នុងវត្តចេញ ទៀតពីនេះ (រើសយកនូវរតនៈដែលគេភ្លេច) ជាបាចិត្តិយ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(៣៨៨) ក្រោយពីនោះ ក្នុងកាសីជនបទ មានស្រុក ១ ជាទីធ្វើការងាររបស់អនាថបិណ្ឌិកគហបតី ។ គហបតីនោះបានបង្គាប់អន្តេវាសី (ក្មួយ) ថា បើលោកម្ចាស់ទាំងឡាយនិមន្តមក អ្នកឯងគប្បីធ្វើភត្តប្រគេនចុះ ។ ក្រោយនោះឯង ភិក្ខុទាំងឡាយច្រើនរូប ត្រាច់ទៅកាន់ចារិកក្នុងកាសីជនបទ ហើយចូលទៅកាន់ស្រុកជាទីធ្វើការងាររបស់អនាថបិណ្ឌិកគហបតី ។ បុរសនោះបានឃើញភិក្ខុទាំងនោះមកអំពីចម្ងាយ លុះបានឃើញច្បាស់ហើយ ក៏ចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ បានថ្វាយបង្គំភិក្ខុទាំងនោះហើយពោលនូវពាក្យនេះថា បពិត្រព្រះករុណា សូមលោកម្ចាស់ទាំងឡាយទទួលចង្ហាន់របស់គហបតី ក្នុងថ្ងៃស្អែក ។

អធិវាសេសុំ ខោ តេ ភិក្ខូ តុណ្ហីភាវេន ។ អថខោ សោ បុរិសោ តស្សា រត្តិយា អច្ចយេន បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា កាលំ អារោចាបេត្វា អង្គុលិមុទ្ទិកំ ឱមុញ្ចិត្វា តេ ភិក្ខូ ភត្តេន បរិវិសិត្វា អយ្យា ភុញ្ជិត្វា គច្ឆន្តុ អហម្បិ កម្មន្តំ គមិស្សាមីតិ អង្គុលិមុទ្ទិកំ វិស្សរិត្វា អគមាសិ ។ ភិក្ខូ បស្សិត្វា សចេ មយំ គមិស្សាម នស្សិស្សតាយំ អង្គុលិមុទ្ទិកាតិ តត្ថេវ អច្ឆិំសុ ។ អថខោ សោ បុរិសោ កម្មន្តា អាគច្ឆន្តោ តេ ភិក្ខូ បស្សិត្វា ឯតទវោច កិស្ស ភន្តេ អយ្យា ន គច្ឆន្តីតិ ។ អថខោ តេ ភិក្ខូ តស្ស បុរិសស្ស ឯតមត្ថំ អារោចេត្វា សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ រតនំ វា រតនសម្មតំ វា អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហេត្វា វា ឧគ្គហាបេត្វា វា និក្ខិបិតុំ យស្ស ភវិស្សតិ សោ ហរិស្សតីតិ ។ ឯវញ្ច



ភិក្ខុទាំងនោះបានទទួលដោយការស្ងៀមនៅ ។ លុះកន្លងរាត្រីនោះទៅ បុរសនោះបានឲ្យគេតាក់តែងខាទនីយភោជនីយាហារដ៏ថ្លៃថ្លា ហើយបានឲ្យគេក្រាបទូលកាល(វេលាបាយ) រួចហើយដោះចិញ្ចៀនចេញ ហើយអង្គាសភិក្ខុទាំងនោះដោយភត្តស្រេចហើយពោលថា លោកម្ចាស់ទាំងឡាយឆាន់ហើយ សូមនិមន្តទៅចុះ ចំណែកខ្ញុំនឹងទៅធ្វើការងារដែរ (និយាយដូច្នេះហើយ) ក៏ភ្លេចចិញ្ចៀន(នោះ)ហើយទៅ ។ ភិក្ខុទាំងឡាយបានឃើញហើយ ក៏ឈប់នៅក្នុងទីនោះដោយគិតថា បើយើងទាំងឡាយនឹងដើរចេញទៅ ចិញ្ចៀននេះនឹងបាត់បង់ទៅក្ដី ។ ឯបុរសនោះកាលមកអំពីធ្វើការងារបានឃើញភិក្ខុទាំងនោះហើយសួរយ៉ាងនេះថា បពិត្រព្រះករុណា ពួកលោកម្ចាស់ឈប់នៅក្នុងទីនេះធ្វើអ្វី ។ ទើបភិក្ខុទាំងនោះប្រាប់សេចក្ដីនុ៎ះដល់បុរសនោះ ហើយទៅកាន់ក្រុងសាវត្ថី បានប្រាប់សេចក្ដីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ទើបព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុរើសឯង ឬឲ្យគេរើស នូវរតនៈក្ដី នូវវត្ថុដែលគេសន្មតថារតនៈក្ដី ក្នុងអារាមក្ដី ក្នុងទីសំណាក់ក្ដី ហើយទុកដាក់ដោយគិតថា វត្ថុនេះរបស់អ្នកណា អ្នកនោះនឹងនាំយកទៅ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើង

បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ រតនំ វា រតនសម្មតំ វា អញ្ញត្រ អជ្ឈារាមា វា អជ្ឈាវសថា វា ឧគ្គណ្ហេយ្យ វា ឧគ្គណ្ហាបេយ្យ វា បាចិត្តិយំ ។ រតនំ វា បន ភិក្ខុនា រតនសម្មតំ វា អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហេត្វា វា ឧគ្គហាបេត្វា វា និក្ខិបិតព្វំ យស្ស ភវិស្សតិ សោ ហរិស្សតីតិ ។ អយំ តត្ថ សាមីចីតិ ។

(៣៨៨) យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ រតនំ នាម មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្កោ មសារគល្លំ ឯតំ រតនំ នាម ។ រតនសម្មតំ នាម យំ មនុស្សានំ ឧបភោគបរិភោគំ ឯតំ រតនសម្មតំ នាម ។ អញ្ញត្រ អជ្ឈារាមា វា អជ្ឈាវសថា វាតិ ឋបេត្វា អជ្ឈារាមំ អជ្ឈាវសថំ ។ អជ្ឈារាមោ នាម បរិក្ខិត្តស្ស អារាមស្ស អន្តោអារាមោ អបរិក្ខិត្តស្ស ឧបចារោ ។ អជ្ឈាវសថោ នាម បរិក្ខិត្តស្ស



នូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយរើសឯងក្តី ឲ្យគេរើសក្តី នូវរតនៈក្តី នូវវត្ថុដែលគេសន្មតថារតនៈក្តី ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែក្នុងវត្តក្តី ក្នុងទីសំណាក់ក្តី ។ ម្យ៉ាងទៀត ភិក្ខុគប្បីរើសឯង ឬឲ្យគេរើស នូវរតនៈក្តី នូវវត្ថុដែលគេសន្មតថារតនៈក្តី ក្នុងវត្តក្តី ក្នុងទីសំណាក់ក្តី ហើយទុកដាក់ដោយគិតថា រតនៈរបស់អ្នកណា អ្នកនោះនឹងនាំយកទៅ ។ នេះជាសាមីចិកម្ម ក្នុងសិក្ខាបទនោះ ។

(៣៨៨) ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា រតនៈនោះ បានដល់កែវមុក្តា កែវមណី កែវពិទូរ្យ សង្ខ កែវសិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (កែវទទឹម) កែវមរកត (កែវក្រួស) នេះឈ្មោះថារតនៈ ។ ដែលហៅថា វត្ថុដែលគេសន្មតថារតនៈនោះ បានដល់វត្ថុឯណាមួយជាគ្រឿងឧបភោគបរិភោគរបស់មនុស្សទាំងឡាយ វត្ថុនេះឈ្មោះថា គេសន្មតថារតនៈ ។ ពាក្យថា វៀរលែងតែក្នុងវត្តក្តី ក្នុងទីសំណាក់ក្តី គឺវៀរលែងតែក្នុងវត្ត នឹងក្នុងទីសំណាក់ ។ ដែលហៅថា ក្នុងវត្តនោះ គឺវត្តដែលមានរបង សំដៅយកទីក្នុងនៃវត្ត (បើ) វត្តដែលមិនមានរបង សំដៅយកត្រឹមទីឧបចារនៃវត្ត ។ ដែលហៅថា ក្នុងទីសំណាក់នោះ គឺទីសំណាក់ដែលមានរបង សំដៅយកទីក្នុង

អាវសថស្ស អន្តោអាវសថោ អបរិក្ខិត្តស្ស ឧបចា-
រោ ។ ឧគ្គណ្ហេយ្យាតិ សយំ គណ្ហាតិ អាបត្តិ បាចិត្តិ-
យស្ស ។ ឧគ្គណ្ហាបេយ្យាតិ អញ្ញំ គណ្ហាបេតិ អាបត្តិ
បាចិត្តិយស្ស ។

[៣៦០] រតនំ វា បន ភិក្ខុនា រតនសម្មតំ វា
អជ្ឈារាមេ វា អជ្ឈាវសថេ វា ឧគ្គហេត្វា វា ឧគ្គហា-
បេត្វា វា និក្ខិបិតព្ពំ រូបេន វា និមិត្តេន វា សញ្ញាណំ
កត្វា និក្ខិបិត្វា អាចិក្ខិតព្ពំ យស្ស ភណ្ឌំ នដ្ឋំ សោ
អាគច្ឆតូតិ ។ សចេ តត្ថ អាគច្ឆតិ សោ វត្តព្វោ អាវុសោ
កឹ តេ ភណ្ឌកន្តិ ។ សចេ រូបេន វា និមិត្តេន វា
សម្បាទេតិ ទាតព្វំ ។ នោ ចេ សម្បាទេតិ វិចិនាហិ
អាវុសោតិ វត្តព្វោ ។ តម្ហា អាវាសា បក្កមន្តេន យេ
តត្ថ ហោន្តិ ភិក្ខូ បតិរូបា តេសំ ហត្ថេ និក្ខិបិត្វា



នៃទីស្នាក់ (របង) ទីស្នាក់ដែលឥតរបង សំដៅយកត្រឹមទីឧបចារ
នៃទីស្នាក់ ។ ពាក្យថា រើសឯង សេចក្តីថា ភិក្ខុកាន់យកដោយខ្លួនឯង
ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា ឲ្យគេរើស សេចក្តីថា ភិក្ខុឲ្យអ្នកដទៃ
កាន់យក ត្រូវអាបត្តិបាចិត្តិយ ។

[៣៦០] ពាក្យថា មួយទៀត ភិក្ខុគប្បីរើសឯង ឬឲ្យគេរើស
នូវរតនៈក្តី នូវវត្ថុដែលគេសន្មតថារតនៈក្តី ខាងក្នុងវត្តក្តី ខាងក្នុងទីស្នាក់ក្តី
ហើយទុកដាក់ សេចក្តីថា ភិក្ខុធ្វើសញ្ញា[១] (គ្រឿងកំណត់ចាំ) ដោយ
រូបក្តី ដោយនិមិត្ត(គ្រឿងសំគាល់)ក្តី គប្បីទុកដាក់ហើយប្រាប់ថា ជន
ណាបាត់ភណ្ឌ ជននោះចូរមកយកចុះ ។ បើម្ចាស់របស់នោះមកក្នុងទី
នោះភិក្ខុគប្បីសួរគេថា អាវុសោ ភណ្ឌរបស់អ្នកដូចម្តេច ។ បើគេ
ប្រាប់ត្រូវតាមរូបក្តី តាមនិមិត្ត(គ្រឿងសំគាល់)ក្តី ភិក្ខុគប្បីឲ្យចុះ ។ បើគេ
ប្រាប់មិនត្រូវ ភិក្ខុគប្បីពោលថា អាវុសោ អ្នកចូររកខ្លួនឯងចុះ ។
កាលភិក្ខុនោះនឹងចៀសចេញចាកទីស្នាក់នោះទៅ ភិក្ខុទាំងឡាយ
ណាដែលសមគួរមាននៅក្នុងទីនោះ គប្បីផ្ញើទុកក្នុងដៃភិក្ខុទាំងឡាយនោះ

---

១ ពាក្យដែលបានរើសយក ៣ ប្រការ មានមាសប្រាក់ជាដើម ដែលគេធ្លោយទុកក្នុងវត្តក្តី ក្នុង
ទីលំនៅរបស់ភិក្ខុក្តី ត្រូវធ្វើសញ្ញាយកទៅទុកនៅទីណាមួយ ទីទុកនេះ ឲ្យដឹងកន្លែងដែល
ទុកនោះ ឯសេចក្តីក្នុងសិក្ខាបទនេះ ចង់ប្រាប់ថា អ្នកណាបាត់របស់អ្វី អ្នកនោះចូលមកទទួលយក ។

បញ្ញាបេតព្វំ ។ យោ ចេ ហោន្តិ ភិក្ខូ បជ្ជិតា យេ តត្ថ ហោន្តិ គហបតិកា បជ្ជិតា តេសំ ហត្ថេ ចិត្តុំ បិត្វា បញ្ញាបិតព្វំ ។ អយំ តត្ថ សាមីចិ អយំ តត្ថ អនុធម្មតា ។

(៣៦១) អនាបត្តិ គេជំ វា គេលសម្មតំ វា អញ្ញាភរេ វា អញ្ញាតសេដេ វា ឧទ្ទិសោហត្តា វា ឧទ្ទិយាបេត្វា វា ចិត្តឹបតិ យស្ស ករិស្សតិ សោ ហរិស្សតីតិ គេលសម្មតិ[១] វិសព្វស់ គណ្ហាតិ តាវកាលិកំ គណ្ហាតិ ឧម្មត្តិកាស្ស អាទិកម្មិកាស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

១ ឧតិ ក ភេលសម្មតំ ភតិ គត្ថិ ហោន្តិ ទិស្សតិ ។



ហើយទៀសចេញទៅ ។ បើមិនមានភិក្ខុដឹងសម្មតទេ ភិក្ខុនោះត្រូវតើទុកនៅដៃរបស់ពួកគហបតីដឹងសម្មត ដែលមាននៅក្នុងទីនោះ ហើយគប្បីទៀសចេញទៅ ។ ពាក្យថា នេះជាសាមីចិកម្មក្នុងសិក្ខាបទនោះ គឺនេះជាអនុធម្មតាក្នុងរឿងនោះ ។

(៣៦១) ក-ដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) ភិក្ខុកើតសង្ស័យ មុខ្សគេកើស ខ្លួនគេនះក្តី ខ្លួនដែលគេសន្មតជាគេនះក្តី នាងកន្លែងក្តី នាងកន្លងឹស្មាក់ក្តី ហើយក្នុងជាក់ដោយគិតថា គេនះរបស់អ្នកណា អ្នកនោះនឹងនាំយកទៅ ១ ភិក្ខុកាន់យកនូវដែលគេសន្មតជាគេនះដោយសំគាល់ ១ ភិក្ខុកាន់យកជារបស់ខ្លី ១ ភិក្ខុសំគាល់ថាជារបស់ឬស្រួល ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

## តតិយសិក្ខាបទំ

[៣៦២] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ វិកាលេ គាមំ បវិសិត្វា សភាយំ និសីទិត្វា អនេកវិហិតំ តិរច្ឆានកថំ កថេន្តិ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ សូរកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ

## សិក្ខាបទទី ៣

(៣៦៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងជេតវន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុចូលទៅកាន់ស្រុកក្នុងវេលាវិកាល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗ ជាច្រើន ក្នុងរោងជាទីប្រជុំនិយាយ តិរច្ឆានកថានោះដូចម្តេចខ្លះ តិរច្ឆានកថានោះ គឺពោលអំពីរឿងស្តេច ពោលអំពីចោរ ពោលអំពីមហាមាត្យ ពោលអំពីសេនាពលហាន ពោលអំពីភ័យ (ទីសត្វសាហាវជាដើម) ពោលអំពីចម្បាំង ពោលអំពីបាយ ពោលអំពីទឹក ពោលអំពីសំពត់ ពោលអំពីទីដេក ពោលអំពីផ្កាកម្រង ពោលអំពីគ្រឿងក្រអូប ពោលអំពីញាតិ ពោលអំពីយាន ពោលអំពីស្រុក ពោលអំពីនិគម ពោលអំពីក្រុង ពោលអំពីជនបទ ពោលអំពីស្រី ពោលអំពីសុរា ពោលអំពីច្រក ពោលអំពីទីដងកល់ខ្ទម គឺកំពង់ទឹក ពោលអំពីញាតិដែលស្លាប់ទៅកាន់បរលោក ពោលអំពីរឿងផ្សេង ១ ដែលឥតប្រយោជន៍ ពោលអំពីលោក (លទ្ធិក្នុងការកកើតលោក) ពោលអំពីសមុទ្រ ពោលអំពីភវៈ[១] និងអភវៈ[២] ដែលជាហេតុ

---

១ ភវៈ គឺសស្សតទិដ្ឋិ ។ ២ អភវៈ គឺឧច្ឆេទទិដ្ឋិ ម្យ៉ាងទៀត ភវៈ គឺសេចក្តីចំរើន អភវៈ គឺសេចក្តីសាបសូន្យ ឬភវៈ គឺសេចក្តីសុខក្នុងកាម អភវៈ គឺសេចក្តីលំបាកដោយធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍ ។

ឥតិ វា ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា វិកាលេ គាមំ បវិសិត្វា សភាយំ និសីទិត្វា អនេកវិហិតំ តិរច្ឆានកថំ កថេស្សន្តិ សេយ្យថីទំ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ សុរាកថំ វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិភវាភវកថំ ឥតិ វា សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ វិកាលេ គាមំ បវិសិត្វា





ឥតប្រយោជន៍ ដូច្នេះខ្លះ ដូច្នោះខ្លះ ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណសក្យបុត្រ មិនគួរនឹងមកចូលស្រុក ក្នុងវេលាវិកាលហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗជាច្រើន ក្នុងរោង ជាទីប្រជុំនិយាយ ដូចពួកគ្រហស្ថអ្នកបរិភោគនូវកាមរសៈ តិរច្ឆានកថា នោះដូចម្តេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្តេច ពោលអំពីចោរ ពោលអំពីមហាមាត្យ ពោលអំពីសេនាពាហន ពោលអំពីភ័យ (គឺទីសត្វ សាហាវជាដើម) ពោលអំពីចម្បាំង ពោលអំពីបាយ ពោលអំពីទឹក ពោលអំពីសំពត់ ពោលអំពីទីដេក ពោលអំពីកម្រងផ្កា ពោលអំពីគ្រឿងក្រអូប ពោលអំពីញាតិ ពោលអំពីយាន ពោលអំពីស្រុក ពោលអំពីនិគម ពោលអំពីនគរ ពោលអំពីជនបទ ពោលអំពីស្រី ពោលអំពីសុរា ពោលអំពីច្រក ពោលអំពីទីដក់ទឹកក្នុងក្អម គឺកំពង់ទឹក ពោលអំពីញាតិ ដែលស្លាប់ទៅកាន់បរលោក ពោលអំពីរឿងផ្សេងៗ ពោលអំពីលោក (លទ្ធិក្នុងភាគនឹងលោក) ពោលអំពីសមុទ្រ ពោលអំពីភវៈនិងអភវៈដែលជា ហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ ។ ភិក្ខុទាំងឡាយបានឮមនុស្ស ទាំងនោះពោលទោសតិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុ មិនគួរនឹងមកចូលស្រុកក្នុងវេលាវិកាល

សភាយំ និសីទិត្វា អនេកវិហិតំ តិរច្ឆានកថំ កថេន្តិ សេយ្យថីទំ រាជកថំ ។បេ។ ឥតិភវាភវកថំ ឥតិ វា ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ វិកាលេ គាមំ បវិសិត្វា សភាយំ និសីទិត្វា អនេកវិហិតំ តិរច្ឆានកថំ កថេថ សេយ្យថីទំ រាជកថំ ។បេ។ ឥតិភវាភវកថំ ឥតិ វា ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា វិកាលេ គាមំ បវិសិត្វា សភាយំ និសីទិត្វា អនេកវិហិតំ តិរច្ឆានកថំ កថេស្សថ សេយ្យថីទំ រាជកថំ ។បេ។ ឥតិភវាភវកថំ ឥតិ វា នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ



ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗ ជាច្រើន ក្នុងរោងជាទីប្រជុំពលករោះ តិរច្ឆានកថាតើដូចម្ដេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្ដេច ។បេ។ ពោលអំពីភពនិងអភព ដែលជាហេតុឥតប្រយោជន៍ ដូច្នេះខ្លះ ដូច្នោះខ្លះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថា ពួកអ្នកឯងចូលស្រុកក្នុងវេលាវិកាល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗ ជាច្រើន តិរច្ឆានកថាតើដូចម្ដេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្ដេច ។បេ។ ពោលអំពីភពនិងអភព ដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ ពួកអ្នកឯងមិនគួរនឹងចូលស្រុក ក្នុងវេលាវិកាល ហើយអង្គុយនិយាយតិរច្ឆានកថាផ្សេងៗ ជាច្រើនឡើយ តិរច្ឆានកថាតើដូចម្ដេចខ្លះ តិរច្ឆានកថានោះគឺ ពោលអំពីរឿងស្ដេច ។បេ។ ពោលអំពីភពនិងអភព ដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំឲ្យជ្រះថ្លា ដល់ពួកជនដែលមិនទាន់ជ្រះថ្លា ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះ

យោ បន ភិក្ខុ វិកាលេ គាមំ បវិសេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៣៦៣) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ កោសលេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តា សាយំ អញ្ញតរំ គាមំ ឧបគច្ឆឹសុ ។ មនុស្សា តេ ភិក្ខូ បស្សិត្វា ឯតទវោចុំ បវិសថ ភន្តេតិ ។ អថខោ តេ ភិក្ខូ ភគវតា បដិក្ខិត្តំ វិកាលេ គាមំ បវិសិតុន្តិ កុក្កុច្ចាយន្តា[១] ន បវិសឹសុ ។ ចោរា តេ ភិក្ខូ អច្ឆិន្ទឹសុ ។ អថខោ តេ ភិក្ខូ សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសុំ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ អាបុច្ឆា វិកាលេ គាមំ បវិសិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អនាបុច្ឆា វិកាលេ គាមំ បវិសេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

១ កុក្កុច្ចាយន្តា ឥតិ ក្វចិ បោត្ថកេ ទិស្សតិ ។



យ៉ាងនេះថា ភិក្ខុណាមួយចូលស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយ យ៉ាងនេះ ។

(៣៦៣) សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូបទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទ ក៏បានចូលទៅកាន់ស្រុកមួយ ក្នុងវេលាល្ងាច ។ មនុស្សទាំងឡាយឃើញភិក្ខុទាំងនោះហើយ ក៏បាននិយាយពាក្យនេះថា សូមលោកម្ចាស់ទាំងឡាយនិមន្តចូលមក ។ ចំណែកភិក្ខុទាំងនោះសង្ស័យថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមនូវការចូលស្រុកក្នុងវេលាវិកាលហើយ បានជាមិនហ៊ានចូលទៅ ។ ពួកចោរបានប្លន់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះទៅក្រុងសាវត្ថីហើយ ក្រាបទូលសេចក្តីនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលបានលាភិក្ខុផងគ្នាហើយចូលស្រុកក្នុងវេលាវិកាលបាន ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនបានលាហើយចូលទៅកាន់ស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

[៣៦៦] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ កោសលេសុ ជនបទេសុ សាវត្ថឹ គច្ឆន្តោ សាយំ អញ្ញតរំ គាមំ ឧបគច្ឆិ ។ មនុស្សា តំ ភិក្ខុំ បស្សិត្វា ឯតទវោចុំ បវិសថ ភន្តេតិ ។ អថខោ សោ ភិក្ខុ ភគវតា បដិក្ខិត្តំ អនាបុច្ឆា វិកាលេ គាមំ បវិសិតុន្តិ កុក្កុច្ចាយន្តោ ន បាវិសិ ។ ចោរា តំ ភិក្ខុំ អច្ឆិន្ទិំសុ ។ អថខោ សោ ភិក្ខុ សាវត្ថឹ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ សន្តំ ភិក្ខុំ អាបុច្ឆា វិកាលេ គាមំ បវិសិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសេយ្យ បាចិត្តិយន្តិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៣៦៧] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អហិនា ទដ្ឋោ ហោតិ ។ អញ្ញតរោ ភិក្ខុ អគ្គឹ អាហរិស្សាមីតិ គាមំ គច្ឆតិ ។ អថខោ សោ ភិក្ខុ



[៣៦៦] សម័យនោះឯង ភិក្ខុមួយរូបទៅកាន់ក្រុងសាវត្ថីក្នុងកោសលជនបទ វេលាល្ងាចបានចូលទៅកាន់ស្រុកមួយ ។ មនុស្សទាំងឡាយឃើញភិក្ខុនោះហើយបាននិយាយនូវពាក្យនេះថា សូមលោកម្ចាស់និមន្តចូលមក ។ ចំណែកភិក្ខុនោះរង្កៀសថា ព្រះដ៏មានព្រះភាគទ្រង់ហាមឃាត់ហាមការដែលមិនបានលាភិក្ខុផងគ្នា ហើយចូលស្រុកក្នុងវេលាវិកាល ទើបមិនហ៊ានចូលទៅ ។ ពួកចោរក៏ប្លន់ភិក្ខុនោះ ។ ភិក្ខុនោះទៅដល់ក្រុងសាវត្ថីក៏ប្រាប់សេចក្តីនុះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក្រាបទូលសេចក្តីនុះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុលាភិក្ខុដែលមាននៅជាមុន ហើយទើបចូលស្រុកក្នុងវេលាវិកាលបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនលាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ ។ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តសិក្ខាបទនេះដល់ភិក្ខុទាំងឡាយយ៉ាងនេះហើយ ។

[៣៦៧] សម័យនោះឯង មានពស់ចឹកភិក្ខុមួយរូប ។ ភិក្ខុមួយរូបទៅកាន់ស្រុកដោយគិតថា អាត្មានឹងទៅយកភ្លើងមក ។ តែភិក្ខុនោះ

ភគវតា បដិក្ខិត្តំ សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសិតុន្តិ កុក្កុច្ចាយន្តា ន បាវិសិំសុ ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ តថារូបេ អច្ចាយិកេ ករណីយេ សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សន្តំ ភិក្ខុំ អនាបុច្ឆា វិកាលេ គាមំ បវិសេយ្យ អញ្ញត្រ តថារូបា អច្ចាយិកា ករណីយា បាចិត្តិយន្តិ ។

[៣៦៦] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សន្តោ នាម ភិក្ខុ សក្កា ហោតិ អាបុច្ឆា បវិសិតុំ ។ អសន្តោ នាម ភិក្ខុ ន សក្កា ហោតិ អាបុច្ឆា បវិសិតុំ ។ វិកាលោ នាម មជ្ឈន្តិកេ វីតិវត្តេ យាវ អរុណុគ្គមនា ។ គាមំ បវិសេយ្យាតិ បរិក្ខិត្តស្ស គាមស្ស បរិក្ខេបំ អតិក្កាមេន្តស្ស អាបត្តិ បាចិត្តិយស្ស ។



រអៀសថា ព្រះដ៏មានព្រះភាគទ្រង់ឃាត់ហាមការមិនបាច់លាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាល ទើបមិនហ៊ានចូលទៅ ។ ភិក្ខុនោះក្រាបទូលដំណើរនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានកិច្ចប្រញាប់ដូច្នោះ មិនបាច់លាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាលបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយមិនបាច់លាភិក្ខុដែលមាននៅ ហើយចូលស្រុកក្នុងវេលាវិកាល ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ ។

[៣៦៦] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ភិក្ខុមាននៅ គឺភិក្ខុដែលគេគួរនឹងលាហើយចូលទៅ (កាន់ស្រុក) បាន ។ ដែលហៅថា ភិក្ខុមិនមាននៅ គឺមិនមានភិក្ខុដែលគេគួរនឹងលាហើយចូលទៅ (កាន់ស្រុក) ។ ដែលហៅថា វេលាវិកាលនោះ គឺកាលដែលថ្ងៃជ្រេកន្លងទៅ ដរាបដល់ទីអរុណរះឡើង ។ ពាក្យថា ចូលទៅកាន់ស្រុក សេចក្តីថា ភិក្ខុណាដើរកន្លងរបងនៃស្រុកដែលមានរបង ត្រូវអាបត្តិបាចិត្តិយ ។

អបរិក្ខិត្តស្ស គាមស្ស ឧបចារំ ឱក្កមន្តស្ស អាបត្តិ បាចិត្តិយស្ស ។ អញ្ញត្រ តថារូបា អច្ចាយិកា ករណីយាតិ ឋបេត្វា តថារូបំ អច្ចាយិកំ ករណីយំ ។

[៣៦៧] វិកាលេ វិកាលសញ្ញី សន្តំ ភិក្ខុំ អនាបុច្ឆា គាមំ បវិសតិ អញ្ញត្រ តថារូបា អច្ចាយិកា ករណីយា អាបត្តិ បាចិត្តិយស្ស ។ វិកាលេ វេមតិកោ សន្តំ ភិក្ខុំ អនាបុច្ឆា គាមំ បវិសតិ អញ្ញត្រ តថារូបា អច្ចាយិកា ករណីយា អាបត្តិ បាចិត្តិយស្ស ។ វិកាលេ កាលសញ្ញី សន្តំ ភិក្ខុំ អនាបុច្ឆា គាមំ បវិសតិ អញ្ញត្រ តថារូបា អច្ចាយិកា ករណីយា អាបត្តិ បាចិត្តិយស្ស ។ កាលេ វិកាលសញ្ញី អាបត្តិ ទុក្កដស្ស ។ កាលេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ កាលេ កាលសញ្ញី អនាបត្តិ ។





ភិក្ខុឈានជំហានចូលទៅកាន់ឧបចារស្រុកដែលគ្មានរបង ត្រូវអាបត្តិបាចិត្តិយ ។ ពាក្យថា វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ សេចក្តីថា លើកលែងតែកិច្ចប្រញាប់មានសភាពដូច្នោះ ។

(៣៦៧) វេលាវិកាល (កាលមិនគួរ) ភិក្ខុសំគាល់ថាវេលាវិកាល ហើយមិនបានលាភិក្ខុដែលមាននៅ ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ ។ វេលាវិកាល ភិក្ខុមានសេចក្តីសង្ស័យ ហើយមិនលាភិក្ខុដទៃគ្នាដែលមាននៅ ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់ដូច្នោះ ។ កាលមិនគួរ ភិក្ខុសំគាល់ថាកាលគួរ ហើយមិនលាភិក្ខុដទៃគ្នាដែលមាននៅ ចូលទៅកាន់ស្រុក ត្រូវអាបត្តិបាចិត្តិយ វៀរលែងតែមានកិច្ចប្រញាប់មានសភាពដូច្នោះ ។ កាលគួរ ភិក្ខុសំគាល់ថាកាលមិនគួរ ហើយមិនលាភិក្ខុដទៃគ្នា ចូលទៅកាន់(ស្រុក) ត្រូវអាបត្តិទុក្កដ ។ កាលគួរ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ កាលគួរ ភិក្ខុសំគាល់ថាកាលគួរ មិនត្រូវអាបត្តិឡើយ ។

(១៦៨) អនាបត្តិ តថារូបេ អច្ចាយិកេ ករណីយេ សន្តំ ភិក្ខុំ អាបុច្ឆា បវិសតិ អសន្តំ ភិក្ខុំ អនាបុច្ឆា បវិសតិ អន្តរារាមំ[១] គច្ឆតិ ភិក្ខុនុបស្សយំ គច្ឆតិ តិត្ថិយសេយ្យំ គច្ឆតិ បដិក្កមនំ គច្ឆតិ គាមេន មគ្គោ ហោតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។

---

១ ឱ. ម. អន្តរាមំ ។



(១៦៨) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១១ យ៉ាង) គឺភិក្ខុមានកិច្ចប្រញាប់មានសភាពដូច្នោះ ១ ភិក្ខុបានលាភិក្ខុដទៃដែលមាននៅហើយចូលទៅ ១ ភិក្ខុមិនបានលា ព្រោះគ្មានភិក្ខុហើយចូលទៅ ១ ភិក្ខុដើរទៅកាន់ចន្លោះអារាម ១ ភិក្ខុទៅកាន់លំនៅភិក្ខុនី ១ ភិក្ខុទៅកាន់លំនៅតិរ្ថិយ ១ ភិក្ខុទៅកាន់ទីឆាន់ហើយត្រឡប់វិញ ១ ភិក្ខុដើរតាមផ្លូវមានទៅកណ្ដាលស្រុក ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់ ។

# បញ្ចមសិក្ខាបទំ

(៣៦៩) តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន អញ្ញតរេន ទន្តការេន ភិក្ខូ បវារិតា ហោន្តិ យេសំ អយ្យានំ សូចិឃរេន អត្ថោ អហំ សូចិឃរេនាតិ ។ តេន ខោ បន សមយេន ភិក្ខូ ពហូ សូចិឃរេ វិញ្ញាបេន្តិ ។ យេសំ ខុទ្ទកា សូចិឃរា តេ មហន្តេ សូចិឃរេ វិញ្ញាបេន្តិ ។ យេសំ មហន្តា សូចិឃរា តេ ខុទ្ទកេ សូចិឃរេ វិញ្ញាបេន្តិ ។ អថ ខោ ទន្តការោ ភិក្ខូនំ ពហូ សូចិឃរេ ករោន្តោ ន សក្កោតិ អញ្ញំ វិក្កាយិកំ ភណ្ឌំ កាតុំ អត្តនាបិ ន យាបេតិ ។ បុត្តទារាបិស្ស កិលមន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា ពហូ សូចិឃរេ វិញ្ញាបេស្សន្តិ អយំ ឥមេសំ ពហូ សូចិឃរេ ករោន្តោ ន សក្កោតិ អញ្ញំ វិក្កាយិកំ ភណ្ឌំ កាតុំ អត្តនាបិ ន យាបេតិ បុត្តទារាបិស្ស

# សិក្ខាបទទី ៥

(៣៦៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ សម័យនោះឯង មានជាងភ្លុកម្នាក់ បានបវារណាភិក្ខុទាំងឡាយថា លោកម្ចាស់ទាំងឡាយណា ត្រូវការបំពង់ម្ជុល ខ្ញុំព្រះករុណានឹងប្រគេនបំពង់ម្ជុល ។ គ្រានោះ ភិក្ខុទាំងឡាយក៏បានសូមបំពង់ម្ជុលជាច្រើន ។ ពួកភិក្ខុណាមានបំពង់ម្ជុលតូច ភិក្ខុទាំងនោះសូមបំពង់ម្ជុលធំទៀត ពួកភិក្ខុណាមានបំពង់ម្ជុលធំ ភិក្ខុទាំងនោះសូមយកបំពង់ម្ជុលតូចទៀត ។ លំដាប់នោះ ជាងភ្លុក រវល់តែធ្វើបំពង់ម្ជុលច្រើនប្រគេនភិក្ខុទាំងឡាយ ក៏មិនអាចនឹងធ្វើរបស់សម្រាប់លក់ដូរឯទៀតបានឡើយ ហើយមិនអាចនឹងចិញ្ចឹមអត្តភាពឲ្យប្រព្រឹត្តទៅបានផង ទាំងកូននឹងប្រពន្ធរបស់ជាងនោះសោត ក៏នឿយព្រួយលំបាក ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តមិនស្គាល់នូវប្រមាណ សូមបំពង់ម្ជុលច្រើន ឯជាងភ្លុកនេះរវល់តែធ្វើបំពង់ម្ជុលច្រើនប្រគេនភិក្ខុទាំងនេះ ក៏មិនអាចធ្វើរបស់សម្រាប់លក់ដូរឯទៀតបាន ហើយមិនបានចិញ្ចឹមអត្តភាពឲ្យប្រព្រឹត្តទៅបានផង ទាំងកូននឹងប្រពន្ធរបស់ជាងនោះសោត

កិលមន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ ន មត្តំ ជានិត្វា ពហូ សូចិឃរានិ វិញ្ញាបេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ ន មត្តំ ជានិត្វា ពហូ សូចិឃរានិ វិញ្ញាបេន្តីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា ន មត្តំ ជានិត្វា ពហូ សូចិឃរានិ វិញ្ញាបេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អដ្ឋិមយំ វា ទន្តមយំ វា វិសាណមយំ វា សូចិឃរំ ការាបេយ្យ ភេទនកំ បាចិត្តិយន្តិ ។



ក៏ទៀតព្រួយលំបាក ។ កាលមនុស្សទាំងនោះកំពុងតែពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយបានឮច្បាស់ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមិនដឹងនូវប្រមាណ សូមបំពង់ម្ជុលច្រើន (ឬសំណាក់) ដូចម្តេចបាន ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាភិក្ខុទាំងឡាយមិនស្គាល់ប្រមាណ សូមបំពង់ម្ជុលច្រើន ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ ពួកមោឃបុរសទាំងនោះមិនដឹងនូវប្រមាណ សូមបំពង់ម្ជុលច្រើនដូច្នេះ ម្នាលភិក្ខុទាំងឡាយ សំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យគេធ្វើបំពង់ម្ជុលជាវិការនៃឆ្អឹងក្តី ជាវិការនៃភ្លុកក្តី ជាវិការនៃស្នែងក្តី ត្រូវភេទនកបាចិត្តិយ(*) ។

* អាបត្តិបាចិត្តិយនេះមានកិច្ចត្រូវបំបែកបំពង់ម្ជុលនោះចេញជាវិនយកម្ម ទើបសំដែងបាន បើមិនបានបំបែកជាវិនយកម្មទេ សំដែងមិនបានឡើយ ។

[៣៨០] យោ បនាតិ យោ យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អដ្ឋិ នាម យំ កិញ្ចិ អដ្ឋិ ។ ទន្តោ នាម ហត្ថិទន្តោ វុច្ចតិ ។ វិសាណំ នាម យំ កិញ្ចិ វិសាណំ ។ ការាបេយ្យាតិ ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ភិន្ទិត្វា បាចិត្តិយំ ទេសេតព្វំ ។

[៣៨១] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។





[៣៨០] ត្រង់ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចពោលក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ឆ្អឹង គឺឆ្អឹងណាមួយ ។ ដែលហៅថា ភ្លុក លោកសំដៅយកភ្លុកដំរីជាប្រមាណ ។ ដែលហៅថា ស្នែង គឺស្នែងណាមួយ ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ត្រូវបំបែកបំពង់ម្ជុលដែលខ្លួនបានមកនោះ ហើយសំដែងអាបត្តិបាចិត្តិយ ។

[៣៨១] ភិក្ខុធ្វើបំពង់ម្ជុលដែលខ្លួនធ្វើមិនទាន់ស្រេច ឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុបង្គាប់អ្នកដទៃឲ្យសម្រេចនូវបំពង់ម្ជុលដែលខ្លួនធ្វើមិនទាន់ស្រេច ត្រូវអាបត្តិបាចិត្តិយ ។ បំពង់ម្ជុលដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ បំពង់ម្ជុលដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើដោយខ្លួនឯងក្តី ប្រើអ្នកដទៃឲ្យធ្វើក្តី នូវបំពង់ម្ជុលដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានបំពង់ម្ជុលដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(៣៨៦) អនាបត្តិ គណ្ឋិកាយ អរណិកេ វិធេ អញ្ជនិយា អញ្ជនិសលាកាយ វាសិជដេ ឧទក-បុញ្ឆនិយា ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ចតុត្ថសិក្ខាបទំ និដ្ឋិតំ ។



(៣៨៦) ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៩ យ៉ាង) គឺភិក្ខុយកឆ្អឹងជាដើមមកធ្វើជាឡេវក្ដុំ ១ ធ្វើជារបស់សម្រាប់កួរភ្លើង ១ ធ្វើជាក្រវិលវត្ថុពន្ធចង្កេះ ១ ធ្វើជាភាជន៍សម្រាប់ដាក់ថ្នាំបន្តក់ភ្នែក ១ ធ្វើជាចង្កឹះដែលខ្ចាក់ភ្នែក ១ ធ្វើជាមៀនកាំបិត ១ ធ្វើជារបស់សម្រាប់ជូតទឹក ១ ភិក្ខុឆ្កួត ១ ភិក្ខុជាដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៤ ចប់ ។

## បញ្ចមសិក្ខាបទំ ។

[៣៩៣] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា ឧបនន្ទោ សក្យបុត្តោ ឧច្ចេ មញ្ចេ សយតិ ។ អថ ខោ ភគវា សម្ពហុលេហិ ភិក្ខូហិ សទ្ធឹ សេនាសនចារិកំ អាហិណ្ឌន្តោ យេន-អាយស្មតោ ឧបនន្ទស្ស សក្យបុត្តស្ស វិហារោ តេនុប-សង្កមិ ។ អទ្ទសា ខោ អាយស្មា ឧបនន្ទោ សក្យបុត្តោ ភគវន្តំ ទូរតោ វ អាគច្ឆន្តំ ទិស្វាន ភគវន្តំ ឯតទវោច អាគច្ឆតុ មេ ភន្តេ ភគវា សយនំ បស្សតូតិ ។ អថ-ខោ ភគវា តតោ វ បដិនិវត្តិត្វា ភិក្ខូ អាមន្តេសិ អាសយតោ ភិក្ខវេ មោឃបុរិសោ វេទិតព្វោតិ ។ អថខោ ភគវា អាយស្មន្តំ ឧបនន្ទំ សក្យបុត្តំ អនេកបរិយាយេន វិគរហិត្វា ទុព្ភរតាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ នវំ បន ភិក្ខុនា មញ្ចំ វា

## សិក្ខាបទទី ៥

[៣៩៣] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះឧបនន្ទសក្យបុត្តដ៏មានអាយុសិងលើគ្រែដ៏ខ្ពស់ ។ វេលានោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាច់ដំណើរទៅកាន់សេនាសនចារិកជាមួយនឹងពួកភិក្ខុច្រើនរូប ហើយចូលទៅកាន់វិហារដែលព្រះឧបនន្ទសក្យបុត្តដ៏មានអាយុនៅ ។ ឯព្រះឧបនន្ទសក្យបុត្តដ៏មានអាយុបានក្រឡេកទៅឃើញព្រះដ៏មានព្រះភាគកំពុងយាងមកអំពីចម្ងាយ លុះបានឃើញហើយ ក៏បានក្រាបទូលពាក្យនេះនឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សូមព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ចូលមកទតមើលទីដេក របស់ខ្ញុំព្រះអង្គចុះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ក៏ទ្រង់ត្រឡប់មកអំពីទីនោះវិញ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឯមោឃបុរស អ្នកទាំងឡាយគប្បីដឹងដោយទីអាស្រ័យ(១) ។ គ្រានោះឯង ព្រះដ៏មានព្រះភាគទ្រង់បន្ទោសព្រះឧបនន្ទសក្យបុត្តដ៏មានអាយុដោយអនេកបរិយាយ ។បេ។ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុធ្វើគ្រែក្តី

១ ដោយលំនៅ ។

បីឋំ វា ការយមានេន អដ្ឋង្គុលបាទកំ ការាបេតព្វំ សុគតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ អដនិយា តំ អតិក្កាមយតោ ឆេទនកំ បាចិត្តិយន្តិ ។

[៣៨៤] នវំ នាម ករណំ ឧបាទាយ វុច្ចតិ ។ មញ្ចោ នាម ចត្តារោ មញ្ចា មសារកោ ពុន្ទិកាពទ្ធោ កុឡីរបាទកោ អាហច្ចបាទកោ ។ បីឋំ នាម ចត្តារិ បីឋានិ មសារកំ ពុន្ទិកាពទ្ធំ កុឡីរបាទកំ អាហច្ចបាទកំ ។ ការយមានេនាតិ ករោន្តោ វា ការាបេន្តោ វា ។ អដ្ឋង្គុលបាទកំ ការាបេតព្វំ សុគតង្គុលេន អញ្ញត្រ ហេដ្ឋិមាយ អដនិយាតិ ឋបេត្វា ហេដ្ឋិមំ អដនឹ ។



តាំងក្ដីថ្មី ត្រូវឲ្យធ្វើឲ្យមានជើង ៨ ធ្នាប់ដោយធ្នាប់ព្រះសុគត វៀរតែ [illegible] ក្រោមចុះទៅ (បើធ្វើ) ឲ្យកន្លងហួសកំណត់នោះទៅ ត្រូវទោសឆេទនកបាចិត្តិយ(១) ។

(៣៨៤) ដែលហៅថា ថ្មី គឺសំដៅយកការធ្វើឡើងជាដំបូងណា ។ ដែលឈ្មោះថាគ្រែ គឺគ្រែមាន ៤ យ៉ាង គឺគ្រែដែលគេដាប់ជើងហើយចាក់ស្លាបទៅក្នុងតួនោះ ១ គ្រែដែលគេចាក់ជើងគ្រែជាប់នឹងគ្រែ ហើយធ្វើជាប់សន្ទឹងដាប់ល្អិត ១ គ្រែដែលគេធ្វើជើងប្រៀបដូចជើងក្ដាម ១ គ្រែដែលគេដាប់បញ្ចូលភ្ជាប់ទៅក្នុងថ្ម ១ ។ ដែលហៅថា តាំង គឺតាំងមាន ៤ យ៉ាង តាំងដែលគេដាប់ជើងហើយចាក់ស្លាបទៅក្នុងតួនោះ ១ តាំងដែលគេចាក់ជើងតាំងជាប់នឹងតាំង ហើយធ្វើជាប់សន្ទឹងដាប់ល្អិត ១ តាំងដែលគេធ្វើជើងប្រៀបដូចជើងក្ដាម ១ តាំងដែលគេដាប់បញ្ចូលភ្ជាប់ទៅក្នុងថ្ម ១ ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្ដី ឲ្យគេធ្វើក្ដី ។ ពាក្យថា ឲ្យធ្វើឲ្យមានជើង ៨ ធ្នាប់ ដោយធ្នាប់ព្រះសុគត វៀរលែងតែក្ដារក្រោម គឺវៀរលែងតែក្ដារក្រោមចុះទៅ

១ [illegible]

តំ អតិក្កាមេត្វា ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ឆិន្ទិត្វា បាចិត្តិយំ ទេសេតព្វំ ។

[៣៩៥] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣៩៦] អនាបត្តិ បមាណិកំ ករោតិ ឩនកំ ករោតិ អញ្ញេន កតំ បមាណាតិក្កន្តំ បដិលភិត្វា ឆិន្ទិត្វា បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



ទទឹងពីរចំអាមដែលមានពីក្រោម ភិក្ខុធ្វើដោយខ្លួនឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ត្រូវកាត់ផ្នែកដែលហួសប្រមាណនោះចេញ ហើយសំដែងអាបត្តិបាចិត្តិយ ។

[៣៩៥] ផ្នែកដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ផ្នែកដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ផ្នែកដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុធ្វើឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ផ្នែកដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសំពត់ដែលអ្នកដទៃធ្វើ (ហើយយកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៩៦] ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៥ យ៉ាង) គឺភិក្ខុធ្វើល្មមប្រមាណ ១ ភិក្ខុធ្វើឲ្យថយចុះពីប្រមាណ ១ ភិក្ខុបានសំពត់ដែលអ្នកដទៃធ្វើឲ្យហួសប្រមាណ (យកមក) កាត់ចេញហើយ ប្រើប្រាស់ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់ ។

## ឆដ្ឋសិក្ខាបទំ

[៣៩៧] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មញ្ចំបិ បីឋំបិ តូលោនទ្ធំ ការាបេន្តិ ។ មនុស្សា វិហារចារិកំ អាហិណ្ឌន្តា បស្សិត្វា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា មញ្ចំបិ បីឋំបិ តូលោនទ្ធំ ការាបេស្សន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ មញ្ចំបិ បីឋំបិ តូលោនទ្ធំ ការាបេស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ មញ្ចំបិ បីឋំបិ តូលោនទ្ធំ ការាបេថាតិ ។ សច្ចំ ភគវាតិ ។

## សិក្ខាបទទី ៦

[៣៩៧] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ពួកឆព្វគ្គិយភិក្ខុឲ្យគេធ្វើគ្រែ តាំង ញាត់ដោយសំឡីរ ឬសំឡីកប្បាស (ដាំដើម) ។ ពួកមនុស្សនាំគ្នាដើរទៅកាន់វិហារចារិក បានឃើញហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តមិនគួរនឹងឲ្យគេធ្វើគ្រែ តាំង ញាត់ដោយសំឡីដូចជាពួកគ្រហស្ថអ្នកបរិភោគកាមគុណសោះ ។ កាលមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮហើយ ។ ពួកភិក្ខុណាមានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងឲ្យគេធ្វើគ្រែ តាំង ញាត់ដោយសំឡីសោះ ។ បេ ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកឲ្យគេធ្វើគ្រែ តាំង ញាត់ដោយសំឡី ពិតមែនឬ ។

បាចិត្តិយកណ្ឌេ រតនវគ្គស្ស ឆដ្ឋសិក្ខាបទស្ស បញ្ញត្តិ

វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ មោឃបុរិសា មញ្ចម្បិ បីឋម្បិ តូលោនទ្ធំ ការាបេស្សន្តិ នេតំ មោឃបុ-រិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោ-ភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ មញ្ចំ វា បីឋំ វា តូលោនទ្ធំ ការាបេយ្យ ឧទ្ទាលនកំ បាចិត្តិយន្តិ ។

[៣៩៨] យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ មញ្ចោ នាម ចត្តារោ មញ្ចា មសារកោ ពុន្ទិកាពទ្ធោ កុឡីរ-បាទកោ អាហច្ចបាទកោ ។ បីឋំ នាម ចត្តារិ បីឋានិ



បាចិត្តិយកណ្ឌ រតនវគ្គ សិក្ខាបទទី ៦ សេចក្តីបញ្ញត្តិ

ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងឲ្យគេធ្វើគ្រែខ្លះ តាំងខ្លះ ញាត់ដោយសំឡីទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យគេធ្វើគ្រែក្តី តាំងក្តី ញាត់ដោយសំឡី ត្រូវទម្លាយចេញ បាចិត្តិយ[១] ។

[៣៩៨] ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបាចិត្តិយកណ្ឌ ។ ដែលហៅថា គ្រែ គឺគ្រែមាន ៤ យ៉ាង គឺ គ្រែដែលគេដាប់ជើង ហើយបញ្ចូលមេគ្រែទៅក្នុងជើងណាប់នោះ ១ គ្រែដែលគេបង្កប់ជើងនឹងគ្រែដោយមេគ្រែ ហើយចាក់ដោយសារដុំបានលុះធ្លុះ ១ គ្រែដែលគេធ្វើជើងប្រហែលនឹងជើងសេះជើងក្តាមជាដើម ១ គ្រែដែលគេបានបញ្ចុះមធ្យមទៅក្នុងជើង ១ ។ ដែលហៅថា តាំង គឺតាំងមាន ៤ យ៉ាង ផ្ទានដល់តាំងដែលគេដាប់ជើង ហើយបញ្ចូលមេតាំងទៅក្នុងជើងណាប់នោះ ១

១ ពាក្យថាបាចិត្តិយនេះមានកិច្ចត្រូវទំលាយ (សំឡី) នោះចេញជាមុនសិន ទើបសំដែងអាបត្តិនោះជាខាងក្រោយ សំដែងអំពីនេះទៀត ។

មសារកំ បុន្ទិកាពទ្ធំ កុឡីរបាទកំ អាហច្ចបាទកំ ។ តូលំ នាម តីណិ តូលានិ រុក្ខតូលំ លតាតូលំ បោដកិតូលំ ។ ការាបេយ្យាតិ ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ឧទ្ទាលេត្វា បាចិត្តិយំ ទេសេតព្វំ ។

[៣៤៩] អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។



តាំងដែលគេបញ្ចុះជើងតាំងដោយមេតាំងចង្កូម ហើយធ្វើដោយសន្ទះជាប់ល្អ ១ តាំងដែលគេធ្វើជើងប្រហែលនឹងជើងសេះជើងពពែជាដើម ១ តាំងដែលគេដំបញ្ចុះជើងទៅក្នុងខ្លួន ១ ។ ដែលហៅថា សំឡី គឺសំឡីមាន ៣ យ៉ាង គឺសំឡីកើតអំពីដើមឈើ (មានដើមគរជាដើម) ១ សំឡីកើតអំពីវល្លិ (មានវល្លិទឹកដោះជាដើម) ១ សំឡីកើតអំពីស្មៅ ១ ។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើដោយខ្លួនឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវរើកកាយសំឡីក្នុងគ្រែតាំងនោះ ដែលបានមក ហើយសំដែងអាបត្តិបាចិត្តិយ ។

[៣៤៩] គ្រែឬតាំងដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ គ្រែឬតាំងដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ គ្រែឬតាំងដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ គ្រែឬតាំងដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើគ្រែឬតាំងដោយខ្លួនឯងក្តី អ្នកដទៃធ្វើក្តី ដើម្បីបុគ្គលដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានគ្រែឬតាំងដែលអ្នកដទៃធ្វើឲ្យ (ហើយយកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(៣៩០) អនាបត្តិ អាយោគេ កាយពន្ធនេ អំសពទ្ធកេ បត្តត្ថវិកាយ បរិស្សាវនេ ពិម្ពោហនំ ករោតិ អញ្ញេន កតំ បដិលភិត្វា ឧទ្ទាលេត្វា បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ឆដ្ឋសិក្ខាបទំ និដ្ឋិតំ ។





(៣៩០) វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុធ្វើជាសំពត់សារោង ១ ធ្វើជាវត្ថពន្ធចង្កេះ ១ ធ្វើជាយោងបាត្រ ១ ធ្វើជាស្បោងបាត្រ ១ ធ្វើជាតម្រងទឹក ១ ធ្វើជាខ្នើយ ១ ភិក្ខុបានសំពត់ដែលអ្នកដទៃធ្វើឲ្យ (ហើយយកមក) ទម្លាយចេញទើបប្រើប្រាស់ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៦ ចប់ ។

# សត្តមសិក្ខាបទំ

[៣៨១] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខូនំ និសីទនំ អនុញ្ញាតំ ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ភគវតា និសីទនំ អនុញ្ញាតន្តិ អប្បមាណិកានិ និសីទនានិ ធារេន្តិ មញ្ចស្សបិ បីឋស្សបិ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អប្បមាណិកានិ និសីទនានិ ធារេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អប្បមាណិកានិ និសីទនានិ ធារេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា អប្បមាណិកានិ និសីទនានិ ធារេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ

# សិក្ខាបទទី ៧

[៣៨១] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សំពត់និសីទនៈ (សំពត់សម្រាប់ក្រាលអង្គុយ) ព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ ។ ឆព្វគ្គិយភិក្ខុគិតថា សំពត់និសីទនៈព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយ ។ ក៏ប្រើប្រាស់សំពត់និសីទនៈទាំងឡាយមិនល្មមប្រមាណ ទុកឲ្យសំពត់និសីទនៈទាំងនោះសំយុងចុះពីខាងមុខខ្លះ ពីខាងក្រោយខ្លះនៃគ្រែនិងតាំង ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងប្រើប្រាស់សំពត់និសីទនៈមិនល្មមប្រមាណសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់សំពត់និសីទនៈមិនល្មមប្រមាណពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគ ទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយ មិនគួរនឹងប្រើប្រាស់សំពត់និសីទនៈមិនល្មមតាមប្រមាណ ។ នែមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយឲ្យកាន់តែជ្រះថ្លាឡើងទេ

។ ឃ ។ បរិញ្ញា បន ភិក្ខវេ ឯវំ សតិវិនយស្ស ទាតព្វោ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វោ ... ឧមាយសោ ... ឥមេ ខោ ... សុភកាវេទេយ្យោ ... ទិន្នោ ... សតិវិនយោ ... ធម្មិកា ... សតិវិនយស្ស ទានា ... ហោតិ ។

(៣៩៦) តេន ខោ បន សមយេន អាយស្មា ទព្វោ មល្លបុត្តោ ... ហោតិ ។ សោ ភគវតោ ... ទិន្នោ ... សមន្តតោ សមញ្ញាយោ ... ។ អថខោ ... អាយស្មតោ ... បកតត្តា ... ទិន្នោ ... សមន្តតោ សមញ្ញាតំ ... ឧបសម្បទំ ... ។ អថ ... ភគវា ... ភិក្ខូ អាមន្តេសិ ... អនុជានាមិ ភិក្ខវេ ... ។





។ ឃ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងនូវសតិវិន័យ ... ក្នុងអធិករណ៍ ... សតិវិន័យ ... ព្រះសង្ឃ ... ម្នាលភិក្ខុទាំងឡាយ ... ធម្មិកា ... ព្រះសង្ឃ ... ព្រះសម្មាសម្ពុទ្ធ ... សតិវិន័យ ... ព្រះសង្ឃ ... ។

(៣៩៦) សម័យនោះឯង ព្រះទព្វមល្លបុត្តមានអាយុ ... ព្រះ ... ព្រះសង្ឃ ... សតិវិន័យ ... ព្រះមានព្រះភាគ ... ព្រះទព្វមល្លបុត្តមានអាយុ ... ព្រះសង្ឃ ... សតិវិន័យ ... ព្រះមានព្រះភាគ ... ភិក្ខុទាំងឡាយ ... ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត (ឲ្យ)

ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ និសី-
ទនំ បន ភិក្ខុនា ការយមានេន បមាណិកំ ការេ-
តព្វំ ។ តត្រិទំ បមាណំ ទីឃសោ ទ្វេ វិទត្ថិយោ
សុគតវិទត្ថិយា តិរិយំ ទិយឌ្ឍំ ទសា វិទត្ថិ ។ តំ
អតិក្កាមយតោ ឆេទនកំ បាចិត្តិយន្តិ ។

[៣៩៣] និសីទនំ នាម សទសំ វុច្ចតិ ។ ការា-
បយមានោតិ ករោន្តោ វា ការាបេន្តោ វា ។ បមាណិកំ
ការេតព្វំ ។ តត្រិទំ បមាណំ ទីឃសោ ទ្វេ វិទត្ថិយោ
សុគតវិទត្ថិយា តិរិយំ ទិយឌ្ឍំ ទសា វិទត្ថិ ។ តំ
អតិក្កាមេត្វា ករោតិ វា ការាបេតិ វា បយោគេ
ទុក្កដំ ។ បដិលាភេន ឆិន្ទិត្វា បាចិត្តិយំ ទេសេតព្វំ ។

[៣៩៤] អត្តនា វិប្បកតំ អត្តនា បរិយោសា-
បេតិ អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ
បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។
បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ



ទុកជាយនៃសំពត់និសីទនៈ ១ ចំអាមទៀត ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-
ឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុនឹងឲ្យគេធ្វើសំពត់
និសីទនៈ ត្រូវឲ្យគេធ្វើឲ្យត្រូវតាមប្រមាណ ។ ឯប្រមាណនៃសំពត់និសីទនៈ
នោះយ៉ាងនេះ គឺបណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្លះ ជាយ ១
ចំអាម ដោយចំអាមព្រះសុគត ។ (បើភិក្ខុធ្វើ) ឲ្យកន្លងហួសពីនោះទៅ
ត្រូវទោសឆេទនកបាចិត្តិយ ។

[៣៩៣] ដែលហៅថា សំពត់និសីទនៈនោះ គឺសំដៅយកសំពត់
និសីទនៈដែលមានជាយ ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្តី ឲ្យគេធ្វើ
ក្តី ។ ភិក្ខុត្រូវធ្វើឲ្យត្រូវតាមប្រមាណ ។ ឯប្រមាណនៃសំពត់និសីទនៈ
នោះយ៉ាងនេះ គឺបណ្តោយ ២ ចំអាម ទទឹង ១ ចំអាមកន្លះ ជាយ ១ ចំ-
អាម ដោយចំអាមព្រះសុគត ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ឲ្យកន្លងហួស
ប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់
និសីទនៈនោះ ដែលបានមក ហើយសំដែងនូវអាបត្តិបាចិត្តិយចេញ ។

[៣៩៤] សំពត់និសីទនៈដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យ
សម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់និសីទនៈដែលខ្លួនធ្វើមិន
ទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ សំពត់និសី-
ទនៈដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិ

បាចិត្តិយស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣៩៩] អនាបត្តិ បមាណិកំ ករោតិ ឩនកំ ករោតិ អញ្ញេន កតំ បមាណាតិក្កន្តំ បដិលភិត្វា ឆិន្ទិត្វា បរិភុញ្ជតិ វិតានំ វា ភូម្មត្ថរណំ វា សាណិបាការំ វា ភិសិំ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

សត្តមសិក្ខាបទំ និដ្ឋិតំ ។



បាចិត្តិយ ។ សំពត់និសីទនៈដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃធ្វើឲ្យសម្រេច ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីអ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសំពត់និសីទនៈដែលបុគ្គលដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៩៩] វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុធ្វើសំពត់និសីទនៈត្រូវតាមប្រមាណ ១ ភិក្ខុធ្វើសំពត់និសីទនៈថយចុះពីប្រមាណ ១ ភិក្ខុបានសំពត់និសីទនៈ ដែលអ្នកដទៃធ្វើឲ្យលើសហួសប្រមាណ ហើយកាត់ចេញរួចហើយប្រើប្រាស់ ១ ភិក្ខុធ្វើសំពត់និសីទនៈឲ្យជាពិតានក្តី ឲ្យជាកម្រាលផែនដីក្តី ឲ្យជារនាំងក្តី ឲ្យជាពូកក្តី ឲ្យជាខ្នើយក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៧ ចប់ ។

# អដ្ឋមសិក្ខាបទំ

[៣៨៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខូនំ កណ្ឌុប្បដិច្ឆាទិ អនុញ្ញាតា ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ភគវតា កណ្ឌុប្បដិច្ឆាទិ អនុញ្ញាតាតិ អប្បមាណិកាយោ កណ្ឌុប្បដិច្ឆាទិយោ ធារេន្តិ បុរតោបិ បច្ឆតោបិ អាកឌ្ឍន្តា អាហិណ្ឌន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អប្បមាណិកាយោ កណ្ឌុប្បដិច្ឆាទិយោ ធារេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អប្បមាណិកាយោ កណ្ឌុប្បដិច្ឆាទិយោ ធារេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា អប្បមាណិកាយោ កណ្ឌុប្បដិច្ឆា-ទិយោ ធារេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច

# សិក្ខាបទទី ៨

[៣៨៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះដ៏មានព្រះភាគបានអនុញ្ញាតសំពត់សម្រាប់បិទកម (ដំបៅ) ដល់ភិក្ខុទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុគិតថា សំពត់សម្រាប់បិទកមព្រះដ៏មានព្រះភាគទ្រង់បានអនុញ្ញាតហើយ ។ ក៏ប្រើប្រាស់នូវសំពត់សម្រាប់បិទកមទាំងឡាយមិនសមប្រមាណ ទាញពីមុខខ្លះពីក្រោយខ្លះហើយចេញដើរទៅ ។ ពួកភិក្ខុណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងប្រើប្រាស់សំពត់សម្រាប់បិទកមមិនសមប្រមាណសោះ ។បេ។ ព្រះដ៏មានព្រះភាគត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់សំពត់សម្រាប់បិទកមទាំងឡាយមិនសមប្រមាណ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយមិនគួរនឹងប្រើប្រាស់សំពត់សម្រាប់បិទកម មិនសមប្រមាណទេ នែពួកមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ

បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ កណ្ឌុ-
ប្បដិច្ឆាទឹ បន ភិក្ខុនា ការយមានេន បមាណិកា
ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ ចតស្សោ
វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ទ្វេ វិទត្ថិយោ ។
តំ អតិក្កាមយតោ ឆេទនកំ បាចិត្តិយន្តិ ។

(៣៨៧) កណ្ឌុប្បដិច្ឆាទិ នាម យស្ស អធោនាភិ
ឧព្ភជាណុមណ្ឌលំ កណ្ឌុ វា បិឡកា វា អស្សាវោ វា
ថុល្លកច្ឆុ វា អាពាធោ តស្ស បដិច្ឆាទនត្ថាយ ។
ការយមានេនាតិ ករោន្តោ វា ការាបេន្តោ វា ។
បមាណិកា ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ
ចតស្សោ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ទ្វេ
វិទត្ថិយោ ។ តំ អតិក្កាមេត្វា ករោតិ វា ការាបេតិ វា
បយោគេ ទុក្កដំ បដិលាភេន ឆិន្ទិត្វា បាចិត្តិយំ
ទេសេតព្វំ ។

(៣៨៨) អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ
អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ បរេហិ



អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុឲ្យគេ
ធ្វើសំពត់សម្រាប់គ្របកម ត្រូវឲ្យគេធ្វើឲ្យត្រូវនឹងប្រមាណ ។ ឯប្រមាណ
គង់សំពត់សម្រាប់គ្របកមនោះ យ៉ាងនេះ គឺបណ្ដោយ ៤ ចំអាម
ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឲ្យកន្លងហួសប្រ-
មាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

(៣៨៧) សំពត់ដែលឈ្មោះថាគ្របបិទ ឬត្រង់ទីណាមួយ គឺកម
ឬរមាស់ក្ដី ឬស្ផូតក្ដី ទឹករងៃក្ដី ឬស្រែងក្ដី តាំងពីខាងក្រោមផ្ចិតចុះមក
តាំងពីមណ្ឌលជង្គង់ឡើងទៅរបស់ភិក្ខុ ហៅថាសំពត់សម្រាប់គ្របកម ។
ពាក្យថា ឲ្យគេធ្វើ គឺធ្វើឯងក្ដី ឲ្យគេធ្វើក្ដី ។ ភិក្ខុត្រូវឲ្យគេធ្វើឲ្យ
ត្រូវនឹងប្រមាណ ។ ឯប្រមាណគង់សំពត់សម្រាប់គ្របកមនោះយ៉ាងនេះ
គឺបណ្ដោយ ៤ ចំអាម ទទឹង ២ ចំអាម ដោយចំអាមព្រះសុគត ។
ភិក្ខុធ្វើឯងក្ដី ឲ្យគេធ្វើក្ដី ឲ្យកន្លងហួសប្រមាណនោះ ត្រូវអាបត្តិទុក្កដ
ក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់សំពត់សម្រាប់គ្របកមក្នុងខណៈដែល
បានមក ហើយសឹមសំដែងអាបត្តិបាចិត្តិយចេញ ។

(៣៨៨) សំពត់សម្រាប់គ្របកមដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុ
ធ្វើឲ្យសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់សម្រាប់គ្របកមដែល

បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣៨៩] អនាបត្តិ បមាណិកំ ករោតិ ឩនកំ ករោតិ អញ្ញេន កតំ បមាណាតិក្កន្តំ បដិលភិត្វា ឆិន្ទិត្វា បរិភុញ្ជតិ វិតានំ វា ភុម្មត្ថរណំ វា សាណិបាការំ វា ភិសិំ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

អដ្ឋមសិក្ខាបទំ និដ្ឋិតំ ។



ខ្លួនធ្វើមិនទាន់ស្រេច ហើយឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ សំពត់សម្រាប់ស្រង់ទឹកដែលអ្នកដទៃធ្វើមិនទាន់ស្រេច ហើយសម្រេចខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់សម្រាប់ស្រង់ទឹកដែលអ្នកដទៃធ្វើមិនទាន់ស្រេច ហើយឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុនីធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីបានសំពត់សម្រាប់ស្រង់ទឹក ដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៨៩] អនាបត្តិមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៦ យ៉ាង) ភិក្ខុនីធ្វើសំពត់សម្រាប់ស្រង់ទឹកត្រឹមប្រមាណ ១ ភិក្ខុនីធ្វើសំពត់សម្រាប់ស្រង់ទឹកថយចុះពីប្រមាណ ១ ភិក្ខុនីបានសំពត់សម្រាប់ស្រង់ទឹកដែលអ្នកដទៃធ្វើឲ្យកន្លងហួសប្រមាណហើយកាត់ចេញ ទើបប្រើប្រាស់ ១ ភិក្ខុនីធ្វើសំពត់សម្រាប់ស្រង់ទឹកឲ្យជាពិតានក្តី ជាកម្រាលផែនដីក្តី ជារនាំងក្តី ជាពូកក្តី ជាខ្នើយក្តី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីជាដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៨ ចប់ ។

## នវមសិក្ខាបទំ

(៣៩០) តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ភគវតា ភិក្ខូនំ វស្សិកសាដិកា អនុញ្ញាតា ហោតិ ។ ឆព្វគ្គិយា ភិក្ខូ ភគវតា វស្សិកសាដិកា អនុញ្ញាតាតិ អប្បមាណិកាយោ វស្សិកសាដិកាយោ ធារេន្តិ បុរតោបិ បច្ឆតោបិ អាកឌ្ឍន្តា អាហិណ្ឌន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ អប្បមាណិកាយោ វស្សិកសាដិកាយោ ធារេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ អប្បមាណិកាយោ វស្សិកសាដិកាយោ ធារេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា អប្បមាណិកាយោ វស្សិកសាដិកាយោ ធារេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច

## សិក្ខាបទទី ៩

(៣៩០) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង សំពត់វស្សិកសាដក ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយដល់ភិក្ខុទាំងឡាយ ។ ឯពួកឆព្វគ្គិយភិក្ខុនិកគ្នាថា សំពត់វស្សិកសាដក ព្រះដ៏មានព្រះភាគទ្រង់អនុញ្ញាតហើយ ។ ក៏ប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណ ទាញពីមុខខ្លះពីក្រោយខ្លះហើយដើរទៅ ។ ពួកភិក្ខុណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុម៉េចក៏នឹងប្រើប្រាស់សំពត់វស្សិកសាដកមិនសមប្រមាណសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយប្រើប្រាស់សំពត់វស្សិកសាដក មិនសមប្រមាណ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា នែពួកមោឃបុរស អ្នកទាំងឡាយម៉េចក៏នឹងប្រើប្រាស់សំពត់វស្សិកសាដក មិនសមប្រមាណទេ នែពួកមោឃបុរស អំពើនុះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុ

បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ វស្សិកសា-
ដិកំ បន ភិក្ខុនា ការយមានេន បមាណិកា
ការេតព្វា ។ តត្រិទំ បមាណំ ទីឃសោ ឆ វិទត្ថិយោ
សុគតវិទត្ថិយា តិរិយំ អឌ្ឍតេយ្យា ។ តំ អតិក្កាម-
យតោ ឆេទនកំ បាចិត្តិយន្តិ ។

(៣៩១) វស្សិកសាដិកា នាម វស្សានេ
ចាតុម្មាសត្ថាយ ។ ការយមានេនាតិ ករោន្តោ វា
ការាបេន្តោ វា ។ បមាណិកា ការេតព្វា ។ តត្រិទំ
បមាណំ ទីឃសោ ឆ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ
អឌ្ឍតេយ្យា ។ តំ អតិក្កាមេត្វា ករោតិ វា ការាបេតិ
វា បយោគេ ទុក្កដំ បដិលាភេន ឆិន្ទិត្វា បាចិត្តិយំ
ទេសេតព្វំ ។

(៣៩២) អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ
អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ បរេហិ បរិ-
យោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ



ចាំទុកចុះ អ្នកទាំងឡាយគប្បីសំដែងនូវសិក្ខាបទនេះយ៉ាងនេះថា
ភិក្ខុឲ្យគេធ្វើសំពត់វស្សិកសាដក ត្រូវឲ្យគេធ្វើឲ្យត្រូវតាមប្រមាណ ។ ឯ
ប្រមាណក្នុងសំពត់វស្សិកសាដកនោះយ៉ាងនេះ គឺបណ្តោយ ៦ ចំអាម
ទទឹង ២ ចំអាមកន្លះ ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឲ្យកន្លងហួស
ប្រមាណនោះទៅ ត្រូវឆេទនកបាចិត្តិយ ។

(៣៩១) ដែលហៅថា សំពត់វស្សិកសាដកនោះ គឺសំពត់ដែលភិក្ខុ
ស្លៀកសម្រាប់ងូតទឹកភ្លៀងអស់ ៤ ខែនៃរដូវវស្សា ។ ពាក្យថា ឲ្យគេធ្វើ គឺធ្វើ
ឯងក្តី ឲ្យគេធ្វើក្តី ។ ភិក្ខុត្រូវឲ្យគេធ្វើឲ្យត្រូវតាមប្រមាណ ។ ឯប្រមាណ
ក្នុងសំពត់វស្សិកសាដកនោះយ៉ាងនេះ គឺបណ្តោយ ៦ ចំអាម ទទឹង ២
ចំអាមកន្លះ ដោយចំអាមព្រះសុគត ។ បើភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី
ឲ្យកន្លងហួសប្រមាណនោះទៅ ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុ
ត្រូវកាត់សំពត់វស្សិកសាដកក្នុងខណៈដែលបានមក ហើយសំដែង
អាបត្តិបាចិត្តិយចេញ ។

(៣៩២) សំពត់វស្សិកសាដកដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យ
សម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់វស្សិកសាដកដែល
ខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។
សំពត់វស្សិកសាដកដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេច

អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ បរេហិ បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

[៣៩៣] អនាបត្តិ បមាណិកំ ករោតិ ឩនកំ ករោតិ អញ្ញេន កតំ បមាណាតិក្កន្តំ បដិលភិត្វា ឆិន្ទិត្វា បរិភុញ្ជតិ វិតានំ វា ភុម្មត្ថរណំ វា សាណិបាការំ វា ភិសិំ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

នវមសិក្ខាបទំ និដ្ឋិតំ ។



ដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ សំពត់ស្លៀកសាដកដែលអ្នកដទៃធ្វើ មិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានសំពត់ស្លៀកសាដកដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

[៣៩៣] ភិក្ខុដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុធ្វើសំពត់ស្លៀកសាដកត្រូវតាមប្រមាណ ១ ភិក្ខុធ្វើសំពត់ស្លៀកសាដកថយចុះពីប្រមាណ ១ ភិក្ខុបានសំពត់ស្លៀកសាដកដែលអ្នកដទៃធ្វើឲ្យហួសប្រមាណ ហើយ (យកមក) កាត់ចេញ ទើបប្រើប្រាស់ ១ ភិក្ខុធ្វើសំពត់ស្លៀកសាដក (នោះ) ឲ្យជាពិតានក្តី ជាកម្រាលផែនដីក្តី ជារនាំងក្តី ជាពូកក្តី ជាខ្នើយក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៩ ចប់ ។

## ទសមសិក្ខាបទំ

[៣៩៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អាយស្មា នន្ទោ ភគវតោ មាតុច្ឆាបុត្តោ អភិរូបោ ហោតិ ទស្សនីយោ បាសាទិកោ ចតុរង្គុលោមកោ ភគវតា ។ សោ សុគតចីវរប្បមាណំ ចីវរំ ធារេតិ ។ អទ្ទសំសុ ខោ ថេរា ភិក្ខូ អាយស្មន្តំ នន្ទំ ទូរតោវ អាគច្ឆន្តំ ទិស្វាន ភគវា អាគច្ឆតីតិ អាសនា វុដ្ឋហន្តិ ។ តេ ឧបគតំ សញ្ជានិត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម អាយស្មា នន្ទោ សុគតចីវរប្បមាណំ ចីវរំ ធារេស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ នន្ទ សុគតចីវរប្បមាណំ ចីវរំ ធារេសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ នន្ទ សុគតចីវរប្បមាណំ ចីវរំ ធារេស្សសិ នេតំ នន្ទ អប្បសន្នានំ វា

## សិក្ខាបទទី ១០

[៣៩៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ព្រះនន្ទដ៏មានអាយុ ជាបុត្តនៃព្រះមាតុច្ឆានៃព្រះដ៏មានព្រះភាគ មានរូបល្អគួរនឹងរមិលមើល គួរជ្រះថ្លា មានកំពស់តិចជាងព្រះដ៏មានព្រះភាគ ៤ ធ្នាប់ ។ ព្រះនន្ទនោះទ្រទ្រង់ចីវរប៉ុនប្រមាណចីវរព្រះសុគត ។ ពួកភិក្ខុជាថេរៈបានឃើញព្រះនន្ទដ៏មានអាយុ ដើរមកអំពីចម្ងាយ លុះឃើញហើយក៏នាំគ្នាក្រោកអំពីអាសនៈ ដោយគិតថា ព្រះដ៏មានព្រះភាគទ្រង់ពុទ្ធដំណើរមក ។ លុះព្រះនន្ទចូលមកដល់ហើយ ភិក្ខុទាំងនោះក៏ស្គាល់ច្បាស់ ទើបពោលទោស តិះដៀល បន្តុះបង្អាប់ថា ព្រះនន្ទដ៏មានអាយុមិនគួរនឹងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគតសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលនន្ទ ឮថាអ្នកឯងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគត ពិតមែនឬ ។ ព្រះនន្ទនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលនន្ទ អ្នកឯងមិនគួរនឹងប្រើប្រាស់ចីវរប៉ុនចីវរព្រះសុគតសោះ ម្នាលនន្ទ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លា

បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ សុគតចីវរប្បមាណំ ចីវរំ ការាបេយ្យ អតិរេកំ វា ឆេទនកំ បាចិត្តិយំ ។ តត្រិទំ សុគតស្ស សុគតចីវរប្បមាណំ ទីឃសោ នវ វិទត្ថិយោ សុគត-វិទត្ថិយា តិរិយំ ឆ វិទត្ថិយោ ។ ឥទំ សុគតស្ស សុគតចីវរប្បមាណន្តិ ។

(៣៩៥) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ សុគតចីវរប្បមាណំ នាម ទីឃសោ នវ វិទត្ថិយោ សុគតវិទត្ថិយា តិរិយំ ឆ វិទត្ថិយោ ។ ការាបេយ្យាតិ ករោតិ វា ការាបេតិ វា បយោគេ ទុក្កដំ បដិលាភេន ឆិន្ទិត្វា បាចិត្តិយំ ទេសេតព្វំ ។

(៣៩៦) អត្តនា វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អត្តនា វិប្បកតំ បរេហិ បរិ-យោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។



ឲ្យជ្រះថ្លាឡើង ឬដើម្បីឲ្យពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងថែម ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុណាមួយឲ្យគេធ្វើចីវរប៉ុនចីវរព្រះសុគតក្តី ធំជាងក្តី ត្រូវឆេទនកបាចិត្តិយ ។ ឯប្រមាណសុគតចីវររបស់ព្រះសុគតនោះមានយ៉ាងនេះ គឺបណ្តោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត ។ នេះជាប្រមាណសុគតចីវររបស់ព្រះសុគត ។

(៣៩៥) ពាក្យថា ភិក្ខុណាមួយ មានសេចក្តីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ដែលហៅថា ប្រមាណសុគតចីវរ គឺបណ្តោយ ៩ ចំអាម ទទឹង ៦ ចំអាម ដោយចំអាមព្រះសុគត ។ ពាក្យថា ឲ្យគេធ្វើ គឺភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ត្រូវអាបត្តិទុក្កដក្នុងប្រយោគដែលធ្វើ ភិក្ខុត្រូវកាត់ចីវរក្នុងខណៈដែលបានមក ហើយសំដែងនូវអាបត្តិបាចិត្តិយចេញ ។

(៣៩៦) ចីវរដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដែលខ្លួនធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ចីវរដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យសម្រេចដោយខ្លួនឯង ត្រូវអាបត្តិបាចិត្តិយ ។

បរេហិ វិប្បកតំ អត្តនា បរិយោសាបេតិ អាបត្តិ បាចិត្តិយស្ស ។ អញ្ញស្សត្ថាយ ករោតិ វា ការាបេតិ វា អាបត្តិ ទុក្កដស្ស ។ អញ្ញេន កតំ បដិលភិត្វា បរិភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

(៣៤៣) អនាបត្តិ ឩនកំ ករោតិ អញ្ញេន កតំ បដិលភិត្វា ឆិន្ទិត្វា បរិភុញ្ជតិ វិតានំ វា ភុម្មត្ថរណំ វា សាណិបាការំ វា ភិសិំ វា ពិម្ពោហនំ វា ករោតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទសមសិក្ខាបទំ និដ្ឋិតំ ។

រតនវគ្គោ នវមោ ។

តស្សុទ្ទានំ

រាជា ច រតនំ សន្តំ   សូចិ មញ្ចញ្ច តូលិកំ

និសីទនញ្ច កណ្ឌុញ្ច   វស្សិកា សុគតេន ចាតិ ។



ចីវរដែលអ្នកដទៃធ្វើមិនទាន់ស្រេច ភិក្ខុឲ្យអ្នកដទៃទៀតសម្រេចឲ្យ ត្រូវអាបត្តិបាចិត្តិយ ។ ភិក្ខុធ្វើឯងក្តី ឲ្យគេធ្វើក្តី ដើម្បីប្រយោជន៍អ្នកដទៃ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយ (យកមក) ប្រើប្រាស់ ត្រូវអាបត្តិទុក្កដ ។

(៣៤៣) ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុធ្វើចីវរថយចុះពីប្រមាណ ១ ភិក្ខុបានចីវរដែលអ្នកដទៃធ្វើហើយ (យកមក) កាត់ចេញ ទើបប្រើប្រាស់ ១ ភិក្ខុធ្វើចីវរនោះ ឲ្យជាពិតានក្តី ជាកម្រាលផែនដីក្តី ជាវាំងននក្តី ជាពូកក្តី ជាខ្នើយក្តី ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ១០ ចប់ ។

រតនវគ្គទី ៩ ចប់ ។

ឧទ្ទានរបស់វគ្គនោះ (មាន ១០ សិក្ខាបទ) គឺ

រាជសិក្ខាបទ ១ រតនសិក្ខាបទ ១

សន្តិសិក្ខាបទ ១ សូចិសិក្ខាបទ ១

មញ្ចសិក្ខាបទ ១ តូលិកសិក្ខាបទ ១

និសីទនសិក្ខាបទ ១ កណ្ឌុសិក្ខាបទ ១

វស្សិកសិក្ខាបទ ១ សុគតសិក្ខាបទ ១ ។

(៣៩៨) ឧទ្ទិដ្ឋា ខោ អាយស្មន្តោ ទ្វេនវុតិ បាចិត្តិយា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ឯវមេតំ ធារយាមីតិ ។

បាចិត្តិយកណ្ឌំ និដ្ឋិតំ ។





(៣៩៨) បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាចិត្តិយ ទាំង ៩២ ខ្ញុំបានសំដែងរួចហើយ ។ ខ្ញុំសូមសួរអស់លោកដ៏មានអាយុក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរអស់វារៈជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយ សុទ្ធតែជាអ្នកបរិសុទ្ធហើយ ក្នុងអាបត្តិទាំងនេះ ព្រោះហេតុនោះបានជាអស់លោកស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្ដីបរិសុទ្ធនេះ ដោយការស្ងៀមនៅយ៉ាងនេះឯង ។

បាចិត្តិយកណ្ឌ ចប់ ។

# បាដិទេសនីយកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ ចត្តារោ បាដិទេសនីយា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## បឋមសិក្ខាបទំ

[៣៩៩] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន អញ្ញតរា ភិក្ខុនី សាវត្ថិយំ បិណ្ឌាយ ចរិត្វា បដិក្កមនកាលេ អញ្ញតរំ ភិក្ខុំ បស្សិត្វា ឯតទវោច ហន្ទយ្យ ភិក្ខំ បដិគ្គណ្ហាហីតិ ។ សាធុ ភគិនីតិ សព្វេវ អគ្គហេសិ ។ សា ឧបកដ្ឋេ កាលេ នាសក្ខិ បិណ្ឌាយ ចរិតុំ ឆិន្នភត្តា អហោសិ ។ អថខោ សា ភិក្ខុនី ទុតិយម្បិ ទិវសំ ។បេ។ តតិយម្បិ ទិវសំ សាវត្ថិយំ បិណ្ឌាយ ចរិត្វា បដិក្កមនកាលេ តំ ភិក្ខុំ បស្សិត្វា ឯតទវោច ហន្ទយ្យ

# បាដិទេសនីយកណ្ឌ

បពិត្រលោកដ៏មានអាយុទាំងឡាយ បាដិទេសនីយធម៌ ៤ នេះ តែងមកកាន់ឧទ្ទេស ។

## សិក្ខាបទទី ១

(៣៩៩) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង មានភិក្ខុនី ១ រូប ត្រាច់ទៅបិណ្ឌបាត ក្នុងក្រុងសាវត្ថី កាលវិលត្រឡប់មកវិញ បានឃើញភិក្ខុ ១ រូប ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួលចង្ហាន់សិន ។ ភិក្ខុនោះតបថា នែនាង ប្រពៃហើយ ៗ ក៏ទទួលយកចង្ហាន់ទាំងអស់ ។ កាលវេលាជិត (ថ្ងៃត្រង់ហើយ) ភិក្ខុនីនោះមិនអាចនឹងដើរទៅបិណ្ឌបាតបានទេ ហើយក៏ដាច់ចង្ហាន់ ។ លុះគ្រាថ្ងៃក្រោយមក ភិក្ខុនីនោះទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី អស់ថ្ងៃជាគំរប់ពីរផងដែរ ។ល។ អស់ថ្ងៃជាគំរប់បីផងដែរ កាលវិលត្រឡប់មកវិញ ក៏បានឃើញភិក្ខុនោះទៀត ហើយបាននិយាយពាក្យនេះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់

កុមារិំ បដិច្ចក្ខាតំ ។ សុត្វា គហបតិ សព្វំ អត្តនោ សំ ។ សា ទុបរក្ខេ ការេ ទាសត្ថំ បិណ្ឌាយ ចរន្តិ ធម្មគត្តា អហោសិ ។ អថខោ សា កុមារី ចតុត្ថេ ទិវសេ រថិយាយ បវេឌ្ឍិ គច្ឆតិ ។ សេដ្ឋី គហបតិ គេហេ បដិបថំ អាគច្ឆន្តោ តំ កុមារី បស្សិត្វា អបេហិ យេ ហិ ។ សា ទុក្ខមត្ថិ ការេ បរិបតិ ។ សេដ្ឋី គហបតិ តំ កុមារិំ ខមាបេសិ ខមាហិ យេ អយ្យេ ។ ចាតិតាតិ ។ អាហ គហបតិ តយា បាតិតា អហំ អយាមេវ ទុព្វលាតិ ។ កិស្ស បន ត្វំ អយ្យេ ទុព្វលាតិ ។ អថខោ សា កុមារី សេដ្ឋិស្ស គហបតិស្ស បវត្តិំ អារោចេសិ ។ សេដ្ឋី គហបតិ តំ កុមារិំ ឃរំ នេត្វា ភោជេត្វា ទុដ្ឋាយតិ ទីយតិ វិហារេតិ គច់ ហិ ខាម កន្ទត្ត កុមារិយា ហត្ថតោ អាមំសំ បដិគ្គហេស្សតិ



ទទួលយកចង្ហាន់សិន ។ កុមារីនោះតបថា នែនាយ ប្រាកដហើយ ។ ក៏ទទួលយកចង្ហាន់តាមតែស ។ កាលនេះបើលោកមិត (ថ្ងៃក្រោយហើយ) កុមារីនោះក៏មិនអាចនឹងដើរទៅបិណ្ឌបាតបានឡើយ ក៏យកចង្ហាន់ ។ ល្មមប៉ុណ្ណោះ ព្រះនឹងហើយថ្ងៃ ៤ កុមារីនោះក៏ចេញដើរទៅតាមស្រុក ។ ដាននសេដ្ឋីគហបតីម្នាក់ កាលបរិភោគដល់ផ្លូវស្រែសព្វគ្រា ក៏បាននិយាយពាក្យនេះនឹងកុមារីនោះថា បពិត្រលោកម្ចាស់ លោកទូលចៀសចេញ ។ កុមារីនោះកាលចៀសចេញទៅក៏ដួលជក់ក្នុងទីនោះឯង ។ សេដ្ឋីគហបតីក៏បានឮពាក្យនៃកុមារីនោះឲ្យអត់ទោសថា បពិត្រលោកម្ចាស់ សូមលោកមេត្តាអត់ទោស (ឲ្យផង) លោកម្ចាស់ខ្ញុំបានធ្វើឲ្យដួលហើយ ។ កុមារីនោះតបថា នែគហបតី ខ្ញុំអត់ អ្នកឯងនឹងបានធ្វើឲ្យដួលក៏ទេ ខ្ញុំការ៉ាតាស្រែកាតកំលាំងដែលស្រេកតែ ។ សេដ្ឋីគហបតីសួរថា បពិត្រលោកម្ចាស់ ព្រោះហេតុអ្វីបានជាលោកមានកំលាំងខ្សោយ ។ ខណៈនោះកុមារីនោះ ក៏បានប្រាប់សេចក្តីទុក្ខដល់សេដ្ឋីគហបតី (ដោយសព្វគ្រប់) ។ សេដ្ឋីគហបតីក៏បានតាំងយកកុមារីនោះ ទៅឯផ្ទះឲ្យបាយឆ្អិនព្រះហើយក៏ពោលទោស ក៏នឹងលែង បន្ទូលប្រាប់ថា លោកម្ចាស់ចាំនឹកឃើញមិនគួរនឹងទទួលតាមជ័យនូវការចិញ្ចឹមកុមារីនោះ ឲ្យអាក្រក់ព្រោះតែលោក

កិច្ឆលាភោ មាតុគ្គាមោតិ ។ អស្សោសុំ ខោ ភិក្ខូ សេដ្ឋិស្ស គហបតិស្ស ឧជ្ឈាយន្តស្ស ខិយ្យន្តស្ស វិបាចេន្តស្ស ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ ភិក្ខុនិយា ហត្ថតោ អាមិសំ បដិគ្គហេស្សតីតិ ។បេ។ សច្ចំ កិរ ត្វំ ភិក្ខុ ភិក្ខុនិយា ហត្ថតោ អាមិសំ បដិគ្គហេសីតិ ។ សច្ចំ ភគវាតិ ។ ញាតិកា តេ ភិក្ខុ អញ្ញាតិកាតិ ។ អញ្ញាតិកា ភគវាតិ ។ អញ្ញាតកោ មោឃបុរិស អញ្ញាតិកាយ ន ជានាតិ បដិរូបំ វា អប្បដិរូបំ វា សន្តំ វា អសន្តំ វា តត្ថ នាម ត្វំ មោឃបុរិស អញ្ញាតិកាយ ភិក្ខុនិយា ហត្ថតោ អាមិសំ បដិគ្គហេស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យោ បន ភិក្ខុ អញ្ញាតិកាយ ភិក្ខុនិយា អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា



ដោយយាកក្រ ។ កាលដែលសេដ្ឋីគហបតី ពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ពួកភិក្ខុណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុមិនគួរនឹងទទួលយកអាមិសៈអំពីដៃភិក្ខុនីសោះ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ ឮថាអ្នកឯងនឹងទទួលយកអាមិសៈអំពីដៃភិក្ខុនី ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា នែភិក្ខុ ភិក្ខុនីនោះត្រូវជាញាតិរបស់អ្នកដែរ ឬមិនត្រូវជាញាតិទេ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ភិក្ខុនីនោះមិនត្រូវជាញាតិទេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នែមោឃបុរស បុគ្គលដែលមិនមែនជាញាតិ តែងមិនដឹងនូវអំពើសមគួរ ឬមិនសមគួរ អំពើល្អក្ដី ឬមិនល្អក្ដីរបស់ស្រីដែលមិនមែនជាញាតិឡើយ នែមោឃបុរស អ្នកឯងមិនគួរនឹងទទួលយកអាមិសៈអំពីដៃភិក្ខុនីដែលមិនមែនជាញាតិទេ នែមោឃបុរស អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុណាមួយទទួលយកខាទនីយៈ ឬភោជនីយៈ ដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលមិនមែនជាញាតិ ដែលចូលទៅកាន់ចន្លោះផ្ទះ

ភុញ្ជេយ្យ វា បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

(៤០០) យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ អញ្ញាតិកា នាម មាតិតោ វា បិតិតោ វា យាវ សត្តមា បិតាមហយុគា អសម្ពទ្ធា ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។ អន្តរឃរំ នាម រថិកា ព្យូហំ សិង្ឃាដកំ ឃរំ ។ ខាទនីយំ នាម បញ្ច ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។ អញ្ញាតិកាយ អញ្ញាតិកសញ្ញី អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទតិ វា

១ [illegible] ។



ហើយទំពាស៊ីក្ដី បរិភោគក្ដី ភិក្ខុនោះត្រូវសំដែងអាបត្តិបាដិទេសនីយៈថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិបាដិទេសនីយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀលហើយមិនជាទីសប្បាយ ខ្ញុំសូមសំដែងអាបត្តិនោះចេញ ។

(៤០០) ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចពាក្យក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ភិក្ខុនីដែលមិនបានជាប់ទាក់ទងនឹងគ្នា គឺពីចំណែកខាងមាតាឬបិតាជាប់រហូតដល់ខ្សែដូនជីតាទី ៧ ហៅថាមិនមែនជាញាតិ ។ ស្រីដែលបានឧបសម្បទាក្នុងសំណាក់សង្ឃទាំងពីរពួក ហៅថាភិក្ខុនី ។ ច្រកល្ហក (ស្ត) ច្រកកាត់ (ស្ត) ទីប្រជុំផ្លូវមានផ្លូវ ៤ ឬមានផ្លូវ ៣ (ស្ត) ផ្ទះរបស់គ្រហស្ថ (ស្ត) ហៅថាចន្លោះផ្ទះ ។ ដែលហៅថា ខាទនីយៈ គឺលើកលែងភោជនទាំង ៥ និងវត្ថុដែលជាយាមកាលិក សត្តាហកាលិក យាវជីវិកចេញ ក្រៅពីនោះហៅថា ខាទនីយៈទាំងអស់ ។ ដែលហៅថា ភោជនីយៈនោះ គឺភោជនមាន ៥ យ៉ាង គឺបាយ ១ នំកុម្មាស ១ សត្តុ ១ ត្រី ១ សាច់ ១ ។ ភិក្ខុទទួលយកខាទនីយៈឬភោជនីយៈ ដោយគំនិតថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈ គ្រប់ៗកំពូតដែលលេបចូលទៅ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុដឹងច្បាស់ថាមិនមែនជាញាតិ ហើយទទួលយកខាទនីយៈ ឬ ភោជនីយៈដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្លោះផ្ទះ យកមកទំពាស៊ីក្ដី

ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ អញ្ញាតិកាយ វេមតិកោ អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ អញ្ញាតិកាយ ញាតិកសញ្ញី អន្តរឃរំ បវិដ្ឋាយ ហត្ថតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ ឯកតោ ឧបសម្បន្នាយ ហត្ថតោ ខាទនីយំ ភោជនីយំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ អញ្ញាតិកសញ្ញី អាបត្តិ ទុក្កដស្ស ។ ញាតិកាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ ញាតិកាយ ញាតិកសញ្ញី អនាបត្តិ ។



បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុមានសេចក្តីសង្ស័យនឹងភិក្ខុនីដែលមិនមែនជាញាតិ ហើយទទួលយកខាទនីយៈឬភោជនីយៈដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្លោះផ្ទះ យកមកទំពាស៊ីក្តី បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុនីមិនមែនជាញាតិ ភិក្ខុសំគាល់ថាជាញាតិ ហើយទទួលយកខាទនីយៈឬភោជនីយៈ ដោយដៃរបស់ខ្លួន អំពីដៃភិក្ខុនីដែលចូលទៅកាន់ចន្លោះផ្ទះ យកមកទំពាស៊ីក្តី បរិភោគក្តី ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុទទួលយករបស់ដែលជាយាមកាលិក សត្តាហកាលិក និងរបស់ដែលជាយាវជីវិក ដើម្បីជាអាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗ ពំនះដែលលេបចូលទៅ ។ ភិក្ខុទទួលយកខាទនីយៈឬភោជនីយៈអំពីដៃភិក្ខុនី ដែលបានឧបសម្បទាក្នុងសំណាក់សង្ឃតែម្ខាង ដោយបំណងថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗ ពំនះដែលលេបចូលទៅ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាមិនមែនជាញាតិ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុនីជាញាតិ ភិក្ខុសំគាល់ថាជាញាតិ មិនត្រូវអាបត្តិឡើយ ។

[៤០១] អនាបត្តិ ញាតិកាយ ទាបេតិ ន ទេតិ ឧបនិក្ខិបិត្វា ទេតិ អន្តោអារាមេ ភិក្ខុនុបស្សយេ តិត្ថិយសេយ្យាយ បដិក្កមនេ គាមតោ នីហរិត្វា ទេតិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជាតិ ទេតិ សិក្ខមានាយ សាមណេរិយា ឧម្មត្តិកាយ អាទិកម្មិកាយាតិ ។

ចប់សិក្ខាបទំ ឆដ្ឋំ ។



[៤០១] ភិក្ខុនីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១១ យ៉ាង) គឺភិក្ខុនីជាញាតិ ១ ភិក្ខុនីមិនមែនជាញាតិឲ្យគេឲ្យនូវខាទនីយៈនិងភោជនីយៈ មិនបានឲ្យដោយខ្លួនឯង ១ ភិក្ខុនីមិនមែនជាញាតិ បានដាក់ចុះនូវខាទនីយៈ និងភោជនីយៈហើយឲ្យ ១ ភិក្ខុនីមិនមែនជាញាតិ បានឲ្យនូវខាទនីយៈនិងភោជនីយៈក្នុងលំនៅរបស់ភិក្ខុនីខាងក្នុងអារាម ១ ភិក្ខុនីមិនមែនជាញាតិ បានឲ្យនូវខាទនីយៈនិងភោជនីយៈក្នុងដំណេករបស់តិរ្ថិយ ១ ភិក្ខុនីមិនមែនជាញាតិ បាននាំយកនូវខាទនីយៈនិងភោជនីយៈអំពីស្រុក ហើយឲ្យក្នុងវេលាដែលត្រឡប់មកវិញ ១ ភិក្ខុនីបាននាំយករបស់ដែលជាយាមកាលិក សត្តាហកាលិក និងរបស់ដែលជាយាវជីវិក ឲ្យដោយពាក្យថា កាលបើហេតុមាន សូមលោកម្ចាស់និមន្តឆាន់ចុះ ១ ភិក្ខុនីឲ្យនូវខាទនីយៈនិងភោជនីយៈអំពីដៃរបស់សិក្ខមានា ១ ភិក្ខុនីឲ្យនូវខាទនីយៈនិងភោជនីយៈអំពីដៃសាមណេរី ១ ភិក្ខុនីឆ្កួត ១ ភិក្ខុនីដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៦ ចប់ ។

## ទុតិយសិក្ខាបទំ

[៤០៦] តេន សមយេន ពុទ្ធោ ភគវា រាជគហេ វិហរតិ វេឡុវនេ កលន្ទកនិវាបេ ។ តេន ខោ បន សមយេន ភិក្ខូ កុលេសុ និមន្តិតា ភុញ្ជន្តិ ។ ឆព្ពគ្គិយា ភិក្ខុនិយោ ឆព្ពគ្គិយានំ ភិក្ខូនំ វោសាសន្តិយោ ឋិតា ហោន្តិ ឥធ សូបំ ទេថ ឥធ ឱទនំ ទេថាតិ ។ ឆព្ពគ្គិយា ភិក្ខូ យាវទត្ថំ ភុញ្ជន្តិ ។ អញ្ញេ ភិក្ខូ ន ចិត្តរូបំ ភុញ្ជន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថញ្ហិ នាម ឆព្ពគ្គិយា ភិក្ខូ ភិក្ខុនិយោ វោសាសន្តិយោ ន និវារេស្សន្តីតិ ។បេ។ សច្ចំ កិរ ភិក្ខវេ ភិក្ខុនិយោ វោសាសន្តិយោ ន និវារេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថញ្ហិ នាម តុម្ហេ មោឃបុរិសា ភិក្ខុនិយោ វោសាសន្តិយោ ន និវារេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ

## សិក្ខាបទទី២

[៤០៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ គ្រានោះឯង មានពួកភិក្ខុ ដែលគេបាននិមន្តមកឆាន់ក្នុងត្រកូលទាំងឡាយ ។ ពួកឆព្វគ្គិយភិក្ខុនីទៅឈរបង្គាប់គេថា អ្នកទាំងឡាយចូរប្រគេនសម្លមកក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះដូច្នេះ ចំពោះឆព្វគ្គិយភិក្ខុទាំងឡាយ ។ ឯពួកឆព្វគ្គិយភិក្ខុបានឆាន់ឆ្អែតតាមសេចក្តីត្រូវការ ។ ពួកភិក្ខុឯទៀតក៏ឆាន់ខ្វះខាតមិនបានបរិបូណ៌ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនគួរនឹងមិនឃាត់ពួកភិក្ខុនីដែលជាអ្នកបង្គាប់គេសោះ ។បេ។ ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយមិនបានឃាត់ពួកភិក្ខុនីដែលកំពុងបង្គាប់គេ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគទ្រង់បន្ទោសថា នែមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងមិនឃាត់ពួកភិក្ខុនីដែលកំពុងបង្គាប់គេទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនមែននាំពួកជនដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លាឡើង ឬនាំពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ

ឧទ្ទិសេយ្យាថ ភិក្ខូ បនេវ កុលេសុ និមន្តិតា ភុញ្ជន្តិ ។ តត្រ ចេ[១] ភិក្ខុនី វោសាសមានរូបា ឋិតា ហោតិ ឥធ សូបំ ទេថ ឥធ ឱទនំ ទេថាតិ ។ តេហិ ភិក្ខូហិ សា ភិក្ខុនី អបសក្កតាវ ភគិនិ យាវ ភិក្ខូ ភុញ្ជន្តីតិ ។ ឯកស្សបិ[២] ភិក្ខុនោ ន បដិភាសេយ្យ តំ ភិក្ខុនឹ អបសក្កតាវ ភគិនិ យាវ ភិក្ខូ ភុញ្ជន្តីតិ បដិទេសេតព្វំ តេហិ ភិក្ខូហិ គារយ្ហំ អាវុសោ ធម្មំ អាបជ្ជិម្ហា អសប្បាយំ បាដិទេស-និយំ តំ បដិទេសេមាតិ ។

[៤០៣] ភិក្ខូ បនេវ កុលេសុ និមន្តិតា ភុញ្ជន្តីតិ កុលំ នាម ចត្តារិ កុលានិ ខត្តិយកុលំ ព្រាហ្មណ-កុលំ វេស្សកុលំ សុទ្ទកុលំ ។ និមន្តិតា ភុញ្ជន្តីតិ បញ្ចន្នំ ភោជនានំ អញ្ញតរេន ភោជនេន និមន្តិតា ភុញ្ជន្តិ ។ ភិក្ខុនី នាម ឧភតោសង្ឃេ ឧបសម្បន្នា ។

១ ចេសាតិ ភក្ខុនី ហេដ្ឋា ទិស្សតិ ។ ២ ម. ឯកស្សបិ ចេ ។



អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុទាំងឡាយដែលគេបាននិមន្តហើយ ឆាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ ។ បើមានភិក្ខុនីមកឈរបង្គាប់គេក្នុងទីនោះថា អ្នកទាំងឡាយចូរប្រគេនសម្លក្នុងទីនេះ អ្នកទាំងឡាយចូរប្រគេនបាយមកក្នុងទីនេះ ។ ភិក្ខុទាំងនោះត្រូវបណ្ដេញភិក្ខុនីនោះថា នែនាង ចូរថយចេញទៅសិន ទម្រាំតែភិក្ខុឆាន់រួចស្រេច ។ ភិក្ខុសូម្បីមួយរូបបើមិនបានពោលបណ្ដេញភិក្ខុនីនោះដោយពាក្យថា នែនាង ចូរថយចេញទៅ ទម្រាំតែភិក្ខុទាំងឡាយឆាន់រួចស្រេច ដូច្នេះទេ ភិក្ខុទាំងនោះត្រូវសំដែងដោយពាក្យថា ម្នាលអាវុសោ យើងត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយៈដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល មិនជាទីសប្បាយចិត្ត ឥឡូវយើងសូមសំដែងអាបត្តិនោះចេញ ។

[៤០៣] ពាក្យថា ភិក្ខុទាំងឡាយដែលគេបាននិមន្តឆាន់ក្នុងសំណាក់របស់ត្រកូលទាំងឡាយ សេចក្ដីថា ដែលហៅថា ត្រកូល បានដល់ត្រកូល ៤ ពួក គឺត្រកូលក្សត្រ ១ ត្រកូលព្រាហ្មណ៍ ១ ត្រកូលឈ្មួញ ១ ត្រកូលអ្នកស្រែ ១ ។ ពាក្យថា ដែលគេនិមន្តហើយ គឺភិក្ខុដែលពួកគេបាននិមន្តដោយភោជនទាំង ៥ ភោជនណាមួយ ។ ដែលហៅថា ភិក្ខុនី គឺស្រីដែលបានឧបសម្បទា ក្នុងសំណាក់សង្ឃទាំងពីរពួក ។

វោសាសន្តី នាម យថាមិត្តតា យថាសន្ទិដ្ឋតា យថា-
សម្ភត្តតា យថាសមានុបជ្ឈាយកតា យថាសមានា-
ចរិយកតា ឥធ សូបំ ទេថ ឥធ ឱទនំ ទេថាតិ
ឯសា វោសាសន្តី នាម ។ តេហិ ភិក្ខូហីតិ ភុញ្ជមា-
នេហិ ភិក្ខូហិ ។ សា ភិក្ខុនីតិ យា សា វោសាសន្តី
ភិក្ខុនី ។ តេហិ ភិក្ខូហិ សា ភិក្ខុនី អបសាទេតព្វា
អបសក្ក តាវ ភគិនិ យាវ ភិក្ខូ ភុញ្ជន្តីតិ ។ ឯកស្សបិ
ចេ ភិក្ខុនោ អនបសាទិតោ[១] គហេស្សាមិ ភុញ្ជិស្សាមីតិ
បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោ-
ហារេ អាបត្តិ បាដិទេសនីយស្ស ។

(៤០៤) ឧបសម្បន្នាយ ឧបសម្បន្នសញ្ញី វោសា-
សន្តិយា ន និវារេតិ អាបត្តិ បាដិទេសនីយស្ស ។
ឧបសម្បន្នាយ វេមតិកោ វោសាសន្តិយា ន និវារេតិ
អាបត្តិ បាដិទេសនីយស្ស ។ ឧបសម្បន្នាយ អនុប-
សម្បន្នសញ្ញី វោសាសន្តិយា ន និវារេតិ អាបត្តិ

---

១ អនបសាទិតោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ អនបសាទិតោ [illegible]
អត្ថតោ ឯកំ ។



ដែលហៅថា បង្គាប់ គឺភិក្ខុនីណា ពោលថា អ្នកទាំងឡាយ ចូរប្រគេនសម្លមក
ក្នុងទីនេះ អ្នកទាំងឡាយ ចូរប្រគេនបាយមកក្នុងទីនេះ តាមសមគួរដល់កិច្ច
ដែលជាមិត្ត កិច្ចដែលធ្លាប់ស្គាល់ កិច្ចដែលធ្លាប់ស្និទ្ធស្នាល កិច្ចដែល
មានឧបជ្ឈាយ៍ស្មើគ្នា កិច្ចដែលមានអាចារ្យស្មើគ្នា កិច្ចនេះហៅថាជាអ្នក
បង្គាប់ ។ ពាក្យថា ភិក្ខុទាំងនោះ គឺពួកភិក្ខុដែលកំពុងឆាន់ (នោះឯង) ។
ពាក្យថា ភិក្ខុនីនោះ គឺភិក្ខុនីដែលកំពុងបង្គាប់នោះឯង ។ ភិក្ខុទាំងនោះ
ត្រូវបណ្ដេញភិក្ខុនីនោះដោយពាក្យថា នែនាង ចូរថយចេញទៅសិន
ទម្រាំតែពួកភិក្ខុឆាន់រួចសព្វគ្រប់ ។ ភិក្ខុសូម្បី១រូប បើមិនបានបណ្ដេញ
ភិក្ខុនីទេ ហើយទទួលយកដោយគិតថា អាត្មាអញនឹងទទួលយក នឹងឆាន់
ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗ ពំនូតដែលលេប
ចូលទៅ ។

(៤០៤) ឧបសម្បន្នា(១)កំពុងបង្គាប់ ភិក្ខុក៏សំគាល់ថាឧបសម្បន្នា
មែន តែមិនបានពោលហាម ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុមាន
សេចក្ដីសង្ស័យក្នុងឧបសម្បន្នាកំពុងបង្គាប់ ហើយមិនបានពោលហាម
ត្រូវអាបត្តិបាដិទេសនីយៈ ។ ឧបសម្បន្នាកំពុងបង្គាប់ ភិក្ខុមានសេចក្ដី
សំគាល់ថាអនុបសម្បន្នាទៅវិញ ហើយមិនបានពោលហាម ត្រូវអាបត្តិ

---

១ ប្រែតែលោកឧបសម្បន្នក្នុងចំណោមសង្ឃ ដែលហៅថា ភិក្ខុនីនោះឯង ។

បាដិទេសនីយស្ស ។ ឯកតោ ឧបសម្បន្នាយ វោសាសន្តិយា ន និវារេតិ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ ឧបសម្បន្នសញ្ញី អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អនុបសម្បន្នាយ អនុបសម្បន្នសញ្ញី អនាបត្តិ ។

(៤០៥) អនាបត្តិ អត្តនោ ភត្តំ ទាបេតិ ន ទេតិ អញ្ញេសំ[១] ភត្តំ ទេតិ ន ទាបេតិ យំ ន ទិន្នំ តំ ទាបេតិ យត្ថ ន ទិន្នំ តត្ថ ទាបេតិ សព្វេសំ សមកំ ទាបេតិ សិក្ខមានា វោសាសតិ សាមណេរី វោសាសតិ បញ្ច ភោជនានិ ឋបេត្វា សព្វត្ថ អនាបត្តិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ទុតិយសិក្ខាបទំ និដ្ឋិតំ ។

១ អញ្ញស្សាបិ [illegible] ។



បាដិទេសនីយៈ ។ ស្រីដែលបានឧបសម្បទាក្នុងសំណាក់ភិក្ខុនីសង្ឃតែម្ខាង កំពុងតែពោលបង្គាប់ ភិក្ខុមិនបានពោលហាម ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាឧបសម្បន្នវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងអនុបសម្បន្ន ត្រូវអាបត្តិទុក្កដ ។ អនុបសម្បន្ន ភិក្ខុសំគាល់ថាអនុបសម្បន្នមែន មិនត្រូវអាបត្តិឡើយ ។

(៤០៥) វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១០ យ៉ាង) ភិក្ខុនីបង្គាប់តាមគេឲ្យប្រគេនភត្តរបស់ខ្លួន មិនប្រគេនដោយខ្លួនឯង ១ ភិក្ខុនីប្រគេនភត្តរបស់ភិក្ខុដទៃ មិនបានប្រើអ្នកដទៃឲ្យប្រគេន ១ ភត្តណាដែលតាមគេមិនទាន់ប្រគេន ភិក្ខុនីក៏បង្គាប់គេឲ្យប្រគេនភត្តនោះ ១ តាមគេមិនទាន់ប្រគេនក្នុងទីណា ភិក្ខុនីបង្គាប់គេឲ្យប្រគេនក្នុងទីនោះ ១ ភិក្ខុនីបង្គាប់គេឲ្យប្រគេនភត្តដ៏ស្មើគ្នាដល់ពួកភិក្ខុទាំងពួង ១ សិក្ខមានាពោលបង្គាប់ ១ សាមណេរីពោលបង្គាប់ ១ អាបត្តិមិនមានដល់ភិក្ខុ ព្រោះភោជនទាំងឡាយក្រៅពីភោជន ៥ យ៉ាងចេញ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ២ ចប់ ។

# តតិយសិក្ខាបទំ

[៤១៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន សាវត្ថិយំ អញ្ញតរំ កុលំ ឧភតោ បសន្នំ ហោតិ សទ្ធាយ វឌ្ឍតិ ភោគេន ហាយតិ ។ យំ តស្មិំ កុលេ ឧប្បជ្ជតិ បុរេខាទនីយំ វា ភោជនីយំ វា តំ សព្វំ ភិក្ខូនំ វិស្សជ្ជេត្វា អប្បេកទា អនសិតា អច្ឆន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ន មត្តំ ជានិត្វា បដិគ្គហេស្សន្តិ ឥមេ ឥមេសំ ទត្វា អប្បេកទា អនសិតា អច្ឆន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មិំ និទានេ ឯតស្មិំ បករណេ ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ យំ កុលំ

# សិក្ខាបទទី ៣

[៤១៦] សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង ក្នុងក្រុងសាវត្ថីមានត្រកូល ១ មានសេចក្តីជ្រះថ្លាទាំងពីរខាង(១) (ប្តីប្រពន្ធ) ចម្រើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ ។ ខាទនីយៈឬភោជនីយៈណា ដែលកើតឡើងក្នុងត្រកូលនោះក្នុងវេលាមុនភត្ត ជនទាំងនោះជួនកាលអត់បរិភោគខ្លួនឯង ព្រោះតែឲ្យនូវខាទនីយៈឬភោជនីយៈទាំងអស់នោះប្រគេនដល់ភិក្ខុទាំងឡាយ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តមិនត្រូវនឹងមិនស្គាល់ប្រមាណហើយទទួលយកសោះ ជនទាំងឡាយនេះបានប្រគេនឲ្យទានខាទនីយៈ និងភោជនីយៈដល់ភិក្ខុទាំងនេះ ហើយជួនកាលអត់បរិភោគខ្លួនឯង ។ កាលពួកមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។ វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាក្នុងគ្រានោះ ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ត្រកូល

---

១ អដ្ឋកថា ថាឮថាក្នុងត្រកូលនោះមានជនតែពីរនាក់ជាអ្នកដល់នូវសោតាបត្តិផល ។

សទ្ធាយ វឌ្ឍតិ ភោគេន ហាយតិ ឯវរូបស្ស កុលស្ស ញត្តិទុតិយេន កម្មេន សេក្ខសម្មតិំ ទាតុំ ។ ឯវញ្ច បន ភិក្ខវេ ទាតព្វា ។ ព្យត្តេន ភិក្ខុនា បដិពលេន សង្ឃោ ញាបេតព្វោ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមំ កុលំ សទ្ធាយ វឌ្ឍតិ ភោគេន ហាយតិ ។ យទិ សង្ឃស្ស បត្តកល្លំ សង្ឃោ ឥត្ថន្នាមស្ស កុលស្ស សេក្ខសម្មតិំ ទទេយ្យ ។ ឯសា ញត្តិ ។ សុណាតុ មេ ភន្តេ សង្ឃោ ឥត្ថន្នាមំ កុលំ សទ្ធាយ វឌ្ឍតិ ភោគេន ហាយតិ ។ សង្ឃោ ឥត្ថន្នាមស្ស កុលស្ស សេក្ខសម្មតិំ ទេតិ ។ យស្សាយស្មតោ ខមតិ ឥត្ថន្នាមស្ស កុលស្ស សេក្ខសម្មតិយា ទានំ សោ តុណ្ហស្ស យស្ស នក្ខមតិ សោ ភាសេយ្យ ។ ទិន្នា សង្ឃេន ឥត្ថន្នាមស្ស កុលស្ស សេក្ខសម្មតិ ។ ខមតិ សង្ឃស្ស តស្មា



ណាដែលចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ តថាគត អនុញ្ញាតដើម្បីឲ្យនូវសេក្ខសម្មតិ និងសម្មតិត្រកូលនោះជាសេក្ខត្រកូល ដោយកម្មមានញត្តិជាគំរប់ពីរ ចំពោះត្រកូលបែបនេះចុះ ម្នាលភិក្ខុទាំងឡាយ (សេក្ខសម្មតិ) សង្ឃត្រូវឲ្យយ៉ាងនេះ ។ ភិក្ខុ ១ រូបដែលជាអ្នកឈ្លាសប្រតិពលត្រូវផ្តៀងសង្ឃឲ្យដឹងថា បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃសូមស្តាប់នូវពាក្យខ្ញុំ (ស៊ូក) ត្រកូលឈ្មោះនេះចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ ។ បើកម្មមានកាលដ៏សមគួរដល់សង្ឃហើយ សង្ឃគប្បីឲ្យនូវសេក្ខសម្មតិដល់ត្រកូលឈ្មោះនេះចុះ ។ នេះជាញត្តិផ្តៀងសង្ឃឲ្យដឹង ។ បពិត្រព្រះសង្ឃដ៏ចំរើន ព្រះសង្ឃសូមស្តាប់នូវពាក្យខ្ញុំ (ស៊ូក) ត្រកូលមានឈ្មោះនេះចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យ ។ ឥឡូវសង្ឃឲ្យនូវសេក្ខសម្មតិដល់ត្រកូលឈ្មោះនេះ ។ ការឲ្យនូវសេក្ខសម្មតិដល់ត្រកូលឈ្មោះនេះ បើសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះត្រូវស្ងៀម បើមិនសមគួរដល់លោកដ៏មានអាយុអង្គណា លោកដ៏មានអាយុអង្គនោះគប្បីពោលឡើង ។ សេក្ខសម្មតិសង្ឃបានឲ្យដល់ត្រកូលមានឈ្មោះនេះរួចស្រេចហើយ ។ ការឲ្យសេក្ខសម្មតិសមគួរដល់សង្ឃហើយ ព្រោះហេតុនោះ

តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ សេក្ខសម្មតានិ កុលានិ យោ បន ភិក្ខុ តថារូបេសុ សេក្ខសម្មតេសុ កុលេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

(៤០៧) តេន ខោ បន សមយេន សាវត្ថិយំ ឧស្សវោ ហោតិ ។ មនុស្សា ភិក្ខូ និមន្តេត្វា ភោជេន្តិ ។ តម្បិ ខោ កុលំ ភិក្ខូ និមន្តេសិ ។ ភិក្ខូ កុក្កុច្ចាយន្តា នាធិវាសេន្តិ បដិក្ខិត្តំ ភគវតា សេក្ខសម្មតេសុ កុលេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទិតុំ ភុញ្ជិតុន្តិ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កិន្នុ ខោ នាម អម្ហាកំ ជីវិតេន យំ



បានជាសង្ឃស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះ ត្រង់ហេតុដែលស្ងៀមនៅយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ពួកត្រកូលណាមួយដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ ភិក្ខុណាមួយទទួលយកខាទនីយៈក្ដី ភោជនីយៈក្ដី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានឲ្យសេក្ខសម្មតិបែបនោះ ហើយទំពាស៊ីក្ដី ឆាន់ក្ដី ភិក្ខុនោះត្រូវសំដែងថា ម្នាលអាវុសោ ខ្ញុំត្រូវអាបត្តិឈ្មោះបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងនូវអាបត្តិនោះចេញ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ពួកភិក្ខុយ៉ាងនេះ ។

(៤០៧) សម័យនោះឯង មហោស្រព (ល្បែង) នៅក្រុងសាវត្ថី ។ ពួកមនុស្សគេបាននិមន្តភិក្ខុទាំងឡាយឲ្យឆាន់ ។ ចំណែកខាងត្រកូលនោះឯង ក៏បាននិមន្តភិក្ខុទាំងឡាយឲ្យ (ឆាន់ចង្ហាន់) ។ ភិក្ខុទាំងឡាយនឹករង្កៀសមិនហ៊ានទទួលនិមន្ត ព្រោះតែថា ការដែលទទួលយកខាទនីយៈក្ដី ភោជនីយៈក្ដី ដោយដៃរបស់ខ្លួន អំពីពួកត្រកូលដែលសង្ឃបានសន្មតថាសេក្ខហើយ (យកមក) ទំពាស៊ី ឬឆាន់ ព្រះដ៏មានព្រះភាគហាមហើយ ។ មនុស្សទាំងឡាយនោះតែងពោលទោស តិះដៀល បន្តុះបង្អាប់ថា យើងនឹងរស់នៅប្រយោជន៍អ្វី ព្រោះលោកម្ចាស់

អយ្យា អម្ហាកំ ន បដិគ្គណ្ហន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ និមន្តិតេន សេក្ខសម្មតេសុ កុលេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទិតុំ ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ សេក្ខសម្មតានិ កុលានិ យោ បន ភិក្ខុ តថារូបេសុ សេក្ខសម្មតេសុ កុលេសុ បុព្វេ អនិមន្តិតោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។



ទាំងឡាយ មិនហ៊ានទទួលយកខាទនីយៈភោជនីយៈរបស់យើង កាល មនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ពួកភិក្ខុបានឮច្បាស់ ។ លំដាប់នោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុដែលមានគេនិមន្ត ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន ក្នុងពួកត្រកូល ដែលសង្ឃបានសន្មតជាជាសេក្ខត្រកូលហើយ (យកមក) ទំពាស៊ី ឬបរិភោគបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ពួកត្រកូលណាមួយ ដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ ភិក្ខុណាមួយឥតមានគេនិមន្តក្នុងកាលមុន ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន ក្នុងពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូល មានសភាពបែបនោះហើយ (យកមក) ទំពាស៊ីក្តី បរិភោគក្តី ភិក្ខុនោះត្រូវសំដែងថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិបាដិទេសនីយៈ មិនគួរសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងនូវអាបត្តិនោះចេញ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ភិក្ខុទាំងឡាយយ៉ាងនេះ ។

(៤១៨) តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ តស្ស កុលស្ស កុលុបកោ ហោតិ ។ អថ ខោ សោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន តំ កុលំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថ ខោ សោ ភិក្ខុ គិលានោ ហោតិ ។ អថ ខោ តេ មនុស្សា តំ ភិក្ខុំ ឯតទវោចុំ ភុញ្ជថ ភន្តេតិ ។ អថ ខោ សោ ភិក្ខុ ភគវតា បដិក្ខិត្តំ អនិមន្តិតេន សេក្ខសម្មតេសុ កុលេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទិតុំ ភុញ្ជិតុន្តិ កុក្កុច្ចាយន្តោ ន បដិគ្គហេសិ នាសក្ខិ បិណ្ឌាយ ចរិតុំ ឆិន្នភត្តោ អហោសិ ។ អថ ខោ សោ ភិក្ខុ អារាមំ គន្ត្វា ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថ ខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា សេក្ខសម្មតេសុ កុលេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា



(៤០៨) សម័យនោះឯង មានភិក្ខុ ១ រូប ជាទីគុនរបស់ត្រកូលនោះ ៗ លំដាប់នោះ គ្រាវេលាព្រឹកព្រហាម ភិក្ខុនោះស្លៀកស្បង់ហើយប្រដាប់ដោយបាត្រនិងចីវរ ដើរចូលទៅកាន់ត្រកូលនោះ លុះចូលទៅហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ វេលានោះ ភិក្ខុនោះជួនជាមានជំងឺ ។ គ្រានោះ មនុស្សទាំងឡាយក៏បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ដ៏ចំរើន សូមលោកម្ចាស់និមន្តឆាន់ចុះ ។ វេលានោះ ភិក្ខុនោះនឹករង្កៀសថា ភិក្ខុដែលគេមិនបាននិមន្តហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន ក្នុងពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ (យកមក) ទំពាស៊ីឬឆាន់ ព្រះដ៏មានព្រះភាគហាមហើយ បានជាមិនហ៊ានទទួល ហើយមិនអាចដើម្បីដើរទៅបិណ្ឌបាតបាន ក៏អត់បាយ ។ វេលានោះ ភិក្ខុនោះត្រឡប់ទៅវត្តវិញ បានដំណាលប្រាប់រឿងនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជំងឺទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន ក្នុងពួកត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខត្រកូលហើយ (យកមក)

ធាតិន្ទំ កុក្កុច្ចំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ សេក្ខសម្មតានិ កុលានិ យោ បន ភិក្ខុ តថារូបេសុ សេក្ខសម្មតេសុ កុលេសុ បុព្វេ អនិមន្តិតោ អគិលានោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

[៤០៨] យានិ ខោ បន តានិ សេក្ខសម្មតានិ កុលានីតិ សេក្ខសម្មតំ នាម យំ កុលំ សទ្ធាយ វឌ្ឍតិ ភោគេន ហាយតិ ឯវរូបស្ស កុលស្ស ញត្តិទុតិយេន កម្មេន សេក្ខសម្មតិ ទិន្នា ហោតិ ។ យោ បនាតិ យោ យាទិសោ ។ បេ ។ ភិក្ខូតិ ។ បេ ។ អយំ ឥមស្មឹ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ តថារូបេសុ សេក្ខសម្មតេសុ កុលេសូតិ ឯវរូបេសុ សេក្ខសម្មតេសុ កុលេសុ ។ អនិមន្តិតោ នាម អជ្ជតនាយ វា ស្វាតនាយ វា ក



ទំពាស៊ី ឬបរិភោគបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ត្រកូលណាមួយដែលសង្ឃបានសន្មតជាសេក្ខត្រកូលហើយ ភិក្ខុណាមួយឥតមានគេនិមន្តពីកាលមុន ហើយឥតមានជម្ងឺ បានទទួលយកខាទនីយៈក្ដី ភោជនីយៈក្ដី ដោយដៃរបស់ខ្លួន ក្នុងត្រកូលដែលសង្ឃបានសន្មតជាសេក្ខត្រកូលបែបនោះហើយ (យកមក) ទំពាស៊ី ឬបរិភោគ ភិក្ខុនោះត្រូវសំដែងថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិជាបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងអាបត្តិនោះបាន ។

[៤០៨] ពាក្យថា ត្រកូលណាមួយដែលសង្ឃបានសន្មតជាសេក្ខត្រកូលហើយ សេចក្ដីថា ត្រកូលណាដែលចំរើនដោយសទ្ធា តែសាបសូន្យចាកទ្រព្យសម្បត្តិ សង្ឃបានឲ្យសេក្ខសម្មតិដោយញត្តិទុតិយកម្មវាចា ដល់ត្រកូលបែបនេះ (ត្រកូលនោះ) ឈ្មោះថាសង្ឃបានសន្មតជាសេក្ខត្រកូល ។ ពាក្យថា ភិក្ខុណាមួយ មានសេចក្ដីដូចគ្នានឹងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ក្នុងត្រកូលដែលសង្ឃបានសន្មតជាសេក្ខត្រកូលបែបនោះ គឺក្នុងត្រកូលដែលសង្ឃបានសន្មតជាសេក្ខត្រកូល មានសភាពយ៉ាងនោះ ។ ដែលហៅថា ឥតគេនិមន្ត គឺឥតគេនិមន្តដើម្បីបានទទួលនូវថ្ងៃនេះ ឬនិមន្តដើម្បីទទួលនូវថ្ងៃស្អែក ដោយ

អនិមន្តិតោ ឃរូបចារំ ឱក្កមន្តំ និមន្តេតិ ឯសោ អនិមន្តិតោ នាម ។ និមន្តិតោ នាម អជ្ជតនាយ វា ស្វាតនាយ វា និមន្តិតោ ឃរូបចារំ អនោក្កមន្តំ និមន្តេតិ ឯសោ និមន្តិតោ នាម ។ អគិលានោ នាម សក្កោតិ បិណ្ឌាយ ចរិតុំ ។ គិលានោ នាម ន សក្កោតិ បិណ្ឌាយ ចរិតុំ ។ ខាទនីយំ នាម បញ្ច ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ អនិមន្តិតោ អគិលានោ ខាទនីយំ វា ភោជនីយំ វា ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

[៦១៥] សេក្ខសម្មតេ សេក្ខសម្មតសញ្ញី អនិមន្តិតោ អគិលានោ ខាទនីយំ វា ភោជនីយំ វា សហត្ថា



ភិក្ខុដើរទៅកាន់ឧបចារផ្ទះ ទើបមានពួកជននិមន្ត ភិក្ខុនេះហៅថា ឥតមានគេនិមន្តទេ ។ ដែលហៅថា មានគេនិមន្ត គឺមានគេនិមន្តដើម្បីឆាន់ក្នុងថ្ងៃនេះ ឬដើម្បីឆាន់ក្នុងថ្ងៃស្អែក កាលភិក្ខុមិនទាន់ចូលដើរទៅកាន់ឧបចារផ្ទះនៅឡើយ ស្រាប់តែមានពួកជននិមន្ត ភិក្ខុនេះហៅថាមានគេនិមន្ត ។ ភិក្ខុណាដែលអាច ដើម្បីនឹងដើរទៅបិណ្ឌបាតបាន ភិក្ខុនោះហៅថាមិនមានជម្ងឺ ។ ភិក្ខុណាដែលមិនអាចនឹងដើរទៅបិណ្ឌបាតបានទេ ភិក្ខុនោះហៅថាមានជម្ងឺ ។ ដែលហៅថា ខាទនីយៈ គឺវៀរលែងនៃភោជន ៥ យ៉ាង នឹងរបស់ជាយាមកាលិក សត្តាហកាលិក នឹងរបស់ជាយាវជីវិកចេញ ក្រៅពីនោះហៅថាខាទនីយៈទាំងអស់ ។ ដែលហៅថា ភោជនីយៈ បានដល់ភោជន ៥ យ៉ាង គឺបាយ ១ នំស្រូស ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ភិក្ខុឥតមានគេនិមន្ត ឥតមានជម្ងឺទទួលយកខាទនីយៈឬភោជនីយៈដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងឆាន់ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ៗ ពំនូតដែលលេបចូលទៅ ។

(៦១៥) ត្រកូលដែលសង្ឃសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថា ត្រកូលសង្ឃបានសន្មតថាជាសេក្ខៈមែន ឥតមានគេនិមន្ត ឥតមានជម្ងឺ ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន (យកមក)

បដិគ្គហេត្វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ សេក្ខសម្មតេ វេមតិកោ អនិមន្តិតោ អគិលានោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ សេក្ខសម្មតេ អសេក្ខសម្មតសញ្ញី អនិមន្តិតោ អគិលានោ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ អសេក្ខសម្មតេ សេក្ខសម្មតសញ្ញី អាបត្តិ ទុក្កដស្ស ។ អសេក្ខសម្មតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ អសេក្ខសម្មតេ អសេក្ខសម្មតសញ្ញី អនាបត្តិ ។



ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុសង្ស័យក្នុងត្រកូលដែលសង្ឃបានសន្មតថាជាសេក្ខៈ ឥតមានគេនិមន្ត ឥតមានជម្ងឺ ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន (យកមក) ទំពាស៊ីឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ ។ ត្រកូលដែលសង្ឃសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថាត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈ ឥតមានគេនិមន្ត ឥតមានជម្ងឺ ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួន (យកមក) ទំពាស៊ី ឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុទទួលយករបស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិក ដើម្បីប្រយោជន៍ដល់អាហារ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗ ពំនូតដែលលេបចូលទៅ ។ ត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថាត្រកូលសង្ឃបានសន្មតថាជាសេក្ខៈវិញ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុមានសេចក្តីសង្ស័យក្នុងត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈ ត្រូវអាបត្តិទុក្កដ ។ ត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈ ភិក្ខុសំគាល់ថាត្រកូលដែលសង្ឃមិនបានសន្មតថាជាសេក្ខៈវិញ មិនត្រូវអាបត្តិឡើយ ។

[៤១១] អនាបត្តិ និមន្តិតស្ស គិលានស្ស និមន្តិ-តស្ស វា គិលានស្ស វា សេសកំ ភុញ្ជតិ អញ្ញេសំ ភិក្ខា តត្ថ បញ្ញត្តា ហោតិ ឃរតោ នីហរិត្វា ទេន្តិ និច្ចភត្តេ សលាកភត្តេ បក្ខិកេ ឧបោសថិកេ បាដិប-ទិកេ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិ-កស្សាតិ ។

តតិយសិក្ខាបទំ និដ្ឋិតំ ។



[៤១១] ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១៣ យ៉ាង) គឺភិក្ខុមានគេនិមន្ត ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឆាន់របស់ដែលសល់អំពីភិក្ខុដែលគេបាននិមន្ត ឬរបស់ដែលសល់អំពីភិក្ខុមានជម្ងឺ ១ ចង្ហាន់ដែលគេបានតាក់តែងទុកក្នុងទីនោះចំពោះពួកភិក្ខុដទៃ ១ ពួកជនបាននាំយកខាទនីយៈ ឬភោជនីយៈមកពីផ្ទះហើយប្រគេន ១ ភិក្ខុទទួលបាននិច្ចភត្ត ១ សលាកភត្ត ១ បក្ខិកភត្ត ១ ឧបោសថិកភត្ត ១ បាដិបទិកភត្ត ១ ជនបានប្រគេននូវរបស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិក ដោយហេតុជាកាលបើមានហេតុ និមន្តលោកម្ចាស់ឆាន់ចុះ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សិក្ខាបទទី ៣ ចប់ ។

## ឆដ្ឋសិក្ខាបទំ

[៤០៦] តេន សមយេន ពុទ្ធោ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ តេន ខោ បន សមយេន សាកិយទាសកា អវរុទ្ធា ហោន្តិ ។ សាកិយានិយោ ឥច្ឆន្តិ អារញ្ញកេសុ សេនាសនេសុ ភត្តំ កាតុំ ។ អស្សោសុំ ខោ សាកិយទាសកា សាកិយានិយោ កិរ អារញ្ញកេសុ សេនាសនេសុ ភត្តំ កត្តុកាមាតិ ។ តេ មគ្គេ បរិយុដ្ឋឹសុ ។ សាកិយានិយោ បណីតំ ខាទនីយំ ភោជនីយំ(១) អាទាយ អារញ្ញកំ សេនាសនំ អគមំសុ ។ សាកិយទាសកា និក្ខមិត្វា សាកិយានិយោ អច្ឆិន្ទឹសុ ច ទូសេសុញ្ច ។ សាកិយា និក្ខមិត្វា តេ ចោរេ សភណ្ឌេ គហេត្វា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថញ្ហិ នាម ភទន្តា អារាមេ ចោរេ បដិវសន្តេ នារោចេស្សន្តីតិ ។ អស្សោសុំ ខោ ភិក្ខូ សាកិយានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។

១ ខាទនីយំ វា ភោជនីយំ វាតិ បោត្ថកេ ទិស្សតិ ។

## សិក្ខាបទទី ៦

[៤០៦] សម័យនោះ ព្រះពុទ្ធមានព្រះភាគ កាលគង់នៅក្នុងនិគ្រោធារាម ទៀបក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះឯង មានពួកទាសៈរបស់សាកិយជន ជាមនុស្សខូចកាច ។ ពួកស្រីសាកិយៈប្រាថ្នាធ្វើម្ហូបចំណីថ្វាយភត្ត (ប្រគេនពួកភិក្ខុដែលនៅ) ក្នុងទីសេនាសនៈដែលតាំងនៅក្នុងព្រៃ ។ ពួកទាសៈរបស់សាកិយជនបានឮដំណឹងថា អម្បាលនេះ ពួកស្រីសាកិយៈមានសេចក្តីប្រាថ្នាដើម្បីនឹងធ្វើថ្វាយភត្ត (ប្រគេនពួកភិក្ខុដែលនៅ) ក្នុងទីសេនាសនៈដែលតាំងនៅក្នុងព្រៃ ។ ពួកទាសៈទាំងនោះនាំគ្នាទៅចូលសម្ងំចាំស្ទាក់ផ្លូវ ។ (លុះ) ពួកស្រីសាកិយៈនាំយកខាទនីយៈនិងភោជនីយៈដ៏ឧត្តមចេញទៅកាន់ទីសេនាសនៈដែលតាំងក្នុងព្រៃ ឯពួកទាសៈរបស់សាកិយជន ក៏ស្ទុះចេញទៅប្លន់ពួកស្រីសាកិយៈ ហើយប្រទូស្តផងទៀតផង ។ ពួកសាកិយជនក៏បានចេញទៅចាប់ពួកចោរទាំងនោះព្រមទាំងភស្តុតាង ហើយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា កាលពួកចោរនៅនាំគ្នានៅក្នុងវត្ត លោកម្ចាស់ទាំងឡាយមិនគួរនឹងមិនប្រាប់ (យើងខ្ញុំដឹងផងសោះ) ។ កាលពួកសាកិយជនពោលទោស តិះដៀល បន្តុះបង្អាប់ ភិក្ខុទាំងឡាយក៏បានឮច្បាស់ ។

អថខោ តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ តេនហិ ភិក្ខវេ ភិក្ខូនំ សិក្ខាបទំ បញ្ញាបេស្សាមិ ទស អត្ថវសេ បដិច្ច សង្ឃសុដ្ឋុតាយ ។ បេ ។ សទ្ធម្មដ្ឋិតិយា វិនយានុគ្គហាយ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានិ សាសង្ក-សម្មតានិ សប្បដិភយានិ យោ បន ភិក្ខុ តថារូបេសុ សេនាសនេសុ វិហរន្តោ[១] បុព្វេ អប្បដិសំវិទិតំ ខាទនី-យំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា ខាទេយ្យ វា ភុញ្ជេយ្យ វា បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជឹ អសប្បាយំ បាដិទេស-និយំ តំ បដិទេសេមីតិ ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

១ ម. ឆ. ពោត្ថកេ អយំ បាឋោ ន ហោតិ ។



វេលានោះ ភិក្ខុទាំងនោះបានក្រាបទូលសេចក្ដីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកទើបត្រាស់ដោយ ព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះតថាគតនឹងបញ្ញត្តសិក្ខាបទ ដល់ពួកភិក្ខុ ព្រោះអាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាង គឺដើម្បី ជាការល្អប្រពៃដល់សង្ឃ ។ បេ ។ ដើម្បីញុំាងព្រះសទ្ធម្មឲ្យឋិតនៅ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បី សំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា សេនាសនៈទាំងឡាយណា ដែលមាននៅក្នុងព្រៃ ដែលគេសន្មតថាប្រកបដោយរង្កៀស ប្រកបដោយភ័យចំពោះមុខ ភិក្ខុណាមួយនៅក្នុងសេនាសនៈទាំងឡាយមានសភាពដូច្នោះ ហើយទទួលយកខាទនីយៈក្ដី ភោជនីយៈក្ដី ដែលគេមិនបានឲ្យដំណឹងពីមុន អំពីដៃរបស់ខ្លួនខាងក្នុងអារាម (យកមក) ទំពាស៊ីឬឆាន់ ភិក្ខុនោះត្រូវសំដែងអាបត្តិថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងអាបត្តិនោះចេញ ។ សិក្ខាបទនេះព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយ ដល់ពួកភិក្ខុដោយន័យដូចបានពោលមកយ៉ាងនេះ ។

[៤១៣] តេន ខោ បន សមយេន អញ្ញតរោ ភិក្ខុ អារញ្ញកេសុ សេនាសនេសុ គិលានោ ហោតិ ។ មនុស្សា ខាទនីយំ ភោជនីយំ អាទាយ អារញ្ញកំ សេនាសនំ អគមំសុ ។ អថខោ តេ មនុស្សា តំ ភិក្ខុំ ឯតទវោចុំ ភុញ្ជថ ភន្តេតិ ។ អថខោ សោ ភិក្ខុ ភគវតា បដិក្ខិត្តំ អារញ្ញកេសុ សេនាសនេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទិតុំ ភុញ្ជិតុន្តិ កុក្កុច្ចាយន្តោ ន បដិគ្គហេសិ នាសក្ខិ បិណ្ឌាយ ចរិតុំ ឆិន្នភត្តោ អហោសិ ។ អថខោ សោ ភិក្ខុ ភិក្ខូនំ ឯតមត្ថំ អារោចេសិ ។ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា អារញ្ញកេសុ សេនាសនេសុ ខាទនីយំ វា ភោជនីយំ វា សហត្ថា បដិគ្គហេត្វា ខាទិតុំ ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ



[៤១៣] សម័យនោះឯង មានភិក្ខុ១រូបមានជម្ងឺនៅក្នុងសេនាសនៈទាំងឡាយដែលតាំងនៅក្នុងព្រៃ ។ មនុស្សទាំងឡាយបាននាំយកខាទនិយភោជនីយាហារទៅសំដៅទៅកាន់ទីសេនាសនៈដែលតាំងនៅក្នុងព្រៃ(នោះ) ។ គ្រានោះឯង មនុស្សទាំងនោះក៏បាននិយាយពាក្យនេះនឹងភិក្ខុនោះថា បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់ចូរនិមន្តឆាន់ ។ វេលានោះ ភិក្ខុនោះនឹករង្កៀសថា ការដែលភិក្ខុទទួលយកខាទនីយៈ ភោជនីយៈ ដោយដៃរបស់ខ្លួនក្នុងទីសេនាសនៈទាំងឡាយដែលតាំងនៅក្នុងព្រៃ (ហើយយកមក) ទំពាស៊ីឬបរិភោគ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ហាមហើយ ក៏មិនហ៊ានទទួលយក ហើយមិនអាចនឹងទៅបិណ្ឌបាតបានឡើយក៏អត់ឆ្នាំង ។ លុះគ្រាតទៅក្រោយមក ភិក្ខុនោះបានចំណាលរឿងនុ៎ះដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយក៏បានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើធម្មីកថា ហើយត្រាស់ហៅភិក្ខុទាំងឡាយមកក្នុងវេលានោះដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជម្ងឺទទួលយកខាទនីយៈ ភោជនីយៈ ដោយដៃរបស់ខ្លួន ក្នុងទីសេនាសនៈទាំងឡាយដែលតាំងនៅក្នុងព្រៃ (យកមក) ទំពាស៊ីឬបរិភោគបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើង

ឧទ្ទិសេយ្យាថ យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានិ សាសង្កសម្មតានិ សប្បដិភយានិ យោ បន ភិក្ខុ តថារូបេសុ សេនាសនេសុ វិហរន្តោ បុព្វេ អប្បដិសំវិទិតំ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា អគិលានោ ខាទេយ្យ វា ភុញ្ជេយ្យ វា បដិទេសេតព្វំ តេន ភិក្ខុនា គារយ្ហំ អាវុសោ ធម្មំ អាបជ្ជិំ អសប្បាយំ បាដិទេសនីយំ តំ បដិទេសេមីតិ ។

[៤១៦] យានិ ខោ បន តានិ អារញ្ញកានិ សេនាសនានីតិ អារញ្ញកំ នាម សេនាសនំ បញ្ចធនុសតិកំ បច្ឆិមំ ។ សាសង្កំ នាម អារាមេ អារាមូបចារេ ចោរានំ និវិដ្ឋោកាសោ ទិស្សតិ ភុត្តោកាសោ ទិស្សតិ ឋិតោកាសោ ទិស្សតិ និសិន្នោកាសោ ទិស្សតិ និបន្នោកាសោ ទិស្សតិ ។ សប្បដិភយំ នាម អារាមេ អារាមូបចារេ ចោរេហិ មនុស្សា ហតា ទិស្សន្តិ វិលុត្តា ទិស្សន្តិ អាកោដិតា ទិស្សន្តិ ។ យោ បនាតិ យោ





នូវសិក្ខាបទនេះយ៉ាងនេះថា ទីសេនាសនៈទាំងឡាយណាមួយដែលមាននៅក្នុងព្រៃ ដែលគេសន្មតថាជាទីប្រកបដោយសេចក្ដីរង្កៀស ប្រកបដោយភ័យចំពោះមុខ ភិក្ខុណាមួយគង់នៅក្នុងទីសេនាសនៈទាំងឡាយមានសភាពដូច្នោះ បានទទួលយកខាទនីយៈក្ដី ភោជនីយៈក្ដី ដែលគេមិនបានឲ្យដំណឹងជាមុន ដោយដៃរបស់ខ្លួនក្នុងអារាម (ហើយយកមក) ទំពាស៊ីឬបរិភោគ ភិក្ខុនោះត្រូវសំដែងអាបត្តិថា ម្នាលអាវុសោ ខ្ញុំត្រូវហើយនូវអាបត្តិឈ្មោះបាដិទេសនីយៈ មិនជាទីសប្បាយ ដែលព្រះដ៏មានព្រះភាគទ្រង់តិះដៀល ខ្ញុំសូមសំដែងនូវអាបត្តិនោះចេញ ។

[៤១៦] ពាក្យថា ទីសេនាសនៈទាំងឡាយណាមួយដែលមាននៅក្នុងព្រៃ គឺទីសេនាសនៈយ៉ាងជិតបំផុតត្រឹម ៥០០ ធ្នូអំពីស្រុក ហៅថា សេនាសនៈតាំងនៅក្នុងព្រៃ ។ ដែលហៅថា ទីប្រកបដោយសេចក្ដីរង្កៀស គឺឱកាសជាទីនៅ ឱកាសសម្រាប់បរិភោគ ឱកាសសម្រាប់ឈរនៅ ឱកាសសម្រាប់អង្គុយនៅ ឱកាសសម្រាប់ដេកនៅ របស់ពួកចោរក៏ប្រាកដក្នុងអារាម ឬក្នុងឧបចារនៃអារាម ។ ដែលហៅថា ទីប្រកបដោយភ័យចំពោះមុខ គឺមនុស្សទាំងឡាយដែលពួកចោរសម្លាប់ ប្លន់ វាយប្រហារក៏ប្រាកដក្នុងអារាម ឬឧបចាររបស់អារាម ។ ពាក្យថា

យាទិសោ ។បេ។ ភិក្ខូតិ ។បេ។ អយំ ឥមស្មិំ អត្ថេ អធិប្បេតោ ភិក្ខូតិ ។ តថារូបេសុ សេនា-សនេសូតិ ឯវរូបេសុ សេនាសនេសុ ។ អប្បដិសំវិទិតំ នាម បញ្ចន្នំ បដិសំវិទិតំ ឯតំ អប្បដិសំវិទិតំ នាម ។ អារាមំ អារាមូបចារំ ឋបេត្វា បដិសំវិទិតំ ឯតំ អប្បដិសំវិទិតំ នាម ។ បដិសំវិទិតំ នាម យោ កោចិ ឥត្ថី វា បុរិសោ វា អារាមំ វា(១) អារាមូប-ចារំ វា(២) អាគន្ត្វា អារោចេតិ ឥត្ថន្នាមស្ស ភន្តេ ខាទនីយំ វា(៣) ភោជនីយំ វា(៤) អាហរិយិស្សតីតិ ។ សចេ សាសង្កំ ហោតិ សាសង្កន្តិ អាចិក្ខិតព្វំ ។ សចេ សប្បដិភយំ ហោតិ សប្បដិភយន្តិ អាចិក្ខិតព្វំ ។ សចេ ហោតុ ភន្តេ អាហរិយិស្សតីតិ ភណតិ ចោរា វត្តព្វា មនុស្សា ឥធូបចរន្តិ អបសក្កថាតិ ។ យាគុយា បដិសំវិទិតេ តស្សា បរិវារោ អាហរិយតិ ឯតំ

១-២-៣-៤ ឱ. ម. បោត្ថកេសុ ឥមេ វាសទ្ទា ន ហោន្តិ ។



ភិក្ខុណាមួយ មានសេចក្ដីដូចក្នុងសិក្ខាបទទី ១ នៃបារាជិកកណ្ឌ ។ ពាក្យថា ក្នុងសេនាសនៈទាំងឡាយមានសភាពដូច្នោះ គឺសេនាសនៈទាំងឡាយមានសភាពបែបនេះឯង ។ ដែលហៅថា គេមិនបានឲ្យដំណឹង នោះបើសហធម្មិកបុគ្គលទាំង ៥ បានឲ្យដំណឹងហើយក្តី ការឲ្យដំណឹងនោះ ក៏នឹងហៅថា គេមិនបានឲ្យដំណឹងដដែល ។ ការឲ្យដំណឹងក្នុងទីជាខាងក្រៅអារាម ឬឧបចារៈរបស់អារាមក្តី ការឲ្យដំណឹងយ៉ាងនេះក៏ឈ្មោះថាគេមិនបានឲ្យដំណឹងដដែល ។ ដែលហៅថា បានគេឲ្យដំណឹង គឺបុគ្គលណាមួយទោះស្រីក្តី ប្រុសក្តី មកកាន់អារាម ឬឧបចារៈរបស់អារាម ប្រាប់ (ចំពោះភិក្ខុ) ថា បពិត្រលោកម្ចាស់ដ៏ចំរើន ត្រកូលឈ្មោះនេះនឹងនាំយកខាទនីយៈឬភោជនីយៈ (មកប្រគេន) ។ បើទីប្រកបដោយសេចក្ដីរង្កៀស ភិក្ខុត្រូវប្រាប់ថា ទីប្រកបដោយសេចក្ដីរង្កៀស ។ បើទីប្រកបដោយភ័យចំពោះមុខ ភិក្ខុត្រូវប្រាប់ថា ទីប្រកបដោយភ័យចំពោះមុខ ។ បើទាយកនិយាយថា បពិត្រលោកម្ចាស់ដ៏ចំរើន សេចក្ដីរង្កៀសក្ដី សេចក្ដីភ័យក្ដីកើតចុះ ខ្ញុំនឹងនាំយក ខាទនីយៈឬភោជនីយៈមកមិនខានទេ (នោះ) ភិក្ខុត្រូវនិយាយនឹងពួកចោរថា ពួកមនុស្សតែងដើរចូលមកក្នុងទីនេះ ពួកអ្នកទាំងឡាយចូរថយចេញទៅ ។ ការនាំយកឲ្យដំណឹងថានឹងប្រគេនបបរ តែនាំយកនោះត្រូវប្រាប់ថានាំយក

បដិសំវិទិតំ នាម ។ ឃរេន បដិសំវិទិតោ តស្ស ឃរតោ អាហរិយតិ ឯតំ បដិសំវិទិតំ នាម ។ ខាទនី-យេន បដិសំវិទិតោ តស្ស ឃរតោ អាហរិយតិ ឯតំ បដិសំវិទិតំ នាម ។ កុលេន បដិសំវិទិតោ យេ តស្មឹ កុលេ មនុស្សា ខាទនីយំ វា ភោជនីយំ វា អាហរន្តិ ឯតំ បដិសំវិទិតំ នាម ។ គាមេន បដិសំវិទិតោ យេ តស្មឹ គាមេ មនុស្សា ខាទនីយំ វា ភោជនីយំ វា អាហរន្តិ ឯតំ បដិសំវិទិតំ នាម ។ បូគេន បដិសំ-វិទិតោ យេ តស្មឹ បូគេ មនុស្សា ខាទនីយំ វា ភោជនីយំ វា អាហរន្តិ ឯតំ បដិសំវិទិតំ នាម ។ ខាទនីយំ នាម បញ្ច ភោជនានិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ ឋបេត្វា អវសេសំ ខាទនីយំ នាម ។ ភោជនីយំ នាម បញ្ច ភោជនានិ ឱទនោ កុម្មាសោ សត្តុ មច្ឆោ មំសំ ។ អជ្ឈារាមោ នាម បរិក្ខិត្តស្ស



ចង្ហាន់របស់បងប្អូននោះមកប្រគេនវិញ នេះហៅថា មានគេឲ្យដំណឹងហើយ ។ កាលគេយកឲ្យដំណឹងថាខ្ញុំនឹងប្រគេនភត្ត តែគេយកនោះត្រឡប់ជាតាំងយកចង្ហាន់របស់ខ្លួននោះប្រគេនវិញ នេះហៅថា មានគេឲ្យដំណឹងហើយ ។ កាលបើគេយកគេប្រាប់ឲ្យដំណឹងថានឹងប្រគេនខាទនីយៈ តែគេយកនោះត្រឡប់ជាតាំងយកចង្ហាន់របស់ខាទនីយៈនោះប្រគេនវិញ នេះក៏ហៅថា គេប្រាប់ឲ្យដំណឹងហើយ ។ កាលបើគេយកគេប្រាប់ឲ្យដំណឹងថាត្រកូលនោះនឹងប្រគេន មានពួកមនុស្សណា ក្នុងត្រកូលនោះគេនាំយកខាទនីយៈឬភោជ-នីយៈមកប្រគេន នេះក៏ហៅថា គេប្រាប់ឲ្យដំណឹងហើយ ។ កាលបើគេយកគេប្រាប់ឲ្យដំណឹងថាអ្នកស្រុកគេនឹងប្រគេន មានពួកមនុស្សណា ក្នុងស្រុកនោះគេនាំយកខាទនីយៈឬភោជនីយៈមកប្រគេន នេះក៏ហៅថា គេប្រាប់ឲ្យដំណឹងហើយ ។ កាលបើគេយកគេប្រាប់ឲ្យដំណឹងថាប្រជុំជនគេនឹងប្រគេន មានពួកមនុស្សណា ក្នុងប្រជុំជននោះគេនាំយកខាទនីយៈឬភោជនីយៈមកប្រគេន នេះក៏ហៅថា គេប្រាប់ឲ្យដំណឹងហើយ ។ ដែលហៅថា ខាទនីយៈ គឺវៀរលែងភោជនទាំង ៥ យ៉ាង និងរបស់ជា យាមកាលិក សត្តាហកាលិក និងយាវជីវិកចេញ ក្រៅពីនេះហៅថា ខាទនីយៈទាំងអស់ ។ ដែលហៅថា ភោជនីយៈ បានដល់ភោជន ៥ យ៉ាងគឺបាយ ១ នំស្រស់ ១ នំក្រៀម ១ ត្រី ១ សាច់ ១ ។ ដែលហៅថា អារាមក្នុងអារាម គឺទីក្នុងអារាមដែលមានរបង

អារាមស្ស អន្តោអារាមេ អបរិក្ខិត្តស្ស ឧបចារោ ។ អគិលានោ នាម សក្កោតិ បិណ្ឌាយ ចរិតុំ ។ គិលានោ នាម ន សក្កោតិ បិណ្ឌាយ ចរិតុំ ។ អប្បដិសំវិទិតំ អគិលានោ ខាទិស្សាមិ ភុញ្ជិស្សាមីតិ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។ អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ បាដិទេសនីយស្ស ។

(៤០៨) អប្បដិសំវិទិតេ អប្បដិសំវិទិតសញ្ញី ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា អគិលានោ ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ អប្បដិសំវិទិតេ វេមតិកោ ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា អគិលានោ ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ អប្បដិសំវិទិតេ បដិសំវិទិតសញ្ញី ខាទនីយំ វា ភោជនីយំ វា អជ្ឈារាមេ សហត្ថា បដិគ្គហេត្វា អគិលានោ ខាទតិ វា ភុញ្ជតិ វា អាបត្តិ បាដិទេសនីយស្ស ។ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ អាហារត្ថាយ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។



ដែលមានរបង ចុះបើអារាមដែលឥតរបង ។ ភិក្ខុណាដែលអាចនឹងដើរទៅបិណ្ឌបាតបាន ភិក្ខុនោះឈ្មោះថាមិនមានជម្ងឺ ។ ភិក្ខុណាដែលមិនអាចនឹងដើរទៅបិណ្ឌបាតបានទេ ភិក្ខុនោះឈ្មោះថាមានជម្ងឺ ។ ភិក្ខុមិនមានជម្ងឺទទួលយកខាទនីយៈភោជនីយៈ ដែលទាយកឥតឲ្យដំណឹង ដោយគិតថា អាត្មាអញនឹងទំពាស៊ី នឹងបរិភោគ ត្រូវអាបត្តិទុក្កដ ។ ភិក្ខុត្រូវអាបត្តិបាដិទេសនីយៈគ្រប់ ៗ ពំ. ដែលលេបចូលទៅ ។

(៤១៨) ទាយកមិនបានឲ្យដំណឹង ភិក្ខុមិនមានជម្ងឺសំគាល់ថា ទាយកមិនបានឲ្យដំណឹង ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួនក្នុងអារាម (យកមក) ទំពាស៊ីឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុមិនមានជម្ងឺមានសេចក្តីសង្ស័យក្នុងរបស់ដែលទាយកមិនទាន់បានឲ្យដំណឹង ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួនក្នុងអារាម (យកមក) ទំពាស៊ីឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ ។ ទាយកមិនបានឲ្យដំណឹង ភិក្ខុមិនមានជម្ងឺសំគាល់ថាទាយកបានឲ្យដំណឹង ហើយទទួលយកខាទនីយៈក្តី ភោជនីយៈក្តី ដោយដៃរបស់ខ្លួនក្នុងអារាម (យកមក) ទំពាស៊ីឬបរិភោគ ត្រូវអាបត្តិបាដិទេសនីយៈ ។ ភិក្ខុទទួលរបស់ជាយាមកាលិក សត្តាហកាលិក នឹងរបស់ជាយាវជីវិក ដើម្បីប្រយោជន៍ជាអាហារ ត្រូវអាបត្តិទុក្កដ ។

អជ្ឈោហារេ អជ្ឈោហារេ អាបត្តិ ទុក្កដស្ស ។ បដិសំវិទិតេ អប្បដិសំវិទិតសញ្ញី អាបត្តិ ទុក្កដស្ស ។ បដិសំវិទិតេ វេមតិកោ អាបត្តិ ទុក្កដស្ស ។ បដិសំវិទិតេ បដិសំវិទិតសញ្ញី អនាបត្តិ ។

(៤១៦) អនាបត្តិ បដិសំវិទិតេ គិលានស្ស បដិសំវិទិតេ វា គិលានស្ស វា សេសកំ ភុញ្ជតិ ពហារាមេ បដិគ្គហេត្វា អន្តោអារាមេ ភុញ្ជតិ តត្ថ ជាតកំ មូលំ វា តចំ វា បត្តំ វា បុប្ផំ វា ផលំ វា ភុញ្ជតិ យាមកាលិកំ សត្តាហកាលិកំ យាវជីវិកំ សតិ បច្ចយេ បរិភុញ្ជតិ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ[1] ។

១ [illegible] ចប់ សិក្ខាបទ [illegible] ។





ភិក្ខុត្រូវអាបត្តិទុក្កដគ្រប់ៗ ពាក្យដែលលេបចូលទៅ ។ របស់ដែលគេយកបានឲ្យដំណឹងហើយ ភិក្ខុសំគាល់ថាគេមិនបានឲ្យដំណឹងទៅវិញ ត្រូវអាបត្តិទុក្កដ ។ របស់ដែលគេយកបានឲ្យដំណឹងហើយ ភិក្ខុមានសេចក្តីសង្ស័យ ត្រូវអាបត្តិទុក្កដ ។ របស់ដែលគេយកបានឲ្យដំណឹងហើយ ភិក្ខុសំគាល់ថាគេបានឲ្យដំណឹងមែន មិនត្រូវអាបត្តិឡើយ ។

[៤១៦] ពួកដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺរបស់ដែលគេយកបានឲ្យដំណឹង ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឆាន់អាហារប្រគេនដែលសល់អំពីភិក្ខុដែលគេបានឲ្យដំណឹង ឬអំពីភិក្ខុមានជម្ងឺ ១ ភិក្ខុទទួលយកអាហារប្រគេនខាងក្រៅអារាម (ហើយយកមក) ឆាន់ខាងក្នុងអារាម ១ ភិក្ខុឆាន់មើមឈើក្តី សំបកឈើក្តី ស្លឹកឈើក្តី ផ្កាឈើក្តី ផ្លែឈើក្តី ដែលដុះនៅខាងក្នុងអារាមនោះ ១ កាលបើមានហេតុ ភិក្ខុឆាន់របស់ជាយាមកាលិក សត្តាហកាលិក និងរបស់ជាយាវជីវិកបាន ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១[1] ។

១ [illegible]

[៤១៧] ឧទ្ទិដ្ឋា ខោ អយ្យាយោ អដ្ឋ បាដិទេសនីយា ធម្មា ។ តត្ថាយ្យាយោ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយ្យាយោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

បាដិទេសនីយកណ្ឌំ និដ្ឋិតំ ។



[៤១៧] បពិត្រលោកដ៏មានអាយុទាំងឡាយ អាបត្តិបាដិទេសនីយៈទាំង ៨ ខ្ញុំបានសំដែងរួចហើយ ។ ខ្ញុំសូមសួរលោកដ៏មានអាយុក្នុងអាបត្តិទាំងនោះ លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុទាំងឡាយជាអ្នកបរិសុទ្ធហើយក្នុងអាបត្តិទាំងនេះ ព្រោះហេតុនោះ បានជាលោកស្ងៀមនៅ ។ ខ្ញុំចាំទុកនូវសេចក្តីបរិសុទ្ធិនោះដោយការស្ងៀមនៅនេះឯង ។

បាដិទេសនីយកណ្ឌ ចប់ប៉ុណ្ណេះ ។

# សេខិយកណ្ឌំ

ឥមេ ខោ បនាយស្មន្តោ សេខិយា

ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។

## បរិមណ្ឌលវគ្គោ

## ឆព្វីសតិ សារុប្បា

[៥១៨] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេស្សន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា

# សេខិយកណ្ឌ

បពិត្រលោកដ៏មានអាយុទាំងឡាយ វត្ថុដែល

គប្បីសិក្សាទាំងនេះតែងមកកាន់ឧទ្ទេស ។

## បរិមណ្ឌលវគ្គ

## សារុប្ប មាន ២៦

(៥១៨) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលសម្រេចឥរិយាបថនៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុស្លៀកស្បង់ឲ្យស្រុយមុខខ្លះ ស្រុយក្រោយខ្លះ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា សមណៈទាំងឡាយជាសក្យបុត្រមិនសមបើនឹងស្លៀកស្បង់ឲ្យស្រុយមុខខ្លះ ស្រុយក្រោយខ្លះ ដូចជាពួកគ្រហស្ថដែលជាអ្នកបរិភោគកាមសោះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងឡាយនោះពោលទោស តិះដៀល បន្តុះបង្អាប់ ។ ពួកភិក្ខុណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ម្តេចក៏ពួកឆព្វគ្គិយភិក្ខុហ៊ាន

ភិក្ខូ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេស្សន្តីតិ ។ អថខោ តេ ភិក្ខូ(១) ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខុសង្ឃំ សន្និបាតាបេត្វា ឆព្វគ្គិយេ ភិក្ខូ បដិបុច្ឆិ សច្ចំ កិរ តុម្ហេ ភិក្ខវេ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា និវាសេស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ បរិមណ្ឌលំ និវាសេស្សាមីតិ សិក្ខា ករណីយាតិ ។

បរិមណ្ឌលំ និវាសេតព្វំ នាភិមណ្ឌលំ ជាណុមណ្ឌលំ បដិច្ឆាទេន្តេន ។ យោ អនាទរិយំ បដិច្ច បុរតោ វា បច្ឆតោ វា ឱលម្ពេន្តោ និវាសេតិ អាបត្តិ ទុក្កដស្ស ។

១ អថខោ តេ ភិក្ខូតិ ឱ. ម. បោត្ថកេ នត្ថិ ។



ស្លៀកស្បង់ឲ្យស្រុយមុខខ្លះ ស្រុយក្រោយខ្លះ ។ ខណៈនោះ ភិក្ខុទាំងនោះក៏ក្រាបទូលរឿងនុ៎ះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ។ ព្រោះនិទាននេះ នៃហេតុនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ហើយត្រាស់ឲ្យប្រជុំភិក្ខុសង្ឃ ហើយទ្រង់សួរចំពោះពួកឆព្វគ្គិយភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ដំណឹងថាអ្នកទាំងឡាយស្លៀកស្បង់ស្រុយមុខខ្លះ ស្រុយក្រោយខ្លះ ពិតមែនឬ ។ ពួកឆព្វគ្គិយភិក្ខុក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់ត្រាស់តិះដៀលថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនសមបើនឹងស្លៀកស្បង់ឲ្យស្រុយមុខខ្លះ ស្រុយក្រោយខ្លះទេ ម្នាលមោឃបុរសទាំងឡាយ អំពើនេះមិនបាននាំឲ្យជ្រះថ្លាដល់ជនទាំងឡាយដែលមិនទាន់ជ្រះថ្លា ឬនាំឲ្យរឹតតែជ្រះថ្លាដល់ជនទាំងឡាយដែលជ្រះថ្លាស្រាប់ហើយក៏ទេ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មានឹងស្លៀក(ស្បង់)ឲ្យជាបរិមណ្ឌល ។

ភិក្ខុត្រូវស្លៀកឲ្យជាបរិមណ្ឌល គឺបិទបាំងមណ្ឌលផ្ចិត(១)មណ្ឌលជង្គង់(២) ។ ភិក្ខុណាមួយ អាស្រ័យសេចក្តីមិនអើពើ ហើយស្លៀកឲ្យស្រុយមុខ ឬស្រុយក្រោយ ត្រូវអាបត្តិទុក្កដ ។

១-២ អដ្ឋកថា ភិក្ខុត្រូវស្លៀកស្បង់ឲ្យជាបរិមណ្ឌល ខាងលើបិទមណ្ឌលផ្ចិត ខាងក្រោមបិទមណ្ឌលជង្គង់ គឺស្លៀកចុះទៅក្រោមពីមណ្ឌលជង្គង់ ប្រមាណ ៨ ធ្នាប់ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៨៧៩) សាវត្ថិនិទានំ(១) ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បុរតោបិ បច្ឆតោបិ ឱលម្ពេន្តា បារុបន្តិ ។ បេ ។ បរិមណ្ឌលំ បារុបិស្សាមីតិ សិក្ខា ករណីយា ។

បរិមណ្ឌលំ បារុបិតព្វំ ឧភោ កណ្ណេ សមំ កត្វា ។ យោ អនាទរិយំ បដិច្ច បុរតោបិ បច្ឆតោបិ ឱលម្ពេន្តោ បារុបតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៨៨០) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កាយំ វិវរិត្វា អន្តរឃរេ គច្ឆន្តិ ។ បេ ។ សុប្បដិច្ឆន្នោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

១ យត្ថ សាវត្ថិនិទានំ ទិស្សតិ តត្ថ តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេតិ បាឡិ យោជេតិ ។



ភាពដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានសតិ ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៨៧៩) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដណ្ដប់ (ចីវរ) ស្ទួយមុខខ្លះ ស្ទួយក្រោយខ្លះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញ្ញុំនឹងដណ្ដប់ (ចីវរ) ឲ្យជាបរិមណ្ឌល ។

ភិក្ខុគប្បីដណ្ដប់ឲ្យជាបរិមណ្ឌលគឺ ធ្វើជាយទាំងពីរឲ្យស្មើគ្នា ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ដណ្ដប់ (ចីវរ) ឲ្យស្ទួយមុខខ្លះ ស្ទួយក្រោយខ្លះ ភិក្ខុនោះត្រូវអាបត្តិទុក្កដ ។

ភាពដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានសតិ ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៨៨០) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ បើកចំហខ្លួនកាយ(១) ហើយដើរទៅក្នុងចន្លោះផ្ទះ (គឺក្នុងស្រុក) ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញ្ញុំនឹងបិទបាំងកាយឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។

១ គឺភិក្ខុមិនបានបិទបាំងកាយឲ្យជាបរិមណ្ឌល ។

សុប្បដិច្ឆន្នេន អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច កាយំ វិវរិត្វា អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៥៦៣] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កាយំ វិវរិត្វា អន្តរឃរេ និសីទន្តិ ។ បេ ។ សុប្បដិច្ឆន្នោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

សុប្បដិច្ឆន្នេន អន្តរឃរេ និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច កាយំ វិវរិត្វា អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។





ភិក្ខុត្រូវបិទបាំង(១)ឲ្យល្អហើយទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយបើកចំហកាយ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ការៈដែលមិនត្រូវអាបត្តិ (គឺសំពត់របងខ្លះ [illegible]) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាអាទិកម្មិក ១ ។

[៥៦១] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ បើកចំហកាយអង្គុយក្នុងចន្លោះផ្ទះ ។ បេ ។ ទើបត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មានឹងបិទបាំង(កាយ)ឲ្យល្អអង្គុយទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុត្រូវបិទបាំង(២)ឲ្យល្អអង្គុយទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយបើកចំហកាយអង្គុយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

---

១ អដ្ឋកថា ថាបិទបាំងឲ្យល្អ [illegible] ភិក្ខុនឹងចូលទៅក្នុងស្រុក ត្រូវយកចីវរមកដាក់ត្រួតលើស្មា [illegible] ហើយយកជាយទាំងពីរបិទបាំង [illegible] ហើយចូលទៅ ។
២ អដ្ឋកថា ថាភិក្ខុដែលនឹងអង្គុយនៅក្នុងស្រុក ត្រូវបើកកាយត្រឹមតែកញ្ចឹងក [illegible] ហើយនឹងអង្គុយ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស វាសូបគតស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៦៦៦) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ហត្ថម្បិ បាទម្បិ កីឡាបេន្តា អន្តរឃរេ គច្ឆន្តិ ។ បេ ។ សុសំវុតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

សុសំវុតេន អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច ហត្ថំ វា បាទំ វា កីឡាបេន្តោ អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៦៦៧) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ហត្ថម្បិ បាទម្បិ កីឡាបេន្តា អន្តរឃរេ និសីទន្តិ ។ បេ ។ សុសំវុតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។



ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុដែលចូលទៅកាន់លំនៅ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៦៦) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ កំរើកដៃខ្លះ កំរើកជើងខ្លះ ដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងសង្រួមឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុត្រូវតែសង្រួមឲ្យល្អដើរទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ហើយក្រវាត់ក្រវៃដៃខ្លះ ជើងខ្លះ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៦៧) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ កំរើកដៃខ្លះ កំរើកជើងខ្លះ អង្គុយក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងសង្រួមឲ្យល្អអង្គុយទៅក្នុងចន្លោះផ្ទះ ។

សុសំវុតេន អន្តរឃរេ និសីទិតព្វំ ។ យោ អនា- ទរិយំ បដិច្ច ហត្ថំ វា បាទំ វា កីឡាបេន្តោ អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា- នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៦៦៤) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ តហំ តហំ ឱលោកេន្តា អន្តរឃរេ គច្ឆន្តិ ។បេ។ ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ឱក្ខិត្តចក្ខុនា អន្តរឃរេ គន្តព្វំ យុគមត្តំ បេក្ខ- មានេន ។ យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោ- កេន្តោ អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា- នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុត្រូវតែសង្រួមឲ្យល្អអង្គុយទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយកំរើកដៃ ឬកំរើកជើងអង្គុយទៅ ក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុភ្លេចស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១ ។

(៦៦៤) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ក្រឡេកមើលត្រង់នេះៗ ដើរទៅក្នុងចន្លោះផ្ទះ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមានភ្នែកសំឡឹងចុះដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុត្រូវតែមានភ្នែកសំឡឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ ក្រឡេកមើលត្រឹមតែមួយជួរនឹម ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយក្រឡេកមើលត្រង់នេះៗ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៧យ៉ាង) គឺភិក្ខុមិនក្លែង១ ភិក្ខុភ្លេចស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១ ។

[៤៤៥] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ តហំ តហំ ឱលោកេន្តា អន្តរឃរេ គច្ឆន្តិ ។ បេ ។ ឱក្ខិត្តចក្ខុ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ឱក្ខិត្តចក្ខុនា អន្តរឃរេ គន្តព្វំ យុគមត្តំ បេក្ខមានេន ។ យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អស្សតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៤៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧក្ខិត្តកាយ អន្តរឃរេ គច្ឆន្តិ ។ បេ ។ ន ឧក្ខិត្តកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ន ឧក្ខិត្តកាយ អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ឧក្ខិបិត្វា អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។



(៤៤៥) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ក្រឡេកមើលត្រង់នេះៗ ត្រង់នោះៗ ដើរទៅក្នុងចន្លោះផ្ទះ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមានភ្នែកសំឡឹងចុះ ដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុត្រូវតែមានភ្នែកសំឡឹងចុះ ក្រឡេកមើលមួយជួរនឹម ដើរទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណាមួយ ព្រោះសេចក្តីមិនអើពើ ហើយក្រឡេកមើលត្រង់នេះៗ ត្រង់នោះៗ ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុគ្មានសតិ ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៤៦) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ពើងខ្លួន ហើយដើរទៅក្នុងចន្លោះផ្ទះ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនពើងខ្លួនដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវពើងខ្លួនដើរទៅក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាមួយ ព្រោះសេចក្តីមិនអើពើ ហើយពើងខ្លួនម្ខាង ឬក៏ទាំងពីរខាង ដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-ឆស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៦៨) សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទុស្សបល្លត្ថិកាយ អន្តរឃរេ និសីទន្តិ ។ បេ ។ ន ទុស្សបល្លត្ថិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

ន ទុស្សបល្លត្ថិកាយ អន្តរឃរេ និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ទុស្សបល្លត្ថិកាយ អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស វាសូបគតស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ខម្ភកតវគ្គោ តតិយោ ។



ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៦៨) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ពាក់បង់ទ្បូយ ហើយចូលអង្គុយនៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនហើយចូលអង្គុយនៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវហើយចូល អង្គុយនៅក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយហើយចូលកាន់ម្ខាងក្ដី ទាំងពីរខាងក្ដី អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុដែលចូលទៅក្នុងអាវាស ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

ខម្ភកតវគ្គទីបី ចប់ ។

## ឧជ្ជគ្ឃិកវគ្គោ[១]

(៦៦៨) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មហាហសិតំ ហសន្តា អន្តរឃរេ គច្ឆន្តិ ។ បេ ។ ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ន ឧជ្ជគ្ឃិកាយ អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច មហាហសិតំ ហសន្តោ អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ហសនីយស្មឹ វត្ថុស្មឹ មិហិតមត្តំ[២] ករោតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៦៦៩) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មហាហសិតំ ហសន្តា អន្តរឃរេ និសីទន្តិ ។ បេ ។ ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

១ ឧជ្ជគ្ឃិកវគ្គោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ហសនមត្តំ ឥតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

## ឧជ្ជគ្ឃិកវគ្គ

(៦៦៨) សាវត្ថីនិទាន ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ សើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសើចខ្លាំង ដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយសើចខ្លាំងដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនចេតនា ១ ភិក្ខុភ្លេចសតិ ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុគ្រាន់តែធ្វើញញឹមក្នុងរឿងដែលគួរញញឹម ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៦៩) សាវត្ថីនិទាន ។ សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយសើចខ្លាំងអង្គុយក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសើចខ្លាំងអង្គុយក្នុងចន្លោះផ្ទះ ។

ន ឧជ្ជគ្ឃិកាយ អន្តរឃរេ និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច មហាហសិតំ ហសន្តោ អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ហសនីយស្មឹ វត្ថុស្មឹ មិហិតមត្តំ[១] ករោតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៣០) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តា អន្តរឃរេ គច្ឆន្តិ ។បេ។ អប្បសទ្ទោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

អប្បសទ្ទេន អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តោ អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៣១) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តា អន្តរឃរេ

១ ហសមត្តន្តិ ឆាយោ កត្ថចិ បោត្ថកេ ទិស្សតិ ។



ភិក្ខុមិនត្រូវសើចខ្លាំងអង្គុយនៅក្នុងចន្លោះផ្ទះឡើយ ។ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ហើយសើចខ្លាំងអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភាន់ស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុគ្រាន់តែធ្វើញញឹមក្នុងវត្ថុដែលគួរញញឹម ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៣០) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើនូវសំឡេងខ្លាំង សំឡេងធំ ដើរទៅក្នុងចន្លោះផ្ទះ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងនិយាយសំដីតិចដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុត្រូវមានសំឡេងតិចដើរទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវសំឡេងខ្លាំង សំឡេងធំដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភាន់ស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៣១) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើនូវសំឡេងខ្លាំង សំឡេងធំ អង្គុយនៅក្នុងចន្លោះផ្ទះ ។បេ។ ទ្រង់ត្រាស់ថា

និសីទន្តិ ។ បេ ។ អប្បសទ្ទោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

អប្បសទ្ទេន អន្តរឃរេ និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច ឧច្ចាសទ្ទំ មហាសទ្ទំ ករោន្តោ អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៣៥] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ កាយប្បចាលកំ អន្តរឃរេ គច្ឆន្តិ កាយំ ឱលម្ពេន្តា ។ បេ ។ ន កាយប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ន កាយប្បចាលកំ អន្តរឃរេ គន្តព្វំ កាយំ បគ្គហេត្វា គន្តព្វំ ។ យោ អនាទរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ គច្ឆតិ កាយំ ឱលម្ពេន្តោ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងនិយាយសំដីតិចអង្គុយទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុត្រូវតែមានសំឡេងតិចអង្គុយទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវសំឡេងខ្លាំង សំឡេងធំអង្គុយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចសតិ ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៣៥] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ក្រវែលកាយ យោលកាយដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនក្រវែលកាយដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវធ្វើកាយឲ្យក្រវែលដើរទៅក្នុងចន្លោះផ្ទះ ។ ត្រូវទ្រទ្រង់កាយដើរទៅ (ក្នុងចន្លោះផ្ទះ) ។ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ហើយក្រវែលកាយ យោលកាយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចសតិ ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៣៣) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កាយប្បចាលកំ អន្តរឃរេ និសីទន្តិ កាយំ ឱលម្ពេន្តា ។ បេ ។ ន កាយប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

ន កាយប្បចាលកំ អន្តរឃរេ និសីទិតព្វំ កាយំ បគ្គហេត្វា និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច កាយប្បចាលកំ អន្តរឃរេ និសីទតិ កាយំ ឱលម្ពេន្តោ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៦៣៤) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ពាហុប្បចាលកំ អន្តរឃរេ គច្ឆន្តិ ពាហុំ ឱលម្ពេន្តា ។ បេ ។ ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ពាហុំ បគ្គហេត្វា គន្តព្វំ ។ យោ អនាទរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ គច្ឆតិ ពាហុំ ឱលម្ពេន្តោ អាបត្តិ ទុក្កដស្ស ។



(៦៣៣) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ ផ្អៀលកាយ យោលកាយអង្គុយនៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនផ្អៀលកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវផ្អៀលកាយ អង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវតម្កល់តម្កើងកាយហើយអង្គុយនៅ (ក្នុងចន្លោះផ្ទះ) ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយផ្អៀលកាយ យោលកាយ អង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភាន់ស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុដែលចូលទៅកាន់ទីនោះ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៣៤) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទាំងឡាយ បង់ដៃ ក៏សដៃដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនបង់ដៃដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវបង់ដៃដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវតាំងដៃឲ្យស្រួល ដើរទៅ (ក្នុងចន្លោះផ្ទះ) ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយបង់ដៃក៏សដៃដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៣៨] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ពាហុប្បចាលកំ អន្តរឃរេ គច្ឆន្តិ ពាហុំ ឱលម្ពេត្វា ។ បេ ។ ន ពាហុប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ន ពាហុប្បចាលកំ អន្តរឃរេ គន្តព្វំ ពាហុំ បគ្គហេត្វា គន្តព្វំ ។ យោ អនាទរិយំ បដិច្ច ពាហុប្បចាលកំ អន្តរឃរេ គច្ឆតិ ពាហុំ ឱលម្ពេត្វា អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស កិស្សុបកស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៣៩] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សីសប្បចាលកំ អន្តរឃរេ គច្ឆន្តិ សីសំ ឱលម្ពេត្វា ។ បេ ។ ន សីសប្បចាលកំ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។



ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភាន់ស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាដើមបញ្ញត្តិ ១ ។

[៤៣៨] សាវត្ថីនិទាន សម័យនោះឯង ឆព្វគ្គិយភិក្ខុទាំងឡាយ ធ្លាក់ដៃ កាលដែលគង់ទៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនធ្លាក់ដៃ គង់ទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវធ្លាក់ដៃ គង់ទៅក្នុងចន្លោះផ្ទះទេ ត្រូវដាក់ដៃឲ្យស្រួល គង់ទៅក្នុងចន្លោះផ្ទះ ។ ភិក្ខុណាមួយ ប្រើយាសេចក្ដីមិនអើពើ ហើយធ្លាក់ដៃ កាលដែលគង់ទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភាន់ស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឈរពោះកាន់ទីទៅ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៣៩] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ធ្លាក់ក្បាល យោលក្បាលដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនយោលក្បាលដើរទៅក្នុងចន្លោះផ្ទះ ។

ន សីសប្បចាលកំ អន្តរឃរេ គន្តព្វំ សីសំ បគ្គហេត្វា គន្តព្វំ ។ យោ អនាទរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ គច្ឆតិ សីសំ ឱលម្ពេន្តោ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៦៣៧] សាវត្ថិយំ និទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សីសប្បចាលកំ អន្តរឃរេ និសីទន្តិ សីសំ ឱលម្ពេត្វា ។បេ។ ន សីសប្បចាលកំ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

ន សីសប្បចាលកំ អន្តរឃរេ និសីទិតព្វំ សីសំ បគ្គហេត្វា និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច សីសប្បចាលកំ អន្តរឃរេ និសីទតិ សីសំ ឱលម្ពេន្តោ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស វសុបគតស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ខម្ភកតវគ្គោ តតិយោ ។



ភិក្ខុមិនត្រូវគ្រវីក្បាលដើរទៅក្នុងចន្លោះផ្ទះទេ ត្រូវតែទប់តម្រង់ក្បាលឲ្យស្រួលដើរទៅ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ គ្រវីក្បាល ទេក្បាលដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុគ្មានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៦៣៧] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ គ្រវីក្បាល ទេក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ ។បេ។ ទើបទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនគ្រវីក្បាល អង្គុយនៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវគ្រវីក្បាលអង្គុយនៅក្នុងចន្លោះផ្ទះទេ ត្រូវតែទប់តម្រង់ក្បាលឲ្យស្រួលអង្គុយនៅ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយគ្រវីក្បាល ទេក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុគ្មានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុចូលទៅកាន់ទីនៅ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

ខម្ភកតវគ្គ ទី ៣ ចប់ ។

## ខម្ភកតវគ្គោ

[៤៣៨] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ខម្ភកតា អន្តរឃរេ គច្ឆន្តិ ។ បេ ។ ន ខម្ភកតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ន ខម្ភកតេន អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ខម្ភំ កត្វា អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៣៩] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ខម្ភកតា អន្តរឃរេ និសីទន្តិ ។ បេ ។ ន ខម្ភកតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយា ។

ន ខម្ភកតេន អន្តរឃរេ និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា ខម្ភំ កត្វា អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។

## ខម្ភកតវគ្គ

[៤៣៨] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ (យកដៃ) ស្ទាបចង្កេះដើរទៅក្នុងចន្លោះផ្ទះ ។ បេ ។ ព្រះអង្គត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិន (យកដៃ) ស្ទាបចង្កេះដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវស្ទាបចង្កេះដើរទៅក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវកិរិយាស្ទាបចង្កេះតែម្ខាងក្តី ទាំងពីរខាងក្តី ហើយដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ឯ.ដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៣៩] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ (យកដៃ) ស្ទាបចង្កេះអង្គុយក្នុងចន្លោះផ្ទះ ។ បេ ។ ព្រះអង្គត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិន (យកដៃ) ស្ទាបចង្កេះអង្គុយក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវ (យកដៃ) ស្ទាបចង្កេះហើយអង្គុយក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើនូវកិរិយាស្ទាបចង្កេះតែម្ខាងក្តី ទាំងពីរខាងក្តី អង្គុយក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៦៦០] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សសីសំ បារុបិត្វា អន្តរឃរេ គច្ឆន្តិ ។បេ។ ន ឱគុណ្ឋិតោ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយាតិ ។

ន ឱគុណ្ឋិតេន អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច សសីសំ បារុបិត្វា អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៦៦១] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សសីសំ បារុបិត្វា អន្តរឃរេ និសីទន្តិ ។បេ។ ន ឱគុណ្ឋិតោ អន្តរឃរេ និសីទិស្សាមីតិ សិក្ខា ករណីយាតិ ។



ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុចូលទៅកាន់ទីនៅ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៦០) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ ។បេ។ ទើបទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះឡើយ ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយទទូរក្បាលដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុភ្លេចស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៦១) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទូរក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ ។បេ។ ទើបទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនទទូរក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ ។

ន ឱគុណ្ឋិតេន អន្តរឃរេ និសីទិតព្វំ ។ យោ អនាទរិយំ បដិច្ច សសីសំ បារុបិត្វា អន្តរឃរេ និសីទតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៦៦៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧក្កុដិកាយ អន្តរឃរេ គច្ឆន្តិ ។បេ។ ន ឧក្កុដិកាយ អន្តរឃរេ គមិស្សាមីតិ សិក្ខា ករណីយា ។

ន ឧក្កុដិកាយ អន្តរឃរេ គន្តព្វំ ។ យោ អនាទរិយំ បដិច្ច ឧក្កុដិកាយ អន្តរឃរេ គច្ឆតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុមិនត្រូវខ្ទប់ក្បាលអង្គុយនៅក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយខ្ទប់ក្បាលអង្គុយនៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

អៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុចូលទៅកាន់ទីនៅ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៦៦៦] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដើរចំអើតដើរទៅក្នុងចន្លោះផ្ទះ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មានឹងមិនចំអើតជើងហើយដើរទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវចំអើតជើងដើរទៅក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយចំអើតជើងដើរទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

អៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុចូលទៅកាន់ទីនៅ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៦៦៧] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុអង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មានឹងមិនអង្គុយត្របោមក្បាលជង្គង់ក្នុងចន្លោះផ្ទះ ។

[៤៤៣] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ចត្តារិមា ភិក្ខវេ បល្លត្តិកាយេ អណ្ឌជយោ ជំសីនទ្ធិ ។បេ ។ ន បល្លត្តិកាយ អណ្ឌជយោ ជំសីជំស្សាមីតិ សំខ្យា គារវាយោ ។

ន បល្លត្តិកាយ អណ្ឌជយោ ជំសីជំតត្ថំ ។ យោ សោគារិយំ បជិត្ត ហត្ថបល្លត្តិកាយេ វា ឧស្សបល្លត្តិកាយ វា អណ្ឌជយោ ជំសីជំតិ អាបត្តិ ឧក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស វាសុបតកស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

## សមត្តំ ឱបជំនប្បជំសំយុត្តា

[៤៤៤] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ចត្តារិមា ភិក្ខវេ អសញ្ញាទំ បិណ្ឌបាតំ បជិគ្គណ្ហាតិ ឧត្តុកាមា វិយ ។បេ ។ សញ្ញាទំ បិណ្ឌបាតំ បជិគ្គហេស្សាមីតិ សិក្ខា ករណីយា ។



ភិក្ខុមិនត្រូវគន្ធិយត្រដោមក្បាលជន្ទំ ក្នុងបន្ទោះផ្ទះឡើយ ។ ភិក្ខុណា ៗ ស្រម័យសេចក្តីមិនអើពើ គន្ធិយត្រដោមក្បាលជន្ទំដោយដៃក្តី ត្រដោមដោយកែនចីវរក្តី ក្នុងបន្ទោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុចូលទៅកាន់ទីនៅ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

## ភោជំនប្បជំសំយុត្ត ៣០

[៤៤៤] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទួលនូវបាយបិណ្ឌបាតមិនគោរព ធ្វើដូចជាមានសេចក្តីប្រាថ្នានឹងចាក់ចោល ។បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលនូវបាយបិណ្ឌបាតដោយគោរព ។

សក្កច្ចំ បិណ្ឌបាតោ បដិគ្គហេតព្វោ ។ យោ អនាទរិយំ បដិច្ច អសក្កច្ចំ បិណ្ឌបាតំ បដិគ្គណ្ហាតិ ឆឌ្ឌេតុកាមោ វិយ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៤៨) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ តហំ តហំ ឱលោកេន្តា បិណ្ឌបាតំ បដិគ្គណ្ហន្តិ អាកិរន្តេបិ អតិក្កន្តេបិ ន ជានន្តិ ។បេ។ បត្តសញ្ញី បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

បត្តសញ្ញិនា បិណ្ឌបាតោ បដិគ្គហេតព្វោ ។ យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ បិណ្ឌបាតំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុត្រូវទទួលអាហារបិណ្ឌបាតដោយគោរព ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយទទួលអាហារបិណ្ឌបាតមិនគោរព ធ្វើដូចជាមានសេចក្តីប្រាថ្នានឹងចាក់ចោល ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៤៨) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំឡឹងមើលទៅក្នុងទីនោះៗ ទទួលបិណ្ឌបាត កាលបើមានគេចាក់ក្តី ដាក់បាត្រក្តី ចាក់ឲ្យហើយដើរទៅក្តី ក៏មិនបានដឹងរឿងនោះ (ព្រោះមិនសង្កេតមើលតែមើលទៅទីផ្សេងៗ) ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងសំគាល់ក្នុងបាត្រហើយទទួលបិណ្ឌបាត ។

ភិក្ខុត្រូវសំគាល់ក្នុងបាត្រហើយទទួលបិណ្ឌបាត ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំឡឹងមើលទៅក្នុងទីនោះៗ ទទួលបិណ្ឌបាត ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៤៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បិណ្ឌបាតំ បដិគ្គណ្ហន្តា សូបំយេវ ពហុំ បដិគ្គណ្ហន្តិ ។បេ។ សមសូបកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

សូបោ នាម ទ្វេ សូបា មុគ្គសូបោ មាសសូបោ ហត្ថហារិយោ ។ សមសូបកោ បិណ្ឌបាតោ បដិគ្គហេតព្វោ ។ យោ អនាទរិយំ បដិច្ច សូបំយេវ ពហុំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អស្សតិយា អជានន្តស្ស គិលានស្ស រសរសេ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៤៧] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ថូបីកតំ[១] បិណ្ឌបាតំ បដិគ្គណ្ហន្តិ ។បេ។ សមតិត្តិកំ បិណ្ឌបាតំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយា ។

១. ម. ថូបីកតំ ។



[៤៤៦] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលទទួលបិណ្ឌបាត ទទួលយកសម្លច្រើនពេក ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល[១] ។

ដែលហៅថា សម្ល បានដល់សម្លពីរយ៉ាង គឺសម្លសណ្តែកបាយ ១ សម្លសណ្តែកកាផាស ១ ដែលគួរជ្រលក់នឹងចាប់ដោយដៃបាន ។ ភិក្ខុត្រូវទទួលបិណ្ឌបាតល្មមគ្នានឹងសម្ល ។ ភិក្ខុណាមួយ ព្រោះសេចក្តីមិនអើពើ ហើយទទួលយកសម្លច្រើនពេក ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១៤ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ សម្លមានរសដ៏ក្រៃលែង ១[២] ភិក្ខុទទួលយករបស់ញាតិ ១ របស់ជនដែលបានបវារណា ១ ភិក្ខុទទួលយកដើម្បីប្រយោជន៍ដល់អ្នកដទៃ ១ ភិក្ខុទទួលយកដោយទ្រព្យរបស់ខ្លួន ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៤៧] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុទទួលបិណ្ឌបាតពេញកំពូលបាត្រ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងទទួលបិណ្ឌបាតឲ្យស្មើត្រឹមកណ្តាប់មាត់បាត្រ ។

១ អដ្ឋកថា សម្លដែលមានប្រមាណប៉ុនភាគទី ៤ នៃបាយ ហៅថា សម្លល្មមនឹងបិណ្ឌបាត ។
២ អដ្ឋកថា ស្លាបព្រាបានដែរ ។ មានសម្លត្រី ត្រីសាច់ជាដើម ដែលក្រៅពីសម្លសណ្តែកបាយនឹងសម្លសណ្តែកផេសែរៈចេញ ។

សមតិត្តិកោ បិណ្ឌបាតោ បដិគ្គហេតព្វោ ។ យោ អនាទរិយំ បដិច្ច ថូបីកតំ បិណ្ឌបាតំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

ខម្ភកតវគ្គោ តតិយោ ។



ភិក្ខុត្រូវទទួលបិណ្ឌបាតឲ្យពេញស្មើត្រឹមកណ្ដាប់មាត់បាត្រ ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយទទួលបិណ្ឌបាត ឲ្យកំពូលលើសកណ្ដាប់មាត់បាត្រទៅ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៦ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

ខម្ភកតវគ្គ ទី ៣ ចប់ ។

## សក្កច្ចវគ្គោ

[៦៦៤] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ អសក្កច្ចំ បិណ្ឌបាតំ ភុញ្ជន្តិ អភុញ្ជិតុកាមា វិយ ។ បេ ។ សក្កច្ចំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

សក្កច្ចំ បិណ្ឌបាតោ ភុញ្ជិតព្វោ ។ យោ អនាទរិយំ បដិច្ច អសក្កច្ចំ បិណ្ឌបាតំ ភុញ្ជតិ អភុញ្ជិតុកាមោ វិយ(១) អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៦៦៥] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ តហំ តហំ ឱលោកេន្តា បិណ្ឌបាតំ ភុញ្ជន្តិ អាកិរន្តេបិ អតិក្កន្តេបិ ន ជានន្តិ ។ បេ ។ បត្តសញ្ញី បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

បត្តសញ្ញិនា បិណ្ឌបាតោ ភុញ្ជិតព្វោ ។ យោ អនាទរិយំ បដិច្ច តហំ តហំ ឱលោកេន្តោ បិណ្ឌបាតំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

១ អភុញ្ជិតុកាមោ វិយាតិ ម. ឆ. បោត្ថកេ នត្ថិ ។

## សក្កច្ចវគ្គ

[៦៦៤] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់បិណ្ឌបាតមិនគោរព ធ្វើដូចជាមិនចង់ឆាន់ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាតដោយគោរព ។

ភិក្ខុត្រូវឆាន់បិណ្ឌបាតដោយគោរព ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយឆាន់បិណ្ឌបាតមិនគោរព ធ្វើហាក់ដូចជាមិនចង់ឆាន់ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៦៦៥] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ក្រឡេកមើលទៅទីនោះៗ ឆាន់បិណ្ឌបាត កាលបើគេយកកំពុសចាក់ក្ដី ចាក់ហួស រួចហើយហៀរចេញទៅក្ដី ក៏មិនដឹងខ្លួនឡើយ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងសំគាល់តែក្នុងបាត្រឆាន់បិណ្ឌបាត ។

ភិក្ខុត្រូវសំគាល់តែក្នុងបាត្រ ហើយឆាន់បិណ្ឌបាត ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ក្រឡេកមើលទៅទីនោះៗ ឆាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៥០] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ តហំ តហំ ឱមសិត្វា(១) បិណ្ឌបាតំ ភុញ្ជន្តិ ។ បេ ។ សបទានំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

សបទានំ បិណ្ឌបាតោ ភុញ្ជិតព្វោ ។ យោ អនាទរិយំ បដិច្ច តហំ តហំ ឱមសិត្វា(២) បិណ្ឌបាតំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អញ្ញេសំ ទេន្តោ ឱមសតិ អញ្ញស្ស ភាជនេ អាកិរន្តោ ឱមសតិ ឧត្តរិភង្គេ អាបទាសុ ឧម្មត្តក-ស្ស អាទិកម្មិកស្សាតិ ។

[៤៥១] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បិណ្ឌបាតំ ភុញ្ជន្តា សូបំយេវ ពហុំ ភុញ្ជន្តិ ។ បេ ។ សមសូបកំ បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

១-២ ម. ឱមទ្ទិត្វា ។



ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៥០] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកកាយបាយឲ្យខ្ទង់ក្នុងទីនោះៗ ឆាន់បិណ្ឌបាត ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាតកុំឲ្យស្មើ ។

ភិក្ខុត្រូវឆាន់បិណ្ឌបាតកុំឲ្យស្មើ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ កកាយបាយឲ្យខ្ទង់ក្នុងទីនោះៗ ឆាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ១០ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុកកាយបិណ្ឌបាតឲ្យខ្ទង់ឲ្យដល់ពួកដទៃដែរ ១ ភិក្ខុកកាយបិណ្ឌបាតឲ្យខ្ទង់ដើម្បីរោយចុះក្នុងភាជនៈដទៃដែរ ១ ភិក្ខុកកាយសម្លក្នុងគ្រឿង ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៥១] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលឆាន់បិណ្ឌបាត ក៏ឆាន់សម្លច្រើនជាង ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងឆាន់បិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល ។

ស្សតោ ឋាម នេ ស្សតា ឧក្កស្សតោ មាសស្សតោ ហត្ថបាសេ ។ សមស្សបតោ បិណ្ឌបាតោ ភុញ្ជិតព្វោ ។ យោ អនាទរិយំ បដិច្ច ស្សបំយេវ ឧបាំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ[១] អត្តនោ ធនេន អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៥៩៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ជួបតោ[២] ឧមន្តិកា បិណ្ឌបាតំ ភុញ្ជន្តិ ។ បេ ។ ន ជួបតោ[៣] ឧមន្តិកា បិណ្ឌបាតំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន ជួបតោ[៤] ឧមន្តិកា បិណ្ឌបាតោ ភុញ្ជិតព្វោ ។ យោ អនាទរិយំ បដិច្ច ជួបតោ[៥] ឧមន្តិកា បិណ្ឌបាតំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

១ អញ្ញស្សត្ថាយាតិ ឱ. ម. បោត្ថកេ នត្ថិ ។ ២-៣-៤-៥ ជួបិកតោតិ ភគ្គំ បោត្ថកេ ទិស្សតិ ។



ដែលហៅថា សម្ល បានដល់សម្លតែយ៉ាងនឹង គឺសម្លសណ្តែកបាយ ១ សម្លសណ្តែកដំណើប ១ ដែលគេធ្វើទឹកពាក់សាច់ជាមួយអាហារ ។ ភិក្ខុត្រូវ ទទួលបិណ្ឌបាតឲ្យល្មមគ្នានឹងសម្ល ។ ភិក្ខុណាការលើការលោកចិត្តមិនអើពើ ទទួលសម្លឲ្យច្រើនជាង ត្រូវអាបត្តិទុក្កដ ។

អនាបត្តិដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១៤ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ សម្លមានពណ៌ផ្សេង ១ ភិក្ខុទទួលសម្លរបស់ញាតិ ១ ភិក្ខុទទួលសម្លរបស់ជនដែលបានបវារណា ១ ភិក្ខុទទួលសម្លដើម្បីប្រយោជន៍អ្នកដទៃ[១] ១ ភិក្ខុទទួលសម្លដែលបានមកដោយទ្រព្យរបស់ខ្លួន ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៥៩៦] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រមូលបាយធំ ហើយឆាន់បិណ្ឌបាត ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មានឹងមិនធ្វើប្រមូលបាយធំ ហើយឆាន់បិណ្ឌបាត ។

ភិក្ខុមិនត្រូវប្រមូលបាយធំ ហើយឆាន់បិណ្ឌបាតទេ ។ ភិក្ខុណាការលើការលោកចិត្តមិនអើពើ ប្រមូលបាយធំហើយឆាន់បិណ្ឌបាត ត្រូវអាបត្តិទុក្កដ ។

១ ពាក្យនេះហាក់ដូចជាលើស ព្រោះក្នុងសិក្ខាបទខាងដើមត្រង់ត្រូវថា ភិក្ខុទទួលសម្លដើម្បីអ្នកដទៃ ទេនឹង តែសិក្ខាបទនេះនិយាយពីឆាន់សម្ល ភិក្ខុឆាន់ដើម្បីអ្នកដទៃ ដូចម្តេចបាន ហាក់ដូចជាមិនសមនឹងហេតុទេ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស បរិត្តកេ សេសេ ឯកតោ សង្កឌ្ឍិត្វា ឱមទ្ទិត្វា ភុញ្ជតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៥៣] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ សូបម្បិ ព្យញ្ជនម្បិ ឱទនេន បដិច្ឆាទេន្តិ ភិយ្យោកម្យតំ ឧបាទាយ ។ បេ ។ ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេស្សាមិ ភិយ្យោកម្យតំ ឧបាទាយាតិ សិក្ខា ករណីយា ។

ន សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេតព្វំ ភិយ្យោកម្យតំ ឧបាទាយ ។ យោ អនាទរិយំ បដិច្ច សូបំ វា ព្យញ្ជនំ វា ឱទនេន បដិច្ឆាទេតិ ភិយ្យោកម្យតំ ឧបាទាយ អាបត្តិ ទុក្កដស្ស ។





កៈដែលមិនក្រេតភក្ត្រ (ត្រង់សំណាកបាយនេះមាន៤យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុប្រមូលបាយដែលសេសសល់បន្តិចបន្តួច ឲ្យមូលជាមួយគ្នា ហើយក្រេបឆាន់ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាអាទិកម្មិក ១ ។

[៤៥៣] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ កកាយបាយលុបសម្លខ្លះ ម្ហូបខ្លះ ព្រោះអាស្រ័យសេចក្តីល្មោភច្រើន ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនកកាយបាយលុបសម្ល ម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន ។

ភិក្ខុមិនត្រូវកកាយបាយលុបសម្ល ម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើនទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយកកាយបាយលុបសម្លម្ហូប ព្រោះអាស្រ័យសេចក្តីល្មោភច្រើន ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស សាមិកា បដិច្ឆាទេត្វា ទេន្តិ ន ភិយ្យោកម្យតំ ឧបាទាយ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៨៦) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សូបម្បិ ឱទនម្បិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា[១] សូបម្បិ ឱទនម្បិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សន្តិ កស្ស សម្បន្នំ ន មនាបំ កស្ស សាទុំ ន រុច្ចតីតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខិយ្យន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូ សូបម្បិ ឱទនម្បិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សន្តីតិ ។ បេ ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ សូបម្បិ ឱទនម្បិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា

១ កថំ ហិ នាម ឆព្វគ្គិយា ភិក្ខូតិ ម. ឆ. បោត្ថកេ ទិស្សតិ ។



ភាពដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្រឹត ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ពួកជនជាម្ចាស់របស់ គេលុបសម្ល ខ្ទប់ ហើយប្រគេន ១ ភិក្ខុមិនអាស្រ័យសេចក្តីល្មោភច្រើន ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៨៦) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ សូមសម្លរ ឬបាយ ដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់ ។ មនុស្សទាំងឡាយក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត មិនសមបើនឹងហ៊ានសូមសម្លរ ឬបាយ ដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់សោះ អ្នកណាហើយដែលមិនគាប់ចិត្តនឹងអាហារដ៏បរិបូណ៌ អ្នកណាហើយដែលមិនគាប់ចិត្តនឹងអាហារដែលមានរសឆ្ងាញ់ ។ ពួកភិក្ខុបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ។ ពួកភិក្ខុណាមានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងហ៊ានសូមសម្លរ ឬបាយ ដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់សោះ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយសូមសម្លរ ឬបាយ ដើម្បីប្រយោជន៍ខ្លួនហើយឆាន់ ពិតមែនឬ ។ ភិក្ខុទាំងនោះក៏ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់

កថំ ហិ នាម តុម្ហេ មោឃបុរិសា សូបំបិ ឱទនំបិ
អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សថ នេតំ មោឃបុ-
រិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោ-
ភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ
ឧទ្ទិសេយ្យាថ ន សូបំ វា ឱទនំ វា អត្តនោ អត្ថាយ
វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយាតិ ។
ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៤៦៩] តេន ខោ បន សមយេន ភិក្ខូ គិលានា
ហោន្តិ ។ គិលានបុច្ឆកា ភិក្ខូ គិលានេ ភិក្ខូ ឯតទ-
វោចុំ កច្ចាវុសោ ខមនីយំ កច្ចិ យាបនីយន្តិ ។
បុព្វេ មយំ អាវុសោ សូបំបិ ឱទនំបិ អត្តនោ អត្ថាយ
វិញ្ញាបេត្វា ភុញ្ជាម តេន នោ ផាសុ ហោតិ ឥទានិ
បន ភគវតា បដិក្ខិត្តន្តិ កុក្កុច្ចាយន្តា ន វិញ្ញាបេម
តេន នោ ន ផាសុ ហោតីតិ ។ ភគវតោ ឯតមត្ថំ



ចំពោះព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំង
ឡាយមិនគួរបើនឹងហ៊ានសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួន
ហើយឆាន់សោះ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះ
នឹងបាននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែល
ជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ
អ្នកទាំងឡាយ ត្រូវសំដែងសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បី
ធ្វើសេចក្ដីសិក្សាថា អញនឹងមិនសូមសម្លបាយ ដើម្បីប្រយោជន៍ខ្លួនឯង
ហើយឆាន់ទេ ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដល់
ពួកភិក្ខុយ៉ាងនេះ ។

[៤៦៩] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺ ។ ឯពួក
ភិក្ខុអ្នកសួរជម្ងឺបានពោលពាក្យនេះនឹងភិក្ខុដែលមានជម្ងឺថា ម្នាលអាវុសោ
អ្នកទាំងឡាយល្មមអត់ធន់បានឬទេ អ្នកទាំងឡាយល្មមញុំាំងអត្តភាពឲ្យ
ប្រព្រឹត្តទៅបានឬទេ ។ ភិក្ខុទាំងនោះឆ្លើយថា ម្នាលអាវុសោ ពីដើម
យើងតែងសូមសម្លខ្លះ បាយខ្លះ ដើម្បីប្រយោជន៍ខ្លួនឯងហើយឆាន់ ហេតុ
នោះបានជាយើងសប្បាយ តែឥឡូវនេះ ព្រះដ៏មានព្រះភាគទ្រង់ហាម
ឃាត់ហើយ ពួកយើងមានសេចក្ដីរង្កៀស ទើបបានជាមិនហ៊ានសូមគេ
ហេតុនោះបានជាយើងមិនសប្បាយ ។ ភិក្ខុទាំងនោះបានក្រាបទូល

អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ[១] អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា សូបម្បិ ឱទនម្បិ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិស្សាមីតិ សិក្ខា ករណីយាតិ ។

ន សូបំ វា ឱទនំ វា អគិលានេន អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច សូបំ វា ឱទនំ វា អគិលានោ អត្តនោ អត្ថាយ វិញ្ញាបេត្វា ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ញាតកានំ បវារិតានំ អញ្ញស្សត្ថាយ អត្តនោ ធនេន អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

១ អថខោ ភគវា ឯតស្មឹ ។ បេ ។ ភិក្ខូ អាមន្តេសីតិ មរម្មបោត្ថកេ នត្ថិ ។





សេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះឯង ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើនូវធម្មីកថាក្នុងហេតុនោះ ហើយទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតដើម្បីឲ្យភិក្ខុដែលមានជម្ងឺសូមសម្លក្តី បាយក្តី ដើម្បីប្រយោជន៍ខ្លួនហើយឆាន់បាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញមិនមានជម្ងឺនឹងមិនបានសូមសម្លឬបាយ ដើម្បីប្រយោជន៍ខ្លួន ហើយឆាន់ ។

ភិក្ខុមិនមានជម្ងឺ មិនត្រូវសូមសម្លឬបាយដើម្បីប្រយោជន៍ខ្លួនហើយឆាន់ទេ ។ ភិក្ខុណាមិនមានជម្ងឺ ព្រោះសេចក្តីមិនអើពើ សូមសម្លឬបាយដើម្បីប្រយោជន៍ខ្លួនហើយឆាន់ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ១០ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុសូមក្នុងសំណាក់ញាតិ ១ ភិក្ខុសូមក្នុងសំណាក់ជនដែលបវារណា ១ ភិក្ខុសូមដើម្បីប្រយោជន៍អ្នកដទៃ ១ ភិក្ខុបាច់មកដោយទ្រព្យរបស់ខ្លួន ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៥៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេន្តិ ។ បេ ។ ន ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេស្សាមីតិ សិក្ខា ករណីយា ។

ន ឧជ្ឈានសញ្ញិនា បរេសំ បត្តោ ឱលោកេតព្វោ ។ យោ អនាទរិយំ បដិច្ច ឧជ្ឈានសញ្ញី បរេសំ បត្តំ ឱលោកេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស ទស្សាមីតិ វា ទាបេស្សាមីតិ វា ឱលោកេតិ ន ឧជ្ឈានសញ្ញិស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៥៧] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ មហន្តំ កពឡំ ករោន្តិ ។ បេ ។ នាតិមហន្តំ កពឡំ ករិស្សាមីតិ សិក្ខា ករណីយា ។

នាតិមហន្តោ កពឡោ កាតព្វោ ។ យោ អនាទរិយំ បដិច្ច មហន្តំ កពឡំ ករោតិ អាបត្តិ ទុក្កដស្ស ។



[៤៥៦] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុប្រកាន់ទោស ហើយសំឡឹងមើលបាត្ររបស់ភិក្ខុដទៃ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនប្រកាន់ទោស ហើយសំឡឹងមើលបាត្ររបស់ភិក្ខុដទៃ ។

ភិក្ខុមិនត្រូវសំឡឹងមើលបាត្ររបស់ភិក្ខុដទៃ ដោយប្រកាន់ទោសទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយប្រកាន់ទោស គឺសំឡឹងមើលបាត្ររបស់ភិក្ខុឯទៀត ត្រូវអាបត្តិទុក្កដ ។

ភាវៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុសំឡឹងមើលដោយគិតថា អាត្មាអញនឹងឲ្យ ឬអាត្មាអញនឹងប្រើគេឲ្យ ១ ភិក្ខុមិនបានប្រកាន់ទោសហើយសំឡឹងមើល ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៥៧] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុធ្វើពំនូតបាយធំពេក ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនធ្វើពំនូតបាយឲ្យធំពេក ។

ភិក្ខុមិនត្រូវធ្វើពំនូតបាយឲ្យធំពេកទេ(១) ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយធ្វើពំនូតបាយឲ្យធំពេក ត្រូវអាបត្តិទុក្កដ ។

---

១ អដ្ឋកថា ពំនូតបាយធំពេក [illegible] ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ខជ្ជកេ ផលាផលេ ឧត្តរិភង្គេ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៩៨] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទីឃំ អាលោបំ ករោន្តិ ។បេ។ បរិមណ្ឌលំ អាលោបំ ករិស្សាមីតិ សិក្ខា ករណីយា ។

បរិមណ្ឌលោ អាលោបោ កាតព្វោ ។ យោ អនាទរិយំ បដិច្ច ទីឃំ អាលោបំ ករោតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ខជ្ជកេ ផលាផលេ ឧត្តរិភង្គេ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។





ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១០ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឆាន់បង្អែម ១ ផ្លែឈើតូចធំ ១ សម្លក្រៅភត្ត ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៩៨] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ធ្វើពំនូតបាយវែងៗហើយឆាន់ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងធ្វើពំនូតបាយឲ្យជាប់បរិមណ្ឌល គឺឲ្យមូល ។

ភិក្ខុត្រូវធ្វើពំនូតបាយឲ្យជាប់បរិមណ្ឌល ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយធ្វើពំនូតបាយឲ្យវែង ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១០ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឆាន់បង្អែម ១ ផ្លែឈើតូចធំ ១ សម្លក្រៅភត្ត ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

## កពឡវគ្គោ

[៦៥៩] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អនាហដេ កពឡេ មុខទ្វារំ វិវរន្តិ ។ បេ ។ ន អនាហដេ កពឡេ មុខទ្វារំ វិវរិស្សាមីតិ សិក្ខា ករណីយា ។

ន អនាហដេ កពឡេ មុខទ្វារំ វិវរិតព្វំ ។ យោ អនាទរិយំ បដិច្ច អនាហដេ កពឡេ មុខទ្វារំ វិវរតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៦៦០] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ភុញ្ជមានា សព្វំ ហត្ថំ មុខេ បក្ខិបន្តិ ។ បេ ។ ន ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបិស្សាមីតិ សិក្ខា ករណីយា ។

## កពឡវគ្គ

[៦៥៩] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាល ពំនូតបាយនៅមិនទាន់មកដល់មាត់ ក៏ហាមាត់ចាំ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា កាលពំនូតបាយមិនទាន់មកដល់ អាត្មានឹងមិនបើកទ្វារមាត់ចាំ ។

ភិក្ខុមិនត្រូវហាមាត់ចាំពំនូតបាយដែលមិនទាន់បានមកដល់មាត់ទេ ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ហើយហាមាត់ចាំពំនូតបាយដែលមិនទាន់មកដល់មាត់ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៦៦០] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុកាលឆាន់បាយ ក៏ញាត់(ទ្រាម)ដៃទាំងអស់ចូលទៅក្នុងមាត់ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាកាលឆាន់បាយ នឹងមិនញាត់(ទ្រាម)ដៃទាំងអស់ចូលទៅក្នុងមាត់ ។

ន ភុញ្ជមានេន សព្វោ ហត្ថោ មុខេ បក្ខិបិតព្វោ ។ យោ អនាទរិយំ បដិច្ច ភុញ្ជមានោ សព្វំ ហត្ថំ មុខេ បក្ខិបតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៦១] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សកពឡេន មុខេន ព្យាហរន្តិ ។ បេ ។ ន សកពឡេន មុខេន ព្យាហរិស្សាមីតិ សិក្ខា ករណីយាតិ ។

ន សកពឡេន មុខេន ព្យាហរិតព្វំ ។ យោ អនាទរិយំ បដិច្ច សកពឡេន មុខេន ព្យាហរតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុកាលឆាន់ចង្ហាន់មិនត្រូវលូក (ម្រាម) ដៃទាំងអស់ចូលទៅក្នុងមាត់ ។ បេ ។ ភិក្ខុណាមួយមិនមានសេចក្ដីអើពើ ហើយឆាន់ចង្ហាន់លូក (ម្រាម) ដៃទាំងអស់ចូលទៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (គឺមិនត្រូវទោសមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៦១] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុនិយាយទាំងពាក់កណ្ដាលបាយនៅក្នុងមាត់ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិននិយាយទាំងពាក់កណ្ដាលបាយនៅក្នុងមាត់ ។

ភិក្ខុមិនត្រូវនិយាយទាំងពាក់កណ្ដាលបាយនៅក្នុងមាត់ទេ ។ ភិក្ខុណាមួយមិនមានសេចក្ដីអើពើ ហើយនិយាយទាំងពាក់កណ្ដាលបាយ នៅក្នុងមាត់ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (គឺមិនត្រូវទោសមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៦៦៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បិណ្ឌុក្ខេបកំ ភុញ្ជន្តិ ។ បេ ។ ន បិណ្ឌុក្ខេបកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន បិណ្ឌុក្ខេបកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច បិណ្ឌុក្ខេបកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ខជ្ជកេ ផលាផលេ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៦៦៧] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ កពឡាវច្ឆេទកំ ភុញ្ជន្តិ ។ បេ ។ ន កពឡាវច្ឆេទកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន កពឡាវច្ឆេទកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច កពឡាវច្ឆេទកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ខជ្ជកេ ផលាផលេ ឧត្តរិភង្គេ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



[៦៦៦] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់បោះដុំបាយ (ទៅក្នុងមាត់) ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់បោះដុំបាយ (ទៅក្នុងមាត់) ។

ភិក្ខុមិនត្រូវឆាន់បោះដុំបាយ (ទៅក្នុងមាត់)ទេ ។ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ ឆាន់បោះដុំបាយ (ទៅក្នុងមាត់) ត្រូវអាបត្តិទុក្កដ ។

ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៩យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឆាន់បង្អែម ១ ផ្លែឈើតូចធំ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៦៦៧] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់កាត់ពំនូតបាយ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់កាត់ពំនូតបាយ ។

ភិក្ខុមិនត្រូវឆាន់កាត់ពំនូតបាយទេ ។ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ ឆាន់កាត់ពំនូតបាយ ត្រូវអាបត្តិទុក្កដ ។

ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ១០ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឆាន់បង្អែម ១ ផ្លែឈើតូចធំ ១ សម្លក្អែក្ដ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៦៤] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អវគណ្ឌការកំ ភុញ្ជន្តិ ។ បេ ។ ន អវគណ្ឌការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន អវគណ្ឌការកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច ឯកតោ វា ឧភតោ វា គណ្ឌំ កត្វា ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស(១) ផលាផលេ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៦៥] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ហត្ថនិទ្ធុនកំ ភុញ្ជន្តិ ។ បេ ។ ន ហត្ថនិទ្ធុនកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន ហត្ថនិទ្ធុនកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច ហត្ថនិទ្ធុនកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស កចវរំ ឆឌ្ឌេន្តោ ហត្ថំ និទ្ធុនតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

---

១ គិលានស្ស ឧទ្ធកេតិ កត្ថចិ បោត្ថកេ ទិស្សតិ ។





[៤៦៤] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់បៀមពំនួតថ្ពាល់ (គឺបៀមដូចស្វា) ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់បៀមពំនួតថ្ពាល់ ។

ភិក្ខុមិនត្រូវឆាន់បៀមពំនួតថ្ពាល់ទេ ។ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ឆាន់បៀមពំនួតថ្ពាល់ម្ខាង ឬទាំងពីរខាង ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុឆាន់ផ្លែឈើតូច ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៦៥] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់រលាស់ដៃ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់រលាស់ដៃ ។

ភិក្ខុមិនត្រូវឆាន់រលាស់ដៃទេ ។ ភិក្ខុណា អាស្រ័យសេចក្តីមិនអើពើ ឆាន់រលាស់ដៃបណ្តើរ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុរលាស់សម្រាមដោយរលាស់ដៃ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៦៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សិត្ថាវការកំ ភុញ្ជន្តិ ។ បេ ។ ន សិត្ថាវការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន សិត្ថាវការកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច សិត្ថាវការកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស កចវរំ អបកឌ្ឍន្តោ សិត្ថំ ឆឌ្ឌយតិ(១) អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៦៧] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ជិវ្ហានិច្ឆារកំ ភុញ្ជន្តិ ។ បេ ។ ន ជិវ្ហានិច្ឆារកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន ជិវ្ហានិច្ឆារកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច ជិវ្ហានិច្ឆារកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

១ ម. ឆឌ្ឌេតិ ។



[៤៦៦] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់ធ្វើក្រាប់បាយឲ្យជ្រុះរាយពាយ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់ក្រាប់បាយ ឲ្យជ្រុះរាយពាយ ។

ភិក្ខុមិនត្រូវឆាន់ធ្វើក្រាប់បាយ ឲ្យជ្រុះរាយពាយទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់ធ្វើក្រាប់បាយ ឲ្យជ្រុះរាយពាយ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនចេតនា១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ភិក្ខុបោសសម្រាមជាប់យកទៅផងនឹងក្រាប់បាយ១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១ ។

[៤៦៧] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លៀនអណ្តាត ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់លៀនអណ្តាត ។

ភិក្ខុមិនត្រូវឆាន់លៀនអណ្តាតទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់លៀនអណ្តាត ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៦៨] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ចបុចបុការកំ ភុញ្ជន្តិ ។ បេ ។ ន ចបុចបុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។ ន ចបុចបុការកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច ចបុចបុការកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

កពឡវគ្គោ បញ្ចមោ ។



ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៦៨] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់ធ្វើសំឡេងឱ្យឮជប់ៗ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើសំឡេងឱ្យឮជប់ៗ ។

ភិក្ខុមិនត្រូវឆាន់ធ្វើសំឡេងឱ្យឮជប់ៗ ទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ឆាន់ធ្វើសំឡេងឱ្យឮជប់ៗ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

កពឡវគ្គ ទី ៥ ចប់ ។

## សុរុសុរុវគ្គោ

[៤៦៤] តេន សមយេន ពុទ្ធោ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អញ្ញតរេន ព្រាហ្មណេន សង្ឃស្ស បយោបានំ បដិយត្តំ ហោតិ ។ ភិក្ខូ សុរុសុរុការកំ ខីរំ បិវន្តិ ។ អញ្ញតរោ នដបុព្វកោ ភិក្ខុ ឯវមាហ សព្វាយំ មញ្ញេ សង្ឃោ សីតីកតោតិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខិយ្យន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខុ សង្ឃំ អារព្ភ ទវំ ករិស្សតីតិ ។ បេ ។ សច្ចំ កិរ ត្វំ ភិក្ខុ សង្ឃំ អារព្ភ ទវំ អកាសីតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម ត្វំ មោឃបុរិស សង្ឃំ អារព្ភ ទវំ ករិស្សសិ នេតំ មោឃបុរិស អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។ បេ ។ វិគរហិត្វា ធម្មឹ កថំ កត្វា ភិក្ខូ

## សុរុសុរុវគ្គ

[៤៦៤] សម័យនោះឯង ព្រះពុទ្ធដ៏មានព្រះភាគ គង់នៅឃោសិតារាម ជិតក្រុងកោសម្ពី ។ សម័យនោះឯង មានព្រាហ្មណ៍ម្នាក់ បានតាក់តែងនូវទឹកដោះចំពោះសង្ឃ ។ អស់ភិក្ខុក៏ឆាន់ទឹកដោះឮសំឡេងស៊ុរៗ ៗ មានភិក្ខុ ១ រូបធ្លាប់ជាអ្នករាំ (ពីដើម) បានពោលពាក្យនេះថា សង្ឃទាំងអស់នេះទំនងជាធ្វើទឹកដោះឲ្យត្រជាក់ទេដឹង ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុ(នេះ)មិនសមបើនឹងហ៊ានពោលកំប្លែងប្រារព្ធព្រះសង្ឃ (ដូច្នេះ) សោះ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុ បានឮថាអ្នកឯងពោលកំប្លែងប្រារព្ធសង្ឃ ពិតមែនឬ ។ ភិក្ខុនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរស អ្នកឯងមិនសមបើនឹងហ៊ានពោលកំប្លែងប្រារព្ធសង្ឃ (ដូច្នេះ) សោះ ម្នាលមោឃបុរស អំពើដែលអ្នកឯងធ្វើនេះមិនបាននាំពួកជនដែលមិនទាន់ជ្រះថ្លាឲ្យបានជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយឲ្យរឹតតែជ្រះថ្លាឡើងទេ ។ បេ ។ ទ្រង់បន្ទោសរួចហើយ ទ្រង់ធ្វើធម្មីកថា

អាមន្តេសិ ន ភិក្ខវេ ពុទ្ធំ វា ធម្មំ វា សង្ឃំ វា អារព្ភ ទវោ កាតព្វោ យោ ករេយ្យ អាបត្តិ ទុក្កដស្សាតិ ។ អថខោ ភគវា តេ ភិក្ខូ អនេកបរិយាយេន វិគរហិត្វា ធម្មិកថំ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន សុរុសុរុការកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន សុរុសុរុការកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច សុរុសុរុការកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៥៧០] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ហត្ថនិល្លេហកំ ភុញ្ជន្តិ ។ បេ ។ ន ហត្ថនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន ហត្ថនិល្លេហកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច ហត្ថនិល្លេហកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។



ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវនិយាយលេងប្រឡែងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃទេ ភិក្ខុណានិយាយ ត្រូវអាបត្តិទុក្កដ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសភិក្ខុទាំងនោះដោយអនេកបរិយាយ ។ បេ ។ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឆាន់ធ្វើសូរឮសុរុ ៗ ។

ភិក្ខុមិនត្រូវឆាន់ធ្វើសូរឮសុរុ ៗ ទេ ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើ ឆាន់ធ្វើសូរឮសុរុ ៗ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្ដែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៥៧០] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លិទ្ធដៃ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អញនឹងមិនឆាន់លិទ្ធដៃ ។

ភិក្ខុមិនត្រូវឆាន់លិទ្ធដៃទេ ។ ភិក្ខុណាអាស្រ័យសេចក្ដីមិនអើពើហើយឆាន់លិទ្ធដៃ ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៧១] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ បត្តនិល្លេហកំ ភុញ្ជន្តិ ។ បេ ។ ន បត្តនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន បត្តនិល្លេហកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច បត្តនិល្លេហកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស បត្តកេ សេសេ ឯកតោ សង្កឌ្ឍិត្វា និល្លេហិត្វា ភុញ្ជតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៧២] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឱដ្ឋនិល្លេហកំ ភុញ្ជន្តិ ។ បេ ។ ន ឱដ្ឋនិល្លេហកំ ភុញ្ជិស្សាមីតិ សិក្ខា ករណីយា ។

ន ឱដ្ឋនិល្លេហកំ ភុញ្ជិតព្វំ ។ យោ អនាទរិយំ បដិច្ច ឱដ្ឋនិល្លេហកំ ភុញ្ជតិ អាបត្តិ ទុក្កដស្ស ។



ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៧១] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លិទ្ធបាត្រ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធបាត្រ ។

ភិក្ខុមិនត្រូវឆាន់លិទ្ធបាត្រទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់លិទ្ធបាត្រ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុប្រមូលភោជនតិចតួច ដែលសេសសល់បន្តិចបន្តួចមកត្រង់ទីតែមួយហើយលិទ្ធ ហើយឆាន់ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៧២] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឆាន់លិទ្ធបបូរមាត់ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនឆាន់លិទ្ធបបូរមាត់ ។

ភិក្ខុមិនត្រូវឆាន់លិទ្ធបបូរមាត់ទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយឆាន់លិទ្ធបបូរមាត់ ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៧៣) តេន សមយេន ពុទ្ធោ ភគវា ភគ្គេសុ វិហរតិ សុសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន ភិក្ខូ កោកនទេ បាសាទេ សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គណ្ហន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សន្តីតិ ។ បេ ។ សច្ចំ កិរ ភិក្ខវេ ភិក្ខូ សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គណ្ហន្តីតិ ។



អនាបត្តិ (គឺមិនត្រូវអាបត្តិមាន ៧ យ៉ាង) ដល់ភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៧៣) សម័យនោះឯង ព្រះពុទ្ធជាម្ចាស់ដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវន (វិហារ) ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ ។ សម័យនោះឯង ពួកភិក្ខុនៅលើកោកនទប្រាសាទ (ប្រាសាទមានសណ្ឋានដូចផ្កាឈូក) មានដៃប្រឡាក់ដោយអាមិសៈ ទទួលភាជនៈទឹកសម្រាប់ផឹក ។ មនុស្សទាំងឡាយ ក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត មានដៃប្រឡាក់ដោយអាមិសៈ មិនសមបើនឹងទទួលយកភាជនៈទឹកសម្រាប់ផឹក ដូចជាពួកគ្រហស្ថដែលបរិភោគកាមគុណនោះ ។ ពួកភិក្ខុបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា មានសេចក្តីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ភិក្ខុទាំងឡាយមានដៃប្រឡាក់ដោយអាមិសៈ មិនសមបើនឹងហ៊ានទទួលភាជនៈទឹកសម្រាប់ផឹកសោះ ។ បេ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បានឮថាភិក្ខុទាំងឡាយ មានដៃប្រឡាក់ដោយអាមិសៈទទួលភាជនៈទឹកសម្រាប់ផឹក ពិតមែនឬ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តេ ភិក្ខវេ មោឃបុរិសា សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គហេស្សាមីតិ សិក្ខា ករណីយាតិ ។

ន សាមិសេន ហត្ថេន បានីយថាលកោ បដិគ្គហេតព្វោ ។ យោ អនាទរិយំ បដិច្ច សាមិសេន ហត្ថេន បានីយថាលកំ បដិគ្គណ្ហាតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ធោវិស្សាមីតិ វា ធោវាបេស្សាមីតិ វា បដិគ្គណ្ហាតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៧៦] តេន សមយេន ពុទ្ធោ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។



ភិក្ខុទាំងនោះក៏ក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំងនោះមានដៃប្រឡាក់ ដោយអាមិសៈ មិនសមបើនឹងទទួលភាជនៈទឹកសម្រាប់ផឹកសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនបានធ្វើពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញមានដៃប្រឡាក់ដោយអាមិសៈ នឹងមិនទទួលភាជនៈទឹកសម្រាប់ផឹក ។

ភិក្ខុមានដៃប្រឡាក់ដោយអាមិសៈ មិនត្រូវទទួលភាជនៈទឹកសម្រាប់ផឹកទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ មានដៃប្រឡាក់ដោយអាមិសៈទទួលភាជនៈទឹកសម្រាប់ផឹក ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុទទួលភាជនៈទឹកសម្រាប់ផឹកដោយគិតថា អញនឹងលាង ឬអញនឹងប្រើគេឲ្យលាង ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៧៦] សម័យនោះឯង ព្រះពុទ្ធដ៏មានព្រះភាគ កាលគង់នៅក្នុងភេសកឡាវ័ន (ព្រៃសម) ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀប

ចុទេ ហោតិ ឋានំ សមយេន ភិក្ខុ ហោតិ ឧទេ ចារំ

សេ សិក្ខាបទំ បត្តនាវាំ អន្តរាយោ ចោទនត្តិ ។ មនុស្ស

ឧជ្ឈាយន្តិ ទីឃន្តិ វិបាចេន្តិ កាថំ ហិ នាម សមណា

សក្យបុត្តិយា សសិក្ខាបទំ បត្តនាវាំ អន្តរាយោ ចោទនត្តិ

សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ

ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ទីយន្តានំ វិបា-

ចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ ។ តេ ឧជ្ឈា-

យន្តិ ទីយន្តិ វិបាចេន្តិ កថំ ហិ នាម ភិក្ខូ សសិក្ខាបទំ

បត្តនាវាំ អន្តរាយោ ចោទេស្សន្តីតិ ។បេ ។ សច្ចំ កិរ

ភិក្ខវេ ភិក្ខូ សសិក្ខាបទំ បត្តនាវាំ អន្តរាយោ ចោទេន្តីតិ ។

សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម

តេ ភិក្ខវេ មោឃបុរិសា សសិក្ខាបទំ បត្តនាវាំ អន្តរាយោ

ចោទេស្សន្តិ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ





ត្រពាំងស្រះហ៊ើរ ជាទីផ្ទុក ។ សម័យនោះឯង ពួកភិក្ខុឆព្វគ្គិយ

កោកនទព្រះអាម ( ព្រះអាមមានសណ្ឋានដូចផ្កាឈូក ) ចាក់ទឹកដែល

លាយដោយត្រីតូចត្រាប់ហុយទៅគ្រឿងឆ្នាំងផង ។ មនុស្សទាំងឡាយក៏ពោល

ទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្ត មិនសមបើនឹង

ហើយចាក់ទឹកដែលលាយដោយត្រីតូចត្រាប់ហុយទៅគ្រឿងឆ្នាំងផង ដូចជាពួក

គ្រហស្ថដែលបរិភោគកាមគុណដូច្នេះ ។ ភិក្ខុទាំងឡាយបានឮពួកមនុស្សទាំង

នោះពោលទោស តិះដៀល បន្តុះបង្អាប់ហើយ ។ ភិក្ខុទាំងឡាយណា

មានសេចក្តីប្រាថ្នាតិច ។បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះ

បង្អាប់ថា ភិក្ខុទាំងឡាយមិនសមបើនឹងហើយចាក់ទឹកដែលលាយដោយត្រីតូច

ត្រាប់ហុយទៅគ្រឿងឆ្នាំងផងសោះ ។បេ ។ ព្រះដ៏មានព្រះភាគទ្រង់

ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ បានឮថា ភិក្ខុទាំងឡាយចាក់ទឹក

លាយដោយត្រីតូចត្រាប់ហុយទៅគ្រឿងឆ្នាំងផងពិតមែនឬ ។ ភិក្ខុទាំងនោះ

ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធជាម្ចាស់

ដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលភិក្ខុទាំងឡាយ មោឃបុរសទាំង

នោះ មិនសមបើនឹងហើយចាក់ទឹកលាយដោយត្រីតូចត្រាប់ហុយទៅគ្រឿង

ឆ្នាំងផងសោះ ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនបាននាំឲ្យជនដែល

មិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយឲ្យកាន់តែ

ចេស្សន្តា ភិ កិលេយ្យកាកយ ។ បេ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេស្សាមីតិ សិក្ខា ករណីយាតិ ។

ន សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេតព្វំ ។ យោ អនាទរិយំ បដិច្ច សសិត្ថកំ បត្តធោវនំ អន្តរឃរេ ឆឌ្ឌេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ឧទ្ធរិត្វា វា ភិន្ទិត្វា វា បដិគ្គហេ វា នីហរិត្វា ឆឌ្ឌេតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

## សោឡស ធម្មទេសនាបដិសំយុត្តា

[៤៧៨] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឆត្តបាណិស្ស ធម្មំ ទេសេន្តិ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។ បេ ។ តេ ឧជ្ឈាយន្តិ ខីយន្តិ



ផ្ដើមដូចរឿងដើម ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនចាក់ទឹកលាងបាត្រដែលមានគ្រាប់បាយទៅក្នុងចន្លោះផ្ទះ ។

ភិក្ខុមិនត្រូវចាក់ទឹកលាងបាត្រដែលមានគ្រាប់បាយទៅក្នុងចន្លោះផ្ទះទេ ។ ភិក្ខុណាមួយ ព្រោះសេចក្ដីមិនអើពើ ចាក់ទឹកលាងបាត្រដែលមានគ្រាប់បាយទៅក្នុងចន្លោះផ្ទះ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនចេតនា ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុប្រមូលគ្រាប់បាយមកដាក់ផ្ដុំហើយស្រឡិតចោលនូវទឹកក្ដី ភិក្ខុបំបែកគ្រាប់បាយឲ្យរលាយជាទឹកហើយចាក់ចោលទាំងអស់ក្ដី ភិក្ខុចាក់ទឹកលាងបាត្រដែលមានគ្រាប់បាយទៅក្នុងភាជន៍ (កន្ធោរ) ក្ដី ភិក្ខុនាំយកទឹកលាងបាត្រដែលមានគ្រាប់បាយទៅចាក់ចោលក្រៅក្ដី ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

## ធម្មទេសនាបដិសំយុត្ត មាន ១៦ សិក្ខាបទ

[៤៧៨] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សមានឆត្រនៅក្នុងដៃ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។ បេ ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល

វិហរេន្តិ តស្មា តិហ ភិក្ខវេ ឥទំ ទុក្ខន្តិ យោគោ ករណីយោ ឥទំ ទុក្ខសមុទយោតិ យោគោ ករណីយោ ។បេ។ ឥទំ ទុក្ខនិរោធគាមិនី បដិបទាតិ យោគោ ករណីយោ ឥទំ ទុក្ខនិរោធគាមិនី បដិបទាតិ យោគោ ករណីយោតិ ។ ឧទ្ទេសនាបទសំយុត្តំ ។

[១៧៦] តេន ខោ បន សមយេន ភិក្ខូ ចក្ខុ ... មនុស្សា ចវិត្វា មនុស្សេសុ បច្ចាយន្តិ ... សេយ្យថាបិ ... ទេវេសុ បច្ចាយន្តិ ។ អថ ខោ ... ភិក្ខូ ... មនុស្សា ចវិត្វា ... បច្ចាយន្តិ ។ អថ ខោ



ចន្ទុបមាថា ពួកសត្វក្នុងលោកនេះមិនសមរម្យនឹងបាន សំដែងមិនដល់មនុស្ស មានតែប្រើនៅក្នុងវិជ្ជានោះ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដូចគ្នាថា ពួកសត្វទាំងឡាយដែលច្យុតចាកមនុស្ស មានតែប្រើនៅក្នុងវិជ្ជ ភិក្ខុនុ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ភិក្ខុនុ ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទាសថា ម្នាលអាយុស្មានទាំងឡាយ ពួកទាំងឡាយមិនគួរនឹងសំដែងមិនដល់មនុស្សមានតែប្រើនៅក្នុងវិជ្ជ ម្នាលអាយុស្មានទាំងឡាយ សំរាប់ ... ដែលមិនបានដាក់ប្រើដោយប្រើដោយឡើង ពួកជនដែលប្រើដោយ ហើយរក្សាទុកប្រើដោយឡើងវិញ ។បេ។ ម្នាលភិក្ខុទាំងឡាយ ពួកទាំងឡាយ សំរាប់ប្រើឡើងវិញ ពួកបុគ្គលនេះហៅថា ភិក្ខុគប្បីធ្វើសេចក្ដីព្យាយាម ពួកនឹងមិនសំដែងមិនដល់មនុស្សមានតែប្រើនៅក្នុងវិជ្ជ ។ សំដែងនេះព្រះដ៏មានព្រះភាគទ្រង់បានបញ្ញត្តហើយដល់ពួកភិក្ខុយ៉ាងនេះ ។

[១៧៦] សម័យនោះឯង ភិក្ខុទាំងឡាយនៅស្រុកចំការសំដែងមិនដល់មនុស្សណាមានតែប្រើនៅក្នុងវិជ្ជ ។ មនុស្សទាំងឡាយក៏គោលពោល តិរច្ឆាន ចន្ទុបមាថា ពួកសមណៈជាសក្យបុត្តមិនសមរម្យនឹងសំដែងមិនដល់មនុស្សណាមានតែប្រើនៅក្នុងវិជ្ជនោះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិរច្ឆាន ចន្ទុបមាហើយ ។ លំដាប់នោះ ភិក្ខុទាំង

តេ ភិក្ខូ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ ឆត្តបាណិស្ស គិលានស្ស ធម្មំ ទេសេតុំ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ឆត្តំ នាម តីណិ ឆត្តានិ សេតច្ឆត្តំ កិលញ្ជច្ឆត្តំ បណ្ណច្ឆត្តំ មណ្ឌលពទ្ធំ សលាកពទ្ធំ ។ ធម្មោ នាម ពុទ្ធភាសិតោ សាវកភាសិតោ ឥសិភាសិតោ ទេវតាភាសិតោ អត្ថូបសញ្ហិតោ ធម្មូបសញ្ហិតោ ។ ទេសេយ្យាតិ[១] បទេន ទេសេតិ បទេ បទេ អាបត្តិ ទុក្កដស្ស ។ អក្ខរាយ ទេសេតិ អក្ខរក្ខរាយ អាបត្តិ ទុក្កដស្ស ។

---

១ ឧប. បាឋ ថៃបរេត្ត មាតិកាយំ ឆន្ទីមាតព្វា ។





នោះបានក្រាបទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ គ្រានោះ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថា ក្នុងវេលានោះ រួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាត ដើម្បីឲ្យភិក្ខុសំដែងធម៌ ដល់មនុស្សឈឺមានឆត្រនៅក្នុងដៃបាន (ឥតមានទោស) ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺមានឆត្រនៅក្នុងដៃ ។

ដែលហៅថា ឆត្រ បានដល់ឆត្រ៣យ៉ាងគឺ ឆត្រដែលគេធ្វើដោយសំពត់មានពណ៌ស១ ឆត្រដែលគេធ្វើដោយកន្ទេល១ ឆត្រដែលគេធ្វើដោយស្លឹកឈើ១ (ឆត្រទាំង៣នេះ) ដែលគេចងឲ្យមានភាពមូល[១] ចងឲ្យជាប់មាំដោយឆ្អឹងឆត្រ[២] ។ ដែលហៅថា ធម៌ គឺធម៌ដែលព្រះពុទ្ធទ្រង់សំដែង សាវកសំដែង ឥសីសំដែង ទេវតាសំដែង ប្រកបដោយអត្ថជា ប្រកបដោយធម៌ ។ ត្រង់ពាក្យថា សំដែង គឺភិក្ខុសំដែងដោយបទ ត្រូវអាបត្តិទុក្កដ គ្រប់ៗបទ ។ ភិក្ខុសំដែងដោយអក្ខរៈ ត្រូវអាបត្តិទុក្កដ គ្រប់ៗអក្ខរៈ ។

---

១ ពីរន័យ ឆត្រនេះគេធ្វើឆ្អឹងទាំងអស់ឲ្យមូលជុំវិញគ្នា ហើយយកខ្សែចងក្បាលឆ្អឹងបណ្តោយចងភ្ជាប់ខាងលើ ។ ២ ឆត្រនេះគេធ្វើឆ្អឹងកណ្តាលឆត្រ និងទាំងខ្សែត្រង់កណ្តាលឲ្យមាំមាន គងខ្ទង់ (ឆ្អឹងស្មុក) ឈើស្រួចទំកបិទបាំង ។

ន ឆត្តបាណិស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច ឆត្តបាណិស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៦៧៨) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ទណ្ឌបាណិស្ស ធម្មំ ទេសេន្តិ ។ បេ ។ ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ទណ្ឌោ នាម មជ្ឈិមស្ស បុរិសស្ស ចតុហត្ថោ ទណ្ឌោ ។ តតោ ឧក្កដ្ឋោ អទណ្ឌោ ឱមកោ អទណ្ឌោ ។ ន ទណ្ឌបាណិស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច ទណ្ឌបាណិស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រនៅក្នុងដៃទេ ។ ភិក្ខុណាមួយ អាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានឆត្រនៅក្នុងដៃ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៦៧៨) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្ស មានដំបងនៅក្នុងដៃ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានដំបងនៅក្នុងដៃ ។

ដែលហៅថា ដំបង បានដល់ឈើដំបងប្រវែង ៤ ហត្ថមធ្យមបុរស ។ វែងជាង ៤ ហត្ថនោះ គឺមិនហៅថាដំបង ខ្លីជាង ៤ ហត្ថនោះ ក៏មិនហៅថាដំបងដែរ ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានដំបងនៅក្នុងដៃទេ ។ ភិក្ខុណាមួយ អាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានដំបងនៅក្នុងដៃ ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៧៨] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សត្ថបាណិស្ស ធម្មំ ទេសេន្តិ ។ បេ ។ ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

សត្ថំ នាម ឯកតោធារំ ឧភតោធារំ បហរណំ[១] ។ ន សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសេតព្វំ ។ យោ អនាទរិយំ បដិច្ច សត្ថបាណិស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៧៩] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ អាវុធបាណិស្ស ធម្មំ ទេសេន្តិ ។ បេ ។ ន អាវុធបាណិស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

---

១ បហរណន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។



[៤៧៨] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សមានគ្រឿងសស្ត្រានៅក្នុងដៃ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងសស្ត្រានៅក្នុងដៃ ។

គ្រឿងដែលសម្រាប់ប្រហារមានមុខមុតតែម្ខាង ឬមានមុខមុតទាំងពីរខាង ហៅថា គ្រឿងសស្ត្រា ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងសស្ត្រានៅក្នុងដៃទេ ។ ភិក្ខុណាមួយ ព្រោះសេចក្ដីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងសស្ត្រានៅក្នុងដៃ ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៧៩] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សមានគ្រឿងអាវុធនៅក្នុងដៃ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ មានគ្រឿងអាវុធនៅក្នុងដៃ ។

អារុឡ្ហំ ធាម ធាតោ វេលនស្សោ ។ ន បាទុការុ-ឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមិ ។ យោ អនាទរិយំ បដិច្ច បាទុការុឡ្ហស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

សុរុសុរុវគ្គោ ឆដ្ឋោ ។



ឈ្នាន់ជើងក្រពើ (ជួងជើងកែ) ឈ្នួញមាសជើងឈូក ហៅថា ស្បែកជើង ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ស្បែកជើង នៅក្នុងវិហារ ។ ភិក្ខុណា ប្រកាន់សេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ពាក់ស្បែកជើងនៅក្នុងវិហារ ត្រូវអាបត្តិទុក្កដ ។

អា. ដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទមានអនាបត្តិ ៧ យ៉ាង) គឺភិក្ខុមិនដឹង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

សុរុសុរុវគ្គទី ៦ ចប់ ។

# បាទុកាវគ្គោ

[៤៨០] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ បាទុការុឡ្ហស្ស ធម្មំ ទេសេន្តិ ។បេ។ ន បាទុការុឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ន បាទុការុឡ្ហស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច អក្កន្តស្ស វា បដិមុក្កស្ស វា ឱមុក្កស្ស វា អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៨១] សាវត្ថីនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឧបាហនារុឡ្ហស្ស ធម្មំ ទេសេន្តិ ។បេ។ ន ឧបាហនារុឡ្ហស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

# បាទុកាវគ្គ

[៤៨០] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ សំដែងធម៌ដល់មនុស្សពាក់ទ្រនាប់ជើង ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ទ្រនាប់ជើង ។

ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ទ្រនាប់ជើងទេ ។ ភិក្ខុណាមួយ ប្រព្រឹត្តសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺជាន់ទ្រនាប់ជើងក្តី ពាក់ក្តី ដោះបន្ទៀបកែងបន្តិចក្តី ត្រូវអាបត្តិទុក្កដ ។

វារៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទទៅខាងមុខក៏យ៉ាងនេះ) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៨១] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សពាក់ស្បែកជើង ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ស្បែកជើង ។

ន ឧបាហនារុឡ្ហស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច អក្កន្តស្ស វា បដិមុក្កស្ស វា ឱមុក្កស្ស វា អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៨៦) សាវត្ថិយំ និទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ យានគតស្ស ធម្មំ ទេសេន្តិ ។បេ។ ន យានគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

យានំ នាម វយ្ហំ រថោ សកដំ សន្ទមានិកា សិវិកា បាដង្កី ។ ន យានគតស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច យានគតស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។





ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺពាក់ស្បែកជើងទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺជាន់លើស្បែកជើងក្តី ពាក់ក្តី ដោះបង្ហើបកែងចេញក្តី ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៨៦) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សនៅលើយាន ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺនៅលើយានទេ ។

ដែលហៅថា យាន គឺសំពៅយាត្រ(១) រថ រទេះ រទេះក្រឿន(២) គ្រែស្នែង ទីនអង្រឹង ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺនៅលើយានទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺនៅលើយាន ត្រូវអាបត្តិទុក្កដ ។

---

១ អដ្ឋកថា [illegible] ។ ២ [illegible] ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៨៣) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ សយនគតស្ស ធម្មំ ទេសេន្តិ ។បេ។ ន សយនគតស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ន សយនគតស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច អន្តមសោ ឆមាយំបិ[១] និបន្នស្ស[២] អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៨៤) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បល្លត្ថិកាយ និសិន្នស្ស ធម្មំ ទេសេន្តិ ។បេ។ ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

---

១ ម. ឆមាយំ ។ ២ ម. យ. និបន្នស្ស សយនគតស្ស ។



ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៨៣) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្សដេកលើដំណេក ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដេកលើដំណេក ។

ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដេកលើដំណេកទេ ។ ភិក្ខុណា ព្រោះសេចក្ដីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ ដោយហោចទៅសូម្បីដេកនៅលើផែនដី ក៏ត្រូវអាបត្តិទុក្កដ ។

ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៨៤) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែងធម៌ដល់មនុស្ស អង្គុយត្រកោងជង្គង់ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺ អង្គុយត្រកោងជង្គង់ ។

ន បល្លត្ថិកាយ និសិន្នស្ស អគិលានស្ស ធម្មោ
ន ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច ហត្ថបល្លត្ថិ-
កាយ វា ទុស្សបល្លត្ថិកាយ វា និសិន្នស្ស អគិ-
លានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-
នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៨៩) សាវត្ថីនិទានំ ។ តេន ខោ បន
សមយេន ឆព្ពគ្គិយា ភិក្ខូ វេឋិតសីសស្ស ធម្មំ
ទេសេន្តិ ។ បេ ។ ន វេឋិតសីសស្ស អគិលានស្ស ធម្មំ
ទេសេស្សាមីតិ សិក្ខា ករណីយា ។

វេឋិតសីសោ នាម កេសន្តំ ន ទស្សាបេត្វា
វេឋិតោ ហោតិ ។ ន វេឋិតសីសស្ស អគិលានស្ស ធម្មោ
ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច វេឋិតសីសស្ស
អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស
គិលានស្ស កេសន្តំ វិវរាបេត្វា ទេសេតិ អាបទាសុ
ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយក្រសោបក្បាលជង្គង់
ទេ ។ ភិក្ខុណាមួយ ព្រោះសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺ
អង្គុយក្រសោបក្បាលជង្គង់ ដោយដៃក្តី អង្គុយក្រសោបក្បាលជង្គង់ដោយ
សំពត់ក្តី ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិន
ក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមាន
សេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៨៩) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុសំដែង
ធម៌ដល់មនុស្សរុំក្បាល ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តី
សិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺរុំក្បាល ។

ដែលហៅថា មនុស្សរុំក្បាល គឺសំដៅយកមនុស្សដែលរុំក្បាល
មិនឲ្យឃើញចុងសក់ ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺរុំ
ក្បាលទេ ។ ភិក្ខុណាមួយ ព្រោះសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្ស
គ្មានជម្ងឺរុំក្បាល ត្រូវអាបត្តិទុក្កដ ។

ការដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិន
ក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុបង្គាប់
មនុស្សនោះឲ្យបើកឈ្នួតក្បាលចុងសក់ចេញ ហើយទើបសំដែង ១
ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៨៦] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឱគុណ្ឋិតសីសស្ស ធម្មំ ទេសេន្តិ ។បេ។ ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ឱគុណ្ឋិតសីសោ នាម សសីសំ បារុតោ វុច្ចតិ ។ ន ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច ឱគុណ្ឋិតសីសស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស សីសំ វិវរាបេត្វា ទេសេតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៨៧] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឆមាយំ[១] និសីទិត្វា អាសនេ និសិន្នស្ស ធម្មំ ទេសេន្តិ ។បេ។ ន ឆមាយំ[២] និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

១-២ ម. ឆមាយ ។



[៤៨៦] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ សំដែងធម៌ដល់មនុស្សខ្ទប់ក្បាល ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនសំដែងធម៌ដល់មនុស្សគ្មានជម្ងឺខ្ទប់ក្បាល ។

ដែលហៅថា មនុស្សខ្ទប់ក្បាល គឺសំដៅយកមនុស្សដណ្តប់សំពត់ទ្រទាំងក្បាល ។ ភិក្ខុមិនត្រូវសំដែងធម៌ដល់មនុស្សគ្មានជម្ងឺខ្ទប់ក្បាលទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺខ្ទប់ក្បាល ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុបង្គាប់អោយគេបើកឈ្នួតក្បាលហើយទើបសំដែង ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុជាដើមបញ្ញត្តិ ១ ។

[៤៨៧] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ អង្គុយផ្ទាល់នឹងដី ហើយសំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនអង្គុយផ្ទាល់នឹងផែនដី ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយលើអាសនៈ ។

៤ ន ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច ឆមាយំ និសីទិត្វា អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៨៨] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស ធម្មំ ទេសេន្តិ ។បេ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស ធម្មំ ទេសេស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស ធម្មំ ទេសេថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា នីចេ អាសនេ និសីទិត្វា



ភិក្ខុមិនត្រូវអង្គុយផ្ទាល់នឹងផែនដី ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយនៅលើអាសនៈទេ ។ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ អង្គុយនៅលើផែនដី ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺអង្គុយនៅលើអាសនៈ ត្រូវអាបត្តិទុក្កដ ។

អ.ន. ដែលមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៨៨] សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយនៅលើអាសនៈខ្ពស់ ។ ភិក្ខុទាំងឡាយណា មានសេចក្ដីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្វគ្គិយភិក្ខុមិនសមបើនឹងអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈខ្ពស់សោះ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាពួកអ្នកទាំងឡាយអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈខ្ពស់ ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយមិនគួរនឹងអង្គុយ

ឧច្ចេ អាសនេ និសិន្នស្ស ធម្មំ ទេសេស្សន្តិ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ វិគរហិត្វា ធម្មិំ កថំ កត្វា ភិក្ខូ អាមន្តេសិ ។

(៤៨៤) ភូតបុព្វំ ភិក្ខវេ អញ្ញតរស្ស ឆវកស្ស[1] បជាបតិ គព្ភិនី អហោសិ ។ អថខោ ភិក្ខវេ សា ឆវកី[2] តំ ឆវកំ ឯតទវោច គព្ភិនីម្ហិ អយ្យបុត្ត ឥច្ឆាមិ អម្ពំ ខាទិតុន្តិ ។ នត្ថិ អម្ពំ អកាលោ អម្ពស្សាតិ ។ សចេ[3] ន លភិស្សាមិ មរិស្សាមីតិ ។ តេន ខោ បន សមយេន រញ្ញោ អម្ពោ ធុវផលោ ហោតិ ។ អថខោ ភិក្ខវេ សោ ឆវកោ យេន សោ អម្ពោ តេនុបសង្កមិ ឧបសង្កមិត្វា តំ អម្ពំ អភិរុហិត្វា និលីនោ អច្ឆិ ។ អថខោ ភិក្ខវេ រាជា បុរោហិតេន ព្រាហ្មណេន សទ្ធិំ យេន សោ អម្ពោ តេនុបសង្កមិ ឧបសង្កមិត្វា ឧច្ចេ អាសនេ និសីទិត្វា

១ ម. ឆ. ឆបកស្ស ។ ២ ម. ឆ. ឆបកី ។ ៣ សព្វាចេត្ត ឥទំ បោត្ថកេ ទិស្សតិ ។



លើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សអង្គុយលើអាសនៈខ្ពស់ទេ ម្នាលមោឃបុរសទាំងឡាយ អំពើដែលអ្នកធ្វើនេះមិនញុំាងជនទាំងឡាយដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លាឡើង ឬពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងដែរ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់បន្ទោសហើយ ទ្រង់ធ្វើធម្មីកថា ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ។

(៤៨៤) ម្នាលភិក្ខុទាំងឡាយ កាលពីដើមក្នុងក្រុងពារាណសី មានស្រីជាប្រពន្ធរបស់បុរសចណ្ឌាលម្នាក់ជាស្រីមានគភ៌ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះ ស្រីចណ្ឌាលនោះនិយាយពាក្យនេះនឹងបុរសចណ្ឌាលនោះថា បពិត្រអ្នកជាអយ្យបុត្រ ខ្ញុំមានគភ៌ហើយ ខ្ញុំចង់ស៊ីផ្លែស្វាយណាស់ ។ ឯបុរសនោះតបវិញថា ផ្លែស្វាយគ្មានទេ (ព្រោះ) កាលនេះមិនមែនជាកាលមានផ្លែស្វាយ ។ ប្រពន្ធនោះនិយាយថា បើខ្ញុំមិនបានផ្លែស្វាយទេ ខ្ញុំមុខជានឹងស្លាប់ (ពុំខានឡើយ) ។ គ្រានោះឯង មានដើមស្វាយរបស់ស្តេច (១ដើម) តែងមានផ្លែជាប់ជានិច្ច ។ ម្នាលភិក្ខុទាំងឡាយ សម័យនោះ បុរសចណ្ឌាលនោះក៏ចូលទៅកាន់ដើមស្វាយនោះ លុះចូលទៅដល់ហើយក៏ឡើងទៅពួនលើដើមស្វាយនោះ ។ ម្នាលភិក្ខុទាំងឡាយ វេលានោះឯង ស្តេចបានទ្រង់យាងចូលទៅកាន់ដើមស្វាយនោះជាមួយនឹងព្រាហ្មណ៍បុរោហិត លុះដល់ហើយក៏គង់លើអាសនៈដ៏ខ្ពស់

មន្តិ ឧរ៉ាយា បុណ្ណាតិ ។ អដ្ឋេតា ភិក្ខវេ គស្ស ចតោតស្ស ឯកឧបោសំ យាតំ អនន្តរោ អយំ កដា យក្ខេ យាំ ជាម ឧទ្ធ អាសវេ ទសឹតិក្ខា មន្តំ ឧរ៉ាយាបុណ្ណិស្សតិ អយក្ខ ព្រាហ្មណោ អនន្តរោ យក្ខេ យាំ ជាម ដេច អាសវេ ទសិតិក្ខា ឧទ្ធ អាសវេ ចិស័ន្តស្ស មន្តំ ភវេស្សតិ មហាញ្ញុម្ពិ អនន្តរោ យោយំ ឥន្ទិយា ការណា ភត្តា អម្ពុំ អបោកម្ម សព្វម៌ងំ ច ចរិតគន្តិ ។ គរុខ្មា ឋបំ ។

ឧតោ អម្ពុំ ច ជាចន្តិ ឧតោ ចម្ពុំ ច មសុប
យោភាយំ មន្តំ ភវេតិ យោពាចម្មេច ជ័យតិ ។
សាលិកំ ឱទនោ កុត្តា សុចិមំសុបសេចនោ[១]
ឥស្សា ឧម្មេ ច វត្តាម៌ ចម្មោ អភិយតិ វណ្ណិតោ

---

១ ម. សុបិមំសុបសេវតោ ។



ហើយគំរៀនខ្ញុំមន្ត ។ មាណពគិតតាំងឲ្យ (ព្រាហ្មណ៍ ឬសេចក្ដីល) ពោះមានរបស់ព្រឹក្សតំយាំងនៅ ស្ដេចណាតនឹងលើកសេចក្ដីស្រុះហើយ រៀនខ្ញុំមន្ត ស្ដេចនោះឯងនឹងទៅជាម្ចាស់ប្រកបដោយជម្ងឺឡើយ ។ មួយទៀត ព្រាហ្មណ៍ណាគង្វិយលើកសេចក្ដីតាម ហើយបង្រៀនមន្តដល់មនុស្ស ដែលគង្វិយលើកសេចក្ដីស្រុះ ព្រាហ្មណ៍នោះឯងនឹងទៅជាម្ចាស់ប្រកបដោយ ធម៌ដែរ ចំណែកខ្ញុំមានញ្ញដែលមកល្បួងផ្លែស្វាយរបស់ស្ដេច ព្រោះហេតុតែ ព្រោះ តញ្ញាតនោះឯងនឹងទៅជាម្ចាស់ប្រកបដោយធម៌ដែរ ឯខ្ញុំប្រព្រឹត្តនោះ ច្រឡំច្រៀតអស់ហើយ ។ ព្រះសេះតានិកថ្មូលហើយក៏លោតទេះ គំរដឹមស្វាយមកគង់ដីនោះឯង (ហើយពោលគាថា) ថា

ព្រាហ្មណ៍ណាបង្រៀនមន្ត (ដល់ស្ដេច) ក្ដី
ស្ដេចអង្គណារៀនមន្តរំងប្រកបដោយធម៌ក្ដី
ជនទាំងពីរនោះឈ្មោះថាមិនស្គាល់នូវហេតុ
ជនទាំងពីរនោះឈ្មោះថាមិនឃើញនូវផល ។

ព្រាហ្មណ៍ក៏ពោលគាថាតបវិញថា

(នែអ្នកចណ្ឌាល) ខ្ញុំបាននទទួលភាជនដោយតន្ទ្រី
ស្រូវសាលីដែលលាយដោយសាច់ដ៏ស្អាតរបស់ស្ដេច
(ជាចណ៌ង) ព្រោះហេតុនោះ ខ្ញុំនឹងប្រព្រឹត្ត

ធិរត្ថុ តំ ធនលាភំ យសលាភញ្ច ព្រាហ្មណ

យា វុត្តិ វិនិបាតេន អធម្មចរណេន វា ។

បព្វជ មហាព្រហ្មេ បចន្តញ្ញេបិ បាណិនោ

មា តំ អធម្មោ អាចរិតោ អស្មា កុម្ភមិវាភិទា ។

(៤៩០) តទាបិ មេ ភិក្ខវេ អមនាបា នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស មន្តេ វាចេតុំ កិមង្គំ បន ឯតរហិ ន អមនាបា ភវិស្សតិ នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស ធម្មំ ទេសេតុំ នេតំ ភិក្ខវេ អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។ វិគរហិត្វា ធម



ទៅក្នុងទីធ្លាក់ចុះទាបទេ (នៃទ្វិជាតិ)

ឬដោយការប្រព្រឹត្តអធម្មៈនៃពិសេសហើយ ។

ចប្បុរសណ្ហោ ឈ្មោះរំលាយជាតំបាញ

បពិត្រព្រាហ្មណ៍ ការដែលបានទ្រព្យ

នឹងបានយសបែបនោះ គួរតិះដៀលនៃជីវិត

(ជាធម្មតា) ម្យ៉ាងទៀត ការចិញ្ចឹមជីវិត

ដែលមិនប្រព្រឹត្តតាមធម៌ ជាហេតុនាំឲ្យធ្លាក់ចុះទៅក្នុង

អបាយ បពិត្រមហាព្រាហ្មណ៍ អ្នកឯងចូរចេញ

សូម្បីពួកសត្វដទៃក៏គង់នៅតែចំអិនបាយបរិភោគ (ដូចគ្នា)

អ្នកកុំប្រព្រឹត្តឲ្យខុសធម៌ទៅឡើយ បើអ្នកប្រព្រឹត្តខុសធម៌

ហើយ មុខជានឹងបែកធ្លាយដូចឆ្នាំងទឹកនឹងថ្មដូច្នេះ ។

[៤៩០] ម្នាលភិក្ខុទាំងឡាយ សូម្បីតែក្នុងគ្រានោះបុគ្គលអង្គុយលើអាសនៈទាបហើយបង្រៀនមន្តដល់បុគ្គលដែលអង្គុយលើអាសនៈខ្ពស់នោះ រមែងជាទីមិនគាប់ចិត្តដល់តថាគត នឹងនិយាយទៅថ្វីដល់បុគ្គលដែលអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់បុគ្គល ដែលអង្គុយលើអាសនៈខ្ពស់ ក្នុងកាលឥឡូវនេះ ក៏រឹតតែមិនជាទីគាប់ចិត្តតថាគតក្រៃពេក ម្នាលភិក្ខុទាំងឡាយ អំពើនេះមិនជាទីជ្រះថ្លាដល់ពួកជនដែល

ភិក្ខូ ។ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ន នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច នីចេ អាសនេ និសីទិត្វា ឧច្ចេ អាសនេ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

(៤៩១) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឋិតា និសិន្នស្ស ធម្មំ ទេសេន្តិ ។ បេ ។ ន ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ន ឋិតេន និសិន្នស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច ឋិតោ និសិន្នស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។



មិនគាប់ប្រែស្ដៅ ពួកភិក្ខុគួរនឹងបែងប្រែស្ដារ ហើយ ឲ្យការតែប្រែស្ដារឡើងវិញ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះ ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយលើអាសនៈខ្ពស់ ។

ភិក្ខុមិនគប្បីអង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយលើអាសនៈខ្ពស់ទេ ។ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ អង្គុយលើអាសនៈទាប ហើយសំដែងធម៌ដល់មនុស្សគ្មានជំងឺ អង្គុយលើអាសនៈខ្ពស់ ត្រូវអាបត្តិទុក្កដ ។

អនាបត្តិមិនត្រូវអាបត្តិ (គឺសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្រែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជំងឺ ១ ភិក្ខុមានសេចក្ដីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ។

(៤៩១) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុឈរសំដែងធម៌ដល់មនុស្សអង្គុយ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្ដីសិក្សាថា អាត្មាអញនឹងមិនឈរសំដែងធម៌ដល់មនុស្សគ្មានជំងឺដែលអង្គុយ ។

ភិក្ខុមិនត្រូវឈរសំដែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយទេ ។ ភិក្ខុណា អាស្រ័យសេចក្ដីមិនអើពើ ហើយឈរសំដែងធម៌ដល់មនុស្សគ្មានជំងឺអង្គុយនោះ ត្រូវអាបត្តិទុក្កដ ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៩២] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ បច្ឆតោ គច្ឆន្តា បុរតោ គច្ឆន្តស្ស ធម្មំ ទេសេន្តិ ។ បេ ។ ន បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។

ន បច្ឆតោ គច្ឆន្តេន បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៩៣] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្វគ្គិយា ភិក្ខូ ឧប្បថេន គច្ឆន្តា បថេន គច្ឆន្តស្ស ធម្មំ ទេសេន្តិ ។ បេ ។ ន ឧប្បថេន គច្ឆន្តោ បថេន គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេស្សាមីតិ សិក្ខា ករណីយា ។



ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនចេតនា ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៩២) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដើរខាងក្រោយ សំដែងធម៌ដល់មនុស្សដើរខាងមុខ ។ បេ ។ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនដើរខាងក្រោយ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរខាងមុខ ។

ភិក្ខុមិនត្រូវដើរខាងក្រោយ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរខាងមុខទេ ។ ភិក្ខុណាៗ អាស្រ័យសេចក្តីមិនអើពើ ដើរខាងក្រោយ ហើយសំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរខាងមុខ ត្រូវអាបត្តិទុក្កដ ។

ការៈដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនចេតនា ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៩៣) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សដើរតាមផ្លូវ ។ បេ ។ (ទ្រង់ត្រាស់ថា) ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អាត្មាអញនឹងមិនដើរក្រៅផ្លូវ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរតាមផ្លូវ ។

ន បច្ឆតោ គច្ឆន្តេន បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មោ ទេសេតព្វោ ។ យោ អនាទរិយំ បដិច្ច បច្ឆតោ គច្ឆន្តោ បុរតោ គច្ឆន្តស្ស អគិលានស្ស ធម្មំ ទេសេតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

## តយោ បកិណ្ណកា

(៤៩៦) សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឋិតា ឧច្ចារម្បិ បស្សាវម្បិ ករោន្តិ ។បេ។ ន ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករិស្សាមីតិ សិក្ខា ករណីយា ។

ន ឋិតេន អគិលានេន ឧច្ចារោ វា បស្សាវោ វា កាតព្វោ ។ យោ អនាទរិយំ បដិច្ច ឋិតោ អគិលានោ ឧច្ចារំ វា បស្សាវំ វា ករោតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលា-នស្ស អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។



ភិក្ខុមិនត្រូវដើរក្រោយ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរតាមមុខទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ ហើយដើរក្រោយ សំដែងធម៌ដល់មនុស្សគ្មានជម្ងឺដើរតាមមុខ ត្រូវអាបត្តិទុក្កដ ។

ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

## បកិណ្ណកៈ មាន ៣ សិក្ខាបទ

(៤៩៦) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ ឈរបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ។បេ។ ទ្រង់ត្រាស់ថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញគ្មានជម្ងឺនឹងមិនឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ។

ភិក្ខុគ្មានជម្ងឺមិនត្រូវឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈទេ ។ ភិក្ខុណាអាស្រ័យសេចក្តីមិនអើពើ គ្មានជម្ងឺហើយឈរបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ត្រូវអាបត្តិទុក្កដ ។

ករណីដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន ៧ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

[៤៩៥] សាវត្ថិនិទានំ ។ តេន ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ហរិតេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករោន្តិ ។បេ។ ន ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។

ន ហរិតេ អគិលានេន ឧច្ចារោ វា បស្សាវោ វា ខេឡោ វា កាតព្វោ ។ យោ អនាទរិយំ បដិច្ច ហរិតេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស អប្បហរិតេ កតោ ហរិតំ ឱត្ថរតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

[៤៩៦] តេន សមយេន ពុទ្ធោ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តេន



(៤៩៥) សាវត្ថីនិទាន ។ សម័យនោះឯង ពួកឆព្វគ្គិយភិក្ខុ បន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ លើស្មៅស្រស់ឬឈើស្រស់ ។ បេ ។ ទ្រង់ត្រាស់ថា ភិក្ខុនឹងប្រព្រឹត្តសេចក្តីសិក្សាថា អញនឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់ ។

ភិក្ខុគ្មានជម្ងឺមិនត្រូវបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់នឹងឈើស្រស់ទេ ។ ភិក្ខុណាគ្មានជម្ងឺតែមិនអើពើ ហើយបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់លើស្មៅស្រស់ ឬឈើស្រស់ ត្រូវអាបត្តិទុក្កដ ។

អាបត្តិមិនត្រូវដល់ភិក្ខុ (ក្នុងសិក្ខាបទនេះមាន ៨ យ៉ាង) គឺភិក្ខុមិនក្លែង ១ ភិក្ខុមិនមានស្មារតី ១ ភិក្ខុមិនដឹងខ្លួន ១ ភិក្ខុមានជម្ងឺ ១ ឧច្ចារៈ ឬបស្សាវៈ ឬទឹកមាត់ដែលភិក្ខុបន្ទោបង់ទៅលើទីដែលប្រាសចាកស្មៅស្រស់ ហើយហូរទៅត្រង់ទីដែលមានស្មៅស្រស់ ឬឈើស្រស់ ១ ភិក្ខុមានសេចក្តីអន្តរាយ ១ ភិក្ខុឆ្កួត ១ ភិក្ខុដើមបញ្ញត្តិ ១ ។

(៤៩៦) សម័យនោះ ព្រះពុទ្ធដ៏មានព្រះភាគ កាលទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ វេលានោះឯង

ខោ បន សមយេន ឆព្ពគ្គិយា ភិក្ខូ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករោន្តិ ។ មនុស្សា ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម សមណា សក្យបុត្តិយា ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករិស្សន្តិ សេយ្យថាបិ គិហី កាមភោគិនោតិ ។ អស្សោសុំ ខោ ភិក្ខូ តេសំ មនុស្សានំ ឧជ្ឈាយន្តានំ ខីយន្តានំ វិបាចេន្តានំ ។ យេ តេ ភិក្ខូ អប្បិច្ឆា ។បេ។ តេ ឧជ្ឈាយន្តិ ខីយន្តិ វិបាចេន្តិ កថំ ហិ នាម ឆព្ពគ្គិយា ភិក្ខូ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករិស្សន្តីតិ ។បេ។ សច្ចំ កិរ តុម្ហេ ភិក្ខវេ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករោថាតិ ។ សច្ចំ ភគវាតិ ។ វិគរហិ ពុទ្ធោ ភគវា កថំ ហិ នាម តុម្ហេ មោឃបុរិសា ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ ករិស្សថ នេតំ មោឃបុរិសា អប្បសន្នានំ វា បសាទាយ បសន្នានំ វា ភិយ្យោភាវាយ ។បេ។



ពួកឆព្ពគ្គិយភិក្ខុបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់លើទឹក ។ មនុស្សទាំងឡាយពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកសមណៈជាសក្យបុត្តម៉េចក៏បន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់លើទឹក ដូចជាពួកគ្រហស្ថអ្នកបរិភោគកាមគុណ ដូច្នោះ ។ ភិក្ខុទាំងឡាយបានឮមនុស្សទាំងនោះពោលទោស តិះដៀល បន្តុះបង្អាប់ ។ ភិក្ខុទាំងឡាយណាដែលមានសេចក្តីប្រាថ្នាតិច ។បេ។ ភិក្ខុទាំងនោះក៏ពោលទោស តិះដៀល បន្តុះបង្អាប់ថា ពួកឆព្ពគ្គិយភិក្ខុ ម៉េចក៏បន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់លើទឹកដូច្នេះ ។បេ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឮថាអ្នកទាំងឡាយបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់លើទឹក ពិតមែនឬ ។ ភិក្ខុទាំងនោះក្រាបទូលថា សូមទ្រង់មេត្តាប្រោស ពិតមែន ។ ព្រះពុទ្ធដ៏មានព្រះភាគទ្រង់បន្ទោសថា ម្នាលមោឃបុរសទាំងឡាយ អ្នកទាំងឡាយម៉េចក៏បន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់លើទឹកដូច្នេះ ម្នាលភិក្ខុទាំងឡាយ អំពើនេះ មិនមែនជាទីជ្រះថ្លានៃពួកជនដែលមិនទាន់ជ្រះថ្លា ឬទាំងពួកជនដែលជ្រះថ្លាហើយ ឲ្យកាន់តែជ្រះថ្លាឡើងទេ ។បេ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង

ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន ឧទកេ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។ ឯវញ្ចិទំ ភគវតា ភិក្ខូនំ សិក្ខាបទំ បញ្ញត្តំ ហោតិ ។

[៦៤៨] តេន ខោ បន សមយេន គិលានា ភិក្ខូ ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ កាតុំ កុក្កុច្ចាយន្តិ(១) ។ ភគវតោ ឯតមត្ថំ អារោចេសុំ ។ អថខោ ភគវា ឯតស្មឹ និទានេ ឯតស្មឹ បករណេ ធម្មឹ កថំ កត្វា ភិក្ខូ អាមន្តេសិ អនុជានាមិ ភិក្ខវេ គិលានេន ភិក្ខុនា ឧទកេ ឧច្ចារម្បិ បស្សាវម្បិ ខេឡម្បិ កាតុំ ។ ឯវញ្ច បន ភិក្ខវេ ឥមំ សិក្ខាបទំ ឧទ្ទិសេយ្យាថ ន ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករិស្សាមីតិ សិក្ខា ករណីយា ។

១ កុក្កុច្ចាយន្តា ឥតិ បាឋោ កត្ថចិ បោត្ថកេ ទិស្សតិ ។



ឡាយត្រូវសំដែងឡើងនូវសិក្ខាបទនេះ យ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញនឹងមិនបានបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ ដាក់លើទឹក ។ សិក្ខាបទនេះ ព្រះដ៏មានព្រះភាគ បានបញ្ញត្តចំពោះពួកភិក្ខុយ៉ាងនេះ ។

[៦៤៨] សម័យនោះឯង ភិក្ខុទាំងឡាយមានជម្ងឺកើតសេចក្តីរង្កៀស ការបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់លើទឹក ។ ភិក្ខុទាំងនោះ ក៏បានក្រាបបង្គំទូលសេចក្តីនុ៎ះចំពោះព្រះដ៏មានព្រះភាគ ។ ព្រោះនិទាននេះ ដំណើរនេះ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម្មីកថាគួរវេលានោះរួចទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកដោយព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យភិក្ខុដែលមានជម្ងឺ បន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ស្តោះទឹកមាត់ខ្លះ ដាក់លើទឹកបាន ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគប្បីសំដែងឡើងនូវសិក្ខាបទនេះយ៉ាងនេះថា ភិក្ខុគប្បីធ្វើសេចក្តីសិក្សាថា អញមិនមានជម្ងឺនឹងមិនបន្ទោបង់ឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ដាក់លើទឹក ។

ន ឧទកេ អគិលានេន[១] ឧច្ចារោ វា បស្សាវោ វា ខេឡោ វា កាតព្វោ ។ យោ អនាទរិយំ បដិច្ច ឧទកេ អគិលានោ ឧច្ចារំ វា បស្សាវំ វា ខេឡំ វា ករោតិ អាបត្តិ ទុក្កដស្ស ។

អនាបត្តិ អសញ្ចិច្ច អសតិយា អជានន្តស្ស គិលានស្ស ថលេ កតោ ឧទកំ ឱត្ថរតិ អាបទាសុ ឧម្មត្តកស្ស អាទិកម្មិកស្សាតិ ។

បាទុកាវគ្គោ សត្តមោ ។

---

១ ភិក្ខុនាតិ បទំ ឧភយេ ទិស្សតិ ។





ភិក្ខុគ្មានជម្ងឺមិនត្រូវបន្ទោបង់នូវឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ ដាក់លើទឹកទេ ។ ភិក្ខុណាគ្មានជម្ងឺ តែប្រើសេចក្តីមិនអើពើ ហើយបន្ទោបង់នូវឧច្ចារៈ ឬបស្សាវៈ ឬស្តោះទឹកមាត់ ដាក់លើទឹក ត្រូវអាបត្តិទុក្កដ ។

ភិក្ខុដែលមិនត្រូវអាបត្តិ (ក្នុងសិក្ខាបទនេះមាន៨យ៉ាង) គឺភិក្ខុមិនចេតនា១ ភិក្ខុមិនមានស្មារតី១ ភិក្ខុមិនដឹងខ្លួន១ ភិក្ខុមានជម្ងឺ១ ឧច្ចារៈ ឬបស្សាវៈ ឬទឹកមាត់ដែលភិក្ខុបន្ទោបង់ដាក់លើគោក ហើយហូរទៅក្នុងទឹក១ ភិក្ខុមានសេចក្តីអន្តរាយ១ ភិក្ខុឆ្កួត១ ភិក្ខុដើមបញ្ញត្តិ១ ។

បាទុកវគ្គទី ៧ ចប់ ។

## តស្សុទ្ទានំ(១)

បរិមណ្ឌលំ បដិច្ឆន្នំ
សុសំវុតោក្ខិត្តចក្ខុនា
ឧក្ខិត្តុជ្ជគ្ឃិកាប្បសទ្ទោ
តយោ ចេវ បចាលនា ។
ខម្ភោគុណ្ឋិតា ចេវ
ឧក្កុដិបល្លត្ថិកាយ ច
សក្កច្ចំ បត្តសញ្ញី ច
សមសូបសមតិត្តិកំ ។
សក្កច្ចំ បត្តសញ្ញី ច
សបទានំ សមសូបកំ
ថូបកតោ បដិច្ឆន្នំ

១ ឧ. ម. ហេតុការណ៍ ក្បួនគាថា ធន្ធ ។





## ចំនួនសិក្ខាបទក្នុងសេខិយវត្ត(១)នោះគឺ

បរិមណ្ឌលនិវាសន ១ បរិមណ្ឌលបារុបន ១ សុប្បដិច្ឆន្នគមន ១
សុប្បដិច្ឆន្ននិសីទន ១ សុសំវុតគមន ១ សុសំវុតនិសីទន ១
ឱក្ខិត្តចក្ខុគមន ១ ឱក្ខិត្តចក្ខុនិសីទន ១ ឧក្ខិត្តកគមន ១
ឧក្ខិត្តកនិសីទន ១ ឧជ្ជគ្ឃិកគមន ១ ឧជ្ជគ្ឃិកនិសីទន ១
អប្បសទ្ទគមន ១ អប្បសទ្ទនិសីទន ១ កាយប្បចាលកគមន ១
កាយប្បចាលកនិសីទន ១ ពាហុប្បចាលកគមន ១
ពាហុប្បចាលកនិសីទន ១ សីសប្បចាលកគមន ១
សីសប្បចាលកនិសីទន ១ ខម្ភកតគមន ១ ខម្ភកតនិសីទន ១
ឱគុណ្ឋិតគមន ១ ឱគុណ្ឋិតនិសីទន ១ ឧក្កុដិកគមន ១
បល្លត្ថិកនិសីទន ១ សក្កច្ចបិណ្ឌបាតបដិគ្គហណ ១
បត្តសញ្ញីបដិគ្គហណ ១ សមសូបកបដិគ្គហណ ១
សមតិត្តិកបដិគ្គហណ ១ សក្កច្ចបិណ្ឌបាតភុញ្ជន ១
បត្តសញ្ញីបិណ្ឌបាតភុញ្ជន ១ សបទានបិណ្ឌបាតភុញ្ជន ១

១ ព្រះវិន័យបិដក [illegible] មិនមានគាថាប្រាប់ចំនួនសិក្ខាបទក្នុងសេខិយកណ្ឌនេះ ដូចក្នុងកណ្ឌឯទៀតៗ ខាងដើមនោះទេ ឯកណ្ឌខាងដើម គឺបារាជិកកណ្ឌក្តី [illegible] ក្តី ព្រោះ [illegible] ក៏សុទ្ធតែមានគាថាប្រាប់ចំនួនសិក្ខាបទទាំងអស់ [illegible] កណ្ឌនេះជាកណ្ឌចុងបំផុត [illegible] ចំនួនសិក្ខាបទ [illegible] ក្នុងសេខិយកណ្ឌ ។

សេក្ខិយកណ្ឌ ឧទ្ទានគាថា

[illegible]



សេក្ខិយកណ្ឌ ឧទ្ទានគាថា

| | |
|---|---|
| សមសូបកបិណ្ឌបាតកុរុន្ទ ១ | ឧច្ចំសាលាមជ្ឈឧក្កុរុន ១ |
| សូបព្យញ្ជនៈគាទឧបដ្ឋានទន ១ | សូបោទនវិញ្ញត្តិ ១ |
| ឧជ្ឈានសញ្ញីមហាកោលាកន ១ | នាតិមហន្តកពលគហណា ១ |
| បរិមណ្ឌលកោលាបគហណា ១ | នអនាហដេ ក្ខាររិវណា ១ |
| នសព្វហត្ថបក្ខិបន ១ | នសកពឡព្យាហារណា ១ |
| នបិណ្ឌុក្ខេបកកុរុន ១ | នកពឡាវច្ឆេទក ១ |
| នអវគណ្ឌការកុរុន ១ | នហត្ថនិទ្ធុនកកុរុន ១ |
| នសិត្ថាវការកកុរុន ១ | នជិវ្ហានិច្ឆារកកុរុន ១ |
| នចបុចបុការកកុរុន ១ | នសុរុសុរុការកកុរុន ១ |
| នហត្ថនិល្លេហកកុរុន ១ | នបត្តនិល្លេហកកុរុន ១ |
| នឱដ្ឋនិល្លេហកកុរុន ១ | នសាមិសបានីយថាលកា ១ |
| នសសិត្ថកឆឌ្ឌន ១ | នឆត្តបាណិរោសន ១ |
| នទណ្ឌបាណិរោសន ១ | នសត្ថបាណិរោសន ១ |
| នអាវុធបាណិរោសន ១ | នបាទុការូឡ្ហរោសន ១ |
| នឧបាហនរោសន ១ | នយានគតរោសន ១ |
| នសយនគតរោសន ១ | នបល្លត្ថិករោសន ១ |
| នវេឋិតសីសរោសន ១ | នឱគុណ្ឋិតសីសរោសន ១ |

ឆមា នីចាសនេ ឋានេ

បច្ឆតោ ឧប្បថេន ច

ឋិតកោ ច ធាតុំ

ហរិតេ ឧទកម្ហិ ជាតំ ។

បរិមណ្ឌលសុត្តន្តិកា

ទុក្ខំ សក្កាទ្ធ ពាហា

ឯ សុរាសុរ ចាតុកា

កោ ឆ្លោ សត្តាក្តិយា ។

ចញ្ញត្តា អកិលោវេ

គោតាមច យសសន្ធិ

សាវេត សិក្ខាបទ្ធាយ

បញ្ញាសន្តំសេក្ខិយាតិ ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ សេក្ខិយា ធម្មា ។ តត្ថា-យស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

សេក្ខិយកណ្ឌំ និដ្ឋិតំ ។





នឆមាទេសនា ១ នទីចាសនទេសនា ១

នឋិតទេសនា ១ នបច្ឆតោទេសនា ១

នឧប្បថេនទេសនា ១ នឋិតកោ ១

នហរិតេករណោ ១ នឧទកករណោ ១ ។

វត្តទាំង ៧ នេះគឺ បរិមណ្ឌលវត្ត ១ នឧជ្ជគ្ឃិកវត្ត ១

នខម្ពុកតវត្ត ១ នសកពលវត្ត ១ នាហជវត្ត ១

នសុរុសុរុវត្ត ១ នបាទុកាវត្ត ១ ។ សេក្ខិយវត្តទាំង

៧៥ សិក្ខាបទ (នេះ) ព្រះតថាគតទ្រង់ទេសនាដោយសង្ខេបនៅត្រៃលែងទាំងនោះ បានបញ្ញត្តហើយ ដើម្បីឲ្យពួកសាវកសិក្សាតាម ។

បពិត្រលោកដ៏មានអាយុទាំងឡាយ វត្តដែលគប្បីសិក្សាទាំងឡាយ ខ្ញុំបានសំដែងឡើងហើយ ។ ខ្ញុំសូមសួរអស់លោកដ៏មានអាយុក្នុងសេក្ខិយវត្តទាំងនោះ លោកទាំងឡាយបរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់ពីរដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសួរជាគំរប់បីដងផង លោកទាំងឡាយជាអ្នកបរិសុទ្ធហើយឬ អស់លោកដ៏មានអាយុជាអ្នកបរិសុទ្ធក្នុងសេក្ខិយវត្តទាំងនេះហើយ ព្រោះហេតុនោះបានជាអស់លោកស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវសេចក្ដីបរិសុទ្ធនេះ ដោយអាការស្ងៀមនៅយ៉ាងនេះ ។

សេក្ខិយកណ្ឌ ចប់ ។

## អធិករណសមថា ធម្មា

[៤៩៥] ឥមេ ខោ បនាយស្មន្តោ សត្ត អធិករណសមថា ធម្មា ឧទ្ទេសំ អាគច្ឆន្តិ ។ ឧប្បន្នុប្បន្នានំ អធិករណានំ សមថាយ វូបសមាយ សម្មុខាវិនយោ ទាតព្វោ សតិវិនយោ ទាតព្វោ អមូឡ្ហវិនយោ ទាតព្វោ បដិញ្ញាយ ការេតព្វំ យេភុយ្យសិកា តស្សបាបិយសិកា តិណវត្ថារកោតិ ។

## ពួកធម៌សម្រាប់រម្ងាប់នូវអធិករណៈ

[៤៩៥] បពិត្រលោកដ៏មានអាយុទាំងឡាយ ពួកធម៌ ៧ យ៉ាង សម្រាប់រម្ងាប់នូវអធិករណៈនេះ តែងមកកាន់ឧទ្ទេស (គឺការដែលសំដែងឡើង) ។ (ធម៌ ៧ យ៉ាងនោះគឺ) សង្ឃត្រូវឲ្យសម្មុខាវិន័យ(១) ១ សង្ឃត្រូវឲ្យសតិវិន័យ(២) ១ សង្ឃត្រូវឲ្យអមូឡ្ហវិន័យ(៣) ១ សង្ឃត្រូវវិនិច្ឆ័យកាត់ទោសតាមពាក្យប្តេជ្ញារបស់ភិក្ខុអ្នកឆ្លើយ ១ សង្ឃត្រូវវិនិច្ឆ័យតាមពាក្យនៃភិក្ខុច្រើនជាប្រមាណ ១ សង្ឃត្រូវរុះទោសតាមកម្មរបស់ភិក្ខុដែលប្រព្រឹត្តលាមក(៤) ១ សង្ឃត្រូវវិនិច្ឆ័យឲ្យពួកភិក្ខុដែលវិវាទគ្នា សម្រេចសម្រួលអត់ទោសគ្នាទៅវិញទៅមក ដូចគេគ្របប្រក់លាមកដោយស្មៅ ដើម្បីរម្ងាប់រម្ងាប់នូវអធិករណៈ (ទាំងនោះ) ដែលកើតឡើងហើយ ១ ។

---

១ សង្ឃត្រូវវិនិច្ឆ័យចំពោះមុខសង្ឃ ចំពោះមុខធម៌ ចំពោះមុខវិន័យ ចំពោះមុខបុគ្គល ទើបរម្ងាប់អធិករណៈនោះបាន ដើម្បីរម្ងាប់អធិករណៈទាំងនោះ ហៅថា សម្មុខាវិន័យ ។ ២ សង្ឃត្រូវឲ្យសតិវិន័យដល់ភិក្ខុដែលបរិសុទ្ធចាកអាបត្តិមានសេចក្ដីតាំងមាំ ដោយញត្តិចតុត្ថកម្មវាចា ។ ៣ សង្ឃត្រូវឲ្យអមូឡ្ហវិន័យដល់ភិក្ខុដែលជាឆ្កួតហើយ ដោយញត្តិចតុត្ថកម្មវាចា ដើម្បីមិនឲ្យភិក្ខុណាមួយចោទភិក្ខុនោះដោយអាបត្តិទាំងឡើយ ។ ៤ ភិក្ខុប្រព្រឹត្តលាមក គឺក្នុងវេលាចោទដោយអាបត្តិក្នុងកណ្ដាលជំនុំសង្ឃ ត្រូវបដិសេធហើយប្រែប្រួលពាក្យ សង្ឃត្រូវធ្វើតស្សបាបិយសិកាកម្មដល់ភិក្ខុនោះ ដោយញត្តិចតុត្ថកម្មវាចា លំដាប់ភិក្ខុនោះត្រូវប្រព្រឹត្តវត្ត មានមិនត្រូវឲ្យឧបសម្បទា ជាដើម ។ (ប្រែដោយកិច្ចសង្ខេប សមន្តបាសាទិកា) ។

ឧទ្ទិដ្ឋា ខោ អាយស្មន្តោ សត្ត អធិករណសមថា ធម្មា ។ តត្ថាយស្មន្តេ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា ទុតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា តតិយម្បិ បុច្ឆាមិ កច្ចិត្ថ បរិសុទ្ធា បរិសុទ្ធេត្ថាយស្មន្តោ តស្មា តុណ្ហី ។ ឯវមេតំ ធារយាមីតិ ។

អធិករណសមថា ធម្មា និដ្ឋិតា ។

(៦៤៤) ឧទ្ទិដ្ឋំ ខោ អាយស្មន្តោ និទានំ ឧទ្ទិដ្ឋា ចត្តារោ បារាជិកា ធម្មា ឧទ្ទិដ្ឋា តេរស សង្ឃាទិសេសា ធម្មា ឧទ្ទិដ្ឋា ទ្វេ អនិយតា ធម្មា ឧទ្ទិដ្ឋា តឹស និស្សគ្គិយា បាចិត្តិយា ធម្មា ឧទ្ទិដ្ឋា ទ្វេនវុតិ បាចិត្តិយា ធម្មា ឧទ្ទិដ្ឋា ចត្តារោ បាដិទេសនីយា ធម្មា ឧទ្ទិដ្ឋា



បពិត្រលោកដ៏មានអាយុទាំងឡាយ ធម៌សម្រាប់រម្ងាប់អធិករណៈ ទាំង៧យ៉ាងនេះ ខ្ញុំបានសំដែងរួចហើយ ។ ខ្ញុំសូមសួរលោកដ៏មានអាយុក្នុងធម៌៧យ៉ាងនោះ លោកជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរជាគំរប់ពីរដងផង លោកជាអ្នកបរិសុទ្ធហើយឬ ខ្ញុំសូមសួរជាគំរប់បីដងផង លោកជាអ្នកបរិសុទ្ធហើយឬ លោកដ៏មានអាយុជាអ្នកបរិសុទ្ធក្នុងធម៌ទាំងនោះហើយ ហេតុនោះបានជាលោកស្ងៀមនៅ ។ ខ្ញុំសូមចាំទុកនូវរឿងនេះដោយអាការស្ងៀមនៅយ៉ាងនេះ ។

ធម៌សម្រាប់រម្ងាប់នូវអធិករណៈ ចប់ ។

(៦៤៤) បពិត្រលោកដ៏មានអាយុទាំងឡាយ និទានខ្ញុំសំដែងឡើងហើយ អាបត្តិបារាជិក៤ ខ្ញុំសំដែងឡើងហើយ អាបត្តិសង្ឃាទិសេស១៣ ខ្ញុំសំដែងឡើងហើយ អនិយតសិក្ខាបទ២ ខ្ញុំសំដែងឡើងហើយ អាបត្តិនិស្សគ្គិយបាចិត្តិយ ៣០ ខ្ញុំសំដែងឡើងហើយ អាបត្តិបាចិត្តិយ ៩២ ខ្ញុំសំដែងឡើងហើយ អាបត្តិបាដិទេសនីយៈ ៤ ខ្ញុំសំដែងឡើងហើយ

## ឧទ្ទានគាថា

សេក្ខិយា ធម្មា ឧទ្ទិដ្ឋា សត្ត អធិករណសមថា ធម្មា ។ ឯត្តកំ តស្ស ភគវតោ សុត្តាគតំ សុត្តបរិយាបន្នំ អន្វឌ្ឍមាសំ ឧទ្ទេសំ អាគច្ឆតិ ។ តត្ថ សព្វេហេវ សមគ្គេហិ សម្មោទមានេហិ អវិវទមានេហិ សិក្ខិតព្វន្តិ ។

មហាវិភង្គោ និដ្ឋិតោ ។

---



## ឧទ្ទានគាថា

សេក្ខិយវត្តខ្ញុំសំដែងឡើងហើយ ធម៌សម្រាប់រម្ងាប់អធិករណៈមាន ៧ យ៉ាង ខ្ញុំក៏សំដែងឡើងហើយ ។ សិក្ខាបទមានប្រមាណប៉ុណ្ណេះ របស់ព្រះដ៏មានព្រះភាគនោះ មកហើយក្នុងសូត្រ (បាតិក) រាប់បញ្ចូលហើយក្នុងសូត្រ តែងមកកាន់ឧទ្ទេស (គឺការសំដែងបាតិមោក្ខ) រាល់ៗ កន្លះខែ ។ អស់លោកគប្បីតែងព្រមព្រៀងគ្នា គប្បីរីករាយនឹងគ្នា កុំវិវាទគ្នា គប្បីសិក្សា ក្នុងសិក្ខាបទទាំងនោះចុះ ។

មហាវិភង្គ ចប់ ។

លេខទំព័រ

សិក្ខាបទទី ៦ ១

និទានឆព្វគ្គិយភិក្ខុ. . . . . . . . . . . . . . . . . . . . . . . . . . 〃
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ. . . . . . . . . . . . . . . . . . ២
បទភាជនីយ . . . . . . . . . . . . . . . . . . . . . . . . ៣
ភាគដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . . . ៤

សិក្ខាបទទី ៧ ៥

និទានសត្តរសវគ្គិយភិក្ខុ . . . . . . . . . . . . . . . . . . . . . . 〃
សេចក្តីបញ្ញត្តិ . . . . . . . . . . . . . . . . . . . . . . ៦
សិក្ខាបទវិភង្គ. . . . . . . . . . . . . . . . . . . . . . . . . . ៨
បទភាជនីយ . . . . . . . . . . . . . . . . . . . . . . ៩
ភាគដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . . ១០

សិក្ខាបទទី ៨ ១១

និទានភិក្ខុ ៦ រូប . . . . . . . . . . . . . . . . . . . . . . . . . . 〃
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ . . . . . . . . . . . . . . . . . . ១២
បទភាជនីយ. . . . . . . . . . . . . . . . . . . . . . . . . . . ១៣
ភាគដែលមិនត្រូវអាបត្តិ . . . . . . . . . . . . . . . . . . . . . . ១៤

សិក្ខាបទទី ៩ ១៥

និទានឧទាយីភិក្ខុ. . . . . . . . . . . . . . . . . . . . . . . . 〃
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ. . . . . . . . . . . . . . . . . . . . ១៦

លេខទំព័រ

បទភាជនីយ ........ ១៨
វារៈដែលមិនត្រូវអាបត្តិ ........ ១៩

សិក្ខាបទទី ១០ ........ ២០

និទានភិក្ខុស្រុកអាឡវីចាក់ទឹកស្រោច ........ [illegible]
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ២០
វារៈដែលមិនត្រូវអាបត្តិ ........ ២២
ឧទ្ទាននៃភូតគាមវគ្គ ........ ២៣

ឱវាទវគ្គ សិក្ខាបទទី ១ ........ ២៤

និទានឆព្វគ្គិយភិក្ខុ ........ [illegible]
ការសន្មតិភិក្ខុឲ្យទៅឲ្យឱវាទដល់ភិក្ខុនី ........ ២៦
សេចក្តីបញ្ញត្តិ ........ ២៧
ការសន្មតិភិក្ខុដែលប្រកបដោយអង្គ ៨ ប្រការឲ្យជាអ្នកឲ្យឱវាទភិក្ខុនី ........ ៣០
សិក្ខាបទវិភង្គ ........ ៣១
គរុធម៌ ៨ ប្រការ ........ ៣៣
បទភាជនីយ ........ ៣៤
វារៈដែលមិនត្រូវអាបត្តិ ........ ៣៥

សិក្ខាបទទី ២ ........ ៣៨

និទានព្រះចូឡបន្ថក ........ [illegible]
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៤២
វារៈដែលមិនត្រូវអាបត្តិ ........ ៤៣





លេខទំព័រ

សិក្ខាបទទី ៣ ........ ៤៤

និទានឆព្វគ្គិយភិក្ខុ ........ [illegible]
សេចក្តីបញ្ញត្តិជាដំបូង ........ ៤៥
និទានព្រះមហាបជាបតីគោតមី ........ ៤៦
សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ ........ ៤៧
បទភាជនីយ ........ ៤៨
វារៈដែលមិនត្រូវអាបត្តិ ........ ៤៩

សិក្ខាបទទី ៤ ........ ៥០

និទានឆព្វគ្គិយភិក្ខុ ........ [illegible]
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៥១
វារៈដែលមិនត្រូវអាបត្តិ ........ ៥៣

សិក្ខាបទទី ៥ ........ ៥៤

និទានភិក្ខុមួយរូបត្រាច់ទៅបិណ្ឌបាត ........ [illegible]
សេចក្តីបញ្ញត្តិជាដំបូង ........ ៥៥
សេចក្តីបញ្ញត្តិជាបន្ទាប់ ........ ៥៦
សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៥៧
វារៈដែលមិនត្រូវអាបត្តិ ........ ៥៨

សិក្ខាបទទី ៦ ........ ៥៩

និទានឧទាយិភិក្ខុ ........ [illegible]
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ៦០
បទភាជនីយ និងវារៈដែលមិនត្រូវអាបត្តិ ........ ៦២

លេខទំព័រ

## សិក្ខាបទទី ៧ ៦៣

និទានបុគ្គលិយភិក្ខុ ..... ២
សេចក្តីបញ្ញត្តិជាដំបូង ..... ៦៥
សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ ..... ៦៦
បទភាជនីយ ..... ៦៧
ភារៈដែលមិនត្រូវអាបត្តិ ..... ៦៨

## សិក្ខាបទទី ៨ ៦៩

និទានបុគ្គលិយភិក្ខុ ..... ២
សេចក្តីបញ្ញត្តិជាដំបូង ..... ៧០
សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ ..... ៧១
បទភាជនីយ ..... ៧២
ភារៈដែលមិនត្រូវអាបត្តិ ..... ៧៣

## សិក្ខាបទទី ៩ ៧៥

និទានឧបនន្ទភិក្ខុ ..... ២
សេចក្តីបញ្ញត្តិជាដំបូង ..... ៧៦
សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ ..... ៧៧
បទភាជនីយ ..... ៧៨
ភារៈដែលមិនត្រូវអាបត្តិ ..... ៧៩

## សិក្ខាបទទី ១០ ៨០

និទានទេវទត្តភិក្ខុ ..... ៣
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ..... ៨១





លេខទំព័រ

បទភាជនីយ និងភារៈដែលមិនត្រូវអាបត្តិ ..... ៨២
ទានដែលអាចវត្ត ..... ៨៣

## ភោជនវគ្គ បឋមសិក្ខាបទ ៨៥

និទានបុគ្គលិយភិក្ខុ ..... ២
សេចក្តីបញ្ញត្តិជាដំបូង និងនិទានព្រះសារីបុត្តត្ថេរ ..... ៨៦
សេចក្តីបញ្ញត្តិជាបន្ទាប់ និងបទភាជនីយ ..... ៨៧
ភារៈដែលមិនត្រូវអាបត្តិ ..... ៨៨

## សិក្ខាបទទី ៦ ៨៩

និទានទេវទត្តភិក្ខុ ..... ៣
បឋមបញ្ញត្តិ និងបឋមានុប្បញ្ញត្តិ ..... ៩០
ទុតិយានុប្បញ្ញត្តិ ..... ៩១
តតិយានុប្បញ្ញត្តិ ..... ៩២
ចតុត្ថានុប្បញ្ញត្តិ ..... ៩៣
បញ្ចមានុប្បញ្ញត្តិ ..... ៩៥
ឆដ្ឋានុប្បញ្ញត្តិ ..... ៩៨
សត្តមានុប្បញ្ញត្តិ ..... ៩៧
បទភាជនីយ និងភារៈដែលមិនត្រូវអាបត្តិ ..... ៩៩

## សិក្ខាបទទី ៣ ១០០

និទានបុរសធ្វើការម្នាក់ជាមនុស្សទ័លក្រ ..... ១
បឋមបញ្ញត្តិ ..... ១០៣
និទានភិក្ខុទ្រុបមានទឹក និងបឋមានុប្បញ្ញត្តិ ..... ១០៦

លេខទំព័រ

ទុតិយបញ្ញត្តិ ... ១០៥

តតិយបញ្ញត្តិ ... ១០៦

និយាយពីភិក្ខុណាឲ្យភិក្ខុណីសាត់រក្សាដែលគេមិនឲ្យជ្រួត ឲ្យដល់ភិក្ខុឯទៀត និង

សិក្ខាបទវិភង្គ ... ១០៧

បទភាជនីយ ... ១០៨

វារៈដែលមិនត្រូវអាបត្តិ ... ១០៩

សិក្ខាបទទី ៤ ... ១១០

និទានមហាសិក្ខាមាតារបស់តាងការណា ... ក

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ... ១១៤

បទភាជនីយ ... ១១៦

វារៈដែលមិនត្រូវអាបត្តិ ... ១១៧

សិក្ខាបទទី ៥ ... ១១៨

និទានភិក្ខុព្រើសខ្សោ ... ក

សេចក្តីបញ្ញត្តិជាដំបូង ... ១១៩

សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ ... ១២០

បទភាជនីយ ... ១២៣

វារៈដែលមិនត្រូវអាបត្តិ ... ១២៤

សិក្ខាបទទី ៦ ... ១២៥

និទានភិក្ខុពីររូបដើរផ្លូវឆ្ងាយ ... ក

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ... ១២៧



លេខទំព័រ

បទភាជនីយ ... ១២៩

វារៈដែលមិនត្រូវអាបត្តិ ... ១៣០

សិក្ខាបទទី ៧ ... ១៣១

និទានសត្តរសវគ្គិយភិក្ខុ ... ក

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ... ១៣២

បទភាជនីយ ... ១៣៣

វារៈដែលមិនត្រូវអាបត្តិ ... ១៣៤

សិក្ខាបទទី ៨ ... ១៣៥

និទានព្រះឧបនន្ទសក្យបុត្រ ... ក

សេចក្តីបញ្ញត្តិ ... ១៣៦

សិក្ខាបទវិភង្គ និងបទភាជនីយ ... ១៣៧

វារៈដែលមិនត្រូវអាបត្តិ ... ១៣៨

សិក្ខាបទទី ៩ ... ១៣៩

និទានឆព្វគ្គិយភិក្ខុ ... ក

សេចក្តីបញ្ញត្តិជាដំបូង ... ១៤០

សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ ... ១៤១

បទភាជនីយ ... ១៤២

វារៈដែលមិនត្រូវអាបត្តិ ... ១៤៤

សិក្ខាបទទី ១០ ... ១៤៥

និទានភិក្ខុ ១ រូបជាអ្នកប្រើត្រៃចីវរក្រឡាសរបស់គ្រហ៍យ៉ាង ... ក

សេចក្តីបញ្ញត្តិជាដំបូង និងសេចក្តីបញ្ញត្តិជាបន្ទាប់ ... ១៤៦

លេខទំព័រ

សិក្ខាបទវិភង្គ ........ ១៤៦
បទភាជនីយៈ និងការដែលមិនត្រូវអាបត្តិ ........ ១៤៧
ឧទ្ទាននៃភោជនវគ្គ ........ ១៤៩

អចេលកវគ្គ សិក្ខាបទទី ១ ........ ១៥០

និទានព្រះអានន្ទដ៏មានអាយុ ........ „
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៥៣
បទភាជនីយ ........ ១៥៤
ការដែលមិនត្រូវអាបត្តិ ........ ១៥៥

សិក្ខាបទទី ២ ........ ១៥៦

និទានព្រះឧបនន្ទសក្យបុត្រ ........ „
សេចក្ដីបញ្ញត្តិ ........ ១៥៧
សិក្ខាបទវិភង្គ ........ ១៥៨
បទភាជនីយ ........ ១៥៩
ការដែលមិនត្រូវអាបត្តិ ........ ១៦០

សិក្ខាបទទី ៣ ........ ១៦១

និទានព្រះឧបនន្ទសក្យបុត្រ ........ „
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៦៣
បទភាជនីយ និងការដែលមិនត្រូវអាបត្តិ ........ ១៦៤

សិក្ខាបទទី ៤ ........ ១៦៥

និទានព្រះឧបនន្ទសក្យបុត្រ ........ „
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៦៦



លេខទំព័រ

បទភាជនីយ ........ ១៦៧
ការដែលមិនត្រូវអាបត្តិ ........ ១៦៨

សិក្ខាបទទី ៥ ........ ១៦៩

និទានព្រះឧបនន្ទសក្យបុត្រ ........ „
សេចក្ដីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ១៧០
បទភាជនីយ ........ ១៧១
ការដែលមិនត្រូវអាបត្តិ ........ ១៧២

សិក្ខាបទទី ៦ ........ ១៧៣

និទានព្រះឧបនន្ទសក្យបុត្រ ........ „
សេចក្ដីបញ្ញត្តិជាដំបូង ........ ១៧៥
សេចក្ដីបញ្ញត្តិជាបន្ទាប់ ទី ១ និង ទី ២ ........ ១៧៦
សេចក្ដីបញ្ញត្តិជាបន្ទាប់ ទី ៣ ........ ១៧៨
សេចក្ដីបញ្ញត្តិជាបន្ទាប់ ទី ៤ និងសិក្ខាបទវិភង្គ ........ ១៧៩
បទភាជនីយ ........ ១៨០
ការដែលមិនត្រូវអាបត្តិ ........ ១៨២

សិក្ខាបទទី ៧ ........ ១៨៣

និទានមហានាមសក្យ ........ „
សេចក្ដីបញ្ញត្តិ សិក្ខាបទវិភង្គ និងបវារណា ៤ យ៉ាង ........ ១៨៤
បទភាជនីយ ........ ១៨៩
ការដែលមិនត្រូវអាបត្តិ ........ ១៩០

លេខទំព័រ


## សិក្ខាបទទី ៨ ៥៩៤

និទានវត្ថុភិក្ខុ .......... ក
សេចក្តីបញ្ញត្តិជាដំបូង .......... ៥៩៣
សេចក្តីបញ្ញត្តិជាបន្ទាប់ និងសិក្ខាបទវិភង្គ .......... ៥៩៦
បទភាជនីយ .......... ៥៩៥
វារៈដែលមិនត្រូវអាបត្តិ .......... ៥៩៦

## សិក្ខាបទទី ៩ ៥៩៧

និទានវត្ថុភិក្ខុ .......... ក
សេចក្តីបញ្ញត្តិជាដំបូង សិក្ខាបទវិភង្គ និងបទភាជនីយ .......... ៥៩៨
វារៈដែលមិនត្រូវអាបត្តិ .......... ៥៩៩

## សិក្ខាបទទី ១០ ៦០០

និទានវត្ថុភិក្ខុ .......... ក
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ .......... ៦០១
បទភាជនីយ .......... ៦០២
វារៈដែលមិនត្រូវអាបត្តិ និងឧទ្ទាននៃបារាជិកកណ្ឌ .......... ៦០៣

## សង្ឃាទិសេស សិក្ខាបទទី ១ ៦០៦

និទានវត្ថុឈ្មោះសេយ្យសកៈ និងឃ្លាសង្ខេប .......... ក
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ .......... ៦០៧
វារៈដែលមិនត្រូវអាបត្តិ .......... ៦០៩




លេខទំព័រ


## សិក្ខាបទទី ២ ៦១០

និទានវត្ថុភិក្ខុ និងសេចក្តីបញ្ញត្តិ .......... ក
សិក្ខាបទវិភង្គ និងបទភាជនីយ .......... ៦១២
វារៈដែលមិនត្រូវអាបត្តិ .......... ៦១៣

## សិក្ខាបទទី ៣ ៦១៦

និទានវត្ថុភិក្ខុ .......... ក
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ .......... ៦១៨
បទភាជនីយ .......... ៦១៦
វារៈដែលមិនត្រូវអាបត្តិ .......... ៦១៩

## សិក្ខាបទទី ៤ ៦១៩

និទានវត្ថុភិក្ខុ និងសេចក្តីបញ្ញត្តិ .......... ក
សិក្ខាបទវិភង្គ បទភាជនីយ .......... ៦១៩
វារៈដែលមិនត្រូវអាបត្តិ .......... ៦២០

## សិក្ខាបទទី ៥ ៦២១

និទានវត្ថុភិក្ខុ និងសេចក្តីបញ្ញត្តិ .......... ក
សិក្ខាបទវិភង្គ និងបទភាជនីយ .......... ៦២២
វារៈដែលមិនត្រូវអាបត្តិ .......... ៦២៣

## សិក្ខាបទទី ៦ ៦២៤

និទានកុដិការប្រ .......... ក
សេចក្តីបញ្ញត្តិជាដំបូង និងសេចក្តីបញ្ញត្តិជាបន្ទាប់ទី ១ .......... ៦២៤

លេខទំព័រ

សេចក្តីបញ្ញត្តិជាបន្ទាប់ទី ២ និងសិក្ខាបទវិភង្គ ............ ៦២៦
បទភាជនីយ និងអាការៈដែលមិនត្រូវអាបត្តិ ............ ៦២៧

សិក្ខាបទទី ៧ ៦២៨

និទានព្រះឧបនន្ទសក្យបុត្ត ............ ។
សេចក្តីបញ្ញត្តិជាដំបូង ............ ៦២៩
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ១ ............ ៦៣១
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ២ ............ ៦៣១
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ៣ ............ ៦៣២
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ៤ ............ ៦៣៣
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ៥ ............ ៦៣៥
សិក្ខាបទវិភង្គ ............ ៦៣៥
បទភាជនីយ និងអាការៈដែលមិនត្រូវអាបត្តិ ............ ៦៣៦

សិក្ខាបទទី ៨ ៦៣៧

និទានភិក្ខុច្រើនរូប ............ ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ............ ៦៣៨
បទភាជនីយ ............ ៦៣៩
អាការៈដែលមិនត្រូវអាបត្តិ ............ ៦៤០

សិក្ខាបទទី ៩ ៦៤០

និទានព្រះឧបនន្ទសក្យបុត្ត ............ ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ............ ៦៤២



លេខទំព័រ

បទភាជនីយ ............ ៦៤៣
អាការៈដែលមិនត្រូវអាបត្តិ ............ ៦៤៤

សិក្ខាបទទី ១០ ៦៤៥

និទានឧបនន្ទសក្យបុត្ត ............ ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ............ ៦៤៦
បទភាជនីយ ............ ៦៤៧
អាការៈដែលមិនត្រូវអាបត្តិ និងរឿងនៃសុបាយវត្ថុ ............ ៦៤៨

សន្ថតវគ្គ សិក្ខាបទទី ១ ៦៤៩

និទានអាឡវកភិក្ខុ ............ ។
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ............ ៦៥០
អាការៈដែលមិនត្រូវអាបត្តិ ............ ៦៥១

សិក្ខាបទទី ៦ ៦៥៦

និទានឆព្វគ្គិយភិក្ខុ និងសេចក្តីបញ្ញត្តិ ............ ។
សិក្ខាបទវិភង្គ បទភាជនីយ និងអាការៈដែលមិនត្រូវអាបត្តិ ............ ៦៥៣

សិក្ខាបទទី ៧ ៦៥៤

និទានឆព្វគ្គិយភិក្ខុ ............ ។
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងអធិករណៈ ៤ យ៉ាង ............ ៦៥៥
បទភាជនីយ និងអាការៈដែលមិនត្រូវអាបត្តិ ............ ៦៥៦

លេខទំព័រ

សិក្ខាបទទី ៤ ២៤៧

និទានព្រះឧបនន្ទសក្យបុត្រ.......... ។
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ.......... ២៤៨
ករណីដែលមិនត្រូវអាបត្តិ.......... ២៥០

សិក្ខាបទទី ៥ ២៥១

និទានឧបាសិកា.......... ។
សេចក្តីបញ្ញត្តិ.......... ២៥៤
សិក្ខាបទវិភង្គ និងបទភាជនីយ.......... ២៥៥
ករណីដែលមិនត្រូវអាបត្តិ.......... ២៥៧

សិក្ខាបទទី ៦ ២៥៩

និទានភិក្ខុ ១ រូប.......... ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......... ២៥៩
បទភាជនីយ.......... ២៦០
ករណីដែលមិនត្រូវអាបត្តិ.......... ២៦០

សិក្ខាបទទី ៧ ២៦៦

និទានភិក្ខុ ១ រូប.......... ។
សេចក្តីបញ្ញត្តិ.......... ២៦៧
សិក្ខាបទវិភង្គ និងបទភាជនីយ.......... ២៦៨
ករណីដែលមិនត្រូវអាបត្តិ.......... ២៦៨



លេខទំព័រ

សិក្ខាបទទី ៨ ២៧៦

និទានភិក្ខុឈ្មោះអរិដ្ឋ ជាអតីតព្រានត្មាត.......... ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......... ២៨២
ការសូត្រសមនុភាសនកម្ម.......... ២៨៤
បទភាជនីយ.......... ២៨៦
ករណីដែលមិនត្រូវអាបត្តិ.......... ២៨៧

សិក្ខាបទទី ៩ ២៨៨

និទានឆព្វគ្គិយភិក្ខុ.......... ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......... ២៨៩
ការបរិហារនាសនា មានពីរយ៉ាង.......... ២៩០
បទភាជនីយ.......... ២៩១
ករណីដែលមិនត្រូវអាបត្តិ.......... ២៩២

សិក្ខាបទទី ១០ ២៩៣

និទានសាមណេរឈ្មោះកណ្តក មានទិដ្ឋិអាក្រក់.......... ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......... ៣០១
បទភាជនីយ.......... ៣០២
ករណីដែលមិនត្រូវអាបត្តិ និងឧទ្ទានក្នុងសប្បាណកវគ្គ.......... ៣០៥

សហធម្មិកវគ្គ សិក្ខាបទទី ១ ៣០៦

និទានភិក្ខុឈ្មោះឆន្ន.......... ។
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ.......... ៣០៧

លេខទំព័រ

បទភាជនីយ ........................ ៣០៤
ភាពដែលមិនត្រូវអាបត្តិ ........................ ៣០៩

សិក្ខាបទទី ២ ........................ ៣១០

និទានព្រះដ៏មានព្រះភាគទ្រង់គង់អាស្រ័យសាវត្ថីយ និងនិទានឆព្វគ្គិយភិក្ខុ ........ ″
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........................ ៣១៣
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ ........................ ៣១៦

សិក្ខាបទទី ៣ ........................ ៣១៧

និទានឆព្វគ្គិយភិក្ខុ ........................ ″
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........................ ៣១៧
អន្តរាបត្តិ ........................ ៣១៨
បទភាជនីយ ........................ ៣១៩
ភាពដែលមិនត្រូវអាបត្តិ ........................ ៣២០

សិក្ខាបទទី ៤ ........................ ៣២១

និទានឆព្វគ្គិយភិក្ខុ ........................ ″
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........................ ៣២២
ភាពដែលមិនត្រូវអាបត្តិ ........................ ៣២៣

សិក្ខាបទទី ៥ ........................ ៣២៤

និទានឆព្វគ្គិយភិក្ខុ ........................ ″
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........................ ៣២៥
ភាពដែលមិនត្រូវអាបត្តិ ........................ ៣២៦



លេខទំព័រ

សិក្ខាបទទី ៦ ........................ ៣២៧

និទានឆព្វគ្គិយភិក្ខុ ........................ ″
សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........................ ៣២៨
ភាពដែលមិនត្រូវអាបត្តិ ........................ ៣២៩

សិក្ខាបទទី ៧ ........................ ៣៣០

និទានឆព្វគ្គិយភិក្ខុ ........................ ″
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........................ ៣៣១
បទភាជនីយ ........................ ៣៣២
ភាពដែលមិនត្រូវអាបត្តិ ........................ ៣៣៣

សិក្ខាបទទី ៨ ........................ ៣៣៤

និទានឆព្វគ្គិយភិក្ខុ ........................ ″
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........................ ៣៣៤
បទភាជនីយ ........................ ៣៣៥
ភាពដែលមិនត្រូវអាបត្តិ ........................ ៣៣៦

សិក្ខាបទទី ៩ ........................ ៣៣៧

និទានឆព្វគ្គិយភិក្ខុ ........................ ″
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........................ ៣៣៨
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ ........................ ៣៤០

សិក្ខាបទទី ១០ ........................ ៣៤១

និទានឆព្វគ្គិយភិក្ខុ ........................ ″

លេខទំព័រ


សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៣៤២
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៣៤៣

សិក្ខាបទទី ១១ ៣៤៥

និទានទេវទត្តបក្ស . . . . . . . . . . ក
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៣៤៦
បទភាជនីយ . . . . . . . . . . ៣៤៧
ភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៣៤៨

សិក្ខាបទទី ១២ ៣៤៩

និទានឆព្វគ្គិយភិក្ខុ . . . . . . . . . . ក
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៣៥១
បទភាជនីយ . . . . . . . . . . ៣៥២
ភាពដែលមិនត្រូវអាបត្តិ និងឧទ្ទាននៃសង្ឃាទិសេស . . . . . . . . . . ៣៥៣

អនិយត សិក្ខាបទទី ១ ៣៥៤

និទានស្នេហព្រះឧទាយី និងសេចក្តីសោមនស្ស . . . . . . . . . . ក
និយាយពីកោសល្លដែលកើតពីមិត្រក្លួលមាន ១០ យ៉ាង . . . . . . . . . . ៣៥៩
សេចក្តីបញ្ញត្តិ . . . . . . . . . . ៣៦២
សិក្ខាបទវិភង្គ . . . . . . . . . . ៣៦៣
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៣៦៤

សិក្ខាបទទី ២ ៣៦៥

និទានភិក្ខុ ១ រូប . . . . . . . . . . ក
សេចក្តីបញ្ញត្តិជាដំបូង និងនិទាននាងវិសាខាមិគារមាតា . . . . . . . . . . ៣៦៦




លេខទំព័រ


សេចក្តីបញ្ញត្តិជាបន្ទាប់ទី ១ និងនិទានភិក្ខុនៅក្នុងត្រកូលពិសាខាសេដ្ឋី . . . . . . . . . . ៣៦៨
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ២ និងសិក្ខាបទវិភង្គ . . . . . . . . . . ៣៧០
បទភាជនីយ . . . . . . . . . . ៣៧១
ភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៣៧២

សិក្ខាបទទី ៣ ៣៧៣

និទានឆព្វគ្គិយភិក្ខុ និយាយពីផ្លាកពក . . . . . . . . . . ក
សេចក្តីបញ្ញត្តិជាដំបូង និទានភិក្ខុច្រើនរូប និងសេចក្តីបញ្ញត្តិជាបន្ទាប់ទី ១ . . . . . . . . . . ៣៧៦
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ២ . . . . . . . . . . ៣៧៧
សេចក្តីបញ្ញត្តិជាបន្ទាប់ទី ៣ និងសិក្ខាបទវិភង្គ . . . . . . . . . . ៣៧៨
បទភាជនីយ . . . . . . . . . . ៣៧៩
ភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៣៨០

សិក្ខាបទទី ៤ ៣៨១

និទានភិក្ខុច្រើនរូប . . . . . . . . . . ក
សេចក្តីបញ្ញត្តិ . . . . . . . . . . ៣៨២
សិក្ខាបទវិភង្គ និងបទភាជនីយ . . . . . . . . . . ៣៨៣
ភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៣៨៤

សិក្ខាបទទី ៥ ៣៨៥

និទានព្រះឧបនន្ទសក្យបុត្រ . . . . . . . . . . ក
សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ . . . . . . . . . . ៣៨៦
បទភាជនីយ និងភាពដែលមិនត្រូវអាបត្តិ . . . . . . . . . . ៣៨៧

លេខទំព័រ


សិក្ខាបទទី ៦ ........ ៣៨៨

និទានវត្ថុនិយកិច្ច ........ ៗ

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ៣៨៩

បទភាជនីយ ........ ៣៩០

ភារៈដែលមិនត្រូវអាបត្តិ ........ ៣៩១

សិក្ខាបទទី ៧ ........ ៣៩២

និទានវត្ថុនិយកិច្ច ........ ៗ

សេចក្តីបញ្ញត្តិជាដំបូង និងនិទានវត្ថុនិយកិច្ច ........ ៣៩៣

សេចក្តីបញ្ញត្តិជាបន្ទាប់ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៣៩៤

ភារៈដែលមិនត្រូវអាបត្តិ ........ ៣៩៥

សិក្ខាបទទី ៨ ........ ៣៩៦

និទានវត្ថុនិយកិច្ច ........ ៗ

សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៣៩៧

ភារៈដែលមិនត្រូវអាបត្តិ ........ ៣៩៨

សិក្ខាបទទី ៩ ........ ៣៩៩

និទានវត្ថុនិយកិច្ច ........ ៗ

សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៤០០

ភារៈដែលមិនត្រូវអាបត្តិ ........ ៤០១

សិក្ខាបទទី ១០ ........ ៤០២

និទានវត្ថុនិយកិច្ច ........ ៗ




លេខទំព័រ


សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៤០៣

ភារៈដែលមិនត្រូវអាបត្តិ ........ ៤០៤

ចង្កោមនៃឧទ្ទាន ........ ៤០៥

ទុតិយសមិយកណ្ឌ សិក្ខាបទទី ១ ........ ៤០៦

និទានកិច្ចទី ១ រឿងទៅបិណ្ឌបាត ........ ៗ

សេចក្តីបញ្ញត្តិ សិក្ខាបទវិភង្គ និងបទភាជនីយ ........ ៤០៧

ភារៈដែលមិនត្រូវអាបត្តិ ........ ៤០៨

សិក្ខាបទទី ២ ........ ៤០៩

និទានវត្ថុនិយកិច្ចទី ........ ៗ

សេចក្តីបញ្ញត្តិ និងសិក្ខាបទវិភង្គ ........ ៤១០

បទភាជនីយ ........ ៤១១

ភារៈដែលមិនត្រូវអាបត្តិ ........ ៤១២

សិក្ខាបទទី ៣ ........ ៤១៣

និទានវត្ថុ ១ មានសេចក្តីផ្ទុះផ្ទាំងកាត់ចោលគ្នីព្រែកទូ ........ ៗ

សេចក្តីសម្មតិ ........ ៤១៥

សេចក្តីបញ្ញត្តិជាដំបូង និងនិទានកិច្ចទីពីរ ........ ៤១៨

សេចក្តីបញ្ញត្តិជាបន្ទាប់ទី ១ ........ ៤១៩

និទានកិច្ច ១ រឿង ........ ៤២០

សេចក្តីបញ្ញត្តិជាបន្ទាប់ទី ២ និងសិក្ខាបទវិភង្គ ........ ៤២១

បទភាជនីយ ........ ៤២២

ភារៈដែលមិនត្រូវអាបត្តិ ........ ៤២៤

# សន្លឹកបន្ទុលប្រាប់មាតិកា


លេខទំព័រ

សិក្ខាបទទី ៤ ........ ៤២៥

និទានក្នុងកាលរបស់សាកិយវង្ស ........ ក
សេចក្តីបញ្ញត្តិជាដំបូង ........ ៤២៦
និទានភិក្ខុ ២ រូប និងសេចក្តីបញ្ញត្តិជាបន្ទាប់ ........ ៤២៧
សិក្ខាបទវិភង្គ ........ ៤២៨
បទភាជនីយ ........ ៤៣០
វារៈដែលមិនត្រូវអាបត្តិ ........ ៤៣២

សេក្ខិយកណ្ឌ ........ ៤៣៤

បរិមណ្ឌលវគ្គ ........ ក
សារុប្ប មាន ២៦ ........ ក
ឧជ្ជគ្ឃិកវគ្គ ........ ៤៤២
ខម្ភកតវគ្គ ........ ៤៤៨

ភោជនប្បដិសំយុត្ត ៣០ ........ ៤៥០

សក្កច្ចវគ្គ ........ ៤៥៥
កពឡវគ្គ ........ ៤៦២
សុរុសុរុវគ្គ ........ ៤៧០

ធម្មទេសនាបដិសំយុត្តមាន ១៦ សិក្ខាបទ ........ ៤៨៤

បាទុកាវគ្គ ........ ៤៨៦
បកិណ្ណក មាន ៣ សិក្ខាបទ ........ ៤៩៣
ពួកធម៌សម្រាប់រម្ងាប់នូវអធិករណៈ ........ ៥០១


---


សៀវភៅនេះ ត្រូវបានបោះពុម្ពឡើងវិញ ដោយប្រាក់អំណោយនៃ
អ្នកនាងនុយតាណាកា ៖

Printing costs were met through the gift of

Nui Tanaka
1197 Nagaoka, Santo-cho, Sakata-gun, Shiga Japan

この本は次の方によって復刻されました。

田中ぬい
〒521-02　滋賀県坂田郡山東町長岡1157
☎0749-55-0022
祈平和平等　兄 戦死 菩提の為に